

# អត្តសញ្ញាណស្របច្បាប់សម្រាប់ស្ត្រី និង កុមារក្នុងតំបន់អាស៊ាន

## ការសំយោគនៅក្នុងតំបន់

ក្រោមគម្រោងសហការរវាង គណៈកម្មាធិការអាស៊ានស្តីពីការលើកកម្ពស់ និងការពារសិទ្ធិស្ត្រី និងកុមារ (ACWC) និង ឧត្តមស្នងការសហប្រជាជាតិទទួលបន្ទុកកិច្ចការជនភៀសខ្លួន (UNHCR) ដើម្បីលើកកម្ពស់បរិយាប័ន្ន និងការអភិវឌ្ឍប្រកបដោយចីរភាពនៅក្នុងការស្ថាបនាសហគមន៍អាស៊ានតាមរយៈការធានាបាននូវការទទួលស្គាល់អត្តសញ្ញាណតាមផ្លូវច្បាប់របស់ស្ត្រី និងកុមារគ្រប់រូបនៅអាស៊ាន

**សំយោគដោយ Sriprapha Petcharamesree និង Bongkot Napaumporn**

# អត្តសញ្ញាណស្របច្បាប់សម្រាប់ស្ត្រី និង កុមារក្មួងតំបន់អាស៊ាន

## ការសំយោគនៅក្នុងតំបន់

សំយោគដោយ

**Sriprapha Petcharamesree**

និង

**Bongkot Napaumporn**

# មាតិកា


សូមថ្លែងអំណរគុណ.......................................................៦

**១. ទិដ្ឋភាពទូទៅអំពីគម្រោង ....................................... ៩**

១.១ ការលើកកម្ពស់បរិយាប័ន្ន និង ការអភិវឌ្ឍប្រកបដោយចីរភាពតាមរយៈការធានាបាននូវការទទួលស្គាល់អត្តសញ្ញាណតាមផ្លូវច្បាប់របស់ស្ត្រី និង កុមារគ្រប់រូបនៅអាស៊ាន.............១០

១.២ ការប្តេជ្ញាចិត្តរបស់អាស៊ានចំពោះសន្ធិសញ្ញាសិទ្ធិមនុស្សអន្តរជាតិ ..................១៦

**២. ការចុះបញ្ជីអត្រានុកូលដ្ឋាន និង ស្ថិតិអត្រានុកូលដ្ឋាន (CRVS) នៅអាស៊ាន ...... ២១**

២.១ សេចក្តីផ្តើម ..........................................................២២

២.២ ច្បាប់ និង គោលនយោបាយដែលទាក់ទងនឹងការចុះបញ្ជីអត្រានុកូលដ្ឋាន ការចុះបញ្ជីកំណើត និង ឯកសារអត្រានុកូលដ្ឋាននៅអាស៊ាន ...............................៣០

២.៣ ការអនុវត្តច្បាប់ និង គោលនយោបាយស្តីពីការចុះបញ្ជីកំណើត និងការចុះបញ្ជី ក្រុមពិបាកទំនាក់ទំនង........................................................៣៣

ក) ច្បាប់ និង នីតិវិធីចុះបញ្ជីកំណើត ...................................៣៣

ខ) កុមារបាត់ខ្លួន ...........................................................៣៥

គ) ជនដែលមិនមែនជាពលរដ្ឋ ...........................................៣៨

ឃ) ជនគ្មានសញ្ជាតិ.........................................................៣៩

២.៤ បញ្ហាប្រឈម និង ទម្លាប់អនុវត្តល្អៗ.........................................៤៣

ក) បញ្ហាប្រឈម ............................................................៤៣

ខ) ទម្លាប់អនុវត្តល្អៗ និង មេរៀនដែលបានរៀនសូត្រ..........................៤៧

**៣. សញ្ជាតិ និង ភាពជាពលរដ្ឋនៅអាស៊ាន.................................. ៥៨**

៣.១ សេចក្តីផ្តើម...........................................................៥៩

៣.២ ច្បាប់ និង គោលនយោបាយដែលទាក់ទងនឹងសញ្ជាតិ និងភាពជាពលរដ្ឋ នៅអាស៊ាន.... ៦២

៣.៣ ការអនុវត្តសញ្ជាតិ និង ភាពជាពលរដ្ឋនៅក្នុងរដ្ឋសមាជិកអាស៊ាន.................. ៦៥

ក) យេនឌ័រនៅក្នុងច្បាប់ជាតិ ................................................ ៦៥

ខ) កូនឥតខាន់ស្លា ...........................................................៦៧

គ) កុមារបាត់ខ្លួន ........................................................... ៦៨

ឃ) កុមារគ្មានសញ្ជាតិ និងកុមារដែលមិនអាចទទួលបានសញ្ជាតិផ្សេងទៀត ......... ៦៩

ង) សញ្ជាតូបនីយកម្ម ........................................................៧២

ច) ការបាត់បង់សញ្ជាតិ/ភាពជាពលរដ្ឋ . . . . . . . . . . . . . . . . . . . . . . . . . . . . . . . ៧៦

៣.៤ បញ្ហាប្រឈម និង ទម្លាប់អនុវត្តល្អៗ . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . ៧៨

ក) បញ្ហាប្រឈម . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . ៧៨

ខ) ទម្លាប់អនុវត្តល្អៗ និង មេរៀនដែលទទួលបាន . . . . . . . . . . . . . . . . . . . . . . . . . ៧៩

## ៤. ទម្លាប់អនុវត្តល្អៗ និង មេរៀនដែលទទួលបានពីតំបន់ដទៃទៀត . . . . . . . . . . . . . . . ៨៨

៤.១ អឺរ៉ុប . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . ៨៩

៤.២ អាហ្វ្រិក . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . ៩១

៤.៣ អាមេរិក . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . ៩២

៤.៤ មជ្ឈិមបូព៌ា និង អាហ្វ្រិកខាងជើង . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . ៩៤

## ៥. សេចក្តីសន្និដ្ឋាន និង អនុសាសន៍ . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . ៩៥

៥.១ ការចុះបញ្ជីកំណើត និង សញ្ជាតិ ជាវិធីកំណត់ព្រំដែនផ្នែកប្រជាសាស្រ្តរបស់រដ្ឋ . . . . . . . . . ៩៦

៥.២ អនុសាសន៍ . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . ១០០

## ៦. ឧបសម្ព័ន្ធ . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . ១០៣

ឧបសម្ព័ន្ធទី១៖ ក្របខណ្ឌច្បាប់ដែលពាក់ព័ន្ធ នៅក្នុងរដ្ឋសមាជិកអាស៊ាន . . . . . . . . . . . . . . . ១០៣

តារាងទី១៖ រដ្ឋសមាជិកអាស៊ាន និងការផ្តល់សច្ចាប័នរបស់ពួកគេលើសន្ធិសញ្ញាសិទ្ធិមនុស្ស (រួមបញ្ចូលទាំង អនុសញ្ញាស្តីពីជនភៀសខ្លួន និងភាពគ្មានសញ្ជាតិផងដែរ) . . . . . ១០៣

តារាងទី២៖ ក្របខណ្ឌច្បាប់នៃ CRVS នៅក្នុងរដ្ឋសមាជិកអាស៊ាន . . . . . . . . . . . . . . . ១០៧

តារាងទី៣៖ ក្រមខណ្ឌច្បាប់នៃសញ្ជាតិ និង ភាពជាពលរដ្ឋនៅក្នុងរដ្ឋសមាជិកអាស៊ាន . . ១១៤

តារាងទី៤៖ ក្របខណ្ឌច្បាប់នៅក្នុងរដ្ឋសមាជិកអាស៊ាន ដែលពាក់ព័ន្ធនឹងការទទួលបានសញ្ជាតិដោយកូនដែលកើតពីពលរដ្ឋ . . . . . . . . . . . . . . . . . . . . . . . . . . . . . ១១៨

តារាងទី៥៖ ក្របខណ្ឌច្បាប់នៅក្នុងរដ្ឋសមាជិកអាស៊ាន ពាក់ព័ន្ធនឹងការទទួលបានសញ្ជាតិរបស់កុមារបាត់ខ្លួន និង កូនសុំ . . . . . . . . . . . . . . . . . . . . . . . . . . . . . ១៣៤

តារាងទី៦៖ ក្របខណ្ឌច្បាប់នៅក្នុងរដ្ឋសមាជិកអាស៊ាន ពាក់ព័ន្ធនឹងការទទួលបានសញ្ជាតិដោយជនដែលមិនមែនជាពលរដ្ឋ (អាចរួមបញ្ចូលកុមារ/ជនគ្មានសញ្ជាតិ) . . . . . . ១៣៦

តារាងទី៧៖ ក្របខណ្ឌច្បាប់នៅក្នុងរដ្ឋសមាជិកអាស៊ាន ពាក់ព័ន្ធនឹងការទទួលបានសញ្ជាតិតាមរយៈសញ្ញាតូបនីយកម្ម និង អាពាហ៍ពិពាហ៍ . . . . . . . . . . . . . . . . . . . . . . ១៤៥

ឧបសម្ព័ន្ធទី២៖ សម្រង់អនុសាសន៍ស្តីពីការចុះបញ្ជីកំណើត និង សញ្ជាតិ ពីសេចក្តីសង្កេតសន្និដ្ឋាន ដែលត្រូវបានធ្វើឡើងដោយគណៈកម្មាធិការសិទ្ធិកុមារ និង គណៈ កម្មាធិការលុបបំបាត់ ការរើសអើងប្រឆាំងនឹងស្ត្រីភេទ សម្រាប់ប្រទេសសមាជិកអាស៊ាន . . . . . . . . . . . . . . . . ១៥៥

# សូមថ្លែងអំណរគុណ

ក្រុមការងារអន្តរក្រសួង ដើម្បីអនុវត្តគម្រោង ស្តីពីការផ្សព្វផ្សាយ និងពង្រឹងសមត្ថភាពមន្ត្រីអត្រានុកូល-ដ្ឋាន ក្នុងការ ចុះបញ្ជីកំណើត ការផ្លាស់ប្តូរបទពិសោធន៍ និងការផ្តល់សញ្ញាតិស្របច្បាប់ដល់ស្ត្រី និងកុមារ ក្នុងតំបន់អាស៊ាន ដែលមានសមាសភាដូចខាងក្រោម៖

## សមាសភាពពីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ចំនួន ០៤រូប

| | | |
|---|---|---|
| ១. ឯកឧត្តម ថេង ឆវិរិទ្ធ | តំណាងគណៈកម្មាធិការអាស៊ានស្តីពីការ លើកកម្ពស់ និង ការពារសិទ្ធិស្ត្រី និងកុមារ ផ្នែកសិទ្ធិកុមារ ជាអគ្គនាយករង នៃអគ្គនាយកដ្ឋានបច្ចេកទេស និងជាទីប្រឹក្សាក្រសួងស.អ.យ | ប្រធាន |
| ២. លោក អ៊ុម ប៊ុនឈឿន | ប្រធានការិយាល័យអាស៊ាន ជាមន្ត្រីបង្គោលការងារសង្គមកិច្ចអាស៊ាន និងជាជំនួយការគម្រោង | សមាជិក |
| ៣. លោក យ៉ា យូសុះ | ប្រធានលេខាធិការដ្ឋាន នៃអគ្គនាយកដ្ឋានបច្ចេកទេស | សមាជិក |
| ៤. លោក ស៊ីវ ស៊ីវ៉ាផេន | អនុប្រធានការិយាល័យគ្រប់គ្រងទិន្នន័យ នៃនាយកដ្ឋាន សហប្រតិបត្តិការអន្តរជាតិ | សមាជិក |

## សមាសភាពពីក្រសួងកិច្ចការនារី ចំនួន ០៥រូប

| | | |
|---|---|---|
| ១. លោកជំទាវ ហ៊ូ និរមិត្តា | តំណាងគណៈកម្មាធិការអាស៊ានស្តីពីការលើកកម្ពស់ និងការពារសិទ្ធិស្ត្រី និងកុមារ ផ្នែកសិទ្ធិស្ត្រី និងជាអនុរដ្ឋលេខាធិការ ក្រសួងកិច្ចការនារី | អនុប្រធាន |
| ២. លោកជំទាវ ប៊ុនឈិត វាសនា | អគ្គលេខាធិការក្រុមប្រឹក្សាជាតិកម្ពុជា ដើម្បីស្ត្រី | សមាជិក |
| ៣. លោកស្រី ឈី រដ្ឋា | ប្រធាននាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ | សមាជិក |
| ៤. លោកស្រី ជា ណាលីន | អនុប្រធាននាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ | សមាជិក |
| ៥. កញ្ញា សូផាន វល័ក្ខ | អនុប្រធានការិយាល័យកិច្ចការស្ត្រី និងអាស៊ាន | សមាជិក |

## សមាសភាពពីក្រសួងមហាផ្ទៃ ចំនួន ០៦រូប

| | | |
|---|---|---|
| ១. ឯកឧត្តម ផុន លីវិរៈ | អគ្គនាយករងនៃអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម | អនុប្រធាន |
| ២. លោក យឹម សំអុល | អនុប្រធាននាយកដ្ឋានអត្រានុកូលដ្ឋាន | សមាជិក |
| ៣. លោក ជា គឹមនេង | អនុប្រធាននាយកដ្ឋានអត្រានុកូលដ្ឋាន | សមាជិក |
| ៤. លោកស្រី លុយ ច័ន្ទម៉ាឡែន | អនុប្រធាននាយកដ្ឋានអត្រានុកូលដ្ឋាន | សមាជិក |
| ៥. លោក ឡាយ គឹមសាន | ប្រធានការិយាល័យ នៃនាយកដ្ឋានអត្រានុកូលដ្ឋាន | សមាជិក |
| ៦. លោក ជឹម ប៊ុណ្ណារដ្ឋ | អនុ.ការិយាល័យនៃនាយកដ្ឋានអត្រានុកូលដ្ឋាន | សមាជិក |

## សមាសភាព ឧត្តមស្នងការអង្គការសហប្រជាជាតិ ទទួលបន្ទុកកិច្ចការជនភៀសខ្លួន (UNHCR) ចំនួន០៤ រូប

| | | |
|---|---|---|
| **១. លោក** Peter Grady | មន្ត្រីជាន់ខ្ពស់ ផ្នែកកិច្ចការពារ នៃការិយាល័យពហុប្រទេស អង្គការ UNHCR ប្រទេសថៃ | សហប្រធាន |
| **២. លោក** Moses Kipronoh | មន្ត្រីជាន់ខ្ពស់ ផ្នែកកម្មវិធី នៃការិយាល័យពហុប្រទេសអង្គការ UNHCR ប្រទេសថៃ | សមាជិក |
| **៣. លោកស្រី** Nantanee Jedsadachaiyut | សហការី ផ្នែកកិច្ចការពារ នៃការិយាល័យពហុប្រទេសអង្គការ UNHCR ប្រទេសថៃ | សមាជិក |
| **៤. លោក ង៉ែត សត្យា** | មន្ត្រីជំនួយការ ផ្នែកកិច្ចការពារ ប្រទេសកម្ពុជា | សមាជិក |

សូមថ្លែងអំណរគុណ ដ៏ជ្រាលជ្រៅចំពោះ **ឯកឧត្តម វង សូត រដ្ឋមន្ត្រី ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា (ស.អ.យ) ឯកឧត្តម លោកជំទាវ លោក លោកស្រី តំណាងក្រសួងកិច្ចការនារី និងក្រសួងមហាផ្ទៃ** ដែលបានចូលរួមសហការការងារ ប្រកបដោយផ្លែផ្កា។ សូមថ្លែងអំណរគុណ ចំពោះ **ឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកកិច្ចការ ជនភៀសខ្លួន (UNHCR) ប្រចាំទីក្រុងបាងកក** ដែលបានផ្តល់ការគាំទ្រទាំងថវិកា និងបច្ចេកទេស ក្នុងការ បោះពុម្ពរបាយការណ៍នេះឡើង ។



# ១. ទិដ្ឋភាពទូទៅអំពីគម្រោង

## ១.១ ការលើកកម្ពស់បរិយាប័ន្ន និង ការអភិវឌ្ឍប្រកបដោយចីរភាពតាមរយៈការធានាបាននូវការទទួលស្គាល់អត្តសញ្ញាណតាមផ្លូវច្បាប់របស់ស្ត្រី និង កុមារគ្រប់រូបនៅអាស៊ាន

ជាញឹកញាប់ ស្ត្រីនិងកុមារដែលគ្មានឯកសារងាយរងគ្រោះដោយសារការមិនអើពើ។ រដ្ឋសមាជិកអាស៊ាន (AMS) កំពុងតែបង្កើតវឌ្ឍនភាពដ៏សំខាន់នៅក្នុង ការលើកកម្ពស់ ការធ្វើបរិយាប័ន្នក្រុមងាយរងគ្រោះ ដើម្បីសម្រេចបាន និង ថែរក្សាការអភិវឌ្ឍ




ប្រកបដោយចីរភាព។ វឌ្ឍនភាពនេះត្រូវបានអនុវត្តតាមរយៈនៅក្នុងចំណោមសកម្មភាពដទៃទៀត បង្កើនការទទួលស្គាល់អត្តសញ្ញាណ តាមផ្លូវច្បាប់ របស់ស្ត្រី និង កុមារ តាមរយៈការពង្រីកវិសាលភាពនៃការចុះបញ្ជីអត្រានុកូលដ្ឋាន និងការទទួលបានឯកសារអត្តសញ្ញាណជាចម្បង ព្រមទាំងទប់ស្កាត់ភាពគ្មានសញ្ជាតិ និង ការទទួលស្គាល់សិទ្ធិទទួលបានសញ្ជាតិតាមរយៈការអនុវត្តច្បាប់ជាតិផងដែរ។ ការអភិវឌ្ឍទាំងនេះរួមចំណែកដល់ការអនុវត្តបញ្ញត្តិដែលពាក់ព័ន្ធនៃអនុសញ្ញាស្តីពីការលុបបំបាត់រាល់ ទម្រង់នៃការរើសអើងប្រឆាំងនឹងស្ត្រីភេទ (CEDAW) អនុសញ្ញាស្តីពីសិទ្ធិកុមារ (CRC) និង អនុសញ្ញាស្តីពី សិទ្ធិជនពិការ (CRPD) ដែល ប្រទេសសមាជិក អាស៊ាន (AMS) ទាំងអស់បានផ្តល់សច្ចាប័ន។ ប៉ុន្តែនៅតែចាំបាច់ត្រូវមានវឌ្ឍនភាពបន្ថែមទៀតនៅក្នុងវិស័យទាំងនេះ ប្រសិនបើAMSនឹងរួមចំណែកទាំងស្រុងដល់ចក្ខុវិស័យរបស់សហគមន៍អាស៊ាន ឆ្នាំ២០២៥ និងផែនការលម្អិតរបស់សហគមន៍សង្គមវប្បធម៌អាស៊ាន (ASCC)[1] ព្រមទាំង ជួយសម្រួលដល់ការទទួលស្គាល់គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព(SDGs) ផង ដែរ។

**កិច្ចប្រជុំលើកទី១៣ របស់គណៈកម្មការអាស៊ានលើកទី១៣ ស្តីពីការលើកកម្ពស់និងការពារសិទ្ធិស្ត្រី និងកុមារ (ACWC) នៅ**ប្រទេសសិង្ហបុរី **កាលពីឆ្នាំ២០១៦** បានយល់ព្រមជាគោលការណ៍លើការរួមបញ្ចូល គម្រោងស្តីពីការលើកកម្ពស់បរិយា-ប័ន្ននិងការអភិវឌ្ឍន៍ប្រកបដោយចីរភាពនៅក្នុងការកសាងសហគមន៍អាស៊ាន តាមរយៈការធានាបាននូវការទទួលស្គាល់អត្តសញ្ញាណតាមផ្លូវច្បាប់របស់ស្ត្រីនិងកុមារគ្រប់រូបនៅអាស៊ាននៅក្នុងផែនការការងារ ACWC ឆ្នាំ២០១៦–២០២០។ គម្រោងនេះមានបំណងពង្រឹងសមត្ថភាពរបស់ ACWC នៅក្នុងការ

1 លេខាធិការដ្ឋានអាស៊ាន អាស៊ាន ឆ្នាំ២០២៥៖ ដំណើរឆ្ពោះទៅមុខទាំងអស់គ្នា ទីក្រុងចាកាតា អាចស្វែងរកបាននៅ៖ https://www.asean.org/storage/2015/12/ASEAN-2025-Forging-Ahead-Together-final.pdf




លើកកម្ពស់ការទទួលស្គាល់សិទ្ធិរបស់ស្ត្រីនិងកុមារនៅអាស៊ាន ចំពោះការចុះបញ្ជីកំណើត ការទទួលបានសំណុំឯកសារ បរិយាប័ន្ន អត្តសញ្ញាណនិងសញ្ជាតិតាមផ្លូវច្បាប់។ គម្រោងនេះក៏មានបំណងកសាងសមត្ថភាពរបស់ AMS នៅក្នុងការទទួលស្គាល់បន្ថែមទៀតលើសិទ្ធិទាំងនេះ ដែលមានចែងនៅក្នុង CEDAW, CRC និង CRPD។ ដើម្បីសម្រេចគោលបំណងទាំងនេះ គម្រោងនេះ នឹងព្យាយាមអនុវត្តអនុសាសន៍នានា ដែលត្រូវបានផ្តល់អាទិភាពនៅក្នុងសិក្ខាសាលាក្នុងតំបន់ចំនួនបី ដែលត្រូវបានរៀបចំឡើងស្តីពីបញ្ហាទាំងនេះ ដែលមានការសហការរៀបចំឡើងដោយតំណាងរបស់ប្រទេសវៀតណាមប្រចាំនៅ ACWC និង UNHCR និងពង្រឹងការអភិវឌ្ឍជាវិជ្ជមាន ដែល ត្រូវបានសម្គាល់ឃើញដោយ AMS នៅក្នុងសិក្ខាសាលាទាំងនោះ។[2] ACWC បានសម្គាល់ឃើញថា សកម្មភាពទាំងនេះគឺជាឧទាហរណ៍នៃទម្លាប់អនុវត្តល្អៗដែលជាផ្នែកមួយនៃយុទ្ធសាស្ត្រកម្មវិធីនៃការងាររបស់ខ្លួន។ គម្រោងនេះក៏នឹងរួមបញ្ចូលធាតុដែលពាក់ព័ន្ធនៃគម្រោង តាមប្រធានបទទាំង១២ របស់ ACWC នៅក្នុងផែនការការងារ ឆ្នាំ២០១២-២០១៦ របស់ខ្លួនផងដែរ ជាពិសេសការអនុវត្ត បញ្ហាទូទៅនៅក្នុងការបញ្ចប់ការសង្កេតនានា របស់ គណៈកម្មការ CRC, CEDAW និង CRPD នៅក្នុងផ្នែកនេះ។

2 “សិក្ខាសាលាថ្នាក់តំបន់ស្តីពីការលើកកម្ពស់សិទ្ធិទទួលបានសញ្ជាតិរបស់ស្ត្រី និង កុមារ នៅក្នុងការអនុវត្ត CEDAW និង CRC នៅអាស៊ាន” ថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៣, “សិក្ខាសាលា និង ការពិគ្រោះយោបល់ថ្នាក់តំបន់ ស្តីពីការលើកកម្ពស់សិទ្ធិទទួលបានសញ្ជាតិរបស់ស្ត្រី និង កុមារ នៅក្នុងរដ្ឋសមាជិកអាស៊ាន និង ដើម្បីការអភិវឌ្ឍសហគមន៍អាស៊ានបន្ថែមទៀត” ថ្ងៃទី១៤-១៥ ខែមករា ឆ្នាំ២០១៦ និង “សិក្ខាសាលាថ្នាក់តំបន់ដើម្បីវាយតម្លៃអំពីសកម្មភាពដែលដឹកនាំដោយ ACWC (វៀតណាម) ទាក់ទងនឹងសិទ្ធិទទួលបានសញ្ជាតិរបស់ស្ត្រី និង កុមារ នៅក្នុងសហគមន៍អាស៊ាន និងអភិវឌ្ឍការស្នើសុំកិច្ចសហការបន្ថែមលើផែនការការងារឆ្នាំ២០១៦-២០២០ របស់សហគមន៍អាស៊ាន ស្តីពីការលើកកម្ពស់ និង ការការពារសិទ្ធិស្ត្រី និង កុមារ” ថ្ងៃទី២១-២២ ខែកញ្ញា ឆ្នាំ២០១៦។

វាត្រូវបានគេទទួលស្គាល់ទូលំទូលាយ ថា អត្តសញ្ញាណតាមផ្លូវច្បាប់ រួមបញ្ចូលទាំង តាមរយៈ ការចុះបញ្ជីកំណើត ការចេញឯកសារ និង ការបង្កើតសញ្ជាតិផងដែរ មានសារសំខាន់នៅក្នុងការជួយសម្រួលដល់បរិយាប័ន្ន និង សុខមាលភាពរបស់ ស្ត្រី និង កុមារគ្រប់រូបនៅក្នុង AMS និងអាចរួមចំណែកដល់ការអភិវឌ្ឍប្រកបដោយចីរភាព ជាពិសេសសម្រាប់ក្រុមងាយរងគ្រោះ។ គេក៏បានកត់សម្គាល់ ផងដែរថា CRC[3] CEDAW[4] និង CRPD[5] មានបញ្ញត្តិបំពេញបន្ថែមសំខាន់ៗ នៅក្នុងផ្នែកនេះ។ សិទ្ធិទទួលបានសញ្ជាតិ ត្រូវបានគ្រប់គ្រងជាចាំបាច់ដោយនីតិបញ្ញត្តិថ្នាក់ជាតិ ប៉ុន្តែសមត្ថកិច្ចរបស់រដ្ឋនៅក្នុងវិស័យនេះ គួរតែត្រូវបានអនុវត្តនៅក្នុងដែនកំណត់ ដែលត្រូវបានកំណត់ដោយកាតព្វកិច្ចរបស់ពួកគេស្របតាមច្បាប់អន្តរជាតិ។ កាតព្វកិច្ចតាមសន្ធិសញ្ញានៅក្នុងផ្នែកនេះ នឹងត្រូវបានយល់ដឹងដោយយោងដល់ខរក្សាសិទ្ធិណាមួយដែលត្រូវបានចុះដោយរដ្ឋ ចំពោះ បញ្ញត្តិដែលពាក់ព័ន្ធ និង គោរពអធិបតេយ្យភាពរបស់ AMS នីមួយៗ។



គម្រោងនេះក៏នឹងកសាងសមត្ថភាព ដើម្បីជួយសម្រួល ដល់ការអនុវត្តផែនការសកម្មភាព ថ្នាក់តំបន់ស្តីពីការបញ្ចប់អំពើហិង្សា លើកុមារ (EVAC) និង ផែនការសកម្មភាពថ្នាក់តំបន់ស្តីពីការបញ្ចប់អំពើហិង្សាលើស្ត្រី (EVAW) ផងដែរ។ EVAC បញ្ជាក់យ៉ាងច្បាស់ថាទាំងកុមារដែលមិនបាន ចុះបញ្ជីកំណើត និងកុមារគ្មានសញ្ជាតិ ងាយរងគ្រោះដោយសារអំពើហិង្សាជាពិសេស។ វាសង្កត់ធ្ងន់ថា ការចុះបញ្ជីកំណើត និង ការតម្កល់ទុកឯកសារនៅថ្នាក់ជាតិដើម្បីជួយ បង្ការអំពើហិង្សាលើកុមារ និង ត្រួតពិនិត្យឡើងវិញ និង ពង្រឹងគោលការណ៍ស្តីពីការបង្ការសម្រាប់កុមារគ្មានសញ្ជាតិនៅថ្នាក់តំបន់ គឺជាវិធីសាស្ត្រសំខាន់ៗដែលត្រូវអនុវត្ត។[6] EVAW ចង្អុលបង្ហាញថា ស្ត្រីចំណាកស្រុក និងស្ត្រីគ្មានសញ្ជាតិទាំងមានឯកសារ និង គ្មានឯកសារ បានរងគ្រោះដោយសារពហុទម្រង់ និង ទម្រង់ដែលមានចំណុចប្រសព្វគ្នារវាងការរើសអើងនិងវិសមភាព ធ្វើឲ្យពួកគេងាយរងគ្រោះដោយសារអំពើហិង្សា ជាពិសេស។ គេក៏បានសង្កត់ធ្ងន់លើ សារសំខាន់នៃការលុបបំបាត់ឧបសគ្គរបស់ស្ត្រីនៅក្នុងការទទួលបាន យុត្តិធម៌ និង កាត់បន្ថយកត្តានានាដែលធ្វើឲ្យប្រជាជន ជាពិសេសស្ត្រី និង កុមារងាយរងគ្រោះដោយសារអំពើ ជួញដូរផងដែរ។[7]

គម្រោងនេះក៏នឹងគាំទ្រដល់ការអនុវត្តវិធីសាស្ត្រមួយចំនួនរបស់អាស៊ានដែលទាក់ទងនឹងការជួញដូរផងដែរ ។ ទំនាក់ទំនងរវាងការទប់ស្កាត់ការជួញដូរ និង ការចេញ លិខិតបញ្ជាក់អត្តសញ្ញាណ ដែលមានការធានាដែលជួយបញ្ជាក់អះអាង អំពីអត្តសញ្ញាណតាមផ្លូវច្បាប់របស់បុគ្គលម្នាក់ត្រូវបានទទួលស្គាល់ នៅក្នុងអនុសញ្ញាអាស៊ានស្តីពីការប្រឆាំងនឹងការជួញដូរមនុស្ស ជាពិសេស ស្ត្រី និង កុមារ[8] និង ផែនការសកម្មភាពអាស៊ានប្រឆាំងនឹងការជួញដូរមនុស្ស ជាពិសេសស្ត្រីនិងកុមារ។[9]

3 CRC មាត្រា ២ ៣ ៧ និង ៨។

4 CEDAW មាត្រា ៩។

5 CRPD មាត្រា ១៨។

6 EVAC ផ្នែក II កថាខណ្ឌ d (ii) និង (ix) និង សកម្មភាព ទី ១ (៧) និង (៨)។

7 EVAW ផ្នែក II (b) និង សកម្មភាពទី ៣ កថាខណ្ឌទី ៣០។

8 អនុសញ្ញាអាស៊ានស្តីពីការប្រឆាំងនឹងការជួញដូរមនុស្ស ជាពិសេស ស្ត្រី និង កុមារ មាត្រា ១១ និង ១៣។

9 ផែនការសកម្មភាពអាស៊ានប្រឆាំងនឹងការជួញដូរមនុស្ស ជាពិសេសស្ត្រី និង កុមារ ផ្នែក ក កថាខណ្ឌ ឆ។





ដូចគ្នានេះដែរ គម្រោងនេះអាចពិចារណា អំពីបញ្ហានានា ដែលទាក់ទងនឹងផែនការការងាររបស់អាស៊ាន ស្តីពីការអប់រំ ឆ្នាំ២០១៦-២០២០ ដែលរួមបញ្ចូល ទាំងអនុគោលដៅនៃ "ការពង្រឹងគុណភាពការទទួលបានការអប់រំសម្រាប់មនុស្សគ្រប់រូប រួមបញ្ចូលទាំងក្រុមជនពិការក្រុមដែលមិនសូវទទួលបានផលប្រយោជន៍ និងក្រុមដែលគេ មិនអើពើដទៃទៀតផងដែរ"។[10] គម្រោងនេះក៏អាចពិចារណាអំពីបញ្ហានានា ដែលទាក់ទងនឹង ការគ្របដណ្តប់លើផ្នែកសុខាភិបាលជាសកល និងសុខភាពរបស់ជនចំណាកស្រុកដែលពាក់ព័ន្ធ នឹងការទទួលស្គាល់របៀបវារៈស្តីពីការអភិវឌ្ឍផ្នែកសុខាភិបាល ក្រោយឆ្នាំ២០១៥ របស់ អាស៊ាន។[11]

**គម្រោងនេះ ក៏នឹងរួមចំណែកដល់ ការទទួលស្គាល់ចក្ខុវិស័យ សហគមន៍អាស៊ានឆ្នាំ២០២៥ ផងដែរ។** សេចក្តីប្រកាស និងផែនការលម្អិតដែលមាន នៅក្នុងចក្ខុវិស័យសហគមន៍អាស៊ានឆ្នាំ២០២៥៖ ដំណើរឆ្ពោះទៅមុខទាំងអស់គ្នា តំណាងឲ្យការប្តេជ្ញាចិត្តដ៏ខ្ពង់ខ្ពស់របស់ថ្នាក់ដឹកនាំនយោបាយនៅអាស៊ាន នៅក្នុងការកសាងសហគមន៍អាស៊ាន។ ពួកគេបានរៀបចំគន្លងសម្រាប់ការកសាងសហគមន៍អាស៊ាននៅក្នុងរយៈពេលដប់ឆ្នាំបន្ទាប់ទៀត ដែលរួមបញ្ចូលទាំងមាន៖ ការសង្កត់ធ្ងន់កាន់តែខ្លាំងលើប្រជាជាតិអាស៊ាន និង សុខមាលភាពរបស់ពួកគេ ការព្យាយាមរួមបញ្ចូលប្រជាជន គ្រប់រូបនៃ AMS តាមរយៈវេទិកាដែលមានប្រសិទ្ធភាព និង មាននវានុវត្តន៍ ដើម្បីលើកកម្ពស់ការប្តេជ្ញាចិត្ត និង ការកំណត់ផលប្រយោជន៍ផ្នែកនយោបាយ និង ផលប្រយោជន៍នៅក្នុងតំបន់របស់អាស៊ាន និង ការធានាចំពោះសេរីភាពកម្រិតមូលដ្ឋាន សិទ្ធិមនុស្ស និង ការរស់នៅដែលល្អប្រសើរឡើងជាងមុនសម្រាប់ប្រជាជនអាស៊ានគ្រប់រូប។[12] **ផែនការលម្អិតរបស់ ASCC ឆ្នាំ២០២៥ មានគោលបំណងយ៉ាងជាក់លាក់នៅក្នុងការធ្វើឲ្យ ASCC មានបរិយាប័ន្ន ចីរភាព ភាពធន់ ថាមវន្ត និង ភ្ជាប់ការផ្តល់អត្ថប្រយោជន៍ដល់ប្រជាជន។**[13]

គោលដៅរបស់ ASCC មួយចំនួន មានទំនាក់ទំនងយ៉ាងជាក់លាក់នឹងគម្រោងនេះ ដែលរួមបញ្ចូលទាំង ការលើកកម្ពស់លទ្ធភាពទទួលបាន និង ឱកាសស្មើៗគ្នាសម្រាប់ប្រជាជនគ្រប់រូប ការលើកកម្ពស់ និងកិច្ចការពារសិទ្ធិមនុស្ស និងការពង្រឹងសមត្ថភាពរបស់អាស៊ាននៅក្នុងការធ្វើនវានុវត្តន៍ និង ក្លាយជាសមាជិកសកម្ម របស់សហគមន៍សកលផងដែរ។ គោលបំណងសំខាន់ៗជាច្រើនរបស់ ASCC ដូចជា ការអនុវត្តសេចក្តីប្រកាស និង លិខិតូបករណ៍ដែលពាក់ព័ន្ធនឹងអាស៊ានទាក់ទងនឹងសិទ្ធិមនុស្សបានយ៉ាងមានប្រសិទ្ធភាព ក៏នឹងត្រូវ បានលើកឡើងបន្ថែមទៀតដោយគម្រោងនេះដែរ។ សេចក្តីប្រកាសសិទ្ធិមនុស្សអាស៊ាន (AHRD) ក៏ទទួលស្គាល់សិទ្ធិរបស់មនុស្សគ្រប់រូបនៅក្នុងការទទួលបានសិទ្ធិមនុស្ស ដែលរួមបញ្ចូលទាំងសិទ្ធិទទួលបានសញ្ជាតិ ស្របតាមច្បាប់ជាតិ និង សិទ្ធិទទួលបានការការពារប្រឆាំងនឹងការដកហូតសញ្ជាតិតាមទំនើងចិត្តផងដែរ។[14]

---

10 ផែនការការងាររបស់អាស៊ានស្តីពីការអប់រំ ឆ្នាំ២០១៦-២០២០ អនុគោលដៅទី២។

11 របៀបវារៈស្តីពីការអភិវឌ្ឍផ្នែកសុខាភិបាលក្រោយឆ្នាំ២០១៥ របស់អាស៊ាន កន្សោមទី៣។

12 ចក្ខុវិស័យសហគមន៍អាស៊ានឆ្នាំ២០២៥៖ ដំណើរឆ្ពោះទៅមុខទាំងអស់គ្នា ទំព័រទី ១០៨។

13 Ibid.

14 សេចក្តីប្រកាសសិទ្ធិមនុស្សអាស៊ាន ប្រការ ១៨។

នៅកម្រិតសកល គម្រោង ACWC រួមចំណែកដល់របៀបវារៈឆ្នាំ២០៣០ សម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាព ដែលត្រូវបានអនុម័តដោយមហាសន្និបាតអង្គការសហប្រជាជាតិ នៅថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០១៥។ គម្រោងនេះសន្យាផ្តល់អាទិភាពដល់ជនដែលគេមិនអើពើ និង ជនដែលងាយរងគ្រោះខ្លាំងបំផុត និងរួមបញ្ចូលគោលដៅសំខាន់ៗ ដែលទាក់ទងនឹងគម្រោងនេះ ដូចជា "អត្តសញ្ញាណតាមផ្លូវច្បាប់សម្រាប់មនុស្សគ្រប់រូប ត្រឹមឆ្នាំ២០៣០ ដែលរួមបញ្ចូលទាំងការចុះបញ្ជីកំណើតផងដែរ"[15] "ការបញ្ចប់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងស្ត្រី និង កុមារី នៅគ្រប់ទីកន្លែង"[16] និង "ធានាចំពោះឱកាសស្មើភាពគ្នា និង កាត់បន្ថយវិសមភាពនៃធាតុចេញ រួមបញ្ចូលមាន៖ ការលុបបំបាត់ច្បាប់ គោលនយោបាយ និង ទម្លាប់អនុវត្តដែលមានការរើសអើង និង លើកកម្ពស់ច្បាប់ គោលនយោបាយ និង ចំណាត់ការសមស្របនៅក្នុងករណីនេះ"។[17] ការទទួល ស្គាល់គោលដៅទាំងនេះមិនត្រឹមតែគាំទ្រដល់បេសកកម្មរបស់ ACWC តែប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងរួមចំណែក ដល់ការទទួលស្គាល់យុទ្ធនាការរបស់ UNHCR ដើម្បីបញ្ចប់ភាពគ្មានសញ្ជាតិ ត្រឹមឆ្នាំ២០២៤ ផងដែរ។[18]

ដូចបានលើកឡើងនៅខាងលើ វត្ថុបំណងរួមរបស់គម្រោងនេះ គឺដើម្បីពង្រឹងសមត្ថភាពរបស់ ACWC នៅក្នុងការលើកកម្ពស់ការអនុវត្តបញ្ញត្តិដែលពាក់ព័ន្ធ នៅក្នុងសន្ធិសញ្ញាសិទ្ធិមនុស្សអន្តរជាតិ ជាពិសេស CEDAW និង CRC និង កសាងសមត្ថភាពរបស់ AMS នៅក្នុងវិស័យនេះ ស្របតាមអាណត្តិរបស់ ACWC។[19] គម្រោងនេះមានបំណងទទួលស្គាល់វត្ថុបំណងទាំងនេះ តាមរយៈការអនុវត្តសកម្មភាពជាច្រើន ដែលរួមបញ្ចូលទាំង

" ការសិក្សាស្តីពីបរិយាប័ន្ន និង ការអភិវឌ្ឍប្រកបដោយចីរភាព និង ការកសាងសហគមន៍អាស៊ាន តាមរយៈការបង្កើន ការគ្របដណ្តប់លើការចុះបញ្ជីអត្រានុកូលដ្ឋាន និង លទ្ធភាពទទួលបានឯកសារអត្តសញ្ញាណ ការទប់ស្កាត់ភាពគ្មានសញ្ជាតិ និង ការទទួលស្គាល់សិទ្ធិទទួលបានសញ្ជាតិ សម្រាប់ស្ត្រី និង កុមារនៅអាស៊ាន តាមរយៈការអនុវត្តច្បាប់ជាតិ។[20] "

### ការសិក្សាដែលបានលើកឡើងខាងលើ មានបំណង៖

- កំណត់មាតិកានៃក្របខណ្ឌ និង ទ្រឹស្តីនៃច្បាប់ជាតិដែលពាក់ព័ន្ធ និង ចំណាត់ការជាសក្តានុពលដែលអាចអនុវត្តបាន ដើម្បីធ្វើឲ្យក្របខណ្ឌ និង ទ្រឹស្តីទាំងនោះស្របតាមបញ្ញត្តិដែលពាក់ព័ន្ធនៃ CRC និង CEDAW ដោយពិចារណាអំពីការរក្សាសិទ្ធិដែលពាក់ព័ន្ធណាមួយរបស់ AMS។
- សម្គាល់ឃើញ និង ចែករំលែកទម្លាប់អនុវត្តល្អៗ និង មេរៀនដែលបានរៀនសូត្រ រួមបញ្ចូលទាំងកិច្ចសហប្រតិបត្តិការទ្វេភាគីរវាង AMS ការអភិវឌ្ឍគោលនយោបាយ និង យុទ្ធសាស្ត្រថ្នាក់ជាតិដែល ពាក់ព័ន្ធ និងវិធីសាស្ត្រនានា ដើម្បីទទួលស្គាល់វត្ថុបំណងទាំងនេះបន្ថែមទៀត ដើម្បីស្ត្រី និង កុមារ ឬ ដោះស្រាយស្ថានភាពរបស់ស្ត្រី និង កុមារដែលងាយរងគ្រោះ ដែលគ្មានឯកសារ ឬ មិនទាន់ទទួលបានអត្តសញ្ញាណតាមផ្លូវច្បាប់។
- សម្គាល់ឃើញទម្លាប់អនុវត្តល្អៗ និង មេរៀនដែលបានរៀនសូត្រ នៅក្នុងវិស័យទាំងនេះ ពីតំបន់ដទៃទៀត ដើម្បីធ្វើការពិចារណាបន្ថែមទៀត។
- សម្គាល់ឃើញចំណុចដែលត្រូវកសាងសមត្ថភាពបន្ថែមទៀត នៅថ្នាក់តំបន់ និង ថ្នាក់ជាតិ។

15 SDG គោលដៅ ១៦.៩។

16 SDG គោលដៅ ៥.១។

17 SDG គោលដៅ ១០.៣។

18 ឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកជនភៀសខ្លួន (UNHCR) ផែនការសកម្មភាពជាសកលដើម្បីបញ្ចប់ភាពគ្មាន សញ្ជាតិ ថ្ងៃទី០៤ ខែវិច្ឆិកា ឆ្នាំ២០១៤ អាចស្វែងរកបាននៅ៖ https://www.refworld.org/docid/545b47d64.html

19 លក្ខខណ្ឌយោងរបស់ ACWC កថាខណ្ឌ ៥.១ ៥.៥ និង ៥.៩។

20 គម្រោងដែលសហការគ្នារវាង ACWC-UNHCR ស្តីពី "ការលើកកម្ពស់បរិយាប័ន្ន និង ការអភិវឌ្ឍប្រកបដោយចីរភាពនៅក្នុងការកសាងសហគមន៍អាស៊ាន តាមរយៈការធានាចំពោះការទទួលស្គាល់អត្តសញ្ញាណតាមផ្លូវច្បាប់របស់ស្ត្រី និង កុមារគ្រប់រូប នៅអាស៊ាន" វត្ថុបំណង ៦.១។

ដោយពិចារណាអំពីបរិបទនិងសាវតាជាក់លាក់របស់ ប្រទេសសមាជិកអាស៊ាន (AMS) នីមួយៗ ការសិក្សានេះ ផ្តោតលើការត្រួតពិនិត្យបញ្ហានានាដែលទាក់ទងនឹងអត្តសញ្ញាណតាមផ្លូវច្បាប់ ជាពិសេសការចុះបញ្ជីអត្រានុកូលដ្ឋាន និងការផ្តល់ឯកសារអត្រានុកូលដ្ឋាន សញ្ជាតិ និង ភាពជាពលរដ្ឋ (រួមបញ្ចូលទាំងការការពារប្រឆាំងនឹងភាពគ្មានសញ្ជាតិ) ដូចបានអនុវត្តនៅថ្នាក់នៅជាតិ។ ការចូលរួមរបស់ AMS និង ភាពជាម្ចាស់ ACWC នៅថ្នាក់តំបន់ និង ថ្នាក់ជាតិ ត្រូវបានផ្តល់អាទិភាពជូនក្នុងអំឡុងពេលរៀបចំ និងអនុវត្តគម្រោង។ តាមរយៈកម្រងសំណួរមួយ AMS ត្រូវបានអញ្ជើញឲ្យចូលរួមឆ្លើយតបនឹងសំណួរនានាដែលទាក់ទងនឹង៖





i. សន្ធិសញ្ញា ដែលប្រទេសនោះបានយល់ព្រមអនុវត្តតាម (រួមបញ្ចូលទាំង សេចក្តីប្រកាស និង ការរក្សាសិទ្ធិណាមួយផងដែរ)
ii. ច្បាប់ និង នីតិវិធីដែលពាក់ព័ន្ធ នៅថ្នាក់ជាតិ
iii. ភាពអាចស្វែងរកបាននៃស្ថិតិ និងស្ថានភាពបច្ចុប្បន្ន និង
iv. ទម្លាប់អនុវត្តល្អៗ មេរៀនដែលបានរៀនសូត្រ និង ផែនការដើម្បីធ្វើឲ្យគម្លាតដែលត្រូវបានសម្គាល់ឃើញមាន ភាពល្អប្រសើរឡើង។

ជាលទ្ធផល ប្រទេសសមាជិកអាស៊ាន (AMS) នីមួយៗ បានតែងតាំងជនបង្គោលម្នាក់ឲ្យធ្វើការសម្របសម្រួលការពិគ្រោះយោបល់ថ្នាក់ជាតិ និង បានផ្តល់មតិលើកម្រងសំណួរនៃការស្រាវជ្រាវនោះ។ ជាផ្នែកមួយនៃការអនុវត្ត AMS នីមួយៗ បានធ្វើការស្រាវជ្រាវលើឯកសារដែលមានស្រាប់នៃច្បាប់ និង គោលនយោបាយជាតិ ដែលរួមបញ្ចូលទាំង នីតិវិធីដែលពាក់ព័ន្ធ និង ទម្លាប់អនុវត្តល្អៗ បញ្ហាប្រឈម និង ផែនការមួយចំនួន (ប្រសិនបើមាន) ដែលត្រូវបានសម្គាល់ឃើញផងដែរ ដើម្បីពង្រឹងប្រព័ន្ធ CRVS របស់ពួកគេ។ AMS មួយចំនួនបានរៀបចំការពិគ្រោះយោបល់ថ្នាក់ជាតិ ដែលទីភ្នាក់ងាររដ្ឋាភិបាលខុសៗគ្នាបានចូលរួម និង បានចែករំលែកបទពិសោធន៍របស់ពួកគេនៅក្នុងការអនុវត្តការចុះបញ្ជីអត្រានុកូលដ្ឋាន និង ការកំណត់សញ្ជាតិ។ AMS មួយ គឺប្រទេសហ្វីលីពីន បានឈានដល់ការអនុវត្តការស្រាវជ្រាវកម្រិតប្រទេសដែលមានលក្ខណៈពេញលេញ ដោយប្រើប្រាស់វិធីសាស្ត្រក្នុងការស្រាវជ្រាវដែលមានភាពជឿនលឿន ដូចជាការសម្ភាសយ៉ាងស៊ីជម្រៅជាមួយអ្នកពាក់ព័ន្ធសំខាន់ៗ ការសិក្សាអំពីករណីជាច្រើន និង ការពិភាក្សាក្រុមគោលដៅ។ របាយការណ៍របស់ប្រទេសចំនួនដប់ត្រូវបានដាក់ជូន UNHCR សម្រាប់ការសំយោគដោយក្រុមការងារថ្នាក់តំបន់។



## ១.២ ការប្តេជ្ញាចិត្តរបស់អាស៊ានចំពោះសន្ធិសញ្ញាសិទ្ធិមនុស្សអន្តរជាតិ

ផ្នែកដ៏សំខាន់នៃគម្រោងគឺ ការកំណត់មាតិកានៃក្របខណ្ឌ និង ទ្រឹស្តីនៃច្បាប់ជាតិដែលពាក់ព័ន្ធ និងចំណាត់ការជាសក្តានុពលដែលអាចអនុវត្តបាន ដើម្បីអនុវត្តបញ្ញត្តិ ដែលពាក់ព័ន្ធនៃសន្ធិសញ្ញាសិទ្ធិមនុស្សបន្ថែមទៀត។ អ្នកស្រាវជ្រាវថ្នាក់ជាតិ និង ថ្នាក់តំបន់បានត្រួតពិនិត្យការផ្តល់សច្ចាប័ន/ការទទួលយកសន្ធិសញ្ញាសិទ្ធិមនុស្សដោយ AMS ដោយពិចារណាអំពីការរក្សាសិទ្ធិដែលពាក់ព័ន្ធ។ ខរក្សាសិទ្ធិគឺអាស្រ័យលើការបកស្រាយពាក់ព័ន្ធនឹងសិទ្ធិនានា ដែលស្ថិតក្រោមការសិក្សានោះ។ **តារាងទី១** នៅក្នុងឧបសម្ព័ន្ធ (ចូរមើលទំព័រទី១០៣) បង្ហាញអំពីឋានៈនៃការផ្តល់សច្ចាប័នលើសិទ្ធិសញ្ញាសិទ្ធិមនុស្សអន្តរ-ជាតិដោយ AMS។

របាយការណ៍ប្រចាំប្រទេស (ដែលត្រូវបានដាក់ជូនដោយ AMS ទាំងអស់) និង ការស្រាវជ្រាវបន្ថែមទៀត បានចង្អុលបង្ហាញថា ក្នុងចំណោមសន្ធិសញ្ញាសិទ្ធិមនុស្សអន្តរជាតិសំខាន់ៗទាំង៩ AMS ទាំងអស់ បានផ្តល់សច្ចាប័នលើ CRC, CEDAW និង CRPD។ **ប្រទេសកម្ពុជា** **ឡាវ** **និង** **ហ្វីលីពីន** មិនបានបង្កើត ខរក្សាសិទ្ធិ ឬ សេចក្តីប្រកាសអំពីការបកស្រាយណាមួយចំពោះសន្ធិសញ្ញាសិទ្ធិមនុស្សអន្តរជាតិ ដែលប្រទេសទាំងនោះគឺជាភាគីនោទេ។ **ប្រទេសមីយ៉ាន់ម៉ា** មិនបានធ្វើសេចក្តីប្រកាស ឬ បង្កើតខរក្សាសិទ្ធិណាមួយចំពោះ CRC, CEDAW និង CRPD ពាក់ព័ន្ធនឹងការចុះបញ្ជីអត្រានុកូលដ្ឋាន ឬសញ្ជាតិនោះទេ។ ដូចគ្នាដែរ **ប្រទេសវៀតណាម** មិនបានធ្វើសេចក្តីប្រកាស ឬ បង្កើតខរក្សាសិទ្ធិណាមួយ ពាក់ព័ន្ធនឹងការចុះបញ្ជីអត្រានុកូលដ្ឋាន ឬ សញ្ជាតិនោះទេ ប៉ុន្តែប្រទេសវៀតណាមបានធ្វើសេចក្តីប្រកាសមួយ ចំពោះ CEDAW ថា “នៅក្នុងការអនុវត្តអនុសញ្ញានេះ សាធារណរដ្ឋសង្គមនិយមវៀតណាម នឹងមិនត្រូវបានកាតព្វកិច្ចដោយបញ្ញត្តិនានានៃកថាខណ្ឌទី ១ នៃមាត្រា ២៩ នោះទេ”។[21]

21 ទាក់ទងនឹងការដោះស្រាយវិវាទអន្តររដ្ឋ ដែលកើតចេញពីការបកស្រាយសន្ធិសញ្ញា។



**ប្រទេស ប្រ៊ុយណេ ដារូសាឡឹម** បានបង្កើត ខរក្សាសិទ្ធិ ចំពោះ CRC, CEDAW និង CRPD។ ប្រទេសប្រ៊ុយណេបានយល់ព្រមអនុវត្តតាម CRC នៅថ្ងៃទី២៧ ខែធ្នូ ឆ្នាំ១៩៩៥ ដោយមាន ខរក្សាសិទ្ធិចំពោះមាត្រា១៤ មាត្រា២០ និង មាត្រា២១ កថាខណ្ឌ ខ គ ឃ និង ង។ ប្រទេសនេះក៏បានបង្កើតខរក្សា សិទ្ធិចំពោះមាត្រា៩ កថាខណ្ឌទី២ និង មាត្រា២៩(១) នៃCEDAW ផងដែរ។[22] ប្រទេសនេះបានបង្កើត "ខរក្សាសិទ្ធិគ្រប់ជ្រុងជ្រោយ"បន្ថែមទៀតចំពោះអនុសញ្ញាទាំងបីពាក់ព័ន្ធនឹង "បញ្ញត្តិនានានៃអនុសញ្ញាដែលបានពោល ដែលអាចផ្ទុយនឹងរដ្ឋធម្មនុញ្ញរបស់ប្រទេសប្រ៊ុយណេដារូសាឡឹម និង ផ្ទុយនឹងជំនឿ និង គោលការណ៍នានានៃសាសនាអ៊ីស្លាម ដែលជាសាសនាផ្លូវការរបស់ ប្រទេសប្រ៊ុយណេដារូសាឡឹម ផងដែរ"។

**ប្រទេសឥណ្ឌូនេស៊ី** តាមរយៈក្រឹត្យរបស់ប្រធានាធិបតីបានប្រកាសថា បញ្ញត្តិនៃ មាត្រា១ មាត្រា១៤ មាត្រា១៦ មាត្រា១៧ មាត្រា២១ មាត្រា២២ និង មាត្រា២៩ នៃ CRC នឹងត្រូវបានអនុវត្តដោយអនុលោម តាមរដ្ឋធម្មនុញ្ញរបស់ខ្លួន។[23] ប្រទេសឥណ្ឌូនេស៊ីក៏បានបង្កើតខរក្សាសិទ្ធិចំពោះ មាត្រា២៩(១) នៃ CEDAW និង មាត្រា១ មាត្រា៦ (១ និង ២) មាត្រា៧ មាត្រា៩ មាត្រា១០ មាត្រា២៤ និង មាត្រា២៥ នៃ CRPD ផងដែរ។[24]

**ប្រទេសម៉ាឡេស៊ី** បន្តអនុវត្តខរក្សាសិទ្ធិចំពោះមាត្រា២ មាត្រា៧[25] មាត្រា១៤ មាត្រា២៨ (១ក) និង មាត្រា៣៧ នៃ CRC ដោយហេតុថា បញ្ញត្តិទាំងនោះគ្មាន សង្គតភាពនឹងបញ្ញត្តិនានានៃធម្មនុញ្ញរបស់សហព័ន្ធព្រមទាំងច្បាប់ និង គោលនយោបាយជាតិដទៃទៀត។ ពាក់ព័ន្ធនឹង CEDAW ប្រទេសម៉ាឡេស៊ីក៏បន្តអនុវត្ត ខរក្សាសិទ្ធិចំពោះមាត្រា ៩[26] និង មាត្រា ១៦ (១)(ក) មាត្រា ១៦ (១)(គ) មាត្រា ១៦ (១)(ច)[27] និង មាត្រា ១៦ (១)(ឆ) ផងដែរ ដោយហេតុថា បញ្ញត្តិទាំងនោះ គ្មានសង្គតភាពនឹងបញ្ញត្តិនានានៃធម្មនុញ្ញរបស់សហព័ន្ធ និង ច្បាប់ Shari'a នៃសាសនាអ៊ីស្លាម ដូចបានបង្កើតជាក្រមនៅគ្រប់រដ្ឋទាំងអស់នៃប្រទេសម៉ាឡេស៊ី។ លើសពីនេះទៀត ប្រទេសម៉ាឡេស៊ីបានបង្កើតខរក្សាសិទ្ធិ ចំពោះមាត្រា ១៥ និង មាត្រា ១៨[28] នៃ CRPD។[29]

---

22 របាយការណ៍ប្រចាំប្រទេសប្រ៊ុយណេដារូសាឡឹម។

23 របាយការណ៍ប្រចាំប្រទេសឥណ្ឌូនេស៊ី។

24 Ibid.

25 ពាក់ព័ន្ធនឹងសិទ្ធិចុះបញ្ជីកំណើត សិទ្ធិទទួលបានឈ្មោះ សិទ្ធិទទួលបានសញ្ជាតិ និង សិទ្ធិក្នុងការស្គាល់ និង ទទួលបានការថែទាំពីសំណាក់មាតាបិតារបស់ពួកគេ។

26 កថាខណ្ឌទី២ - សិទ្ធិស្មើភាពគ្នាក្នុងការផ្ទេរសញ្ជាតិរបស់ពួកគេទៅកាន់កូនៗរបស់ពួកគេ។

27 សិទ្ធិ និង ទំនួលខុសត្រូវស្មើៗគ្នា ពាក់ព័ន្ធនឹងអាណាព្យាបាលភាព សិទ្ធិចិញ្ចឹមកូន អាណត្តិព្យាបាលភាព និង សុំកូន។

28 ពាក់ព័ន្ធនឹងសិទ្ធិសេរីភាពក្នុងការធ្វើដំណើរ និង ទទួលបានសញ្ជាតិ។

29 ការកែសម្រួលដែលត្រូវបានស្នើសុំ ត្រូវបានធ្វើឡើងដោយប្រទេសម៉ាឡេស៊ី។ ជើងទំព័រត្រូវបានបន្ថែមដោយអ្នកនិពន្ធការសំយោគថ្នាក់តំបន់។




**ប្រទេសសិង្ហបុរី** បានបង្កើត ខរក្សាសិទ្ធិ/សេចក្តីប្រកាសចំពោះ ១៤ មាត្រា នៃ CRC។ សេចក្តីប្រកាសត្រូវបានធ្វើឡើងចំពោះមាត្រា ១២ រហូតដល់មាត្រា ១៧ មាត្រា ១៩ និង មាត្រា ៣៧ និង ខរក្សាសិទ្ធិចំពោះមាត្រា ៧ មាត្រា ៩ មាត្រា ១០ មាត្រា ២២ មាត្រា ២៨ និង មាត្រា ៣២។ ប្រទេសនេះបានធ្វើសេចក្តីថ្លែងការណ៍មួយ (យោងដល់ CRC) ថា "រដ្ឋធម្មនុញ្ញ និង ច្បាប់នានារបស់សាធារណរដ្ឋសិង្ហបុរីផ្តល់កិច្ចការពារយ៉ាងគ្រប់គ្រាន់ និង សិទ្ធិ និងសេរីភាពមូលដ្ឋាន ដើម្បីឧត្តមប្រយោជន៍របស់កុមារ។ ការទទួលយកអនុសញ្ញានេះ ដោយសាធារណរដ្ឋសិង្ហបុរី មិនបានបញ្ជាក់ដោយតុល្យភាពអំពីការទទួលយកកាតព្វកិច្ចនានា លើសពីដែនកំណត់ ដែលត្រូវបានបញ្ញត្តិដោយរដ្ឋធម្មនុញ្ញរបស់សាធារណរដ្ឋសិង្ហបុរីនោះទេ និងមិនទទួលយកកាតព្វកិច្ចណាមួយនៅក្នុងការណែនាំអំពីសិទ្ធិណាមួយដែលលើសពីសិទ្ធិដែលត្រូវបានបញ្ញត្តិនៅក្រោមរដ្ឋធម្មនុញ្ញនោះទេ"។[30] "ប្រទេសសិង្ហបុរីរក្សាសិទ្ធិក្នុងការអនុវត្តច្បាប់ និង លក្ខខណ្ឌដែលពាក់ព័ន្ធនឹងការចុះ ការបន្ថមាន និង ការទទួលបាន និងការមានកម្មសិទ្ធិលើភាពជាពលរដ្ឋរបស់ជនដែលគ្មាន ឬលែងមានសិទ្ធិស្របតាមច្បាប់របស់សាធា-រណរដ្ឋសិង្ហបុរី..."។[31]

> " សេចក្តីប្រកាស/ខរក្សាសិទ្ធិទាំងនេះ អាចមានផលជះចំពោះសិទ្ធិផ្តល់ឯកសារ និង សញ្ជាតិតាមផ្លូវច្បាប់របស់កុមារដែលគ្មានសញ្ជាតិ នៅក្នុងប្រទេសសិង្ហបុរី។

ចំពោះ CEDAW ប្រទេសសិង្ហបុរីបន្តអនុវត្ត ខរក្សាសិទ្ធិចំពោះកថាខណ្ឌមួយចំនួននៃមាត្រា ២ (ស្តីពីវិធីសាស្ត្រផ្នែកគោលនយោបាយ) និង មាត្រា ១៦ (ស្តីពីអាពាហ៍ពិពាហ៍ និង ជីវិតគ្រួសារ) មាត្រា ១១ (ស្តីពីការងារ) និង មាត្រា ២៩ (ស្តីពីការគ្រប់គ្រងអនុសញ្ញា)។ ប្រទេសសិង្ហបុរីបានដាក់ ខរក្សាសិទ្ធិលើមាត្រា ១២(៤) មាត្រា ២៥(ង) និង មាត្រា ២៩(ក)(iii) នៃ CRPD។

30 ICRC សន្ធិសញ្ញា ភាគីរដ្ឋ និង សេចក្តីអធិប្បាយ https://ihl-databases.icrc.org/applic/ihl/ihl.nsf/Notification.xsp?action=openDocument&documentId=528733252989BC3DC1256402003FD77F

31 Ibid.



ប្រទេសថៃ ដំបូងឡើយ បានបង្កើត ខរក្សាសិទ្ធិចំពោះមាត្រា ៧ នៃ CRC ប៉ុន្តែបានដកចេញវិញនៅឆ្នាំ២០១០។ ទោះបីជាយ៉ាងណាក៏ដោយ ប្រទេសនេះនៅតែបន្តដាក់ ខរក្សាសិទ្ធិចំពោះមាត្រា ២២ នៃ CRC ពាក់ព័ន្ធនឹងការការពារអ្នកស្វែងរកសិទ្ធិជ្រកកោន និង កុមារភៀសខ្លួន ជាពិសេសកុមារដែលគ្មានអ្នកអមដំណើរជាមួយ។

**តារាងទី១** ( ចូរមើលទំព័រទី ១០៣ ) បង្ហាញថា ប្រទេសកម្ពុជា **និង** ប្រទេសហ្វីលីពីនបានផ្តល់សច្ចាប័នលើអនុសញ្ញាឆ្នាំ១៩៥១ ទាក់ទងនឹងឋានៈជនភៀសខ្លួន និង ពិធីសារឆ្នាំ១៩៦៧ របស់អនុ-សញ្ញានេះ។ ចាប់តាំងពីឆ្នាំ២០១១ មកប្រទេសហ្វីលីពីនគឺជាភាគីនៃអនុសញ្ញាឆ្នាំ១៩៥៤ ទាក់ទងនឹងឋានៈរបស់ជនគ្មានសញ្ជាតិ ប៉ុន្តែមិនទាន់បានផ្តល់សច្ចាប័ន លើអនុសញ្ញាស្តីពីការកាត់បន្ថយភាព គ្មានសញ្ជាតិ ឆ្នាំ១៩៦១ នោះទេ។ ទោះបីជាយ៉ាងណាក៏ដោយ របាយការណ៍ប្រចាំប្រទេសហ្វីលីពីន បានបញ្ជាក់ថា “នៅខណៈពេលដែលហ្វីលីពីនមិនមែនជាភាគីនៃអនុសញ្ញាស្តីពីការកាត់បន្ថយ ភាពគ្មានសញ្ជាតិឆ្នាំ១៩៦១ទេនោះ តុលាការកំពូលបានចេញសេចក្តីសម្រេចលើសំណុំរឿង Poe-Llamanzares vs. COMELEC, G.R. លេខ ២២១៦៧៩៧ ២២៦៩៨-៧០០ (ថ្ងៃទី០៨ ខែមីនា ឆ្នាំ២០១៦) ថា មាត្រា ២ នៃអនុសញ្ញា ឆ្នាំ១៩៦១ គ្រាន់តែ “ផ្តល់ប្រសិទ្ធភាពអនុវត្ត” ដល់ មាត្រា ១៥( ១ ) នៃសេចក្តីប្រកាសជាសកល ស្តីពីសិទ្ធិមនុស្ស ដែលហ្វីលីពីគឺជារដ្ឋហត្ថលេខី តែ ប៉ុណ្ណោះ”។[32]

32 ធាតុចូលបន្ថែម ត្រូវបានផ្តល់ជូនដោយជនបង្គោលនៃប្រទេសហ្វីលីពីន។



> “
> នៅថ្នាក់តំបន់ AMS ទាំងអស់បាន អនុម័ត សេចក្តីប្រកាសសិទ្ធិមនុស្សអាស៊ាន (AHRD) ដែលមិនមែនជាឯកសារចង កាតព្វកិច្ចតាមផ្លូវច្បាប់នោះទេ។

ប្រការ ១៨ ទទួលស្គាល់ថា “មនុស្សគ្រប់រូបមានសិទ្ធិទទួលបានសញ្ជាតិ ដូចត្រូវបានបញ្ញត្តិដោយច្បាប់។ ពុំមានអ្នកណាម្នាក់ នឹងត្រូវបានដកហូតសញ្ជាតិតាមអំពើចិត្ត និង ត្រូវបានបដិសេធចំពោះការផ្លាស់ប្តូរសញ្ជាតិនោះទេ”។[33] សិទ្ធិនេះអាស្រ័យលើច្បាប់ក្នុងប្រទេសដែលមានស្រាប់។ ទោះបីជាយ៉ាងណាក៏ដោយ AHRD ចែងនៅក្នុងមាត្រា ៤០ ថា “ពុំមានចំណុចណាមួយនៅក្នុងសេចក្តីប្រកាសនេះ អាចត្រូវបានបកស្រាយជាការផ្តល់ជូនរដ្ឋ ក្រុម ឬ បុគ្គលណាម្នាក់ដោយតុណ្ហីភាព នូវសិទ្ធិធ្វើទង្វើណាមួយដែលមានបំណងធ្វើឲ្យគោលបំណង និង គោលការណ៍របស់អាស៊ានចុះខ្សោយ ឬបំផ្លាញសិទ្ធិ និង សេរីភាពមូលដ្ឋានណាមួយដូចមានចែង នៅក្នុងសេចក្តីប្រកាសនេះ និង លិខិតូបករណ៍សិទ្ធិមនុស្សអន្តរជាតិ ដែលរដ្ឋសមាជិកអាស៊ានជាភាគីនោះទេ”។ បញ្ញត្តិនេះ ផ្តល់ “ឱកាស” ឲ្យរដ្ឋផ្តល់ប្រសិទ្ធភាពអនុវត្តដល់សិទ្ធិរបស់ប្រជាជន ដូចមានចែងនៅក្នុងច្បាប់ជាតិ និង លិខិតូបករណ៍សិទ្ធិមនុស្សអន្តរជាតិ ដែលពួកគេគឺជាភាគី។ ជំពូកបន្តបន្ទាប់ទៀតនៃ របាយការណ៍នេះផ្តោតជាចម្បងលើរបាយការណ៍ ប្រចាំប្រទេសដែលត្រូវបានដាក់ជូន។ ជំពូក ២ និយាយអំពីការចុះបញ្ជីអត្រានុកូលដ្ឋាន និង ស្ថិតិអត្រានុកូលដ្ឋាននៅអាស៊ាន នៅខណៈពេលដែលជំពូក ៣ លើកឡើងអំពីបញ្ហានានា ដែលពាក់ព័ន្ធនឹងភាពជាពលរដ្ឋ និង សញ្ជាតិ។ ជំពូក ៤ ផ្តល់គំរូទម្លាប់អនុវត្តល្អៗ និង មេរៀនដែលបានរៀនសូត្រអំពីវិស័យទាំង នេះពីតំបន់ផ្សេងទៀត។ ជំពូក ៥ ផ្អែកតាមរបាយ-ការណ៍ប្រចាំប្រទេស និងការស្រាវជ្រាវឯកសារដែលមានស្រាប់បន្ថែមទៀត មានបំណងទាញសេចក្តីសន្និដ្ឋាន និង ផ្តល់អនុសាសន៍។ ផ្នែកចុងក្រោយរួមបញ្ចូល ឧបសម្ព័ន្ធ ដែលផ្តល់តារាងស្តីពីច្បាប់ និង គោល នយោបាយនានា ព្រមទាំងបញ្ញត្តិដែលពាក់ព័ន្ធ ស្តីពីការចុះបញ្ជីអត្រានុកូលដ្ឋាន ភាពជាពលរដ្ឋ និង សញ្ជាតិផងដែរ។

33 សេចក្តីប្រកាសសិទ្ធិមនុស្សអាស៊ាន អាចស្វែងរកបាននៅ៖ https://www.asean.org/storage/images/ASEAN_RTK_2014/6_AHRD_Booklet.pdf




# ២. ការចុះបញ្ជីអត្រានុកូលដ្ឋាន និង ស្ថិតិអត្រានុកូលដ្ឋាន (CRVS) នៅអាស៊ាន

## ២.១ សេចក្ដីផ្ដើម[34]

**ការចុះបញ្ជីអត្រានុកូលដ្ឋាន** ត្រូវបានកំណត់និយមន័យដោយអង្គការសហប្រជាជាតិថាជា

"...ការកត់ត្រាជាបន្តបន្ទាប់ អចិន្ត្រៃយ៍ ជាចាំបាច់ និង ជាសកល អំពីការកើតឡើង និង លក្ខណៈរបស់ព្រឹត្តិការណ៍អត្រានុកូលដ្ឋានទាក់ទងនឹងប្រជាជន ដូចបានផ្ដល់ជូនតាមរយៈក្រឹត្យ ឬ បទប្បញ្ញត្តិ ស្របតាមលក្ខខណ្ឌតម្រូវនៃច្បាប់នៅក្នុងប្រទេសនីមួយៗ។[35]"

**ព្រឹត្តិការណ៍អត្រានុកូលដ្ឋាន** គឺជាព្រឹត្តិការណ៍ដែលពាក់ព័ន្ធនឹងជីវិត និង ការស្លាប់របស់បុគ្គល ព្រមទាំងគ្រួសារ និង ស្ថានភាពអត្រានុកូលដ្ឋានរបស់ពួកគេផងដែរ។

**មានប្រភេទអត្រានុកូលដ្ឋាន យ៉ាងតិចដប់ប្រភេទ រួមមាន កំណើត មរណភាព ទារកស្លាប់កើត អាពាហ៍ពិពាហ៍ និង ទម្រង់ខុសៗគ្នាជាច្រើនទៀតនៃស្ម៊ុំកូន និង ការរំលាយអាពាហ៍ពិពាហ៍។** របាយការណ៍របស់ប្រទេសទាំងដប់ បានផ្ដោតលើ កំណើត មរណភាព និង អាពាហ៍ពិពាហ៍ ព្រមទាំងការទទួលបានសញ្ជាតិផងដែរ ពីព្រោះទាំងនេះគឺជាព្រឹត្តិការណ៍អត្រានុកូលដ្ឋានដែលការបញ្ជី (ឬកង្វះខាតការចុះបញ្ជី) ព្រឹត្តិការណ៍ទាំងនេះ គឺជាបច្ច័យដែលកើតឡើងច្រើនបំផុត ចំពោះប្រជាជនគ្រប់រូប រួមទាំងជនភៀសខ្លួន អ្នកស្វែងរកសិទ្ធិជ្រកកោន ជនគ្មានសញ្ជាតិ កុមារបាត់ខ្លួន និង ជនដែល មិនបានកំណត់សញ្ជាតិច្បាស់លាស់។

វត្ថុបំណងចម្បងនៃការចុះបញ្ជីអត្រានុកូលដ្ឋាន គឺដើម្បីកត់ត្រា និង តម្កល់ទុកកំណត់ត្រាផ្លូវការ និង អចិន្ត្រៃយ៍នៃព្រឹត្តិការណ៍អត្រានុកូលដ្ឋាន។ កំណត់ត្រាទាំងនេះ អាចធ្វើជាឯកសារតាមផ្លូវច្បាប់ សម្រាប់បុគ្គលទាំងឡាយ នៅក្នុងទម្រង់នៃកំណត់ត្រាដែលមានការបញ្ជាក់ និង ជាញឹកញាប់មានលក្ខណៈបំពេញ (ឧ. សំបុត្រកំណើត សំបុត្រមរណភាព និង សំបុត្រអាពាហ៍ពិពាហ៍)។ កំណត់ត្រា និង ឯកសារតាមផ្លូវច្បាប់ទាំងនេះ ត្រូវបានប្រើប្រាស់តាមផ្លូវច្បាប់នៅផ្នែករដ្ឋបាលផ្នែកស្ថិតិ និងការប្រើប្រាស់ជាច្រើនផ្សេងទៀតដូចជា ការបង្កើតបញ្ជីអត្រានុកូលដ្ឋានដែលដើរតួជាភ័ស្តុតាងសម្រាប់ បញ្ជាក់អះអាងថាព្រឹត្តិការណ៍អត្រានុកូលដ្ឋានមួយ បានកើតឡើង បញ្ជាក់អំពីព័ត៌មានលម្អិតនៃព្រឹត្តិការណ៍អត្រានុកូលដ្ឋាននោះ និង ការបំបែកកំណត់ត្រាទៅតាមអថេរផ្នែកប្រជាសាស្ត្រសំខាន់ៗ (ឧ. អាយុ ភេទ សញ្ជាតិ។ល។)។ ការចុះបញ្ជីនេះ អាចផ្ដល់ព័ត៌មានដែលមានតម្លៃពាក់ព័ន្ធនឹង សុខភាព និង សុខមាលភាពរបស់ប្រជាជនខុសៗគ្នាជាច្រើន។ ស្ថិតិអត្រានុកូលដ្ឋាន ដូចជាអត្រាសាយកូនសរុប អត្រាកំណើតរបស់មនុស្សវ័យជំទង់ អត្រាមរណភាពទារក។ល។ គឺជាសូចនាករនៃការអភិវឌ្ឍសំខាន់ៗ ដែលពឹងផ្អែកលើទិន្នន័យបញ្ជីអត្រានុកូលដ្ឋាន។ ស្ថិតិទាំងនេះត្រូវបានប្រើប្រាស់ដោយ អ្នកបង្កើតគោលនយោបាយ ដើម្បីពិនិត្យតាមដាន សុខភាព និង សុខមាលភាពរបស់ប្រជាជន និងនៅពេលបំបែកស្ថិតិអាចរៀបរាប់អំពីវិសមធម៌ផ្នែក សុខភាពនៅក្នុងចំណោមក្រុមប្រជាជនខុសៗគ្នា និងអាចផ្ដល់ព័ត៌មានអំពីការបែងចែកធនធាន។

34 កថាខណ្ឌមួយចំនួននៃផ្នែកនេះ ត្រូវបានយកចេញពី ឧបករណ៍ប៉ាន់ប្រមាណអំពីការចុះបញ្ជីអត្រានុកូលដ្ឋានក្រោមដំណើរការបាលី ដែលត្រូវបានរៀបចំដោយការិយាល័យគាំទ្រនៅក្នុងតំបន់សម្រាប់ដំណើរការបាលី (RSO) ដោយមានការកែសម្រួល និង ការបន្ថែមនានា។

35 UNSD ២០១៤ គោលការណ៍ និង អនុសាសន៍របស់អង្គការសហប្រជាជាតិ ចំពោះប្រព័ន្ធស្ថិតិអត្រានុកូលដ្ឋាន ការកែសម្រួលលើកទី ៣ ទំព័រ ៦៥ អាចស្វែងរកបាននៅ៖ http://unstats.un.org/unsd/demographic/standmeth/principles/M19Rev3en.pdf

36 គោលដៅ ១៦.៩ នៅក្រោមគោលដៅទី ១៦ នៃ SDG ស្ដីពីសង្គមដែលប្រកបដោយសន្តិភាព និង បរិយាប័ន្ន យុត្តិធម៌ សម្រាប់មនុស្សគ្រប់រូប និង ស្ថាប័នរឹងមាំ។ គោលដៅ ១៦.៩ នៃ SDG ស្ដីពីអត្តសញ្ញាណតាមផ្លូវច្បាប់ និងការចុះបញ្ជី កំណើតបានចង្អុលបង្ហាញថា "ត្រឹមឆ្នាំ២០៣០ ផ្ដល់

ចំពោះរដ្ឋនានា ការចុះបញ្ជីអត្រានុកូលដ្ឋានគឺជាការកត់ត្រាជាផ្លូវការដោយរដ្ឋ អំពីកំណើត មរណភាព អាពាហ៍ពិពាហ៍ និង ព្រឹត្តិការណ៍អត្រានុកូលដ្ឋានដទៃទៀត ដែលកើតឡើងនៅ ក្នុងចំណោមប្រជាជន ដែលស្ថិតនៅក្នុងទឹកដីរបស់ខ្លួន។ វាបណ្តាលឲ្យមានការបង្កើតកំណត់ត្រាអចិន្ត្រៃយ៍ និងការចេញឯកសារតាមផ្លូវច្បាប់ (ឧ. សំបុត្រកំណើត សំបុត្រមរណភាព និង សំបុត្រ អាពាហ៍ពិពាហ៍) ដែលដើរតួជាភ័ស្តុតាងផ្លូវការនៃហេតុការណ៍ និង លក្ខណៈរបស់ព្រឹត្តិការណ៍អត្រានុកូលដ្ឋានទាំងនោះ។ ស្របពេលជាមួយគ្នានេះ ទិន្នន័យប្រជាជនដែលត្រូវបានប្រមូលជាបន្តបន្ទាប់តាមរយៈការចុះបញ្ជីអត្រានុកូលដ្ឋាន ជួយដល់រដ្ឋនៅក្នុងការតាមដានប្រជាជន ដែលស្ថិតនៅក្នុងទឹកដីរបស់ខ្លួន និង ធ្វើផែនការការផ្តល់សេវានាពេលអនាគត និង តាមធម្មតាផ្តល់មូលដ្ឋានគ្រឹះសម្រាប់ប្រព័ន្ធគ្រប់គ្រងអត្តសញ្ញាណ និង មូលដ្ឋានទិន្នន័យនៃប្រជាជននៅក្នុងប្រទេស។ ចំពោះបុគ្គល ភ័ស្តុតាងកម្រិតមូលដ្ឋាននេះអាចចាំបាច់ចំពោះការបញ្ជាក់អះអាងអំពីអត្តសញ្ញាណតាមផ្លូវច្បាប់ និង ទំនាក់ទំនងគ្រួសាររបស់ពួកគេ ដែលមានទំនាក់ទំនងយ៉ាងខ្លាំងចំពោះការអនុវត្ត និងការការពារសិទ្ធិរបស់ពួកគេ ការទទួលបានសេវាសង្គម និង ការទទួលបានឯកសារអត្តសញ្ញាណផ្សេងៗទៀត ដូចជាការបញ្ជាក់អះអាងអំពីសញ្ជាតិ អត្តសញ្ញាណប័ណ្ណ និង លិខិតឆ្លងដែនជាដើម។

ការចុះបញ្ជីអត្រានុកូលដ្ឋាន គឺជាមុខងារមូលដ្ឋាននៃរដ្ឋបាលសាធារណៈ និង ជាចំណុចសំខាន់នៃការអភិវឌ្ឍប្រកបដោយបរិយាប័ន្ន។ នៅក្នុងចំណោមមូលហេតុផ្សេងទៀត គឺថា របៀបវារៈ SDG រួមបញ្ចូលគោលដៅ ១៦.៩[36] ត្រឹមឆ្នាំ២០៣០ ដើម្បីសម្រេចឲ្យបាននូវការផ្តល់អត្តសញ្ញាណតាមផ្លូវច្បាប់ដល់មនុស្សគ្រប់រូប រួមបញ្ចូលទាំងការចុះបញ្ជីកំណើតផងដែរ។ ជាក់ស្តែង រដ្ឋសន្យាថាពុំមានអ្នកណាម្នាក់នឹង "ត្រូវបានគេទុកចោល" នោះទេ ដោយកំណត់បទដ្ឋានមួយថាពុំមាន SDG ឬ គោលដៅណាមួយត្រូវបានចាត់ទុកថាបាន បំពេញតាមនោះទេ លើកលែងតែវាបានបំពេញតាម សម្រាប់ ប្រជាជនគ្រប់រូប/ក្រុមតូចៗ និងថា អ្នកដែល "ត្រូវបានគេទុកចោលខ្លាំងជាងគេបំផុត" គួរតែទទួលបានមុនគេបង្អស់។ ដូចគ្នាដែរ រដ្ឋសមាជិកនៃគណៈកម្មាធិការអង្គការសហប្រជា ជាតិផ្នែកសេដ្ឋកិច្ច និង សង្គម ប្រចាំតំបន់អាស៊ី និងប៉ាស៊ីហ្វិក (ESCAP) នៅចុងឆ្នាំ២០១៤ បានអនុម័តលើសេចក្តីប្រកាស របស់រដ្ឋមន្ត្រីដើម្បី "រួមបញ្ចូលអ្នករាល់គ្នានៅក្នុងរូបភាព" នៅ ក្នុងតំបន់អាស៊ី និង ប៉ាស៊ីហ្វិក[37] ដែលពួកគេបានកំណត់គោលដៅចំនួនបី៖

- ♣ គោលដៅទី១៖ ការចុះបញ្ជីកំណើត មរណភាព និង ព្រឹត្តិការណ៍អត្រានុកូលដ្ឋានដទៃទៀត ជាសកល
- ♣ គោលដៅទី២៖ បុគ្គលគ្រប់រូបត្រូវបានផ្តល់ជូន នូវឯកសារតាមផ្លូវច្បាប់នៃការចុះបញ្ជីកំណើត មរណភាព និង ព្រឹត្តិការណ៍អត្រានុកូលដ្ឋានដទៃទៀតតាមភាពចាំបាច់ ដើម្បីអះអាង អំពីអត្តសញ្ញាណ អត្រានុកូលដ្ឋាន និង ធានាចំពោះការទទួល បានសិទ្ធិនានា
- ♣ គោលដៅទី៣៖ ស្ថិតិអត្រានុកូលដ្ឋាន (រួមបញ្ចូលមូលហេតុនៃការស្លាប់ផងដែរ) ដែលត្រឹមត្រូវ ពេញលេញ និង ទាន់ពេលវេលា ត្រូវបានបង្កើតឡើង និង ចែកចាយ។

---

អត្ត សញ្ញាណ តាមផ្លូវច្បាប់ដល់មនុស្សគ្រប់រូប រួមបញ្ចូលទាំងការចុះបញ្ជីកំណើត ផងដែរ"។

សូចនាករដែលវាស់វែងអំពីការគ្របដណ្តប់លើចុះបញ្ជីអត្រានូកូលដ្ឋាន៖

- សូចនាករ ១៦.៩.១ សម្រាប់ SDG គោលដៅ១៦.៩ "សមាមាត្រនៃកុមារអាយុក្រោម ៥ឆ្នាំ ដែលបានចុះបញ្ជីកំណើតជាមួយអាជ្ញាធរស៊ីវិលណាម្នាក់ តាមអាយុ"
- សូចនាករ ១៧.១៩.២ វាស់ "សមាមាត្រានៃប្រទេសដែល... សម្រេចបានការចុះបញ្ជីកំណើត ១០០ ភាគរយ និង ការចុះបញ្ជីមរណភាព ៨០ ភាគរយ"។

37 UNESCAP សន្និបាតថ្នាក់រដ្ឋមន្ត្រី ស្តីពីការចុះបញ្ជីអត្រានុកូលដ្ឋាន និង ស្ថិតិអត្រានុកូលដ្ឋាននៅតំបន់អាស៊ី និង ប៉ាស៊ីហ្វិក (ថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០១៤) ឯកសាររបស់ UN E/ESCAP/MCCRVS/4 អាចស្វែងរកបាននៅ៖ http://undocs.org/en/E/ESCAP/MCCRVS/4

ដើម្បីគាំទ្រដល់វត្ថុបំណងទាំងនេះ រដ្ឋសមាជិក ESCAP បានប្រកាសអំពីទសវត្សរ៍នៃសកម្មភាព និង បានចារអនុម័តលើក្របខណ្ឌសកម្មភាពថ្នាក់តំបន់ ស្តីពីការចុះបញ្ជីអត្រានុកូលដ្ឋាន និង ស្ថិតិអត្រានុកូលនៅតំបន់អាស៊ី និងប៉ាស៊ីហ្វិក[38] ដែលផ្តល់មគ្គុទ្ទេសក៍ណែនាំ អំពីការអនុវត្តសេចក្តីប្រកាសរបស់រដ្ឋមន្ត្រី រួមបញ្ចូលទាំងការពិនិត្យតាមដានគោលដៅជាតិទាំង ១៥ ដែលរដ្ឋត្រូវពិនិត្យឡើងវិញ អំពីវឌ្ឍនភាពនៃគោលដៅទាំងនោះ នៅថ្នាក់តំបន់ នៅឆ្នាំ២០២១ និង ឆ្នាំ២០២៥។ AMS ទាំងអស់ ក៏បានអនុម័តលើ សេចក្តីថ្លែងការណ៍ទីក្រុងសេអ៊ូលនៅក្នុងសន្និបាត ស្តីពីការគ្រប់គ្រងអត្តសញ្ញាណអន្តរជាតិ នៅទីក្រុងសេអ៊ូលឆ្នាំ២០១៤ផងដែរ។[39] លើសពីនេះទៀត AMS ទាំងអស់គឺភាគីនៃ ESCAP និងបានប្តេជ្ញាចិត្តសម្រេចឲ្យបាននូវប្រព័ន្ធ CRVS ជាសកល និង មានការឆ្លើយតបត្រឹមឆ្នាំ២០២៤ ទោះបីជាអាស៊ានផ្ទាល់ មិនទាន់មានយុទ្ធសាស្ត្រ ឬ ផែនការការងារថ្នាក់តំបន់ ស្តីពី CRVS ក៏ដោយ។

ចក្ខុវិស័យសហគមន៍អាស៊ាន ឆ្នាំ២០២៥ ក្រោមសហគមន៍សង្គម-វប្បធម៌ បានសង្កត់ធ្ងន់លើបរិយាប័ន្ន និង រួមបញ្ចូល "ការទទួលបានប្រកបដោយសមធម៌សម្រាប់មនុស្សគ្រប់រូប" ជាវិស័យដ៏សំខាន់មួយ ដែលមានវិធីសាស្ត្រផ្នែកយុទ្ធសាស្ត្រមួយចំនួនដើម្បី **"គាំទ្រដល់គំនិតផ្តួចផ្តើមរបស់រដ្ឋសមាជិកអាស៊ាននៅក្នុង ការពង្រឹងមូលដ្ឋានទិន្នន័យ និង ការវិភាគអំពីយេនឌ័រ និង ការបែងចែកតាមអាយុ ដែលរួមបញ្ចូលទាំង មូលដ្ឋានទិន្នន័យ និង ការវិភាគអំពីភាពក្រីក្រ និង សមធម៌ផងដែរ និង បង្កើតមូលដ្ឋានទិន្នន័យថ្នាក់តំបន់ ដែលអាចទុកចិត្តបាន សម្រាប់វិស័យសំខាន់ៗ ដើម្បីគាំទ្រដល់គោលនយោបាយ និង កម្មវិធីរបស់អាស៊ាន"**។[40] បន្ថែមពីលើការងាររបស់ ACWC ទៀតនោះ គណៈកម្មការអន្តររដ្ឋាភិបាលអាស៊ាន ស្តីពីសិទ្ធិមនុស្ស



"

រដ្ឋសមាជិកអាស៊ាន (AMS) កំពុងតែបង្កើតវឌ្ឍនភាពសំខាន់។ នៅក្នុងការលើក កម្ពស់ការធ្វើបរិយាប័ន្ន ក្រុមដែលងាយរងគ្រោះ និង បង្កើនការអភិវឌ្ឍប្រកបដោយចីរភាព

(AICHR) ក៏បានពិចារណា អំពីបញ្ហានៃការចុះបញ្ជីកំណើតផងដែរ។ នៅឆ្នាំ២០១២ AICHR និង UNHCR បានសហការគ្នារៀបចំសិក្ខាសាលាថ្នាក់តំបន់ស្តីពីទម្លាប់អនុវត្តល្អៗនៃការចុះបញ្ជីកំណើត។ ចាប់តាំងពីមានសិក្ខាសាលានោះមក អ្នកតំណាងរបស់ AICHR បានរៀបចំកិច្ចប្រជុំជាច្រើនស្តីពីការចុះបញ្ជីកំណើត ដែលបានសិក្សាស្វែងយល់អំពីវិធីលើកកម្ពស់កិច្ចសហប្រតិបត្តិការ នៅក្នុងចំណោម AMS ដើម្បីបង្កើនកម្រិតនៃការគ្របដណ្តប់លើការចុះបញ្ជីកំណើតរៀងៗខ្លួនរបស់ពួកគេ។ របាយការណ៍

38 Ibid.

39 សន្និបាតស្តីពីការគ្រប់គ្រងអត្តសញ្ញាណអន្តរជាតិលើកទីមួយ សេចក្តីថ្លែងការណ៍ទីក្រុងសេអ៊ូល អាចស្វែងរកបាននៅ៖ https://unstats.un.org/unsd/demographic/crvs/Global_CRVS_Docs/news/Seoul_Statement_ENG.pdf

40 Ibid អាស៊ានឆ្នាំ២០២៥៖ ដំណើរឆ្ពោះទៅមុខទាំងអស់គ្នា។

របស់ប្រទេសហ្វីលីពីន បានសង្កត់ធ្ងន់លើការប្ដេជ្ញាចិត្តទាំងនោះ ដែលថា “**រដ្ឋសមាជិកអាស៊ាន (AMS) កំពុងតែបង្កើតវឌ្ឍនភាពសំខាន់ៗ នៅក្នុងការលើកកម្ពស់ការធ្វើបរិយាប័ន្នក្រុម ដែលងាយរងគ្រោះ និង បង្កើនការអភិវឌ្ឍប្រកបដោយចីរភាព តាមរយៈការបង្កើតការទទួលស្គាល់អត្តសញ្ញាណតាមផ្លូវច្បាប់របស់ស្ត្រី និង កុមារជាចម្បងតាមរយៈការបង្កើនការគ្របដណ្ដប់លើការចុះបញ្ជីអត្រានុកូលដ្ឋាន និងលទ្ធភាពក្នុងការទទួលបានឯកសារអត្តសញ្ញាណ ព្រមទាំងទប់ស្កាត់ភាពគ្មានសញ្ជាតិ និង ការទទួលស្គាល់សិទ្ធិទទួលបានសញ្ជាតិ តាមរយៈការអនុវត្តច្បាប់ជាតិផងដែរ**”។[41]

ទោះបីជាមានការប្ដេជ្ញាចិត្ត និង ជាទូទៅវឌ្ឍនភាពដ៏សំខាន់ ត្រូវបានទទួលស្គាល់នាពេលថ្មីៗនេះនៅក្នុងចំណោម AMS ក៏ដោយ ក៏ប្រទេសមួយចំនួន នៅក្នុងកម្រិតខុសៗគ្នា នៅតែខ្វះខាតដំណើរការប្រព័ន្ធចុះបញ្ជីអត្រានុកូលដ្ឋានយ៉ាងល្អដែល<u>កត់ត្រារាល់ព្រឹត្តិការណ៍អត្រានុកូលដ្ឋានទាំងអស់</u> ដែលកើតឡើង នៅក្នុងទឹកដីរបស់ពួកគេ ជាពិសេសប្រជាជនដែលពិបាកទំនាក់ទំនង ឬ ដែលគេមិនអើពើ។ និយមន័យនៃការចុះបញ្ជីអត្រានុកូលដ្ឋានដែលកំណត់ដោយអង្គការសហប្រជាជាតិរួមបញ្ចូលលក្ខណៈមួយចំនួនរួមមានការចុះបញ្ជីអត្រានុកូលដ្ឋានមានលក្ខណៈអចិន្ត្រៃយ៍[42] ចាំបាច់[43] ជាសកល[44] មានការរក្សាការសម្ងាត់[45] ទាន់ពេលវេលា[46] និង ត្រឹមត្រូវ[47]។ ភាពអាចទទួលបានសំបុត្រកំណើត សំបុត្រមរណភាព និង សំបុត្រអាពាហ៍ពិពាហ៍ដើម្បីបញ្ជាក់អះអាង អំពីអត្តសញ្ញាណតាមផ្លូវច្បាប់ និង ទំនាក់ទំនងគ្រួសារ មានភាពចាំបាច់ចំពោះកិច្ចការពារភ្លាមៗ និង សុខមាលភាពរបស់ប្រជាជនរួមបញ្ចូលទាំងជនភៀសខ្លួន អ្នកស្វែងរកសិទ្ធិជ្រកកោន ជនគ្មានសញ្ជាតិ និង ជនដែលគេមិនបានកំណត់សញ្ជាតិច្បាស់លាស់ផងដែរ។ នៅក្នុងករណីជាច្រើន ជាលទ្ធផលនៃការទុកឲ្យនៅក្រៅប្រព័ន្ធចុះបញ្ជីអត្រានុកូលដ្ឋានចម្បង ប្រជាជនទាំងនេះ



41 Ibid.

42 ការចុះបញ្ជីព្រឹត្តិការណ៍អត្រានុកូលដ្ឋានគួរតែត្រូវបានធ្វើឡើងនៅពេលដែលព្រឹត្តិការណ៍ទាំងនោះកើតឡើង និង ធ្វើឡើងជាបន្តបន្ទាប់ ហើយកំណត់ត្រាទាំងនោះគួរតែត្រូវបានរក្សាទុកជារៀងរហូត។

43 ការចុះបញ្ជីព្រឹត្តិការណ៍អត្រានុកូលដ្ឋានដែលកើតឡើងនៅក្នុងដែនដី និង យុត្តាធិការរបស់រដ្ឋមួយ តាមធម្មតា ត្រូវធ្វើឡើងជាចាំបាច់។

44 ការចុះបញ្ជីព្រឹត្តិការណ៍អត្រានុកូលដ្ឋានដែលកើតឡើងនៅក្នុងដែនដី និង យុត្តាធិការរបស់ពួកគេ គួរតែត្រូវបានធ្វើឡើងដោយមិនគិតអំពីបុគ្គលិកលក្ខណៈរបស់បុគ្គលដែលជាប់ពាក់ព័ន្ធនោះទេ ដូចជា ជាតិពន្ធ យេនឌ័រ សាសនា សញ្ជាតិ ឋានៈតាមផ្លូវច្បាប់ ឬ លក្ខណៈពិសេសណាមួយផ្សេងទៀត ជាដើម។

45 ការចុះបញ្ជីអត្រានុកូលដ្ឋានគួរតែគោរពឯកជនភាពរបស់បុគ្គលដែលពាក់ព័ន្ធនឹងព្រឹត្តិការណ៍អត្រានុកូលដ្ឋាន ដោយសារតែវាពាក់ព័ន្ធនឹងការប្រមូលទិន្នន័យផ្ទាល់ខ្លួន និង ទិន្នន័យដែលអាចមានភាពរសើប។

46 គួរតែមានរយៈពេលខ្លីបំផុតតាមដែលអាចធ្វើបាន នៅចន្លោះការកើតឡើងនៃព្រឹត្តិការណ៍អត្រានុកូលដ្ឋាន និង ការចុះបញ្ជីរបស់ខ្លួន ពីព្រោះនៅពេលដែលពេលវេលាកន្លងផុតទៅ មានការកើនឡើងនូវភាពទំនងនៃការរាយការណ៍អំពីព្រឹត្តិការណ៍អត្រានុកូលដ្ឋានដែលមិនត្រឹមត្រូវ ឬ ការខកខានមិនបានរាយការណ៍ទាំងអស់គ្នា។

47 ទិន្នន័យដែលប្រមូលបានតាមរយៈទង្វើនៃការចុះបញ្ជីអត្រានុកូលដ្ឋាន គួរតែត្រឹមត្រូវ ដោយសារតែព័ត៌មាននេះមានទំនាក់ទំនងដោយតុណ្ហិភាពនឹងសិទ្ធិរបស់បុគ្គល និង សុចរិតភាពនៃកំណត់ត្រា។

ជាពិសេសកុមារ មិនត្រូវបានយកចិត្តទុកដាក់ដោយច្បាប់នោះទេ និង អាចប្រឈមមុខនឹងហានិភ័យកាន់តែខ្លាំង នៃការផាត់ចេញពីសង្គម-សេដ្ឋកិច្ច ការជួញដូរ ទេសន្តរប្រវេសន៍ខុស ច្បាប់ និង ភាពគ្មានសញ្ជាតិ។ ការកត់ត្រាព្រឹត្តិការណ៍ អត្រានុកូលដ្ឋានរបស់ប្រជាជនទាំងនេះ នឹងពង្រឹងសមត្ថភាពរបស់រដ្ឋ នៅក្នុងការគ្រប់គ្រងប្រជាជនទាំងនេះ។ វាជួយដល់រដ្ឋនៅក្នុងការស្វែងយល់ អំពីប្រជាជនដែលស្ថិតនៅក្នុងដែនដីរបស់ពួកគេ (ឧ. តើពួកគេជាអ្នកណា និង តើពួកគេស្នាក់នៅកន្លែងណា) ជួយសម្រួលដល់ដំណោះស្រាយក្នុងរយៈពេលវែង (ឧ. ការធ្វើសមាហរណកម្ម ការវិលត្រឡប់ទៅវិញ និង មាតុភូមិនិវត្តន៍) និង កាត់បន្ថយ និង ទប់ស្កាត់ភាពគ្មានសញ្ជាតិ។ ដោយសារតែ កាលៈទេសៈរបស់ពួកគេ ជនភៀសខ្លួន អ្នកស្វែងរក សិទ្ធិជ្រកកោន ជនគ្មានសញ្ជាតិ និង ជនដែលមិនបានកំណត់សញ្ជាតិច្បាស់លាស់ ជាញឹកញាប់ ប្រឈមមុខនឹងឧបសគ្គសំខាន់ៗ និង ពិសេសៗ នៅក្នុងការចុះបញ្ជីព្រឹត្តិ-ការណ៍អត្រានុកូលដ្ឋានរបស់ពួកគេ នៅក្នុងប្រព័ន្ធចុះបញ្ជីអត្រានុកូលដ្ឋាន "ចម្បង" (ពោលគឺ ប្រព័ន្ធដូចគ្នានឹងប្រព័ន្ធ ដែលកត់ត្រាព្រឹត្តិការណ៍អត្រានុ-កូលដ្ឋានរបស់ពលរដ្ឋដែរ) នៃប្រទេសដែលព្រឹត្តិ-ការណ៍ទាំងនោះបានកើតឡើង ហើយរដ្ឋជាញឹកញាប់ប្រឈមមុខនឹងបញ្ហាប្រឈម នៅក្នុងទំនាក់ទំនងប្រជាជនទាំងនោះ ។ តាមពិត ប្រជាជនទាំងនេះនៅតែផ្តល់កំណើត រៀបអាពាហ៍ពិពាហ៍ ឬ ទទួលមរណភាព ដោយមិនគិតអំពីប្រទេសដែលពួកគេស្នាក់នៅ និង ឋានៈតាមផ្លូវច្បាប់របស់ពួកគេនោះទេ។ ការរួមបញ្ចូលពួកគេទៅក្នុងប្រព័ន្ធចុះបញ្ជីអត្រា-នុកូលដ្ឋានចម្បង ផ្តល់អត្ថប្រយោជន៍ទាំងចំពោះប្រជាជនដោយផ្ទាល់ និង ចំពោះរដ្ឋដែលពួកគេស្នាក់នៅ។

ដោយសារតែ វាមានសារសំខាន់យ៉ាងខ្លាំង ការចុះបញ្ជីអត្រានុកូលដ្ឋាន មិនត្រឹមតែត្រូវបានទទួលស្គាល់ថាជាសិទ្ធិមនុស្សមួយនោះទេ ប៉ុន្តែវាក៏ជួយសម្រាប់ដល់ការប្រកាន់ខ្ជាប់ នូវការប្តេជ្ញាចិត្តរបស់រដ្ឋចំពោះសិទ្ធិមនុស្សផងដែរ។ សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស (UDHR) ឆ្នាំ១៩៤៨ នៅក្នុង មាត្រា ៦ ចែងថា "មនុស្សគ្រប់រូបមានសិទ្ធិទទួលបានការទទួលស្គាល់នៅគ្រប់ទីកន្លែងទាំងអស់ថាជាមនុស្សម្នាក់នៅចំពោះមុខច្បាប់"។

UDHR នៅក្នុងមាត្រា ១៥ បញ្ជាក់បន្ថែមទៀតថា "១) មនុស្សគ្រប់រូបមានសិទ្ធិទទួលបានសញ្ជាតិ និង ២) ពុំមានអ្នកណាម្នាក់ត្រូវបានគេដកហូតសញ្ជាតិរបស់គាត់តាមអំពើចិត្ត និង ត្រូវបានបដិសេធចំពោះ ការផ្លាស់ប្តូរសញ្ជាតិរបស់គាត់នោះទេ"។ ដូចគ្នាដែរ កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និង សិទ្ធិនយោបាយ ឆ្នាំ១៩៦៦ (ICCPR) នៅក្រោមមាត្រា ២៤ ទទួលស្គាល់សិទ្ធិរបស់កុមារគ្រប់រូបនៅក្នុងការចុះបញ្ជីភ្លាមៗក្រោយពេលកើត និង មានឈ្មោះមួយ ព្រមទាំងទទួលបានសញ្ជាតិមួយផងដែរ។[48] ជាអកុសល មិនមែនគ្រប់ AMS ទាំងអស់សុទ្ធតែជាភាគីនៃ ICCPR នោះទេ។

---

48 ICCPR មាត្រា ២៤៖

១. កុមារគ្រប់រូបមានសិទ្ធិទទួលបានវិធានការការពារ តម្រូវនឹងស្ថានភាពរបស់ខ្លួនជាអនីតិជន ពីសំណាក់គ្រួសាររបស់ខ្លួន សង្គម និង រដ្ឋ ដោយគ្មានការរើសអើសពូជសាសន៍ ពណ៌សម្បុរ ភេទ ភាសា សាសនា ដើមកំណើតជាតិ ឬ សង្គម ទ្រព្យសម្បត្តិ ឬ កំណើតឡើយ។

២. កុមារគ្រប់រូបត្រូវបានចុះក្នុងសៀវភៅអត្រានុកូលដ្ឋានភ្លាម បន្ទាប់ពីពេលកើត និង ត្រូវមានឈ្មោះ។

៣. កុមារគ្រប់រូបមានសិទ្ធិទទួលបានសញ្ជាតិមួយ។

https://www.ohchr.org/Documents/ProfessionalInterest/ccpr.pdf

ទោះបីជាយ៉ាងណាក៏ដោយ វាមានសារសំខាន់នៅក្នុងការកត់សម្គាល់ថា AMS ទាំងអស់ គឺជាភាគីនៃអនុសញ្ញាស្តីពីសិទ្ធិកុមារ (CRC) ឆ្នាំ១៩៩០។ អនុសញ្ញានេះ នៅក្រោមមាត្រា ៧ ចែងអំពីសិទ្ធិរបស់កុមារចំពោះការចុះបញ្ជីកំណើត។[49] មាត្រា ៨ បញ្ជាក់បន្ថែមអំពីសិទ្ធិរបស់កុមារចំពោះរក្សាអត្តសញ្ញាណរបស់គាត់ ឬ នាង។[50] លើសពីនេះទៀត ក្រុមប្រឹក្សាសិទ្ធិមនុស្ស នៅថ្ងៃទី២១ ខែមីនា ឆ្នាំ២០១៣ បានអនុម័តលើសេចក្តីសម្រេចលេខ ២២/៧ ស្តីពីការចុះបញ្ជីកំណើត និង សិទ្ធិរបស់មនុស្សគ្រប់រូបចំពោះការទទួលស្គាល់នៅគ្រប់ទីកន្លែងទាំងអស់ ថាជាមនុស្សម្នាក់នៅចំពោះមុខច្បាប់។[51] សេចក្តីសម្រេចនេះបានរំឭករដ្ឋយ៉ាងច្បាស់លាស់អំពីកាតព្វកិច្ចរបស់ពួកគេនៅក្នុងការចុះបញ្ជីកំណើតដោយគ្មានការរើសអើងលើឋានៈគ្រប់ប្រភេទ និង ដោយមិនគិតអំពីឋានៈរបស់ឪពុកម្តាយនោះទេ។[52] គណៈកម្មាធិការនៃអនុសញ្ញាស្តីពីសិទ្ធិកុមារបានផ្តល់អនុសាសន៍បន្ថែមអំពីបទដ្ឋានសម្រាប់ការប្រកាន់ខ្ជាប់នូវសិទ្ធិចុះបញ្ជីកំណើតយ៉ាងមានប្រសិទ្ធភាព៖ "... គណៈកម្មាធិការផ្តល់អនុសាសន៍ថា ភាគីរដ្ឋត្រូវអនុវត្តរាល់វិធានការចាំបាច់ទាំងអស់ដើម្បីធានាថា កុមារគ្រប់រូបត្រូវបានចុះបញ្ជីអត្រានុកូលដ្ឋាននៅពេលកើត។ សកម្មភាពនេះអាចសម្រេចបានតាមរយៈប្រព័ន្ធចុះបញ្ជីជាសកលមួយដែលត្រូវបានគ្រប់គ្រងបានយ៉ាងល្អ ដែលអាចប្រើប្រាស់បានដោយមនុស្សគ្រប់រូប និង ដោយឥតគិតថ្លៃ។ ប្រព័ន្ធដែលមានប្រសិទ្ធភាពមួយត្រូវតែអាចបត់បែនបាន និង ឆ្លើយតបទៅនឹងកាលៈទេសៈរបស់គ្រួសារ ឧទាហរណ៍៖ តាមរយៈការផ្តល់ជូននូវផ្នែកចុះបញ្ជីចល័ត ប្រសិនបើសមស្រប។ គណៈកម្មាធិការកត់សម្គាល់ថា កុមារដែលឈឺ ឬ ពិការ មិនសូវទំនងជាត្រូវបានចុះបញ្ជីអត្រានុកូលដ្ឋាននៅក្នុងតំបន់មួយចំនួននោះទេ និង សង្កត់ធ្ងន់ថា កុមារគ្រប់រូបគួរតែត្រូវបានចុះបញ្ជីអត្រានុកូលដ្ឋាននៅពេលកើត ដោយគ្មានការរើសអើងគ្រប់ប្រភេទ (មាត្រា ២)។ គណៈកម្មាធិការក៏រំឭកដល់ភាគីរដ្ឋអំពីសារសំខាន់នៃការជួយសម្រួលដល់ការចុះបញ្ជីកំណើតយឺតពេលផងដែរ"។[53]

---

49 CRC មាត្រា ៧៖

១. កុមារត្រូវបានចុះក្នុងសៀវភៅអត្រានុកូលដ្ឋានភ្លាម បន្ទាប់ពីពេលកើត និង ត្រូវមានសិទ្ធិពីកំណើតក្នុងការទទួលបានឈ្មោះមួយ មានសិទ្ធិទទួលបានសញ្ជាតិមួយ និង តាមលទ្ធភាពដែលអាចធ្វើបាន កុមារត្រូវមានសិទ្ធិស្គាល់ឪពុកម្តាយ និង ទទួលការថែទាំពីឪពុកម្តាយ។

២. រដ្ឋភាគីត្រូវធានាការអនុវត្តសិទ្ធិទាំងនេះ ស្របតាមច្បាប់ជាតិ និង កាតព្វកិច្ចរបស់ពួកគេ ក្រោមលិខិតូបករណ៍អន្តរជាតិក្នុង វិស័យនេះ ពិសេសក្នុងករណីដែលកុមារនឹងក្លាយជាជនឥតស្រុកទេស បើគ្មានការអនុវត្តនោះទេ។

50 CRC មាត្រា ៨៖

១. រដ្ឋភាគីសន្យាគោរពសិទ្ធិរក្សាអត្តសញ្ញាណរបស់កុមារ រួមមានសញ្ជាតិ ឈ្មោះ និង ទំនាក់ទំនងគ្រួសារផងដែរ ដូចបានទទួលស្គាល់ដោយច្បាប់ ដោយគ្មានការជ្រៀតជ្រែកដោយខុសច្បាប់ឡើយ។

២. បើកុមារម្នាក់ត្រូវរងការដកហូតដោយខុសច្បាប់ នូវធាតុមួយចំនួន ឬ ទាំងអស់នៃអត្តសញ្ញាណរបស់ខ្លួននោះ រដ្ឋភាគីត្រូវផ្តល់ជំនួយ និងការការពារយ៉ាងសមស្រប ដើម្បីស្តារអត្តសញ្ញាណរបស់កុមារឡើងវិញឲ្យបានឆាប់រហ័ស។

51 មហាសន្និបាតអង្គការសហប្រជាជាតិ A/HRC/22/L.14/Rev.1

បញ្ជាក់ឡើងវិញអំពីសិទ្ធិមនុស្សរបស់ជនគ្រប់រូបក្នុងការទទួលបាន ការទទួលស្គាល់នៅគ្រប់ទីកន្លែងទាំងអស់ ថាជាមនុស្សម្នាក់នៅចំពោះមុខច្បាប់ ដែលមានចែង ក្នុងចំណោមលិខិតូបករណ៍ផ្សេងទៀត នៅក្នុងសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និង សិទ្ធិនយោបាយ អនុសញ្ញាស្តីពីសិទ្ធិកុមារ អនុសញ្ញាស្តីពីសិទ្ធិជនពិការ និង លិខិតូករណ៍អន្តរជាតិដែលពាក់ព័ន្ធដទៃទៀត

រំឭកអំពីកាតព្វកិច្ចរបស់រដ្ឋនៅក្នុងការចុះបញ្ជីកុមារគ្រប់រូបភ្លាមៗ បន្ទាប់ពីកើត ដូចមានចែងនៅក្នុងកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និង សិទ្ធិនយោបាយ អនុសញ្ញាស្តីពីសិទ្ធិកុមារ អនុសញ្ញាអន្តរជាតិស្តីពីសិទ្ធិរបស់ពលករទេសន្តរប្រវេសន៍គ្រប់រូប និង សមាជិកគ្រួសាររបស់ពួកគេ និង លិខិតូករណ៍អន្តរជាតិដទៃទៀត ដែលពួកគេគឺជាភាគី

ទទួលស្គាល់សារសំខាន់នៃការចុះបញ្ជីកំណើត រួមបញ្ចូលទាំងការចុះបញ្ជីកំណើតយឺតពេល និង ការផ្តល់ឯកសារបញ្ជាក់អះអាងអំពីកំណើត ថាជាមធ្យោបាយមួយសម្រាប់ផ្តល់កំណត់ត្រាផ្លូវការអំពីវត្តមានរបស់មនុស្សម្នាក់ និង ការទទួលស្គាល់បុគ្គលរូបនោះជាមនុស្សម្នាក់នៅចំពោះមុខច្បាប់ ដោយបង្ហាញអំពីកង្វល់ថាបុគ្គលដែលមិនបាន ចុះបញ្ជីអត្រានុកូលដ្ឋានមានការដាក់កម្រិតលើការទទួលបាន ឬ មិនទទួលបានសេវា និង សិទ្ធិទាំងអស់ ដែលមានគេមានសិទ្ធិទទួលបាន ព្រមទាំងពិចារណាថា ជនដែលមិនបានចុះបញ្ជីកំណើតងាយរងគ្រោះដោយសារកង្វះខាតការការពារ និង ដឹងថា ការចុះបញ្ជីកំណើត របស់មនុស្សម្នាក់ គឺជាជំហានដ៏សំខាន់មួយដើម្បីឆ្ពោះទៅកាន់ការ លើកកម្ពស់ និង ការការពារសិទ្ធិមនុស្សរបស់គាត់ ឬ នាងទាំងអស់ និង ការការពារពីអំពើហិង្សា ការកេងប្រវ័ញ្ច និង ការបំពាន

ទទួលស្គាល់ផងដែរនូវសារសំខាន់នៃការចុះបញ្ជីកំណើត រួមបញ្ចូលទាំង ការចុះបញ្ជីកំណើតយឺតពេលផងដែរ ចំពោះការអភិវឌ្ឍស្ថិតិអត្រានុកូលដ្ឋាន និង ការអនុវត្តប្រកបដោយប្រសិទ្ធភាពនៃកម្មវិធី និង គោលនយោបាយនានាដែលមានបំណងសម្រេចឲ្យបាននូវគោលដៅអភិវឌ្ឍន៍ដែលបានយល់ព្រមជាអន្តរជាតិ រួមបញ្ចូលទាំងគោលដៅ អភិវឌ្ឍន៍សហវត្សរ៍ផងដែរ។

https://documents-ddsny.un.org/doc/RESOLUTION/LTD/G13/123/89/PDF/G1312389.pdf?OpenElement

52 Ibid.

53 គណៈកម្មាធិការសិទ្ធិកុមារ មតិយោបល់ទូទៅ លេខ ៧ (២០០៥) ស្តីពីការអនុវត្តសិទ្ធិកុមារនៅវ័យកុមារតូច កឋាខណ្ឌទី ២៥ អាចស្វែងរកបាននៅ៖ http://www.refworld.org/docid/460bc5a62.html

លើសពីនេះទៀត មាត្រា ៩ នៃអនុសញ្ញាស្ដីពីការលុបបំបាត់ រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងស្ត្រីភេទ (CEDAW) ដែលរដ្ឋទាំងអស់ AMS ជាភាគី បញ្ញត្តិអំពីភារកិច្ចរបស់រដ្ឋចំពោះ "១) ការផ្ដល់ជូនស្ត្រីនូវសិទ្ធិស្មើគ្នានឹងបុរស ក្នុងការទទួលផ្លាស់ប្ដូរ ឬ រក្សាទុកសញ្ជាតិរបស់ខ្លួន។ រដ្ឋភាគីត្រូវធានាជា ពិសេសថា ការរៀបអាពាហ៍ពិពាហ៍ជាមួយជនបរទេស និង ការផ្លាស់ប្ដូរសញ្ជាតិរបស់ប្ដីក្នុងពេលអាពាហ៍ពិពាហ៍ មិនធ្វើឲ្យមានការផ្លាស់ប្ដូរជាស្វ័យប្រវត្តិនូវសញ្ជាតិរបស់ប្រពន្ធ មិនធ្វើឲ្យប្រពន្ធគ្មានសញ្ជាតិ ឬ បង្ខំឲ្យប្រពន្ធយកសញ្ជាតិរបស់ប្ដីឡើយ និង ២) ផ្ដល់ជូនស្ត្រីនូវសិទ្ធិស្មើគ្នានឹងបុរសក្នុងការ សម្រេចអំពីសញ្ជាតិរបស់កូន"។[54] ដូចគ្នានេះដែរ **អនុសញ្ញាស្ដីពីសិទ្ធិជនពិការ (CRPD)** នៅក្នុងមាត្រា ១៨ (១) សង្កត់ធ្ងន់លើកាតព្វកិច្ចរបស់រដ្ឋក្នុង "ការទទួលស្គាល់សិទ្ធិរបស់ជនពិការ... ចំពោះសញ្ជាតិ ដោយឈរលើមូលដ្ឋានស្មើភាពគ្នាជាមួយអ្នកដទៃ រួមទាំងការធានាឲ្យជនពិការ៖ ក) មាន សិទ្ធិទទួលបាន និង ប្ដូរសញ្ជាតិ ហើយមិនត្រូវដកហូតសញ្ជាតិរបស់ពួកគេដោយ មិនសមហេតុផល ឬ ដោយសារតែពិការភាពនោះទេ ខ) មិនត្រូវដកហូតលទ្ធភាពរបស់ពួកគេ ក្នុងការទទួលបានកាន់កាប់ និងប្រើប្រាស់ឯកសារសញ្ជាតិ ឬ ឯកសារបញ្ជាក់អត្តសញ្ញាណដទៃទៀត... ដោយសារតែពិការភាពនោះទេ និង (២) កុមារពិការត្រូវបានចុះបញ្ជីអត្រានុកូលដ្ឋានភ្លាមៗបន្ទាប់ពីកើត និងត្រូវមានសិទ្ធិពីកំណើត ក្នុងការទទួលបានឈ្មោះមួយ សិទ្ធិទទួលបានសញ្ជាតិមួយ និង តាមលទ្ធភាពដែលអាចធ្វើបាន មានសិទ្ធិស្គាល់ឪពុកម្ដាយ និងទទួលការថែទាំពី ឪពុកម្ដាយ"។[55]



សិទ្ធិចុះបញ្ជីកំណើត មិនត្រូវបានរឹតត្បិតចំពោះច្បាប់ស្ដីពីសិទ្ធិមនុស្សនោះទេ ជាក់ស្ដែងវាមានទំនាក់ទំនងយ៉ាងសំខាន់ ទៅនឹងបញ្ហានានាដែលកើតឡើង ទាំងនៅក្នុងច្បាប់អន្តរជាតិស្ដីពីជនភៀសខ្លួន និង ច្បាប់មនុស្សធម៌អន្តរជាតិ។[56] នៅក្នុងករណីនេះ **គណៈកម្មាធិការប្រតិបត្តិនៃការិយាល័យឧត្ដមស្នងការអង្គការសហប្រជាជាតិ ទទួលបន្ទុកជនភៀសខ្លួន** (UNHCR) បានលើកឡើងជាបន្តបន្ទាប់អំពីបញ្ហាការចុះបញ្ជីកំណើត របស់ជនភៀសខ្លួន អ្នកស្វែងរកសិទ្ធិជ្រកកោន និង ជនគ្មានសញ្ជាតិនៅក្នុងសេចក្ដីសន្និដ្ឋាន អំពីកិច្ចការពារអន្តរជាតិរបស់ខ្លួន ដែលនៅក្នុងនោះ មានសេចក្ដីសន្និដ្ឋានចំនួនប្រាំបួន បានរួមបញ្ចូលអនុសាសន៍ជាក់លាក់ស្ដីពីការចុះបញ្ជីកំណើត និង សិទ្ធិទទួលបានអត្តសញ្ញាណ។ នៅខែតុលា ឆ្នាំ២០១៣ គណៈកម្មាធិការប្រតិបត្តិនេះ បានអនុម័តសេចក្ដីសន្និដ្ឋានអំពីកិច្ចការពារអន្តរជាតិមួយ ដែលផ្ដោតជាពិសេសលើការចុះបញ្ជីអត្រានុកូលដ្ឋាន។ នៅក្នុងសេចក្ដីសន្និដ្ឋាននោះ គណៈកម្មាធិការប្រតិបត្តិបានលើកទឹកចិត្តឲ្យរដ្ឋធានាថា កុមារគ្រប់រូបត្រូវបានចុះបញ្ជីអត្រានុកូលដ្ឋានភ្លាមៗ បន្ទាប់ពីកើតដោយគ្មានការរើសអើងគ្រប់ប្រភេទ សេចក្ដីសន្និដ្ឋាននេះ គឺជាឯកសារដ៏សំខាន់មួយដែលកំណត់ក្របខណ្ឌសកម្មភាព សម្រាប់ការការពារសិទ្ធិរបស់ជនភៀសខ្លួន អ្នកស្វែងរកសិទ្ធិជ្រកកោន និង ជនគ្មានសញ្ជាតិ។ លើសពីនេះទៀត UNHCR បានធ្វើឲ្យ

54 អនុសញ្ញាស្ដីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងស្ត្រីភេទ http://www.un.org/womenwatch/daw/cedaw/text/econvention.htm#part2

55 អនុសញ្ញាស្ដីពីសិទ្ធិជនពិការ https://www.un.org/development/desa/disabilities/convention-on-the-rights-of-persons-with-disabilities/article-18- liberty-of-movement-and-nationality.html



ការចុះបញ្ជីកំណើត ក្លាយជាអាទិភាពផ្នែកយុទ្ធសាស្ត្រជាសកលមួយ។ ក្របខណ្ឌសម្រាប់ការការពារកុមារ ដែលត្រូវបានចេញដោយ UNHCR នៅឆ្នាំ២០១២[57] ក៏រួមបញ្ចូលវត្ថុបំណងជាក់លាក់នៅក្នុងការធានាថាកុមារី និង កុមារាទទួលបានឯកសារតាមផ្លូវច្បាប់ ដែលរួមបញ្ចូលទាំង ការទទួលបានសំបុត្រកំណើត ដោយគ្មានការរើសអើងផងដែរ (គោលដៅទី៤)។[58] លើសពីនេះទៀត ការធានាចំពោះការចុះបញ្ជីកំណើត ដើម្បីទប់ស្កាត់ភាពគ្មានសញ្ជាតិ គឺជាសកម្មភាពមួយក្នុងចំណោមសកម្មភាពទាំងដប់នៃផែនការសកម្មភាពជាសកល ដើម្បីបញ្ចប់ភាពគ្មានសញ្ជាតិរបស់ UNHCR ឆ្នាំ ២០១៤ - ២០២៤។[59]

សិទ្ធិទាំងនេះធ្វើឲ្យមនុស្សម្នាក់មានសមត្ថភាពក្លាយជាអ្នកកាន់កាប់សិទ្ធិ និង កាតព្វកិច្ចយ៉ាងស្របច្បាប់ ដែលចង្អុលបង្ហាញអំពីឋានៈតាមផ្លូវច្បាប់ និងសមត្ថភាពនៅក្នុងការអនុវត្តកាតព្វកិច្ចតាមកិច្ចសន្យា។ ច្បាប់សិទ្ធិមនុស្សអន្តរជាតិក៏ បញ្ញត្តិ អំពីកាតព្វកិច្ចរបស់រដ្ឋ ដែលមិនត្រឹមតែទទួលស្គាល់នោះទេ ប៉ុន្តែថែមទាំងធានាផងដែរថាប្រជាជនគ្រប់រូប នៅក្នុងដែនដីរបស់ពួកគេនឹងអាចទទួលបានសិទ្ធិទាំងនោះ ដែលជាមូលដ្ឋានគ្រឹះ ដើម្បីទទួលបានសិទ្ធិដទៃទៀត។ កំណត់ត្រា និងឯកសារនានាដែលត្រូវបានបង្កើតឡើង តាមរយៈការចុះបញ្ជីកំណើត និង អាពាហ៍ពិពាហ៍ ផ្តល់ជូនបុគ្គលទាំងឡាយ នូវភ័ស្តុតាងបញ្ជាក់អំពីអត្តសញ្ញាណតាមផ្លូវច្បាប់ និងទំនាក់ទំនងគ្រួសាររបស់ពួកគេ ដែលជាមូលដ្ឋានគ្រឹះសម្រាប់លទ្ធភាពនៅក្នុងការទទួលបាន និង ការប្រើប្រាស់សិទ្ធិដទៃទៀតរបស់ពួកគេ។ ជាពិសេស ការចុះបញ្ជីកំណើតមានបំណង ធ្វើជាសមាសធាតុនៃអត្តសញ្ញាណតាមផ្លូវច្បាប់របស់មនុស្សម្នាក់ ដោយសារតែសំបុត្រកំណើត តាមធម្មតា គឺជាឯកសារអត្តសញ្ញាណទីមួយដែលមនុស្សម្នាក់ទទួលបាន និង ជាញឹកញាប់គឺជា ឯកសារមូលដ្ឋាន ដើម្បីទទួលបានឯកសារអត្តសញ្ញាណណាមួយផ្សេងទៀតជាលើកទីមួយ។[60] ដោយសារតែសារសំខាន់របស់វា ACWC សហការជាមួយ UNHCR បានព្រមព្រៀងគ្នាធ្វើការសិក្សានេះ នៅក្នុងប្រទេសសមាជិកអាស៊ានទាំង១០ប្រទេស ដើម្បីលើកកម្ពស់បរិយាប័ន្ន និង ការអភិវឌ្ឍប្រកបដោយចីរភាពនៅក្នុងការកសាងសហគមន៍អាស៊ាន តាមរយៈការធានាចំពោះការទទួលស្គាល់អត្តសញ្ញាណតាមផ្លូវច្បាប់របស់ស្ត្រី និង កុមារគ្រប់រូបនៅអាស៊ាន។

---

56 អនុសញ្ញាស្តីពីការកាត់បន្ថយជនគ្មានសញ្ជាតិ មាត្រា ១-៦ និង អនុសញ្ញាទីក្រុងហ្សឺណែវទាក់ទងនឹងការការពារសិទ្ធិរបស់ជនស៊ីវិលក្នុងពេលមានសង្គ្រាម មាត្រា ៥០។

57 www.refworld.org/docid/4fe875682.html. ដកស្រង់ដោយរបៀបវារៈនៃកិច្ចប្រជុំលើកទីម្ភៃប្រាំពីររបស់ក្រុមប្រឹក្សាសិទ្ធិមនុស្ស ចំណុចទី២ និង ទី៣ របាយការណ៍ប្រចាំឆ្នាំរបស់ឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស និង របាយការណ៍របស់ការិយាល័យឧត្តមស្នងការ និង អគ្គលេខាធិការ A/HRC/២៧/២២ ថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១៤។

58 Ibid.

59 UNHCR ផែនការសកម្មភាពជាសកលដើម្បីបញ្ចប់ភាពគ្មានសញ្ជាតិ ឆ្នាំ២០១៤-២០២៤https://www.unhcr.org/protection/statelessness/54621bf49/global-action-plan-end-statelessness-2014-2024.html

60 RSO ឧបករណ៍ប៉ាន់ប្រមាណអំពីការចុះបញ្ជីអត្រានុកូលដ្ឋានក្រោមដំណើរការបាលី
https://www.baliprocess.net/UserFiles/baliprocess/File/Bali%20Process%20Civil%20Registration%20Assessment%20Toolkit%20FINAL.pdf

## ២.២ ច្បាប់ និង គោលនយោបាយដែលទាក់ទងនឹងការចុះបញ្ជីអត្រានុកូលដ្ឋាន ការចុះបញ្ជីកំណើត និង ឯកសារអត្រានុកូលដ្ឋាននៅអាស៊ាន

**ការចុះបញ្ជីកំណើត** ត្រូវបានយល់ថាជាសិទ្ធិមូលដ្ឋានរបស់កុមារ ដូចបានសរសេរដោយ UNICEF នៅឆ្នាំ២០១៥។[61] ដូចមានចែងនៅក្នុងសេចក្តីផ្តើម ការចុះបញ្ជីកំណើតផ្តល់

“ អត្តសញ្ញាណតាមផ្លូវច្បាប់ ដែលមានទំនាក់ទំនងនឹងប្រទេសកំណើត និង សិទ្ធិទទួលបានសេវានានារបស់រដ្ឋ រួមមាន ការអប់រំ ការការពារ ការថែទាំសុខភាព និង កម្មវិធីពិសេស។សម្រាប់ប្រជាជនងាយរងគ្រោះ ដែលមានបំណងមិនទុកអ្នកណាម្នាក់ចោល” ។[62]

ក្រុមប្រឹក្សាសិទ្ធិមនុស្ស នៅក្នុងរបាយការណ៍របស់ខ្លួនដែលបានចេញនៅថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១៤ បានចែងថា

“ ការបំពេញតាមសិទ្ធិចុះបញ្ជីអត្រានុកូលដ្ឋាននៅពេលកើត មានទំនាក់ទំនងយ៉ាងជិតស្និទ្ធនឹងការទទួលស្គាល់សិទ្ធិជាច្រើនផ្សេងទៀត សិទ្ធិសេដ្ឋកិច្ចសង្គម ដូចជា សិទ្ធិទទួលបានការថែទាំសុខភាព និង សិទ្ធិទទួលបានការអប់រំ ជាដើម ដែលប្រឈមមុខនឹងហានិភ័យជាពិសេស ប្រសិនបើការចុះបញ្ជីកំណើតមិនត្រូវបានអនុវត្តជាប្រព័ន្ធទេនោះ និងមានភាពអន្តរាយចំពោះការការពារកុមារ” ។[63]



61 ដកស្រង់ដោយ Leslie Butt និង Jesica Ball ការចុះបញ្ជីកំណើតនៅអាស៊ីអាគ្នេយ៍៖ សិទ្ធិមូលដ្ឋានរបស់កុមារ? ទិន្នានុប្បវត្តិនៃការសិក្សាអំពីប្រជាជនអាស៊ី ច្បាប់ទី១៣ ឆ្នាំ២០១៧ - ចេញផ្សាយលើកទី ៣ RSO ឧបករណ៍ប៉ាន់ប្រមាណអំពីការចុះបញ្ជីអត្រានុកូលដ្ឋានក្រោមដំណើរការបាលី Ibid.

62 Ibid.

63 ក្រុមប្រឹក្សាសិទ្ធិមនុស្ស Ibid.

ក្រុមប្រឹក្សាសិទ្ធិមនុស្សបានសង្កត់ធ្ងន់បន្ថែមទៀតថា “ការចុះបញ្ជីកំណើតមានដំណើរការចំនួនបីដែលមានទំនាក់ទំនងនឹងគ្នាទៅវិញទៅមក។ ទីមួយ ត្រូវតែការជូនដំណឹងអំពីហេតុការណ៍ នៃកំណើតទៅកាន់មន្ត្រី



> “ វាបានបញ្ជាក់ច្បាស់ថា៖ ការចុះបញ្ជីកំណើតមានដំណើរការចំនួនបី ដែលមានទំនាក់ទំនងនឹងគ្នាទៅវិញទៅមក។ ទីមួយ ត្រូវតែមានប្រកាសស្តីពីព្រឹត្តិការណ៍កំណើតដល់មន្ត្រីអត្រានុកូលដ្ឋាន។ ទីពីរ ទទួលដំណឹងរួចរាល់ហើយ មន្ត្រីអត្រានុកូលដ្ឋានធ្វើការកត់ត្រាអំពីកំណើតជាផ្លូវការ [...]

អត្រានុកូលដ្ឋាន។ ទីពីរ បន្ទាប់ពីបានទទួលដំណឹងរួចរាល់ហើយ មន្ត្រីអត្រានុកូលដ្ឋានធ្វើការកត់ត្រាអំពីកំណើតជាផ្លូវការ។ ការចុះបញ្ជីគួរតែរួមបញ្ចូល ឈ្មោះ ថ្ងៃខែឆ្នាំកំណើត និង ទីកន្លែងកំណើត ព្រមទាំង ប្រសិនបើអាចធ្វើបាន ឈ្មោះ អាយុ ឬ ថ្ងៃខែឆ្នាំកំណើត ទីលំនៅធម្មតា និង សញ្ជាតិរបស់ឪពុកម្តាយទាំងសងខាងផងដែរ។ ទីបី រដ្ឋចេញសំបុត្រកំណើត ដែលជាឯកសារផ្ទាល់ខ្លួនមួយ ដើម្បីបញ្ជាក់អះអាងអំពីការចុះ បញ្ជីកំណើត និងជាភ័ស្តុតាងជាក់ស្តែងបំផុតនៃការទទួលស្គាល់កុមារតាមផ្លូវច្បាប់របស់រដ្ឋ។ នីតិវិធីនេះត្រូវបានអនុវត្តតាមដោយស្វ័យប្រវត្តិ បន្ទាប់ពីចុះបញ្ជីរួច ឬ តម្រូវឲ្យមានការដាក់ពាក្យស្នើសុំមួយផ្សេងទៀតអាស្រ័យលើប្រទេស”។[64]

នៅទូទាំងអាស៊ាន ការចុះបញ្ជីអត្រានុកូលដ្ឋានត្រូវបានបញ្ញត្តិដោយច្បាប់ (ចូរមើល**តារាងទី២** នៅទំព័រទី១០៧)។ នៅប្រទេសប្រ៊ុយណេដារូសាឡឹម មានច្បាប់ខុសៗគ្នាដែលគ្របដណ្តប់លើការចុះបញ្ជីកំណើត និង មរណភាព (ច្បាប់ស្តីពីការចុះបញ្ជីកំណើត និង មរណភាព ឆ្នាំ១៩៩៣ ត្រូវបានធ្វើវិសោធនកម្មដោយ S១៧/២០១២ និង ត្រូវបានកែសម្រួលនៅឆ្នាំ២០១៣) ការចុះបញ្ជីអត្តសញ្ញាណប័ណ្ណ (ច្បាប់ស្តីពីការចុះបញ្ជីជាតិ ឆ្នាំ១៩៨៤) ការចុះបញ្ជីសុំកូន (ច្បាប់ស្តីពីការចុះបញ្ជីសុំកូន ឆ្នាំ១៩៨៤) និង អាពាហ៍ពិពាហ៍ (ច្បាប់ស្តីពីការចុះបញ្ជីអាពាហ៍ពិពាហ៍ ឆ្នាំ១៩៨៤)។ ច្បាប់ក្រោយៗអនុវត្តខុសគ្នាចំពោះអ្នកមិនកាន់សាសនាឥស្លាម

64 Ibid.



(ជំពូក ១២៤) និង អ្នកកាន់សាសនាឥស្លាម (ជំពូក ២១៧)។[65] នៅ**ប្រទេសកម្ពុជា** ការចុះបញ្ជីកំណើតត្រូវបានបញ្ញត្តិដោយអនុក្រឹត្យលេខ ១០៣ អនក្រ.បក ដែលត្រូវបានអនុម័តនៅ ថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០០ ហើយបច្ចុប្បន្នកំពុងត្រូវបានត្រួតពិនិត្យឡើងវិញ។ ច្បាប់ដទៃទៀតនៃប្រទេសកម្ពុជា ដូចជា ច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និង គ្រួសារ ឆ្នាំ១៩៨៩ និង ច្បាប់អន្តោប្រវេសន៍ ឆ្នាំ១៩៩៤ គ្របដណ្តប់លើទង្វើផ្សេងទៀត នៃការចុះបញ្ជីអត្រានុកូលដ្ឋាន។[66] នៅ**ប្រទេសឥណ្ឌូនេស៊ី** ច្បាប់លេខ ២៣/២០០៦ ដូចដែលត្រូវបានធ្វើវិសោធនកម្ម ដោយច្បាប់លេខ ២៤/២០១៣ ស្តីពីរដ្ឋបាលប្រជាជន ធ្វើឲ្យប្រជាជនឥណ្ឌូនេស៊ីមានកាតព្វកិច្ចរាយការណ៍ និង ចុះបញ្ជីកំណើត និង ព្រឹត្តិការណ៍អត្រានុកូលដ្ឋានផ្សេងទៀត (មាត្រា ២៧)។ មាត្រា ១ កថា ខណ្ឌទី ២ កំណត់ថាប្រជាជនឥណ្ឌូនេស៊ី រួមបញ្ចូលទាំងពលរដ្ឋឥណ្ឌូនេស៊ី និងជនបរទេស (ដែលរស់នៅក្នុងប្រទេសឥណ្ឌូនេស៊ី) ផងដែរ និង ចែងថា ពួកគេមានសិទ្ធិធ្វើការរាយការណ៍ និងចុះបញ្ជីកំណើតនៅកន្លែងដែលពួកគេកើត។[67] នៅ**ប្រទេសឡាវ** ការចុះបញ្ជីអត្រានុ-កូលដ្ឋាន រួមមានការចុះបញ្ជីកំណើត អាពាហ៍ពិពាហ៍ និង មរណភាព ការផ្លាស់ប្តូរសញ្ជាតិ។ល។ នឹងលេចឡើងនៅក្នុងសៀវភៅគ្រួសារ ដូចមានចែងនៅក្រោមច្បាប់ស្តីពីការចុះបញ្ជីគ្រួសារ។[68] នៅ**ប្រទេសម៉ាឡេស៊ី** ច្បាប់ដែលទាក់ទងនឹងអាពាហ៍ពិពាហ៍មានភាពខុសគ្នាចំពោះអ្នកកាន់សាសនាឥស្លាម និង អ្នកមិនកាន់សាសនាឥស្លាម។ ច្បាប់ / ការអនុវត្តច្បាប់ស្តីពីគ្រួសាររបស់អ្នកកាន់សាសនាឥស្លាមរបស់រដ្ឋនីមួយៗ នៅក្នុងប្រទេសម៉ាឡេស៊ីអនុវត្តចំពោះអ្នកកាន់សាសនាឥស្លាម នៅខណៈពេលដែលកំណែទម្រង់ច្បាប់ (ច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និង ការលែងលះ ឆ្នាំ១៩៧៦ [ច្បាប់លេខ ១៦៤]) អនុវត្តចំពោះអ្នកមិនកាន់សាសនាឥស្លាមគ្រប់រូប។ ការចុះបញ្ជីកំណើតនៅប្រទេសម៉ាឡេស៊ីត្រូវបានគ្រប់គ្រងដោយច្បាប់ស្តីពីការចុះបញ្ជីកំណើត និង មរណភាព ឆ្នាំ១៩៥៧ [ច្បាប់លេខ ២៩៩] បទប្បញ្ញត្តិស្តីពីការចុះបញ្ជីកំណើត និង មរណភាព ឆ្នាំ១៩៤៨ (Sabah Cap. ១២៣) បទប្បញ្ញត្តិស្តីពីការចុះបញ្ជីកំណើត និង មរណភាព ឆ្នាំ១៩៥១ (Sarawak Cap. ១០) រៀងៗគ្នា។[69]

នៅ**ប្រទេសមីយ៉ាន់ម៉ា** សេចក្តីជូនដំណឹងលេខ ១/២០១៤ តម្រូវឲ្យក្រសួងអន្តោប្រវេសន៍ និង ប្រជាជនអនុវត្តការចុះបញ្ជីអត្រានុកូលដ្ឋាន យោងតាមអំណាចដែលត្រូវបានប្រគល់ជូន ស្របតាម មាត្រា១៦ នៃ ច្បាប់អន្តោប្រវេសន៍មីយ៉ាន់ម៉ា ឆ្នាំ១៩៤៧ (បញ្ញត្តិស្តីពីគ្រាអាសន្ន)។[70] នៅ**ប្រទេសហ្វីលីពីន** មានបញ្ជីដ៏វែងមួយស្តីពីច្បាប់នានាដែលពាក់ព័ន្ធនឹងការចុះបញ្ជីកំណើត និង ការចុះបញ្ជីអត្រានុកូលដ្ឋាន។ ក្រឹត្យរបស់ប្រធានាធិបតីលេខ ៦៥១ តម្រូវឲ្យមានការចុះបញ្ជីកំណើត និង មរណភាពនៅក្នុងប្រទេសហ្វីលីពីន ដែលបានកើតឡើង ចាប់ពីខែមករា ឆ្នាំ១៩៧៤ រហូតមក។ ច្បាប់ដែលពាក់ព័ន្ធដទៃទៀត រួមមាន ច្បាប់លេខ ៣៧៥៣ (ច្បាប់ស្តីពីគល់បញ្ជីអត្រានុកូលដ្ឋាន) ច្បាប់សាធារណរដ្ឋ លេខ ៨៣៧១ (ច្បាប់ស្តីពីសិទ្ធិរបស់ជនជាតិដើមភាគតិច) និង ច្បាប់លេខ ៣៦១៣ (ច្បាប់ស្តីពីអាពាហ៍ពិពាហ៍)។[71] វាមានសារសំខាន់នៅក្នុងការកត់សម្គាល់ថា នៅប្រទេសហ្វីលីពីន ច្បាប់លេខ ៣៧៥៣ ហៅថា ច្បាប់ស្តីពីគល់បញ្ជីអត្រានុកូលដ្ឋាន ឆ្នាំ១៩៣០ បង្គាប់ថា រាល់ព្រឹត្តការណ៍អត្រានុកូលដ្ឋានទាំងអស់ដែលសម្គាល់អំពីការចូលរួម និង ការចាកចេញរបស់មនុស្សម្នាក់នៅក្នុងមួយជីវិតរបស់គាត់ និង ការផ្លាស់ប្តូរអត្រានុកូលដ្ឋានរបស់គាត់ នឹងត្រូវចុះបញ្ជី។[72] នៅ**ប្រទេសសិង្ហបុរី**

65 ចូរមើលរបាយការណ៍ប្រចាំប្រទេសប្រ៊ុយណេដារូសាឡឹម។

66 ចូរមើលរបាយការណ៍ប្រចាំប្រទេសកម្ពុជា។

67 ធាតុចូលរបស់ប្រទេសឥណ្ឌូនេស៊ីត្រូវបានធ្វើឡើងនៅថ្ងៃទី២៩ ខែមីនា ឆ្នាំ២០១៩។

68 របាយការណ៍ប្រចាំប្រទេសឡាវ។

69 ការកែសម្រួលត្រូវបានស្នើឡើងដោយជនបង្គោលនៃ ប្រទេសម៉ាឡេស៊ី របាយការណ៍ប្រចាំប្រទេសម៉ាឡេស៊ី។

70 របាយការណ៍ប្រចាំប្រទេសមីយ៉ាន់ម៉ា។

71 របាយការណ៍ប្រចាំប្រទេសហ្វីលីពីន។

72 Ibid.

ការចុះបញ្ជីកំណើត និង ការចុះបញ្ជីសញ្ជាតិ ត្រូវបានបញ្ញត្តិដោយច្បាប់ស្តីពីការចុះបញ្ជីកំណើត និង មរណភាព និង ច្បាប់ស្តីពីការចុះបញ្ជីសញ្ជាតិ។[73] នៅប្រទេសថៃ ច្បាប់ស្តីពីការចុះបញ្ជីអត្រានុកូលដ្ឋាន ឆ្នាំ១៩៩១ (ពស. ២៥៣៤)[74] តម្រូវថា "នៅពេលដែលមនុស្សម្នាក់កើត ត្រូវជូនដំណឹងអំពីកំណើតនោះ។ នៅពេលដែលសេចក្តីជូនដំណឹងអំពីកំណើតត្រូវបានធ្វើឡើងសម្រាប់កុមារម្នាក់ មន្ត្រីអត្រានុកូលដ្ឋានត្រូវចុះបញ្ជីកំណើតនោះ និង ចេញសំបុត្រកំណើត ដោយរួមបញ្ចូលការពិតយ៉ាងលម្អិតបំផុតតាមដែលអាចធ្វើបាន ជាភ័ស្តុតាងជូនអ្នកជូនដំណឹងអំពីកំណើតនោះ"។[75] នៅប្រទេសវៀតណាម ច្បាប់ស្តីពីការចុះបញ្ជីអត្រានុកូលដ្ឋាន ឆ្នាំ២០១៤ (ច្បាប់លេខ ៦០/២០១៤/QH១៣) ចែងថា ការចុះបញ្ជីកំណើតគួរតែត្រូវបានបញ្ចប់រួចរាល់នៅក្នុងរយៈពេល ៦០ថ្ងៃ ក្រោយកំណើតរបស់កុមារនោះ ដោយឪពុកម្តាយ ឬ សាច់ញាតិ ឬ បុគ្គលណាម្នាក់ ឬ អង្គភាពណាមួយ ដែលកំពុងតែចិញ្ចឹមកុមារនោះ។ លើសពីនេះ ច្បាប់ស្តីពីកុមារ ឆ្នាំ២០១៦ ទទួលស្គាល់សិទ្ធិរបស់កុមារក្នុងការចុះបញ្ជីកំណើតរបស់គាត់ និង ទទួលបានភាពជាពលរដ្ឋ។[76]

## ២.៣ ការអនុវត្តច្បាប់ និង គោលនយោបាយស្តីពីការចុះបញ្ជីកំណើត និងការចុះបញ្ជីក្រុមពិបាកទំនាក់ទំនង

### ក) ច្បាប់ និង នីតិវិធីចុះបញ្ជីកំណើត



**ការចុះបញ្ជីកំណើតត្រូវបានចែងដោយច្បាប់ជាតិនៅគ្រប់ AMS ទាំងអស់។** នៅប្រទេសប្រ៊ុយណេដារូសាឡឹម ច្បាប់ស្តីពីការចុះបញ្ជីកំណើត និង មរណភាព សង្កត់ធ្ងន់លើតម្រូវការឲ្យចុះបញ្ជីរាល់កំណើតទាំងអស់ដែលកើតឡើងនៅក្នុងប្រទេស។[77] នៅប្រទេសកម្ពុជា អនុក្រឹត្យលេខ១០៣ ចែងថានៅពេលដែលទារកម្នាក់កើត ឪពុកម្តាយរបស់គាត់មានកាតព្វកិច្ចរាយការណ៍និងចុះបញ្ជីកំណើតនៅក្នុងសៀវភៅចុះបញ្ជីកំណើតនៅចំពោះមុខមន្ត្រីអត្រានុកូលដ្ឋាននៅការិយាល័យឃុំ / សង្កាត់របស់ឪពុកម្តាយ។[78] ទោះបីជាយ៉ាងណាក៏ដោយ វាមានតម្លៃនៅក្នុងការកត់សម្គាល់ថាការចុះបញ្ជីអត្រានុកូលដ្ឋាននៅក្នុងប្រទេសកម្ពុជា មិនមែនមានប្រវត្តិជាយូរលង់មកហើយនោះទេ។ នៅក្នុងទសវត្សរ៍ឆ្នាំ១៩៧០ នៅពេលដែលប្រទេសមានសង្គ្រាមស៊ីវិល ប្រព័ន្ធចុះបញ្ជីកំណើតមានវត្តមានតែនៅក្នុងទីក្រុងប៉ុណ្ណោះ ហើយនៅក្នុងរបបខ្មែរក្រហមនៅចន្លោះឆ្នាំ១៩៧៥ និងឆ្នាំ១៩៧៩ បញ្ជីកំណើតត្រូវបានបំផ្លាញ។ ការចុះបញ្ជីកំណើតបានចាប់ផ្តើមឡើងវិញនៅក្នុងទសវត្សរ៍ឆ្នាំ១៩៨០ ប៉ុន្តែវាមិនបានធ្វើឡើងជាប្រព័ន្ធនោះទេ ហើយការគ្របដណ្តប់នៃការចុះបញ្ជីកំណើតនៅមានកម្រិត។ ចាប់តាំងពីដើមទសវត្សរ៍ឆ្នាំ២០០០មក ការចុះបញ្ជីអត្រានុកូលដ្ឋាន និង ការចុះបញ្ជីកំណើតត្រូវបានធ្វើឡើងនៅទូទាំងប្រទេស ប៉ុន្តែនៅតែមានបញ្ហាប្រឈមមួយចំនួន។[79] ចំពោះប្រទេសឥណ្ឌូនេស៊ី ច្បាប់ស្តីពីវិសោធនកម្មច្បាប់លេខ ២៣ ឆ្នាំ២០០៦ ស្តីពីរដ្ឋបាលប្រជាជនចែងនៅក្នុងមាត្រា ១ (១៥) ថា "ការចុះបញ្ជីអត្រានុកូលដ្ឋាន

---

73 របាយការណ៍ប្រចាំប្រទេសសិង្ហបុរី។

74 បានធ្វើវិសោធនកម្មនៅក្នុងឆ្នាំ២០០៨ (ច្បាប់ស្តីពីការចុះបញ្ជីអត្រានុកូលដ្ឋាន (លេខ ២) ពស. ២៥៥១ (២០០៨) ចូរមើល file:///C:/Users/Admin/AppData/Local/Temp/Civil%20 Registration%20Act%202008_Thailand%20(En).pdf (បកប្រែមិនផ្លូវការដោយលោកស្រី Bongkot Napaumporn (ថ្ងៃទី២០ ខែមីនា ឆ្នាំ២០០៨))

75 របាយការណ៍ប្រចាំប្រទេសថៃ។

76 របាយការណ៍របស់ប្រទេសវៀតណាម។

77 របាយការណ៍ប្រចាំប្រទេសប្រ៊ុយណេដារូសាឡឹម។

78 របាយការណ៍ប្រចាំប្រទេសកម្ពុជា។

79 ធាតុចូលបន្ថែមពីប្រទេសកម្ពុជា។

គឺជាការកត់ត្រាព្រឹត្តិការណ៍អត្រានុកូលដ្ឋាន ដែលត្រូវបានឆ្លងកាត់ ដោយមនុស្សម្នាក់នៅក្នុងគល់បញ្ជីអត្រានុកូលដ្ឋាន នៅទីភ្នាក់ងារអនុវត្ត"។[80] លើសពីនេះទៀត ច្បាប់របស់សាធារណរដ្ឋឥណ្ឌូនេស៊ី លេខ ២៤ ឆ្នាំ២០១៣ ស្ដីពីវិសោធនកម្មលើច្បាប់របស់សាធារណរដ្ឋឥណ្ឌូនេស៊ី លេខ ២៣ ឆ្នាំ២០០៦ ស្ដីពីរដ្ឋបាលប្រជាជនចែងថា "ប្រជាជនឥណ្ឌូនេស៊ី(ពលរដ្ឋ ឬ ជនបរទេសដែលរស់នៅក្នុងប្រទេសឥណ្ឌូនេស៊ី និង កាន់ទិដ្ឋាការអចិន្ត្រៃយ៍ឬ ទិដ្ឋាការមានកំណត់) គួរតែរាយការណ៍ និង ចុះបញ្ជីកំណើតនៅទីលំនៅរបស់ពួកគេ។ ពលរដ្ឋឥណ្ឌូនេស៊ី ដែលមិនរស់នៅក្នុងប្រទេសឥណ្ឌូនេស៊ី និង ជនបរទេស ដែលកាន់ទិដ្ឋាការបណ្ដោះអាសន្ន គួរតែរាយការណ៍ និង ចុះបញ្ជីកំណើតនៅទីកន្លែងកំណើត"។[81]



នៅប្រទេសឡាវ ដូចបានចង្អុលបង្ហាញនៅខាងលើ ច្បាប់ស្ដីពីការចុះបញ្ជីគ្រួសារ គ្របដណ្ដប់លើព្រឹត្តិការណ៍អត្រានុកូលដ្ឋាន ដែលរួមបញ្ចូលទាំងកំណើត និងការចេញអត្តសញ្ញាណប័ណ្ណ ព្រមទាំងការផ្លាស់ប្ដូរសញ្ជាតិរបស់ពលរដ្ឋឡាវ ជនបរទេស និង ជនគ្មានសញ្ជាតិផងដែរ។ ការចុះបញ្ជីកំណើតត្រូវបានអនុវត្តដោយក្រសួងមហាផ្ទៃតាមរយៈប្រធានភូមិ និង ការិយាល័យចុះបញ្ជីគ្រួសារប្រចាំស្រុក ឬក្រុង នៅក្នុងរយៈពេល៣០ថ្ងៃក្រោយពេលកើត។[82] នៅប្រទេសម៉ាឡេស៊ី ការចុះបញ្ជីកំណើតត្រូវបានគ្រប់គ្រងដោយច្បាប់ស្ដីពីការចុះបញ្ជីកំណើត និងមរណភាព ឆ្នាំ១៩៥៧ បទប្បញ្ញត្តិស្ដីពីការចុះបញ្ជីកំណើត និងមរណភាព ឆ្នាំ១៩៤៨ (Sabah Cap. ១២៣) និង បទប្បញ្ញត្តិស្ដីពីការចុះ បញ្ជីកំណើត និង មរណភាព ឆ្នាំ ១៩៥១ (Sarawak Cap. ១០) រៀងៗគ្នា។ កំណើតរបស់កុមារគ្រប់រូប នៅប្រទេសម៉ាឡេស៊ីគួរតែត្រូវបានចុះបញ្ជីដោយមន្ត្រីអត្រានុកូលដ្ឋាន។[83] បច្ចុប្បន្ន ប្រទេសមីយ៉ាន់ម៉ា កំពុងតែអនុវត្ត "ការចុះបញ្ជីកំណើតជាសកល"។ ការចុះបញ្ជីកំណើតត្រូវបានអនុវត្តចំពោះ "កុមារគ្រប់រូបដែលមានអាយុចាប់ពី ០ រហូតដល់ ១០ ឆ្នាំ ដែលកើតនៅក្នុងប្រទេសមីយ៉ាន់ម៉ា ដោយមិនគិតអំពីទីកន្លែងដែលពួកគេស្នាក់នៅនោះទេ។ ចំពោះកុមារដែលកើតនៅខាងក្រៅប្រទេសមីយ៉ាន់ម៉ា ជាកូនរបស់ឪពុកម្ដាយដែលជាពលរដ្ឋមីយ៉ាន់ម៉ា កំណើតរបស់ពួកគេនឹងត្រូវចុះបញ្ជីនៅកន្លែងដែលឪពុកម្ដាយរបស់ពួកគេមានឈ្មោះនៅក្នុងបញ្ជីស្នាក់នៅ។ ការចុះបញ្ជីកំណើតនឹងត្រូវធ្វើឡើងក្នុងរយៈពេលមួយឆ្នាំ"។[84]

នៅប្រទេសហ្វីលីពីន វិធានទី១៩ នៃការអនុវត្តវិធាន និង បទប្បញ្ញត្តិនៃច្បាប់លេខ ៣៧៥៣ ដែលមានចែងនៅក្នុងបទបញ្ជាផ្ទៃករដ្ឋបាលលេខ១ សេរីឆ្នាំ១៩៩៣ ចែងថា "កំណើតរបស់កុមារម្នាក់នឹងត្រូវចុះបញ្ជីនៅក្នុងរយៈពេល៣០ថ្ងៃ ចាប់ពីពេលចាប់កំណើតនៅការិយាល័យមន្ត្រីអត្រានុកូលដ្ឋានប្រចាំក្រុងឬរាជធានីដែលកំណើតនោះបានកើតឡើង"។[85]

ស្របតាមច្បាប់ រាល់កំណើត មរណភាព និងទារកដែលស្លាប់នៅក្នុងពោះម្ដាយទាំងអស់ ដែលកើតឡើងនៅក្នុង ប្រទេសសិង្ហបុរី និង នៅក្នុងដែនទឹករបស់ខ្លួន តម្រូវឲ្យចុះបញ្ជីនៅក្នុងរយៈពេល

80 ឥណ្ឌូនេស៊ី៖ ច្បាប់លេខ ២៣ ឆ្នាំ២០០៦ ស្ដីពីរដ្ឋបាលប្រជាជន [ឥណ្ឌូនេស៊ី] ថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០៦ បានធ្វើវិសោធនកម្មដោយច្បាប់របស់សាធារណរដ្ឋឥណ្ឌូនេស៊ី លេខ ២៤ ឆ្នាំ២០១៣ ស្ដីពីវិសោធនកម្មលើច្បាប់លេខ ២៣ ឆ្នាំ២០០៦ ស្ដីពីរដ្ឋបាលប្រជាជន នៃសាធារណរដ្ឋឥណ្ឌូនេស៊ី https://www.refworld.org/docid/54eeefce4.html។

81 ធាតុចូលបន្ថែមពីប្រទេសឥណ្ឌូនេស៊ី។

82 របាយការណ៍របស់ប្រទេសឡាវ។

83 ព័ត៌មានត្រូវបានផ្ដល់ជូនដោយជនបង្គោលនៃប្រទេសម៉ាឡេស៊ី។

84 ព័ត៌មានត្រូវបានផ្ដល់ជូនដោយជនបង្គោលនៃប្រទេសមីយ៉ាន់ម៉ា។

85 របាយការណ៍ប្រចាំប្រទេសហ្វីលីពីន។

១៤ថ្ងៃ ក្រោយពេលដែលព្រឹត្តិការណ៍នោះបានកើតឡើង។ "កំណើតអាចត្រូវបានចុះបញ្ជី នៅមណ្ឌលចុះបញ្ជីកំណើត ដែលមានទីតាំងស្ថិតនៅមន្ទីរសម្ភព ឬ នៅការិយាល័យចុះបញ្ជីកំណើត និង មរណភាពនៅអាជ្ញាធរ អន្តោប្រវេសន៍ និង ការត្រួតពិនិត្យតាមព្រំដែន។ លិខិតបញ្ជាក់មួយច្បាប់អាចត្រូវបានចេញ ជូនអ្នកដែលត្រូវបានចុះបញ្ជីទាំងនោះ"។[86] នៅប្រទេសថៃដូចបានលើកឡើងរួចហើយតាមច្បាប់កំណើតទាំងអស់នឹងត្រូវចុះបញ្ជី។[87] នៅ **ប្រទេសវៀតណាម** ច្បាប់ស្តីពីកុមារ (ច្បាប់លេខ ១០២/២០១៦/QH១៣) ទទួលស្គាល់ថាកុមារមានសិទ្ធិទទួលបានការចុះ បញ្ជីកំណើត និង ការចុះបញ្ជីមរណភាព ដើម្បីមាននាមត្រកូល និងឈ្មោះមួយ ទទួលបានភាពជាពលរដ្ឋ និង មានអត្តសញ្ញាណកម្មឪពុកម្តាយ សញ្ជាតិ និង ភេទរបស់គាត់ដោយអនុលោមតាមច្បាប់។[88] ច្បាប់ស្តីពីការធ្វើអត្តសញ្ញាណកម្មពលរដ្ឋ (ច្បាប់លេខ ៥៩/២០១៤/QH១៣) ផ្តល់ជូនពលរដ្ឋ (វៀតណាម) នូវសំបុត្រកំណើត និង ឯកសារតាមផ្លូវច្បាប់ដទៃទៀត ដែលរួមបញ្ចូលទាំងអត្តសញ្ញាណប័ណ្ណផងដែរ ដែលនឹងគិតថ្លៃសេវាចំនួន ៨.០០០ ដុងវៀតណាម។ ប៉ុន្តែ ថ្លៃសេវាអាចត្រូវបានលើកលែង សម្រាប់ជនដែលបានចុះបញ្ជីមុនកាលកំណត់ សម្រាប់ជនពិការ និងសមាជិកគ្រួសារដែលមានភក្តីភាពចំពោះជាតិ ឬ គ្រួសារក្រីក្រ។ ការលើកលែងថ្លៃសេវាសម្រាប់ការចុះបញ្ជីកំណើតមុនពេលកំណើត នឹងត្រូវសម្រេចតាមករណីដោយសេចក្តីសម្រេចរបស់គណៈកម្មាធិការខេត្ត។[89]

ជាទូទៅ ការចុះបញ្ជីកំណើត គឺចាំបាច់នៅគ្រប់ AMS ទាំងអស់ និង លើកលែងចំពោះប្រទេសហ្វីលីពីន និងប្រទេសវៀតណាម ការចុះបញ្ជីកំណើតត្រូវបានផ្តល់ជូនដោយឥតគិតថ្លៃ។ ទោះបីជាយ៉ាងណាក៏ដោយ មានការខិតខំប្រឹងប្រែងជួយសម្រួល និង លើកទឹកចិត្តចំពោះការចុះបញ្ជីកំណើត តាមរយៈការលើកលែងថ្លៃសេវា ជាពិសេសសម្រាប់ការចុះបញ្ជីមុនកាលកំណត់។ ថ្លៃសេវាលើការចុះបញ្ជីយឺតពេលត្រូវបានអនុវត្តនៅក្នុងប្រទេសមួយចំនួន។

### ខ) កុមារបាត់ខ្លួន

**AMS ជាច្រើន តម្រូវឲ្យមាននីតិវិធីខុសៗគ្នា/ពិសេសៗ ចំពោះការចុះបញ្ជីកំណើតរបស់កុមារដែលត្រូវបានបោះបង់ចោល ឬកុមារបាត់ខ្លួន។** តាមធម្មតា តម្រូវឲ្យមានលិខិត ឬ លិខិតបញ្ជាក់មួយច្បាប់ពីប៉ុស្តិ៍នគរបាលនៅក្នុងមូលដ្ឋាន និង/ឬ នាយកដ្ឋាន/ក្រសួងសង្គមកិច្ចរបស់ប្រទេសឬ ទីភ្នាក់ងារដែលពាក់ព័ន្ធ ដែលទទួលខុសត្រូវចំពោះសុខមាលភាពរបស់កុមារ។ នៅ ប្រទេសប្រ៊ុយណេដារូសាឡឹម ចាំបាច់ ត្រូវមានលិខិតផ្លូវការពីនាយកដ្ឋានអភិវឌ្ឍសហគមន៍ ដើម្បីអនុញ្ញាតឲ្យចុះបញ្ជីកុមារម្នាក់ដោយនាយកដ្ឋានអន្តោប្រវេសន៍ និង ការចុះបញ្ជីជាតិបាន។[90] នៅប្រទេសកម្ពុជា ប្រសិនបើកុមារម្នាក់ត្រូវបានរកឃើញថាត្រូវបានគេបោះបង់ចោល គាត់គួរ





86 របាយការណ៍ប្រចាំប្រទេសសិង្ហបុរី។ ការកែសម្រួលត្រូវបានធ្វើឡើងដោយជនបង្គោលនៃប្រទេសសិង្ហបុរី។

87 របាយការណ៍ប្រចាំប្រទេសថៃ។

88 មាត្រា ១៣ ច្បាប់ស្តីពីកុមារ ឆ្នាំ២០១៦ សិទ្ធិទទួលបានការចុះបញ្ជីកំណើត និង ភាពជាពលរដ្ឋ របាយការណ៍របស់ប្រទេសវៀតណាម។

89 របាយការណ៍របស់ប្រទេសវៀតណាម។

90 របាយការណ៍ប្រចាំប្រទេសប្រ៊ុយណេដារូសាឡឹម សេចក្តីបន្ថែម ២។

តែត្រូវបានបញ្ជូនទៅ កាន់ការិយាល័យចុះបញ្ជីអត្រានុកូលដ្ឋានឃុំ/សង្កាត់ ដែលនឹងចុះបញ្ជីកំណើត ដោយផ្អែកលើព័ត៌មានដែលទទួលបាន។[91] នៅប្រទេសឥណ្ឌូនេស៊ី បទប្បញ្ញត្តិរបស់ប្រធានាធិបតី លេខ ៩៦/២០១៨ ចែងថា ការចុះបញ្ជី កំណើតសម្រាប់កុមារបាត់ខ្លួន តម្រូវឲ្យមានលិខិតមួយច្បាប់ពីមន្ត្រីនគរបាល ឬអ្នកដាក់ពាក្យស្នើសុំ ដែលបញ្ជាក់អំពីការពិតនៃកំណើតរបស់កុមារបាត់ខ្លួននោះ (ទីកន្លែង និង កាលបរិច្ឆេទ) ដោយ មានសាក្សីចំនួនពីរនាក់ (និងឈ្មោះ និង អត្តសញ្ញាណរបស់ពួកគេ)។[92] នៅប្រទេសឡាវ អ្នកណាម្នាក់ដែលរកឃើញទារកទើបនឹងកើត ដែលត្រូវបានគេបោះបង់ចោល ត្រូវតែផ្តល់ជំនួយ និង ជូនដំណឹងដល់មេភូមិ ឬ មន្ត្រីនគរបាលអំពីទីកន្លែងដែលរកឃើញកុមាររូបនោះ។ មេភូមិត្រូវចេញសំបុត្រកំណើតជូនកុមាររូបនោះ ក្នុងរយៈពេល ៥ ថ្ងៃធ្វើការ បន្ទាប់ពីមានការជូនដំណឹង។[93]

នៅ ប្រទេសម៉ាឡេស៊ី ប្រសិនបើកុមារដែលនៅមានជីវិតម្នាក់ ត្រូវបានរកឃើញ និង ពុំមានព័ត៌មានអំពីទីកន្លែងកំណើតទេនោះ លក្ខខណ្ឌដែលមានចែងនៅក្នុងមាត្រាវង ៧(១) នៃច្បាប់ស្តីពីកំណើត និង ការចុះបញ្ជី ឆ្នាំ១៩៥៧ តម្រូវឲ្យមាន ការចុះបញ្ជីកំណើតដោយមន្ត្រីអត្រានុកូលដ្ឋាននៃតំបន់ចុះបញ្ជីដែលកុមារនោះត្រូវបានរកឃើញ។ ប្រសិនបើមានទារកទើបនឹងកើតដែលនៅមានជីវិតម្នាក់ត្រូវបានរកឃើញនោះ មាត្រា ៩ នៃ ច្បាប់ដដែលនោះដាក់ភារកិច្ចលើជនដែលរកឃើញកុមារនោះ និងអ្នកណាម្នាក់ដែលប្រហែលជាត្រូវទទួលបន្ទុកលើកុមារនោះ នៅក្នុងការផ្តល់ព័ត៌មានពាក់ព័ន្ធនឹងការរកឃើញកុមារនោះទៅកាន់មន្ត្រីអត្រានុកូលដ្ឋាននៅក្នុងរយៈពេល ១៤ ថ្ងៃ ចាប់ពីកាលបរិច្ឆេទដែលកុមារនោះត្រូវបានរកឃើញ។[94] នៅប្រទេសមីយ៉ាន់ម៉ា អ្នកណាម្នាក់ដែលរកឃើញកុមារដែលត្រូវគេបោះបង់ចោល (ឬកុមារបាត់ខ្លួន) នឹងរាយការណ៍ទៅកាន់អាជ្ញាធរភូមិ/ផ្នែកណាមួយដែលនឹងបញ្ជូនកុមារនោះទៅកាន់មជ្ឈមណ្ឌលថែទាំកុមារ ឬផ្ទះសម្រាប់កុមារកំព្រាដែលនៅក្បែរនោះបំផុត ដែលបន្ទាប់មកនឹងដាក់ពាក្យស្នើសុំចុះបញ្ជីកំណើតទៅកាន់អាជ្ញាធរពាក់ព័ន្ធ។[95]

នៅក្នុងករណី ប្រទេសហ្វីលីពីន ការចុះបញ្ជីកំណើតសម្រាប់កុមារដែលត្រូវគេបោះបង់ចោល ឬ កុមារបាត់ខ្លួននឹងត្រូវធ្វើឡើងដោយបុគ្គលដែលរកឃើញកុមារនោះ ឬ ស្ថាប័នសប្បុរសធម៌ណាមួយនៅក្នុងរយៈពេល ៣០ថ្ងៃ ចាប់ពីកាលបរិច្ឆេទដែលកុមារនោះត្រូវបានគេរកឃើញ។ របាយការណ៍ណាមួយដែលត្រូវបានធ្វើឡើងក្រោយរយៈពេល ៣០ថ្ងៃ ត្រូវបានចាត់ទុកថាយឺតយ៉ាវ និង តម្រូវឲ្យមានការពន្យល់។ លក្ខខណ្ឌតម្រូវសម្រាប់ការចុះបញ្ជីកុមារបាត់ខ្លួន រួមមានលិខិតថ្លែងសច្ចាពីអ្នករកឃើញ ដែលចែងអំពីអង្គហេតុ និង ស្ថានភាពរបស់កុមារ និង ការបញ្ជាក់ដោយមេដឹកនាំ barangay ឬ អាជ្ញាធរនគរបាល នៅលើរបាយការណ៍ដែលធ្វើឡើងដោយអ្នករកឃើញ។[96] មាននីតិវិធីពិសេសមួយ សម្រាប់ការចុះបញ្ជីកំណើតរបស់កុមារ ដែលត្រូវគេបោះបង់ចោល/កុមារបាត់ខ្លួន នៅប្រទេសសិង្ហបុរី។ តម្រូវឲ្យមានរបាយការណ៍វេជ្ជសាស្ត្រ ព្រមទាំងរបាយការណ៍ពីនគរបាល ដែលបញ្ជាក់ថា មិនអាចបញ្ជាក់អំពីអត្តសញ្ញាណឪពុកម្តាយរបស់កុមារបាននោះទេ ដើម្បីឲ្យក្រសួងអភិវឌ្ឍសង្គម និង គ្រួសារ (MSF) ធ្វើការចុះបញ្ជីកុមាររូបនោះ។[97]

---

91 របាយការណ៍ប្រចាំប្រទេសកម្ពុជា។
92 របាយការណ៍ប្រចាំប្រទេសឥណ្ឌូនេស៊ី រួមជាមួយការកែសម្រួលដែលត្រូវបានស្នើឡើងនៅថ្ងៃទី២៩ ខែមីនា ឆ្នាំ២០១៩។
93 របាយការណ៍ប្រចាំប្រទេសប្រទេសឡាវ។
94 ការកែសម្រួលរបាយការណ៍ប្រចាំប្រទេសម៉ាឡេស៊ី។
95 របាយការណ៍ប្រចាំប្រទេសមីយ៉ាន់ម៉ា និង ព័ត៌មានដែលបានធ្វើបច្ចុប្បន្នភាពដោយជនបង្គោលនៃប្រទេសមីយ៉ាន់ម៉ា។
96 របាយការណ៍របស់ប្រទេសហ្វីលីពីន។
97 របាយការណ៍របស់ប្រទេសសិង្ហបុរី។

**ប្រទេសថៃ**បានអនុវត្តដំណើរការប្រហាក់ប្រហែលគ្នាមួយ។ ច្បាប់ស្តីពីការចុះអត្រានុកូលដ្ឋាន ដាក់កាតព្វកិច្ចលើអ្នកណាម្នាក់ដែលជួបប្រទះនឹងកុមារបាត់ខ្លួន ឬ កុមារដែលត្រូវគេបោះបង់ចោល ឲ្យនាំកុមារនោះទៅកាន់ និង ជូនដំណឹងដល់មន្ត្រីរដ្ឋបាល មន្ត្រីនគរបាល ឬ ការិយាល័យក្រសួងអភិវឌ្ឍសង្គម និងសន្តិសុខមនុស្ស (MSDHS) នៅក្នុងតំបន់ដែលកុមារនោះត្រូវបានរកឃើញ។ បន្ទាប់ពីទទួលបានកុមារនោះហើយ កំណត់ត្រាស្តីពីការទទួលយកមួយច្បាប់នឹងត្រូវធ្វើឡើងដោយមន្ត្រីដែលពាក់ព័ន្ធ។ ក្នុងករណីដែលមន្ត្រីរដ្ឋបាល ឬ មន្ត្រីនគរបាល ទទួលបានកុមារនោះ ពួកគេត្រូវនាំកុមារនោះទៅកាន់ និង ប្រគល់របាយការណ៍ទទួលយក ជូនមន្ត្រីណាម្នាក់ របស់ MSDHS ដែលទទួលបន្ទុកលើតំបន់នោះ ដែលមន្ត្រីរូបនោះនឹងជូនដំណឹងទៅកាន់មន្ត្រីអត្រានុកូលដ្ឋានកំណើត ហើយ មន្ត្រីអត្រានុកូលដ្ឋាននឹងចេញសំបុត្រកំណើតមួយច្បាប់។[98] **ប្រទេសវៀតណាម** មានខចែងដាច់ដោយឡែកមួយនៃការចុះបញ្ជីកំណើត សម្រាប់កុមារដែលត្រូវគេបោះបង់ចោល/កុមារបាត់ខ្លួន ដែលរួមមាន មាត្រា ១៦ នៃច្បាប់ស្តីពីអត្រានុកូលដ្ឋាន និង មាត្រា ១៤ នៃក្រឹត្យលេខ ១២៣/២០១៥/ NĐ-CP របស់រដ្ឋាភិបាល ចុះថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០១៥ ដែលណែនាំអំពីការអនុវត្តមាត្រាមួយចំនួន និង វិធីសាស្រ្តអនុវត្តច្បាប់ស្តីពីអត្រានុកូលដ្ឋាន ឆ្នាំ២០១៤។[99] មាត្រាដែលបានពោល ចែងថា៖

> “ចំពោះការចុះបញ្ជីកំណើតជូនកុមារដែលត្រូវគេបោះបង់ចោល ត្រូវតែមានកំណត់ត្រាជាលាយលក្ខណ៍អក្សរ ដែលបញ្ជាក់អំពីការបោះបង់ចោលកុមារនោះ ដែលត្រូវបានធ្វើឡើងដោយទីភ្នាក់ងារមានសមត្ថកិច្ចណាមួយ... អ្នកដែលរកឃើញកុមារដែលត្រូវគេបោះបង់ចោល ត្រូវការពារកុមារ និង ជូនដំណឹងភ្លាម។ ទៅកាន់គណៈកម្មាធិការឃុំ ឬ ទីភ្នាក់ងារសន្តិសុខសាធារណៈនៃទីកន្លែងដែលកុមារត្រូវគេបោះបង់ចោល។ ចំពោះកុមារដែលត្រូវគេបោះបង់ចោលនៅគ្រឹះស្ថានសុខាភិបាល ប្រធានគ្រឹះស្ថានត្រូវធ្វើការជូនដំណឹងបែបនោះ។ បុគ្គល ឬ អង្គការដែលផ្តល់ការថែទាំបណ្តោះអាសន្នដល់កុមារនោះ ត្រូវចុះបញ្ជីកំណើតជូនកុមារនោះ។ នីតិវិធីចុះបញ្ជីកំណើតត្រូវអនុវត្តស្របតាមខចែងទី២ មាត្រា ១៦ នៃច្បាប់ស្តីពីអត្រានុកូលដ្ឋាន”។[100]

98 របាយការណ៍របស់ប្រទេសថៃ។

99 របាយការណ៍របស់ប្រទេសវៀតណាម។

100 Ibid.

### គ) ជនដែលមិនមែនជាពលរដ្ឋ

AMS ភាគច្រើន មិនតម្រូវឲ្យមាននីតិវិធីខុសៗគ្នា/ពិសេសៗ ដើម្បីចុះបញ្ជីកំណើតជនដែលមិនមែនជាពលរដ្ឋនោះទេ ប៉ុន្តែត្រូវតែផ្តល់ឯកសារបន្ថែម។ នៅប្រទេសប្រ៊ុយណេដារូសាឡឹម ជនដែលមិនមែនជាពលរដ្ឋ នឹងត្រូវតម្រូវឲ្យផ្តល់លិខិតឆ្លងដែនរបស់ពួកគេ បន្ថែមពីលើលក្ខខណ្ឌតម្រូវនៃឯកសារបទដ្ឋាន នៅពេលដាក់ពាក្យស្នើសុំចុះបញ្ជីកំណើត ប៉ុន្តែការចុះបញ្ជីនៅតែឥតគិតថ្លៃនោះទេ។[101] នៅប្រទេសកម្ពុជា កូនរបស់ជនបរទេស និង ជនទេសន្តរ-ប្រវេសន៍ ដែលស្នាក់នៅដោយស្របច្បាប់នៅក្នុងប្រទេសកម្ពុជា អាចត្រូវបានចុះបញ្ជីដោយឪពុកម្តាយរបស់ពួកគេនៅការិយាល័យឃុំ ឬ សង្កាត់ ឬ នៅស្ថានកុងស៊ុល/ស្ថានទូតរបស់ពួកគេរៀងៗខ្លួន តាមរយៈការផ្តល់លិខិតឆ្លងដែន និង ទិដ្ឋាការដែលមានសុពលភាពរបស់ឪពុកម្តាយ ឬ ឯកសារអនុញ្ញាតដល់ការស្នាក់នៅរបស់ពួក គេនៅក្នុងប្រទេសកម្ពុជា ព្រមទាំងសំបុត្រអាពាហ៍ពិពាហ៍ (ឬ សំណៅចម្លងមួយច្បាប់) ផងដែរ។[102] នៅប្រទេសឥណ្ឌូនេស៊ី ដូចបានលើកឡើងនៅខាងលើ "ចាប់តាំងពីខែតុលា ឆ្នាំ២០១៨មក បទប្បញ្ញត្តិរបស់ប្រធានាធិបតីលេខ ២៥/២០១៨ ត្រូវបានជំនួសដោយបទប្បញ្ញត្តិរបស់ប្រធានាធិបតី លេខ ៩៦/២០១៨។ មាត្រា ៣២ នៃបទប្បញ្ញត្តិរបស់ប្រធានាធិបតី ឆ្នាំ២០១៨ បានបញ្ញត្តិអំពីសិទ្ធិរបស់ជនបរទេស (ទិដ្ឋាការអចិន្ត្រៃយ៍ / មានកម្រិត/បណ្តោះអាសន្ន) ក្នុងការរាយការណ៍ និងចុះបញ្ជីកំណើត។ មាត្រា ៣៣ នៃបទប្បញ្ញត្តិរបស់ប្រធានាធិបតីដែលបានពោល បានបញ្ជាក់អំពីឯកសារដែល ត្រូវបានតម្រូវសម្រាប់ការចុះបញ្ជីកំណើតរបស់កូនជនបរទេស ដែលរួមមានលិខិតឆ្លងដែន លិខិតជូនដំណឹងអំពីកំណើត និង អត្តសញ្ញាណប័ណ្ណ (KTP-e1/អត្តសញ្ញាណប័ណ្ណជាតិ សម្រាប់ជនបរទេស ដែលកាន់ប័ណ្ណទិដ្ឋាការអចិន្ត្រៃយ៍ ឬ ប័ណ្ណទិដ្ឋាការដែលមានកម្រិត / បណ្តោះអាសន្ន អាស្រ័យតាម ប្រភេទទិដ្ឋាការរបស់ពួកគេ" ។[103] ប្រទេសឡាវ ពុំមាននីតិវិធីខុសគ្នា សម្រាប់ការចុះបញ្ជីជនដែលមិនមែនជាពលរដ្ឋនោះទេ។ ច្បាប់ស្តីពីការចុះបញ្ជីគ្រួសារ ត្រូវបានអនុវត្តចំពោះកុមារគ្រប់រូបដែលកើតនៅក្នុងដែនដីឡាវ (មាត្រា ១៧ ត្រូវបានកែសម្រួលឡើងវិញ)។[104] ប្រទេសម៉ាឡេស៊ី មិនអនុវត្តនីតិវិធីខុសគ្នាចំពោះ ការចុះបញ្ជីកំណើតកូនរបស់ជនដែលមិនមែនជាពលរដ្ឋនោះទេ។ ប៉ុន្តែឯកសារភស្តុតាងដែលត្រូវបានតម្រូវ អាចមានភាពខុសគ្នា ដោយសារស្ថានភាពនៃសញ្ជាតិខុសៗគ្នារបស់ជនដែលមិនមែនជាពលរដ្ឋ។[105] ពុំមាននីតិវិធីពិសេសសម្រាប់ការចុះ បញ្ជីកំណើតជនដែលមិនមែនជាពលរដ្ឋនៅក្នុងប្រទេសហ្វីលីពីនទេ។ ប៉ុន្តែជនដែលមិនមែនជាពលរដ្ឋត្រូវបានតម្រូវឲ្យរាយការណ៍ទៅកាន់ស្ថានកុងស៊ុលរបស់ពួកគេ។[106] ដូចគ្នានេះដែរ នៅប្រទេសសិង្ហបុរី ពុំមាននីតិវិធីពិសេសសម្រាប់ជនដែលមិនមែនជាពលរដ្ឋនោះទេ។ ប៉ុន្តែ ជនបរទេសត្រូវតែផ្តល់ឯកសារភស្តុតាងបន្ថែម ដូចជាលិខិតឆ្លងដែន លិខិតអនុញ្ញាតឲ្យចូល ឬ ឆ្លងកាត់ និង ប័ណ្ណចុះចត/ចាកចេញ របស់ឪពុកម្តាយរបស់កុមារ។[107]

នៅប្រទេសថៃ នីតិវិធីជូនដំណឹងអំពីកំណើតសម្រាប់ជនដែលមិនមែនជាពលរដ្ឋថៃ មានលក្ខណៈដូចគ្នានឹងនីតិវិធី សម្រាប់កូនរបស់ពលរដ្ឋថៃដែរ។ ចំណុចខុសគ្នាតែមួយគត់ រវាងអ្នកទាំងពីរ គឺទម្រង់នៃសំបុត្រកំណើត លេខអត្តសញ្ញាណកម្ម និង សៀវភៅបញ្ជីផ្ទះ។ ឧទាហរណ៍ កូនរបស់ជន

101 របាយការណ៍ប្រចាំប្រទេសប្រ៊ុយណេដារូសាឡឹម។

102 របាយការណ៍ប្រចាំប្រទេសកម្ពុជា។

103 ធាតុចូលត្រូវបានផ្តល់ជូនដោយជនបង្គោលនៃប្រទេសឥណ្ឌូនេស៊ី នៅថ្ងៃទី២៩ ខែមីនា ឆ្នាំ២០១៩។

104 របាយការណ៍ប្រចាំប្រទេសប្រទេសឡាវ។

105 របាយការណ៍ប្រចាំប្រទេសម៉ាឡេស៊ី (រួមជាមួយមតិយោបល់របស់ UNHCR)។

106 របាយការណ៍ប្រចាំប្រទេសហ្វីលីពីន។

107 ការរួមចំណែកដោយជនបង្គោលនៃប្រទេសសិង្ហបុរី។

ទេសន្តរប្រវេសន៍ស្របច្បាប់ ទទួលបានសំបុត្រកំណើតមួយច្បាប់ (ថ.រ.៣) ដែលត្រូវបានកំណត់ឲ្យមានលេខអត្តសញ្ញាណកម្ម ដែលចាប់ផ្តើមដោយលេខ ៧ ហើយឈ្មោះកុមារត្រូវបានបញ្ចូលទៅក្នុងសៀវភៅបញ្ជីផ្ទះ របស់និវាសនជនបណ្តោះអាសន្ន (ថ.រ.១៣)។ កូនរបស់ពលករចំណាកស្រុកពីប្រទេសមីយ៉ាន់ម៉ា ឡាវ ឬ កម្ពុជា ទទួលបានសំបុត្រកំណើតមួយច្បាប់ (ថ.រ.៣) ដែលត្រូវបានកំណត់ឲ្យមានលេខអត្តសញ្ញាណកម្ម ដែលចាប់ផ្តើមដោយលេខ ០០ ហើយឈ្មោះកុមារត្រូវបានបញ្ចូលទៅក្នុងការចុះបញ្ជីប្រវត្តិរូប (ថ.រ.៣៨)។[108]

ប្រទេសវៀតណាម ហាក់បីដូចជាប្រទេសតែមួយគត់ ដែលច្បាប់បានបង្កើតនីតិវិធីពិសេសសម្រាប់ការចុះបញ្ជីកំណើតរបស់ជនដែលមិនមែនជាពលរដ្ឋនៅក្នុងប្រទេស។ នៅខណៈពេលដែលការចុះបញ្ជីកំណើតសម្រាប់កូនរបស់ពលរដ្ឋខ្លួន ត្រូវបានធ្វើឡើងនៅគណៈកម្មាធិការឃុំនោះ ការចុះបញ្ជីកំណើត សម្រាប់ "(១) កុមារដែលកើតនៅក្នុងប្រទេសវៀតណាម និង ក/ មានឪពុក/ម្តាយជាពលរដ្ឋវៀតណាម និង អ្នកដទៃទៀតជាជនបរទេស ឬ ជនគ្មានសញ្ជាតិ, ខ/ មានឪពុក/ម្តាយជាពលរដ្ឋវៀតណាមដែលស្នាក់នៅក្នុងប្រទេស និង អ្នកដទៃទៀតជាពលរដ្ឋវៀតណាម ដែលស្នាក់នៅក្រៅប្រទេស, គ/ មានទាំងឪពុក និង ម្តាយជាពលរដ្ឋវៀតណាម ដែលស្នាក់នៅក្រៅប្រទេស, ឃ/ មានទាំងឪពុក និង ម្តាយជាជនបរទេស ឬ ជនគ្មានសញ្ជាតិ ឬ (២) កុមារកើតនៅក្រៅប្រទេស ដែលមិនទាន់បានចុះបញ្ជីកំណើតនៅក្រៅប្រទេស និងត្រូវបាននាំមកស្នាក់នៅក្នុងប្រទេស វៀតណាម និង ក/ មានទាំងឪពុក និង ម្តាយជាពលរដ្ឋវៀតណាម, ខ/ មានឪពុក/ម្តាយជាពលរដ្ឋ វៀតណាម" នឹងត្រូវអនុវត្តនៅគណៈកម្មាធិការថ្នាក់ស្រុក (មាត្រា ៣៥ នៃច្បាប់ស្តីពីអត្រានុកូលដ្ឋាន ឆ្នាំ២០១៤)។[109]

វាមានភាពចាំបាច់ នៅក្នុងការកត់សម្គាល់ថា ភាពស្របច្បាប់នៃឋានៈ និង ការស្នាក់នៅរបស់ជនដែលមិនមែនជាពលរដ្ឋនៅ AMS ទាំងអស់ មានសារសំខាន់ចំពោះការចុះបញ្ជីកំណើត។ នៅក្នុងប្រទេសភាគច្រើន ឪពុកម្តាយដែលមិនមែនជាពលរដ្ឋអាចជ្រើសរើសចុះបញ្ជីកូនរបស់ពួកគេ នៅស្ថានកុងស៊ុល ឬ ស្ថានទូតរបស់ពួកគេ។

## ឃ) ជនគ្មានសញ្ជាតិ

AMS ភាគច្រើន មិនមែនទាំងអស់នោះទេ តម្រូវឲ្យមានការចុះបញ្ជីកំណើតទាំងអស់ នៅក្នុងដែនដី ដូច្នេះគេបានរំពឹងទុកថា កុមារដែលគ្មានសញ្ជាតិក៏ត្រូវបានចុះបញ្ជីនៅពេលកើតដែរ។ ទោះបីជាយ៉ាងណាក៏ដោយ ពុំមានទិន្នន័យដែលទាក់ទងនឹងចំណុចនេះ នៅក្នុងរបាយការណ៍របស់ប្រទេសភាគច្រើន។ នៅប្រទេសប្រ៊ុយណេដារូសាឡឹម ជំពូក ៧៩ នៃច្បាប់ស្តីពីការចុះបញ្ជីកំណើត និង មរណភាព សង្កត់ធ្ងន់លើតម្រូវការឲ្យមានការចុះបញ្ជីរាល់កំណើតទាំងអស់ រួមបញ្ចូលទាំងកំណើតរបស់ជនគ្មានសញ្ជាតិផងដែរ ដែលកើតឡើងនៅក្នុងប្រទេសប្រ៊ុយណេដារូសាឡឹម។[110] ប្រទេសកម្ពុជា មិនបានផ្តល់ព័ត៌មាន អំពីការចុះបញ្ជីអត្រានុកូលដ្ឋាន/ការចុះបញ្ជីកំណើត របស់ជនគ្មានសញ្ជាតិ និង/ឬ ជនដែលមិនបានកំណត់សញ្ជាតិច្បាស់លាស់នោះទេ ដោយផ្តល់យោបល់ថា គ្មានទិន្នន័យនោះទេ។[111] របាយការណ៍ប្រចាំប្រទេសឡាវ មិនបានលើកឡើងអំពីការចុះបញ្ជីអត្រានុកូលដ្ឋានរបស់ជនគ្មានសញ្ជាតិ/ជនដែលមិនបានកំណត់សញ្ជាតិច្បាស់លាសនោះទេ ប៉ុន្តែច្បាប់ស្តីពីសញ្ជាតិឡាវ (មាត្រា ៧) កំណត់និយមន័យជនដែលមិនមែនជាពលរដ្ឋថាជា "បុគ្គលម្នាក់ដែលស្នាក់នៅក្នុងដែនដីរបស់ប្រទេសឡាវ ដែលមិនមែនជាពលរដ្ឋឡាវ និងមិនអាចបញ្ជាក់សញ្ជាតិរបស់គាត់ (របស់នាង) បាន"។[112]

108 របាយការណ៍របស់ប្រទេសថៃ។
109 របាយការណ៍របស់ប្រទេសវៀតណាម។
110 របាយការណ៍របស់ប្រទេសប្រ៊ុយណេដារូសាឡឹម។
111 របាយការណ៍របស់ប្រទេសកម្ពុជា។
112 របាយការណ៍របស់ប្រទេសឡាវ។

ទោះបីជាយ៉ាងណាក៏ដោយ ជនដែលមិន មែនជាពលរដ្ឋទទួលបានសិទ្ធិមូលដ្ឋានមួយចំនួនដែលអាចរួមបញ្ចូលទាំងសិទ្ធិចុះបញ្ជីអត្រានុកូលដ្ឋាន នៅពេលកើតផងដែរ។ នៅ**ប្រទេសម៉ាឡេស៊ី** ឋានៈនៃភាពជាពលរដ្ឋ របស់មនុស្សម្នាក់នឹងត្រូវបានកត់ត្រាទុកជា "ពលរដ្ឋ" ឬ "មិនមែនពលរដ្ឋ" នៅក្នុងការចុះបញ្ជីកំណើត ផ្អែកលើភ័ស្តុតាង ឬ ឯកសារដែលមានសុពលភាព។[113] ជនភៀសខ្លួនអាចមាន ឬ គ្មានសញ្ជាតិ ទោះបីជាបានដឹងអំពីប្រទេសនៃទីលំនៅអចិន្ត្រៃយ៍កាលពីមុនក៏ដោយ។ សហគមន៍ជនភៀសខ្លួន ( Rohingya, Palesti-nians ឬ Bajau Lauts ) នៅប្រទេសម៉ាឡេស៊ី មិនត្រូវបានលើកលែងសម្រាប់ការចុះបញ្ជីកំណើតរបស់ពួកគេនោះទេ ហើយស្ថានភាពនៃភាពជាពលរដ្ឋរបស់ពួកគេនឹងត្រូវបានកត់ត្រាទុកថាមិនមែនជាពលរដ្ឋ។[114] គេបានចង្អុលបង្ហាញថា កូនរបស់ជនភៀសខ្លួន និង អ្នកស្វែងរកសិទ្ធិជ្រកកោន ដែលសញ្ជាតិរបស់ពួកគេត្រូវបានបំផុតតាមច្បាប់ ក៏ត្រូវបានចុះបញ្ជីកំណើតដែរ។ របាយការណ៍ប្រចាំ **ប្រទេសមីយ៉ាន់ម៉ា** មិនបានផ្តល់ព័ត៌មានអំពីការចុះ បញ្ជីអត្រានុកូលដ្ឋាន របស់ជនដែលសញ្ជាតិរបស់ពួកគេមិនបានកំណត់ច្បាស់លាស់ និង/ឬ ជនដែលគ្មានសញ្ជាតិ នោះទេ។ មាត្រា ៦៥ នៃច្បាប់ស្តីពីភាពជាពលរដ្ឋ របស់ប្រទេសមីយ៉ាន់ម៉ា ចែងថា "មនុស្សម្នាក់អាច ដាក់ពាក្យស្នើ សុំទៅកាន់អង្គភាពកណ្តាល ប្រសិន បើចាំបាច់ ដើម្បីស្នើសុំសចេក្តីសម្រេចលើភាពជាពលរដ្ឋរបស់គាត់"[115]។ យោងតាមរបាយការណ៍នេះ ពុំមានជនគ្មានសញ្ជាតិនៅក្នុងប្រទេសមីយ៉ាន់ម៉ានោះទេ ហើយជនដែលសញ្ជាតិរបស់ពួកគេត្រូវបានបំផ្លាញ ត្រូវកាន់ប័ណ្ណដែលសមស្របមួយយោងតាមមាត្រា ៦៥ នៃច្បាប់នេះ។[116]

ក្នុងនាមជារដ្ឋភាគីនៃអនុសញ្ញា ឆ្នាំ១៩៥៤ ដែលទាក់ទងនឹងឋានៈរបស់ជនគ្មានសញ្ជាតិ ច្បាប់នៃ**ប្រទេសហ្វីលីពីន** ហាក់បីដូចជាបើកចំហរចំពោះការគ្របដណ្តប់ លើការចុះបញ្ជីកំណើតជនគ្មានសញ្ជាតិ។ របាយការណ៍ប្រចាំប្រទេសបានសម្គាល់ឃើញក្រុមងាយរងគ្រោះខុសៗគ្នា ដែលប្រឈមមុខនឹងហានិភ័យនៃកង្វះខាតការចុះបញ្ជីកំណើត ឬ ការចុះបញ្ជីអត្រានុកូលដ្ឋាន ដែលរួមមានជនជាតិដើមភាគតិច Sama Dilaut ឬ Sama Badjao និង កុមារដែលមានដើមកំណើតហ្វីលីពីន និង ស្ថិតនៅក្នុងស្ថានភាពទេសន្តរប្រវេសន៍នៅសាបា។ ជនទាំងនេះ តាមធម្មតា ពុំមានឯកសារអត្តសញ្ញាណនោះទេ ដែលធ្វើឲ្យពួកគេគ្មានសញ្ជាតិ។[117] ប្រទេសហ្វីលីពីនទទួលស្គាល់អំពីគម្លាត និង បញ្ហាប្រឈមនានាបាន និងកំពុងដោះស្រាយបញ្ហាទាំងនោះ ដើម្បីធានាថាជនទាំងនោះ ទទួលបានការចុះបញ្ជីកំណើត និង ការចុះបញ្ជីអត្រានុកូលដ្ឋានដទៃទៀត។[118] យោងតាមរបាយការណ៍ប្រចាំ **ប្រទេសសិង្ហបុរី** ពុំមានហានិភ័យនៃកង្វះខាតការចុះបញ្ជីកំណើត ឬ ការចុះបញ្ជីអត្រានុកូលដ្ឋានសម្រាប់បុគ្គលណាម្នាក់ ឬ សហគមន៍ណាមួយនៅក្នុងប្រទេសនោះទេ ដែលមានន័យថា ផ្អែកជនគ្មានសញ្ជាតិ នៅក្នុងរបាយ-ការណ៍ប្រចាំប្រទេសអូស្ត្រាលី ប្រហែលជាមិនពាក់ព័ន្ធនឹងករណីនេះនោះទេ។[119] គេបានសន្មតថាដោយសារតែរាល់កំណើតទាំងអស់ ត្រូវបានចុះបញ្ជីរួចរាល់ហើយ នោះចំណុចនេះនឹងគ្របដណ្តប់លើកុមារគ្មានសញ្ជាតិផងដែរប្រសិនបើមាន។ របាយការណ៍ប្រចាំ**ប្រទេសថៃ**ចែងថា រដ្ឋាភិបាលថៃបាននិងកំពុងអនុវត្តវិធីសាស្រ្ត និង វិធានការគោលនយោបាយដើម្បីដោះស្រាយបញ្ហានានា ដែលពាក់ព័ន្ធនឹងការចុះបញ្ជីអត្រានុកូលដ្ឋាន និងភាពគ្មានសញ្ជាតិរួមបញ្ចូលទាំងតាមរយៈការធ្វើវិសោធនកម្ម ដោយនាយកដ្ឋានរដ្ឋបាលខេត្តនៃក្រសួងមហាផ្ទៃលើច្បាប់ស្តីពីការចុះបញ្ជីអត្រានុកូលដ្ឋាន ឆ្នាំ១៩៩១ (ពស. ២៥៣៤) (កែសម្រួលលើកទី២) ឆ្នាំ២០០៨ (ពស. ២៥៥១) ដែលចែងថា មន្រ្តីអត្រានុកូលដ្ឋានត្រូវដំណើរការការចុះបញ្ជីអត្រានុកូលដ្ឋាន សម្រាប់ជនគ្មានសញ្ជាតិនៅក្នុងលក្ខណៈដូចគ្នានឹងករណីរបស់ជនជាតិថៃដែរ។[120]

113 ការកែសម្រួលត្រូវបានស្នើឡើងដោយជនបង្គោលនៃប្រទេសម៉ាឡេស៊ី។
114 របាយការណ៍របស់ប្រទេសម៉ាឡេស៊ី។
115 របាយការណ៍របស់ប្រទេសមីយ៉ាន់ម៉ា។
116 ព័ត៌មានត្រូវបានធ្វើបច្ចុប្បន្នភាពដោយជនបង្គោលនៃប្រទេសមីយ៉ាន់ម៉ា។
117 របាយការណ៍របស់ប្រទេសហ្វីលីពីន។
118 Ibid.
119 របាយការណ៍របស់ប្រទេសសិង្ហបុរី។
120 របាយការណ៍របស់ប្រទេសថៃ។

ច្បាប់ដែលត្រូវបានកែសម្រួលនោះ បានទទួលស្គាល់ និង តម្រូវឲ្យមាន ការចុះបញ្ជីកំណើត របស់ជនគ្រប់រូបដែលកើតនៅក្នុងព្រះរាជាណាចក្រថៃ ដោយមិនគិតអំពីប្រភេទឋានៈ តាមផ្លូវច្បាប់របស់ឪពុកម្ដាយនោះ ទេ ឬ ថាតើពួកគេមានឯកសារអន្ដោប្រវេសន៍ត្រឹមត្រូវ ឬ អត់នោះទេ។ វិសោធនកម្មនោះចែងអំពីការបង្កើតប្រវត្តិរូបនៅក្នុងមូលដ្ឋានទិន្នន័យ សម្រាប់ជនគ្មានសញ្ជាតិ យោងតាមសេចក្ដីសម្រេចរបស់គណៈរដ្ឋមន្ត្រីព្រមទាំងច្បាប់ស្ដីពីការចុះបញ្ជីអន្ដោប្រវេសន៍ (មា ត្រា ៣៨ កថា ខណ្ឌទី២) និង បន្ទាប់មកចេញអត្តសញ្ញាណប័ណ្ណ សម្រាប់ជនដែលគ្មានសញ្ជាតិថៃ និង ជនដែលគ្មានឋានៈនៃការចុះបញ្ជីអន្ដោប្រវេសន៍។[121] នៅ**ប្រទេសវៀតណាម** ដំណើរការមួយដែលប្រហាក់ប្រហែលគ្នា នឹងការចុះបញ្ជីសម្រាប់ជនដែលមិនមែនជាពលរដ្ឋវៀតណាម ត្រូវបានអនុវត្តចំពោះជនគ្មានសញ្ជាតិ។[122]

របាយការណ៍ប្រចាំប្រទេសមួយចំនួន ផ្ដល់ជូននូវស្ថិតិកំណើត ដែលត្រូវបានចុះបញ្ជីរួចហើយ សម្រាប់ទាំងពលរដ្ឋ និង ជនដែលមិនមែនជាពលរដ្ឋ ដូចជា ប្រទេសប្រ៊ុយណេដារូសាឡឹម ប្រទេសកម្ពុជា ឡាវ និង ថៃ។[123] **ប្រទេសឥណ្ឌូនេស៊ី**មិនបានផ្ដល់ស្ថិតិនានា នៅក្នុងរបាយការណ៍ប្រចាំប្រទេសដែលត្រូវបានដាក់ជូននោះទេ ប៉ុន្តែបានបន្ថែមនៅក្នុងការកែសម្រួលដែលត្រូវបានស្នើឡើងនៅថ្ងៃទី ២៩ ខែមីនា ឆ្នាំ២០១៩ ថា "ប្រទេសឥណ្ឌូនេស៊ីមានស្ថិតិកំណើតដែលបានចុះបញ្ជីរួចរាល់ហើយ នៅថ្នាក់ជាតិ និង ថ្នាក់ក្រោមជាតិ (ស្រុក/ក្រុង និង ខេត្ត)។ ស្ថិតិសម្រាប់កុមារក្រោមអាយុ ១៨ ឆ្នាំ (ច្បាប់ជាតិស្ដីពីកិច្ចការពារកុមារ – ច្បាប់លេខ ៣៥/២០១៤ បានធ្វើនិយ័តកម្មថា កុមារមានអាយុក្រោម ១៨ ឆ្នាំ)។ គិតត្រឹមចុងឆ្នាំ២០១៨ ការគ្រប់ដណ្ដប់លើសំបុត្រកំណើតរបស់កុមារដែលមានអាយុក្រោម ១៨ ឆ្នាំ មានចំនួន ៩១,៩៥% (ចំនួនកុមារក្រោមអាយុ ១៨ ឆ្នាំ៖ ៧៩.៥៩០.៦២៩ នាក់ មានសំបុត្រកំណើតចំនួន ៧៣.១៨២.៣៤១) [sic]"។[124] ស្ថិតិដែលត្រូវបានចែងនៅក្នុងរបាយការណ៍របស់ប្រទេសម៉ាឡេស៊ី គឺជាស្ថិតិដែលទទួលបានពីឆ្នាំ២០១០។[125] របាយការណ៍ប្រចាំ**ប្រទេសមីយ៉ាន់ម៉ា**បានចង្អុលបង្ហាញថា នៅចន្លោះឆ្នាំ ២០១៥-២០១៦ ៨១,៣% នៃកុមារដែលមានអាយុក្រោម ៥ ឆ្នាំ បានចុះបញ្ជីកំណើតរបស់ពួកគេ។[126]

របាយការណ៍ពីប្រទេសសិង្ហបុរី មិនបានផ្ដល់ស្ថិតិណាមួយនោះទេ។ ដោយសារអសង្គតភាពនៃស្ថិតិដែលផ្ដល់ជូនដោយប្រទេសនីមួយៗ វាមានការពិបាកនៅក្នុងការទាញសេចក្ដីសន្និដ្ឋាន។ លើសពីនេះទៀត ស្ថិតិមិនបានផ្ដល់ព័ត៌មានជាច្រើនអំពីការគ្របដណ្ដប់លើការចុះបញ្ជីនៅក្នុង ប្រទេសនីមួយៗនោះទេ។

បញ្ហាដ៏សំខាន់មួយគឺ ការទទួលបានសិទ្ធិមនុស្សមូលដ្ឋាន ដូចជាការអប់រំ និង ការថែទាំសុខភាពជាដើម ចំពោះអ្នកដែលខ្វះខាតឯកសារតាមផ្លូវច្បាប់។ នៅ**ប្រទេសប្រ៊ុយណេដារូសាឡឹម** មានការរឹតត្បិតលើសិទ្ធិរបស់កុមារ ដែលគ្មានឯកសារតាមផ្លូវច្បាប់ ប៉ុន្តែមានការផ្ដល់ជូននានាសម្រាប់កុមារដែលនឹងត្រូវចុះបញ្ជី។[127] នៅ**ប្រទេសកម្ពុជា** និង **ប្រទេសឡាវ** ការទទួលបានសិទ្ធិមូលដ្ឋាន មិនអាស្រ័យលើការចុះបញ្ជីកំណើតនោះទេ។ នៅ**ប្រទេសឥណ្ឌូនេស៊ី** មានទំនាក់ទំនងទៅវិញទៅមក រវាងការមានសំបុត្រកំណើត និង ការទទួលបានសេវាសាធារណៈ។ គេតម្រូវឲ្យមានសំបុត្រកំណើត ដើម្បីទទួលបានសេវាសាធារណៈ ប៉ុន្តែនៅពេលដែលមន្ត្រីមុខងារសាធារណៈដឹងថាកុមារម្នាក់ពុំមានសំបុត្រកំណើតទេ នោះពួកគេនឹងជូនដំណឹង ទៅកាន់ការិយាល័យអន្ដោប្រវេសន៍-

121 Ibid.

122 របាយការណ៍របស់ប្រទេសវៀតណាម។

123 ប្រទេសប្រ៊ុយណេដារូសាឡឹម (២០១០-២០១៧) ប្រទេសកម្ពុជា ឆ្នាំ២០១៧ របាយការណ៍ប្រចាំប្រទេសឡាវ (ឆ្នាំ២០១៣-២០១៦) ប្រទេសម៉ាឡេស៊ី (ឆ្នាំ២០១០) ប្រទេសហ្វីលីពីន (ឆ្នាំ២០១៥-២០១៧) ប្រទេសថៃ (ឆ្នាំ២០១២-២០១៦) ប្រទេសវៀតណាម (ឆ្នាំ២០១៤-២០១៦)។

124 ជាតុចូលបន្ថែមដោយជនបង្គោលនៃប្រទេសឥណ្ឌូនេស៊ី នៅថ្ងៃទី២៩ ខែមីនា ឆ្នាំ២០១៩។

125 របាយការណ៍របស់ប្រទេសម៉ាឡេស៊ី។

126 របាយការណ៍របស់ប្រទេសមីយ៉ាន់ម៉ា។

127 របាយការណ៍ប្រចាំប្រទេសប្រ៊ុយណេដារូសាឡឹម។

កូលដ្ឋានឲ្យចេញសំបុត្រកំណើតមួយច្បាប់។ ទោះបីជាបែបនេះក៏ដោយ ក៏កុមារដែលគ្មានសំបុត្រកំណើតអាចទទួលបានសេវាសុខភាព និង ការអប់រំនៅក្នុងប្រទេសឥណ្ឌូនេស៊ីដែរ។[128] នៅ**ប្រទេសម៉ាឡេស៊ី** កុមារដែល គ្មានឯកសារស្តីពីឋានៈតាមផ្លូវច្បាប់ ឬ ការចុះបញ្ជីកំណើត អាចទទួលបានការអប់រំនៅក្នុងមណ្ឌលរៀនសូត្រ ដែលត្រូវបានបង្កើតឡើងដោយអង្គការមិនមែនរដ្ឋាភិបាល (NGOs)។ ទោះបីជាយ៉ាងណាក៏ដោយ កុមារដែលគ្មានឯកសារតាមផ្លូវច្បាប់ ប៉ុន្តែឪពុក ឬ ម្តាយរបស់ពួកគេគឺជាពលរដ្ឋម៉ាឡេស៊ី អាចទទួលបានការអប់រំនៅសាលារដ្ឋ។ នៅក្នុងករណីនេះ តម្រូវឲ្យមានលិខិតបញ្ជាក់យល់ព្រមមួយច្បាប់ ដែលត្រូវបានបញ្ជាក់ដោយភូមិ មុនពេលអនុញ្ញាតឲ្យកុមារចូល រៀននៅសាលារដ្ឋ។[129]



នៅ**ប្រទេសហ្វីលីពីន** គេបានចង្អុល បង្ហាញថា ប្រសិនបើគ្មានសំបុត្រកំណើតទេនោះ មនុស្សម្នាក់នឹងមានការពិបាកនៅក្នុងការទទួលបានទាំងសេវា និង កម្មវិធីរបស់រដ្ឋាភិបាល និង របស់វិស័យឯកជន។ ការកើនឡើង នៃកម្រិតក្នុងការចុះបញ្ជីកំណើតនៅក្នុងរយៈពេលជាច្រើនឆ្នាំ កន្លងមកនេះ ជាចម្បងគឺដោយសារតែសំបុត្រកំណើត មានសារសំខាន់ ចំពោះលទ្ធភាពក្នុងការទទួលបានសេវា និង អត្ថប្រយោជន៍នានា។[130] **ប្រទេសសិង្ហបុរី** តម្រូវឲ្យអ្នកដាក់ពាក្យស្នើសុំចូលរៀននៅសាលារៀនដាក់ជូនឯកសារនានា សម្រាប់ការផ្ទៀងផ្ទាត់អត្តសញ្ញាណ សម្រាប់ការអនុញ្ញាតឲ្យចូលរៀន ប៉ុន្តែជនដែលគ្មានឯកសារអាចទទួលបានថែទាំសុខភាព ដែលចាំបាច់ រួមបញ្ចូលទាំងការសង្គ្រោះបន្ទាន់ផង ដែរ។[131] **ប្រទេសមីយ៉ាន់ម៉ា** មានទម្លាប់អនុវត្តដែលប្រហាក់ប្រហែលគ្នានឹងប្រទេសសិង្ហបុរីដែរដែលតម្រូវ ឲ្យអ្នកដាក់ពាក្យស្នើសុំ ចូលរៀននៅសាលារៀនដាក់ ជូនឯកសារនានា សម្រាប់ការផ្ទៀងផ្ទាត់អត្តសញ្ញាណ មុនពេលអនុញ្ញាតឲ្យចូលរៀន។ ទោះបីជាយ៉ាងណាក៏ដោយ ជនដែលគ្មានឯកសារ អាចទទួលបានការថែទាំសុខភាពដែលចាំបាច់។[132] របាយការណ៍ប្រចាំ**ប្រទេសថៃ** មិនបានគ្របដណ្តប់លើបញ្ហានេះទេ។[133] នៅ**ប្រទេសវៀតណាម** កុមារដែលគ្មានឯកសារមិនអាចទទួលបានសិទ្ធិមូលដ្ឋាន ដោយគ្មានករណីពិសេសណាមួយនោះទេ។[134] យើងអាចទាញសេចក្តីសន្និដ្ឋានមួយថា នៅពាក់កណ្តាលនៃ AMS ឯកសារគឺចាំបាច់ ដើម្បីទទួលបានសិទ្ធិមូលដ្ឋានដែលរួមបញ្ចូលទាំងការថែទាំសុខភាព និង ការអប់រំផងដែរ។ របាយការណ៍ប្រចាំប្រទេស ក៏បង្ហាញផងដែរថា ក្រុមកុមារមួយចំនួន មានហានិភ័យខ្ពស់ នៃកង្វះខាតការចុះបញ្ជីកំណើត និង ការចុះបញ្ជីអត្រានុកូលដ្ឋាន។ ក្រុមកុមារទាំងនេះរួមបញ្ចូលកូនរបស់ជនអន្តោប្រវេសន៍ អ្នកស្វែងរកសិទ្ធិជ្រកកោន នៅក្នុងទីក្រុង ជាតិពន្ធភាគតិច ជនជាតិដើមភាគតិច និង អ្នកដែលរស់នៅតាមទីជនបទ និង តំបន់ដាច់ស្រយាល។ របាយការណ៍ប្រចាំ**ប្រទេសឥណ្ឌូនេស៊ី** ចង្អុលបង្ហាញថា ប្រជាជនដែលជាជនរងគ្រោះដោយសារគ្រោះធម្មជាតិ ជនរងគ្រោះដោយសារចលាចល និងកុប្បកម្មនៅក្នុងសង្គម និង ជនដែលគ្មានផ្ទះសម្បែង មានហានិភ័យនៃការមិន ទទួលបានការចុះបញ្ជី។

**ប្រទេសហ្វីលីពីន**ចង្អុលបង្ហាញថា កុមារដែល

---

128 ធាតុចូលបន្ថែមត្រូវបានធ្វើឡើងនៅថ្ងៃទី២៩ ខែមីនា ឆ្នាំ២០១៩ ដោយជនបង្គោលនៃប្រទេសឥណ្ឌូនេស៊ី។

129 ការកែសម្រួលត្រូវបានស្នើឡើងដោយជនបង្គោលនៃ ប្រទេសម៉ាឡេស៊ី។

130 របាយការណ៍ប្រចាំប្រទេសហ្វីលីពីន។

131 របាយការណ៍ប្រចាំប្រទេសសិង្ហបុរី។

132 ព័ត៌មានត្រូវបានធ្វើបច្ចុប្បន្នភាពដោយជនបង្គោលនៃ ប្រទេសមីយ៉ាន់ម៉ា។

133 ច្បាប់ស្តីពីការអប់រំនៅប្រទេសថៃមិនតម្រូវឲ្យមានសំបុត្រកំណើតដើម្បីទទួលបានការអប់រំដែលចាំបាច់នោះទេ។ ទោះបីជាយ៉ាងណាក៏ដោយ នៅក្នុងការអនុវត្តជាក់ស្តែង ការ ទទួលបានអាស្រ័យលើឆន្ទានុសិទ្ធិរបស់សាលារៀន (ត្រូវបាន កត់សម្គាល់ដោយអ្នកនិពន្ធឯកសារស្តីពីការសំយោគនេះ)។

134 របាយការណ៍របស់ប្រទេសវៀតណាម។

កើតពីអាពាហ៍ពិពាហ៍របស់អ្នកម្ដាយវ័យជំទង់ កុមារដែលមានដើមកំណើតហ្វីលីពីន ដែលរស់នៅទីកន្លែងសម្រាប់ជនទេសន្តរប្រវេសន៍ (សាបានៅប្រទេសម៉ាឡេស៊ី[135] ប្រទេសជប៉ុន និង ប្រទេស អារ៉ាប៊ីសាអូឌីត និង Sama Dilaut ឬ Sama Badjao) មានហានិភ័យនៃការមិនទទួលបានការចុះបញ្ជីកំណើត។ របាយការណ៍របស់**ប្រទេសវៀតណាម** បានសម្គាល់ឃើញក្រុមជាក់លាក់មួយដែលមានហានិភ័យ នៃការមិនទទួលបានសំបុត្រកំណើត គឺកុមារដែលមានម្ដាយជាជនជាតិវៀតណាម ដែលបានរៀបអាពាហ៍ពិពាហ៍ជាមួយជនបរទេស ប៉ុន្តែបានត្រឡប់មកកាន់ប្រទេសវៀតណាម ជាមួយកូនរបស់ពួកគេវិញក្រោយពេលលែងលះ ឬបែកបាក់គ្នា និងដោយគ្មានឯកសារផ្ទាល់ខ្លួនរបស់ពួកគេ។[136] មានតែរបាយការណ៍ប្រចាំប្រទេសម៉ាឡេស៊ី និង ប្រទេសសិង្ហបុរីប៉ុណ្ណោះដែលបញ្ជាក់ថាពុំមានបុគ្គល ឬ សហគមន៍ណាមួយប្រឈមមុខនឹងកង្វះខាតការ ចុះបញ្ជីកំណើត ឬ ការចុះបញ្ជីអត្រានុកូលដ្ឋាននោះទេ។[137]

## ២.៤ បញ្ហាប្រឈម និង ទម្លាប់អនុវត្តល្អៗ

### ក) បញ្ហាប្រឈម

របាយការណ៍ របស់គ្រប់ប្រទេសទាំងអស់លើកលែង តែរបាយការណ៍ប្រចាំ**ប្រទេសប្រ៊ុយណេដារូសាឡឹម** និង **ប្រទេសសិង្ហបុរី** បានសម្គាល់ឃើញគម្លាត និង បញ្ហាប្រឈមមួយចំនួននៅក្នុងការអនុវត្តការចុះបញ្ជីអត្រានុកូលដ្ឋាន ជាទូទៅ និង ជាពិសេស ការចុះបញ្ជីកំណើត។ **ប្រទេសកម្ពុជា** ចង្អុលបង្ហាញថា ក្របខណ្ឌច្បាប់ដែលមានកម្រិត និង មូលនិធិដែលមានកម្រិត បង្កើតជាបញ្ហាប្រឈមនានា ចំពោះការអនុវត្តយ៉ាងពេញលេញ នូវការចុះបញ្ជី អត្រានុកូលដ្ឋាន ស្របតាមបទដ្ឋានអន្តរជាតិ។[138] បញ្ហាធ្ងន់ធ្ងរចំពោះ **ប្រទេសឥណ្ឌូនេស៊ី** មានទំនាក់ ទំនងនឹងភាពជាប្រជុំកោះ ដែលមានផ្ទៃដីលាតសន្ធឹង ដ៏ធំ និង មានក្រុមជាតិពន្ធុ និង ក្រុមជាតិពន្ធុតូចៗ ខុសៗគ្នាជាច្រើន ដែលក្រុមជាតិពន្ធុនីមួយៗមាន វប្បធម៌ និង ភាសាក្នុងមូលដ្ឋានរបស់ពួកគេផ្ទាល់ ព្រមទាំងមានក្រុមដែលមានប្រាក់ចំណូលទាបជាច្រើនក្រុម ជាពិសេស ជនដែលគ្មានផ្ទះសម្បែង។ គ្រោះធម្មជាតិ ក៏បានបន្សល់ទុកនូវមនុស្សជាច្រើនដែលគ្មានឯកសារផងដែរ។[139] ទោះបីជាយ៉ាងណាក៏ដោយ តាមរយៈការប្រើមូលដ្ឋានទិន្នន័យជាតិអំពីប្រជាជន នៅក្នុងករណីមានគ្រោះមហន្តរាយ ឯកសាររបស់ប្រជាជននៅក្នុងតំបន់នោះអាចត្រូវបានចេញជូនឡើងវិញភ្លាមៗ។ នៅពេលនេះការដំណើរការឡើងវិញនូវសេវានានារបស់ប្រជាជនអាចកើតឡើងក្នុងរយៈពេល ២៤ ម៉ោងក្រោយពេលមានគ្រោះធម្មជាតិ។[140] ចំពោះ **ប្រទេសឡាវ** កង្វះ

135 នៅប្រទេសម៉ាឡេស៊ី ការចុះបញ្ជីកំណើតត្រូវបានគ្រប់គ្រងដោយច្បាប់ស្ដីពីការចុះបញ្ជីកំណើត និង មរណភាព ឆ្នាំ១៩៥៧ បទប្បញ្ញត្តិស្ដីពីការចុះបញ្ជីកំណើត និង មរណភាព ឆ្នាំ១៩៤៨ (Sabah Cap. ១២៣) និង បទប្បញ្ញត្តិស្ដីពីការចុះបញ្ជីកំណើត និង មរណភាព ឆ្នាំ១៩៥១ (Sarawak Cap. ១០) ហើយកំណើតរបស់កុមារគ្រប់រូបដែលកើតនៅក្នុង ប្រទេសម៉ាឡេស៊ីនឹងត្រូវចុះបញ្ជី ដោយមន្ត្រីអត្រានុកូលដ្ឋាននៅក្នុងតំបន់ចុះបញ្ជីណាមួយ។ ទិន្នន័យបន្ថែមត្រូវបានផ្ដល់ ជូននៅក្នុងការកែសម្រួលការសំយោគ នៅក្នុងតំបន់ដែលត្រូវបានស្នើឡើងដោយជនបង្គោលនៃប្រទេសម៉ាឡេស៊ី។

136 Ibid.

137 របាយការណ៍របស់ប្រទេសម៉ាឡេស៊ី និង ប្រទេសសិង្ហ បុរី។ ទោះបីជាយ៉ាងណាក៏ដោយ កុមារនៅក្នុងសហគមន៍ដាច់ស្រយាល ដូចជា នៅសាបា និង Sarawak ជាដើម ប្រឈមមុខនឹងហានិភ័យនៃកង្វះខាតការចុះបញ្ជីកំណើត។ អ្នកតំណាងរបស់ប្រទេសសិង្ហបុរីប្រចាំនៅ ACWC បានចង្អុលបង្ហាញថា មានជនគ្មានសញ្ជាតិចំនួន ១.១៤១ នាក់នៅក្នុងប្រទេស។

138 របាយការណ៍របស់ប្រទេសកម្ពុជា។

139 របាយការណ៍ប្រចាំប្រទេសឥណ្ឌូនេស៊ី។

140 ទម្លាប់អនុវត្តល្អបំផុតពី Lombok Earthquake ឆ្នាំ២០១៨៖ Palu Tsunami ឆ្នាំ២០១៨ ត្រូវបានដកស្រង់នៅក្នុងធាតុចូលបន្ថែមដែលត្រូវបានធ្វើឡើងដោយប្រទេសឥណ្ឌូនេស៊ី នៅថ្ងៃទី២៩ ខែមីនា ឆ្នាំ២០១៩។

ខាតការយល់ដឹងអំពីសារសំខាន់នៃការចុះបញ្ជីកំណើត គឺជាឧបសគ្គមួយជាពិសេស នៅក្នុងចំណោមប្រជាជនដែលរស់នៅតាមតំបន់ដាច់ស្រយាល ជាពិសេសជាតិពន្ធុភាគតិច ដែលមិនអាចនិយាយភាសាផ្លូវការបាន។ ហេដ្ឋារចនាសម្ព័ន្ធមិនល្អ បានធ្វើឲ្យប្រជាជនមានការលំបាកនៅក្នុងការចុះបញ្ជី សូម្បីតែនៅការិយាល័យនៅក្នុងមូលដ្ឋានរបស់ពួកគេ។[141] ចំពោះ **ប្រទេសមីយ៉ាន់ម៉ា** នាយកដ្ឋានរដ្ឋបាលទូទៅអនុវត្តតាមមាត្រា ១៣ (ក) នៃច្បាប់ស្តីពីមន្ត្រីរដ្ឋបាលភូមិ និង ឃុំ និង កថាខណ្ឌទី២០(ក) (ខ) និង (គ) នៃបទប្បញ្ញត្តិស្តីពីមន្ត្រីរដ្ឋបាលភូមិ និង ឃុំ សម្រាប់ការចុះបញ្ជីកំណើត និង មរណភាព។[142] ការរួមចំណែកបន្ថែមទៀតដល់របាយការណ៍ ប្រចាំប្រទេសមីយ៉ាន់ម៉ាចង្អុលបង្ហាញថា មានការពិបាកមួយចំនួននៅតាមតំបន់ដាច់ស្រយាល មួយចំនួនពាក់ព័ន្ធនឹងដំណើរការចុះបញ្ជីកំណើត។[143] នាពេលថ្មីៗនេះ ការផ្លាស់ប្តូរ ពីការចុះបញ្ជីនៅកន្លែងកើតហេតុទៅចុះបញ្ជីនៅទីលំនៅវិញ បានធ្វើឲ្យមនុស្សជាច្រើនមានការយល់ច្រឡំ។ វាមានការពិបាកនៅក្នុងចូលទៅដល់ក្រុមប្រជាជនដែលពិបាកឈោងចាប់ ដែលមានផលជះដល់អត្រាចុះបញ្ជីកំណើត។ ការចុះបញ្ជីនៅលើក្រដាស ក៏ត្រូវបានសម្គាល់ឃើញថាជាឧបសគ្គដ៏ចម្បង មួយផងដែរ ទាំងក្នុងអំឡុងពេលចុះបញ្ជីដោយផ្ទាល់ និង ចំពោះការវាយតម្លៃអំពីការចុះបញ្ជីអត្រានុកូលដ្ឋាន។[144]

របាយការណ៍ប្រចាំ**ប្រទេសម៉ាឡេស៊ី**មិនបានបញ្ជាក់អំពីគម្លាត ឬ បញ្ហាប្រឈមនានានោះទេ។ ទោះបីជាយ៉ាងណាក៏ដោយ វាមានតម្លៃនៅក្នុងការកត់សម្គាល់ថា នៅឧបទ្វីបម៉ាឡេ រដ្ឋាភិបាលបានពន្យារពេលការចុះបញ្ជីកំណើតពី ១៤ថ្ងៃ ទៅ៦០ថ្ងៃ។[145] ចំពោះ**ប្រទេសហ្វីលីពីន** ការទទួលបានការចុះបញ្ជីកំណើត និង ការចុះបញ្ជីអត្រានុកូលដ្ឋានដោយក្រុមមួយចំនួន ជាពិសេស ជនជាតិម៉ូរ៉ូ ឬជនជាតិមូស្លីមនៅក្នុងតំបន់ស្វយ័តសម្រាប់ជនជាតិមូស្លីមនៅ Mindanao (ARMM) និង Lumad ឬក្រុមជនជាតិដើមភាគតិចនៅ Davao Occidental មានចំនួនតិចតួចខ្លាំងណាស់ ប្រសិនបើប្រៀបធៀបនឹងចំនួនជាមធ្យមនៅថ្នាក់ជាតិ។ ARMM បានបង្ហាញអត្រាទាបបំផុតនៃ ការចុះបញ្ជីកំណើតនៅក្នុងឆ្នាំ២០១៥ដែលមានការចុះបញ្ជីចំនួន ៤០,៨៦% នៅក្នុងឆ្នាំ២០១៥។ ចំនួនជាមធ្យមនៅថ្នាក់ជាតិគឺ ៩៣,៥% នៅក្នុងឆ្នាំ២០១០។[146] ករណីរបស់ក្រុមទាំងពីរនេះត្រូវបានត្រួតពិនិត្យយ៉ាងលម្អិតនៅក្នុងរបាយការណ៍របស់ប្រទេសហ្វីលីពីន។[147] ករណីសិក្សាទាំងពីរនេះបង្ហាញថា ការចុះបញ្ជីកំណើតអាពាហ៍ពិពាហ៍ និង មរណភាពនៅក្នុងតំបន់ទាំងនេះមានចំនួនទាបបំផុតនៅក្នុងប្រទេសទាំងមូលដោយសារមូលហេតុជាច្រើន ដូចជា៖ ជម្លោះប្រដាប់អាវុធភាពដាច់ស្រយាល និង ការពិបាក ក្នុងការចេញចូលតំបន់ទាំងនោះ កង្វះខាតការយល់ដឹង និង ចំណេះដឹងអំពីសារសំខាន់នៃ ការចុះបញ្ជីអត្រានុកូលដ្ឋាន ភាពធម្មតានៃការសម្រាលកូននៅផ្ទះ / តាមបែបប្រពៃណី ដែលអ្នកចូលរួមនៅក្នុងការសម្រាលកូនតាមបែបប្រពៃណីនោះ មានភាពស្ទាក់ស្ទើរនៅក្នុងការចុះបញ្ជីកំណើត ដោយភ័យខ្លាចរងទោសទណ្ឌពីសំណាក់រដ្ឋាភិបាលមូលដ្ឋាន[148] សោហ៊ុយលើការចុះបញ្ជី និង ការធ្វើដំណើរ ដំណើរការយឺតយ៉ាវនៃការចុះបញ្ជី ការបាត់បង់ទំនុកចិត្តលើប្រព័ន្ធ កង្វះខាតការិយាល័យចុះបញ្ជីនៅក្នុងមូលដ្ឋាន និង ទម្លាប់អនុវត្តផ្នែកវប្បធម៌ និង សាសនា។ អត្រាអក្ខរភាពទាបនៅក្នុងចំណោមមាតា ក៏ត្រូវបានសម្គាល់ឃើញថាជាមូលហេតុមួយ នៅក្នុងចំណោមមូលហេតុនានាដែលនាំឲ្យមានអត្រាចុះបញ្ជីទាបដែរ ជាពិសេសនៅក្នុងចំណោមជនជាតិដើមភាគតិច។ អាពាហ៍ពិពាហ៍ជាច្រើន មិនបានចុះបញ្ជីនោះទេ ដែលមានផលជះលើការចុះបញ្ជីកំណើត។[149] ក៏មានបញ្ហា

141 របាយការណ៍ប្រចាំប្រទេសឡាវ។

142 ព័ត៌មានដែលមានបច្ចុប្បន្នភាពត្រូវបានផ្តល់ជូនដោយជនបង្គោលនៃប្រទេសមីយ៉ាន់ម៉ា។

143 Ibid.

144 របាយការណ៍ប្រចាំប្រទេសមីយ៉ាន់ម៉ា។

145 របាយការណ៍ប្រចាំប្រទេសមីឡេស៊ី។

146 ព័ត៌មានដែលមានបច្ចុប្បន្នភាពត្រូវបានផ្តល់ជូនដោយជនបង្គោលនៃប្រទេសហ្វីលីពីន។

147 របាយការណ៍ប្រចាំប្រទេសហ្វីលីពីន។

148 ព័ត៌មានដែលមានបច្ចុប្បន្នភាពត្រូវបានផ្តល់ជូនដោយជនបង្គោលនៃប្រទេសហ្វីលីពីន។

149 Ibid.

ប្រឈម និង គម្លាតនានាដែលត្រូវបានសម្គាល់ឃើញនៅក្នុងប្រព័ន្ធ ចុះបញ្ជីដោយផ្ទាល់ផងដែរ ដូចជា៖ ការកសាងសមត្ថភាព នៃការចុះបញ្ជីអត្រានុកូល ដ្ឋាននៅកម្រិតមូលដ្ឋាន (LCR) និង កម្រិត barangay នៅមានកម្រិតកង្វះខាតការចូលរួមរវាង PSA និង អ្នកពាក់ព័ន្ធដទៃទៀត, ច្បាប់ និង បទប្បញ្ញត្តិ[150] ដែលត្រូវបានចេញ ដោយគ្មានការពិគ្រោះយោបល់យ៉ាងត្រឹមត្រូវជាមួយ LCRs នោះទេ, ការយល់ដឹងអំពីផែនការយុទ្ធសាស្ត្ររបស់ប្រទេសហ្វីលីពីនចំពោះ CRVS នៅក្នុងចំណោមបុគ្គលិក និង មន្ត្រីអត្រានុកូលដ្ឋាននៃ PSA នៅក្នុងតំបន់ នៅមានកម្រិត, ភាពយឺតយ៉ាវនៃការចេញឯកសារគល់បញ្ជីអត្រានុកូលដ្ឋាន, ធនធានមនុស្ស និង ការគាំទ្រផ្នែកថវិកាសម្រាប់ LCR មានចំនួនមិនគ្រប់គ្រាន់, កង្វះខាតការផ្តល់តម្លៃដល់សារសំខាន់របស់ CRVS ពីសំណាក់ថ្នាក់ដឹកនាំនៅក្នុងមូលដ្ឋាន និង ភាពយឺតយ៉ាវនៃការដំណើរការការចុះបញ្ជីនៅខាងក្រៅទីក្រុងសម្រាប់ប្រជាជនដែលកំពុងផ្លាស់ទី។[151] ប្រទេសសិង្ហបុរីមិនបានសម្គាល់ឃើញចន្លោះប្រហោងនានានោះទេ ប៉ុន្តែមានបំណងពង្រឹងប្រព័ន្ធចុះបញ្ជីអត្រានុកូលដ្ឋានតាមរយៈឌីជីថលនីយកម្ម។[152]

ប្រទេសថៃ បានសម្គាល់ឃើញមនុស្សជាច្រើនក្រុមដែលប្រឈមមុខ នឹងហានិភ័យនៃការមិនបានចុះបញ្ជីកំណើត ជាពិសេស បុគ្គលដែលកើតនៅក្រៅ មន្ទីរពេទ្យ និង រស់នៅតាមតំបន់ដាច់ស្រយាលក្រុមដែលគេមិនអើពើ និង ក្រុមងាយរងគ្រោះ និង អ្នកស្វែងរកសិទ្ធិជ្រកកោននៅក្នុងទីក្រុង។ ដើម្បីដោះស្រាយបញ្ហានេះ ក្រសួងសុខាភិបាលសាធារណៈ នាយកដ្ឋានរដ្ឋបាលខេត្ត នៃក្រសួងមហាផ្ទៃ និង ការិយាល័យគាំពារសុខភាពជាតិ (NHSO) សហការជាមួយមូលនិធិសហប្រជាជាតិដើម្បីកុមារ បានផ្តួចផ្តើមគំនិតបង្កើតគម្រោង អភិវឌ្ឍការចុះបញ្ជីកំណើតដើម្បីធានាចំពោះសិទ្ធិរបស់កុមារគ្រប់រូប ដែលកើតនៅប្រទេសថៃ ដែលរួមបញ្ចូលទាំង កុមារថៃ និង កុមារបរទេសផងដែរ។ មន្ទីរពេទ្យរដ្ឋនៅទូទាំងប្រទេស ត្រូវបានស្នើសុំឲ្យចូលរួមនៅក្នុងប្រព័ន្ធពិនិត្យតាមដានការចុះបញ្ជីអត្រានុកូលដ្ឋាន។ នៅចន្លោះឆ្នាំ២០១១ និង ឆ្នាំ២០១៣ គម្រោងនេះបានបណ្តាលឲ្យមានការថយចុះនៃចំនួនកុមារ ដែលមិនបានចុះបញ្ជីកំណើត នៅក្នុងរយៈពេល ១៥ថ្ងៃ។

ក្រសួងសុខាភិបាលសាធារណៈ ការិយាល័យគាំពារសុខភាពជាតិ (NHSO) ព្រមទាំងទីភ្នាក់ងារដែលពាក់ព័ន្ធដទៃទៀត កំពុងដំណើរការការអភិវឌ្ឍប្រព័ន្ធចុះបញ្ជី ដើម្បីសម្រេចគោលដៅនៃការចុះបញ្ជីយ៉ាងពេញលេញ។ ទោះបីជាគម្រោងនេះទទួលបានជោគជ័យក៏ដោយ ក៏គេបានមើលឃើញថា ពុំទាន់មានទីភ្នាក់ងារណាមួយ ទទួលបន្ទុកលើការប្រមូល និង កត់ត្រាព័ត៌មានសម្រាប់កុមារដែលកើតនៅខាងក្រៅមន្ទីរពេទ្យ និង កុមារដទៃទៀតដែលគេមិនអើពើនៅឡើយទេ។[153] ចំពោះប្រទេសវៀតណាម

150 បទបញ្ជាផ្នែករដ្ឋបាល (AO) និង/ឬ សារាចរនៃអនុស្សរណៈ (MC)។
151 ចូរមើលការសិក្សាលម្អិតនៅក្នុងរបាយការណ៍ប្រចាំប្រទេសហ្វីលីពីន។
152 របាយការណ៍ប្រចាំប្រទេសសិង្ហបុរី។
153 របាយការណ៍ប្រចាំប្រទេសថៃ។

ប្រទេសនេះ កំពុងដំណើរការកំណែទម្រង់នីតិវិធីរដ្ឋបាល ដែលអនុវត្តតាមច្បាប់ស្តីពីអត្រានុកូលដ្ឋានឆ្នាំ២០១៤ ដែលរួមបញ្ចូលទាំងការផ្ទេរទំនួលខុសត្រូវលើការចុះបញ្ជីអត្រានុកូលដ្ឋានរបស់ "ជនបរទេស" និង/ឬ "ធាតុបរទេស"[154] ពីនាយកដ្ឋានយុត្តិធម៌ ទៅកាន់គណៈកម្មាធិការស្រុកវិញ ដើម្បីជួយសម្រួលដល់ប្រជាជនបានកាន់តែល្អប្រសើរឡើង។ ទោះបីជាយ៉ាងណាក៏ដោយ មិនទាន់មានការបង្កើតការអនុវត្តបានយ៉ាងល្អនៅឡើយទេ ដោយសារមានចន្លោះប្រហោងមួយចំនួនតូច រួមមាន ចំនួនមន្ត្រីរាជការមិនគ្រប់គ្រាន់ និង មន្ត្រីរាជការនៅថ្នាក់ឃុំ និង ស្រុក ពុំមានសមត្ថភាពវិជ្ជាជីវៈ ជំនាញកុំព្យូទ័រ ជំនាញភាសាបរទេសគ្រប់គ្រាន់នោះទេ។ល។[155]

តាមរយៈចន្លោះ ប្រហោងដែលបានសម្គាល់ឃើញនៅក្នុងរបាយការណ៍ប្រចាំប្រទេស វាបង្ហាញថា ប្រទេសជាច្រើនកំពុងតែប្រឈមមុខនឹងបញ្ហាប្រឈមមួយចំនួនដូចៗគ្នា ដូចជាការចូលទៅជិតក្រុមពិបាកទំនាក់ទំនង កង្វះខាតការយល់ដឹងអំពីសារសំខាន់នៃការចុះបញ្ជីអត្រានុកូលដ្ឋាន និង បញ្ហាប្រឈមនានាដែលពាក់ព័ន្ធនឹងប្រព័ន្ធចុះបញ្ជីអត្រានុកូលដ្ឋានដោយផ្ទាល់។ ទោះបីជាយ៉ាងណាក៏ដោយ មានទម្លាប់អនុវត្តល្អៗមួយចំនួន ដែល AMS អាចរៀនសូត្រពីគ្នាទៅវិញទៅមកបាន ដើម្បីដោះស្រាយបញ្ហាប្រឈមទាំងនេះ។



154 ដែលសំដៅលើស្វាមីភរិយាដែលមានជាតិសាសន៍ចម្រុះ កុមារម្នាក់ដែលកើតពីឪពុកម្តាយដែលជាជនជាតិវៀតណាម និង ជាជនបរទេស។ ឧទាហរណ៍ចំពោះការចុះបញ្ជីកំណើត៖ មាត្រា ៣៥ នៃច្បាប់ស្តីពីអត្រានុកូលដ្ឋាន ដែលបានចេញនៅថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០១៤ បានចែងដូចខាងក្រោម៖

គណៈកម្មាធិការស្រុកនៃទីលំនៅរបស់ឪពុក ឬ ម្តាយត្រូវចុះបញ្ជីកំណើតឲ្យកូន នៅក្នុងករណីដូចខាងក្រោម៖

១. កុមារដែលកើតនៅក្នុងប្រទេសវៀតណាម៖

ក/ មានឪពុក/ម្តាយម្នាក់ជាពលរដ្ឋវៀតណាម និង ឪពុក/ម្តាយម្នាក់ទៀតជាជនបរទេស ឬ ជនគ្មានសញ្ជាតិ

ខ/ មានឪពុក/ម្តាយម្នាក់ជាពលរដ្ឋវៀតណាមដែលរស់នៅក្នុងប្រទេស និង ឪពុក/ម្តាយម្នាក់ទៀតជាពលរដ្ឋវៀតណាមដែលរស់នៅបរទេស

គ/ មានឪពុកម្តាយទាំងពីរនាក់ជាពលរដ្ឋវៀតណាមដែលរស់នៅបរទេស

ឃ/ មានឪពុកម្តាយទាំងពីរនាក់ជាជនបរទេស ឬ ជនគ្មានសញ្ជាតិ។

២. កុមារដែលកើតនៅបរទេស ដែលមិនទាន់បានចុះបញ្ជីកំណើតនៅបរទេស និង ត្រូវបាននាំមករស់នៅក្នុងប្រទេសវៀតណាម

ក/ មានឪពុកម្តាយទាំងពីរនាក់ជាពលរដ្ឋវៀតណាម

ខ/ មានឪពុក/ម្តាយម្នាក់ជាពលរដ្ឋវៀតណាម។

ចូរមើលមាត្រា ៣៧ និង ៣៨ សម្រាប់ការចុះបញ្ជីអាពាហ៍ពិពាហ៍ មាត្រា ៣៩ និង ៤០ សម្រាប់ការចុះបញ្ជីភាពជាអាណាព្យាបាល មាត្រា ៥១ និង ៥២ សម្រាប់ការចុះបញ្ជីមរណភាព សាធារណរដ្ឋសង្គមនិយមវៀតណាម ឯកសារនិយាមតាមផ្លូវច្បាប់ http://vbpl.vn/TW/Pages/vbpqen-toanvan.aspx?ItemID=11031

155 របាយការណ៍របស់ប្រទេសវៀតណាម។

## ខ) ទម្លាប់អនុវត្តល្អៗ និង មេរៀនដែលបានរៀនសូត្រ

នៅក្នុងរបាយការណ៍ គ្រប់ប្រទេសទាំងអស់ ទម្លាប់អនុវត្ត និង មេរៀនល្អៗមួយចំនួនត្រូវបាន ចែករំលែក។ របាយការណ៍មួយចំនួនបានផ្តល់បញ្ជី ទម្លាប់អនុវត្ត/មេរៀនល្អៗ ចាប់ពី កំណែទម្រង់ច្បាប់ លើគោលនយោបាយជាក់ស្តែងមួយចំនួន ដូចជា ការបង្កើនការយល់ដឹង ដើម្បីមានក្រុមចុះបញ្ជីចល័ត ដើម្បីធានា ចំពោះការចុះបញ្ជីកំណើតបានកាន់តែ ទូលំទូលាយ នៅខណៈពេលដែលរបាយការណ៍ដទៃ ទៀតបានគ្របដណ្តប់លើចំណុចផ្ទាល់ខ្លួនយ៉ាងលម្អិត។ ខាងក្រោមគឺជាបញ្ជីទម្លាប់ល្អៗដែលត្រូវបានសម្គាល់ ឃើញដោយរបាយការណ៍ប្រចាំប្រទេសនានា។

### ប្រទេសប្រ៊ុយណេដារូសាឡឹម

i. ធ្វើឲ្យមានទីតាំងចុះបញ្ជីអត្តសញ្ញាណប័ណ្ណនៅក្នុងស្រុកទាំងបួននៃប្រទេសប្រ៊ុយណេដារូសាឡឹម។ ការផ្ទៀងផ្ទាត់ត្រូវបានធ្វើឡើងតាមរយៈការចុះសួរសុខទុក្ខដោយមន្ត្រីអត្រានុកូលដ្ឋាន និង អាចស្វែងរកបានដោយអ្នកដែលមិនអាចទៅកាន់ការិយាល័យចុះបញ្ជីដោយផ្ទាល់បាន ឧទាហរណ៍៖ ជនពិការ និង មនុស្សវ័យចំណាស់ នៅពេលចុះបញ្ជីអត្តសញ្ញាណប័ណ្ណ ឬ អនុវត្តសកម្មភាពនៃការចុះបញ្ជីផ្សេងទៀត។

### ប្រទេសកម្ពុជា

i. បង្កើតផែនការយុទ្ធសាស្ត្រជាតិស្តីពីអត្តសញ្ញាណកម្មឆ្នាំ ២០១៧-២០២៦ ដែលបានកំណត់គោលដៅយ៉ាងច្បាស់លាស់ រួមជាមួយ ចក្ខុវិស័យ បេសកកម្ម វត្ថុបំណង និង គោលដៅយុទ្ធសាស្ត្រ ព្រមទាំងផែនការសកម្មភាពដ៏ច្បាស់លាស់ផងដែរ។ ផែនការយុទ្ធសាស្ត្រនេះ គឺជាក្របខណ្ឌដែលមានបំណងកំណត់ការធ្វើអត្តសញ្ញាណកម្មបុគ្គល នៅឆ្នាំ២០១៨ បង្កើតប្រព័ន្ធចុះបញ្ជីអត្រានុកូលដ្ឋាន និង ស្ថិតិអត្រានុកូលដ្ឋាន ដែលស្របនឹងបទដ្ឋានអន្តរជាតិនៅឆ្នាំ២០១៩ និង មានប្រព័ន្ធចុះបញ្ជីអត្រានុកូលដ្ឋានដែលបំពេញមុខងារយ៉ាងពេញលេញ និង យ៉ាងត្រឹមត្រូវ មុនឆ្នាំ២០២៣

ii. អនុម័តវិធីសាស្ត្រតាមផ្លូវច្បាប់ដើម្បីធ្វើឲ្យការសម្របសម្រួលនៅក្នុងចំណោមទីភ្នាក់ងាររដ្ឋាភិបាលមានភាពល្អប្រសើរឡើង រួមមាន៖

   ក. អនុក្រឹត្យលេខ ១៣៤ ចុះថ្ងៃទី០៥ ខែកក្កដា ឆ្នាំ២០១៦ ស្តីពីមន្ត្រីអត្រានុកូលដ្ឋានថ្នាក់ជាតិ

   ខ. សេចក្តីប្រកាសអន្តរក្រសួងលេខ ១៤៣៤២ ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០១៦ ស្តីពីការផ្តល់សេវារដ្ឋបាលនៅថ្នាក់ក្រោមជាតិ រវាង ក្រសួងមហាផ្ទៃ និង ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

   គ. សេចក្តីណែនាំលេខ ០៣៥ ចុះថ្ងៃទី២០ ខែតុលា ឆ្នាំ២០១៧ ស្តីពីការកែតម្រូវ និង ការធ្វើមោឃភាពទិន្នន័យនៃបញ្ជីអត្រានុកូលដ្ឋាន

   ឃ. សេចក្តីណែនាំលេខ ០៤៥ សលន ចុះថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០១៩ ស្តីពីការកែបន្តដំណើរការកែតំរូវ និងការធ្វើមោឃភាពទិន្នន័យនៃបញ្ជីអត្រានុកូលដ្ឋាន

iii. បង្កើតយុទ្ធនាការចុះបញ្ជីចល័តដើម្បីបង្កើតការទទួលបានការចុះបញ្ជីកំណើត សំបុត្រអាពាហ៍ពិពាហ៍ និង សំបុត្រមរណភាព។ ជាផ្នែកមួយនៃយុទ្ធនាការចុះបញ្ជីចល័តនេះ ក្រុមការងារ MOI បានដាក់សមាជិកក្រុមការងារចល័តឲ្យចុះបំពេញការងារចំនួន ១៣.០០០ នាក់ ដែលរួមបញ្ចូលទាំង មន្ត្រីកម្រិតរដ្ឋបាលផងដែរ។ ពួកគេបានទទួលការបណ្តុះបណ្តាលយ៉ាងជិតដល់នៅក្នុងការអនុវត្តការចុះបញ្ជីចល័ត។ ដោយមានជំនួយហិរញ្ញវត្ថុ និង ជំនួយបច្ចេកទេសពីអង្គការសហប្រជាជាតិ និង អង្គការផ្លែនអន្តរជាតិ អ្នកស្ម័គ្រចិត្តអន្តរជាតិចំនួន ២៧ នាក់ ក៏ត្រូវបានបញ្ជូនឲ្យទៅផ្តល់ជំនួយ ដល់យុទ្ធនាការចល័តនេះដែរ។

# ប្រទេសឥណ្ឌូនេស៊ី

i. បង្កើតកិច្ចសហការរវាងក្រសួងមហាផ្ទៃ និង ក្រសួងការបរទេស ដើម្បីបង្កើនការគ្រប់ដណ្តប់លើការចុះបញ្ជីនៅក្នុងចំណោមពលរដ្ឋ និង ជនដែលមិនមែនជាពលរដ្ឋ ព្រមទាំង ជនជាតិឥណ្ឌូនេស៊ីដែលរស់នៅក្រៅប្រទេសផងដែរ។ សកម្មភាពសហការគ្នា រួមមាន ឧទាហរណ៍៖ ការរួមបញ្ចូលប្រព័ន្ធផ្តល់សំបុត្រកំណើតនៅស្ថានទូត ការតែងតាំងទីប្រឹក្សាម្នាក់ជាមន្ត្រីអត្រានុកូលដ្ឋាន និង ផ្តល់ការបណ្តុះបណ្តាលនៃការកសាងសមត្ថភាពរួមគ្នា ស្តីពីសេវាចុះបញ្ជីអត្រានុកូលដ្ឋាននៅស្ថានទូត
ii. ធ្វើឌីជីថលនីយកម្មគ្រប់សេវាទាំងអស់នៅថ្នាក់តំបន់ និង ថ្នាក់ក្រុង តាមរយៈការប្រើប្រាស់ប្រព័ន្ធព័ត៌មានរដ្ឋបាល (SIAK) ស្តីពីប្រជាជន
iii. អនុវត្តការកសាងសមត្ថភាព រួមបញ្ចូលទាំង ការបណ្តុះបណ្តាលអំពីការចុះបញ្ជីអត្រានុកូលដ្ឋានសម្រាប់មន្ត្រីមូលដ្ឋានដែលត្រូវបានធ្វើឡើងយ៉ាងតិចពីរដងក្នុងមួយឆ្នាំ
iv. មិនគិតថ្លៃចុះបញ្ជីអត្រានុកូលដ្ឋាន
v. ធ្វើឲ្យដំណើរការចុះបញ្ជី រួមជាមួយ ប្រព័ន្ធពិនិត្យតាមដាន និង វាយតម្លៃមានភាពសាមញ្ញ ព្រមទាំងអភិវឌ្ឍ "Halo Dukcapil" ឬ សេវាអតិថិជនដែលប្រមូលមតិត្រឡប់ពី "អតិថិជន" ផងដែរ ដើម្បីផ្តល់ធាតុចូលសម្រាប់ការធ្វើឲ្យកាន់តែល្អប្រសើរឡើងបន្ថែមទៀតនៅថ្នាក់មូលដ្ឋាន
vi. ប្រើប្រាស់ហត្ថលេខាឌីជីថលសម្រាប់ការចុះបញ្ជីកំណើត ព្រមទាំង ការដំណើរការសំបុត្រកំណត់តាមប្រព័ន្ធអនឡាញផងដែរ។ នេះអនុញ្ញាតឲ្យមានការផ្តល់សេវាដោយមិនចាំបាច់មានការដាក់ពាក្យស្នើសុំដោយផ្ទាល់នោះទេ
vii. រួមបញ្ចូលសេវានានានៅក្នុងការចេញឯកសារសម្រាប់ផ្នែករដ្ឋបាលប្រជាជន។ ការដាក់ពាក្យស្នើសុំចុះបញ្ជីកំណើតតែមួយលើក ផ្តល់ឯកសារយ៉ាងតិច ២ ច្បាប់ ជូនអ្នកដាក់ពាក្យស្នើសុំ៖ សំបុត្រកំណើត សៀវភៅគ្រួសារ អត្តសញ្ញាណប័ណ្ណ។ល។[156]

# ប្រទេសឡាវ

i. រៀបចំយុទ្ធសាស្ត្រចុះបញ្ជីពលរដ្ឋ និង ផ្នែកស្ថិតិ ឆ្នាំ ២០១៦-២០២៥
ii. ធ្វើបច្ចុប្បន្នភាពច្បាប់ស្តីពីការចុះបញ្ជី
iii. បង្កើតអង្គភាពចុះបញ្ជីកំណើតចល័ត
iv. កំណត់គោលដៅថា ត្រឹមឆ្នាំ២០២៤ ពលរដ្ឋ និង ទារកទើបនឹងកើតគ្រប់រូបត្រូវបានចុះបញ្ជី និងយ៉ាងហោចណាស់ ៧០% នៃចំនួនប្រជាជនសរុប មានសំបុត្រកំណើតផ្លូវការ
v. ទទួលយកអនុសាសន៍ដែលត្រូវបានផ្តល់ជូន ស្របតាមការត្រួតពិនិត្យឡើងវិញម្តងម្កាលជាសកល ពាក់ព័ន្ធនឹងការធ្វើទំនើបកម្ម/កំណែទម្រង់ប្រព័ន្ធចុះបញ្ជីកំណើត រួមជាមួយជនបង្គោល ដើម្បីអនុវត្ត។

156 ធាតុចូលបន្ថែមត្រូវបានផ្តល់ជូនដោយជនបង្គោលនៃប្រទេសឥណ្ឌូនេស៊ី នៅថ្ងៃទី២៩ ខែមីនា ឆ្នាំ២០១៩។

# ប្រទេសម៉ាឡេស៊ី

i. បង្កើតគណៈកម្មាធិការចំនួនពីរដើម្បីអនុវត្ត CRVS នៅក្នុងប្រទេសម៉ាឡេស៊ី រួមមាន គណៈកម្មាធិការអចិន្ត្រៃយ៍ និង គណៈកម្មាធិការបច្ចេកទេស ដើម្បីអនុម័តផែនការ ពិនិត្យតាមដានវឌ្ឍនភាពនៃការអនុវត្តវិធីសាស្ត្រ និង ប៉ាន់ប្រមាណអំពីគោលដៅ និង គោលដៅអនុវត្ត ព្រមទាំង របាយការណ៍ដែលត្រូវបានបញ្ជាក់យល់ព្រម នៃសកម្មភាព CRVS នៅប្រទេសម៉ាឡេស៊ីផងដែរ

ii. ពង្រឹងការត្រួតពិនិត្យឡើងវិញជាទៀងទាត់ និង ប្រកបដោយសង្គតភាព នៃរចនាសម្ព័ន្ធ និង ប្រព័ន្ធនានា នៅក្នុងរយៈពេលជាច្រើនឆ្នាំ ជាពិសេស ដោយមានការសម្របតាមបច្ចេកវិទ្យាបច្ចុប្បន្ន និង មូលដ្ឋានគ្រឹះដ៏រឹងមាំនៃក្របខណ្ឌច្បាប់

iii. ធ្វើវិសោធនកម្មច្បាប់ស្តីពីការចុះបញ្ជីកំណើត និង មរណភាព ឆ្នាំ១៩៥៧ នៅក្នុងឆ្នាំ២០១៧[157] ដើម្បីពង្រឹងប្រព័ន្ធទាំងមូលបន្ថែមទៀត

iv. ពន្យារពេលការចុះបញ្ជីកំណើតធម្មតាពី ១៤ថ្ងៃ ទៅ ៦០ថ្ងៃសម្រាប់ឧបទ្វីបម៉ាឡេស៊ីដែលមានប្រសិទ្ធភាពអនុវត្តចាប់ពីខែសីហាឆ្នាំ២០១៧

v. បង្កើតកម្មវិធីនៅខាងក្រៅ ដើម្បីចូលទៅក្បែរសហគមន៍ដែលពិបាកទំនាក់ទនង រួមបញ្ចូលទាំងសហគមន៍នៅតាមតំបន់ជនបទផងដែរ

vi. ប្រើប្រាស់បច្ចេកវិទ្យាផ្ទៀងផ្ទាត់ទិន្នន័យ ដើម្បីពង្រឹងគុណភាពរបស់ស្ថិតិអត្រានុកូលដ្ឋាន ដែលត្រូវបានបង្កើតឡើង។



© UNHCR/Roger Arnold

# ប្រទេសមីយ៉ាន់ម៉ា

i. បង្កើតយុទ្ធនាការចុះបញ្ជីកំណើតរយៈពេលប្រាំថ្ងៃ នៅក្នុងរដ្ឋ/តំបន់ចំនួន ៩ ក្នុងចំណោមរដ្ឋ/តំបន់ទាំង ១៤។ យុទ្ធនាការ ដែលត្រូវបានផ្តល់មគ្គុទ្ទេសក៍ណែនាំដោយ សៀវភៅណែនាំអំពីការចុះបញ្ជីកំណើត និង មរណភាព ដែលត្រូវបានកែសម្រួលឡើងវិញនៅឆ្នាំ២០១៧ នេះ បានជួយសម្រួលដល់ដំណើរការ និង បានរួមចំណែកដល់ការបង្កើនការចុះបញ្ជីកំណើតនៅក្នុងតំបន់ទាំងនោះ

ii. កែសម្រួលសៀវភៅណែនាំអំពីការចុះបញ្ជីកំណើត និង មរណភាព ឆ្នាំ២០១៧ ដើម្បីធ្វើឲ្យដំណើរការមានភាពងាយស្រួលជាងមុន និង មិនស្មុគស្មាញជាងមុន។[158]

157 ទិន្នន័យបន្ថែមត្រូវបានផ្តល់ជូននៅក្នុងការកែសម្រួលការសំយោគនៅក្នុងតំបន់ ដែលត្រូវបានស្នើឡើងដោយជនបង្គោលនៃប្រទេសម៉ាឡេស៊ី។
158 ព័ត៌មានដែលមានបច្ចុប្បន្នភាពត្រូវបានផ្តល់ជូនដោយជនបង្គោលនៃប្រទេសមីយ៉ាន់ម៉ា។

# ប្រទេសហ្វីលីពីន

i. រៀបចំយុទ្ធសាស្រ្តរយៈពេលវែង ព្រមទាំង ទសវត្សរ៍នៃការចុះបញ្ជីកំណើត[159] ដើម្បីបំពេញតាមគោលដៅ ដែលត្រូវបានកំណត់ដោយ ESCAP។ PSA និង LCRs ក៏អនុវត្តវិធីសាស្រ្តនានាដើម្បីជួយសម្រួលដល់ការទទួលបានការចុះបញ្ជីកំណើត និង ការចុះបញ្ជីអត្រានុកូលដ្ឋានរបស់ក្រុមងាយរងគ្រោះផងដែរ។

ii. តាមរយៈ PSA ពង្រឹងប្រព័ន្ធចុះបញ្ជីអត្រានុកូលដ្ឋានរបស់ Barangay Civil Registration System (BCRS) ដែលព្យាយាមយកឈ្នះលើបញ្ហានានានៃការចុះបញ្ជីកំណើត និង ការចុះបញ្ជីអត្រានុកូលដ្ឋាន នៅក្នុងចំណោមក្រុមងាយរងគ្រោះ និង ជនដែលរស់នៅតាមតំបន់ដាច់ស្រយាល



iii តាមរយៈ BCRS ប្រើប្រាស់គ្រោងការណ៍ចុះបញ្ជីចល័ត នៅកន្លែងដែលមន្ត្រីអត្រានុកូលដ្ឋានក្នុងមូលដ្ឋានអនុវត្តយុទ្ធនាការចុះបញ្ជីនៅតាមផ្ទះ នៅតាមភូមិដាច់ស្រយាល ដើម្បីធានាចំពោះការចុះបញ្ជីកំណើត។ នេះរួមបញ្ចូលទាំងការចុះបញ្ជីចល័តនៅតាម barangays ដែលនៅឆ្ងាយផងដែរ។ សេវាចុះបញ្ជីចល័តត្រូវបានផ្តល់ជូនដោយឥតគិតថ្លៃ ហើយនឹងរួមបញ្ចូលការបង្កើនការយល់ដឹងអំពីគុណប្រយោជន៍នៃការចុះបញ្ជីអត្រានុកូលដ្ឋានផងដែរ។ ភាពញឹកញាប់នៃការចុះបញ្ជីចល័ត អាស្រ័យលើតម្រូវការរបស់ barangay នីមួយៗ ដែលអាចដាក់សំណើតាមរយៈក្រុមប្រឹក្សា Barangay របស់ខ្លួន

iv. ជម្រុញឲ្យ LCROs និង ភាគីពាក់ព័ន្ធដទៃទៀត នៅក្នុងអំឡុងខែចុះបញ្ជីអត្រានុកូលដ្ឋាន ចូលរួមនៅក្នុងយុទ្ធនាការនេះ តាមរយៈការស្នើផ្តល់ការចុះបញ្ជីព្រឹត្តិការណ៍អត្រានុកូលដ្ឋានដោយឥតគិតថ្លៃ ការចេញសំបុត្រកំណើតដោយឥតគិតថ្លៃនៅអង្គភាពរដ្ឋាភិបាលមូលដ្ឋាន រៀបចំពិធីមង្គលការច្រើនគូ សិក្ខាសាលាការបង្រៀន និង វេទិកានានា និង ស្នើផ្តល់សេវាចុះបញ្ជីអត្រានុកូលដ្ឋានដទៃទៀតដែលពាក់ព័ន្ធ

v. អនុវត្តការដង្ហែរក្បែចុះបញ្ជីដោយឥតគិតថ្លៃ ឆ្លងកាត់រដ្ឋាភិបាលមូលដ្ឋានខុសៗគ្នា នៅទូទាំងប្រទេស ជាពិសេសនៅក្នុងអំឡុងខែចុះបញ្ជីអត្រានុកូលដ្ឋាន (ខែកុម្ភៈ) នៅក្នុងចំណោមប្រជាជនដែលងាយរងគ្រោះ ដូចជា ជនជាតិដើមភាគតិច សហគមន៍ម៉ូស្លីម និង ក្រុមដទៃទៀត

vi. ចាប់ផ្តើមអនុវត្តប្រព័ន្ធផ្តល់រង្វាន់ ដើម្បីលើកទឹកចិត្តរដ្ឋាភិបាលមូលដ្ឋានឲ្យលើកកម្ពស់ការចុះបញ្ជីអត្រានុកូលដ្ឋាន។ នៅឆ្នាំ២០១៤ PSA បានចាប់ផ្តើមអនុវត្តប្រព័ន្ធផ្តល់រង្វាន់ ដែលទទួលស្គាល់ការិយាល័យចុះបញ្ជីអត្រានុកូលដ្ឋាននៃរដ្ឋាភិបាលមូលដ្ឋាននៅ ១០ លំដាប់លើគេ ពាក់ព័ន្ធនឹងយុទ្ធនាការដ៏សកម្មរបស់ពួកគេចំពោះការចុះបញ្ជីអត្រានុកូល-ដ្ឋាន។ ការផ្តល់គ្រឿងលើកទឹកចិត្តដល់ LGUs ដើម្បីលើកកម្ពស់ការចុះបញ្ជីអត្រានុកូលដ្ឋាន បានជួយបង្កើនការផ្តល់ឯកសារកំណើត និង ព្រឹត្តិការណ៍អត្រានុកូលដ្ឋានដទៃទៀត។




vii. រៀបចំសិក្ខាសាលាស្តីពីការចុះបញ្ជីអត្រានុកូលដ្ឋាន។ PSA បានរៀបចំសិក្ខាសាលាថ្នាក់ជាតិស្តីពីការចុះបញ្ជីអត្រានុកូលដ្ឋានរៀងរាល់ពីរឆ្នាំម្តង ដើម្បីផ្តល់បច្ចុប្បន្នភាពជូនមន្ត្រីអត្រានុកូលដ្ឋាន និង ភាគីពាក់ព័ន្ធដទៃទៀត អំពីច្បាប់ គោលនយោបាយ និង នីតិវិធីសម្រាប់ការចុះបញ្ជីអត្រានុកូល-ដ្ឋាន

viii. សហការជាមួយដៃគូឯកជន។ PSA បានរួមបញ្ចូល និង ទទួលបានសេវានានាពីដៃគូឯកជន សម្រាប់ការធ្វើឌីជីថលនីយកម្ម។ការចុះបញ្ជីព្រឹត្តិការណ៍អត្រានុកូលដ្ឋាន។ សេវាគ្រប់គ្រង UNYSIS បានចាប់ផ្តើមធ្វើឌីជីថលនីយកម្ម។ការចុះបញ្ជី កាលពីខែវិច្ឆិកា ឆ្នាំ២០១៨ ដោយបានបង្កើតទីតាំងផ្តល់សេវាសម្រាប់ខេត្តនីមួយៗ ដែលពង្រឹងប្រសិទ្ធភាពនៃការចុះបញ្ជី និង ការស្នើសុំឯកសារ។ នេះគឺជាការបង្កើនភាពជាដៃគូ ដែលកើតឡើងរវាង PSA និង SM Malls នៅទូទាំងប្រទេស ដែលផ្តល់ទីធ្លាទំនេរសម្រាប់ការចុះបញ្ជី និង ការស្នើសុំឯកសារនៅនឹងកន្លែង

---

159 ឆ្នាំ២០១៥ រហូតដល់ឆ្នាំ២០២៤ គឺជា "ទសវត្សរ៍នៃការចុះបញ្ជីកំណើត និង ស្ថិតិអត្រានុកូលដ្ឋាន" នៅប្រទេសហ្វីលីពីន។

ix. លើកលែងថ្លៃសេវានានា (រួមបញ្ចូលទាំងថ្លៃសេវាសម្រាប់ការចុះបញ្ជីយឺតពេលផងដែរ) សម្រាប់ក្រុមជនជាតិដើមភាគតិច និង ក្រុមជនក្រីក្រដទៃទៀតនៅតាមទីតាំងនានា ដូចជាទីក្រុង Davao ជាដើម។ ស្រដៀងគ្នានេះដែរ នៅទីក្រុង Glan នៃខេត្ត Sarangani (ឆ្នាំ២០១៦) និងទីក្រុង Jose Abad Santos នៃខេត្ត Davao Occidental (ឆ្នាំ២០១៧) ក្រុមប្រឹក្សានីតិបញ្ញត្តិក្នុងមូលដ្ឋានរៀងៗគ្នា បានអនុម័តសេចក្តីសម្រេចមួយ ដោយលើកលែងការទូទាត់ថ្លៃសេវាចុះបញ្ជីកំណើត និង ប្រាក់ពិន័យសម្រាប់ការចុះបញ្ជីយឺតពេល រួមបញ្ចូលទាំង ថ្លៃសេវាកែតម្រូវការបញ្ចូលទិន្នន័យដោយស្មៀនផងដែរ សម្រាប់ជនក្រីក្រនៃប្រទេសឥណ្ឌូនេស៊ី ដែលជាចំនួនប្រជាជនភាគច្រើន

x. រៀបចំវេទិកាជាមួយទីភ្នាក់ងាររដ្ឋាភិបាល LCR រៀបចំវេទិកាអ្នកប្រើប្រាស់ ជាទៀងទាត់ ជាមួយទីភ្នាក់ងារ រដ្ឋាភិបាលខុសៗគ្នា ដូចជា នាយកដ្ឋានការបរទេស គណៈកម្មការនិយ័តកម្មវិជ្ជាជីវៈ នាយកដ្ឋានសុខាភិបាល នាយកដ្ឋានសេវាសង្គម និង ការិយាល័យអភិវឌ្ឍ ព្រមទាំងភាគីពាក់ព័ន្ធដទៃទៀត រួមបញ្ចូលទាំង អង្គភាពឯកជនផងដែរ ដើម្បីផ្តល់បច្ចុប្បន្នភាពជូនពួកគេ អំពីការអភិវឌ្ឍការចុះបញ្ជីអត្រានុកូលដ្ឋាននាពេលថ្មីៗនេះ។ វេទិកានេះអនុញ្ញាតឲ្យទីភ្នាក់ងារដែលពាក់ព័ន្ធ និង ភាគីពាក់ព័ន្ធដឹងអំពីវិធីដែលមន្ត្រីអត្រានុកូលដ្ឋានក្នុងមូលដ្ឋាន និង PSA ដោះស្រាយបញ្ហាការចុះបញ្ជីអត្រានុកូលដ្ឋាន។ ជាចុងក្រោយ វេទិកានេះត្រូវបានរៀបចំឡើងវិញនៅថ្នាក់ជាតិ ដោយ PSA ជាអ្នកដឹកនាំ





xi. បង្កើតប្រព័ន្ធចុះបញ្ជីនៅតាមសាលារៀននៅទីក្រុង Davao ដោយត្រូវបានបញ្ចូលសម្លេងជា "Sa paaralan kp pwede nang magparehistro"។ គម្រោងនេះបានបង្កើតទីតាំងចុះបញ្ជីអត្រានុកូលដ្ឋាននៅក្នុងសាលារៀននៅតំបន់ដាច់ស្រយាល ជាពិសេស សាលារៀននៅតំបន់ដែលមានជនជាតិដើមភាគតិចរស់នៅ។ វត្ថុបំណងចម្បង គឺដើម្បីធានាថា មុនពេលដែលសិស្សានុសិស្សបានបញ្ចប់បឋមសិក្សា (ថ្នាក់ទី ៤) កំណត់ត្រារបស់ពួកគេនឹងត្រូវបានកែតម្រូវ និងសម្រេចបានការចុះបញ្ជីកំណើតរបស់ពួកគេ និង ឯកសារតាមផ្លូវច្បាប់ដទៃទៀត។ គម្រោងនេះបានចាប់ផ្តើមសាលារៀនចំនួន ១១ ខ្នងនៅក្នុងឆ្នាំ២០១១ និង បានគ្របដណ្តប់លើសាលារៀនចំនួន ៤០ ខ្នងនៅក្នុងឆ្នាំ២០១៨។ ការិយាល័យចុះបញ្ជីអត្រានុកូលដ្ឋានប្រចាំទីក្រុង (CCRO) បានធ្វើការយ៉ាងជិតស្និទ្ធជាមួយនាយកដ្ឋានអប់រំ (DepEd)។ ពួកគេបានជ្រើសរើសគ្រូបង្រៀនដែលស័ក្តិសមបំផុត រួមបញ្ចូលទាំង គ្រូបង្រៀនចល័តនៃប្រព័ន្ធរៀនសូត្រតាមវិធីជំនួស (ALS) ផងដែរ ដែលត្រូវឆ្លងកាត់ការបណ្តុះបណ្តាលស្តីពីការចុះបញ្ជីអត្រានុកូលដ្ឋាន នៅខាងក្រៅចំនួនពីរថ្ងៃ និង ការបណ្តុះបណ្តាលនៅពេលបំពេញការងារចំនួនដប់ប្រាំថ្ងៃ នៅការិយាល័យ CCRO ប្រចាំស្រុកខុសៗគ្នា។ គ្រូបង្រៀនទាំងនេះស្ថិតនៅក្រោមការគ្រប់គ្រងរបស់ចៅហ្វាយស្រុក ហើយពួកគេមានសិទ្ធិទទួលបានប្រាក់លើកទឹកចិត្តពី CCRO ដែលជាផ្នែកមួយនៃគម្រោង អាស្រ័យលើនីតិវិធីគណនេយ្យ និង សវនកម្មដែលរដ្ឋាភិបាលមានស្រាប់



xii. ផ្តល់ការចុះបញ្ជីដល់ក្រុមដែលប្រឈមនឹងហានិភ័យ។ "Rehistro nyo, sagot ng gobyerno" ទីក្រុង Davao ផ្តល់ការចុះបញ្ជីកំណើតដល់ជនជាតិដើមភាគតិច អ្នកកាន់សាសនាគ្រិស្ត និង អ្នកកាន់សាសនាអ៊ីស្លាមដែលក្រីក្រ កុមារទំនាស់នឹងច្បាប់ (CICL) និង កុមារដែលត្រូវការការការពារជាពិសេស (CNSP)។ នេះរួមបញ្ចូល "kasalan ng bayan" ឬ ការរៀបមង្គលការច្រើនគូ សម្រាប់មាតាបិតានៅក្នុងក្រុមគោលដៅដូចគ្នា។ រាល់ចំណាយទាំងអស់ត្រូវបានរ៉ាប់រងដោយ CCRO រួមបញ្ចូលទាំង ថ្លៃសេវាចុះបញ្ជីកំណើត ការបញ្ជាក់កំណើតអវិជ្ជមានពី NSO ឬ ការចេញលិខិតបញ្ជាក់មិនធ្លាប់រៀបអាពាហ៍ពិពាហ៍ (CENOMAR) ផងដែរ។ ពុំមានថ្លៃដឹកជញ្ជូនសម្រាប់សមាសភាពដែលភាគច្រើនមកពីតំបន់ដាច់ស្រយាលនោះទេ ពីព្រោះ CCRO អនុវត្តការចុះបញ្ជីចល័ត។

xiii. បង្កើតគម្រោងបង្គោល។ គម្រោងសុខភាពទូទាំង Mindanao រួមបញ្ចូលទាំងការចុះបញ្ជីកំណើតសម្រាប់ជនជាតិដើមភាគតិចនៅក្នុងតំបន់ត្រូវបានជ្រើសរើសនៃ Mindanao។ គម្រោងជនជាតិដើមភាគតិច-មាតា ទារកទើបនឹងកើត សុខភាពកុមារ និងអាហារូបត្ថម្ភ (IP MNCHN) ដែលបានទទួលមូល-និធិពីសហគមន៍អឺរ៉ុប មានបំណងរួមចំណែកដល់ការកែលម្អយ៉ាងសំខាន់ និង ប្រកបដោយនិរន្តភាព ផ្នែកសុខភាពមាតា និងកុមារនៅតាមសហគមន៍គោលដៅនៅក្នុង Mindanao។ គម្រោងនេះត្រូវបានអនុវត្ត ជាចម្បងដោយគណៈកម្មការជាតិស្តីពីជនជាតិដើមភាគតិច សហការជាមួយមូលនិធិសហប្រជាជាតិសម្រាប់ប្រជាជន (UNFPA) ដែលជាដៃគូដ៏សំខាន់។ ដោយសារតែការចុះបញ្ជីកំណើត នៅមានកម្រិតទាបនៅក្នុងចំណោម IPs ការចុះបញ្ជីកំណើត នៅខាងក្រៅសហគមន៍/ដោយចល័ត ត្រូវបានដាក់បញ្ចូលជាផ្នែកមួយនៃគម្រោងនេះ

xiv. ផ្តួចផ្តើមគំនិតកិច្ចសហការទ្វេភាគី តាមរយៈគម្រោងរួមគ្នា ជុំវិញការចុះបញ្ជីនៅក្នុងបរិបទទេសន្តរប្រវេសន៍ ដូចជា គម្រោងរួមគ្នារវាងរដ្ឋាភិបាលហ្វីលីពីន និង រដ្ឋាភិបាលឥណ្ឌូនេស៊ី ស្តីពីការចុះបញ្ជី និង ការបញ្ជាក់អំពីសញ្ជាតិរបស់ជនក្រីក្រនៃប្រទេសឥណ្ឌូនេស៊ី (PIDS) នៅ Mindanao ដែលទទួលបានមូលនិធិពី UNHCR។ រដ្ឋាភិបាលទាំងពីរបានព្រមព្រៀងគ្នាកាលពីខែកុម្ភៈ ឆ្នាំ២០១៤ លើការកំណត់ឋានៈតាមផ្លូវច្បាប់របស់ PIDs ស្របតាមផែនការសកម្មភាព ឆ្នាំ២០១៤-២០១៦ របស់ពួកគេដែលជាចំណុចចាប់ផ្តើមនៃគម្រោង PID។ តាមរយៈការអនុវត្តខុសៗគ្នា PIDs សរុបចំនួន ៨.៧៤៥ នាក់ត្រូវបានចុះបញ្ជីនៅក្នុងគម្រោងនេះ ដែលបានផ្តល់អត្ថប្រយោជន៍ដល់ពលរដ្ឋទាំងពីរប្រទេស ដែលបានទទួលការបញ្ជាក់ ព្រមទាំងជនដែលត្រូវបានកំណត់ដោយភាពជាពលរដ្ឋទាំងពីរប្រទេស ដែលបានកំណត់ថាជាពលរដ្ឋហ្វីលីពីន និង ជាពលរដ្ឋឥណ្ឌូនេស៊ីផងដែរ។ មកទល់សព្វថ្ងៃ ៧៧% នៃអ្នកដែលបានចុះបញ្ជី PID បានទទួលដំណោះ ស្រាយរយៈពេលវែង តាមរយៈការបញ្ជាក់អំពីឋានៈនៃភាពជាពលរដ្ឋរបស់ពួកគេរួចរាល់ហើយ នៅខណៈ ពេលដែល ២៣% កំពុងតែស្ថិតនៅក្រោមការត្រួត ពិនិត្យពាក្យស្នើសុំរបស់ពួកគេឡើងវិញ ជាលើកចុង ក្រោយដោយ DOJ-RSPPU។[160]

គំនិតផ្តួចផ្តើមនេះបានបង្ហាញ អំពីទម្លាប់អនុវត្តល្អនៅក្នុងការដោះស្រាយបញ្ហា ដែលទាក់ទងនឹងភាពគ្មានសញ្ជាតិ។ ប្រទេសហ្វីលីពីនចាត់ទុកគម្រោង PID ថាជាព្រឹត្តិការណ៍ ដ៏សំខាន់មួយនៅក្នុងការដោះស្រាយបញ្ហាភាពគ្មានសញ្ជាតិ ឬ ជនដែលប្រឈមមុខនឹងហានិភ័យនៃការមានឋានៈបែបនោះនៅក្នុងប្រទេស។ គម្រោងនេះក៏ ស្របតាមផែនការសកម្មភាពជាតិ(NAP) របស់រដ្ឋាភិបាល ដើម្បីបញ្ចប់ភាពគ្មានសញ្ជាតិ ដែលត្រូវបានអភិវឌ្ឍឡើងនៅក្នុងឆ្នាំ២០១៥ ដោយអនុវត្តតាមរចនាបថរបស់ UNHCR ២០១៤ ១-Belong Global ផងដែរ។[161] ករណីនេះគឺជាឧទាហរណ៍មួយដ៏ល្អមួយ ពីការព្រមព្រៀងទ្វេភាគីដើម្បីដោះស្រាយបញ្ហានៃការទទួលបានការចុះបញ្ជីកំណើត ដល់ជនដែលប្រឈមមុខនឹងហានិភ័យ នៃភាពគ្មានសញ្ជាតិ ព្រមទាំង បញ្ហានានានៃភាពគ្មានសញ្ជាតិដោយផ្ទាល់ផងដែរ។



© UNHCR/Roger Arnold

160 ធាតុចូលបន្ថែមត្រូវបានផ្តល់ជូនដោយជនបង្គោលនៃប្រទេសហ្វីលីពីន។
161 Ibid.

i. នៅឆ្នាំ២០១៦ ប្រទេសសិង្ហបុរី បានធ្វើឲ្យដំណើរការចុះបញ្ជីកំណើតមាន ប្រសិទ្ធភាពតាមរយៈឌីជីថលនីយកម្មជាទម្រង់ជូនដំណឹងអំពីកំណើតរស់ (NLB)។ NLB គឺជាឯកសារដ៏ចាំបាច់មួយដែលចេញដោយវេជ្ជបណ្ឌិត/ឆ្មប ដើម្បីបញ្ជាក់អំពីកំណើតរបស់កុមារម្នាក់នៅក្នុងប្រទេសសិង្ហបុរី។ នៅលើ NLB នីមួយៗ មានលេខរៀងដ៏ពិសេសមួយដែលត្រូវបានប្រើប្រាស់ដើម្បីចាប់ផ្តើមការចុះបញ្ជីកំណើត។ ដំណើរការនេះធានាថា រាល់កំណើតរស់ទាំងអស់នៅក្នុងប្រទេសសិង្ហបុរីមានកំណត់ត្រាចុះបញ្ជីកំណើតតែមួយប៉ុណ្ណោះ នៅក្នុងមូលដ្ឋានទិន្នន័យថ្នាក់ជាតិ។ ឪពុកម្តាយត្រូវបានតម្រូវឲ្យប្រគល់ NLB សម្រាប់ការចុះបញ្ជីកំណើត ពីព្រោះកំណត់ត្រាអំពីកំណើតរបស់កុមារ គឺផ្អែកលើព័ត៌មានលម្អិតដែលមាននៅក្នុង NLB នោះ។ NLB ក៏ជាប្រភពឯកសារ សម្រាប់តាមដានរាល់កំណើតរស់ទាំងអស់ដែលកើត នៅក្នុងប្រទេសសិង្ហបុរី និង ពិនិត្យតាមដានករណីដែលឪពុកម្តាយមិនទាន់បានចុះបញ្ជីកំណើតជូនកូន របស់ពួកគេផងដែរ។ តាមរយៈឌីជីថលនីយកម្ម។ NLB វេជ្ជបណ្ឌិត/ឆ្មប មិនចាំបាច់ត្រូវបំពេញទម្រង់ ដោយដៃទៀតនោះទេ។ ព័ត៌មាន របស់កុមារ និង ឪពុកម្តាយនឹងត្រូវបំពេញតាមប្រព័ន្ធអេឡិចត្រូនិចនៅក្នុង e-NLB ដោយប្រព័ន្ធគ្រប់គ្រងរបស់មន្ទីរពេទ្យ។ ទិន្នន័យ e-NLB ទាំងអស់នឹងត្រូវបញ្ជូនទៅកាន់មូលដ្ឋានទិន្នន័យ របស់រដ្ឋាភិបាល ក្នុងគោលបំណងធ្វើការតាមដាន។ ឪពុកម្តាយមិនចាំបាច់ប្រគល់ NLB សម្រាប់ការចុះបញ្ជីកំណើតទៀតនោះទេ ពីព្រោះរាល់កំណត់ត្រាមានជាស្រេច នៅក្នុងមូលដ្ឋានទិន្នន័យរបស់រដ្ឋាភិបាល។ ដំណើរ ការនេះកាត់បន្ថយពេលវេលា ដែលត្រូវចំណាយលើប្រតិបត្តិការនៅតាមបញ្ជរនានា សម្រាប់ការចុះបញ្ជីកំណើត

ii. ណែនាំអំពីការចុះបញ្ជីអនឡាញ។ បន្ទាប់ពីទទួលបានជោគជ័យនៅក្នុងការអនុវត្ត e-NLB រួចរាល់ហើយ ប្រទេសសិង្ហបុរី កំពុងតែណែនាំអំពីការចុះបញ្ជីកំណើត អនឡាញ។ ប្រទេសសិង្ហបុរីបានអភិវឌ្ឍកម្មវិធីនៅលើឧបករណ៍ចល័តមួយ ដែលត្រូវបានអនុវត្តសាក ល្បងកាលពីខែមិថុនា ឆ្នាំ២០១៨ ដើម្បីផ្តល់សរោចរកចញ្ចេលតម្មែយដល់ឪពុកម្តាយ តាមរយៈការរួមបញ្ចូលគ្នានូវការចុះបញ្ជីកំណើតអនឡាញ និងកម្ម វិធីផ្តល់ប្រាក់រង្វាន់ដល់ទារក នៅក្នុងទម្រង់អេឡិចត្រូនិចតែមួយ។ កម្មវិធីចល័តផ្តល់បណ្តាញបន្ថមែមួយដល់ឪពុកម្តាយនៅក្នុងការចុះបញ្ជីកំណើតកូន របស់ពួកគេនៅគ្រប់ពេល និង ប្រកបដោយផាសុកភាព នៅក្នុងផ្ទះរបស់ពួកគេផ្ទាល់ ដោយប្រើប្រាស់ឧប-ករណ៍ចល័ត ដោយមិនចាំបាច់ត្រូវបំពេញទម្រង់បែប បទដោយដៃនោះទេ។



# ប្រទេសថៃ

i. ធ្វើវិសោធនកម្មច្បាប់ ស្តីពីការចុះបញ្ជីអត្រានុកូលដ្ឋាន ឆ្នាំ១៩៩១ (ព.ស. ២៥៣៤) (កែសម្រួលលើកទី២) ឆ្នាំ២០០៨ (ព.ស. ២៥៥១) ដែលចែងថា មន្ត្រីអត្រានុកូលដ្ឋានត្រូវដំណើរការ ការចុះបញ្ជីអត្រានុកូលដ្ឋាន សម្រាប់ជនគ្មានសញ្ជាតិនៅក្នុងលក្ខណៈដូចគ្នានឹងករណីរបស់ជនជាតិថៃដែរ ពោលគឺ ១) ទទួលស្គាល់ការជូនដំណឹងអំពីកំណើត ឬ ចុះបញ្ជីកំណើត និង ចេញសំបុត្រកំណើតជូនជនគ្រប់រូប ដែលកើតនៅក្នុងព្រះរាជាណាចក្រថៃ ដោយមិនគិតអំពីប្រភេទឋានៈជាជនបរទេស របស់ឪពុកម្តាយកុមារនោះទេ ឬថាតើពួកគេមានឯកសារអត្រានុកូលដ្ឋាន ឬ អត់នោះទេ ២) បង្កើតប្រវត្តិរូបនៅក្នុងមូលដ្ឋានទិន្នន័យសម្រាប់ជនគ្មានសញ្ជាតិ យោងតាមសេចក្តីសម្រេចរបស់ខុទ្ទកាល័យ ព្រមទាំងច្បាប់ស្តីពីការចុះបញ្ជីអត្រានុកូលដ្ឋាន (មាត្រា ៣៨ កថាខណ្ឌទី២) និង ៣) ផ្តល់អត្តសញ្ញាណប័ណ្ណសម្រាប់ជនដែលគ្មានសញ្ជាតិថៃ និង ជនដែលគ្មានឋានៈនៃការចុះបញ្ជីអត្រានុកូលដ្ឋាន

ii. ការបង្កើត "គម្រោងអភិវឌ្ឍការចុះបញ្ជីកំណើត" ក្រសួងសុខាភិបាលសាធារណៈ នាយកដ្ឋានរដ្ឋបាលខេត្តនៃក្រសួងមហាផ្ទៃ និង ការិយាល័យគាំពារសុខភាពជាតិ (NHSO) សហការជាមួយមូលនិធិអង្គការសហប្រជាជាតិដើម្បីកុមារ (UNICEF) បានផ្តួចផ្តើមគំនិតបង្កើត "គម្រោងអភិវឌ្ឍការចុះបញ្ជីកំណើត" ដើម្បីធានាចំពោះសិទ្ធិរបស់កុមារគ្រប់រូប ដែលកើតនៅប្រទេសថៃ រួមបញ្ចូលទាំង កុមារថៃ និង កុមារបរទេសផងដែរ។ មន្ទីរពេទ្យរដ្ឋនៅទូទាំងប្រទេស ត្រូវបានស្នើសុំឲ្យ ចូលរួមនៅក្នុងប្រព័ន្ធពិនិត្យតាមដានការចុះបញ្ជីអត្រានុកូលដ្ឋាន។ នៅចន្លោះឆ្នាំ២០១១ ដល់ឆ្នាំ២០១៣ គម្រោងនេះបានបណ្តាលឲ្យមានការថយចុះនៃចំនួនកុមារ ដែលមិនបានចុះបញ្ជីកំណើត នៅក្នុងរយៈពេល១៥ថ្ងៃ។ ក្រសួងសុខាភិបាលសាធារណៈ NHSO និង ទីភ្នាក់ងារដែលពាក់ព័ន្ធដទៃទៀត កំពុងដំណើរការការអភិវឌ្ឍប្រព័ន្ធចុះបញ្ជីដើម្បីសម្រេចគោលដៅ (ដែលកំណត់ដោយ ESCAP)។ ទោះបីជាគម្រោងនេះ ទទួលបានជោគជ័យក៏ដោយ ក៏គេបានមើលឃើញថា ពុំទាន់មានទីភ្នាក់ងារណាមួយទទួលបន្ទុកលើការប្រមូលព័ត៌មាន អំពីកុមារ ដែលកើតនៅខាងក្រៅមន្ទីរពេទ្យ និង កុមារដែលគេមិនអើពើនោះទេ។

# ប្រទេសវៀតណាម

របាយការណ៍របស់ប្រទេសវៀតណាមបានសម្គាល់ឃើញបញ្ជីដ៏វែងមួយនៃគំនិតផ្តួចផ្តើមនានា ដែលអាចយកមកពិចារណាថាជាទម្លាប់អនុវត្តល្អៗ ដោយផ្អែកលើការអនុម័តច្បាប់ស្តីពីអត្រានុកូលដ្ឋាន ឆ្នាំ២០១៤៖

i. ការអនុម័តច្បាប់ស្តីពីអត្រានុកូលដ្ឋាន នៅថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០១៤ និង បានចូលជាធរមាននៅថ្ងៃទី០១ ខែមករា ឆ្នាំ២០១៥។ ច្បាប់នេះរួមបញ្ចូលធាតុសំខាន់ៗ ដែលរួមចំណែកដល់កំណែទម្រង់ដ៏ខ្លាំងក្លានៃការចុះបញ្ជី និង ការគ្រប់គ្រងអត្រានុកូលដ្ឋាន ជាពិសេស និង ការគ្រប់គ្រងប្រជាជនជាទូទៅ។ យោងតាមច្បាប់ស្តីពីអត្រានុកូលដ្ឋាន បន្ថែមពីលើនីតិស្តីពីការចុះបញ្ជី និង ការគ្រប់គ្រងអត្រានុកូលដ្ឋាន ក៏បានផ្តល់ជូននូវបញ្ញត្តិមូលដ្ឋានថ្មីៗផងដែរ ដូចជា ការផ្តល់លេខអត្តសញ្ញាណកម្មផ្ទាល់ខ្លួន រួមជាមួយ ការចុះបញ្ជីកំណើត កំណែទម្រង់នីតិវិធីរដ្ឋបាល និង ការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាន យ៉ាងខ្លាំងក្លានៅក្នុងការចុះបញ្ជី និង ការគ្រប់គ្រងអត្រានុកូលដ្ឋាន (ដោយធ្វើឲ្យមានភាពសាមញ្ញ និង កាត់បន្ថយ

ឯកសារមិនចាំបាច់ជាច្រើន នៅក្នុងការចុះបញ្ជីអត្រានុកូលដ្ឋាន)។ ស្របពេលជាមួយគ្នានោះ ច្បាប់នេះចែងយ៉ាងច្បាស់អំពីបទដ្ឋាន លក្ខណៈសម្បត្តិ និង ទំនួលខុសត្រូវរបស់មន្ត្រីរាជការដែលបម្រើការងារផ្នែកអត្រានុកូលដ្ឋាន ព្រមទាំងទំនួលខុសត្រូវរបស់ប្រធានគណៈកម្មាធិការប្រជាជន នៅគ្រប់កម្រិតទាំងអស់ ពាក់ព័ន្ធនឹងកំហុសឆ្គង និងការរំលោភបំពានលើការ ចុះបញ្ជី និងការគ្រប់គ្រងអត្រានុកូលដ្ឋានផងដែរ។ បុគ្គលទាំងឡាយមានសិទ្ធិជ្រើសរើសគល់បញ្ជីអត្រានុកូលដ្ឋានសម្រាប់ខ្លួនឯង ដោយមិនគិតអំពីទីលំនៅរបស់ពួកគេកាលពីមុននោះទេ(អត្រានុកូលដ្ឋានប្រហែលជា ត្រូវបានចុះនៅទីលំនៅអចិន្ត្រៃយ៍ ទីលំនៅបណ្តោះអាសន្ន ឬ ទីលំនៅបច្ចុប្បន្នរបស់ពួកគេ)

ii. បើកចំហរបណ្តាញកាន់តែច្រើនសម្រាប់ការដាក់ជូននូវទម្រង់បែបបទនានា ដែលអាចដាក់ជូនដោយផ្ទាល់ តាមរយៈប្រៃសណីយ៍ ឬតាមរយៈប្រព័ន្ធចុះបញ្ជីអត្រានុកូលដ្ឋាន កាត់បន្ថយពេលវេលាដែលមានកំណត់ សម្រាប់ការបញ្ចប់កិច្ចការអត្រានុកូលដ្ឋានភាគច្រើន

iii. បង្កើតមូលដ្ឋានទិន្នន័យពលរដ្ឋ តាមប្រព័ន្ធអេឡិចត្រូនិច ដើម្បីរក្សាទុកព័ត៌មានស្តីពីអត្រានុកូលដ្ឋានរបស់បុគ្គលទាំងឡាយ និងដើម្បីភ្ជាប់ទៅកាន់មូលដ្ឋានទិន្នន័យថ្នាក់ជាតិស្តីពីប្រជាជន និង ផ្តល់ជូនមូលដ្ឋានទិន្នន័យនោះ នូវព័ត៌មានអត្រានុកូលដ្ឋានកម្រិតមូលដ្ឋានរបស់បុគ្គលទាំងឡាយ។ នៅថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០១៥ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌បានចុះហត្ថលេខាលើសេចក្តីសម្រេចលេខ ២១៧៣/QD-BTP ស្តីពីការចេញគម្រោងមូលដ្ឋានទិន្នន័យពលរដ្ឋតាមប្រព័ន្ធអេឡិចត្រូនិចនៅទូទាំងប្រទេស។ បន្ទាប់ពីមានការអនុវត្តជាផ្លូវការនូវសូហ្វវែរចុះបញ្ជីកំណើត ដែលភ្ជាប់ទំនាក់ទំនងការចុះបញ្ជីកំណើតទៅនឹងការចេញលេខអត្តសញ្ញាណកម្មផ្ទាល់ខ្លួន សម្រាប់កុមារនៅតាមទីភ្នាក់ងារចុះបញ្ជីអត្រានុកូលដ្ឋាន (ថ្នាក់ឃុំ និងស្រុក) នៃទីក្រុងចំនួន ៤ (ហាណូយ ហូជីមិញ ដាណាំង ហៃផុង) និង ស្រុក Que Phong ខេត្ត Nghe An ចាប់ពីថ្ងៃទី០១ ខែមករា ឆ្នាំ២០១៦ រហូតមកដល់បច្ចុប្បន្ន ក្រសួងយុត្តិធម៌បានបន្តពង្រីកការដាក់បញ្ចូលខេត្ត និង ក្រុងចំនួន ១៦ ឲ្យស្ថិតនៅក្រោមរដ្ឋាភិបាលកណ្តាល និង បានអនុវត្តសាកល្បងនៅក្នុងស្រុក Bac Ai នៃខេត្ត Ninh Thuan។ គេបានរំពឹងទុកថាក្នុងឆ្នាំ២០២០ មូលដ្ឋានទិន្នន័យពលរដ្ឋតាមប្រព័ន្ធអេឡិចត្រូនិចនៅទូទាំងប្រទេស នឹងរួមបញ្ចូលទិន្នន័យដែលទទួលបានពី ៦៣ ខេត្ត/ក្រុងនៅទូទាំងប្រទេស។ ព័ត៌មានដែលបានចុះបញ្ជីអំពីកំណើត មរណភាព និង អាពាហ៍ពិពាហ៍ ត្រូវបានរួមបញ្ចូលគ្នាដោយក្រសួងយុត្តិធម៌ បន្ទាប់មកបោះពុម្ពផ្សាយនៅលើគេហទំព័ររបស់ខ្លួន និងផ្ញើជូនទីភ្នាក់ងារដែលពាក់ព័ន្ធស្របតាមច្បាប់ស្តីពីស្ថិតិ ឆ្នាំ២០១៥



iv. ធ្វើវិមជ្ឈការ និង ធ្វើអនុប្បទានទៅកាន់រដ្ឋបាលមូលដ្ឋាន សម្រាប់ការអនុវត្តសកម្មភាពនានា ដូចជាការដោះស្រាយបញ្ហាអត្រានុកូលដ្ឋានដែលពាក់ព័ន្ធនឹងជនបរទេស ការកែប្រែ ឬ កែតម្រូវអត្រានុកូលដ្ឋានរបស់និវាសនជនដែលមានអាយុ ១៤ ឆ្នាំឡើងទៅ កំណត់ឡើងវិញនូវសញ្ជាតិរបស់អ្នកណាម្នាក់។ល។



v. អនុម័តផែនការសកម្មភាពថ្នាក់ជាតិ សម្រាប់ការចុះបញ្ជី និង ស្ថិតិអត្រានុកូលដ្ឋាន ឆ្នាំ២០១៥-២០២៤ ដើម្បីធានាចំពោះ ការចុះបញ្ជីអត្រានុកូលដ្ឋានបានទាន់ពេលវេលាពេញលេញនិងត្រឹមត្រូវ សម្រាប់ពលរដ្ឋវៀតណាមជនបរទេសដែលស្នាក់នៅប្រទេសវៀតណាម និងពលរដ្ឋវៀតណាមដែលរស់នៅក្រៅប្រទេស ដោយអនុលោមតាមបញ្ញត្តិនៃច្បាប់។ ផែនការនេះក៏មានបំណងពង្រឹងការសម្របសម្រួល រវាងទីភ្នាក់ងារដែលពាក់ព័ន្ធផងដែរ

vi. អនុស្សរណៈយោគយល់គ្នា សម្រាប់ជនទេសន្តរប្រវេសន៍ដោយឯកឯង[162] នៅជុំវិញតំបន់ព្រំដែនប្រទេសវៀតណាម-ឡាវ រដ្ឋាភិបាលនៃសាធារណរដ្ឋសង្គមនិយមវៀតណាម និងរដ្ឋាភិបាលនៃសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ បានចុះហត្ថលេខាលើអនុស្សរណៈយោគយល់គ្នាស្តីពីការដោះស្រាយទេសន្តរប្រវេសន៍ដោយឯកឯង និងកំណើត ដែលឪពុកម្តាយមិនបានរៀបអាពាហ៍ពិពាហ៍តាមផ្លូវច្បាប់។ កិច្ចព្រមព្រៀងនេះផ្តល់សិទ្ធិអំណាចដល់ការសម្របសម្រួលដំណោះស្រាយ ចំពោះបញ្ហាខាងលើ រៀបចំផែនការ និង ផែនទីបង្ហាញផ្លូវសម្រាប់អនុវត្តខ្លឹមសារនៃកិច្ចព្រមព្រៀង ប្រភេទឯកសារ ទម្រង់បែបបទ និង វិធីដោះស្រាយបញ្ហាដែលពាក់ព័ន្ធ។ កិច្ចព្រមព្រៀងនេះបានបន្តសុពលភាព តាមរយៈសេចក្តីសម្រេចលេខ ២៣២៤/QD-CTN ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ ២០១៦។ កិច្ចព្រមព្រៀងនេះត្រូវបានបន្តរយៈពេលបីឆ្នាំ ចាប់ពីកាលបរិច្ឆេទចេញសេចក្តីប្រកាសនេះ

vii. ពង្រឹងប្រព័ន្ធចុះបញ្ជីអត្រានុកូលដ្ឋាន និង ស្ថិតិអត្រានុកូលដ្ឋាន ដែលរួមបញ្ចូលទាំងការបង្កើនកម្រិតនៃការចុះបញ្ជីកំណើតនៅក្នុងចំណោមក្រុមប្រឈមនឹងហានិភ័យផងដែរ ដើម្បីទប់ស្កាត់ភាពគ្មានសញ្ជាតិ និង ការអនុវត្តវិធីសាស្ត្រនានា ជាពិសេស សម្រាប់ក្រុមពិបាកឈោងចាប់ និងក្រុមដែលគេមិនអើពើ រួមបញ្ចូលទាំងការចូលរួមពីសំណាក់សហគមន៍ ការសហការ និងការបង្កើនការយល់ដឹង ដើម្បីជួយសម្រួលដល់ការទទួលបានឯកសារអត្តសញ្ញាណ

viii. ការពារសិទ្ធិនានាតាមរយៈច្បាប់៖ ច្បាប់កុមារឆ្នាំ២០១៦ ចែងថា កុមារមានសិទ្ធិទទួលបានការចុះបញ្ជីកំណើត មរណភាព នាមត្រកូល និង សញ្ជាតិរបស់ពួកគេ ស្របតាមច្បាប់។ ច្បាប់នេះក៏ទទួលស្គាល់សិទ្ធិរបស់កុមារដែលគ្មានសញ្ជាតិវៀតណាម ដែលកំពុងរស់នៅ និងធ្វើការនៅក្នុងប្រទេសវៀតណាម កុមារដែលរស់នៅក្នុងប្រទេសផ្សេងទៀត ដែលកំពុងតែដាក់ពាក្យស្នើសុំសិទ្ធិជ្រកកោន កុមារភៀសខ្លួនដោយគ្មានមនុស្សពេញវ័យមកជាមួយ ត្រូវស្ថិតនៅក្រោមការការពាររបស់ប្រទេសវៀតណាម និង អ្នកទទួលផលពីការថែទាំជំនួសផងដែរ

ix. នីតិវិធីតាមរយៈផ្លូវច្បាប់ត្រូវបានបង្កើត៖ ច្បាប់ស្តីពីអត្រានុកូលដ្ឋាន ឆ្នាំ២០១៤ ចែងអំពីនីតិវិធីចុះបញ្ជីកំណើតសម្រាប់កុមារ រួមបញ្ចូលទាំងនៅក្នុងករណីរបស់កុមារគេបោះបង់ចោល ដោយសារឪពុកម្តាយរបស់ពួកគេគ្មានសញ្ជាតិ ដើម្បីធានាចំពោះការផ្តល់សំបុត្រកំណើតដល់កុមារគ្រប់រូបនៅក្នុងដែនដីវៀតណាម និង ធានាថាកុមារគ្រប់រូបដែលកើតនៅក្នុងដែនដីវៀតណាមមានសញ្ជាតិវៀតណាម

x. រៀបចំកំណែទម្រង់រដ្ឋបាល៖ រដ្ឋាភិបាលវៀតណាមបន្តកិច្ចខិតខំប្រឹងប្រែងរបស់ខ្លួនដើម្បីអនុវត្តកំណែទម្រង់រដ្ឋបាលនៃការងារចុះបញ្ជីកំណើត ចុះបញ្ជីអត្រានុកូលដ្ឋាន និងសញ្ជាតិ។ នៅថ្ងៃទី០៤ ខែសីហា ឆ្នាំ២០១៤ រដ្ឋាភិបាលបានចេញសេចក្តីសម្រេចលេខ ១២៩៩/QD-TTg ដែលឯកភាពលើគ្រោងការណ៍ភ្ជាប់ទំនាក់ទំនងទៅវិញទៅមករវាងការចុះបញ្ជីកំណើត ការចុះបញ្ជីទីលំនៅអចិន្ត្រៃយ៍ និងការផ្តល់ប័ណ្ណធានារ៉ាប់រងសុខភាព សម្រាប់កុមារដែលមានអាយុក្រោម ៦ ឆ្នាំ។ ផ្អែកលើសេចក្តីសម្រេចនេះ គណៈកម្មាធិការនៃគ្រប់មូលដ្ឋានទាំងអស់ បានដាក់ចេញនូវផែនការ

162 ពាក្យ “ជនទេសន្តរប្រវេសន៍ដោយឯកឯង” ត្រូវបានប្រើប្រាស់ជាផ្លូវការនៅក្នុងប្រទេសវៀតណាម ដើម្បីកំណត់និយមន័យរបស់ជនដែលមិនដឹងអំពីសញ្ជាតិរបស់ខ្លួន និង បានឆ្លងព្រំដែនដោយឯកឯង ដើម្បីទៅស្នាក់នៅក្នុងតំបន់ព្រំដែននៅខាងវៀតណាម។

សម្រាប់អនុវត្តសេចក្តីសម្រេចនេះនៅទូទាំងប្រទេស។ នេះគឺជាគំរូអនុវត្ត “៣ រួមបញ្ចូលតែ ១” ដែលដោះស្រាយការចុះបញ្ជីកំណើត ការចុះបញ្ជីទីលំនៅអចិន្ត្រៃយ៍ និងការផ្តល់ប័ណ្ណធានារ៉ាប់រងសុខភាពរបស់កុមារ ធានាថាពួកគេបំពេញតាមលក្ខណវិនិច្ឆ័យនៃការចាត់តាំងយ៉ាងឆាប់រហ័ស ដែលមានចំនួនតិច ប្រកបដោយប្រសិទ្ធភាព និងសន្សំសំចៃធនធាន។ កន្លងមក ប្រជាជនត្រូវទៅកាន់ទីភ្នាក់ងារខុសៗគ្នាចំនួនបី ដើម្បីបំពេញនីតិវិធីទាំងនេះមួយម្តងៗ រួមមាន៖ ទៅកាន់គណៈកម្មាធិការប្រជាជនដើម្បីចុះបញ្ជីកំណើត ទៅកាន់នគរបាលដើម្បីចុះបញ្ជីទីលំនៅអចិន្ត្រៃយ៍ និង ទៅកាន់ទីភ្នាក់ងារធានារ៉ាប់រងសង្គមដើម្បីចុះបញ្ជីទទួលប័ណ្ណធានារ៉ាប់រងសុខភាព។ បច្ចុប្បន្ននេះ ប្រជាជនអាចត្រូវទៅកាន់ទីភ្នាក់ងារតែមួយប៉ុណ្ណោះដើម្បីបញ្ចប់កិច្ចការទាំងអស់នេះ

xi. ផ្តួចផ្តើមគំនិតបង្កើតសេវាដឹកជញ្ជូនដល់ផ្ទះ។ គណៈកម្មាធិការប្រចាំទីក្រុងដាណាងបានផ្តួចផ្តើមគំនិតបង្កើតសេវាដឹកជញ្ជូនសំបុត្រកំណើត សៀវភៅចុះបញ្ជីទីលំនៅអចិន្ត្រៃយ៍ និងប័ណ្ណធានារ៉ាប់រងសុខភាពសម្រាប់ក្មេងដែលទើបនឹងកើត ទៅដល់ផ្ទះផងដែរ នៅក្នុងករណីដែលឪពុកម្តាយរបស់ពួកគេបានបំពេញនីតិវិធីនៃការចុះបញ្ជីកំណើតនៅគណៈ កម្មាធិការ ថ្នាក់ឃុំ តំបន់ ឬ ស្រុករួចរាល់។ ឪពុកម្តាយត្រូវទទួលបានសំបុត្រកំណើត សៀវភៅចុះបញ្ជីគ្រួសារ និង ប័ណ្ណធានារ៉ាប់រងសុខភាព ក្នុងរយៈពេលមិនលើសពីមួយថ្ងៃ ចាប់ពីកាលបរិច្ឆេទចេញលទ្ធផលនៃនីតិវិធីរដ្ឋបាលនោះទេ។

មានទម្លាប់អនុវត្តល្អៗមួយចំនួនដែលត្រូវបាន សម្គាល់ឃើញនៅក្នុងរបាយកាណ៍ប្រចាំប្រទេសនីមួយៗ។ ចំណុចដែលដូចគ្នាច្រើនបំផុតគឺ កំណែទម្រង់ និងការអនុម័តច្បាប់/ការធ្វើវិសោធនកម្មច្បាប់ពាក់ព័ន្ធនឹងការចុះបញ្ជីកំណើត និងការចុះបញ្ជីអត្រានុកូលដ្ឋាន។ ការបង្កើតក្រុមការងារចុះបញ្ជីចល័តក៏ត្រូវបានលើកឡើងដោយប្រទេសមួយចំនួនផងដែរ។ គំនិតផ្តួចផ្តើមជាច្រើនត្រូវបានបង្កើតឡើងដើម្បីភ្ជាប់ទំនាក់ទំនងជាមួយក្រុមពិបាកឈោងចាប់ ដែលរស់នៅតាមតំបន់ដាច់ស្រយាល។ យុទ្ធនាការបង្កើនការយល់ដឹង និងផ្តល់ព័ត៌មាន ក៏មានភាពទូទៅគួរសមដែរ នៅក្នុងបណ្តាលប្រទេសជាច្រើន។ គំនិតផ្តួចផ្តើមដែលគួរឲ្យចាប់អារម្មណ៍មួយចំនួន គឺជាការផ្តួចផ្តើមនៃការចុះបញ្ជីនៅតាមសាលារៀននៃប្រទេសហ្វីលីពីន ព្រមទាំង កិច្ចសហការជាមួយទីភ្នាក់ងាររដ្ឋាភិបាលដែលពាក់ព័ន្ធដទៃទៀត (ក្រសួងសុខាភិបាល និងមន្ទីរពេទ្យនានា) នៅក្នុងករណីរបស់ប្រទេសហ្វីលីពីន ប្រទេសថៃ និង ប្រទេសវៀតណាម។ សេវាច្រកចេញចូលតែមួយ ឬ គំរូ ៣ រួមបញ្ចូលតែ ១ នៅប្រទេសវៀតណាម ផ្តល់គំរូដ៏ល្អមួយសម្រាប់ឲ្យប្រទេសដទៃទៀតយកទៅពិចារណា។ ប្រទេសសិង្ហបុរីបានជ្រើសរើសអនុវត្ត កុំព្យូទ័រភាវូបនីយកម្ម និងចុងក្រោយ ឌីជីថលនីយកម្ម គឺជាចំណុចសំខាន់ដើម្បីសម្រេចបានការចុះបញ្ជីកំណើតជាសកល និងគោលដៅនៃ “រួមបញ្ចូលអ្នករាល់គ្នានៅក្នុងរូបភាព” និង “ការមិនទុកនរណាម្នាក់ចោល” ។



# ៣. សញ្ជាតិ និង ភាពជាពលរដ្ឋនៅអាស៊ាន[163]



163 កថាខណ្ឌមួយចំនួននៃផ្នែកសេចក្តីផ្តើមនេះត្រូវបានយកចេញពីឧបករណ៍ប៉ាន់ប្រមាណអំពីការចុះបញ្ជីអត្រានុកូលដ្ឋានក្រោមដំណើរការបាលី ដែលត្រូវបានរៀបចំដោយការិយាល័យគាំទ្រនៅក្នុងតំបន់សម្រាប់ដំណើរការបាលី (RSO) ដោយមានការកែសម្រួលនានា។

## ៣.១ សេចក្តីផ្តើម

សិទ្ធិទទួលបានសញ្ជាតិ ត្រូវបានទទួលស្គាល់ដោយសន្ធិសញ្ញាសិទ្ធិមនុស្សអន្តរជាតិ ដែលរួមបញ្ចូលទាំងមាត្រា ១៥ នៃសេចក្តីប្រកាសជាសកល ស្តីពីសិទ្ធិមនុស្ស ឆ្នាំ១៩៤៨ ផងដែរ។[164] សិទ្ធិនេះក៏បានរំលេច នៅក្នុងអនុសញ្ញាអន្តរជាតិចំនួនបីផងដែរ រួមមាន CRC, CEDAW និង CRPD ដែលរដ្ឋសមាជិកអាស៊ានទាំងអស់គឺជាភាគីនៃអនុសញ្ញាទាំងនេះ។

មាត្រា៧ នៃ CRC មិនត្រឹមតែបញ្ញត្តិអំពីសិទ្ធិរបស់កុមារ ក្នុងការទទួលបានការចុះបញ្ជីកំណើតតែប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងទទួលស្គាល់សិទ្ធិទទួលបានសញ្ជាតិផងដែរ។ មាត្រាដដែលនេះ ធ្វើឲ្យរដ្ឋភាគីមានកាតព្វកិច្ចធានាចំពោះការអនុវត្តសិទ្ធិនានាស្របតាមច្បាប់ជាតិ និងកាតព្វកិច្ចរបស់ពួកគេស្របតាមលិខិតូបករណ៍អន្តរជាតិ ដែលពាក់ព័ន្ធនៅ ក្នុងវិស័យនេះ ជាពិសេសនៅកន្លែងដែលកុមារអាចនឹងគ្មានសញ្ជាតិ។[165] ក្នុងគោលបំណងដូចគ្នា CEDAW បានដាក់ភារកិច្ចលើរដ្ឋក្នុងការ “ផ្តល់ជូនស្ត្រីនូវសិទ្ធិស្មើគ្នានឹងបុរស ក្នុងការទទួលផ្លាស់ប្តូរ ឬរក្សាទុកសញ្ជាតិរបស់ខ្លួន។ រដ្ឋភាគីត្រូវធានាជាពិសេសថា ការរៀបអាពាហ៍ពិពាហ៍ជាមួយជនបរទេស ឬការផ្លាស់ប្តូរសញ្ជាតិ របស់ប្តីក្នុងពេលអាពាហ៍ពិពាហ៍ មិនធ្វើឲ្យផ្លាស់ប្តូរជាស្វ័យប្រវត្តិនូវសញ្ជាតិរបស់ប្រពន្ធ មិនធ្វើឲ្យប្រពន្ធគ្មានសញ្ជាតិ ឬ បង្ខំឲ្យប្រពន្ធទទួលយកសញ្ជាតិរបស់ប្តីឡើយ។ អនុសញ្ញានេះបានបញ្ជាក់បន្ថែមទៀតដែរថា រដ្ឋភាគីត្រូវផ្តល់ជូនស្ត្រីនូវសិទ្ធិស្មើគ្នានឹងបុរស ពាក់ព័ន្ធនឹងសញ្ជាតិរបស់កូន”។[166] កថាខណ្ឌទី១ នៃ មាត្រា ១៨ នៃ CRPD ចែងថា នៅក្នុងចំណោមលក្ខខណ្ឌតម្រូវដទៃទៀត រដ្ឋភាគីត្រូវទទួលស្គាល់សិទ្ធិរបស់ជនពិការចំពោះសញ្ជាតិ ដោយឈរលើមូលដ្ឋានស្មើភាពគ្នាជាមួយអ្នកដទៃ។[167] ដូចគ្នាដែរ យោងតាមមាត្រា ១៨(១)(ក) នៃ CRPD រដ្ឋត្រូវធានាថាជនពិការមានសិទ្ធិទទួលបាន និង ប្តូរសញ្ជាតិ ហើយមិនត្រូវដកហូតសញ្ជាតិរបស់ពួកគេ ដោយមិនសមហេតុផល ឬដោយសារតែពិការភាពនោះទេ។ មាត្រា ១៨(១)(ខ) នៃ CRPD ចែងបន្ថែមទៀតថា ជនពិការមិនត្រូវដកហូត លទ្ធភាពរបស់ពួកគេក្នុងការទទួលបាន កាន់កាប់ និងប្រើប្រាស់ឯកសារសញ្ជាតិ ឬឯកសារបញ្ជាក់អត្តសញ្ញាណដទៃទៀត ឬក្នុងការប្រើប្រាស់នីតិវិធីពាក់ព័ន្ធនានា ដូចជា នីតិវិធីអន្តោប្រវេសន៍ជាដើម ដោយសារតែពិការភាពនោះទេ ដែលពួកគេអាចត្រូវការ ដើម្បីសម្រួលដល់ការអនុវត្តសិទ្ធិមានសេរីភាពក្នុងការធ្វើដំណើរ។[168] កថាខណ្ឌទី២ នៃ មាត្រា ១៨ ទទួលស្គាល់ថា កុមារពិការមានសិទ្ធិទទួលបានសញ្ជាតិ។[169]

សេចក្តីប្រកាសសិទ្ធិមនុស្សអាស៊ាន (AHRD) ទទួលស្គាល់សិទ្ធិរបស់មនុស្សគ្រប់រូបក្នុងការទទួលបានសញ្ជាតិ ដូចបានបញ្ញត្តិដោយច្បាប់ និង សង្កត់ធ្ងន់ថា ពុំមានអ្នកណាម្នាក់ត្រូវបានដកហូតសញ្ជាតិតាមអំពើចិត្តនោះទេ និងត្រូវបានបដិសេធចំពោះការផ្លាស់ប្តូរសញ្ជាតិនោះទេ។ វាមានតម្លៃនៅក្នុងការកត់សម្គាល់ថា គោលការណ៍ទូទៅរបស់ AHRD មាត្រា ២ ហាមឃាត់ចំពោះការរើសអើង ដោយសារតែពិការភាព និង មាត្រា ៣ ទទួលស្គាល់សិទ្ធិស្មើភាពគ្នារបស់មនុស្សគ្រប់រូបនៅចំពោះមុខច្បាប់ និងថាមនុស្សគ្រប់រូបមានសិទ្ធិទទួលការការពារពីច្បាប់ដោយគ្មានការរើសអើង។[170]

164 មាត្រា ១៥ នៃ UDHR៖

(១) មនុស្សគ្រប់រូបមានសិទ្ធិទទួលបានសញ្ជាតិមួយ។

(២) ពុំមានអ្នកណាម្នាក់ត្រូវបានគេដកហូតសញ្ជាតិរបស់គាត់តាមអំពើចិត្ត និង ត្រូវបានបដិសេធចំពោះសិទ្ធិធ្វើការផ្លាស់ប្តូរសញ្ជាតិរបស់គាត់នោះទេ”។

165 CRC មាត្រា ៧ កថាខណ្ឌទី២។

166 CEDAW មាត្រា ៩។

167 CRPD មាត្រា ១៨។

168 CRPD មាត្រា ១៨។

169 Ibid.

170 AHRD។

កង្វះខាតការចុះបញ្ជីកំណើតអាចបង្កើតហានិភ័យនៃភាពគ្មានសញ្ជាតិ។ ការចុះបញ្ជីកំណើត គឺជាទង្វើតាមផ្លូវច្បាប់ដ៏សំខាន់មួយពីព្រោះ វាបង្កើតកំណត់ត្រាអចិន្ត្រៃយ៍ តាមផ្លូវច្បាប់នៃវត្តមានរបស់កុមារ ប៉ុន្តែការចុះបញ្ជី



កំណើតកុមារម្នាក់ មិនបានផ្តល់ជូនកុមារនោះដោយស្វ័យប្រវត្តិនូវសញ្ជាតិនៃរដ្ឋ ដែលកុមារា ឬ កុមារី កើតនោះទេ។[171]

> “ កង្វះខាតការចុះបញ្ជីអត្រានុកូលដ្ឋាន និង ឯកសារដែលពាក់ព័ន្ធ ធ្វើឲ្យជនងាយរងគ្រោះដោយសារភាពគ្មានសញ្ជាតិ និង ហានិភ័យនៃការការពារដែលពាក់ព័ន្ធ និងថា ការចុះបញ្ជីកំណើត ជាញឹកញាប់ មានសារសំខាន់ចំពោះការកាត់បន្ថយ និង ការទប់ស្កាត់ភាពគ្មានសញ្ជាតិ

ផ្ទុយមកវិញ សញ្ជាតិត្រូវបានទទួលស្របតាមប្រតិបត្តិការនៃច្បាប់ស្តីសញ្ជាតិនៃរដ្ឋនីមួយៗ។ នេះអាចផ្អែកលើដើមកំណើត ដែលកុមារទទួលបានសញ្ជាតិពីឪពុកម្តាយរបស់ពួកគេ (jus sanguinis) ឬ តាមរយៈកំណើតរបស់កុមារ នៅក្នុងដែនដីនៃប្រទេសមួយ (jus soli) ឬ តាមរយៈការរួមបញ្ចូលនៃអភិក្រម ទាំងនេះដែលមានចែងនៅក្នុងបញ្ញត្តិដ៏លម្អិតនៃច្បាប់ជាតិ។ រដ្ឋសមាជិកអាស៊ាន (AMS) ទាំងអស់បានបង្កើតច្បាប់ និងនីតិវិធីនានាដែលមានការកំណត់ និងកត់ត្រាសញ្ជាតិរបស់កុមារ នៅពេលដែលកំណើតរបស់កុមារត្រូវបានចុះបញ្ជី។

ការចុះបញ្ជីកំណើតកុមារអាចបង្កើតទម្រង់ ដ៏សំខាន់មួយនៃការបញ្ជាក់អះអាងអំពីទំនាក់ទំនងរវាងបុគ្គល និង រដ្ឋ តាមរយៈការបង្កើតកំណត់ត្រាអចិន្ត្រៃយ៍នៃធាតុសំខាន់ៗនៃអត្តសញ្ញាណរបស់កុមារ រួមបញ្ចូលទាំងថ្ងៃខែឆ្នាំកំណើត និង ទីកន្លែងកំណើត និង អត្តសញ្ញាណរបស់ឪពុកម្តាយរបស់គាត់ ឬនាងផងដែរ។ ជាញឹកញាប់ ព័ត៌មាននេះមានសារសំខាន់នៅក្នុងការបង្កើតសញ្ជាតិរបស់កុមារម្នាក់ ស្របតាមច្បាប់ស្តីពីសញ្ជាតិ

171 សម្រាប់ព័ត៌មានបន្ថែម សូមមើលកំណត់សម្គាល់ព័ត៌មាន E ស្តីពីការចុះបញ្ជីអត្រានុកូលដ្ឋាន សញ្ជាតិ និង សិទ្ធិមនុស្ស៖ http://www.getinthepicture.org/sites/default/files/resources/Information_Note_E_%20Civil_Registration_Nationality_and_Human_Rights.pdf

ខុសៗគ្នា នៃរដ្ឋដែលកុមារ ឬ កុមារីមានទំនាក់ទំនងជាមួយ។ ជាលទ្ធផល គណៈកម្មាធិការប្រតិបត្តិនៃឧត្តមស្នងការទទួលបន្ទុកជនភៀសខ្លួន បានកត់សម្គាល់ថា **"កង្វះខាតការចុះបញ្ជីអត្រានុកូលដ្ឋាន និង ឯកសារដែលពាក់ព័ន្ធ ធ្វើឲ្យជនងាយរងគ្រោះដោយសារភាពគ្មានសញ្ជាតិ និងហានិភ័យនៃការការពារដែលពាក់ព័ន្ធ និងការចុះបញ្ជីកំណើត ជាញឹកញាប់ មានសារសំខាន់ចំពោះការកាត់បន្ថយ និង ការទប់ស្កាត់ភាពគ្មានសញ្ជាតិ"**។[172]

"កង្វះខាតការចុះបញ្ជីអត្រានុកូលដ្ឋាន និង ឯកសារដែលពាក់ព័ន្ធ ធ្វើឲ្យជនងាយរងគ្រោះដោយសារភាពគ្មានសញ្ជាតិ និងហានិភ័យនៃការការពារដែលពាក់ព័ន្ធ និងថាការចុះបញ្ជីកំណើត ជាញឹកញាប់ មានសារសំខាន់ចំពោះការកាត់បន្ថយ និង ការទប់ស្កាត់ភាពគ្មានសញ្ជាតិ

ការចុះបញ្ជីកំណើត និងអាពាហ៍ពិពាហ៍បង្កើតកំណត់ត្រា និង ឯកសារដែលបញ្ជាក់អំពីទំនាក់ទំនងរវាងមនុស្សម្នាក់ និង រដ្ឋ រួមបញ្ចូលទាំងរដ្ឋនៃសញ្ជាតិរបស់ឪពុកម្តាយ ឬស្វាមី/ភរិយារបស់ពួកគេ ព្រមទាំងរដ្ឋដែលមនុស្សម្នាក់នោះកើតផងដែរ ក្នុងករណីចុះបញ្ជីកំណើត។ ការងារនេះអនុញ្ញាតឲ្យពួកគេទទួលបានសញ្ជាតិ ស្របតាមច្បាប់ស្តីពីសញ្ជាតិដែលពាក់ព័ន្ធ។ មិនមែនមនុស្សគ្រប់រូបដែលមិនបានចុះបញ្ជីកំណើតសុទ្ធតែជាជនគ្មានសញ្ជាតិនោះទេ។ ទោះបីជាយ៉ាងណាក៏ដោយ ចំពោះអ្នកដែលបានកើតនៅក្នុងស្ថានភាពមួយចំនួន (ឧ. ឪពុកម្តាយមានសញ្ជាតិខុសគ្នា នៅក្នុងកន្លែងធ្វើទេសន្តរប្រវេសន៍ មានឪពុកម្តាយជាជនភៀសខ្លួន ឬ អ្នកស្វែងរកសិទ្ធិជ្រកកោន ឬ នៅតាមតំបន់ព្រំដែន) កង្វះខាតការចុះបញ្ជីកំណើតអាចបណ្តាលឲ្យគ្មានសញ្ជាតិ។ កំណត់ត្រាអាពាហ៍ពិពាហ៍របស់ឪពុកម្តាយពួកគេនៅក្នុងប្រព័ន្ធចុះបញ្ជីអត្រានុកូលដ្ឋានចម្បង ក៏អាចមានសារសំខាន់ចំពោះកុមារ ក្នុងការទទួលបានសញ្ជាតិតាមរយៈដើមកំណើតពីឪពុក/ម្តាយផងដែរ ជាពិសេស នៅក្នុងរដ្ឋដែលឈ្មោះរបស់ឪពុក/ម្តាយមិនអាចបន្ថែមចូលទៅក្នុងសំបុត្រកំណើតបាន ដោយគ្មានអាពាហ៍ពិពាហ៍របស់ឪពុកម្តាយ ដែលត្រូវបានបញ្ជាក់អះអាង តាមរយៈសំបុត្រអាពាហ៍ពិពាហ៍នោះទេ។ នៅក្នុងរដ្ឋមួយចំនួន ប្រសិនបើមិនបានចុះបញ្ជីអាពាហ៍ពិពាហ៍ទេនោះ កូនក៏នឹងមិនអាចទទួលបានសញ្ជាតិរបស់ឪពុកដោយស្របច្បាប់ដែរ។

ស្រដៀងគ្នាដែរ ទីលំនៅស្របច្បាប់នៅក្នុងដែនដីរបស់រដ្ឋមួយ តាមធម្មតា មិនត្រូវបានកំណត់ដោយវិធានដែលគ្រប់គ្រងការចុះបញ្ជីអត្រានុកូលដ្ឋាននោះទេ។ សញ្ជាតិ ឬភាពជាពលរដ្ឋ តាមធម្មតា រួមបញ្ចូលសិទ្ធិចូលក្នុង និង ស្នាក់នៅនៅលើដែនដីនៃរដ្ឋមួយ។[173] លើសពីនេះទៀត រដ្ឋ តាមធម្មតា មានច្បាប់ និង បទប្បញ្ញត្តិលម្អិត ដែលចែងអំពីវិធាននានា ទាក់ទងនឹងការចូលក្នុងដែនដី និងការស្នាក់នៅរបស់ជនដែលមិនមែនជាពលរដ្ឋ រួមបញ្ចូលទាំង ជនគ្មានសញ្ជាតិផងដែរ។ ការចុះបញ្ជីអត្រានុកូលដ្ឋានអាចជួយបង្កើតទំនាក់ទំនងគ្រួសារ ដូចជា ទំនាក់ទំនងស្វាមីភរិយាជាដើម ដែលអាស្រ័យតាមច្បាប់ និងបទប្បញ្ញត្តិដែលមានស្រាប់ អាចជួយបង្កើតសិទ្ធិចូលក្នុងដែនដីរបស់រដ្ឋមួយ ឬ សិទ្ធិស្នាក់នៅយ៉ាងស្របច្បាប់នៅក្នុងដែនដីនោះ។

រដ្ឋជាសមាជិកអាស៊ាន (AMS) ខុសៗគ្នា មានច្បាប់ស្តីពីសញ្ជាតិ ឬ ភាពជាពលរដ្ឋ ដែលគ្រប់គ្រងលើការផ្តល់សិទ្ធិទទួលបានសញ្ជាតិ ដោយមានលក្ខខណ្ឌផ្ទាល់ខ្លួនរបស់ពួកគេ។ លក្ខខណ្ឌទូទៅបំផុតគឺ ឪពុកម្តាយម្ខាង ឬ ទាំងសងខាង ជាពលរដ្ឋនៃរដ្ឋជាក់លាក់នោះ។ តារាងទី៣ នៅក្នុងឧបសម្ព័ន្ធ (ចូរមើលទំព័រទី ១១៤) បង្ហាញអំពីច្បាប់ និងគោលនយោបាយទាក់ទងនឹងសញ្ជាតិដែលមានស្រាប់ នៅក្នុង AMS ទាំង១០។

172 សេចក្តីសន្និដ្ឋានអំពីការចុះបញ្ជីកំណើត ដែលត្រូវបានរកឃើញនៅក្នុងរបាយការណ៍នៃកិច្ចប្រជុំលើកទី ៦៤ នៃគណៈកម្មាធិការអចិន្ត្រៃយ៍នៃកម្មវិធីរបស់ឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកជនភៀសខ្លួន ទីក្រុងហ្សឺណែវ ខែកញ្ញា ឆ្នាំ២០១៣។

173 UNHCR ឆ្នាំ២០១៤. សៀវភៅណែនាំរបស់ UNHCR ស្តីពីការការពារជនគ្មានសញ្ជាតិ ទំព័រទី ២២ កថាខណ្ឌទី ៥៣។ អាចស្វែងរកបាននៅ៖ Handbook on Protecting Stateless Persons, pp. 22, para 53. Available at: http://www.refworld.org/docid/53b676aa4.html

## ៣.២ ច្បាប់ និង គោលនយោបាយដែលទាក់ទងនឹងសញ្ជាតិ និងភាពជាពលរដ្ឋ នៅអាស៊ាន

នៅអាស៊ាន រដ្ឋភាគច្រើនអនុវត្តគោលការណ៍ jus sanguinis ចំពោះការទទួលបានសញ្ជាតិ ដែលមានន័យថា គេទទួលបានសញ្ជាតិតាមរយៈខ្សែស្រឡាយ។ ប្រទេសកម្ពុជា ប្រទេសថៃ និង ប្រទេសវៀតណាមអនុវត្តទាំងគោលការណ៍ jus sanguinis និង jus soli។ នៅប្រទេសប្រ៊ុយណេដារូសាឡឹម ជំពូកទី១៥ នៃច្បាប់ស្តីពីសញ្ជាតិប្រ៊ុយណេ ចែងថាសញ្ជាតិត្រូវបានកំណត់ដោយការមានឪពុកម្តាយម្ខាង ឬ ទាំងសងខាង ជាពលរដ្ឋ។[174] ទោះបីជាយ៉ាងណាក៏ដោយ របាយការណ៍បង្ហាញអំពីលក្ខខណ្ឌតម្រូវខុសៗគ្នា សម្រាប់កុមារដែលមានឪពុកម្តាយបានរៀបអាពាហ៍ពិពាហ៍ និង កុមារដែលឪពុកម្តាយ មិនបានរៀបអាពាហ៍ពិពាហ៍ដោយមានម្តាយ/ឪពុកតែម្ខាងជាពលរដ្ឋ និង ជនដែលត្រូវបានទទួលស្គាល់ជាទូទៅថា ជាសមាជិករបស់ក្រុមជនជាតិដើមភាគតិចនៃជាតិសាសន៍ Malay រួមមាន Belait, Bisayah, Brunei, Dusun, Kedayan, Murut ឬ Tutong។ កំណើត ឬ ការស្នាក់នៅរបស់ឪពុកក៏មានតួនាទីសំខាន់នៅក្នុងការកំណត់សញ្ជាតិរបស់កូនដែលឪពុកម្តាយមិនបានរៀបអាពាហ៍ពិពាហ៍ផងដែរ។[175]

ច្បាប់ស្តីពីសញ្ជាតិ (ឆ្នាំ១៩៩៦) របស់ប្រទេសកម្ពុជា មានលក្ខណៈបើកចំហរច្រើន ដែលច្បាប់នេះបានអនុវត្តទាំង "jus sanguinis" និង "jus sol"i។ ជំពូក ២ មាត្រា ៤ ចំណុចទី២ ចែងថា សញ្ជាតិ/ភាពជាពលរដ្ឋខ្មែរ អាចទទួលបានតាមរយៈការកើតនៅក្នុងប្រទេសកម្ពុជា ដែល ក) កុមារម្នាក់ដែលមានម្តាយជាជនបរទេស និងឪពុកបានកើត និង រស់នៅដោយស្របតាមនៅក្នុងព្រះរាជាណាចក្រកម្ពុជា ឬ ខ) កុមារម្នាក់ដែលមិនស្គាល់ឪពុកម្តាយបានកើតនៅក្នុងព្រះរាជាណាចក្រកម្ពុជា។[176] នេះរួមបញ្ចូលទាំងកុមារ ដែលមានលក្ខណៈស្រប ច្បាប់ និង មិនស្របច្បាប់ផងដែរ។ របាយការណ៍ប្រចាំប្រទេសឥណ្ឌូនេស៊ី មិនបានផ្តល់ព័ត៌មានអំពីសញ្ជាតិ និង ភាពជាពលរដ្ឋនោះទេ។[177]

ករណី ប្រទេសឡាវ គឺគួរឲ្យចាប់អារម្មណ៍ ពីព្រោះច្បាប់ស្តីពីសញ្ជាតិឡាវបានកំណត់និយមន័យជនដែលមានសញ្ជាតិ ពលរដ្ឋ និង ជនដែលមិនមែនជាពលរដ្ឋបានច្បាស់លាស់គួរសម។[178] ពាក្យ"ពលរដ្ឋ" ត្រូវបានកំណត់និយមន័យយ៉ាងទូលំទូលាយ ដោយសំដៅលើ "ពលរដ្ឋឡាវ ជនបរទេស និងជនដែលមិនមែនជាពលរដ្ឋដែលរស់នៅក្នុងប្រទេសឡាវ"។[179] គេទទួលបានសញ្ជាតិឡាវតាមរយៈកំណើត នៅពេលដែលឪពុក ឬម្តាយម្នាក់ ឬទាំងពីរនាក់គឺជាពលរដ្ឋឡាវ (ដោយមិនគិតអំពីទីលំនៅរបស់ពួកគេនោះទេ) តាមរយៈសញ្ជាតូបនីយកម្ម ការទទួលបានសញ្ជាតិឡាវម្តងទៀត និងមធ្យោបាយដទៃទៀតដូចដែល បានបញ្ញត្តិដោយច្បាប់ស្តីពីសញ្ជាតិឡាវ។[180] ច្បាប់ដែលគ្រប់គ្រងភាពជាពលរដ្ឋ នៅក្នុងប្រទេសម៉ាឡេស៊ី គឺរដ្ឋធម្មនុញ្ញរបស់សហព័ន្ធ។ ផ្នែកទាំងមូលនៃរដ្ឋធម្មនុញ្ញរបស់សហព័ន្ធ ពោលគឺ ផ្នែកទី៣ មានបីជំពូក ផ្តោតលើប្រធានបទនៃភាពជាពលរដ្ឋ។ ជំពូក ១ និយាយអំពីការទទួលបានភាពជាពលរដ្ឋ ជំពូក ២ និយាយអំពីការបញ្ឈប់ភាព ជាពលរដ្ឋ និង ជំពូក ៣ មានបញ្ញត្តិបន្ថែម។ ជំពូក I ផ្នែក III នៃរដ្ឋធម្មនុញ្ញរបស់សហព័ន្ធចែងថា ភាពជាពលរដ្ឋ

---

174 របាយការណ៍ប្រចាំប្រទេសប្រ៊ុយណេដារូសាឡឹម។

175 Ibid.

176 របាយការណ៍ប្រចាំប្រទេសកម្ពុជា។

177 ផ្នែកស្តីពីសញ្ជាតិ និង ភាពជាពលរដ្ឋ ពុំមានព័ត៌មានដែលត្រូវបានផ្តល់ជូនដោយរបាយការណ៍ប្រចាំប្រទេសឥណ្ឌូនេស៊ីនោះទេ។ ព័ត៌មានដែលបានបង្ហាញនៅក្នុងតារាងនានា គឺផ្អែកលើការស្រាវជ្រាវដែលត្រូវបានធ្វើឡើងដោយសហអ្នកនិពន្ធ Bongkot Napaumporn។ អ្នកនិពន្ធបានសម្រេចចិត្តមិនគ្របដណ្តប់លើប្រទេសឥណ្ឌូនេស៊ីនៅក្នុងផ្នែកអធិប្បាយនេះ។

178 "មិនមែនជាពលរដ្ឋ" គឺជាបុគ្គលដែលរស់នៅក្នុងដែនដីនៃប្រទេសឡាវ ដែលមិនមែនជាពលរដ្ឋឡាវ និង ដែលមិនអាចបញ្ជាក់អំពីសញ្ជាតិរបស់ខ្លួនបាន" របាយការណ៍ប្រចាំប្រទេសឡាវ។

179 Ibid.

180 Ibid.

អាចទទួលបាន តាមរយៈប្រតិបត្តិការនៃច្បាប់[181] ការចុះបញ្ជី[182] សញ្ជាតូបនីយកម្ម[183] និងការរួមបញ្ចូលដែនដីថ្មីណាមួយទៅក្នុងសហគមន៍។[184,185] នៅ**ប្រទេសមីយ៉ាន់ម៉ា** ភាពជាពលរដ្ឋត្រូវបានកំណត់និយមន័យស្របតាមមាត្រា ២(ខ) នៃច្បាប់ស្តីពីភាពជាពលរដ្ឋ ឆ្នាំ១៩៨២។

សញ្ជាតិត្រូវបានកំណត់ដោយការមានឪពុក/ម្តាយម្នាក់ ឬទាំងពីរនាក់ជាពលរដ្ឋ។ ភាពជាពលរដ្ឋនៅក្នុងប្រទេសមីយ៉ាន់ម៉ា ត្រូវបានបែងចែកជាបីប្រភេទ រួមមាន ភាពជាពលរដ្ឋពេញលេញ ភាពជាពលរដ្ឋតាមផ្លូវច្បាប់ និងភាពជាពលរដ្ឋដែលបានធ្វើសញ្ជាតូបនីយកម្ម។[186] ចំពោះ**ប្រទេសហ្វីលីពីន** មានច្បាប់ខុសៗគ្នាជាច្រើន ដែលទាក់ទងនឹងសញ្ជាតិ។[187] ទោះបីជាយ៉ាងណាក៏ដោយ ច្បាប់ចម្បង ដែលទាក់ទងនឹងសញ្ជាតិគឺរដ្ឋធម្មនុញ្ញ។ ផ្នែកទី១ នៃមាត្រា IV នៃរដ្ឋធម្មនុញ្ញរបស់ប្រទេសហ្វីលីពីន ឆ្នាំ១៩៨៧ រៀបរាប់អំពីពលរដ្ឋរបស់ប្រទេសហ្វីលីពីន។ រដ្ឋធម្មនុញ្ញ ឆ្នាំ១៩៨៧ និង ១៩៧៣ អនុវត្តតាមគោលការណ៍ jus sanguinis យ៉ាងម៉ឺងម៉ាត់ នៅក្នុងការទទួលបានភាពជាពលរដ្ឋ។ នេះមានន័យថា ខ្សែស្រឡាយឪពុកម្តាយគឺជាអ្នកកំណត់ភាពជាពលរដ្ឋ មិនមែនទីកន្លែងកំណើតនោះទេ។ ចំណុចនេះផ្អែកលើបញ្ញត្តិស្តីពីភាពជាពលរដ្ឋនៃរដ្ឋធម្មនុញ្ញ ដែលចែងថា "ពលរដ្ឋហ្វីលីពីន គឺជាកូនដែលមានឪពុក ឬម្តាយជាជនជាតិ ហ្វីលីពីន"។[188] មានភាពជាពលរដ្ឋបួនប្រភេទនៅ ក្នុងប្រទេសហ្វីលីពីន រួមមាន៖

(១) ជនដែលជាពលរដ្ឋរបស់ប្រទេសហ្វីលីពីននៅពេលអនុម័តរដ្ឋធម្មនុញ្ញ

(២) ជនដែលមានឪពុក ឬ ម្តាយជាពលរដ្ឋរបស់ប្រទេសហ្វីលីពីន

(៣) ជនដែលកើតមុនថ្ងៃទី១៧ ខែមករា ឆ្នាំ១៩៧៣ ដែលមានម្តាយជាជនជាតិហ្វីលីពីន ដែលជ្រើសរើសភាពជាពលរដ្ឋហ្វីលីពីន នៅពេលពេញវ័យ និង

(៤) ជនដែលបានធ្វើសញ្ជាតូបនីយកម្មដោយស្របច្បាប់។

ប្រភេទទីមួយសំដៅលើជនដែល នៅពេលអនុម័តរដ្ឋធម្មនុញ្ញ ឆ្នាំ១៩៨៧ គឺជាពលរដ្ឋហ្វីលីពីនរួចហើយ ស្របតាមរដ្ឋធម្មនុញ្ញឆ្នាំ១៩៣៥ និង ១៩៧៣។ ប្រភេទទីពីរសំដៅលើជនដែល នៅក្រោយពេលអនុម័តរដ្ឋធម្មនុញ្ញ បានកើតជាកូនរបស់ឪពុក ឬម្តាយដែលជាពលរដ្ឋរបស់ប្រទេសហ្វីលីពីន។ ដូច្នេះ មនុស្សម្នាក់ដែលជាកូនរបស់ឪពុកម្តាយដែលមានសញ្ជាតិចម្រុះ ដែលមួយក្នុងចំណោមនោះ ជាសញ្ជាតិហ្វីលីពីន អាចមានសញ្ជាតិពីរ អាស្រ័យលើច្បាប់ជាតិរបស់ឪពុក/ម្តាយដែលមិនមែនជាពលរដ្ឋហ្វីលីពីននោះ។ ប្រភេទទីបីនៃពលរដ្ឋហ្វីលីពីន ពាក់ព័ន្ធនឹងជនដែលមានសិទ្ធិជ្រើសរើសភាពជាពលរដ្ឋហ្វីលីពីន។ ចំណុចនេះគ្របដណ្តប់លើជនដែលបានកើត ស្របតាមរដ្ឋធម្មនុញ្ញ ឆ្នាំ១៩៣៥ និងមានម្តាយជាពលរដ្ឋហ្វីលីពីន និង ឪពុកជាជនបរទេស។ ប្រភេទចុងក្រោយគ្របដណ្តប់លើពលរដ្ឋហ្វីលីពីន ដែលបានធ្វើសញ្ជាតូបនីយកម្ម។[189]

181 មាត្រា ១៤ នៃរដ្ឋធម្មនុញ្ញរបស់សហព័ន្ធ នៃប្រទេសម៉ាឡេស៊ី។

182 មាត្រា ១៥ ១៥ក ១៦ និង ១៦ក នៃរដ្ឋធម្មនុញ្ញរបស់សហព័ន្ធ នៃប្រទេសម៉ាឡេស៊ី។

183 មាត្រា ១៩ នៃរដ្ឋធម្មនុញ្ញរបស់សហព័ន្ធ នៃប្រទេសម៉ាឡេស៊ី។

184 មាត្រា ២២ នៃរដ្ឋធម្មនុញ្ញរបស់សហព័ន្ធ នៃប្រទេសម៉ាឡេស៊ី។

185 ការកែសម្រួលត្រូវបានស្នើឡើងដោយជនបង្គោលនៃប្រទេសម៉ាឡេស៊ី។

186 ច្បាប់ស្តីពីភាពជាពលរដ្ឋ ឆ្នាំ១៩៨២ របាយការណ៍ប្រចាំប្រទេសមីយ៉ាន់ម៉ា។

187 យោងតាមរបាយការណ៍ប្រចាំប្រទេសហ្វីលីពីន ច្បាប់ស្តីពីសញ្ជាតិ និង ភាពជាពលរដ្ឋ មានដូចក្រោម៖
- ច្បាប់សាធារណរដ្ឋ លេខ ៩២២៥ – ច្បាប់ដែលបង្កើតភាពជាពលរដ្ឋសម្រាប់ពលរដ្ឋហ្វីលីពីនដែលទទួលបានភាពជាពលរដ្ឋបរទេសចិន្ត្រៃយ៍ដែលធ្វើវិសោធនកម្មដើម្បីគោលបំណងនៃច្បាប់របស់រដ្ឋសហធន លេខ ៦៣ ដូចដែលបានធ្វើវិសោធនកម្ម និង ដើម្បីគោលបំណងដទៃទៀត។
- ច្បាប់សាធារណរដ្ឋ លេខ ៩១៣៩ – ច្បាប់ដែលចែងអំពីការទទួលបានភាពជាពលរដ្ឋហ្វីលីពីន សម្រាប់ជនបរទេសមួយចំនួន តាមរយៈសញ្ជាតូបនីយកម្មផ្នែករដ្ឋបាល និង សម្រាប់គោលបំណងដទៃទៀត។
- RA ៨១៧១ – ច្បាប់ដែលចែងអំពីការធ្វើមាតុភូមិនិវត្តន៍របស់ស្ត្រីជនជាតិហ្វីលីពីន ដែលបានបាត់បង់ភាពជាពលរដ្ឋហ្វីលីពីន ដោយសារការរៀបអាពាហ៍ពិពាហ៍ជាមួយជនបរទេស និង អ្នកដែលមានឪពុកម្តាយជាជនជាតិហ្វីលីពីន។
- RA ៧៨៣៧ – ច្បាប់ដែលផ្តល់ឋានៈជានិវាសនជនអចិន្ត្រៃយ៍ សិទ្ធិ និងបុព្វសិទ្ធិដទៃទៀតដល់អតីតយុទ្ធជនហ្វីលីពីននៃសង្គ្រាមលោកលើកទី២ ដែលបានទទួលភាពជាពលរដ្ឋអាមេរិក ស្របតាមច្បាប់អន្តោប្រវេសន៍នៃសហរដ្ឋអាមេរិក ឆ្នាំ១៩៩០ និង សម្រាប់គោលបំណងដទៃទៀត។
- បទបញ្ជាប្រតិបត្តិលេខ ២០៩ s. ១៩៨៧ – ក្រមគ្រួសារនៃប្រទេសហ្វីលីពីន។
- ច្បាប់សាធារណរដ្ឋ លេខ ៣៨៦ – ក្រមរដ្ឋប្បវេណីនៃប្រទេសហ្វីលីពីន។
- ច្បាប់របស់រដ្ឋសហធន លេខ ៤៧៣ – ច្បាប់ដែលចែងអំពីការទទួលបានភាពជាពលរដ្ឋហ្វីលីពីនតាមរយៈសញ្ជាតូបនីយកម្ម និង និរាករណ៍ច្បាប់លេខ ២៩២៧ និង ៣៤៤៨។
- ច្បាប់របស់រដ្ឋសហធន លេខ ៦៣ – ច្បាប់ដែលចែងអំពីវិធីនានាដែលអាចធ្វើឲ្យបាត់បង់ ឬ ទទួលបានភាពជាពលរដ្ឋហ្វីលីពីន។

188 របាយការណ៍ប្រចាំប្រទេសហ្វីលីពីន។

189 Ibid.

ចំពោះប្រទេសសិង្ហបុរី រដ្ឋធម្មនុញ្ញចែងថា ភាពជាពលរដ្ឋអាចទទួលបានតាមរយៈដើមកំណើត នៃការចុះបញ្ជី ឬសញ្ជាតូបនីយកម្ម។ មានតែកូនរបស់ពលរដ្ឋសិង្ហបុរីប៉ុណ្ណោះ ទើបអាចជាពលរដ្ឋដោយកំណើត ឬដោយវង្សត្រកូល។[190] ច្បាប់បញ្ជាក់បន្ថែមទៀតថា "មនុស្សគ្រប់រូបដែលកើតនៅក្នុងប្រទេសសិង្ហបុរី ក្រោយថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ១៩៦៣ ត្រូវជាពលរដ្ឋរបស់ប្រទេសសិង្ហបុរីដោយកំណើត ប្រសិនបើមានឪពុក/ម្តាយម្នាក់ជាពលរដ្ឋសិង្ហបុរី (SC)។ ក្នុងករណីកុមារដែលកើតនៅក្នុងប្រទេសសិង្ហបុរីមិនស្របច្បាប់ មាត្រា១៥(១) នៃឧបសម្ព័ន្ធទីបី ចែងថា កុមារដែលកើតនៅក្នុងប្រទេសសិង្ហបុរីមិនស្របច្បាប់ មិនមែនជាពលរដ្ឋរបស់ប្រទេសសិង្ហបុរីនោះទេ លើកលែងតែម្តាយរបសកុមារម្នាក់នោះ គឺជាពលរដ្ឋរបស់ប្រទេសសិង្ហបុរី"។[191] អនីតិជនដែលកើតនៅក្រៅប្រទេសសិង្ហបុរី អាចចុះបញ្ជីជា SC បាន តាមរយៈវង្សត្រកូល ប្រសិនបើ ក) ឪពុក/អ្នកធានា (SC ដោយកំណើត) បានរៀបអាពាហ៍ពិពាហ៍ស្របច្បាប់ជាមួយម្តាយរបស់អនីតិ-ជន ឬ ខ) ម្តាយ (SC ដោយកំណើត) គឺជាអ្នកធានាដែលនីតិជនត្រូវកើតនៅ ឬនៅក្រោយថ្ងៃទី ១៥ ខែឧសភា ឆ្នាំ២០០៤ ឬ គ) អ្នកធានា (ម្តាយ ឬ ឪពុក) ដែលជា SC ដោយវង្ស ត្រកូល បានរស់នៅក្នុងប្រទេសសិង្ហបុរីក្នុងរយៈពេល (សរុប) មិនតិចជាង ៥ ឆ្នាំ មុនកំណើតរបស់អនីតិជន ឬ មិនតិចជាង ២ ឆ្នាំ (សរុប) ក្នុងអំឡុងរយៈពេល ៥ ឆ្នាំ មុនកំណើតរបស់អនីតិជន។[192] នៅប្រទេសថៃ ច្បាប់ស្តីពីសញ្ជាតិ ឆ្នាំ១៩៦៥ (ពស. ២៥០៨) ចែងថា មនុស្សម្នាក់នឹងទទួលបានសញ្ជាតិថៃដោយកំណើត ប្រសិនបើមនុស្ស ម្នាក់នោះមានឪពុក ឬម្តាយមានសញ្ជាតិថៃ ទោះបីជាកើតនៅក្នុង ឬ នៅក្រៅព្រះរាជាណាចក្រថៃក៏ដោយ ឬប្រសិនបើមនុស្សម្នាក់បានកើតនៅក្នុងព្រះរាជាណាចក្រថៃ លើកលែងតែអ្នកដែលស្ថិតនៅក្រោម មាត្រា ៧ ស្ទួន កថាខណ្ឌទី១។ នេះមានន័យថា របៀបទទួលបានសញ្ជាតិនៅក្នុងប្រទេសថៃ គឺជាការរួមបញ្ចូលគ្នានៃ jus sanguinis និង jus soli។ កុមារម្នាក់អាចទទួលបានសញ្ជាតិថៃ ប្រសិនបើគេមានឪពុក/ម្តាយម្នាក់ជាជនជាតិថៃ។ នៅក្នុងប្រទេស វៀតណាម ច្បាប់ស្តីពីសញ្ជាតិវៀតណាម ឆ្នាំ២០០៨ កំណត់និយមន័យនៃពាក្យទាំងពីរ – សញ្ជាតិ និង ភាពជាពលរដ្ឋ។ ច្បាប់នេះ អនុវត្តគោលការណ៍ទាំងពីរ ទាំង jus sanguinis និង jus soli[193] ដោយសារកំណើត ឬ បានធ្វើសញ្ជាតូបនីយកម្មនៅក្នុងប្រទេសវៀតណាម ការប្រើប្រាស់សញ្ជាតិវៀតណាមឡើងវិញ ដូចមានចែងដោយមាត្រា ១៨[194] ៣៥ និង ៣៧ នៃច្បាប់នេះ និងដោយសន្ធិសញ្ញាដែលសាធារណរដ្ឋសង្គម និយមវៀតណាម ជាភាគីចុះកិច្ចសន្យា។[195]

ចូរមើល**តារាងទី៤** ស្តីពីក្របខណ្ឌច្បាប់របស់ AMS ដែលពាក់ព័ន្ធនឹងការទទួលបានសញ្ជាតិដោយកុមារដែលបានកើតនៅក្នុងប្រទេសនានា នៅក្នុងឧបសម្ព័ន្ធ ទំព័រ ១១៨។



190 របាយការណ៍ប្រចាំប្រទេសសិង្ហបុរី។
191 Ibid.
192 Ibid.
193 របាយការណ៍របស់ប្រទេសវៀតណាម។
194 Ibid មាត្រា ១៨(១) ចែងថា "ទារកទើបនឹង និង កុមារដែលត្រូវគេបោះបង់ចោល ត្រូវបានរកឃើញនៅក្នុងដែនដីនៃប្រទេសវៀតណាម ដោយមិនស្គាល់ឪពុកម្តាយ មានសញ្ជាតិវៀតណាម"។
195 Ibid

## ៣.៣ ការអនុវត្តសញ្ជាតិ និង ភាពជាពលរដ្ឋនៅក្នុងរដ្ឋសមាជិកអាស៊ាន



“ នៅ AMS ភាគច្រើន ពាក់ព័ន្ធនឹងសញ្ជាតិ ស្ត្រីទទួលបានសិទ្ធិស្មើគ្នានឹងបុរស លើកលែងតែនៅក្នុងប្រទេសមួយចំនួនតូច” ។

### ក ) យេនឌ័រនៅក្នុងច្បាប់ជាតិ

នៅក្នុងច្បាប់ស្តីពីសញ្ជាតិ របស់ប្រទេសប្រ៊ុយណេដារូសាឡឹម ស្ត្រីទទួលបានសញ្ជាតិដោយ ផ្អែកលើលក្ខខណ្ឌដូចគ្នានឹងបុរសដែរ យោងតាមច្បាប់ បទប្បញ្ញត្តិ និងគោលនយោបាយនានា។ ពួកគេអាច ថែរក្សាសញ្ជាតិរបស់ពួកគេបាន ក្រោយពេលរៀបអាពាហ៍ពិពាហ៍ ជាមួយ ជនបរទេស និងអាចផ្ទេរសញ្ជាតិរបស់ពួកគេទៅកាន់កូនៗរបស់ពួកគេបាន តាមមធ្យោបាយនៃការដាក់ពាក្យស្នើសុំ។[196] ច្បាប់ស្តីសញ្ជាតិនៃប្រទេសកម្ពុជា អនុវត្តតាមរដ្ឋធម្មនុញ្ញ នៅក្នុងស្មារតីដែលស្ត្រីមានសិទ្ធិស្មើគ្នានឹងបុរស និងថា ពលរដ្ឋកម្ពុជាមិនបាត់បង់សញ្ជាតិដោយសារការរៀបអាពាហ៍ពិពាហ៍ជាមួយជនបរទេសនោះទេ។[197] នៅក្នុងច្បាប់ស្តីសញ្ជាតិរបស់ ប្រទេសឡាវ ចែងថា អាពាហ៍ពិពាហ៍របស់ពលរដ្ឋឡាវ ឬ ការលែងលះរវាងពលរដ្ឋឡាវ និងបុគ្គលដែលមានសញ្ជាតិផ្សេងទៀត ឬគ្មានសញ្ជាតិ នឹងមិនកែប្រែសញ្ជាតិឡាវរបស់ពួកគេនោះទេ និងថាការទទួលបាន ឬ ការដកហូតសញ្ជាតិឡាវ នឹងមិនបង្កការកែប្រែណាមួយចំពោះសញ្ជាតិរបស់ស្វាមី/ភរិយារបស់ពួកគេនោះទេ។[198] គេសន្មតថា ស្ត្រីឡាវអាចផ្ទេរសញ្ជាតិរបស់នាងទៅឲ្យកូនបាន។ ទោះបីជាយ៉ាងណាក៏ដោយ ច្បាប់ចែងថា “ប្រសិនបើឪពុកម្តាយមានសញ្ជាតិខុសគ្នា កូនអាចយក [សញ្ជាតិ] របស់ឪពុក ឬ របស់ម្តាយពួកគេបាន ស្របតាមច្បាប់ស្តីពីសញ្ជាតិឡាវ”។[199] នៅប្រទេសម៉ាឡេស៊ី ស្ត្រី និង បុរសគ្រប់រូប បានទទួលការព្រមព្រៀងថាមានសិទ្ធិស្មើគ្នាចំពោះភាពជាពលរដ្ឋ ស្របតាមរដ្ឋធម្មនុញ្ញរបស់សហព័ន្ធ។ មាត្រា ១៤(១)(ខ) និង ផ្នែក II នៃឧបសម្ព័ន្ធទីពីរនៃរដ្ឋធម្មនុញ្ញរបស់សហព័ន្ធ ចែងអំពីភាពជា

196 របាយការណ៍របស់ប្រទេសប្រ៊ុយណេដារូសាឡឹម។
197 របាយការណ៍របស់ប្រទេសកម្ពុជា។
198 មាត្រា ៤ នៃច្បាប់ស្តីពីសញ្ជាតិឡាវ របាយការណ៍របស់ប្រទេសឡាវ។
199 Ibid.

ពលរដ្ឋ តាមរយៈការប្រតិបត្តិការច្បាប់សម្រាប់មនុស្សគ្រប់រូបដែលកើតនៅក្រៅប្រទេសម៉ាឡេស៊ី ដែលមានឪពុកជាពលរដ្ឋម៉ាឡេស៊ី នៅពេលកើត។ ស្ត្រីជនជាតិម៉ាឡេស៊ីអាចដាក់ពាក្យស្នើសុំការចុះបញ្ជីជាពលរដ្ឋជូនកូនរបស់នាង ស្របតាមមាត្រា ១៥(២) នៃរដ្ឋធម្មនុញ្ញរបស់សហព័ន្ធ។ នៅក្នុងករណីនេះ រដ្ឋាភិបាលបានពង្រឹងការអនុវត្តមាត្រា ១៥(២) តាមវិធីនៃនីតិវិធីរដ្ឋបាលបណ្តោះអាសន្ន ដែលត្រូវបានអនុវត្តនៅថ្ងៃទី០១ ខែមិថុនា ឆ្នាំ២០១០ និងអនុវត្តចំពោះកូនរបស់ស្ត្រីម៉ាឡេស៊ី ដែលបានរៀបអាពាហ៍ពិពាហ៍ជាមួយជនបរទេស ដែលកើតនៅក្រៅប្រទេស នៅក្រោយថ្ងៃទី០១ ខែមករា ឆ្នាំ២០១០។ ការដាក់ពាក្យស្នើសុំអាចធ្វើឡើងដោយស្ត្រីម៉ាឡេស៊ី នៅស្ថានកុងស៊ុលម៉ាឡេស៊ីរបស់ពួកគេ នៅក្នុងរយៈពេលមួយឆ្នាំចាប់ពីកាលបរិច្ឆេទនៃកំណើតរបស់កូននោះ។ នីតិវិធីរដ្ឋបាលនេះពង្រឹងបន្ថែមនូវសិទ្ធិស្មើភាពរបស់ស្ត្រីក្នុងការកំណត់ឋានៈនៃភាពជាពលរដ្ឋរបស់កុមារ។[200] ស្វាមីភរិយា/ភរិយារបស់បុរសជនជាតិម៉ាឡេស៊ី អាចដាក់ពាក្យស្នើសុំចុះបញ្ជីជាពលរដ្ឋម៉ាឡេស៊ីបាន ក្នុងលក្ខខណ្ឌដែលពួកគេបានបំពេញតាមលក្ខខណ្ឌតម្រូវនៃការស្នាក់នៅរយៈពេល២ឆ្នាំ។ ទោះបីជាយ៉ាងណាក៏ដោយ ស្វាមីភរិយា/ស្វាមីរបស់ស្ត្រីជនជាតិម៉ាឡេស៊ីត្រូវតែដាក់ពាក្យស្នើសុំភាពជាពលរដ្ឋតាមវិធីធ្វើសញ្ជាតូបនីយកម្ម[201] ដែលពួកគេចាំបាច់ត្រូវតែស្នាក់នៅក្នុងប្រទេសម៉ាឡេស៊ីយ៉ាងតិច ១០ ឆ្នាំ ក្នុងរយៈពេល ១២ ឆ្នាំ ភ្លាមៗមុនកាលបរិច្ឆេទនៃពាក្យស្នើសុំ។[202]

ស្ត្រីទទួលបានសញ្ជាតិ ស្របតាមលក្ខខណ្ឌដូចគ្នានឹងបុរសដែរ ស្របតាមច្បាប់ស្តីពីភាពជាពលរដ្ឋនៃ**ប្រទេសមីយ៉ាន់ម៉ា**។ សញ្ជាតិរបស់ពួកគេមិនមានការកែប្រែក្រោយពេលរៀបអាពាហ៍ពិពាហ៍ជាមួយជនបរទេសនោះទេ។[203] ទោះបីជាយ៉ាងណាក៏ដោយ ការផ្ទេរសញ្ជាតិរបស់ពួកគេទៅកាន់កូនៗរបស់ពួកគេ គឺអាស្រ័យលើឆន្ទានុសិទ្ធិនៃច្បាប់។[204] នៅ**ប្រទេសហ្វីលីពីន** រដ្ឋធម្មនុញ្ញ ឆ្នាំ១៩៧៣ និង ឆ្នាំ១៩៨៧ ចែងថា បុរស និង ស្ត្រីទទួលបានភាពជាពលរដ្ឋហ្វីលីពីននៅក្នុងលក្ខណៈដូចគ្នា និង គ្មានភាពខុសគ្នាណាមួយនោះទេ។ ស្របតាមរដ្ឋធម្មនុញ្ញ ឆ្នាំ១៩៨៧ ស្ត្រីមិនបាត់បង់ភាពជាពលរដ្ឋរបស់ពួកគេក្រោយពេលរៀបអាពាហ៍ពិពាហ៍ជាមួយជនបរទេសនោះទេ។[205] ដោយសារតែភាពជាពលរដ្ឋអនុវត្តតាមគោលការណ៍ jus sanguinis កូនរបស់ស្ត្រីហ្វីលីពីនទទួលភាពជាពលរដ្ឋហ្វីលីពីនបន្តពីនាង។ នៅក្នុងច្បាប់នៃការមានស្វាមី/ភរិយាបរទេស កុមារក៏ទទួលបានភាពជាពលរដ្ឋពីឪពុក/ម្តាយបរទេសដែរ កុមារត្រូវបានចាត់ទុកថាមានសញ្ជាតិពីរ ស្របតាមច្បាប់នៃប្រទេសហ្វីលីពីន។[206] ចំណុចនេះត្រូវបានបញ្ជាក់ដោយ មាត្រា ១៩ នៃច្បាប់ស្តីពីសិទ្ធិមនុស្សរបស់ស្ត្រី (Magna Carta of Women) (RA ៩៧១០ ឆ្នាំ២០០៩)៖ សិទ្ធិស្មើភាពនៅគ្រប់រឿងរ៉ាវទាំងអស់ដែលទាក់ទងនឹងទំនាក់ទំនងអាពាហ៍ពិពាហ៍ និង គ្រួសារ។[207] នៅ**ប្រទេសថៃ** ស្ត្រីទទួលបានសញ្ជាតិផ្អែកតាមលក្ខខណ្ឌដូចគ្នានឹងបុរសដែរ។ ស្ត្រីអាចថែរក្សាសញ្ជាតិរបស់ពួកគេបាន លើកលែងតែក្នុងករណីនៃការលះ

---

200 ការកែសម្រួលត្រូវបានស្នើឡើងដោយជនបង្គោលនៃប្រទេសម៉ាឡេស៊ី។

201 Ibid.

202 មាត្រា ១៥ និង ១៩ នៃរដ្ឋធម្មនុញ្ញរបស់សហព័ន្ធ របាយការណ៍ប្រចាំប្រទេសម៉ាឡេស៊ី។

203 របាយការណ៍របស់ប្រទេសមីយ៉ាន់ម៉ា។

204 Ibid.

205 របាយការណ៍របស់ប្រទេសហ្វីលីពីន។ ព័ត៌មានបន្ថែមដែលត្រូវបានផ្តល់ជូនដោយប្រទេសហ្វីលីពីនបានបញ្ជាក់ថា "រដ្ឋធម្មនុញ្ញ ឆ្នាំ១៩៨៧ ជាទូទៅអនុម័តលើបញ្ញត្តិនានានៃរដ្ឋធម្មនុញ្ញ ឆ្នាំ១៩៧៣ លើកលែងអនុមាត្រា (៣) ដែលមានបំណងកែតម្រូវស្ថានភាពមិនប្រក្រតីដែលត្រូវបានបង្កើតឡើងដោយបដិញ្ញាដែលគួរឲ្យសង្ស័យនៅក្នុងរដ្ឋធម្មនុញ្ញឆ្នាំ១៩៣៥។

ផ្នែកទី១ នៃមាត្រា IV នៃរដ្ឋធម្មនុញ្ញ ឆ្នាំ១៩៨៧ នៅពេលនេះចែងថា៖ "បុគ្គលខាងក្រោមជាពលរដ្ឋរបស់ប្រទេសហ្វីលីពីន៖

(១) ជនដែលជាពលរដ្ឋរបស់ប្រទេសហ្វីលីពីននៅពេលអនុម័តរដ្ឋធម្មនុញ្ញនេះ

(២) ជនដែលមានឪពុក ឬ ម្តាយជាពលរដ្ឋរបស់ប្រទេសហ្វីលីពីន

(៣) ជនដែលកើតមុនថ្ងៃទី១៧ ខែមករា ឆ្នាំ១៩៧៣ ដែលមានម្តាយជាជនជាតិហ្វីលីពីន ដែលជ្រើសរើសភាពជាពលរដ្ឋហ្វីលីពីន នៅពេលពេញវ័យ និង

(៤) ជនដែលបានធ្វើសញ្ជាតូបនីយកម្ម ដោយស្របច្បាប់"។

206 Ibid.

207 ច្បាប់ចែងថា "រដ្ឋត្រូវអនុវត្តរាល់វិធានការដែលសមស្របទាំងអស់ដើម្បីលុបបំបាត់ការរើសអើងចំពោះស្ត្រីនៅគ្រប់បញ្ហាទាំងអស់ដែលទាក់ទងនឹងទំនាក់ទំនងអាពាហ៍ពិពាហ៍ និង គ្រួសារ និង ត្រូវធានាថា៖ (ឆ) ស្ត្រីត្រូវមានសិទ្ធិស្មើគ្នានឹងបុរស នៅក្នុងការទទួលបានការផ្លាស់ប្តូរ ឬ ការថែរក្សាសញ្ជាតិរបស់ពួកគេ។ រដ្ឋត្រូវធានាជាពិសេសថា ការរៀបអាពាហ៍ពិពាហ៍ជាមួយជនបរទេស និង ការផ្លាស់ប្តូរសញ្ជាតិរបស់ប្តីក្នុងអំឡុងពេលរៀបអាពាហ៍ពិពាហ៍ មិនធ្វើឲ្យមានការផ្លាស់ប្តូរដោយស្វ័យប្រវត្តិនូវសញ្ជាតិរបស់ប្រពន្ធ មិនធ្វើឲ្យប្រពន្ធគ្មានសញ្ជាតិ ឬ បង្ខំឲ្យប្រពន្ធយកសញ្ជាតិរបស់ប្តីឡើយ។ ច្បាប់ខុសៗគ្នារបស់ប្រទេសដទៃទៀត ពាក់ព័ន្ធនឹងការមិនសញ្ជាតិពីរ ដែលអាចទទួលបានដោយស្មើភាពគ្នារវាងស្ត្រី និង បុរស ក៏ត្រូវបានយកមកពិចារណាដូចគ្នាដែរ Ibid។

បង់សិទ្ធិ។ ម្តាយអាចផ្ទេរសញ្ជាតិរបស់នាងទៅកាន់កូនរបស់នាងបាន។[208] នៅប្រទេសវៀតណាម ច្បាប់ស្តីពីសញ្ជាតិវៀតណាម ឆ្នាំ២០០៨ ធានាចំពោះសមភាពរវាងបុរស និងស្ត្រី ដោយគ្មានការរើសអើងចំពោះស្ត្រីពាក់ព័ន្ធនឹងសញ្ជាតិឡើយ។ អាពាហ៍ពិពាហ៍ ការលែងលះ ឬការធ្វើមោឃភាពអាពាហ៍ពិពាហ៍មិនស្របច្បាប់រវាងពលរដ្ឋវៀតណាម និង ជនបរទេសមិនបានកែប្រែសញ្ជាតិវៀតណាម របស់ភាគីដែលពាក់ព័ន្ធ ព្រមទាំងកូនៗ ដែលជាអនីតិជនរបស់ពួកគេឡើយ (ប្រសិនបើមាន) ច្បាប់នេះក៏បញ្ជាក់ផងដែរថា ប្រសិនបើស្វាមី ឬភរិយាទទួលបានឡើងវិញ ឬ បាត់បង់សញ្ជាតិវៀតណាមរបស់គាត់/នាង មិនបានកែប្រែសញ្ជាតិរបស់ស្វាមី/ភរិយារបស់គាត់/នាងនោះទេ។[209]

### ខ) កូនឥតខាន់ស្លា

នៅប្រទេសប្រ៊ុយណេដារូសាឡឹម មានបញ្ញត្តិមួយនៅក្នុងច្បាប់ស្តីពីសញ្ជាតិប្រ៊ុយនេ ដែលអ្នកម្តាយចិញ្ចឹមកូនតែម្នាក់ឯង ដែលមានសញ្ជាតិប្រ៊ុយនេ អាចដាក់ពាក្យស្នើសុំឲ្យកូនដែលកើតនៅក្រៅអាពាហ៍ពិពាហ៍របស់នាងទទួលបានសញ្ជាតិរបស់នាង។[210] ច្បាប់របស់ប្រទេសកម្ពុជា មិនបានពិចារណាថាតើ កុមារម្នាក់ត្រូវបានកើតនៅក្នុង ឬនៅក្រៅអាពាហ៍ពិពាហ៍នោះទេ ដរាបណាគាត់មានឪពុក ឬម្តាយដែលមានសញ្ជាតិខ្មែរ។[211] បញ្ហានេះមិនត្រូវបានលើកឡើងនៅក្នុងរបាយការណ៍របស់ប្រទេសឡាវនោះទេ។ នៅប្រទេសម៉ាឡេស៊ី បញ្ញត្តិខុសៗគ្នាត្រូវបាន អនុវត្តចំពោះអ្នកកាន់សាសនាអ៊ីស្លាម និង អ្នកមិនកាន់សាសនាអ៊ីស្លាម និង កូនស្របច្បាប់ និងមិនស្របច្បាប់។[212] ចំពោះកុមារកាន់សាសនាអ៊ីស្លាម ឈ្មោះរបស់ឪពុកបង្កើតមិនអាចចុះបញ្ជីជាឪពុករបស់កុមារបានឡើយ។[213] ចំពោះកុមារមិនកាន់សាសនាអ៊ីស្លាម ឈ្មោះរបស់ឪពុកនឹងមិនត្រូវបានបញ្ចូលទៅក្នុងបញ្ជីកំណើតនោះទេ លើកលែងតែមានពាក្យស្នើសុំរួមគ្នាមួយត្រូវបានធ្វើឡើងដោយម្តាយ និងជនដែលអះអាងថាជាឪពុករបស់កុមារនោះ។[214,215] ច្បាប់ស្តីពីភាពជាពលរដ្ឋរបស់ប្រទេសហ្វីលីពីន ប្រកាន់ខ្ជាប់តាមគោលការណ៍ jus sanguinis (សិទ្ធិទទួលបានសញ្ជាតិដោយសារចំណងលោហិត) ដែលផ្តល់ភាពជាពលរដ្ឋតាមរយៈទំនាក់ទំនងឈាម។[216] កុមារ ដែលមិនស្របច្បាប់ គឺជាពលរដ្ឋហ្វីលីពីន ដោយអនុវត្តតាមភាពជាពលរដ្ឋរបស់ឪពុក ឬម្តាយដែលជាពលរដ្ឋហ្វីលីពីន។ តាមរយៈភាពជាកូនមិនស្របច្បាប់របស់ម្តាយដែលជាពលរដ្ឋហ្វីលីពីន គាត់ក្លាយជាពលរដ្ឋហ្វីលីពីនដោយស្វ័យប្រវត្តិក្រោយពេលកើត។[217] នៅក្នុងច្បាប់ស្តីពីសញ្ជាតិរបស់ប្រទេសថៃ ដោយសារតែការទទួលបានសញ្ជាតិថៃ គឺផ្អែកលើមូលដ្ឋាន jus sanguinis ពុំមានខុសគ្នារវាងកូនដែលកើតនៅក្រៅចំណងអាពាហ៍ពិពាហ៍ និងកូនដែលកើតនៅក្នុងចំណងអាពាហ៍ពិពាហ៍នោះ

---

208 ការទទួលបានសញ្ជាតិថៃសម្រាប់កុមារម្នាក់ ដោយមូលហេតុ jus sanguinis (សិទ្ធិទទួលបានសញ្ជាតិដោយសារចំណងលោហិត) ត្រូវបានចែងនៅក្រោម មាត្រា ៧ (១) នៃច្បាប់ស្តីពីសញ្ជាតិ ឆ្នាំ១៩៦៥ (ពស. ២៥០៨) ដែលចែងអំពីការផ្តល់ជូនដូចៗគ្នា ទាំងនៅក្នុងករណីរបស់ឪពុក និង ករណីរបស់ម្តាយ ដោយគ្មានករណីលើកលែងនោះទេ របាយការណ៍របស់ប្រទេសថៃ។

209 របាយការណ៍របស់ប្រទេសវៀតណាម។

210 របាយការណ៍របស់ប្រទេសប្រ៊ុយណេដារូសាឡឹម។

211 របាយការណ៍របស់ប្រទេសកម្ពុជា។

212 ប្រទេសម៉ាឡេស៊ីមិនបានបែងចែករបស់កូនស្របច្បាប់ ឬ កូនមិនស្របច្បាប់ ពាក់ព័ន្ធនឹងសិទ្ធិទទួលបានការអប់រំ សេវាសុខភាព។ល។

213 នេះដោយសារតែនៅក្នុងសាសនាអ៊ីស្លាម កុមារត្រូវតែកើតនៅក្នុងចំណងអាពាហ៍ពិពាហ៍ ទើបមានឋានៈតាមផ្លូវច្បាប់ ហើយវាក៏ពាក់ព័ន្ធនឹងបញ្ហា “nasab” (វង្សត្រកូល) ផងដែរ។

214 ផ្នែកទី នៃរដ្ឋធម្មនុញ្ញរបស់សហព័ន្ធត្រូវបានអនុវត្តចំពោះកុមារដែលកើតក្នុងចំណងអាពាហ៍ពិពាហ៍។ នៅក្នុងករណីកុមារមិនស្របច្បាប់ ពុំមានអ្នកណាម្នាក់ នៅក្នុងនាមជាឪពុករបស់កុមារ ត្រូវបានតម្រូវឲ្យផ្តល់ព័ត៌មានដែលពាក់ព័ន្ធនឹងកំណើតរបស់កុមារនោះទេ ហើយមន្ត្រីអត្រានុកូលដ្ឋានមិនត្រូវបញ្ចូលឈ្មោះអ្នកណាម្នាក់ ក្នុងនាមជាឪពុករបស់កុមារ នៅក្នុងបញ្ជីនោះទេ លើកលែងតែមានសំណើរួមគ្នារវាងម្តាយ និងជនដែលទទួលស្គាល់ខ្លួនគាត់ថាជាឪពុករបស់កុមារ ហើយបុគ្គលរូបនោះ នៅក្នុងករណីនោះ ត្រូវចុះហត្ថលេខាលើបញ្ជីកំណើតរួមគ្នាជាមួយម្តាយ។

215 ការកែសម្រួលត្រូវបានស្នើឡើងដោយជនបង្គោលនៃប្រទេសម៉ាឡេស៊ី។

216 ការកែសម្រួលផ្អែកលើធាតុចូលបន្ថែមពីប្រទេសហ្វីលីពីន។

217 របាយការណ៍ប្រចាំប្រទេសហ្វីលីពីន។ ព័ត៌មានបន្ថែមដែលផ្តល់ជូនដោយប្រទេសហ្វីលីពីនបានចែងបន្ថែមទៀតថា “វាគឺជាវិធានមួយដែលត្រូវបានកំណត់នៅក្នុងយុត្តាធិការនេះ ដែលថាមានតែកូនស្របច្បាប់ប៉ុណ្ណោះដែលបន្តភាពជាពលរដ្ឋរបស់ឪពុកពួកគេ និងថាកូនមិនស្របច្បាប់ ស្ថិតនៅក្រោមអំណាចមេបាររបស់ម្តាយ និង បន្តសញ្ជាតិរបស់នាង [សាធារណរដ្ឋហ្វីលីពីន ទល់នឹង Nora Fe Sagun, G.R. លេខ ១៨៧៥៦៧ ថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០១២)]។ គេក៏បានធ្វើសេចក្តីសម្រេចផងដែរថា កូនមិនស្របច្បាប់របស់ជនជាតិហ្វីលីពីនមិនចាំបាច់ធ្វើសកម្មភាពណាមួយដើម្បីផ្តល់ជូនខ្លួនគាត់នូវរាល់សិទ្ធិ និង បុព្វសិទ្ធិទាំងអស់ដែលពលរដ្ឋរបស់ប្រទេសហ្វីលីពីនមាននោះទេ គាត់ក្លាយជាពលរដ្ឋម្នាក់ដោយស្វ័យប្រវត្តិ ដោយខ្លួនគាត់”។

ទេ លើកលែងតែនៅក្នុងករណីកូនដែលកើតនៅក្រៅចំណងអាពាហ៍ពិពាហ៍រវាងឪពុកជន ជាតិថៃ និងម្ដាយជាជនបរទេស និងនៅខាងក្រៅព្រះរាជាណាចក្រថៃ។ “នៅក្នុងកម្រិតនេះ តម្រូវឲ្យមានបញ្ជាក់អះអាងអំពីបិតុភាព ស្របតាមមាត្រា ៧ កថាខណ្ឌទី២ ឬការចុះបញ្ជីកូនស្របច្បាប់ ស្របតាមមាតា ១៥៤៨ នៃក្រមរដ្ឋប្បវេណី និង ពាណិជ្ជកម្ម”។[218] របាយការណ៍របស់**ប្រទេសវៀតណាម** មិនបានពិភាក្សាអំពីបញ្ហានេះទេ ប៉ុន្តែបានបញ្ជាក់ថា ពុំមានភាពខុសគ្នារវាងកូនមានខាន់ស្លា និងកូនឥតខាន់ស្លានោះទេ។[219]

## គ ) កុមារបាត់ខ្លួន

នៅ**ប្រទេសប្រ៊ុយណេដារូសាឡឹម** បន្ទាប់ពីពាក្យស្នើសុំត្រូវបានធ្វើឡើងដោយឪពុកម្ដាយ ឬ អាណាព្យាបាលរួចរាល់ហើយ កូនដែលជាអនីតិជនអាចដាក់ពាក្យស្នើសុំសញ្ជាតិ ដោយផ្អែកលើ មាត្រា ៦( ១ ) នៃច្បាប់ស្តីពីសញ្ជាតិប្រ៊ុយនេ។[220] នៅ**ប្រទេសកម្ពុជា** កុមារដែលត្រូវគេបោះបង់ចោល នឹងត្រូវបានចាត់ទុកថាជាពលរដ្ឋកម្ពុជាដោយស្វ័យប្រវត្តិ។[221] ច្បាប់ស្តីពីសញ្ជាតិនៃ **ប្រទេសឡាវ** ចែងថា កុមារដែលត្រូវបានរកឃើញនៅក្នុងដែនដី និងដែលមិនស្គាល់អត្តសញ្ញាណរបស់ឪពុកម្ដាយ នឹងត្រូវបានចាត់ទុកថាជាពលរដ្ឋឡាវ។ ទោះបីជាយ៉ាងណាក៏ដោយ “នៅក្នុងករណីដែល នៅខណៈពេលដែលកុមារទាំងនោះមានអាយុក្រោម ១៨ ឆ្នាំ មានភ័ស្តុតាង [ត្រូវបានរកឃើញថា] បង្ហាញថា ឪពុកម្តាយរបស់ពួកគេ ជាពលរដ្ឋបរទេស ពួកគេនឹងត្រូវបានចាត់ទុកជា ពលរដ្ឋបរទេសពីកំណើត”។[222] នៅប្រទេសម៉ាឡេស៊ី យោងតាមមាត្រា ១៩ខ ផ្នែក III នៃឧបសម្ព័ន្ធទីពីរនៃរដ្ឋធម្មនុញ្ញរបស់សហព័ន្ធ នៅក្នុងករណីកុមារទើបនឹងកើត ត្រូវបានរកឃើញថានៅកន្លែងណាមួយ ត្រូវបានសន្មតជាមុនថាបានកើតនៅក្នុងប្រទេសម៉ាឡេស៊ី មានម្តាយជានិវាសនជនអចិន្ត្រៃយ៍ និងពុំមានភ័ស្តុតាងផ្ទុយពីនេះទេនោះ កុមារនោះត្រូវបានចាត់ទុកថាជាពលរដ្ឋម៉ាឡេស៊ី។[223] នៅ**ប្រទេសហ្វីលីពីន** បញ្ញត្តិនានានៃរដ្ឋធម្មនុញ្ញមិនបានចែងអំពីបញ្ហារបស់កុមារបាត់ខ្លួននោះទេ។ ប្រទេសហ្វីលីពីនពុំមានច្បាប់ជាតិដែលមានស្រាប់ ឬច្បាប់ដែលត្រូវបានអនុម័តដោយសមាជ ស្តីពីកុមារបាត់ខ្លួន និង ឋានៈនៃភាពជាពលរដ្ឋរបស់ពួកគេនោះទេ ប៉ុន្តែបានទទួលស្គាល់ថាមានកុមារបាត់ខ្លួននៅក្នុងប្រទេស។[224] ទោះបីជាយ៉ាងណាក៏ដោយ តុលាការកំពូលបានប្រកាសថា “កុមារបាត់ខ្លួនគ្រប់រូប ដែលត្រូវបានរកឃើញនៅក្នុងប្រទេសហ្វីលីពីន ថាយ៉ាងហោចណាស់មានឪពុកជាពលរដ្ឋហ្វីលីពីន ឬម្តាយជាពលរដ្ឋហ្វីលីពីន គឺជាពលរដ្ឋហ្វីលីពីនពីកំណើត លើកលែងតែមានការបញ្ជាក់អះអាងដ៏សំខាន់ផ្សេងពីនេះ”។[225] ដូចគ្នានេះដែរ នៅ**ប្រទេសសិង្ហបុរី** ស្របតាមឧបសម្ព័ន្ធទីបីនៃ



218 របាយការណ៍របស់ប្រទេសថៃ។

219 ការកែសម្រួលត្រូវបានធ្វើឡើងដោយជនបង្គោលនៃប្រទេសវៀតណាម។

220 របាយការណ៍របស់ប្រទេសប្រ៊ុយណេដារូសាឡឹម។

221 កុមារដែលកើតដោយមិនស្គាល់ឪពុកម្ដាយ ដែលកើតនាពេលថ្មីៗនេះ និង ត្រូវបានរកឃើញនៅក្នុងប្រទេសកម្ពុជា ត្រូវបានចាត់ទុកថាបានកើតនៅក្នុងប្រទេសកម្ពុជា ( ច្បាប់ស្តីពីសញ្ជាតិ នៅក្នុងជំពូក ២ មាត្រា ៤ ចំណុចទី២ ) របាយការណ៍របស់ប្រទេសកម្ពុជា។

222 របាយការណ៍របស់ប្រទេសឡាវ។

223 ចូរមើលតារាងទី៥ ស្តីពីក្របខណ្ឌច្បាប់របស់ AMS ពាក់ព័ន្ធនឹងការទទួលបានសញ្ជាតិរបស់កុមារបាត់ខ្លួន និង កូនស្មុំ ទំព័រ ១០២។

224 ព័ត៌មានបន្ថែមត្រូវបានផ្តល់ជូនដោយប្រទេសហ្វីលីពីន។

225 របាយការណ៍របស់ប្រទេសហ្វីលីពីន។ ព័ត៌មានលម្អិតបន្ថែមទៀតត្រូវបានផ្តល់ជូនដោយប្រទេសហ្វីលីពីន ដោយដកស្រង់ “សេចក្តីសម្រេចសំខាន់ៗរបស់តុលាការកំពូល នៅក្នុងសំណុំរឿង David v. សាលាជម្រះក្តីការបោះឆ្នោតជ្រើសរើសសមាជិកព្រឹទ្ធសភា ( SET ) ( G R. លេខ ២២១៥៣៨ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០១៦ ) និង Poe- Llamanzares v. COMELEC ( G R. លេខ ២២១៦៩៧ និង

រដ្ឋធម្មនុញ្ញ កុមារទើបនឹងកើត ដែលត្រូវបានរកឃើញនៅក្នុងប្រទេសសិង្ហបុរី ដែលមិនស្គាល់ និងមិនអាចបញ្ជាក់អំពីឪពុកម្តាយបាន រហូតទល់តែមានភ័ស្តុតាងបញ្ជាក់អំពីការជំទាស់ ត្រូវចាត់ទុកថាជាពលរដ្ឋសិង្ហបុរីពីកំណើត ហើយកាលបរិច្ឆេទនៃការរកឃើញនឹងក្លាយជាថ្ងៃខែឆ្នាំកំណើតរបស់កុមាររូបនោះ។[226] នៅប្រទេសថៃ កុមារបាត់ខ្លួនដែលត្រូវបានបញ្ជាក់អះអាងថាបានកើតនៅក្នុងប្រទេស និងដោយគ្មានឪពុក និងម្តាយ គឺជាកម្មវត្ថុនៃបញ្ញត្តិនានា ក្រោមមាត្រា ៧ ស្ទួន នៃច្បាប់ស្តីពីសញ្ជាតិ ឆ្នាំ១៩៦៥ (ពស. ២៥០៨)។[227] ស្របតាមច្បាប់របស់ប្រទេសវៀតណាម កុមារទើបនឹងកើតដែលត្រូវបានបោះបង់ និងកុមារដែលត្រូវបានរកឃើញនៅក្នុងដែនដីវៀតណាម ដែលមិនស្គាល់ឪពុកម្តាយរបស់ពួកគេ មានសញ្ជាតិវៀតណាម។ ទោះបីជាយ៉ាងណាក៏ដោយ ចំពោះកុមារដែលមានអាយុក្រោម ១៥ ឆ្នាំ ពួកគេនឹងលែងមានសញ្ជាតិវៀតណាមទៀតហើយ ប្រសិនបើគាត់បានរកឃើញឪពុកម្តាយរបស់គាត់ ដែលមានសញ្ជាតិបរទេស ឬ គាត់បានរកឃើញម្តាយ ឬ ឪពុករបស់គាត់ ដែលមានសញ្ជាតិបរទេស។[228]

វាមានសារសំខាន់នៅក្នុងការលើកឡើងថា មានការយល់ព្រមជាឯកច្ឆ័ន្ទលើបញ្ហាកុមារបាត់ខ្លួន ដោយ AMS ទាំងដប់ នៅក្នុងអំឡុងពេលនៃសិក្ខាសាលាស្តីពីការប្រឹក្សាយោបល់ថ្នាក់តំបន់ ស្តីពីការលើកកម្ពស់បរិយាប័ន្ន និង ការអភិវឌ្ឍប្រកបដោយចីរភាពនៅក្នុងការបង្កើតសហគមន៍អាស៊ាន តាមរយៈការធានាចំពោះការទទួលស្គាល់អត្តសញ្ញាណតាមផ្លូវច្បាប់របស់ស្ត្រី និងកុមារគ្រប់រូបនៅអាស៊ាន ដែលត្រូវបានប្រារព្ធធ្វើឡើងនៅទីក្រុងដាឡាត់ ប្រទេសវៀតណាម នៅថ្ងៃទី០៨-០៩ ខែវិច្ឆិកា ឆ្នាំ២០១៨។ គេបានព្រមព្រៀងគ្នាថា "ដើម្បីអត្ថប្រយោជន៍របស់ AMS និង ដើម្បីឧត្តមប្រយោជន៍របស់កុមារ កុមារបាត់ខ្លួនគ្រប់រូបគួរតែត្រូវបានចុះបញ្ជី និង ថាពួកគេគួរតែទទួលបានសញ្ជាតិ"។ ACWC បានយល់ព្រមបន្តការស្វែងរកមតិគាំទ្រនៅថ្នាក់តំបន់ស្តីពីបញ្ហានេះ។

ចូរមើល**តារាងទី៩** ស្តីពីក្របខណ្ឌច្បាប់របស់ AMS ពាក់ព័ន្ធនឹងការទទួលបានសញ្ជាតិដោយកុមារបាត់ខ្លួន និង កូនសុំ នៅក្នុងឧបសម្ព័ន្ធ ទំព័រ ១៣៤។

### ឃ) កុមារគ្មានសញ្ជាតិ និងកុមារដែលមិនអាចទទួលបានសញ្ជាតិផ្សេងទៀត

មាន AMS តិចតួចខ្លាំងណាស់ដែលមានបញ្ញត្តិពាក់ព័ន្ធនឹង ការផ្តល់សញ្ជាតិដល់កុមារ/ជនគ្មានសញ្ជាតិ។ នៅប្រទេសប្រ៊ុយណេដារូសាឡឹម ពាក្យស្នើសុំសម្រាប់កុមារគ្មានសញ្ជាតិ និងកុមារដែលមិនអាចទទួលបានសញ្ជាតិផ្សេងទៀត អាចត្រូវបានធ្វើឡើងស្របតាម ជំពូក ១៥ នៃច្បាប់ស្តីពីសញ្ជាតិប្រ៊ុយណេ មាត្រា ៤ ៥ ៦ និង ៨។[229] ទោះបីជារបាយការណ៍ប្រទេសកម្ពុជាចែងថា ពុំមាន

---

២២១៦៩៨-៧០០ ថ្ងៃទី០៨ ខែមីនា ឆ្នាំ២០១៦) តុលាការជាន់ខ្ពស់បានធ្វើសេចក្តីសម្រេចជាពិសេសចំពោះសំណុំរឿង David v. SET ថា "កុមារបាត់ខ្លួនគ្រប់រូបដែលត្រូវបានរកឃើញនៅក្នុងប្រទេសហ្វីលីពីន ដែលយ៉ាងហោចណាស់មានឪពុកជាពលរដ្ឋហ្វីលីពីន ឬម្តាយជាពលរដ្ឋហ្វីលីពីន ដូច្នេះពួកគេជាពលរដ្ឋហ្វីលីពីនពីកំណើត លើកលែងមានការបញ្ជាក់អះអាងសំខាន់ៗផ្សេងពីនេះ"។ ជាពិសេស នៅក្នុងសំណុំរឿង Poe- Llamanzares តុលាការបានប្រកាសថា តាមច្បាប់ កុមារបាត់ខ្លួនត្រូវបានចាត់ថ្នាក់ជាពលរដ្ឋពីកំណើត ថាច្បាប់ក្នុងប្រទេសស្តីពីសុំកូន ផ្តល់ការគាំទ្រដល់គោលការណ៍ដែលថាកុមារបាត់ខ្លួនគឺជាពលរដ្ឋហ្វីលីពីន ថាកូនសុំត្រូវតែជាពលរដ្ឋហ្វីលីពីន នៅពេលដំបូងដែលត្រូវបានសុំ ថាច្បាប់ស្តីពីសុំកូននៅប្រទេសហ្វីលីពីន ដូចជា ច្បាប់សាធារណរដ្ឋ (R.A.) លេខ ៨០៤៣ (ច្បាប់សុំកូនអន្តរប្រទេស) និង R.A. លេខ ៨៥៥២ (ច្បាប់ស្តីពីសុំកូនក្នុងប្រទេស) និង សេចក្តីសម្រេចរបស់តុលាការកំពូល (SC) លើសុំកូនក្រោមបញ្ជារដ្ឋបាល (A.M.) លេខ ០២-៦០២-SC គ្រប់ចំណុចទាំងអស់ត្រូវបានសំដៅយ៉ាងច្បាស់លើ "កុមារហ្វីលីពីន" និង រួមបញ្ចូលកុមារបាត់ខ្លួននៅក្នុងចំណោមកុមារហ្វីលីពីនដែលអាចត្រូវបានសុំ ថាក្រសួងការបរទេស (DFA) ចេញលិខិតឆ្លងដែនជូនកុមារបាត់ខ្លួន លិខិតឆ្លងដែនត្រូវបានចេញជូនតែពលរដ្ឋប៉ុណ្ណោះ និងថាកុមារបាត់ខ្លួនត្រូវបានចាត់ទុកថាជាពលរដ្ឋ ស្របតាមច្បាប់អន្តរជាតិ ដោយបានដកស្រង់ មាត្រា ១៥ នៃសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស មាត្រា ៧ នៃអនុសញ្ញាស្តីពីសិទ្ធិកុមារ មាត្រា ២៤ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និង សិទ្ធិនយោបាយ មាត្រា ១៤ នៃអនុសញ្ញាទីក្រុងឡាអេ និង មាត្រា ២ នៃអនុសញ្ញាស្តីពីការកាត់បន្ថយភាពគ្មានសញ្ជាតិ ឆ្នាំ១៩៦១"។

226 របាយការណ៍របស់ប្រទេសសិង្ហបុរី។

227 របាយការណ៍របស់ប្រទេសថៃ។

228 របាយការណ៍របស់ប្រទេសវៀតណាម។

229 ពាក្យស្នើសុំប្រភេទនេះអាចត្រូវបានទទួលយក ស្របតាមជំពូក ១៥ នៃច្បាប់ស្តីពីសញ្ជាតិប្រ៊ុយណេ មាត្រា ៤ មាត្រា ៥ មាត្រា ៦ និង មាត្រា ៨។ របាយការណ៍របស់ប្រទេសប្រ៊ុយណេដារូសាឡឹម។

ទិន្នន័យដែលអាចស្វែងរកបាន និងមិនបានផ្តល់ទិន្នន័យអំពីកុមារគ្មានសញ្ជាតិក៏ដោយ ច្បាប់ជាតិស្តីពីសញ្ជាតិអាចត្រូវបានអនុវត្ត ចំពោះកុមារគ្មានសញ្ជាតិ ដោយមិនចាំបាច់ដាក់ពាក្យស្នើសុំសញ្ជាតូបនីយកម្មនោះទេ។[230] ច្បាប់ស្តីពីសញ្ជាតិរបស់ប្រទេសឡាវ មានលក្ខណៈបើកចំហរដូចគ្នានឹងច្បាប់របស់ប្រទេសកម្ពុជាដែរ។ ទោះបីជាគ្មានបញ្ញត្តិដែលលើកឡើងអំពីកុមារគ្មានសញ្ជាតិ និងកុមារដែលសញ្ជាតិរបស់ពួកគេត្រូវបានបំផ្លាញ ក៏ដោយក៏ច្បាប់ចែងថា កុមារដែលជាកូនរបស់ឪពុកម្តាយដែលគ្មានសញ្ជាតិ នៅក្នុងដែនដីឡាវ ដែលស្នាក់នៅជាអចិន្ត្រៃយ៍នៅប្រទេសឡាវ និងធ្វើសមាហរណកម្មនៅក្នុងសង្គម និង វប្បធម៌ឡាវ នឹងទទួលបានភាពជាពលរដ្ឋឡាវ ប្រសិនបើមានការស្នើសុំពីសំណាក់ឪពុកម្តាយរបស់ពួកគេ។[231] នៅប្រទេសម៉ាឡេស៊ី មាត្រា ១៤(១)(ខ) ផ្នែក II (១)(ង) នៃឧបសម្ព័ន្ធទីពីរនៃរដ្ឋធម្មនុញ្ញរបស់សហព័ន្ធ ត្រូវបានដកស្រង់ជានីតិគំរូ សម្រាប់ការទប់ស្កាត់ភាព គ្មានសញ្ជាតិ។ ទោះបីជាយ៉ាងណាក៏ដោយ ការការពារដែលត្រូវបានផ្តល់ជូនដោយមាត្រានេះ មិនលាតសន្ធឹងទៅកាន់កុមារជាច្រើននាក់ ដែលគ្មានសញ្ជាតិ ឬ ប្រឈមមុខនឹងហានិភ័យនៃការគ្មានសញ្ជាតិនៅក្នុងប្រទេសនោះទេ។ នៅខណៈពេលដែលមាត្រានេះចែងថា កុមារដែលកើតនៅក្នុងប្រទេសម៉ាឡេស៊ី តាមរយៈប្រតិបត្តិការរបស់ច្បាប់ គឺជាពលរដ្ឋម៉ាឡេស៊ី ប្រសិនបើគាត់ ឬនាង “មិនមែនជាពលរដ្ឋរបស់ប្រទេសណាមួយទេនោះ” នៅតែបន្តមានការចេញសំបុត្រកំណើត ជូនក្រុមកុមារដែលគេមិនអើពើ ដូចជា កុមារដែលត្រូវគេបោះបង់ចោលនៅផ្ទះ Jabatan Kebajikan Masyarakat (JKM)[232] ដោយគ្មានឯកសារអត្តសញ្ញាណជាដើមដែលចាចែងអំពីភាពឋានៈនៃភាព ជាពលរដ្ឋរបស់កុមារថាជា “bukan warganegara” (មិនមែនជាពលរដ្ឋ) ទោះបីជាពួកគេមិនមែនជាពលរដ្ឋរបស់ប្រទេសណាមួយផ្សេងទៀតក៏ដោយ។[233]

នៅក្នុងឆ្នាំ១៩៥៥ ប្រទេសហ្វីលីពីន គឺជាប្រទេសមួយក្នុងចំណោមប្រទេសដំបូងៗដែលបានចុះហត្ថលេខាលើអនុសញ្ញាដែលទាក់ទងនឹងឋានៈរបស់ជនគ្មានសញ្ជាតិ ឆ្នាំ១៩៥៤ និងជាប្រទេសនៃទ្វីបអាស៊ីដំបូងគេបង្អស់ ដែលក្លាយជារដ្ឋភាគីនៃអនុសញ្ញាដែលបានពោល នៅខែកញ្ញាឆ្នាំ២០១១។[234] នីតិវិធីកំណត់ភាពគ្មានសញ្ជាតិ នឹងត្រូវដំណើរការដោយនាយកដ្ឋានយុត្តិធម៌ តាមរយៈអង្គភាពការពារជនភៀសខ្លួន និង ជនគ្មានសញ្ជាតិ (RSPPU) ស្របតាមសារាចររបស់នាយកដ្ឋាន DOJ (D.C.) លេខ ៥៨ ចេញនៅឆ្នាំ២០១២។[235] ក្រោយមក ជនគ្មានសញ្ជាតិ ដូចដែលត្រូវបានកំណត់ដោយ RSPPU អាចដាក់ពាក្យស្នើសុំសញ្ជាតូបនីយកម្ម តាមប្រព័ន្ធតុលាការ ឬ រដ្ឋបាល ស្របតាមច្បាប់របស់ប្រទេសហ្វីលីពីន។[236] ប្រទេសហ្វីលីពីន ជាក់ស្តែងពុំមានជនឬប្រជាជនគ្មានសញ្ជាតិដោយផ្ទាល់នោះទេ ផ្អែកតាមនិយមន័យរបស់ជនគ្មានសញ្ជាតិ ស្របតាមអនុសញ្ញាស្តីពីភាពគ្មានសញ្ជាតិ ឆ្នាំ១៩៥៤ “មនុស្សម្នាក់ដែលមិនត្រូវបានចាត់ទុក ថាជាពលរដ្ឋដោយរដ្ឋណាមួយ ស្របតាមប្រតិបត្តិការនៃច្បាប់របស់រដ្ឋនោះ”។ ទោះបីជាយ៉ាងណាក៏ដោយ នៅឆ្នាំ ២០១០-២០១១ រដ្ឋាភិបាលហ្វីលីពីន ដោយបានសហការជាមួយ UNHCR បានរៀបចំកិច្ចប្រជុំ



230 ការបកស្រាយត្រូវបានធ្វើឡើងដោយអ្នកនិពន្ធ ដោយផ្អែកលើរបាយការណ៍របស់ប្រទេសកម្ពុជា។

231 របាយការណ៍របស់ប្រទេសឡាវ។

232 ឬនាយកដ្ឋានសុខមាលភាពសង្គមនៃប្រទេសម៉ាឡេស៊ី។

233 របាយការណ៍របស់ប្រទេសម៉ាឡេស៊ី។

234 ធាតុចូលបន្ថែមពីជនបង្គោលនៃប្រទេសហ្វីលីពីន។

235 សារាចររបស់នាយកដ្ឋាន លេខ ៥៨ ស្តីពីការបង្កើតនីតិវិធីកំណត់ឋានៈរបស់ជនភៀសខ្លួន និង ជនគ្មានសញ្ជាតិ Refworld https://www.refworld.org/pdfid/5086932e2.pdf.

236 របាយការណ៍របស់ប្រទេសហ្វីលីពីន។

តុមូលអន្តរទីភ្នាក់ងារ ជាលទ្ធផល បានសម្គាល់ឃើញប្រជាជន "ដែលប្រឈមនឹងហានិភ័យនៃភាពគ្មានសញ្ជាតិ" រួមមាន៖

ក. កុមារដែលមិនបានចុះបញ្ជី ឬ កុមារដែលគ្មានបញ្ជីកំណើត

ខ. កុមារបាត់ខ្លួន

គ. កុមារដែលមានដើមកំណើតហ្វីលីពីន នៅតាមបណ្ដាទីតាំងធ្វើអន្តោប្រវេសន៍ (កុមារដែលកើតនៅប្រទេសអារ៉ាប៊ីសាអូឌីត សាបា ឬ ប្រទេសជប៉ុន)

ឃ. ជនដែលមានដើមកំណើតឥណ្ឌូនេស៊ីនៅក្នុងប្រទេសហ្វីលីពីនភាគខាងត្បូង (Marori ឬ Sangir) និង

ង. The Badjaos (Sama Dilaut ឬ ប្រជាជនរស់នៅលើទូក)។[237]

ដូចគ្នានឹង PIDs ដែរ អាចមានប្រជាជនដទៃទៀត ដែលមានវត្តមាននៅក្នុងប្រទេសដែលប្រឈមមុខ នឹងហានិភ័យនៃភាពគ្មានសញ្ជាតិ ហៅថា ជនដែលមានដើមកំណើតជប៉ុន ដែលរួមបញ្ចូលកូនស្របច្បាប់របស់ម្ដាយ ដែលជាពលរដ្ឋហ្វីលីពីន និង ឪពុកជាពលរដ្ឋជប៉ុន នៅក្នុងអំឡុងសម័យសង្គ្រាមលោកលើកទី២ និង ស្របតាមប្រសិទ្ធភាពអនុវត្តនៃអនុសញ្ញាឆ្នាំ១៩៣៥។[238] នៅក្នុងករណីនេះ សញ្ជាតូបនីយកម្ម គឺជាដំណោះស្រាយមួយដើម្បីទទួលយកជនដែលគ្មានសញ្ជាតិ។[239] របាយការណ៍របស់ប្រទេសសិង្ហបុរីបានលើកឡើងថា ជនគ្មានសញ្ជាតិ អាចដាក់ពាក្យស្នើសុំភាពជានិវាសនជនអចិន្ត្រៃយ៍ និង ភាពជាពលរដ្ឋសិង្ហបុរីបាន។ ពាក្យស្នើសុំភាពជានិវាសនជន អចិន្ត្រៃយ៍ និង ភាពជាពលរដ្ឋសិង្ហបុរី នីមួយៗ ត្រូវបានប៉ាន់ប្រមាណលើគុណសម្បត្តិនៃពាក្យស្នើសុំនោះផ្ទាល់ និង ផ្អែកតាមលក្ខខណ្ឌតម្រូវ សម្រាប់សិទ្ធិទទួលបាននៅពេលនោះ។ ជាក់ស្ដែង "កុមារចំណាកស្រុក" ដែលជាកូនរបស់ជនបរទេសនៅក្នុងប្រទេសសិង្ហបុរី នឹងត្រូវផ្ដល់ជូននូវសិទ្ធិឆ្លងកាត់ពិសេស ដើម្បីស្នាក់នៅក្នុងប្រទេសសិង្ហបុរីបន្តទៀត ដែលមានសុពលភាពរយៈពេល ៤២ ថ្ងៃចាប់ពីថ្ងៃកើត។ ក្រោយរយៈពេលនោះ ដើម្បីស្នាក់នៅក្នុងប្រទេសសិង្ហបុរីបន្តទៀត ត្រូវតែស្នើសុំការបន្តសិទ្ធិឆ្លងកាត់ពិសេស ឬ ការឆ្លងកាត់សម្រាប់អន្តោប្រវេសន៍ ឬ លិខិតអនុញ្ញាត សម្រាប់កុមាររូបនោះ។[240] កុមារគ្មានសញ្ជាតិដែលកើតនៅប្រទេសថៃ អាចទទួលបានសញ្ជាតិថៃ យោងតាម មាត្រា ៧ (២) នៃច្បាប់ស្ដីពីសញ្ជាតិ។ នៅក្នុងករណីកុមារគ្មានសញ្ជាតិដែលមិនអាចទទួលបានសញ្ជាតិថៃ យោងតាម មាត្រា ៧ ស្ទួន (១) (២) ឬ (៣) ពួកគេអាចទទួលបានសញ្ជាតិថៃ ប្រសិនបើពួកគេបំពេញតាមលក្ខណៈសម្បត្តិនានាដែលបញ្ញត្តិ ដោយរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ យោងតាម មាត្រា ៧ ស្ទួន កថាខណ្ឌទី២។[241] ច្បាប់ស្ដីពីសញ្ជាតិរបស់**ប្រទេសវៀតណាម** មានលក្ខណៈបើកចំហរគួរសមចំពោះជនគ្មានសញ្ជាតិ ព្រោះវាបង្កើតលក្ខខណ្ឌនានា ឲ្យកុមារដែលកើតនៅលើដែនដីវៀតណាម មានសញ្ជាតិវៀតណាម និង ជនគ្មានសញ្ជាតិដែលស្នាក់នៅជាអចិន្ត្រៃយ៍នៅក្នុងប្រទេសវៀតណាម ទទួលបានសញ្ជាតិវៀតណាម។ ច្បាប់នេះចែងថា កុមារម្នាក់ដែលកើតនៅលើដែនដីវៀតណាម ដែលឪពុកម្ដាយរបស់កុមារ នៅពេលដែលគាត់កើត គឺជាជនគ្មានសញ្ជាតិទាំងពីរនាក់ ដែលកំពុងតែស្នាក់នៅជាអចិន្ត្រៃយ៍នៅក្នុងប្រទេសវៀតណាម មានសញ្ជាតិវៀតណាម និង ថាកុមារដែលកើតនៅលើទឹកដីវៀតណាម ដែលម្ដាយរបស់កុមារនោះ នៅពេលដែលគាត់កើត គឺជាជនគ្មានសញ្ជាតិ ដែលកំពុងតែស្នាក់នៅជាអចិន្ត្រៃយ៍នៅក្នុងប្រទេសវៀតណាម និងដែលមិនស្គាល់ឪពុករបស់កុមារនោះ មានសញ្ជាតិវៀតណាម។[242]

ចូរមើល**តារាងទី៦** ស្ដីពីក្របខណ្ឌច្បាប់របស់ AMS ពាក់ព័ន្ធនឹងការទទួលបានសញ្ជាតិដោយកុមារ / ជនគ្មានសញ្ជាតិ នៅក្នុងឧបសម្ព័ន្ធ ទំព័រ ១៣៦។

237 Ibid.

238 Ibid.

239 Ibid.

240 របាយការណ៍របស់ប្រទេសសិង្ហបុរី។ ទោះបីជាយ៉ាងណាក៏ដោយ អ្នកតំណាងរបស់ប្រទេសសិង្ហបុរី នៅ ACWC បានលាតត្រដាងក្នុងអំឡុងពេលសិក្ខាសាលាពិគ្រោះយោបល់ថ្នាក់តំបន់ ស្ដីពី "ការលើកកម្ពស់បរិយាប័ន្ន និង ការអភិវឌ្ឍប្រកបដោយចីរភាពនៅក្នុងការកសាងសហគមន៍អាស៊ាន តាមរយៈការធានាបាននូវការទទួលស្គាល់អត្តសញ្ញាណតាមផ្លូវច្បាប់របស់ស្ត្រី និង កុមារគ្រប់រូបនៅអាស៊ាន" ថាមានជនគ្មានសញ្ជាតិចំនួន ១.១៤១ នាក់នៅប្រទេសសិង្ហបុរី។

241 របាយការណ៍របស់ប្រទេសថៃ។

242 របាយការណ៍របស់ប្រទេសវៀតណាម។

### ង) សញ្ជាតូបនីយកម្ម

ច្បាប់របស់ AMS ទាំងអស់ បានចែងអំពីសញ្ជាតូបនីយកម្ម។ ច្បាប់ស្តីពីសញ្ជាតិរបស់ ប្រទេសប្រ៊ុយណេដារូសាឡឹម អនុញ្ញាតឲ្យមានសញ្ជាតូបនីយកម្មតាមរយៈការដាក់ពាក្យស្នើសុំ យោងតាមការបំពេញលក្ខខណ្ឌនានាដែលត្រូវបានតម្រូវ រួមមាន រយៈពេលស្នាក់នៅក្នុងប្រទេសប្រ៊ុយណេដារូសាឡឹម ការត្រួតពិនិត្យលើភាសាម៉ាឡេ ការមានអត្តចរិតល្អ និងមានការស៊ើបអង្កេតផ្នែកសន្តិសុខដ៏ច្បាស់លាស់មួយ។[243] មានព័ត៌មានតិចតួចណាស់ដែលពាក់ព័ន្ធនឹងសញ្ជាតូបនីយកម្ម ត្រូវបានផ្តល់ជូននៅក្នុងរបាយការណ៍របស់ប្រទេសកម្ពុជា។ ទោះបីជាយ៉ាងណាក៏ដោយ គេអាចសន្មតបានថា បុគ្គលដែលមិនមែនជាពលរដ្ឋកម្ពុជាពីកំណើត អាចទទួលបានសញ្ជាតិតាមរយៈអាពាហ៍ពិពាហ៍ ឬ សញ្ជាតូបនីយកម្ម។[244] នៅប្រទេសឡាវ សញ្ជាតូបនីយកម្មរបស់ពលរដ្ឋបរទេស ឬ ជនមិនមែនជាពលរដ្ឋ អាចត្រូវបានផ្តល់ជូនដោយផ្អែកលើលក្ខខណ្ឌមួយចំនួន ដូចជា មានអាយុ ១៨ ឆ្នាំឡើងទៅ គោរពរដ្ឋធម្មនុញ្ញ និង ច្បាប់របស់ប្រទេសឡាវ និយាយ អាន និងសរសេរភាសាឡាវបានយ៉ាងស្ទាត់ជំនាញ មានភ័ស្តុតាងបញ្ជាក់អំពីការធ្វើសមាហរណកម្មផ្នែកសង្គម និងវប្បធម៌ និងមានចំណេះដឹង និងគោរពប្រពៃណីឡាវ មានសុខភាពល្អ និងពុំមានជំងឺឆ្លងធ្ងន់ធ្ងរណាមួយ ឬ មិនញៀនថ្នាំ មិនត្រូវបានកាត់ទោសឲ្យជាប់ពន្ធនាគារដោយតុលាការណាមួយ ចូលរួមនៅក្នុងការការពារ និងអភិវឌ្ឍប្រទេស មិនបានបង្កក្តីអន្តរាយចំពោះផលប្រយោជន៍ជាតិ យល់ព្រមបោះបង់សញ្ជាតិកាលពីមុនរបស់ពួកគេ (លើកលែងតែពួកគេគ្មានសញ្ជាតិ) និង (បានបង្កើត) ការស្នាក់នៅចិន្ត្រៃយ៍ជាបន្តបន្ទាប់នៅសាធារណរដ្ឋប្រជាមានិតឡាវ អស់រយៈពេលដប់ឆ្នាំ មុនពេលដាក់ពាក្យស្នើសុំសញ្ជាតិ។[245] រយៈពេលស្នាក់នៅដែលត្រូវបានតម្រូវ អាចត្រូវបានកាត់បន្ថយសម្រាប់បុគ្គល ដែលមានលក្ខណៈសម្បត្តិផ្នែកវិជ្ជាជីវៈនៅកម្រិតជំនាញណាមួយ ឬ មានវិជ្ជាជីវៈ និងលក្ខណៈសម្បត្តិនៅក្នុងផ្នែកមួយចំនួន និង មានស្ថានភាពសេដ្ឋកិច្ចដែលមាន លំនឹង។[246] គេបានកត់សម្គាល់ថា ប្រទេសឡាវ មិនអនុញ្ញាតឲ្យមានសញ្ជាតិពីរនោះទេ។ ច្បាប់នៅក្នុង**ប្រទេសម៉ាឡេស៊ី** ក៏ចែងអំពីសញ្ជាតូបនីយកម្មផងដែរ។ មានលក្ខខណ្ឌនានាសម្រាប់ ការដាក់ពាក្យស្នើសុំសញ្ជាតិម៉ាឡេស៊ី រួមមាន ការមានអាយុលើសពី ២១ឆ្នាំ ស្នាក់នៅប្រទេសម៉ាឡេស៊ីក្នុងរយៈពេលដែលត្រូវបានតម្រូវ[247] និងមានបំណង ប្រសិនបើមានលិខិតបញ្ជាក់ ត្រូវបានផ្តល់ជូនស្នាក់នៅប្រទេសម៉ាឡេស៊ីជាអចិន្ត្រៃយ៍ មានអត្តចរិតល្អ និងចេះភាសាម៉ាឡេក្នុងកម្រិតសមស្រប។[248] ច្បាប់ស្តីពីសញ្ជាតិនៃ**ប្រទេសមីយ៉ាន់ម៉ា** ចែងអំពីសញ្ជាតូបនីយកម្មសម្រាប់ក្រុមមនុស្សខុសៗគ្នា។[249] នេះមានន័យថា សញ្ជាតូបនីយកម្មនៅក្នុងប្រទេសមីយ៉ាន់ម៉ា គឺអាស្រ័យលើកាលបរិច្ឆេទចុះបញ្ជីនៅក្នុងប្រទេសមីយ៉ាន់ម៉ា និង ប្រភេទភាពជា



243 របាយការណ៍របស់ប្រទេសប្រ៊ុយណេដារូសាឡឹម។

244 របាយការណ៍របស់ប្រទេសកម្ពុជា។

245 របាយការណ៍របស់ប្រទេសឡាវ។

246 Ibid.

247 ដែលមានចំនួនសរុប មិនតិចជាង ១០ ឆ្នាំ ក្នុងរយៈពេល ១២ ឆ្នាំភ្លាមៗមុនកាលបរិច្ឆេទនៃពាក្យស្នើសុំលិខិតបញ្ជាក់ និង រួមបញ្ចូលរយៈពេល ១២ ខែភ្លាមៗមុនកាលបរិច្ឆេទនោះ។ នឹងបានបន្ថែមថា ការស្នាក់នៅមុនទិវាបុណ្យជាតិម៉ាឡេស៊ី នៅលើដែនដីនានា រួមមាន នៅរដ្ឋ សាបា និង Sarawak នឹងត្រូវចាត់ទុកជាការស្នាក់នៅក្នុងសហព័ន្ធ និង សម្រាប់គោលបំណងនៃខចែង (២) ការស្នាក់នៅក្នុងប្រទេសសិង្ហបុរីមុនទិវាបុណ្យជាតិម៉ាឡេស៊ី ឬ ដោយមានការឯកភាពពីរដ្ឋាភិបាលសហព័ន្ធ ការស្នាក់នៅក្រោយទិវាបុណ្យជាតិម៉ាឡេស៊ី នឹងត្រូវបានចាត់ទុកថាជាការស្នាក់នៅក្នុងសហព័ន្ធ។ របាយការណ៍របស់ប្រទេសម៉ាឡេស៊ី។

248 Ibid.

249 របាយការណ៍របស់ប្រទេសមីយ៉ាន់ម៉ាចែងថា៖

ពលរដ្ឋនៃ ឪពុកម្ដាយរបស់បុគ្គលរូបនោះ។[250] មាត្រា ៨ (ក) នៃច្បាប់ស្ដីពីភាពជាពលរដ្ឋមីយ៉ាន់ម៉ា ចែងថា ប្រធានាធិបតីរបស់រដ្ឋ ឬរដ្ឋាភិបាលរបស់សហភាព ដើម្បីផលប្រយោជន៍របស់រដ្ឋ អាចផ្ដល់ភាគជាពលរដ្ឋ ឬ ភាពជាពលរដ្ឋតាមផ្លូវច្បាប់ ឬ ភាពជាពលរដ្ឋដែលបានធ្វើសញ្ជាតូបនីយកម្ម ដល់នរណាម្នាក់បាន។[251] នៅប្រទេសហ្វីលីពីន មានវិធីបីស្របតាមក្របខណ្ឌច្បាប់បច្ចុប្បន្ន ដែលជនមិនមែនជាពលរដ្ឋអាចក្លាយជាពលរដ្ឋហ្វីលីពីន បានតាមរយៈសញ្ជាតូបនីយកម្ម។[252] ជនដែលមានដើមកំណើតបរទេស មានជម្រើសដាក់ពាក្យស្នើសុំសញ្ជាតូបនីយ-កម្ម តាមផ្លូវតុលាការ ឬតាមផ្នែករដ្ឋបាល អាស្រ័យលើការមាន និងគ្មានលក្ខណៈសម្បត្តិដែលត្រូវបានបញ្ញត្តិ។ ដូច្នេះ វាមិនពិបាកសន្មតនោះទេថា “ជនគ្មានសញ្ជាតិដែលត្រូវបានកំណត់ដោយ DOJ-RSPPU អាចមានលក្ខណៈគ្រប់គ្រាន់ នៅក្នុងការប្រើប្រាស់ដំណោះស្រាយនៃសញ្ជាតូបនីយកម្មតាមផ្លូវច្បាប់ តាមវិធីណាមួយដូចដែលត្រូវបានរៀបរាប់ នៅក្នុងយុត្តិសាស្ត្រ ដែលបានដកស្រង់ដែលអាចអនុវត្តបានចំពោះពួកគេ”។[253] លក្ខខណ្ឌតម្រូវមួយចំនួន មានលក្ខណៈខុសគ្នាពីប្រទេសដទៃទៀត ពីព្រោះច្បាប់នៅក្នុងប្រទេសហ្វីលីពីនតម្រូវឲ្យមានការស្នាក់នៅរយៈពេលដប់ឆ្នាំជាបន្តបន្ទាប់ ប៉ុន្តែលក្ខខណ្ឌនេះ អាចត្រូវបានកាត់បន្ថយមកត្រឹមប្រាំឆ្នាំ សម្រាប់អ្នក ដាក់ពាក្យស្នើសុំដែលបានបំពេញតាមលក្ខខណ្ឌមួយចំនួន។[254] លើសពីនេះទៀត ភាពជាពលរដ្ឋហ្វីលីពីនក៏អាចត្រូវបានផ្ដល់ជូនតាមរយៈទង្វើរបស់សមាជចំពោះជនបរទេសដែលបានធ្វើការរួមចំណែក



- ជនដែលបានចូល និង បានស្នាក់នៅក្នុងរដ្ឋ មុនថ្ងៃទី០៤ ខែមករា ឆ្នាំ១៩៤៨ និង កូនៗរបស់ពួកគេ ដែលកើតនៅក្នុងរដ្ឋ ប្រសិនបើមិនទាន់បានដាក់ពាក្យស្នើសុំស្របតាមច្បាប់ស្ដីពីភាពជាពលរដ្ឋរបស់សហភាព ឆ្នាំ១៩៤៨ អាចដាក់ពាក្យស្នើសុំភាពជាពលរដ្ឋដែលបានធ្វើសញ្ជាតូបនីយកម្ម ទៅកាន់អង្គភាពថ្នាក់កណ្ដាលបាន
- ជនដែលកើតនៅក្នុង ឬ នៅក្រៅរដ្ឋ ចាប់ពីកាលបរិច្ឆេទដែលច្បាប់នេះចូលជាធរមាន (ឆ្នាំ១៩៨២) ក៏អាចដាក់ពាក្យស្នើសុំភាពជាពលរដ្ឋដែលបានធ្វើសញ្ជាតូបនីយកម្មបានដែរ
- ជនដែលមានឪពុកម្ដាយម្នាក់ជាពលរដ្ឋ និង ម្នាក់ទៀតជាជនបរទេស
- ជនដែលមានឪពុកម្ដាយម្នាក់ជាពលរដ្ឋតាមផ្លូវច្បាប់ និង ម្នាក់ទៀតជាពលរដ្ឋដែលបានធ្វើសញ្ជាតូបនីយកម្ម
- ជនដែលមានឪពុកម្ដាយ ដែលម្នាក់ក្នុងចំណោមពួកគេជាពលរដ្ឋតាមផ្លូវច្បាប់ និង ម្នាក់ទៀតជាជនបរទេស
- ជនដែលមានឪពុកម្ដាយទាំងពីរនាក់ជាពលរដ្ឋដែលបានធ្វើសញ្ជាតូបនីយកម្ម
- ជនដែលមានឪពុកម្ដាយម្នាក់ជាពលរដ្ឋដែលបានធ្វើសញ្ជាតូបនីយកម្ម និង ម្នាក់ទៀតជាជនបរទេស។

250 របាយការណ៍របស់ប្រទេសមីយ៉ាន់ម៉ា។

251 Ibid.

252 ជម្រើសរួមមាន៖

ក) សញ្ជាតូបនីយកម្មផ្នែករដ្ឋបាល យោងតាមច្បាប់សាធារណរដ្ឋ (R.A.) លេខ ៩១៣៩ ឬ ហៅម៉្យាងទៀតថា ច្បាប់ស្ដីពីសញ្ជាតូបនីយ-កម្មផ្នែករដ្ឋបាល ឆ្នាំ២០០០

ខ) សញ្ជាតូបនីយកម្មតាមប្រព័ន្ធតុលាការ យោងតាមច្បាប់រដ្ឋសហធន (C.A.) លេខ ៤៧៣ ឬ ហៅម៉្យាងទៀតថា ច្បាប់ស្ដីពីសញ្ជាតូប-នីយកម្មផ្នែករដ្ឋបាលដែលបានកែសម្រួលឡើងវិញ ដែលបានធ្វើវិសោធនកម្ម និង

គ) សញ្ជាតូបនីយកម្មតាមនីតិកម្ម នៅក្នុងទម្រង់នៃច្បាប់មួយដែលត្រូវបានអនុម័តដោយសមាជ ដែលផ្ដល់ភាពជាពលរដ្ឋហ្វីលីពីនដល់ជនបរទេសណាម្នាក់។ ធាតុចូលបន្ថែមទៀតដែលត្រូវបានផ្ដល់ជូនដោយប្រទេសហ្វីលីពីន C.A. លេខ ៤៧៣ និង R.A. លេខ ៩១៣៩ គឺជាច្បាប់ដាច់ដោយឡែកពីគ្នា និង ខុសគ្នា – C.A. លេខ ៤៧៣ គ្របដណ្ដប់លើជនបរទេសគ្រប់រូប ដោយមិនគិតអំពីវណ្ណៈនោះទេ នៅខណៈពេលដែល R.A. លេខ ៩១៣៩ គ្របដណ្ដប់លើជនដែលមានដើមកំណើតបរទេស ដែលបានរស់នៅទីនេះ នៅក្នុងប្រទេសហ្វីលីពីនពេញមួយជីវិត ដែលមិនធ្លាប់ឃើញនៅប្រទេសណាមួយផ្សេងទៀត និង តែងតែត្រូវបានគេគិតថា ពួកគេគឺជាពលរដ្ឋហ្វីលីពីន ដែលបានបង្ហាញអំពីសេចក្ដីស្រលាញ់ និង ភាពស្មោះត្រង់ចំពោះប្រទេសហ្វីលីពីន និង ចូលចិត្តទំនៀមទម្លាប់ និង ប្រពៃណី។ នៅចំណុចទីបី របាយការណ៍របស់ប្រទេសហ្វីលីពីនសំដៅដល់ “សញ្ជាតូបនីយកម្មដែលមានលក្ខណៈក្លាយ” ដែលអាចកើតឡើងចំពោះស្ត្រីដែលជាជនបរទេសរៀបអាពាហ៍ពិពាហ៍ជាមួយស្វាមីដែលជាពលរដ្ឋហ្វីលីពីន។

253 ធាតុចូលបន្ថែមត្រូវបានផ្ដល់ជូនដោយជនបង្គោលនៃប្រទេសហ្វីលីពីន។

254 លក្ខណៈសម្បត្តិដែលបានលើកឡើងរួមមាន៖
- មានមុខតំណែងខ្ពង់ខ្ពស់នៅក្រោមរដ្ឋាភិបាលហ្វីលីពីន ឬ នៅក្រោមរដ្ឋបាលខេត្ត ក្រុង រាជធានី ឬ អនុផ្នែកនយោបាយណាមួយនៃខេត្ត ក្រុង ឬ រាជធានីនោះ
- បានបង្កើតឧស្សាហកម្មថ្មីមួយ ឬ បានណែនាំការបង្កើតថ្មីដែលមានសារប្រយោជន៍នៅក្នុងប្រទេសហ្វីលីពីន
- បានរៀបអាពាហ៍ពិពាហ៍ជាមួយស្ត្រីហ្វីលីពីន
- បានចូលរួមធ្វើជាគ្រូបង្រៀននៅប្រទេសហ្វីលីពីន នៅសាលារដ្ឋ ឬ សាលាឯកជនដែលមានការទទួលស្គាល់ ដែលមិនទាន់បានបង្កើតឡើង ដើម្បីផ្ដល់ការបង្ហាត់បង្រៀនផ្ដាច់មុខដល់កូនរបស់បុគ្គលដែលមានសញ្ជាតិ ឬ ជាតិសាសន៍ជាក់លាក់មួយ នៅសាខានៃការអប់រំ ឬ ឧស្សាហកម្មណាមួយ ក្នុងរយៈពេលមិនតិចជាងពីរឆ្នាំ និង
- បានកើតនៅក្នុងប្រទេសអូស្ត្រាលី។ Ibid.

“សំខាន់” ដល់រដ្ឋាភិបាល ឬមរតកជាតិផងដែរ។[255] លើសពីនេះទៀត តាមរយៈដំណើរការនៃសញ្ជាតូបនីយកម្ម ដែលមានលក្ខណៈក្លាយភរិយាស្របច្បាប់ និង កូនរបស់ជនបរទេសដែលបានទទួលភាពជាពលរដ្ឋ ក៏អាចទទួលបានអត្ថប្រយោជន៍ដោយប្រយោលពីសញ្ជាតូបនីយកម្ម ដែលទទួលបានដោយស្វាមី/ឪពុក ដែលជាជនបរទេសរបស់ពួកគេផងដែរ។ នេះអនុញ្ញាតឲ្យជនបរទេសទទួលបានភាពជាពលរដ្ឋដោយ មិនចាំបាច់បង្ហាញលក្ខណៈសម្បត្តិបន្ថែមណាមួយ ឬមិនចាំបាច់ឆ្លងកាត់ដំណើរការធ្វើសញ្ជាតូបនីយកម្មតាមផ្នែករដ្ឋបាល ឬតាមប្រព័ន្ធតុលាការ ដូចស្វាមីភរិយា ឬឪពុកម្ដាយរបស់ពួកគេនោះទេ។[256] ទោះបីជាយ៉ាងណាក៏ដោយ គេបានកត់សម្គាល់នៅក្នុងធាតុចូលបន្ថែម ដែលត្រូវបានផ្ដល់ជូនដោយជនបង្គោល នៃប្រទេសហ្វីលីពីន ចំពោះសញ្ជាតូបនីយកម្មដែលមាន លក្ខណៈក្លាយថា “ច្បាប់ដែលពាក់ព័ន្ធនឹងការធ្វើសញ្ជាតូបនីយកម្មរបៀបនេះមានផលជះចំពោះស្ត្រីនិងបុរសខុសៗគ្នា។ ស្របតាម ក្របខណ្ឌច្បាប់ស្ដីពីសញ្ជាតូបនីយកម្មនាពេលបច្ចុប្បន្ន មានតែបុរសដែលបានធ្វើសញ្ជាតូបនីយកម្មប៉ុណ្ណោះ ដែលអាចបន្តបុព្វសិទ្ធិនៃភាពជាពលរដ្ឋហ្វីលីពីនជូនភរិយា ដែលជាជនបរទេស និងកូនៗរបស់ពួកគេបាន។ សញ្ជាតូបនីយកម្មរបស់ស្ត្រីមានអត្ថប្រយោជន៍តែចំពោះកូនៗ ដែលជាអនីតិជនរបស់ពួកគេប៉ុណ្ណោះ និងពុំមានផលជះតាមផ្លូវច្បាប់ចំពោះស្វាមី ដែលជាជនបរទេសរបស់ពួកគេនោះទេ”។[257] នៅប្រទេសសិង្ហបុរី រដ្ឋាភិបាលសិង្ហបុរី បន្ទាប់ពីពាក្យស្នើ សុំត្រូវបានធ្វើឡើងដោយនរណាម្នាក់ ឬ នៅពេលដែលមនុស្សម្នាក់មានអាយុលើស ២១ ឆ្នាំ ដែលមិនមែនជាពលរដ្ឋសិង្ហបុរី អាចផ្តល់លិខិតបញ្ជាក់សញ្ជាតូបនីយកម្មជូនគាត់ ប្រសិនបើ រដ្ឋាភិបាលមានការពេញចិត្ត៖

ក. ថាមនុស្សម្នាក់នោះ បានស្នាក់នៅក្នុងប្រទេសសិង្ហបុរីក្នុងរយៈពេលដែលបានតម្រូវ និង មានបំណង ប្រសិនបើមានលិខិតបញ្ជាក់ត្រូវបានផ្ដល់ជូន ស្នាក់នៅប្រទេសសិង្ហបុរីជាអចិន្ត្រៃយ៍
ខ. ថាមនុស្សម្នាក់នោះមានអត្តចរិតល្អ និង
គ. ថាមនុស្សម្នាក់នោះចេះភាសាជាតិក្នុងកម្រិតសមស្រប។[258]

រយៈពេលស្នាក់នៅក្នុងប្រទេសសិង្ហបុរី ដែលត្រូវបានតម្រូវ សម្រាប់ការផ្ដល់លិខិតបញ្ជាក់សញ្ជាតូបនីយកម្ម ដែលមានការបូកបញ្ចូលគ្នានៃចំនួនសរុប មិនតិចជាង ១០ ឆ្នាំ ក្នុងរយៈពេល ១២ ឆ្នាំភ្លាមៗ មុនកាលបរិច្ឆេទនៃពាក្យស្នើសុំលិខិតបញ្ជាក់ និងដែលរួមបញ្ចូលរយៈពេល ១២ខែភ្លាមៗ មុនកាលបរិច្ឆេទនោះផងដែរ។ ជនដែលនឹងទទួលបានលិខិតបញ្ជាក់សញ្ជាតូបនីយកម្ម នឹងក្លាយជាពលរដ្ឋរបស់ប្រទេសសិង្ហបុរី តាមរយៈសញ្ជាតូបនីយកម្មចាប់ពីកាលបរិច្ឆេទដែលលិខិតបញ្ជាក់នោះត្រូវបានផ្ដល់ជូន។ ពុំមានលិខិតបញ្ជាក់សញ្ជាតូបនីយកម្មណាមួយនឹងត្រូវផ្ដល់ជូននរណាម្នាក់នោះទេ រហូតទាល់តែអ្នកដាក់ពាក្យស្នើសុំ បានធ្វើការស្បថចំពោះការលះបង់ ភាពស្មោះត្រង់ និងភក្ដីភាព នៅក្នុងទម្រង់ដែលត្រូវបានកំណត់ នៅក្នុងឧបសម្ព័ន្ធទីពីរនៃរដ្ឋធម្មនុញ្ញ។[259] នៅប្រទេសថៃ ជនបរទេសដែល



255 Ibid.

256 ធាតុចូលបន្ថែមត្រូវបានផ្ដល់ជូនដោយជនបង្គោលនៃប្រទេសហ្វីលីពីន។

257 Ibid.

258 របាយការណ៍របស់ប្រទេសសិង្ហបុរី។

259 Ibid.

260 របាយការណ៍របស់ប្រទេសថៃ។

261 លក្ខខណ្ឌដែលបានលើកឡើងគឺ៖
ក/ មានសមត្ថភាពធ្វើសកម្មភាពរបស់ពលរដ្ឋយ៉ាងពេញលេញ ដូចបានបញ្ញត្តិដោយច្បាប់របស់ប្រទេសវៀតណាម
ខ/ គោរពរដ្ឋធម្មនុញ្ញ និង ច្បាប់របស់ប្រទេសវៀតណាម គោរពប្រពៃណី ទំនៀមទម្លាប់ និង ទម្លាប់អនុវត្តរបស់ប្រទេសវៀតណាម
គ/ យល់ដឹងអំពីភាសាវៀតណាមបានយ៉ាងសមស្រប ដើម្បីធ្វើសមាហរណកម្មទៅក្នុងសហគមន៍វៀតណាម
ឃ/ បានស្នាក់នៅក្នុងប្រទេសវៀតណាមអស់រយៈពេល ៥ ឆ្នាំ ឬលើសពីនេះ គិតត្រឹមពេលដាក់ពាក្យស្នើសុំសញ្ជាតូបនីយកម្ម
ង/ មានសមត្ថភាពទ្រទ្រង់ជីវភាពរស់នៅរបស់ពួកគេនៅក្នុងប្រទេសវៀតណាម។

មានលក្ខណៈសម្បត្តិដូចបានបញ្ញត្តិដោយច្បាប់ស្តីពីសញ្ជាតិ អាចដាក់ពាក្យស្នើសុំសញ្ជាតូបនីយកម្មដើម្បីទទួលបានសញ្ជាតិថៃ។ លក្ខណៈសម្បត្តិទាំងនោះរួមមាន ក) ក្លាយជា sui juris ស្របតាមច្បាប់របស់ប្រទេសថៃ និងច្បាប់ដែលបុគ្គលនោះមានសញ្ជាតិ ខ) មានអាកប្បកិរិយាល្អ គ) មានការងារទៀងទាត់ ឃ) មានទីលំនៅនៅក្នុង ព្រះរាជាណាចក្រថៃ ក្នុងរយៈពេលមិនតិចជាងប្រាំឆ្នាំជាប់ៗគ្នាមុនកាលបរិច្ឆេទដាក់ពាក្យស្នើសុំសញ្ជាតូបនីយកម្ម និង ង) ចេះភាសាថៃ ដូចបានបញ្ញត្តិនៅក្នុងបទប្បញ្ញត្តិរបស់ក្រសួងនានា។[260] សញ្ជាតូបនីយកម្មនៅក្នុងច្បាប់ស្តីពីសញ្ជាតិ របស់**ប្រទេសវៀតណាម** អនុញ្ញាតឲ្យជនបរទេស និងជនគ្មានសញ្ជាតិ ដែលស្នាក់នៅជាអចិន្ត្រៃយ៍ នៅក្នុងប្រទេសវៀតណាម ដាក់ពាក្យស្នើសុំសញ្ជាតិវៀតណាម ដោយមានលក្ខខណ្ឌមួយចំនួន[261] រួមជាមួយ ករណីលើកលែងមួយចំនួនផងដែរ។[262]

គេអាចមើលឃើញថា គ្រប់រដ្ឋទាំងអស់នៅក្នុងអាស៊ាន អនុញ្ញាតចំពោះសញ្ជាតូបនីយកម្មដោយមានលក្ខខណ្ឌមួយចំនួនដូចៗគ្នា ដូចជា ចំណេះដឹងផ្នែកភាសា មានអត្តចរិតល្អ បានស្នាក់នៅលើសរយៈពេលស្នាក់នៅជាក់លាក់ណាមួយ ។ល។ ទោះបីជាយ៉ាងណាក៏ដោយ មានប្រទេសមួយចំនួនតូចប៉ុណ្ណោះ រួមបញ្ចូលទាំង ប្រទេសថៃ និង ប្រទេសវៀតណាមផងដែរ អនុញ្ញាតចំពោះការធ្វើសញ្ជាតូបនីយកម្មជនគ្មានសញ្ជាតិ។ របាយការណ៍របស់ប្រទេសតិចតួចខ្លាំងណាស់ ដែលផ្តល់ព័ត៌មានអំពីការទទួលបានភាពជាពលរដ្ឋ របស់ជនដែលពុំមានការកំណត់អំពីសញ្ជាតិរបស់ពួកគេ។ មានតែរបាយការណ៍របស់ប្រទេសហ្វីលីពីនប៉ុណ្ណោះ ដែលចែងយ៉ាងច្បាស់ថា នីតិវិធីកំណត់ភាពគ្មានសញ្ជាតិនឹងត្រូវដំណើរការ ដោយនាយកដ្ឋានយុត្តិធម៌ (DOJ) តាមរយៈអង្គភាពការពារ ជនភៀសខ្លួន និងជនគ្មានសញ្ជាតិ (RSPPU) ស្របតាមសារាចររបស់នាយកដ្ឋាន DOJ (D.C.) លេខ ៥៨ ឆ្នាំ២០១២។ ក្រោយមក ជនគ្មានសញ្ជាតិដូចដែលត្រូវបានកំណត់ដោយ RSPPU អាចដាក់ពាក្យស្នើសុំសញ្ជាតូបនីយកម្មតាមប្រព័ន្ធតុលាការ ឬតាមផ្នែករដ្ឋបាល ឬសញ្ជាតូបនីយកម្មដែលមានលក្ខណៈក្លាយ ស្របតាមច្បាប់របស់ប្រទេសហ្វីលីពីន ដោយមានវិធានជាក់លាក់ និង ករណីលើកលែងដែលត្រូវបានទទួលស្គាល់។ លើសពីនេះទៀត របាយការណ៍ក៏បានលើកឧទាហរណ៍អំពីគម្រោង PIDs ដែលលើកឡើងអំពីកូនរបស់ជនអន្តោប្រវេសន៍ (មកពីប្រទេសឥណ្ឌូនេស៊ី) ដែលត្រូវបានផ្តល់ជូននូវលទ្ធភាពទទួលបាន អត្តសញ្ញាណតាមផ្លូវច្បាប់របស់ពួកគេ។ កុមារដែលត្រូវបានបញ្ជាក់ថាជាពលរដ្ឋឥណ្ឌូនេស៊ីនឹងត្រូវបានផ្តល់ជូននូវលិខិតឆ្លងដែន និង ទិដ្ឋាការ។ ដំណើរការនេះកំពុងតែអនុវត្ត។[263]

ចូរមើល**តារាងទី៧** ស្តីពីក្របខណ្ឌច្បាប់របស់ AMS ពាក់ព័ន្ធនឹងការទទួលបានសញ្ជាតិតាមរយៈសញ្ជាតូបនីយកម្ម នៅក្នុងឧបសម្ព័ន្ធ ទំព័រ ១៤៥។



262 ករណីលើកលែងរួមមាន៖
ក/ ជាស្វាមីភរិយា ឪពុកម្តាយបង្កើត ឬ កូនបង្កើតរបស់ពលរដ្ឋវៀតណាម
ខ/ បានធ្វើការរួមចំណែកដែលគួរឲ្យកោតសរសើរចំពោះការកសាង និង ការការពារជាតិវៀតណាម
គ/ ផ្តល់ជំនួយដល់រដ្ឋនៃសាធារណរដ្ឋសង្គមនិយមវៀតណាម។

263 របាយការណ៍របស់ប្រទេសហ្វីលីពីន។

### ច) ការបាត់បង់សញ្ញាតិ/ភាពជាពលរដ្ឋ

នៅប្រទេសប្រ៊ុយណេដារូសាឡឹម មនុស្សម្នាក់អាចបាត់បង់សញ្ញាតិរបស់គាត់ ប្រសិនបើគាត់អវត្តមានពី ប្រទេសប្រ៊ុយណេដារូសាឡឹមអស់រយៈពេលប្រាំឆ្នាំជាបន្តបន្ទាប់ និង មិនផ្តល់ភ័ស្តុតាងដែលគួរជាទីពេញចិត្តថា គាត់នៅតែមានទំនាក់ទំនងដ៏សំខាន់ជាមួយ ប្រទេសប្រ៊ុយណេដារូសាឡឹមនៅក្នុងអំឡុងរយៈពេលនោះ។ ចំណុចនេះក៏អនុវត្តចំពោះនរណាម្នាក់ដែលទទួលយកសញ្ញាតិ ឬភាពជាពលរដ្ឋរបស់រដ្ឋ ឬប្រទេសណាមួយដែលនៅខាងក្រៅ ប្រទេសប្រ៊ុយណេដារូសាឡឹមដោយស្ម័គ្រចិត្ត ឬ ស្ត្រីដែលទទួលបានដោយមូលហេតុនៃការរៀបអាពាហ៍ពិពាហ៍របស់នាង សញ្ញាតិ ឬ ភាពជាពលរដ្ឋរបស់ស្វាមីនាង ដែលមានសញ្ញាតិ ឬ ជាពលរដ្ឋរបស់រដ្ឋ ឬ ប្រទេសណាមួយដែលនៅខាងក្រៅ ប្រទេសប្រ៊ុយណេដារូសាឡឹម។[264] ក្នុងករណីប្រទេសកម្ពុជា ការបាត់បង់សញ្ញាតិត្រូវបានបញ្ញត្តិដោយមាត្រា ១៨ នៃច្បាប់ស្តីពីសញ្ញាតិ ដែលចែងថា "មនុស្សម្នាក់ដែលមានសញ្ញាតិខ្មែរ និងមានអាយុយ៉ាងតិច ១៨ ឆ្នាំ អាចស្នើសុំបោះបង់សញ្ញាតិខ្មែររបស់គាត់បាន ដោយគ្មានការបង្ខិតបង្ខំបន្ទាប់ពីមនុស្សម្នាក់ នោះទទួលបានសញ្ញាតិផ្សេងទៀត"។[265] ចំពោះ ប្រទេសឡាវ ការបាត់បង់សញ្ញាតិ អាចកើតឡើងនៅក្នុងស្ថានភាពចំនួនបីរួមមាន សញ្ញាតិឡាវត្រូវបានបោះបង់ចោល ត្រូវបានដកហូត ឬ ភាគីដែលពាក់ព័ន្ធបានធ្វើទេសន្តរ-ប្រវេសន៍ទៅកាន់ប្រទេសផ្សេងទៀត។ ទោះបីជាយ៉ាងណាក៏ដោយ ច្បាប់ធ្វើឲ្យមានភាពច្បាស់លាស់ថា ចំណុចនេះពុំមានជះឥទ្ធិពលចំពោះសញ្ញាតិរបស់ស្វាមី/ភរិយា ឬកូនៗរបស់បុគ្គលនោះទេ។[266] នៅប្រទេសមីយ៉ាន់ម៉ា ក្រុមប្រឹក្សារដ្ឋអាចដកហូត "ភាពជាពលរដ្ឋ ឬ ភាពជាពលរដ្ឋតាមផ្លូវច្បាប់ ឬ ភាពជាពលរដ្ឋដែលបានធ្វើសញ្ញាតូបនីយកម្មរបស់នរណាម្នាក់បាន លើកលែងពលរដ្ឋពីកំណើត"។[267] មាត្រា ១៦ នៃ ច្បាប់ស្តីពីភាពជាពលរដ្ឋភូមា ក៏បានបញ្ញត្តិផងដែរថា "ពលរដ្ឋដែលចាកចេញពីរដ្ឋជាអចិន្ត្រៃយ៍ ឬ ដែលទទួលបានភាពជាពលរដ្ឋ ឬចុះបញ្ជីជាពលរដ្ឋនៃប្រទេសមួយផ្សេងទៀត ឬដែលទទួលបានលិខិតឆ្លងដែរ ឬ លិខិតបញ្ជាក់ប្រហាក់ប្រហែលគ្នារបស់ប្រទេសមួយផ្សេងទៀត ឈប់ជាពលរដ្ឋម្នាក់ហើយ"។[268] ការបាត់បង់ភាពជាពលរដ្ឋត្រូវបានបញ្ញត្តិបន្ថែមទៀតនៅក្នុងមាត្រា ១៧-២២ (សម្រាប់ពលរដ្ឋ) មាត្រា ៣៤-៤១ (សម្រាប់ពលរដ្ឋតាមផ្លូវច្បាប់ និង មាត្រា ៥៧-៦១ (សម្រាប់ពលរដ្ឋដែលបានធ្វើសញ្ញាតូបនីយកម្ម)។[269] វាមានសារសំខាន់នៅក្នុងការកត់សម្គាល់ថា ទោះបីជាមានមូលហេតុដូចៗគ្នាមួយចំនួនចំពោះការបាត់បង់សញ្ញាតិក្តី ក៏លក្ខខណ្ឌទាំងនេះ អនុវត្តខុសៗគ្នាទៅតាមប្រភេទនៃភាពជាពលរដ្ឋ។

ច្បាប់របស់ប្រទេសហ្វីលីពីន ចែងអំពីការបាត់បង់ភាពជាពលរដ្ឋថា ប្រសិនបើមនុស្សម្នាក់បានធ្វើសញ្ញាតូបនីយកម្មនៅបរទេស បោះបង់ភាពជាពលរដ្ឋរបស់ពួកគេ ធ្វើការស្បថថានឹងស្មោះត្រង់ចំពោះការគាំទ្ររដ្ឋធម្មនុញ្ញ ឬច្បាប់នានារបស់បរទេស នៅមុនពេលឈានចូលវ័យ ២១ ឆ្នាំឡើងទៅ ផ្តល់សេវាជូន ឬទទួលបានអាណត្តិនៅក្នុងកងកម្លាំងប្រដាប់អាវុធនៅបរទេស បានលុបចោលលិខិតបញ្ជាក់សញ្ញាតូបនីយកម្មរបស់ពួកគេ និងត្រូវបានប្រកាសដោយអាជ្ញាធរ មានសមត្ថកិច្ចថាបានចាកចេញពីកងកម្លាំងប្រដាប់អាវុធនៅពេលធ្វើសង្គ្រាម លើកលែងតែមានការសូមទោសនៅក្នុងកិច្ចប្រជុំក្រុមធំ ឬ ការលើកលែងទោសត្រូវបានផ្តល់ជូននៅពេលក្រោយ។[270] នៅប្រទេសសិង្ហបុរី មាត្រា ១២៨ ១២៩ ១៣០ និង ១៣៣ នៃរដ្ឋធម្មនុញ្ញសិង្ហបុរី ចែងអំពីដំណើរការ និងលក្ខណវិនិច្ឆ័យសម្រាប់ការបាត់បង់ភាពជាពលរដ្ឋ តាមរយៈការ

264 របាយការណ៍របស់ប្រទេសប្រ៊ុយណេដារូសាឡឹម។

265 Refworld ច្បាប់ស្តីពីសញ្ញាតិ https://www.refworld.org/docid/3ae6b5210.html.

266 របាយការណ៍របស់ប្រទេសឡាវ។

267 មាត្រា ៨(ខ) នៃច្បាប់ស្តីពីភាពជាពលរដ្ឋភូមា ថ្ងៃទី១០ ខែតុលា ឆ្នាំ១៩៨២ https://www.refworld.org/docid/3ae6b4f71b.html.

268 បានដកស្រង់ពីមាត្រា ១៦។

269 ចូរមើលច្បាប់ស្តីពីភាពជាពលរដ្ឋភូមា Ibid.

270 របាយការណ៍របស់ប្រទេសហ្វីលីពីន។ ចូលមើលព័ត៌មានលម្អិតនៅក្នុង ច្បាប់របស់រដ្ឋសហធន (C.A.) លេខ ៦៣ ហៅថា "ច្បាប់ដែលចែងអំពីវិធីនានាដែលភាពជាពលរដ្ឋហ្វីលីពីនអាចត្រូវបាត់បង់ ឬ ទទួលបានឡើងវិញ" ចែងអំពីលក្ខណៈ ដែលភាពជាពលរដ្ឋហ្វីលីពីនអាចត្រូវបាត់បង់ ឬ ទទួលបានឡើងវិញ។ ផ្នែកទី១។

បោះបង់ចោល ឬ ការដកហូត។ ពលរដ្ឋសិង្ហបុរីណាម្នាក់ដែលមានអាយុ ឬលើស ២១ឆ្នាំ និងមានសុខភាពផ្លូវចិត្តល្អ ដែលនឹងក្លាយជាពលរដ្ឋម្នាក់របស់ប្រទេសផ្សេងទៀតអាចបោះបង់ចោលភាពជាពលរដ្ឋសិង្ហបុរីរបស់គាត់បាន។ ចំពោះការដកហូត រដ្ឋាភិបាលសិង្ហបុរីតាមបញ្ញា អាចដកហូតភាពជាពលរដ្ឋរបស់ពលរដ្ឋណាម្នាក់ ដែលបានធ្វើសញ្ញា-តូបនីយកម្ម។[271] ច្បាប់របស់ប្រទេសថៃអនុញ្ញាតឲ្យមានសញ្ជាតិពីរ ប៉ុន្តែការបាត់បង់សញ្ជាតិអាចកើតឡើងតាមរយៈការបោះបង់ចោល ប្រសិនបើត្រូវបានតម្រូវដោយច្បាប់ស្តីពីសញ្ជាតិ របស់ប្រទេសមួយផ្សេងទៀត ឬការដកហូត ប្រសិនបើមានភ័ស្តុតាងដែលបង្ហាញថា គាត់ប្រើប្រាស់សញ្ជាតិរបស់ឪពុក ឬ ម្តាយរបស់គាត់ ឬ ប្រើប្រាស់សញ្ជាតិបរទេសដទៃទៀត ឬថា គាត់មានផលប្រយោជន៍យ៉ាងសកម្មនៅក្នុងសញ្ជាតិរបស់ឪពុក ឬម្តាយរបស់គាត់ ឬសញ្ជាតិបរទេសដទៃទៀត។[272] គាត់ក៏អាចបាត់បង់សញ្ជាតិ ដោយសារការប្រព្រឹត្តិទង្វើណាមួយដែលមានផលប៉ះពាល់ ចំពោះសន្តិសុខជាតិ ឬមានទំនាស់នឹងផលប្រយោជន៍ជាតិ ឬមើលងាយជាតិផងដែរ និងគាត់បានប្រព្រឹត្តិទង្វើណាមួយដែលផ្ទុយនឹងសណ្តាប់ធ្នាប់សាធារណៈ ឬ សីលធម៌ល្អ។[273] គេអាចសង្កេតឃើញថា មូលហេតុមួយចំនួនគឺមិនសូវច្បាស់លាស់នោះទេ និង អាស្រ័យលើការបកស្រាយដោយមន្ត្រីនានា។ ច្បាប់ស្តីពីសញ្ជាតិរបស់**ប្រទេសវៀតណាម** ចែងអំពីការបាត់បង់សញ្ជាតិដោយសារមូលហេតុខុសៗគ្នា រួមមានការបោះបង់ចោលសញ្ជាតិវៀតណាម ការដកហូតសញ្ជាតិវៀតណាម ការខកខានមិនបានចុះបញ្ជីរក្សាទុកសញ្ជាតិវៀតណាម ដូចបានបញ្ញត្តិនៅក្នុងខចែងទី២ មាត្រា ១៣ នៃច្បាប់ស្តីពីសញ្ជាតិវៀតណាម ឆ្នាំ២០០៨ ការធ្លាក់ចូលទៅក្នុងករណីនានាដែលបានបញ្ជាក់នៅក្នុងខចែងទី២ មាត្រា ១៨[274] និង មាត្រា ៣៥ និង ការធ្លាក់ចូលទៅក្នុងករណីនានាដែលបានបញ្ជាក់ នៅក្នុងសន្ធិសញ្ញានានា ដែលសាធារណរដ្ឋវៀតណាមគឺជាភាគីចុះកិច្ចសន្យា។[275] វាមានសារសំខាន់នៅក្នុងការកត់ សម្គាល់ថា ខចែងទី២ នៃមាត្រា ១៣ ត្រូវបានធ្វើវិសោធនកម្មដោយច្បាប់លេខ ៥៦/២០១៤/QH១៣ ដោយមានបញ្ញត្តិបន្ថែម នៃច្បាប់ស្តីពីសញ្ជាតិវៀតណាម។[276]

គេអាចមើលឃើញថា ការបាត់បង់សញ្ជាតិផ្អែកជាចម្បងលើការបោះបង់ចោលដោយបុគ្គល ឬការដកហូត តាមរយៈសេចក្តីសម្រេចរបស់រដ្ឋ ផ្អែកលើមូលហេតុខុសៗគ្នា ដូចបានកំណត់ដោយច្បាប់ជាតិរបស់ប្រទេសនីមួយៗ។ ដូចបានលើកឡើងនៅខាងលើ មូលហេតុមួយចំនួនសម្រាប់ការដកហូតសញ្ជាតិគឺមិនសូវច្បាស់លាស់នោះទេ និង អាស្រ័យលើឆន្ទានុសិទ្ធិរបស់មន្ត្រី/រដ្ឋាភិបាល។ ប្រទេសមួយចំនួនដូចជា ប្រទេសកម្ពុជា និងប្រទេសឡាវ ផ្តល់ការការពារមួយចំនួន ប្រឆាំងនឹងភាពគ្មានសញ្ជាតិជាពិសេសការចែងថា ការបាត់បង់សញ្ជាតិ នឹងមានប្រសិទ្ធភាពអនុវត្ត លុះត្រាតែមនុស្សម្នាក់ទទួលបានសញ្ជាតិមួយផ្សេងទៀតតែប៉ុណ្ណោះ និងថា ការបាត់បង់សញ្ជាតិរបស់បុគ្គលម្នាក់ពុំមានជះឥទ្ធិពលដល់សញ្ជាតិរបស់ស្វាមី/ភរិយា ឬកូនៗរបស់បុគ្គលនោះទេនៅក្នុងករណីប្រទេសឡាវ។ ធាតុដូចគ្នាមួយដែលត្រូវបានរកឃើញនៅក្នុង AMS ទាំងអស់ គឺថាការទទួលបានសញ្ជាតិដោយសញ្ញាតូបនីយកម្ម ឬភាពជាពលរដ្ឋតាមផ្លូវច្បាប់ (ក្នុងករណីប្រទេសមីយ៉ាន់ម៉ា) អាចត្រូវបានលុប ចោលដោយរដ្ឋស្របតាមឆន្ទានុសិទ្ធិរបស់រដ្ឋ។

---

271 របាយការណ៍របស់ប្រទេសសិង្ហបុរី។

272 របាយការណ៍របស់ប្រទេសថៃ។

273 Ibid.

274 សញ្ជាតិរបស់កុមារទើបនឹងកើតដែលត្រូវគេបោះបង់ចោល និង កុមារដែលត្រូវបានរកឃើញនៅលើដែនដីវៀតណាម។

275 របាយការណ៍របស់ប្រទេសវៀតណាម។

276 មាត្រា ១៣. ជនដែលមានសញ្ជាតិវៀតណាម.

១. ជនដែលមានសញ្ជាតិវៀតណាម រួមបញ្ចូល ជនដែលមានសញ្ជាតិវៀតណាមត្រឹមកាលបរិច្ឆេទមានប្រសិទ្ធភាពអនុវត្តនៃច្បាប់នេះ និង អ្នកដែលបានទទួលសញ្ជាតិវៀតណាម ស្របតាមច្បាប់នេះ។

២. ជនជាតិវៀតណាមដែលរស់នៅក្រៅប្រទេស ដែលមិនទាន់បានបាត់បង់សញ្ជាតិវៀតណាម ដូចបានបញ្ញត្តិដោយច្បាប់របស់ប្រទេសវៀតណាម មុនកាលបរិច្ឆេទមានប្រសិទ្ធភាពអនុវត្តនៃច្បាប់នេះ អាចថែរក្សាសញ្ជាតិវៀតណាមរបស់ពួកគេបាន។

ជនជាតិវៀតណាមដែលរស់នៅក្រៅប្រទេស ដែលមិនទាន់បានបាត់បង់សញ្ជាតិវៀតណាម ប៉ុន្តែគ្មានឯកសារបញ្ជាក់អះអាងអំពីសញ្ជាតិវៀតណាម ដូចបានបញ្ញត្តិនៅក្នុងមាត្រា ១១ នៃច្បាប់នេះ ត្រូវចុះបញ្ជីជាមួយបេសកកម្មតំណាងរបស់ប្រទេសវៀតណាម ដើម្បីធ្វើការផ្ទៀងផ្ទាត់អំពីសញ្ជាតិវៀតណាមរបស់ពួកគេ និង នឹងត្រូវបានផ្តល់ជូននូវលិខិតឆ្លងដែនវៀតណាម។

រដ្ឋាភិបាលត្រូវបញ្ជាក់អំពីខចែងនេះ។

## ៣.៤ បញ្ហាប្រឈម និង ទម្លាប់អនុវត្តល្អៗ

### ក) បញ្ហាប្រឈម

ពុំមានព័ត៌មានពាក់ព័ន្ធនឹងបញ្ហាប្រឈមនានា នៅក្នុងរបាយការណ៍របស់ប្រទេសប្រ៊ុយណេដារូសាឡឹម កម្ពុជា ឡាវ ម៉ាឡេស៊ី មីយ៉ាន់ម៉ា និង ថៃនោះទេ។ របាយការណ៍របស់ប្រទេសសិង្ហបុរីអះអាងថា មានបញ្ហាប្រឈមនានា នៅពេលនិយាយអំពីបញ្ហាភាពជាពលរដ្ឋ និង សញ្ជាតិ។[277]

មានរបាយការណ៍នៃប្រទេសតែមួយចំនួនតូចប៉ុណ្ណោះ រួមមាន ប្រទេសហ្វីលីពីន ប្រទេសថៃ និង ប្រទេសវៀតណាម ដែលបានសម្គាល់ឃើញចន្លោះប្រហោង និងបញ្ហាប្រឈមមួយចំនួនពាក់ព័ន្ធនឹងបញ្ហាសញ្ជាតិ និងភាពជាពលរដ្ឋ។ ចំពោះប្រទេសហ្វីលីពីន របាយការណ៍របស់ប្រទេសនេះបានអះអាងថា ទោះបីជាមានវត្តមាននៃផែនការសកម្មភាពជាតិដើម្បីបញ្ចប់ភាពគ្មានសញ្ជាតិ (NAP) ដែលចែងអំពីក្របខណ្ឌនៃចំណុចសកម្មភាពទាំង ៧[278] ដែល រដ្ឋាភិបាលនៃប្រទេសហ្វីលីពីនបានប្តេជ្ញាចិត្តអនុវត្តរហូតដល់ឆ្នាំ២០២៤ ក៏ដោយ ក៏នៅតែមានបញ្ហាមួយចំនួន ជាពិសេសការលុបការរើសអើងចេញពីច្បាប់ជាតិ។ របាយការណ៍នេះសង្កត់ធ្ងន់លើតម្រូវការក្នុងការត្រួតពិនិត្យច្បាប់ស្តីពីសញ្ជាតិ និង ភាពជាពលរដ្ឋឡើងវិញ ដើម្បីធានាចំពោះការអនុម័តច្បាប់ដែលបានធ្វើវិសោធនកម្ម ដែលធានាថាមានសមភាពយេនឌ័រនៅក្នុងការទទួលបានភាពជាពលរដ្ឋដោយជនបរទេស ដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់។[279] លើសពីនេះទៀត របាយការណ៍បង្ហាញថា វាមានការពិបាកនៅក្នុងការអនុវត្ត PIDs ចំពោះសញ្ជាតូបនីយកម្ម ដោយសារតែថ្លៃដើមមានតម្លៃខ្ពស់ខ្លាំងពេក និងនីតិវិធីមានភាពស្មុគស្មាញ។ ដោយសារតែបញ្ហាសញ្ជាតិ PIDs កំពុងតែប្រឈមមុខនឹងការពិបាកមួយចំនួន ដូចជា ការដកចេញពីកិច្ចព្រមព្រៀងជួល កង្វះខាតការទទួលបានព័ត៌មានដែលពាក់ព័ន្ធនឹងតម្លៃផលិតផល ជម្រើសទីលំនៅដែលមានកម្រិត ដែលមានផលជះដល់ឱកាសការងារ និង ការទទួលបានសេវា និងការជួយសម្រួលនានា ការរើសអើងនៅកន្លែងធ្វើការ ការគ្មានសិទ្ធិកាន់កាប់អចលនទ្រព្យ និងការពិបាកនានាដែលត្រូវប្រឈមមុខដោយកូនៗរបស់ពួកគេនៅសាលារៀន ដូចជាការគំរាមសម្លុត និង មិនអាចចូលរួមការប្រឡងដើម្បីទទួលបានអាជ្ញាប័ណ្ណថ្នាក់ជាតិ។[280]

នៅប្រទេសថៃ គេបានវាយតម្លៃថា មានមនុស្សជាង ៤០.០០០ នាក់ដែលមានលក្ខណសម្បត្តិគ្រប់គ្រាន់ ប៉ុន្តែមិនបានចុះបញ្ជីនៅក្នុងមូលដ្ឋានទិន្នន័យនៃការចុះបញ្ជីអត្រានុកូលដ្ឋាន របស់នាយកដ្ឋានរដ្ឋបាលខេត្តនោះទេ។ ការស្ទង់មតិអំពីមូលដ្ឋានទិន្នន័យហាក់បីដូចជាមើលរំលងក្រុមមនុស្សទាំងនេះ។ ពួកគេមិនទាន់ទទួលបានការកំណត់លេខអត្តសញ្ញាណប័ណ្ណ ឬកំណើតរបស់ពួកគេមិនត្រូវបានជូនដំណឹងទៅកាន់មន្ត្រីអត្រានុកូលដ្ឋាននោះទេ។[281] នៅក្នុងករណីប្រទេសវៀតណាម គេបានសម្គាល់ឃើញចន្លោះប្រហោងនៅក្នុងបញ្ហាសញ្ជាតិ។ បច្ចុប្បន្ន ច្បាប់ស្តីពីសញ្ជាតិរបស់ប្រទេសវៀតណាមមិនបានបញ្ញត្តិអំពីសមត្ថកិច្ច និង នីតិវិធីជាក់លាក់សម្រាប់ការកំណត់សញ្ជាតិវៀតណាមនោះទេ។ ការកំណត់សញ្ជាតិវៀតណាមត្រូវបានអនុវត្តយោងតាមវិធីសាស្ត្ររដ្ឋបាល ដែលត្រូវបានរួមបញ្ចូលជាមួយនីតិវិធីសម្រាប់ការចុះបញ្ជីកំណើត រួមបញ្ចូលទាំងការចុះបញ្ជីកំណើតសម្រាប់កុមារដែលទើបនឹងកើត និងការចុះបញ្ជីកំណើតយឺតពេលផងដែរ។ របាយការណ៍នេះ

---

277 របាយការណ៍របស់ប្រទេសសិង្ហបុរី។

278 (១) ដោះស្រាយស្ថានភាពនៃភាពគ្មានសញ្ជាតិដែលមានស្រាប់ (២) ពុំមានកុមារណាម្នាក់ដែលកើតមកដោយគ្មានសញ្ជាតិនោះទេ (៣) លុបការរើសអើងយេនឌ័រចេញពីច្បាប់ស្តីពីសញ្ជាតិ (៤) ផ្តល់ការការពារដល់ជនអន្តោរប្រវេសន៍ដែលគ្មានសញ្ជាតិ និង ជួយសម្រួលដល់ការធ្វើសញ្ជាតូបនីយកម្មរបស់ពួកគេ (៥) ធានាចំពោះការចុះបញ្ជីកំណើត ដើម្បីទប់ស្កាត់ភាពគ្មានសញ្ជាតិ (៦) ធ្វើការព្រមព្រៀងចំពោះអនុសញ្ញាអង្គការសហប្រជាជាតិស្តីពីភាពគ្មានសញ្ជាតិ និង (៧) ពង្រឹងទិន្នន័យផ្នែកបរិមាណ និង គុណភាព ស្តីពីប្រជាជនដែលគ្មានសញ្ជាតិ។ ចំណុចសកម្មភាពទាំងនេះគឺត្រៀមសម្រាប់ (១) ការដោះស្រាយស្ថានភាពនៃភាពគ្មានសញ្ជាតិដែលមានស្រាប់ ២) ការទប់ស្កាត់ករណីថ្មីៗមិនឲ្យកើតឡើង និង ៣) ការកំណត់ និងការពារប្រជាជនដែលគ្មានសញ្ជាតិឲ្យបានកាន់តែល្អប្រសើរ។ របាយការណ៍របស់ប្រទេសហ្វីលីពីន។

279 Ibid.

280 Ibid.

281 របាយការណ៍របស់ប្រទេសថៃ។

ផ្តល់អនុសាសន៍ថា នីតិវិធីចំនួនពីរគួរតែត្រូវបានបំបែកចេញពីគ្នា ដូចដែលត្រូវបានអនុវត្តជាអន្តរជាតិ។ ការធ្វើបែបនេះនឹងជួយសម្រួលដល់ការកំណត់ភាពជាពលរដ្ឋបានកាន់តែមានតម្លាភាព។[282] លើសពីនេះទៀត ច្បាប់ស្តីពីសញ្ជាតិចែងថា ជនគ្មានសញ្ជាតិត្រូវតែមានទីលំនៅដែលមានលំនឹងនៅក្នុងដែនដីវៀតណាម ក្នុងរយៈពេលយ៉ាងតិច ២០ឆ្នាំ ដើម្បីទទួលបានការពិចារណាសម្រាប់ការធ្វើសញ្ជាតូបនីយកម្មនៅក្នុងប្រទេសវៀតណាម។ របាយការណ៍នេះបានណែនាំការសិក្សាមួយសម្រាប់ការកែសម្រួល និង ការកែប្រែ ដើម្បីបង្កើតលក្ខខណ្ឌដែលអំណោយផលចំពោះជនអន្តោប្រវេសន៍ដែលគ្មានសញ្ជាតិ នៅតាមតំបន់ព្រំដែននៃប្រទេសវៀតណាម ឲ្យទទួល បានសញ្ជាតិកាន់តែឆាប់រហ័ស ដូច្នេះពួកគេអាចទទួលបានស្ថេរភាព និងសិទ្ធិមូលដ្ឋានដទៃទៀតរបស់ពលរដ្ឋ។[283]

### ខ) ទម្លាប់អនុវត្តល្អៗ និង មេរៀនដែលទទួលបាន

នៅក្នុងចំណោមរបាយការណ៍របស់ប្រទេសទាំងអស់ មានទម្លាប់អនុវត្តល្អៗ និងមេរៀនដែលទទួលបានមួយចំនួនត្រូវបានចែករំលែក។ របាយការណ៍មួយចំនួនបានពិភាក្សាអំពីទម្លាប់អនុវត្តល្អៗ និងមេរៀនដែលទទួលបានទាំងនេះយ៉ាងលម្អិត នៅខណៈពេលដែលរបាយការណ៍មួយចំនួនទៀតបានលើកឡើងត្រួសៗអំពីចំណុចនីមួយៗ ដែលជាផ្នែកមួយនៃបញ្ជីដែលវែងជាងនោះ។ ទម្លាប់អនុវត្តល្អៗ និងមេរៀនដែលទទួលបានទាំងនេះ មានចាប់ពីកំណែទម្រង់ច្បាប់រហូតដល់គោលនយោបាយជាក់ស្តែង។ ខាងក្រោមគឺជាទម្លាប់អនុវត្តល្អៗដែលត្រូវបានសម្គាល់ឃើញនៅក្នុងរបាយការណ៍របស់ប្រទេសនានា។

## ប្រទេសប្រ៊ុយណេដារូសាឡឹម

i. ប្រគល់ជូនមន្ត្រីនគរបាល និងមេភូមិ (Ketua Kampong) នូវភារកិច្ចក្នុងការធានាថា មានការការពារសុខមាលភាពរបស់និវាសនជននៅក្នុងភូមិ។ ប្រសិនបើមានបញ្ហាទាក់ទងនឹងសញ្ជាតិ នាយកដ្ឋានអន្តោប្រវេសន៍ និងការចុះបញ្ជីថ្នាក់ជាតិនឹងទទួលបានការជូនដំណឹង។[284]

ii. បង្កភាពងាយស្រួលកាន់តែខ្លាំងដល់លទ្ធភាពក្នុងការទទួលបានការចុះបញ្ជីផ្នែករូបវន្ត។ នាយកដ្ឋានអន្តោប្រវេសន៍ និងការចុះបញ្ជីថ្នាក់ជាតិមានការិយាល័យនៅក្នុងស្រុកនីមួយៗក្នុងចំណោមស្រុកទាំងបួន ដែលជួយសម្រួលដល់ការចូលទៅជួបជនដែលមានបញ្ហាជាមួយការចុះបញ្ជីកំណើត និង សញ្ជាតិ។[285]

## ប្រទេសកម្ពុជា

i. បញ្ជាក់អំពីនីតិវិធីនៃការតាក់តែងច្បាប់។ យោងតាមរដ្ឋធម្មនុញ្ញ និង ច្បាប់ស្តីពីសញ្ជាតិ (ជំពូក ១ មាត្រា ១ និង ជំពូក ២ មាត្រា ៤) ស្ត្រីគ្រប់រូប ដោយមិនគិតអំពីសញ្ជាតិនោះទេ ដែលរស់នៅយ៉ាងស្របច្បាប់នៅក្នុងប្រទេសកម្ពុជា មានសិទ្ធិចុះបញ្ជីកំណើតឲ្យកូនរបស់ពួកគេ និងដាក់ពាក្យស្នើសុំភាពជាពលរដ្ឋសម្រាប់កូនដែលទើបនឹងកើតរបស់ពួកគេ។ រាល់កំណើតទាំងអស់នឹងត្រូវចុះបញ្ជីនៅការិយាល័យឃុំ/សង្កាត់ ក្នុងរយៈពេល ៣០ ថ្ងៃក្រោយពេលកើត។ កុមារដែលមិនបានចុះបញ្ជីនៅក្នុងរយៈពេល៣០ថ្ងៃក្រោយពេលកើតទេនោះ អាចទទួលបានសំបុត្រកំណើតស្របតាម

282 របាយការណ៍របស់ប្រទេសវៀតណាម។

283 Ibid.

284 របាយការណ៍របស់ប្រទេសប្រ៊ុយណេដារូសាឡឹម។

285 Ibid.

286 របាយការណ៍របស់ប្រទេសកម្ពុជា។

គោលការណ៍ណែនាំថ្នាក់ជាតិ ដែលផ្តល់ជូនកុមារនូវសិទ្ធិដូចគ្នានឹងការចុះបញ្ជីកំណើតដែរ។ គោលការណ៍ណែនាំអំពីការចុះបញ្ជីកំណើត និងនីតិវិធីក្នុងការបញ្ជាក់អំពីកំណើតចែងអំពីដំណើរការដែលនឹងត្រូវអនុវត្តតាមលក្ខខណ្ឌតម្រូវចាំបាច់ និងឯកសារត្រឹមត្រូវ ដែលគេត្រូវការ។ ចំណុចនេះត្រួសត្រាយផ្លូវទៅកាន់សញ្ជាតិ រួមជាមួយច្បាប់ស្តីពីសញ្ជាតិ នៅក្នុងជំពូក ២ មាត្រា ៤ ចំណុចទី ២ ដែលចែងថា កុមារដែលមានឪពុកម្តាយជាជនបរទេស ដែលបានកើត និង រស់នៅដោយស្របច្បាប់នៅក្នុងប្រទេសកម្ពុជា អាចទទួលបានសញ្ជាតិខ្មែរ។[286]

## ប្រទេសឡាវ

i. កាត់បន្ថយរយៈពេលស្នាក់នៅដែលត្រូវបានតម្រូវដោយច្បាប់ស្តីពីសញ្ជាតិឡាវ (១០ ឆ្នាំ) សម្រាប់សញ្ជាតូបនីយកម្មរបស់បុគ្គលទាំងឡាយដែលមានលក្ខណៈសម្បត្តិផ្នែកវិជ្ជាជីវៈនៅកម្រិតជំនាញ ឬ មានវិជ្ជាជីវៈ និង លក្ខណៈសម្បត្តិនៅក្នុងផ្នែកមួយចំនួន និងមានស្ថានភាពសេដ្ឋកិច្ចដែលមានលំនឹង[287]

ii. បង្កើតសិទ្ធិស្មើភាពគ្នារវាងជនជាតិឡាវ និងជនបរទេស និងជនដែលមិនមែនជាពលរដ្ឋ រួមបញ្ចូលទាំងសិទ្ធិបោះឆ្នោតផងដែរ។ ជនបរទេស និងជនដែលមិនមែនជាពលរដ្ឋក៏អាចដំណើរការការបោះឆ្នោតស្របតាមវិធាន និងច្បាប់ស្តីពីការបោះឆ្នោត ដែលកំណត់លក្ខខណ្ឌ និងនីតិវិធីជាក់លាក់សម្រាប់បេក្ខភាពឈរឈ្មោះបោះឆ្នោតផងដែរ[288]

iii. ចុះកិច្ចព្រមព្រៀងទ្វេភាគីរវាង ប្រទេសឡាវ និងប្រទេសថៃ និងរវាងប្រទេសឡាវ និងប្រទេសវៀតណាម ដើម្បីសហការគ្នាដោះស្រាយបញ្ហានានារបស់ពលករចំណាកស្រុកខុសប្រក្រតី ដែលប្រហែលជាមិនទទួលបានសិទ្ធិរបស់ពួកគេនោះទេ (រួមបញ្ចូលទាំងសិទ្ធិចុះបញ្ជីអត្រានុកូលដ្ឋាន និង សញ្ជាតិផងដែរ)[289]

iv. ធានាចំពោះការអនុវត្តការប្តេជ្ញាចិត្តតាមសេចក្តីសង្កេតសន្និដ្ឋានដែលត្រូវបានធ្វើឡើងដោយ CEDAW និង CRC ព្រមទាំងអនុសាសន៍ដែលត្រូវបានផ្តល់ជូនដោយការពិនិត្យឡើងវិញជាសកលតាមកាលកំណត់(UPR) ពាក់ព័ន្ធនឹងការធ្វើឲ្យច្បាប់ស្តីពីសញ្ជាតិមានភាពល្អប្រសើរឡើង តាមរយៈការបន្ថែមព័ត៌មានលម្អិត និងខ្លឹមសារស្តីពីការការពារជាតិ និងលក្ខខណ្ឌសម្រាប់ការអនុម័តឲ្យទទួលបានសញ្ជាតិវៀតណាម និងកំណត់និយមន័យសិទ្ធិ និងទំនួលខុសត្រូវព្រមទាំងការលុបចោលសញ្ជាតិផងដែរ[290]

v. ប្រទេសឡាវបានបង្កើតយន្តការដាក់ពាក្យបណ្តឹងស្របច្បាប់។ ក៏មានបណ្តាញទូរស័ព្ទផ្តល់ជំនួយបន្ទាន់របស់រដ្ឋាភិបាល (១៥១៦) ដើម្បីទទួលពាក្យបណ្តឹង និងដោះស្រាយបញ្ហាដែលទាក់ទងនឹងសញ្ជាតិផងដែរ។[291]

## ប្រទេសម៉ាឡេស៊ី

i. ណែនាំអំពីគំនិតផ្តួចផ្តើមនានា តាមរយៈនាយកដ្ឋានចុះបញ្ជីថ្នាក់ជាតិ (NRD) ដើម្បីពង្រឹងប្រព័ន្ធចុះបញ្ជីកំណើតរួមជាមួយទីភ្នាក់ងារដែលពាក់ព័ន្ធដទៃទៀត ដោយមានបំណងធានាថា រាល់កំណើតនៅក្នុងប្រទេសម៉ាឡេស៊ីទាំងអស់ត្រូវបានចុះបញ្ជី។ គំនិតផ្តួចផ្តើមទាំងនោះ រួមមាន កម្មវិធីដែលជួយដល់សហគមន៍ និងការចុះបញ្ជីចល័ត ដើម្បីលើកឡើងអំពីសហគមន៍ដែលពិបាកឈោងចាប់ រួមបញ្ចូលទាំង អ្នកដែលរស់នៅតាមតំបន់ជនបទផងដែរ

ii. ប្រើប្រាស់បច្ចេកវិទ្យាដើម្បីផ្ទៀងផ្ទាត់ទិន្នន័យ ដើម្បីពង្រឹងគុណភាពនៃស្ថិតិអត្រានុកូលដ្ឋានដែលត្រូវបានបង្កើតឡើង។ វិធីសាស្ត្រទាំងនេះមិនរួមបញ្ចូលបញ្ហាសញ្ជាតិនោះទេ។[292]

---

287 របាយការណ៍របស់ប្រទេសឡាវ។

288 Ibid.

289 Ibid.

290 Ibid.

291 Ibid.

292 របាយការណ៍របស់ប្រទេសម៉ាឡេស៊ី រួមជាមួយ ការធ្វើឲ្យល្អប្រសើរឡើងដែលត្រូវបានស្នើឡើងដោយជនបង្គោលនៃប្រទេសម៉ាឡេស៊ី។

# ប្រទេសហ្វីលីពីន

i. រៀបចំកិច្ចពិភាក្សា/កិច្ចសហការអន្តរទីភ្នាក់ងារ។ នៅឆ្នាំ២០០៩ UNHCR និងរដ្ឋាភិបាលហ្វីលីពីន (GOP) បានរួមគ្នារៀបចំកម្រងនៃកិច្ចពិភាក្សាតុមូលអន្តរទីភ្នាក់ងារ ស្តីពីភាពគ្មានសញ្ជាតិ ដោយមានការចូលរួមពីទីភ្នាក់ងារជំនាញរបស់ GOP ទីភ្នាក់ងាររបស់អង្គការសហប្រជាជាតិ និងអង្គការអន្តរជាតិដទៃទៀត ព្រមទាំងសង្គមស៊ីវិលផងដែរ។ កិច្ចពិភាក្សាទាំងនេះមានបំណងបង្កើនការយល់ដឹងអំពីភាពគ្មានសញ្ជាតិ សម្គាល់ឃើញបញ្ហានានានៃគោលនយោបាយ និងការឆ្លើយតបផ្នែកប្រតិបត្តិការទៅនឹងភាពគ្មានសញ្ជាតិនៅក្នុងបរិបទរបស់ប្រទេសហ្វីលីពីន និងពង្រឹងសមត្ថភាពរបស់ភាគីពាក់ព័ន្ធខុសៗគ្នា ដែលចូលរួមដោះស្រាយបញ្ហាទាំងនោះ។ ជាលទ្ធផល កិច្ចពិភាក្សាទាំងនោះបានសម្គាល់ឃើញប្រជាជនចំនួនប្រាំប្រភេទដែលប្រឈមនឹងហានិភ័យនៃភាពគ្មានសញ្ជាតិនៅក្នុងបរិបទរបស់ប្រទេសហ្វីលីពីន៖ (១) កុមារដែលមិនបានចុះបញ្ជីនៅក្នុងប្រទេសហ្វីលីពីន (២) កុមារបាត់ខ្លួន (៣) កុមារដែលមានដើមកំណើតហ្វីលីពីន នៅតាមបណ្តាទីតាំងធ្វើអន្តោប្រវេសន៍ (កុមារដែលកើតនៅប្រទេសអារ៉ាប៊ីសាអូឌីត និង សាបា) (៤) ជនដែលមានដើមកំណើតឥណ្ឌូនេស៊ីនៅក្នុងប្រទេសហ្វីលីពីនភាគខាងត្បូង (PIDs) និង (៥) Sama Dilaut។[293] នៅក្នុងចំណោមលទ្ធផលនានានៃកិច្ចពិភាក្សាទាំងនោះ នៅក្នុងអំឡុងពេលពិភាក្សាតុមូលអន្តរភាគី មាន៖

- ការសន្យាដោយ GOP ក្នុងអំឡុងពេលនៃកិច្ចប្រជុំរដ្ឋមន្ត្រីរបស់រដ្ឋភាគីនៃអនុសញ្ញាស្តីពីជនភៀសខ្លួន និងភាពគ្មានសញ្ជាតិ ឆ្នាំ១៩៦១ នៅថ្ងៃទី០៧-០៨ ខែធ្នូ ឆ្នាំ២០១១ ដើម្បីដោះស្រាយភាពគ្មានសញ្ជាតិនៅក្នុងប្រទេសហ្វីលីពីន រួមបញ្ចូលទាំងការវិភាគ និង ការប៉ាន់ប្រមាណជាបន្តបន្ទាប់អំពីភាពគ្មានសញ្ជាតិ និង ការគូរផែនទីជនដែលប្រឈមនឹងហានិភ័យនៃភាពជាគ្មានសញ្ជាតិ ដោយទទួលបានការគាំទ្រ និងកិច្ចសហការពី UNHCR (ជាពិសេស ជនដែលមានដើមកំណើតជាពលរដ្ឋឥណ្ឌូនេស៊ី)
- ការផ្តល់សច្ចាប័នរបស់ GOP នៅខែមិថុនា ឆ្នាំ២០១២ លើអនុសញ្ញាឆ្នាំ១៩៥៤ ពាក់ព័ន្ធនឹងឋានៈរបស់ជនគ្មានសញ្ជាតិ និង បន្ទាប់ពីនោះ
- ការបង្កើតជនបង្គោលថ្នាក់ជាតិនៅក្នុងនាយកដ្ឋានយុត្តិធម៌ – អង្គភាពការពារជនភៀសខ្លួន និងជនគ្មានសញ្ជាតិនៃនាយកដ្ឋានយុត្តិធម៌ ('DOJ RSPPU') ដើម្បីត្រួតពិនិត្យការសម្របសម្រួលបញ្ហានានាដែលទាក់ទងនឹងភាពគ្មានសញ្ជាតិ និង ការពារជនគ្មានសញ្ជាតិ តាមរយៈការចេញសារាចររបស់នាយកដ្ឋានលេខ ៥៨ (វិធានស្តីពីការបង្កើតនីតិវិធីកំណត់ឋានៈរបស់ជនភៀសខ្លួន និងជនគ្មានសញ្ជាតិ) នៅថ្ងៃទី១៨ ខែតុលា ឆ្នាំ២០១២ ដោយនាយកដ្ឋានយុត្តិធម៌។[294]

ii. បង្កើតនីតិវិធីកំណត់ភាពគ្មានសញ្ជាតិ។ នៅខែតុលា ឆ្នាំ២០១២ ប្រទេសហ្វីលីពីនបានបង្កើតនីតិវិធីកំណត់អំពីឋានៈគ្មានសញ្ជាតិ នៅលើការធ្វើអត្តសញ្ញាណកម្ម ការប្រព្រឹត្តិចំពោះ និងការការពារជនគ្មានសញ្ជាតិនៅក្នុងប្រទេសហ្វីលីពីនតាមរយៈ DOJ DC លេខ ៥៨

iii. បង្កើតកម្មវិធីរួមគ្នា។ កាលពីឆ្នាំ២០១៤ រវាងរដ្ឋាភិបាលហ្វីលីពីន ធ្វើការជាដៃគូជាមួយ រដ្ឋាភិបាលឥណ្ឌូនេស៊ី (GOI) ដោយបានទទួលការគាំទ្រពី UNHCR បានអនុវត្តកម្មវិធីរួមគ្នាមួយដើម្បីកំណត់ផែនទី និង ដោះស្រាយបញ្ហាភាពជាពលរដ្ឋរបស់ជនដែលមានដើមកំណើតជាពលរដ្ឋឥណ្ឌូនេស៊ី (PIDs) រាប់ពាន់នាក់ដែលស្នាក់នៅក្នុងប្រទេសហ្វីលីពីន។ គិតត្រឹមខែវិច្ឆិកា ឆ្នាំ២០១៧ ប្រហែល ៧៥% នៃ PIDs ៨.៧៤៥ នាក់ ទទួលបានការបញ្ជាក់ភាពជាពលរដ្ឋរបស់ពួកគេ។ របាយការណ៍បានផ្តល់ករណីសិក្សាដែលលម្អិតយ៉ាងខ្លាំងមួយ អំពីវិធីដែលប្រទេសហ្វីលីពីនបាន និងកំពុងតែដោះស្រាយបញ្ហានានាដែលទាក់ទងនឹងសញ្ជាតិ និងឋានៈតាមផ្លូវច្បាប់របស PIDs។ វាមានសារសំខាន់នៅក្នុងការកត់សម្គាល់ថា គណៈកម្មាធិការរួមស្តីពីកិច្ចសហការទ្វេភាគីរវាងប្រទេសហ្វីលីពីន និងប្រទេសឥណ្ឌូនេស៊ី (JCBC) ក៏ត្រូវបានបង្កើតឡើងផងដែរ។ គណៈកម្មាធិការរួមស្តីពីកិច្ចសហការទ្វេភាគី (JCBC) រវាង GOP និង GOI គឺជាការឆ្លើយតបដ៏រឹងមាំមួយចំពោះចំណុចសកម្មភាពលេខ ១ (ដោះស្រាយស្ថានភាពនៃភាពគ្មានសញ្ជាតិ

293 របាយការណ៍របស់ប្រទេសហ្វីលីពីន។

294 Ibid.

ដែលមានស្រាប់) នៅក្នុងចំណោមចំណុចសកម្មភាពទាំង ១០ នៃផែនការសកម្មភាពជាសកលដើម្បីបញ្ចប់ភាពគ្មានសញ្ជាតិ៖ ឆ្នាំ២០១៤-២០២៤។ ផែនការសកម្មភាពជាសកលនេះ ដោយត្រូវបានអភិវឌ្ឍឡើងដោយមានការពិគ្រោះយោបល់ជាមួយរដ្ឋ អង្គការសង្គមស៊ីវិល និងអង្គការអន្តរជាតិនោះ មានបំណងបញ្ចប់ភាពគ្មានសញ្ជាតិនៅក្នុងរយៈពេល ១០ ឆ្នាំ។ ផែនការសកម្មភាពជាតិដើម្បីបញ្ចប់ភាពគ្មានសញ្ជាតិរបស់ប្រទេសហ្វីលីពីន (ឆ្នាំ២០១៥-២០២៤) ឬ NAP ត្រូវបានបង្កើតឡើងនៅក្នុងឆ្នាំ២០១៥។ គោលដៅមួយក្នុងចំណោមគោលដៅនានារបស់ផែនការសកម្មភាពនេះ គឺផ្តល់ឋានៈតាមផ្លូវច្បាប់ដល់ PIDs តាមរយៈទិដ្ឋាការស្នាក់នៅអចិន្ត្រៃយ៍ ឬការទទួលបានភាពជាពលរដ្ឋហ្វីលីពីន[295]

iv. ផ្តល់ការតំណាងតាមផ្លូវច្បាប់ដល់ជនគ្មានសញ្ជាតិដោយឥតគិតថ្លៃ។ ក៏មានអនុស្សរណៈនៃការយោគយល់គ្នាដែលបានចុះហត្ថលេខា រវាងការិយាល័យមេធាវីសាធារណៈ (PAO) ការិយាល័យផ្តល់ជំនួយផ្នែកច្បាប់ជាសាធារណៈរបស់រដ្ឋាភិបាលហ្វីលីពីន និង UNHCR សម្រាប់ផ្តល់ជំនួយផ្នែកច្បាប់ និង ការតំណាងឲ្យជនគ្មានសញ្ជាតិ និង ជនដែលប្រឈមមុខនឹងហានិភ័យនៃភាពគ្មានសញ្ជាតិដោយឥតគិតថ្លៃ នៅគ្រប់ដំណាក់កាលទាំងអស់នៃសញ្ជាតូបនីយកម្ម និង នីតិវិធីរឿងក្តីភាពជាពលរដ្ឋ។ ដោយរំពឹងទុកថានឹងមានសំណុំឯកសារស្តីពីរឿងក្តីរបស់បុគ្គលក្នុងទ្រង់ទ្រាយធំនោះ សកម្មភាពកសាងសមត្ថភាពត្រូវបានអនុវត្តសម្រាប់មេធាវីរបស់ PAO ដើម្បីគាំទ្រពួកគេនៅក្នុងការផ្តល់ជំនួយផ្នែកច្បាប់ និង ជំនួយនានាដោយឥតគិតថ្លៃ។ បណ្តាញអ្នកស្ម័គ្រចិត្តធ្វើជាជំនួយការមេធាវី និងអង្គការសង្គមស៊ីវិលដែលអាចផ្តល់ជំនួយផ្នែក វិជ្ជាជីវៈដោយស្ម័គ្រចិត្តដល់ PIDs នៅក្នុងតំបន់ទាំងនេះ ក៏ត្រូវបានបង្កើតឡើងផងដែរ[296]

v. ផ្តល់លិខិតឆ្លងដែនជូនក្រុមជាក់លាក់។ កាលពីខែមករា ឆ្នាំ២០១៨ PIDs មួយចំនួន ជានិមិត្តរូប បានទទួលលិខិតឆ្លងដែនឥណ្ឌូនេស៊ីពីរដ្ឋមន្ត្រីក្រសួងការបរទេសឥណ្ឌូនេស៊ី Retno LP Marsudi។ PIDs ត្រូវស្នើសុំលិខិតឆ្លងដែនជាសមូហភាព។ លិខិតឆ្លងដែនត្រូវបានចេញជូនដោយឥតគិតថ្លៃ និងអាចធ្វើទៅបាន ដែលវានឹងត្រូវបានចេញរួមជាមួយទិដ្ឋាការស្នាក់នៅក្នុងប្រទេសហ្វីលីពីន។ គោលដៅនៅពេលនោះ គឺអាចចេញលិខិតឆ្លងដែនជូន PIDs គ្រប់រូបដែលត្រូវបានបញ្ជាក់ ត្រឹមចុងឆ្នាំ២០១៨[297]

vi. បង្កើតផែនការសកម្មភាពគោល។ នៅថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០១៧ រដ្ឋាភិបាលហ្វីលីពីនបានចាប់ផ្តើមដំណើរការផែនការសកម្មភាពជាតិ (NAP) របស់ប្រទេស ដើម្បីបញ្ចប់ភាពគ្មានសញ្ជាតិ។ ដូចដែលបានដកស្រង់ដូចខាងលើ NAP គឺជាក្របខណ្ឌនៃចំណុចសកម្មភាពចំនួន ៧[298] ដែលរដ្ឋាភិបាលហ្វីលីពីនបានប្តេជ្ញាចិត្តអនុវត្ត។ ចំណុចសកម្មភាពទាំងនេះមានលក្ខណៈស្របគ្នានឹងផែនការសកម្មភាពជាសកលដើម្បីបញ្ចប់ភាពគ្មានសញ្ជាតិ ដែលជាផ្នែកមួយនៃយុទ្ធនាការបញ្ចប់ភាពគ្មានសញ្ជាតិ រយៈពេល ១០ ឆ្នាំរបស់ UNHCR។[299] NAP របស់ប្រទេសហ្វីលីពីនគ្របដណ្តប់លើឆ្នាំ២០១៥-២០២០។ ផែនការនេះត្រូវបានបង្កើតឡើងក្រោមការដឹកនាំរបស់នាយកដ្ឋានយុត្តិធម៌ សហការជាមួយទីភ្នាក់ងាររដ្ឋាភិបាលដទៃទៀត អង្គការមិនមែនរដ្ឋាភិបាល អង្គការសង្គមស៊ីវិល និងវិស័យដែលពាក់ព័ន្ធដទៃទៀត ដោយមានការគាំទ្រផ្នែកបច្ចេកទេសពី UNHCR។ ផែនការនេះមានបំណងដោះស្រាយបញ្ហានានារបស់ "ជនដែលប្រឈមមុខនឹងហានិភ័យនៃការគ្មានសញ្ជាតិ" រួមមាន កុមារបាត់ខ្លួន Sama Badjaos ជនដែលដើមកំណើតជាពលរដ្ឋឥណ្ឌូនេស៊ី និង កុមារដែលគ្មានឯកសារនៅតាមទីតាំងធ្វើអន្តោប្រវេសន៍[300]

295 របាយការណ៍របស់ប្រទេសហ្វីលីពីន។

296 Ibid.

297 Ibid.

298 ចំណុចសកម្មភាពទាំងប្រាំពីរដែលត្រូវបានសម្គាល់ឃើញនៅក្នុង NAP រួមមាន៖
ចំណុចសកម្មភាព លេខ ១ (ដោះស្រាយស្ថានភាពនៃភាពគ្មានសញ្ជាតិដែលមានស្រាប់)
ចំណុចសកម្មភាព លេខ ២ (ពុំមានកុមារណាម្នាក់ដែលកើតមកដោយគ្មានសញ្ជាតិនោះទេ)
ចំណុចសកម្មភាព លេខ ៣ (លុបការរើសអើងយេនឌ័រចេញពីច្បាប់ស្តីពីសញ្ជាតិ)
ចំណុចសកម្មភាព លេខ ៦ (ផ្តល់ការការពារដល់ជនអន្តោរប្រវេសន៍ដែលគ្មានសញ្ជាតិ និង ជួយសម្រួលដល់ការធ្វើសញ្ជាតូបនីយកម្មរបស់ពួកគេ)
ចំណុចសកម្មភាព លេខ ៧ (ធានាចំពោះការចុះបញ្ជីកំណើត ដើម្បីទប់ស្កាត់ភាពគ្មានសញ្ជាតិ)
ចំណុចសកម្មភាព លេខ ៩ (ធ្វើការព្រមព្រៀងចំពោះអនុសញ្ញាអង្គការសហប្រជាជាតិស្តីពីភាពគ្មានសញ្ជាតិ) និង
ចំណុចសកម្មភាព លេខ ១០ (ពង្រឹងទិន្នន័យផ្នែកបរិមាណ និង គុណភាព ស្តីពីប្រជាជនដែលគ្មានសញ្ជាតិ)។

299 របាយការណ៍របស់ប្រទេសហ្វីលីពីន។

300 ធាតុចូលបន្ថែមត្រូវបានផ្តល់ជូនដោយជនបង្គោលនៃប្រទេសហ្វីលីពីន។

vii. សម្គាល់ និងកាត់បន្ថយចំណុចនៃការរើសអើងយេនឌ័រ។ រដ្ឋាភិបាលហ្វីលីពីនបានរួមបញ្ចូលការលុបការរើសអើងយេនឌ័រចេញពីច្បាប់ស្តីពីសញ្ជាតិ នៅក្នុងផែនការសកម្មភាពជាតិដើម្បីបញ្ចប់ភាពគ្មានសញ្ជាតិ របស់ខ្លួន។ UNHCR និង រដ្ឋាភិបាលហ្វីលីពីន (តំណាងដោយទីភ្នាក់ងារដឹកនាំផែនការ ក្រសួងយុត្តិធម៌ និង ការដឹកនាំរួមគ្នានៅក្នុងចំណុចសកម្មភាព គណៈកម្មការហ្វីលីពីនស្តីពីស្ត្រី) បានប្តេជ្ញាចិត្តធ្វើការត្រួតពិនិត្យឡើងវិញលើ CA ៤៧៣ និង RA ៩១៣៩ និង ធានាចំពោះការអនុម័តច្បាប់ដែលបានធ្វើវិសោធនកម្ម ដែលធានាថាមានសមភាពយេនឌ័រក្នុងការទទួលបានភាពជាពលរដ្ឋហ្វីលីពីន ដោយជនបរទេសដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់[301]

viii. ចុះបញ្ជីជនជាតិហ្វីលីពីនដែលនៅក្រៅប្រទេស។ គំនិតផ្តួចផ្តើមនៃកិច្ចសហប្រតិបត្តិការ រវាងក្រសួងការបរទេស (DFA) ក្រសួងសុខមាលភាពសង្គម (DSWD) និង អាជ្ញាធរស្ថិតិនៃប្រទេសហ្វីលីពីន (PSA) នៅក្នុងការចុះបញ្ជីកំណើតរបស់កុមារដែលគ្មានឯកសារនៅសាខា តាមរយៈក្រុមការងារដែលចុះទៅកាន់សហគមន៍ហ្វីលីពីនជាលក្ខណៈផ្ទាល់ខ្លួន។ ដូចគ្នានេះដែរ អនុព័ន្ធផ្នែកសុខមាលភាពសង្គមក៏ត្រូវបានបញ្ជូនទៅកាន់ប្រទេសនានានៅមជ្ឈិមបូព៌ា ដោយ DSWD ដើម្បីជួយសម្រួលដល់លក្ខខណ្ឌតម្រូវផ្នែកឯកសារ និងឯកសារធ្វើដំណើរ សម្រាប់ការធ្វើមាតុភូមិនិវត្តន៍របស់កូនជនចំណាកស្រុក ហ្វីលីពីនដែលគ្មានឯកសារ ដែលត្រូវគេបោះបង់ និង បានបាត់ខ្លួន[302]

ix. ពង្រឹងកិច្ចប្រឹងប្រែងផ្នែកនីតិបញ្ញត្តិដើម្បីឆ្ពោះទៅកាន់ការពង្រឹងប្រព័ន្ធចុះបញ្ជីអត្រានុកូលដ្ឋាន។ សេចក្តីព្រាងច្បាប់ជាច្រើនត្រូវបានដាក់ជូនសភាទាំងពីរ ពាក់ព័ន្ធនឹងការធ្វើស្ថាប័នភាវូបនីយកម្មប្រព័ន្ធចុះបញ្ជីអត្រានុកូលដ្ឋាន និងស្ថិតិអត្រានុកូលដ្ឋានគ្រប់ជ្រុងជ្រោយ ឬការធ្វើឌីជីថលនីយកម្មទិន្នន័យ។ ការស្វែងរកមតិគាំទ្រជាបន្តបន្ទាប់ដើម្បីអនុម័តលើសេចក្តីព្រាងច្បាប់ទាំងនោះឲ្យក្លាយទៅជាច្បាប់ កំពុងតែត្រូវបានធ្វើឡើងដោយបណ្តាញសិទ្ធិកុមារ (CRN) ដែលជាអង្គការមេរបស់ក្រុមសិទ្ធិកុមារនៅក្នុងប្រទេស។[303]

## ប្រទេសសិង្ហបុរី

i. អនុញ្ញាតិឲ្យជនគ្មានសញ្ជាតិដាក់ពាក្យស្នើសុំការស្នាក់នៅអចិន្ត្រៃយ៍ និងភាពជាពលរដ្ឋសិង្ហបុរី។ ពាក្យស្នើសុំរបស់ពួកគេនឹងត្រូវបានប៉ាន់ប្រមាណ ដោយផ្អែកលើលក្ខខណ្ឌតម្រូវសម្រាប់សិទ្ធិទទួលបានដែលមានសុពលភាព ដោយពាក្យស្នើសុំនីមួយៗនឹងត្រូវបានគេប៉ាន់ប្រមាណយ៉ាងប្រុងប្រយ័ត្ន ដោយផ្អែកលើគុណតម្លៃរបស់ពាក្យស្នើសុំទាំងនោះ។ PRs សិង្ហបុរីដែលគ្មានសញ្ជាតិក៏អាចដាក់ពាក្យស្នើសុំលិខិតបញ្ជាក់អត្តសញ្ញាណបានដែរ ដែលអាចប្រើប្រាស់ដើម្បីជួយសម្រួលដល់ការធ្វើដំណើរទៅក្រៅប្រទេសរបស់គាត់។ ជនគ្មានសញ្ជាតិក៏ទទួលបានការចុះបញ្ជីកំណើតដែរ[304]

ii. កាត់បន្ថយការរើសអើងយេនឌ័រ។ ប្រទេសសិង្ហបុរីបានគូសបញ្ជាក់នៅក្នុងរបាយការណ៍តាមកាលកំណត់លើកទី ២ និង ទី ៣ របស់ខ្លួន សម្រាប់អនុសញ្ញាអង្គការសហប្រជាជាតិស្តីពីសិទ្ធិកុមារ (CRC) ថា ប្រទេសសិង្ហបុរីបានធ្វើវិសោធនកម្មលើរដ្ឋធម្មនុញ្ញរបស់ខ្លួនកាលពីឆ្នាំ២០០៤ ដើម្បីអនុញ្ញាឲ្យស្ត្រីសិង្ហបុរីអាចផ្ទេរភាពជាពលរដ្ឋសិង្ហបុរីតាមវង្សត្រកូលរបស់ពួកគេទៅកាន់កូន ដែលជាជនបរទេស របស់ពួកគេ។ នេះគឺជាការអភិវឌ្ឍជាវិជ្ជមានមួយដើម្បីពង្រឹងច្បាប់នៅក្នុងវិស័យសិទ្ធិកុមារ[305]

iii. ទប់ស្កាត់ការដកហូតភាពជាពលរដ្ឋ។ ដើម្បីឆ្លើយតបទៅនឹងសេចក្តីសង្កេតសន្និដ្ឋានរបស់គណៈកម្មាធិការ CRC ប្រទេសសិង្ហបុរីបានអះអាងនៅក្នុងរបាយការណ៍តាមកាលកំណត់នៃ CRC លើកទី ៤ និងទី ៥ របស់ខ្លួនថា ច្បាប់របស់ប្រទេសសិង្ហបុរីមិនបានចែងអំពីការដកហូតភាពជាពលរដ្ឋរបស់កុមារណាម្នាក់ដែលជាពលរដ្ឋសិង្ហបុរីពីកំណើត ឬតាមរយៈវង្សត្រកូលនោះទេ។ ដូចគ្នានឹងអ្នកដទៃទៀតដែរ កុមារគ្មានសញ្ជាតិអាចដាក់ពាក្យស្នើសុំភាពជាពលរដ្ឋសិង្ហបុរីស្របតាមច្បាប់។ កុមារជាកូនរបស់ម្តាយដែលជាពលរដ្ឋសិង្ហបុរីនៅមុនខែឧសភា ឆ្នាំ២០០៤ អាចដាក់ពាក្យស្នើសុំភាពជាពលរដ្ឋសិង្ហបុរីតាមរយៈការចុះបញ្ជីស្របតាមច្បាប់របស់ប្រទេសសិង្ហបុរី។[306]

---

301 Ibid.
302 Ibid.
303 Ibid.
304 របាយការណ៍របស់ប្រទេសសិង្ហបុរី។
305 Ibid.
306 Ibid.

## ប្រទេសថៃ

ផ្អែកតាមគម្រោងសាកល្បងដែលត្រូវបានអនុវត្តនៅខេត្តមេហុងសន ដែលមានបំណងដោះស្រាយឋានៈតាមផ្លូវច្បាប់របស់ក្រុមជាតិពន្ធនានា ទម្លាប់អនុវត្តជាទូទៅមួយចំនួនអាចត្រូវបានចែករំលែកដូចខាងក្រោម៖

i. បង្កើតគោលការណ៍ណែនាំដែលអាចអនុវត្តបានជាទូទៅ។ យោងតាមមាត្រា ៧ ស្ទួន [307] កថាខណ្ឌទី២ នៃច្បាប់ស្តីពីសញ្ជាតិ រួមជាមួយ សេចក្តីសម្រេចរបស់ខុទ្ទកាល័យ ចុះថ្ងៃទី០៧ ខែធ្នូ ឆ្នាំ២០១៦ (ពស. ២៥៥៩) រដ្ឋមន្ត្រីក្រសួងមហាផ្ទៃបានចេញបទបញ្ជារបស់ក្រសួងមហាផ្ទៃស្តីពីការផ្តល់សញ្ជាតិថៃ តាមដែលអាចអនុវត្តបានជាទូទៅទៅកាន់មនុស្សម្នាក់ដែលកើតនៅក្នុងព្រះរាជាណាចក្រថៃ ជាកូនរបស់ឪពុក និង ម្តាយជាជនបរទេស ដែលមិនទទួលបានសញ្ជាតិថៃ និងការផ្តល់សញ្ជាតិថៃនៅក្នុងករណីពិសេស ចុះថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០១៧ (ពស. ២៥៦០) ដែលចែងអំពីមនុស្សបួនប្រភេទ[308]ដែលបំពេញតាមលក្ខណៈសម្បត្តិដែលបានតម្រូវ ដូចបានបញ្ញត្តិដោយខុទ្ទកាល័យ នឹងទទួលបានសញ្ជាតិថៃ ក្នុងករណីទូទៅ ឬជាក់លាក់។ ពួកគេអាចដាក់ពាក្យស្នើសុំទៅកាន់ការិយាល័យចុះបញ្ជីប្រចាំស្រុកដែលអ្នកដាក់ពាក្យស្នើសុំបានចុះបញ្ជី (នៅក្នុងសៀវភៅចុះបញ្ជីផ្ទះ ឬ ការចុះបញ្ជីទិន្នន័យរបស់គាត់)[309]

ii. ពង្រឹងកិច្ចសហការរវាងរដ្ឋ និងអង្គការមិនមែនរដ្ឋាភិបាល (NGOs)។ គេបានកត់សម្គាល់ថា កិច្ចសហការរវាង NGOs និងតួអង្គរដ្ឋ មិនត្រឹមតែបានបង្កើនប្រសិទ្ធភាព និងផលិតភាពរបស់ការងារជាងប្រាំដងនោះទេ ប៉ុន្តែវាថែមទាំងមិនមានផលជះដល់ថវិការបស់រដ្ឋាភិបាលទៀតផង ដោយសារតែ NGOs មានថវិកាផ្ទាល់ខ្លួនរបស់ពួកគេ ឬ ម៉្យាងវិញទៀត ពួកគេអាចប្រើប្រាស់ភាពជោគជ័យរបស់គម្រោងសាកល្បងដើម្បីស្នើសុំការគាំទ្រ និងការផ្តល់មូលនិធិបន្ថែមទៀត។ ជាក់ស្តែង កិច្ចសហការនេះមានអត្ថប្រយោជន៍ចំពោះទាំងរដ្ឋាភិបាល និងNGOs។ លើសពីនេះទៀត កិច្ចសហការជាមួយប្រធានភូមិ ឬមន្ត្រីរដ្ឋបាលក្នុងមូលដ្ឋាន បុគ្គលិករបស់ NGOs នៅក្នុងមូលដ្ឋាន ក៏អាចជួយត្រួតពិនិត្យ និងផ្ទៀងផ្ទាត់ព័ត៌មានដែលពាក់ព័ន្ធនឹងការស្នាក់នៅរបស់អ្នកដាក់ពាក្យស្នើសុំ ដើម្បីទប់ស្កាត់ការបោកបញ្ឆោតជាសក្តានុពលណាមួយផងដែរ។ លើសពីនេះទៀត ក្រុមប្រតិបត្តិការចល័តក៏ត្រូវបានបង្កើតឡើងដើម្បីទទួលយកពាក្យស្នើសុំនៅតាមតំបន់ដាច់ស្រយាលផងដែរ។ ដោយសារតែកិច្ចសហការរបស់អ្នកពាក់ព័ន្ធទាំងអស់នៅក្នុងអំឡុងខែតុលា ឆ្នាំ២០១៦ (ពស. ២៥៥៩) - ខែមីនា ឆ្នាំ២០១៨ (ពស. ២៥៦១) មានពាក្យស្នើសុំចំនួន ៤.២២៥ ច្បាប់ត្រូវបានដំណើរការ។[310]

---

307 ច្បាប់ស្តីពីសញ្ជាតិ ឆ្នាំ១៩៦៥ (ពស. ២៥០៨) និង វិសោធនកម្មរបស់ច្បាប់នេះ ប្រការ ៧ ស្ទួន

មនុស្សម្នាក់ដែលកើតនៅក្នុងព្រះរាជាណាចក្រថៃ ដែលមានឪពុកម្តាយជាជនបរទេសមិនទទួលបានសញ្ជាតិថៃនោះទេ ប្រសិនបើនៅពេលកំណើតរបស់គាត់ ឪពុកស្របច្បាប់របស់គាត់ ឬ ឪពុករបស់គាត់ ដែលមិនបានរៀបអាពាហ៍ពិពាហ៍ស្របច្បាប់ជាមួយម្តាយរបស់គាត់ ឬ ម្តាយរបស់គាត់ គឺជា៖

(១) ជនដែលបានទទួលការអនុញ្ញាត នៅក្នុងករណីពិសេស ឲ្យស្នាក់នៅក្នុងព្រះរាជាណាចក្រថៃ

(២) ជនដែលបានទទួលការអនុញ្ញាតឲ្យស្នាក់នៅក្នុងព្រះរាជាណាចក្រថៃ បណ្តោះអាសន្ន

(៣) ជនដែលបានចូលក្នុងព្រះរាជាណាចក្រថៃដោយគ្មានការអនុញ្ញាត ស្របតាមច្បាប់អន្តោប្រវេសន៍។

ដូចដែលត្រូវបានចាត់ទុកថាសមស្រប រដ្ឋមន្ត្រីអាចពិចារណា និង ចេញបទបញ្ជាសម្រាប់ករណីជាក់លាក់នីមួយៗ ឬ នៅក្នុងករណីទូទៅ ឲ្យផ្តល់សញ្ជាតិថៃដល់អ្នកណាម្នាក់ ស្របតាមកថាខណ្ឌទី១ ដោយអនុលោមតាមបទប្បញ្ញត្តិនានាដែលបានបញ្ញត្តិដោយខុទ្ទកាល័យ។ របាយការណ៍របស់ប្រទេសថៃ។

308 Ibid.

១. ជនដែលកើតនៅក្នុងប្រទេសថៃ ជាកូនរបស់ឪពុក ឬ ម្តាយជាជនជាតិភាគតិច ឬ ជាកូនរបស់ឪពុក ឬ ម្តាយដែលជាសមាជិកក្រុមជាតិពន្ធ ដែលបានធ្វើចំណាកស្រុក និង បានរស់នៅក្នុងប្រទេសថៃ យ៉ាងតិច ១៥ ឆ្នាំជាប់ៗគ្នា និង ដែលទិន្នន័យរបស់ពួកគេត្រូវបានកត់ត្រាទុក និង ត្រូវបានចុះបញ្ជី

២. ជនដែលកើតនៅក្នុងប្រទេសថៃ ជាកូនរបស់ឪពុក និង ម្តាយបរទេស ដែលមិនស្ថិតនៅក្នុងក្រុមដែលបានលើកឡើងនៅក្នុងចំណុចទី១ (ជាពលករបរទេស ឬ ជនគ្មានរដ្ឋ ដែលគ្មានលេខអត្តសញ្ញាណកម្ម) និង យ៉ាងហោចណាស់បានទទួលសញ្ញាប័ត្រថ្នាក់បរិញ្ញាបត្រ ឬ សញ្ញាបត្រដែលមានតម្លៃស្មើ

៣. ជនគ្មានសញ្ជាតិដែលកើតនៅក្នុងប្រទេសថៃ ដែលបច្ចុប្បន្នបានចុះឈ្មោះចូលរួមនៅក្នុងវិទ្យាស្ថានអប់រំណាមួយ (គ្មានឪពុកម្តាយ ឬ ត្រូវបានឪពុកម្តាយបោះបង់ចោលតាំងពីកុមារភាព)។ នៅក្នុងករណីនេះ លក្ខខណ្ឌតម្រូវចំនួនពីរបន្ថែមទៀតត្រូវតែបានបំពេញតាម ពោលគឺ ត្រូវតែមានលិខិតបញ្ជាក់ជនគ្មានសញ្ជាតិដែលចេញដោយនាយកដ្ឋានមានសមត្ថកិច្ចនៃក្រសួងអភិវឌ្ឍសង្គម និង សន្តិសុខមនុស្ស ហើយ មនុស្សម្នាក់នៅត្រូវតែមានទីលំនៅនៅក្នុងប្រទេសថៃ ក្នុងរយៈពេលមិនតិចជាង ១០ ឆ្នាំ។

៤. ជនដែលកើតនៅក្នុងប្រទេសថៃ និង បានធ្វើសកម្មភាពដើម្បីអត្ថប្រយោជន៍របស់ប្រទេសថៃ ដែលត្រូវបានទទួលស្គាល់យ៉ាងទូលំទូលាយ។ នៅក្នុងករណីនេះ តម្រូវឲ្យមានលិខិតបញ្ជាក់ការទទួលស្គាល់ ដែលចេញដោយទីភ្នាក់ងាររដ្ឋាភិបាលដែលមានសមត្ថកិច្ចយ៉ាងហោចណាស់នៅកម្រិតនាយកដ្ឋាន ឬ កម្រិតសមមូល។

309 Ibid.

310 Ibid.

របាយការណ៍របស់ប្រទេសវៀតណាមលើកឧទាហរណ៍អំពីវិធីសាស្ត្រដោះស្រាយបញ្ហាសញ្ជាតិ សម្រាប់ក្រុមដែលងាយរងគ្រោះខុសៗគ្នា រួមបញ្ចូលទាំង ស្ត្រី និងកុមារផងដែរ។ ករណីរបស់ប្រទេសវៀតណាមគឺជាឧទាហរណ៍នៃច្បាប់ស្តីពីសញ្ជាតិដែលមានលក្ខណៈបើកចំហរយ៉ាងខ្លាំង។ UNHCR ចាត់ទុកវៀតណាមថាជាប្រទេសដែលល្អបំផុតនៅក្នុងការដោះស្រាយបញ្ហាភាពគ្មានសញ្ជាតិនៅក្នុងតំបន់អាស៊ី-បាស៊ីហ្វិក និង ជាគំរូដ៏ល្អមួយសម្រាប់ការទប់ស្កាត់ភាពគ្មានសញ្ជាតិ។[311]

i. បង្កើតជម្រើសច្បាស់លាស់សម្រាប់សញ្ជាតូបនីយកម្ម។ ច្បាប់ស្តីពីសញ្ជាតិវៀតណាម ឆ្នាំ២០០៨ មានមាត្រាជាក់លាក់មួយ (មាត្រា ២២) ចែងអំពីជម្រើសនៃការធ្វើសញ្ជាតូបនីយកម្មនៅប្រទេសវៀតណាម សម្រាប់ជនគ្មានសញ្ជាតិ៖ "ជនគ្មានសញ្ជាតិដែលពុំមានឯកសារអត្តសញ្ញាណផ្ទាល់ខ្លួនគ្រប់គ្រាន់ ប៉ុន្តែបាន និងកំពុងស្នាក់នៅយ៉ាងមានស្ថេរភាពនៅលើដែនដីវៀតណាមអស់រយៈពេល ២០ ឆ្នាំ ឬ លើសពីនេះ គិតត្រឹមកាលបរិច្ឆេទមានប្រសិទ្ធភាពនៃច្បាប់នេះ និង គោរពរដ្ឋធម្មនុញ្ញ និងច្បាប់របស់ប្រទេសវៀតណាម នឹងត្រូវបានអនុញ្ញាតឲ្យធ្វើសញ្ជាតូបនីយកម្មនៅក្នុងប្រទេសវៀតណាម ស្របតាមលំដាប់លំដោយ នីតិវិធី និងសំណុំឯកសារនានាដែលត្រូវបានបញ្ជាក់ដោយរដ្ឋាភិបាល"។ នេះគឺជាបញ្ញត្តិនៃប្រតិបត្តិការមួយដែលនឹងត្រូវអនុវត្តក្នុងរយៈពេល៣ឆ្នាំ (ចាប់ពីកាលបរិច្ឆេទមានប្រសិទ្ធភាពអនុវត្តនៃច្បាប់ស្តីពីសញ្ជាតិវៀតណាម ឆ្នាំ២០០៨ រហូតដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១២)។ ក្រឹត្យ សារាចរ និងបទប្បញ្ញត្តិមួយចំនួនត្រូវបានអនុម័តដើម្បីជួយសម្រួលដល់ដំណើរការនេះ ដូចជា ការលើកលែងថ្លៃសេវាជាដើម[312]

ii. ការពារសិទ្ធិរបស់កុមារដែលប្រឈមនឹងហានិភ័យ។ ច្បាប់ស្តីពីកុមារ ឆ្នាំ២០១៦ ទទួលស្គាល់សិទ្ធិរបស់កុមារដែលគ្មានភាពជាពលរដ្ឋវៀតណាម និងកំពុងរស់នៅក្នុងប្រទេសវៀតណាម កុមារស្វែងរកសិទ្ធិជ្រកកោន និង កុមារស្វែងរកសិទ្ធិជ្រកកោនដោយគ្មានមនុស្សពេញវ័យមកជាមួយ ក្នុងការទទួលបានការការពារដោយច្បាប់នៃប្រទេសវៀតណាម និង សិទ្ធិទទួលបានគោលនយោបាយថែទាំជំនួស[313]

iii. បញ្ជាក់អំពីនីតិវិធីនានានៅក្នុងផ្នែកនីតិបញ្ញត្តិ។ ច្បាប់ស្តីពីអត្រានុកូលដ្ឋាន ឆ្នាំ២០១៤ ចែងអំពីលំដាប់-លំដោយ និងនីតិវិធីសម្រាប់ការចុះបញ្ជីកំណើតជូនកុមារ រួមបញ្ចូលទាំងករណីរបស់កុមារដែលត្រូវគេបោះបង់ចោល និង កុមារដែលឪពុកម្តាយរបស់ពួកគេមិនមែនជាពលរដ្ឋផងដែរ ដើម្បីធានាចំពោះការចេញសំបុត្រកំណើតសម្រាប់កុមារគ្រប់រូបនៅលើដែនដីវៀតណាម និងថាកុមារគ្រប់រូបដែលកើតនៅលើដែនដីវៀតណាមមានសញ្ជាតិរបស់ពួកគេ[314]

iv. លើកកម្ពស់កិច្ចសហការអន្តរជាតិ៖ កិច្ចព្រមព្រៀងទ្វេភាគីរវាងប្រទេសវៀតណាម និង ប្រទេស ឡាវ។ ចំពោះជនដែលធ្វើអន្តោប្រវេសន៍ដោយខ្លួនឯង នៅតាមតំបន់ព្រំដែននៃប្រទេសវៀតណាម-ឡាវ រដ្ឋាភិបាលរបស់សាធារណរដ្ឋសង្គមនិយមវៀតណាម និងរដ្ឋាភិបាលរបស់សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវបានចុះហត្ថលេខាលើអនុស្សរណៈនៃការយោគយល់គ្នា ស្តីពីការដោះស្រាយការធ្វើអន្តោប្រវេសន៍ដោយសេរី និងកុមារដែលកើតនៅក្រៅអាពាហ៍ពិពាហ៍។ រដ្ឋាភិបាលបានចាត់តាំងអាជ្ញាធរដើម្បីសម្របសម្រួលដំណោះស្រាយចំពោះបញ្ហាខាងលើ រៀបចំផែនការ និង ផែនទីបង្ហាញផ្លូវសម្រាប់ការអនុវត្ត ខ្លឹមសារនៃកិច្ចព្រមព្រៀងនោះ ទម្រង់បែបបទនៃឯកសារនានា វិធីចាត់ការ និង ដោះស្រាយបញ្ហានានាដែលពាក់ព័ន្ធ។ កិច្ចព្រមព្រៀងនេះត្រូវបានបន្តសុពលភាពដោយសេចក្តីសម្រេចលេខ ២៣២៤/QD-CTN ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០១៦។ រយៈពេលបន្តសុពលភាពកិច្ចព្រមព្រៀងនេះគឺ ៣ ឆ្នាំ ចាប់ពីកាលបរិច្ឆេទចេញសេចក្តីសម្រេចនេះ[315]

---

311 របាយការណ៍របស់ប្រទេសវៀតណាម។

312 សារាចរលេខ ១៤៦/២០០៩/TT-BTC ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០០៩ ផ្តល់មគ្គុទ្ទេសក៍ណែនាំអំពីរបបនៃការប្រមូល ការទូទាត់ ការប្រើប្រាស់ និង ការគ្រប់គ្រងថ្លៃសេវាសម្រាប់បញ្ហានានាដែលទាក់ទងនឹងសញ្ជាតិ និង សារាចរលេខ ១៣៥/២០១០ TT-BTC ចុះថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០១០ របស់ក្រសួងហិរញ្ញវត្ថុ ដែលធ្វើវិសោធនកម្ម និង បន្ថែមពីលើសារាចរលេខ ១៤៦/២០០៩/TT-BTC - សុទ្ធតែជាឯកសារច្បាប់ដែលមានសារសំខាន់សម្រាប់ការដោះស្រាយសញ្ជាតូបនីយកម្ម ស្របតាមមាត្រា ២២ ដែលបញ្ជាក់យ៉ាងច្បាស់ថា រាល់ករណីសញ្ជាតូបនីយកម្មនៅក្នុងប្រទេសវៀតណាមទាំងអស់ ដែលស្ថិតនៅក្រោម មាត្រា ២២ ត្រូវបានលើកលែងថ្លៃសេវាសម្រាប់សញ្ជាតិ។ របាយការណ៍របស់ប្រទេសវៀតណាម។

313 Ibid.

314 Ibid.

315 Ibid.

v. ប្តេជ្ញាចិត្តអនុវត្តអនុសាសន៍របស់ UPR និងសេចក្តីសង្កេតសន្និដ្ឋានដែលធ្វើដោយ CEDAW និង CRC[316] ពាក់ព័ន្ធនឹងបញ្ហាសញ្ជាតិ និង ភាពគ្មានសញ្ជាតិ

vi. បង្កើតលក្ខខណ្ឌអំណោយផលសម្រាប់ជនគ្មានសញ្ជាតិ ដើម្បីធ្វើសមាហរណកម្មជាមួយសហគមន៍ក្នុងមូលដ្ឋាននៅក្នុងប្រទេសវៀតណាម និងដើម្បីទប់ស្កាត់ភាពគ្មានសញ្ជាតិ។ ច្បាប់របស់ប្រទេសវៀតណាមបានចែងអំពីខចែងដែលមានលក្ខណៈបើកចំហរជាច្រើនសម្រាប់ជនគ្មានសញ្ជាតិ។ ចំណុចនេះត្រូវបានឆ្លុះបញ្ចាំងនៅក្នុងមាត្រា ៨ នៃច្បាប់ស្តីពីសញ្ជាតិវៀតណាមដែលចែងថា "រដ្ឋនៃសាធារណរដ្ឋសង្គមនិយមវៀតណាមបង្កើតលក្ខខណ្ឌនានា ដើម្បីឲ្យកុមារដែលកើតនៅលើដែនដីនៃប្រទេសវៀតណាមមានសញ្ជាតិ និងដើម្បីឲ្យជនគ្មានសញ្ជាតិដែលស្នាក់នៅជាអចិន្ត្រៃយ៍នៅក្នុងប្រទេសវៀតណាម ទទួលបានសញ្ជាតិវៀតណាម ស្របតាមច្បាប់នេះ" [317]

vii. បង្កើតលក្ខខណ្ឌអំណោយផល ដើម្បីឲ្យកុមារដែលកើតនៅក្នុងប្រទេសវៀតណាមមានសញ្ជាតិ និង ប្រើប្រាស់ច្បាប់ដើម្បីទប់ស្កាត់កុមារមិនឲ្យប្រែជាគ្មានសញ្ជាតិ។ ច្បាប់ស្តីពីសញ្ជាតិចែងថា៖

   កុមារដែលកើតនៅលើដែនដីនៃប្រទេសវៀតណាម ដែលឪពុកម្តាយរបស់គាត់ នៅពេលផ្តល់កំណើតរបស់គាត់ គឺជាជនគ្មានសញ្ជាតិទាំងពីរនាក់ ដែលមានទីលំនៅអចិន្ត្រៃយ៍នៅក្នុងប្រទេសវៀតណាម មានសញ្ជាតិវៀតណាម (ខចែងទី១ មាត្រា ១៧ ច្បាប់ស្តីពីសញ្ជាតិវៀតណាម ឆ្នាំ២០០៨)

   កុមារដែលកើតនៅលើដែនដីនៃប្រទេសវៀតណាម ដែលម្តាយរបស់គាត់ នៅពេលផ្តល់កំណើតរបស់គាត់ គឺជាជនគ្មានសញ្ជាតិ ដែលមានទីលំនៅអចិន្ត្រៃយ៍នៅក្នុងប្រទេសវៀតណាម និង មិនស្គាល់ឪពុករបស់គាត់ មានសញ្ជាតិវៀតណាម (ខចែងទី២ មាត្រា ១៧ ច្បាប់ស្តីពីសញ្ជាតិវៀតណាម ឆ្នាំ២០០៨)[318]

viii. អនុញ្ញាតឲ្យទទួលបានសញ្ជាតិឡើងវិញ។ ច្បាប់នេះក៏ចែងអំពីករណីដាក់ពាក្យស្នើសុំសញ្ជាតិវៀតណាមឡើងវិញ (មាត្រា ២៣ ច្បាប់ស្តីពីសញ្ជាតិវៀតណាម ឆ្នាំ២០០៨) ផងដែរ ដោយចែងថា៖ "ជនដែលបានបាត់បង់សញ្ជាតិវៀតណាមរបស់គាត់ និងដាក់ពាក្យស្នើសុំសញ្ជាតិវៀតណាមរបស់គាត់ឡើងវិញ អាចទទួលបានសញ្ជាតិវៀតណាម

---

316 សេចក្តីសង្កេតសន្និដ្ឋានរបស់ CEDAW និង CRC ស្តីពីសញ្ជាតិរបស់ស្ត្រី និង កុមារ៖

គណៈកម្មាធិការ CRC ផ្តល់អនុសាសន៍ឲ្យប្រទេសវៀតណាមផ្តល់សច្ចាប័នលើអនុសញ្ញាស្តីពីឋានៈរបស់ជនគ្មានសញ្ជាតិ ឆ្នាំ១៩៥៤ និងអនុសញ្ញាស្តីពីការកាត់បន្ថយភាពគ្មានសញ្ជាតិ ឆ្នាំ១៩៦១។ សូមកត់សម្គាល់ថា នាពេលបច្ចុប្បន្ន ប្រទេសវៀតណាមកំពុងតែពិចារណាលើការផ្តល់សច្ចាប័នលើអនុសញ្ញាទាំងពីរនេះ។

គណៈកម្មាធិការ CEDAW ផ្តល់អនុសាសន៍អំពីចំណុចនានាដូចខាងក្រោម ពាក់ព័ន្ធនឹងភាពគ្មានសញ្ជាតិ សិទ្ធិជ្រកកោន និង ឋានៈជាជនភៀសខ្លួនរបស់ស្ត្រី៖

"ស្របតាមអនុសាសន៍ទូទៅ លេខ ៣២ ស្តីពីទំហំដែលទាក់ទងនឹងយេនឌ័រ នៃឋានៈជាជនភៀសខ្លួន សិទ្ធិជ្រកកោន សញ្ជាតិ និង ភាពគ្មានសញ្ជាតិរបស់ស្ត្រី គណៈកម្មាធិការផ្តល់អនុសាសន៍ឲ្យរដ្ឋភាគី៖

(ក) អនុម័តច្បាប់ និង នីតិវិធីដែលមានប្រសិទ្ធភាពសម្រាប់ការផ្តល់សិទ្ធិជ្រកកោន និង ឋានៈជាជនភៀសខ្លួន និង ផ្តល់ការការពារការធ្វើទុក្ខបុកម្នេញលើយេនឌ័រ

(ខ) បន្តជួយសម្រួលដល់ការកាត់បន្ថយភាពគ្មានសញ្ជាតិ ជាពិសេសការទទួលបានសញ្ជាតិវៀតណាមឡើងវិញដោយស្ត្រីដែលបានក្លាយជាគ្មានសញ្ជាតិដោយសារការបោះបង់ចោលសញ្ជាតិនោះ

(គ) ជម្រុញការចូលជាភាគីអនុសញ្ញាឆ្នាំ១៩៥១ ពាក់ព័ន្ធនឹងឋានៈរបស់ជនភៀសខ្លួន និង ពិធីសារឆ្នាំ១៩៦៧ អនុសញ្ញាឆ្នាំ១៩៥៤ ពាក់ព័ន្ធនឹងឋានៈរបស់ជនគ្មានសញ្ជាតិ និង អនុសញ្ញាឆ្នាំ១៩៦១ ស្តីពីការកាត់បន្ថយភាពគ្មានសញ្ជាតិ" Ibid.

317 Ibid.

318 Ibid.

របស់គាត់ឡើងវិញ ប្រសិនបើគាត់ស្ថិតនៅក្នុងករណីណាមួយក្នុងចំណោមករណីនានាដូចខាងក្រោម៖

ក/ បានដាក់ពាក្យស្នើសុំការអនុញ្ញាតឲ្យត្រឡប់ចូលប្រទេសវៀតណាមវិញ

ខ/ ស្វាមី/ភរិយារបស់គាត់ ឪពុក/ម្តាយ ឬ កូនបង្កើតរបស់គាត់គឺជាពលរដ្ឋវៀតណាម

គ/ បានរួមចំណែកដែលគួរឲ្យកោតសរសើរចំពោះការកសាង និង កិច្ចការពារជាតិនៃប្រទេសវៀតណាម

ឃ/ មានសារប្រយោជន៍ចំពោះរដ្ឋនៃសាធារណរដ្ឋសង្គមនិយមវៀតណាម

ង/ បានធ្វើសកម្មភាពវិនិយោគទុននៅក្នុងប្រទេសវៀតណាម

ច/ បានបោះបង់ចោលសញ្ជាតិវៀតណាមដើម្បីទទួលបានសញ្ជាតិបរទេសណាមួយ ប៉ុន្តែមិនទទួលបានការអនុញ្ញាតឲ្យទទួលបានសញ្ជាតិបរទេសនោះទេ”។[319]



319 Ibid.



# ៤. ទម្លាប់អនុវត្តល្អៗ និង មេរៀនដែលទទួលបានពីតំបន់ដទៃទៀត

## ៤.១ អឺរ៉ុប

អឺរ៉ុបគឺជាតំបន់ដែលមានកម្រិតខ្ពស់បំផុតនៃការចុះបញ្ជីកំណើត និងមានបញ្ហាបន្តិចបន្តួចពាក់ព័ន្ធនឹងការចុះបញ្ជីអត្រានុកូលដ្ឋាន។[320] វាក៏ជាទ្វីបដែលមាននិយាមដែលត្រូវបានអនុវត្តយ៉ាងទូលំទូលាយបំផុត ពាក់ព័ន្ធនឹងការទទួលបានសញ្ជាតិ និងការការពារពីភាពគ្មានសញ្ជាតិផងដែរ។ ប្រទេសនៅទ្វីបអឺរ៉ុបចំនួន ៣៣ ប្រទេស គឺជាភាគីនៃអនុញ្ញាឆ្នាំ១៩៥៤ នៅខណៈពេលដែលអនុសញ្ញា ឆ្នាំ១៩៦១ ត្រូវបានផ្តល់សច្ចាប័នដោយប្រទេសនៅទ្វីបអឺរ៉ុបចំនួន ២៨ ប្រទេស។ លើសពីនេះទៀត អនុសញ្ញាស្តីពីសញ្ជាតិនៅទ្វីបអឺរ៉ុបឆ្នាំ១៩៩៧ (ECN) ត្រូវបានផ្តល់សច្ចាប័នដោយ ២១ ប្រទេស។ នៅខណៈពេលដែលសហភាពអឺរ៉ុបពុំមានសមត្ថកិច្ចនៅក្នុងបញ្ហាសញ្ជាតិ ក្រុមប្រឹក្សាអឺរ៉ុបបែរជាមានភាពសកម្មយ៉ាងខ្លាំង។ ECN ដូចបានលើកឡើងខាងលើ គឺជាលិខិតូបករណ៍ថ្នាក់តំបន់ដែលមានភាពគ្រប់ជ្រុងជ្រោយខ្លាំងជាងគេបំផុត ចំពោះច្បាប់ស្តីពីសញ្ជាតិ ប៉ុន្តែនៅឆ្នាំ២០០៩ អនុសាសន៍ដែលមានអំណាចយ៉ាងខ្លាំង ២០០៩/១៣ ត្រូវបានអនុម័ត។[321] វាបន្តពីគោលការណ៍ទី២៣ នៃអនុសាសន៍នេះ ដែលថា ការចុះបញ្ជីកំណើតមានសារសំខាន់ខ្លាំងបំផុត ពីព្រោះវាគឺជាសំបុត្រមួយសន្លឹកដើម្បីចូលសញ្ជាតិ និង ទទួលបានសិទ្ធិមនុស្សដទៃទៀត។ ដូច្នេះ ស្របតាមគោលការណ៍ទី ២៣ ការចុះបញ្ជីកំណើតតែងតែចាំបាច់ត្រូវធ្វើឡើង ទោះបីជាឪពុក/ម្តាយជាជនបរទេស ជនអន្តោប្រវេសន៍ខុសច្បាប់ ឬ គ្មានឯកសារក៏ដោយ។ ឧត្តមប្រយោជន៍របស់កុមារ តម្រូវឲ្យមានការចុះបញ្ជីអំពីវត្តមានរបស់គាត់នៅគ្រប់កាលៈទេសៈទាំងអស់ ដោយគ្មានករណីលើកលែងនោះទេ។

ការរើសអើងយេនឌ័រក៏ត្រូវបានលុបបំបាត់បន្តិចម្តងៗនៅក្នុងទ្វីបអឺរ៉ុប ចាប់តាំងពីទសវត្សរ៍ឆ្នាំ១៩៧០មកម្ល៉េះ។ ការរើសអើងជាតិពន្ធ និងសាសនានៅក្នុងច្បាប់ស្តីពីសញ្ជាតិ ក៏ត្រូវបានហាមឃាត់ដោយសន្ធិសញ្ញាអន្តរជាតិខុសៗគ្នាផងដែរ ហើយការហាមឃាត់នេះក៏ត្រូវបានពង្រឹងបន្ថែមនៅថ្នាក់តំបន់ ដោយ ECN ផងដែរ។ ការស្រាវជ្រាវដែលមានលក្ខណៈប្រៀបធៀបស្តីពីការការពារពីភាពគ្មានសញ្ជាតិបង្ហាញថា ប្រទេសភាគច្រើនអនុលោមតាមបទដ្ឋានអន្តរជាតិ រួមទាំងបទដ្ឋានដែលពាក់ព័ន្ធនឹងកុមារគ្មានសញ្ជាតិដែលកើតនៅលើដែនដីរបស់ពួកគេផងដែរ ប៉ុន្តែបទដ្ឋានទាំងនេះអាច និងគួរតែបានអនុវត្តឲ្យបានច្បាស់លាស់ជាងនេះ។[322] ឧទាហរណ៍៖ ប្រទេសមួយចំនួនផ្តល់ការការពារដល់កុមារគ្មានសញ្ជាតិ ប៉ុន្តែលុះត្រាតែឪពុកម្តាយរបស់គាត់ជាជនគ្មានសញ្ជាតិដែរ ឬក្នុងលក្ខខណ្ឌដែល លក្ខខណ្ឌតម្រូវសម្រាប់ការធ្វើសមាហរណកម្មមួយចំនួន ត្រូវបានបំពេញតាម។ លក្ខខណ្ឌតម្រូវទាំងនោះមិនត្រូវបានអនុញ្ញាត ស្របតាមលិខិតូបករណ៍អន្តរជាតិនោះទេ។

ដូចគ្នានឹងតំបន់ដទៃទៀតដែរ ទ្វីបអឺរ៉ុបប្រឈមមុខនឹងតម្រូវការក្នុងការកែលម្អទិន្នន័យអំពីចំនួនជនគ្មានសញ្ជាតិដែលកើត ឬស្នាក់នៅក្នុងទ្វីបអឺរ៉ុប។ ការអភិវឌ្ឍដែលសំខាន់ជាងគេបំផុតនៅក្នុងទ្វីបអឺរ៉ុប គឺការទទួលស្គាល់អំពីតម្រូវការក្នុងការបង្កើតនីតិវិធីកំណត់ភាពគ្មានសញ្ជាតិ – ទាំងដោយរដ្ឋនានាដោយផ្ទាល់[323] និងដោយ EU។[324] ជាក់ស្តែង វាកើតឡើងជាញឹកញាប់ ដែលជនគ្មានសញ្ជាតិមិនត្រូវបានគេទទួលស្គាល់នោះទេ ឬ ត្រូវបានផ្តល់ជូននូវឋានៈ "សញ្ជាតិដែលមិនត្រូវបានកំណត់" ដែលមិនជាប់ពាក់ព័ន្ធនឹងសិទ្ធិណាមួយដែលស្ថិតនៅក្រោមអនុសញ្ញាស្តីពីភាពគ្មានសញ្ជាតិនោះទេ។ បញ្ហានេះត្រូវបានសម្គាល់ឃើញនៅក្នុង "ការ

320 https://data.unicef.org/wp-content/uploads/2015/12/Birth_Registration_lores_final_24.pdf ទំព័រទី ១៧។

321 https://rm.coe.int/16807096bf

322 http://eudo-citizenship.eu/images/docs/eudocit_vink_degroot_statelessness_final.pdf

323 នីតិវិធីកំណត់ភាពគ្មានសញ្ជាតិ នៅពេលនេះ អាចស្វែងរកបាននៅក្នុងប្រទេសប៊ុលហ្គារី ប្រទេសបារាំង ប្រទេសចចជៀ ប្រទេសហុងហ្គារី ប្រទេសអ៊ីតាលី ប្រទេសក្សូវ៉ូ ប្រទេសឡាតវៀ ប្រទេសម៉ូលដូវ៉ា ប្រទេសអេស្ប៉ាញ ប្រទេសទួរគី និង សហរាជអាណាចក្រ។ ចូរមើល http://www.institutesi.org/worldsstateless17.pdf ទំព័រទី៨២។

324 http://www.europarl.europa.eu/RegData/etudes/STUD/2015/536476/IPOL_STU(2015)536476_EN.pdf. ចូរមើលសេចក្តីសន្និដ្ឋានរបស់ក្រុមប្រឹក្សាអឺរ៉ុប ដែលត្រូវបានអនុម័តនៅខែធ្នូ ឆ្នាំ២០១៥ ដែលក្រុមប្រឹក្សានេះបានអញ្ជើញរដ្ឋសមាជិកឲ្យចូលរួមដោះដូរទម្លាប់អនុវត្តល្អៗ ដែលពាក់ព័ន្ធនឹងនីតិវិធីកំណត់ភាពគ្មានសញ្ជាតិផងដែរ អាចស្វែងរកបាននៅ http://www.consilium.europa.eu/en/press/press-releases/2015/12/04/council-adopts-conclusions-on-statelessness/#.

សិក្សាអំពីការគួរផែនទី" ជាច្រើន នៅទ្វីបអឺរ៉ុប ដែលត្រូវបានធ្វើឡើងដោយ UNHCR។ ជាក់ស្តែង ចំណុចខាងក្រោយបានចាត់ទុកនីតិវិធីកំណត់ភាពគ្មានសញ្ជាតិជាឧបករណ៍ដ៏ចាំបាច់សម្រាប់រដ្ឋ នៅក្នុងការបំពេញកាតព្វកិច្ចនៃការការពាររបស់ពួកគេ ស្របតាមច្បាប់អន្តរជាតិ។[325]

បណ្តាញអឺរ៉ុបស្តីពីភាពគ្មានសញ្ជាតិបានបោះពុម្ពផ្សាយរបាយការណ៍ទូលំទូលាយស្តីពីទម្លាប់អនុវត្តល្អបំផុត ពាក់ព័ន្ធនឹងនីតិវិធីកំណត់ភាពគ្មានសញ្ជាតិនៅអឺរ៉ុប[326] ហើយ UNHCR បានកំណត់ការបង្កើតនីតិវិធីទាំងនោះជាសកម្មភាពទី ៦ នៅក្នុងយុទ្ធនាការជាសកលដើម្បីបញ្ចប់ភាពគ្មានសញ្ជាតិឱ្យបានត្រឹមឆ្នាំ២០២៤។[327] នៅខណៈពេលដែលនីតិវិធីកំណត់ភាពគ្មានសញ្ជាតិត្រូវបានបញ្ជាក់អះអាងថា មិនបានដើរតួជាកត្តាអូសទាញទេនោះ គេគួរតែបានកត់សម្គាល់ថា ចំនួនអ្នកដាក់ពាក្យស្នើសុំមានចំនួនតិច (រាប់រយនាក់ ជារៀងរាល់ឆ្នាំ) ហេតុដូចនេះ មិនបានធ្វើឲ្យប្រទេសមានភាពប្រកួតប្រជែងនោះទេ។ គេនៅតែមើលឃើញ ថាតើនីតិវិធីប្រហាក់ប្រហែលគ្នាអាចដំណើរការបានយ៉ាងមានប្រសិទ្ធភាពដល់កម្រិតណា នៅក្នុងប្រទេសដែលមានប្រជាជនគ្មានសញ្ជាតិក្នុងចំនួនច្រើន ទោះបីជា UNHCR បានចង្អុលបង្ហាញថា នីតិវិធីកំណត់ទាំងនោះមិនមែនជាលិខិតូបករណ៍ដែលស័ក្តិសមនឹងប្រទេសដែលមានប្រជាជនគ្មានសញ្ជាតិនៅក្នុងប្រទេស (in situ) ក្នុងចំនួនច្រើននោះទេ (ចូរមើលផ្នែកទី II នៅខាងក្រោម)។

ប្រទេសហុងគ្រីត្រូវបានចាត់ទុកថាជាជើងឯកនៅក្នុងនីតិវិធីនេះ ពីព្រោះវាមាននីតិវិធីកំណត់ភាពគ្មានសញ្ជាតិដែលមានប្រសិទ្ធភាព និងផ្តោតលើគោលដៅជាក់លាក់ និងពីព្រោះវាបានដោះស្រាយកំហុសឆ្គងដ៏ធំមួយ តាមរយៈការលុបចោលលក្ខខណ្ឌតម្រូវឱ្យមានតែជនដែលស្នាក់នៅដោយស្របច្បាប់ប៉ុណ្ណោះទើបអាចដាក់ពាក្យស្នើសុំបាន ដោយអនុវត្តតាមសាលក្រមរបស់តុលាការរដ្ឋធម្មនុញ្ញនៃប្រទេសហុងគ្រី ឆ្នាំ២០១៥។[328]

បណ្តាញអឺរ៉ុបស្តីពីភាពគ្មានសញ្ជាតិបានបោះពុម្ពផ្សាយរបាយការណ៍មួយ ដែលផ្តោតជាពិសេសលើចន្លោះប្រហោង និងទម្លាប់អនុវត្តល្អបំផុត ពាក់ព័ន្ធនឹងភាពគ្មានសញ្ជាតិរបស់កុមារ។ នៅខណៈពេលដែលរបាយការណ៍នេះបានផ្តល់ទិដ្ឋភាពទូទៅដែលងាយស្រួលយល់ សេចក្តីសន្និដ្ឋានរបស់របាយការណ៍បានប្រើប្រាស់ជាចម្បងនូវការវិភាគតាមបែបប្រៀបធៀបកាលពីមុន ដែលធ្វើឡើងតាមរយៈការសង្កេតរបស់ GLOBALCIT សហការជាមួយ UNHCR ស្តីពីភាពចុះសម្រុងគ្នា រវាងវិធានស្តីពីសញ្ជាតិ និង ភាពគ្មានសញ្ជាតិនៅថ្នាក់ក្រុង និងបទដ្ឋានអន្តរជាតិ។[329]




325 http://www.unhcr.org/protection/statelessness/53b698ab9/handbook-protection-stateless-persons.html

326 https://www.statelessness.eu/sites/www.statelessness.eu/files/attachments/resources/Statelessness%20determination%20and%20the%20protection%20status%20of%20stateless%20persons%20ENG.pdf

327 http://www.refworld.org/pdfid/57836cff4.pdf

328 http://www.institutesi.org/worldsstateless17.pdf ទំព័រទី១៦។

329 http://eudo-citizenship.eu/databases/protection-against-statelessness

## ៤.២ អាហ្វ្រិក



ធម្មនុញ្ញស្តីពីសិទ្ធិ និង សុខមាលភាពរបស់កុមារនៃប្រទេសអាហ្វ្រិក បានចូលជាធរមាននៅឆ្នាំ១៩៩៩ ធានាចំពោះសិទ្ធិរបស់កុមារក្នុងការចុះបញ្ជីភ្លាមៗក្រោយពេលកើត និងសិទ្ធិទទួលបានសញ្ជាតិ នៅក្នុងមាត្រា ៦។[330] គណៈកម្មាធិការសិទ្ធិ និងសុខមាលភាពរបស់កុមារនៃប្រទេសអាហ្វ្រិក បានចេញសេចក្តីអធិប្បាយរួមក្នុង ការបញ្ជាក់អំពីសិទ្ធិនានាដែលបានបង្ហាញនៅក្នុងមាត្រានោះ។[331]

ផ្ទុយមកវិញ ធម្មនុញ្ញស្តីពីសិទ្ធិមនុស្ស និងសិទ្ធិប្រជាជននៃប្រទេសអាហ្វ្រិក ដែលបានចូលជាធរមាននៅ ឆ្នាំ១៩៨៦ មិនបានរួមបញ្ចូលបញ្ញត្តិណាមួយស្តីពីសញ្ជាតិនោះទេ ប៉ុន្តែបានចែងនៅក្នុងមាត្រា ៥ អំពីអ្វីដែលត្រូវបានចាត់ ទុកជាទូទៅថាជាការយោងដល់ទស្សនាទានស្តីពីអត្តសញ្ញាណតាមផ្លូវច្បាប់៖ “បុគ្គលគ្រប់រូបត្រូវមានសិទ្ធិទទួល បានការគោរពចំពោះសេចក្តីថ្លៃថ្នូរដែលមានជាប់ពីកំណើតមកនៅក្នុងខ្លួនមនុស្សម្នាក់ៗ និងការទទួលស្គាល់ឋានៈតាមផ្លូវច្បាប់របស់គាត់”។[332]

ធម្មនុញ្ញនេះក៏រួមបញ្ចូលបញ្ញត្តិនានាដែលពាក់ព័ន្ធនឹងភាពជាពលរដ្ឋផងដែរ (ឧ. មាត្រា ១២ ចែងថាបុគ្គលគ្រប់រូបមានសិទ្ធិចាកចេញពីប្រទេសណាមួយ រួមបញ្ចូលទាំងប្រទេសកំណើតរបស់គាត់ផ្ទាល់ផងដែរ) ហើយគណៈកម្មការសិទ្ធិមនុស្ស និង សិទ្ធិប្រជាជននៃប្រទេសអាហ្វ្រិកបានរកឃើញម្តងហើយម្តងទៀតនៅក្នុងករណីខុសៗគ្នា ដែលសិទ្ធិទទួលបានសញ្ជាតិត្រូវបានបញ្ជាក់នៅក្នុងមាត្រា ៥ នៃធម្មនុញ្ញនេះ។[333] ទោះបីជាយ៉ាងណាក៏ដោយ វាគឺជាសេចក្តីសម្រេចស្តីពីសិទ្ធិទទួលបានសញ្ជាតិ ឆ្នាំ២០១៣ ដែលត្រូវបានអនុម័តដោយគណៈកម្មការនៃប្រទេសអាហ្វ្រិក ដែលបញ្ជាក់ឡើងវិញយ៉ាងច្បាស់ថា៖ “សិទ្ធិទទួលបានសញ្ជាតិរបស់មនុស្សគ្រប់រូបគឺជាសិទ្ធិមនុស្សមូលដ្ឋាន ដែលត្រូវបានបញ្ជាក់ដោយតុណ្ហីភាពនៅក្នុងបញ្ញត្តិនានានៃមាត្រា ៥ នៃធម្មនុញ្ញស្តីពីសិទ្ធិមនុស្ស និង សិទ្ធិប្រជាជននៃប្រទេសអាហ្វ្រិក និង មានសារសំខាន់ចំពោះការទទួលបានសិទ្ធិ និង សេរីភាពកម្រិតមូលដ្ឋានដទៃទៀត ស្របតាមធម្មនុញ្ញនេះ៖”។[334]

ចំណុចសំខាន់ កាលពីឆ្នាំ២០១៤ គណៈកម្មការបានបន្តអនុវត្តតាមការប្តេជ្ញាចិត្តក្នុងការធ្វើសេចក្តីព្រាងពិធីសារមួយជូនធម្មនុញ្ញស្តីពីសិទ្ធិទទួលបានសញ្ជាតិនៃប្រទេសអាហ្វ្រិក។ ពាក់ព័ន្ធនឹងខ្លឹមសារ សំណៅសេចក្តីព្រាងនៃពិធីសារនេះមានខ្លឹមសារលើសពីអ្វីដែលមាននៅក្នុងអនុសញ្ញាស្តីពីសញ្ជាតិនៅទ្វីបអឺរ៉ុប ហើយប្រសិនបើត្រូវបានអនុម័ត នឹងក្លាយជាលិខិតូបករណ៍ស្តីពីសញ្ជាតិដែលមានវឌ្ឍនភាពខ្លាំងជាងគេបំផុតនៅលើទ្វីបណាមួយ។ ពិធីសារនេះរួមបញ្ចូលបណ្តុំគោលការណ៍លម្អិតៗ ដែលពាក់ព័ន្ធនឹងការទទួលស្គាល់ភាពជាពលរដ្ឋ ការកែសម្រួលច្បាប់ និង នីតិវិធីនានា ដើម្បីផលប្រយោជន៍របស់ក្រុមពនេចរ ការលើកកម្ពស់សមភាពយេនឌ័រ បម្រាមលើការរើសអើងជាតិសាសន៍ សាសនា និងទិដ្ឋភាពដទៃទៀតនៃច្បាប់ស្តីពីសញ្ជាតិ។

330 http://www.achpr.org/instruments/child/

331 http://www.refworld.org/docid/54db21734.html

332 ធម្មនុញ្ញស្តីពីសិទ្ធិមនុស្ស និង សិទ្ធិប្រជាជននៃប្រទេសអាហ្វ្រិក អាចស្វែងរកបាននៅ៖ https://www.achpr.org/legalinstruments/detail?id=49

333 Bronwen Manby ភាពជាពលរដ្ឋ និង ភាពគ្មានសញ្ជាតិនៅប្រទេសអាហ្វ្រិក ទំព័រទី ៤៦២។ អាចស្វែងរកបាននៅ៖https://pub.maastrichtuniversity.nl/f91d9081-73da-4125-9a7a-887ceb4acca7

334 http://www.achpr.org/sessions/53rd/resolutions/234/

ទម្លាប់អនុវត្តល្អបំផុតនៅទ្វីបអាហ្វ្រិក និងដែលត្រូវបានទទួលស្គាល់ថាទម្លាប់ល្អបំផុតដោយគណៈកម្មាធិការស្តីពីសិទ្ធិ និងសុខមាលភាពរបស់កុមារនៃប្រទេសអាហ្វ្រិកផងដែរនោះ[335] គឺវត្តមាននៃទម្រង់ខុសៗគ្នានៃ jus soli មាននៅ ២៥ ប្រទេសនៅក្នុងទ្វីបអាហ្វ្រិក។ ១០ ប្រទេសនៅទ្វីបអាហ្វ្រិកភាគខាងលិច (ប្រទេសទាំងនេះស្ទើរតែទាំងអស់គឺជាប្រទេសហ្វ្រង់កូហ្វូន ដូចជា ប្រទេស Benin, Burkina Faso, Cameroon និងប្រទេសដទៃទៀត) បានចែងអំពី jus soli ទ្វេដង (ពោលគឺ កុមារដែលកើតនៅក្នុងប្រទេសណាមួយ ដែលមានឪពុក/ម្តាយម្នាក់ដែលបានកើតនៅទីនោះដែរ នឹងទទួលបានភាពជាពលរដ្ឋដោយស្វ័យប្រវត្តិ) នៅខណៈពេលដែលប្រទេសជាច្រើនផ្សេងទៀត ចែងអំពីលក្ខណៈខុសៗគ្នានៃ jus soli ទ្វេដង។[336] ចំណុចដែលមានបញ្ហាច្រើនជាងនេះទៀតនោះគឺ មានតែ ១៣ ប្រទេសប៉ុណ្ណោះដែលផ្តល់ភាពជាពលរដ្ឋដោយស្វ័យប្រវត្តិ ដល់កុមារដែលកើតនៅក្នុងប្រទេស បើមិនដូច្នោះទេពួកគេនឹងក្លាយជាកុមារគ្មានសញ្ជាតិ[337] នៅខណៈពេលដែល ១១ ប្រទេសផ្សេងទៀតបង្កើតលក្ខខណ្ឌសម្រាប់ផ្តល់ភាពជាពលរដ្ឋដល់តែកុមារដែលមានឪពុកម្តាយជាជនគ្មានសញ្ជាតិតែប៉ុណ្ណោះ។ លក្ខខណ្ឌតម្រូវខាងក្រោយនេះ ដូចដែលត្រូវបានមើលឃើញនៅខាងលើ ដែលពាក់ព័ន្ធនឹងទ្វីបអឺរ៉ុប មិនត្រូវបានអនុញ្ញាតស្របតាមបទដ្ឋានអន្តរជាតិនោះទេ និងផ្តល់ការការពារមិនបានគ្រប់គ្រាន់ ដល់កុមារដែលមានឪពុកម្តាយមានសញ្ជាតិ ប៉ុន្តែមិនអាចផ្ទេរសញ្ជាតិរបស់ពួកគេទៅកាន់កូនរបស់ពួកគេបានទេ។ ២៧ ប្រទេស និង ១៩ ប្រទេសនៃទ្វីបអាហ្វ្រិកគឺជាភាគីនៃអនុសញ្ញាឆ្នាំ១៩៥៤ និង ១៩៦១ រៀងៗគ្នា។

ជាចុងបញ្ចប់ ឧទាហរណ៍អំពីទ្វីបអាហ្វ្រិក យោងតាម Manby បង្ហាញថាការជម្រុញឲ្យបង្កើត និងចងក្រងឯកសារអត្តសញ្ញាណតាមផ្លូវច្បាប់ គឺជាការបង្កើតបញ្ហានៃសញ្ជាតិ ជាពិសេស ប្រសិនបើច្បាប់ស្តីពីសញ្ជាតិដែលមានការរើសអើង និងមានការផាត់ចេញ មិនត្រូវបានដោះស្រាយជាមុនសិន។ នាងបានពណ៌នាពីចំណុចនេះថាជាដំណើរការមួយដែលនាំមកនូវហានិភ័យនៃ "ការបង្កើតជនគ្មានសញ្ជាតិ ដែលកាលពីមុនមានតែជនដែលគ្មានឯកសារតែប៉ុណ្ណោះ"។[338] ផ្ទុយមកវិញ ដូចដែលត្រូវបានកត់សម្គាល់ដោយ Van Waas "ប្រសិនបើសញ្ជាតិ តាមនិយមន័យ គឺជាចំណងតាមផ្លូវច្បាប់រវាងមនុស្ស និងរដ្ឋនោះ តើគេអាចលុបបំបាត់ភាពគ្មានសញ្ជាតិ ដោយគ្មានការដោះស្រាយបញ្ហាជាមូលដ្ឋានដែលមើលមិនឃើញតាមផ្លូវច្បាប់ ឬកង្វះខាតអត្តសញ្ញាណតាមផ្លូវច្បាប់បានដោយរបៀបណា?"[339]



## ៤.៣ អាមេរិក

335 http://www.institutesi.org/worldsstateless17.pdf ទំព័រទី ២៣។

336 Manby ទំព័រទី ១២៥។

337 នៅក្នុងគំនិតផ្តួចផ្តើមលុបបំបាត់ភាពគ្មានសញ្ជាតិនៅទ្វីបអាហ្វ្រិក ចូរមើល សេចក្តីប្រកាស Abidjan ឆ្នាំ២០១៥ ជាពិសេស៖ http://www.unhcr.org/ecowas2015/

338 https://www.statelessness.eu/blog/right-legal-identity-or-right-legal-id

339 Ibid.

ទ្វីបអាមេរិកមានប្រពៃណី jus soli ដ៏រឹងមាំ ដោយប្រទេសចំនួន ៣០ ក្នុងចំណោមប្រទេសទាំង ៣៥ បានចែងអំពីការទទួលបានសញ្ជាតិដោយស្វ័យប្រវត្តិតាមរយៈការកើតនៅលើ។ ចំណុចនេះផ្តល់ជូននិវាសនជនភាគច្រើន នូវការទទួលបានសញ្ជាតិ និងការការពារពីភាពគ្មានសញ្ជាតិ។ ទោះបីជាយ៉ាងណាក៏ដោយ នៅតែមានក្រុមជនគ្មានសញ្ជាតិ ជាពិសេសនៅតំបន់ខារីបៀន ដែលប្រទេស មួយចំនួននៅតែរើសអើងចំពោះយេនឌ័រ (ឧ. Bahamas) និង សាធារណរដ្ឋដូមីនីកែនបានដកហូតសញ្ជាតិ ដូមីនីកែន ពីពលរដ្ឋដែលមានដើមកំណើតជាជនជាតិហៃទី តាមអំពើចិត្ត ដោយផ្អែកលើជាតិពន្ធុរបស់ពួកគេ។

ផ្នែកមួយនៃសេចក្តីប្រកាស របស់ប្រទេសប្រេស៊ីល ឆ្នាំ២០១៤ ប្រទេសចំនួន ២៨ និង ដែនដីនៃតំបន់អាមេរិកឡាទីន និងខារីបៀន ចំនួន៣បានប្តេជ្ញាចិត្តលុបបំបាត់ ភាពគ្មានសញ្ជាតិនៅក្នុងទ្វីបអាមេរិកត្រឹមឆ្នាំ២០២៤ ដោយអនុវត្តតាមគោលការណ៍ណែនាំរបស់ ផែនការសកម្មភាពជាសកលដើម្បីបញ្ចប់ភាពគ្មានសញ្ជាតិរបស់ UNHCR។[340] សេចក្តីប្រកាសរបស់ប្រទេសប្រេស៊ីល មានលក្ខណៈគ្រប់ជ្រុងជ្រោយដែលនៅក្នុងនោះ គេបានស្នើឲ្យរដ្ឋអនុម័តវិធីសាស្រ្តនានានៅក្នុងវិស័យទាំងបី ដែលពាក់ព័ន្ធនឹងភាពគ្មានសញ្ជាតិ រួមមាន ការបង្ការ ការការពារ និង ការដោះស្រាយ។[341]

យោងតាម Juan Mondelli នៃការិយាល័យប្រចាំតំបន់ របស់ UNHCR នៅ San José ប្រទេសកូស្តារីកា វិធីសាស្រ្តទាំងបីនេះអាចបំបែកបន្តទៀតដូចខាងក្រោម៖

- **ការបង្ការ៖** ការទទួលយកអនុសញ្ញា ឆ្នាំ ១៩៦១ និង ធ្វើសុខដុមរមនីយកម្មបទបញ្ញាផ្ទៃក្នុង និងទម្លាប់អនុវត្តដែលពាក់ព័ន្ធនឹងសញ្ជាតិ ជាមួយបទដ្ឋានអន្តរជាតិ[342]
- **ការការពារ៖** ការទទួលយកអនុសញ្ញា ឆ្នាំ ១៩៥៤ បង្កើតនីតិវិធីកំណត់ភាពគ្មានសញ្ជាតិ[343] និង អនុម័តក្របខណ្ឌការពារ ដើម្បីផ្តល់ប្រសិទ្ធភាពអនុវត្តឱ្យបានពេញលេញដល់អនុសញ្ញា ឆ្នាំ១៩៥៤ និង សន្ធិសញ្ញាសិទ្ធិមនុស្សដទៃទៀត
- **ការដោះស្រាយ៖** សម្រួលដល់ការផ្តល់សញ្ជាតូបនីយកម្មដែលមាន ការជួយសម្រួល[344] បញ្ជាក់អំពីសញ្ជាតិ (ឧ. តាមរយៈការជួយសម្រួល ដល់ការចុះបញ្ជីកំណើតយឺតពេល និងការចេញសំណុំឯកសារដែលពាក់ព័ន្ធ)[345] និងជួយសម្រួលដល់ការទទួលបានសញ្ជាតិឡើងវិញ និង ការប្រគល់សញ្ជាតិជូនវិញ។

បន្ទាប់ពីមានយុទ្ធនាការរបស់ UNHCR ចាប់ពីពាក់កណ្តាលទសវត្សរ៍ឆ្នាំ២០០០ រហូតមកបន្ថែមពីលើសេចក្តីប្រកាសរបស់ប្រទេសប្រេស៊ីល ចំនួនរដ្ឋដែលបានទទួលយកអនុសញ្ញា ឆ្នាំ១៩៥៤ និង/ឬ ឆ្នាំ១៩៦៤ មានការកើនឡើងយ៉ាងឆាប់រហ័សនៅក្នុងទ្វីបអាមេរិក៖ ១៩ ប្រទេស ក្នុងចំនួន ៣៥ ប្រទេស នៅពេលនេះ គឺជាភាគីរបស់អនុសញ្ញាឆ្នាំ១៩៥៤ នៅខណៈដែល ១៧ ប្រទេស ក្នុងចំនួន ៣៥ ប្រទេស នៅពេលនេះ គឺជាភាគីរបស់អនុសញ្ញា ឆ្នាំ១៩៦១។[346] វាក៏កើតឡើងបន្ទាប់ពីមានសេចក្តីប្រកាសរបស់ប្រេស៊ីល ដែលបានចែងថា រដ្ឋគួរតែបង្កើតនីតិវិធីសម្រាប់កំណត់ភាពគ្មានសញ្ជាតិ ដើម្បីអនុលោមតាមកាតព្វកិច្ចរបស់ពួកគេនៅក្រោម អនុសញ្ញាឆ្នាំ១៩៥៤ ផងដែរ។ ជាក់ស្តែង វាត្រូវបានពង្រឹងបន្ថែមដោយ សេចក្តីសម្រេចឆ្នាំ

340 http://www.unhcr.org/ibelong/global-action-plan-2014-2024/

341 http://www.fmreview.org/latinamerica-caribbean/mondelli.html

342 ចំពោះបញ្ហាដែលនៅតែត្រូវការដំណោះស្រាយ ដូចជាគោលជំហរនៃសញ្ជាតិរបស់កុមារបាត់ខ្លួន និង ភាពគ្មានសញ្ជាតិដែលអាចកើតឡើងបានចំពោះកុមារដែលកើតនៅក្រៅប្រទេស ចូរមើល Mondelli, Juan Ignacio។ "ឆ្ពោះទៅកាន់ការលុបបំបាត់ភាពគ្មានសញ្ជាតិនៅទ្វីបអាមេរិក៖ សេចក្តីប្រកាសរបស់ប្រទេសប្រេស៊ីល និង ផែនការសកម្មភាព" នៅក្នុង ការដោះស្រាយភាពគ្មានសញ្ជាតិ eds. Laura van Waas និង Melanie Khanna ២៨៥-៣១៦។ Oisterwijk៖ Wolf Legal Publishers ឆ្នាំ២០១៦ ទំព័រទី ៣០៣-៣០៦។

343 រដ្ឋអាមេរិកប្រហែល ១២ រដ្ឋ បានណែនាំអំពីនីតិវិធីកំណត់ភាពគ្មានសញ្ជាតិ ឬ កំពុងដំណើរការនីតិវិធីនេះ។ ដោយសារតែនេះគឺជាការអភិវឌ្ឍនាពេលថ្មីៗនេះ មានមនុស្សតិចតួចណាស់ដែលដឹងអំពីការអនុវត្តយ៉ាងជាក់ស្តែងរបស់ពួកគេ។ ចូរមើល Mondelli ទំព័រ ៣០៩-៣១១។

344 ពុំមានប្រទេសណាមួយនៅក្នុងទ្វីបអាមេរិកដែលមិនទាន់បានណែនាំអំពីសញ្ជាតូបនីយកម្មដែលមានការជួយសម្រួលនោះទេ ប៉ុន្តែប្រទេស Bolivia បានកាត់បន្ថយយ៉ាងខ្លាំងនូវចំណាយលើការស្នើសុំសញ្ជាតូបនីយកម្ម។

345 ចូរមើលសកម្មភាពទី៨ នៃផែនការសកម្មភាពជាសកល ("ការចេញសំណុំឯកសារស្តីពីសញ្ជាតិដល់ជនដែលមានសិទ្ធិទទួលបាន") នៅ http://www.unhcr.org/statelesscampaign2014/Global-Action-Plan-eng.pdf

346 http://www.refworld.org/docid/54576a754.html

២០១៦ របស់អង្គការនៃរដ្ឋអាមេរិក (OAS) ស្តីពីការលើកកម្ពស់ និង ការការពារសិទ្ធិមនុស្ស។[347] ដូច្នេះ វាសង្កត់ធ្ងន់លើ “សារសំខាន់របស់អនុសញ្ញានានា ស្តីពីភាពគ្មានសញ្ជាតិ និងអញ្ជើញរដ្ឋសមាជិកដែលមិនទាន់បានចូលរួមឲ្យពិចារណាផ្តល់សច្ចាប័នលើ ឬទទួលយកអនុសញ្ញាទាំងនោះ តាមភាពសមស្រប និងអញ្ជើញរដ្ឋជាសមាជិកឲ្យបង្កើតនីតិវិធីកំណត់ភាពគ្មានសញ្ជាតិដែលមានភាពសុក្រឹតមានប្រសិទ្ធភាព និងផ្តល់ការជួយសម្រួលដល់ការធ្វើសញ្ជាតូបនីយកម្មរបស់ជនគ្មានសញ្ជាតិតាមដែល អាចអនុវត្តបាន”។[348]

រដ្ឋជាច្រើនបានអនុវត្តតាម តាមរយៈការអនុម័តបទប្បញ្ញត្តិពិសេសៗសម្រាប់គោលបំណងនេះ ឬ តាមរយៈការធ្វើវិសោធនកម្មច្បាប់ស្តីពីភាពជាពលរដ្ឋ ឬ ច្បាប់អន្តោប្រវេសន៍របស់ពួកគេ។ ចំពោះការដោះស្រាយបញ្ហាភាពគ្មានសញ្ជាតិ ប្រទេសជាច្រើនបាន និងកំពុងអនុវត្តគម្រោងនានាដើម្បីផ្ទៀងផ្ទាត់ ឬ ត្រួតពិនិត្យឡើងវិញលើការចុះបញ្ជីកំណើតរបស់ប្រជាជន និង ធានាចំពោះការចុះបញ្ជីយ៉ាងសមស្រប និងការទទួលបានសំណុំឯកសារបញ្ជាក់អំពីសញ្ជាតិ។

ស្របពេលជាមួយគ្នានេះ មានវឌ្ឍនភាពនៅក្នុងការធានាចំពោះការចុះបញ្ជីកំណើត នៅទ្វីបអាមេរិក។[349] នៅខណៈពេលដែល ៧៦% នៃកុមារដែលមានអាយុក្រោមប្រាំឆ្នាំ ត្រូវបានចុះបញ្ជីរួចរាល់នៅដើមទសវត្សរ៍ឆ្នាំ២០០០ តួលេខនេះបានកើតឡើងរហូតដល់ ៩៤% នៅក្នុងឆ្នាំ២០១៦។ អង្គការ UNICEF បានចង្អុលបង្ហាញថា នេះដោយសារតែ “សមត្ថភាពរបស់ស្ថាប័នទទួលបន្ទុកលើការចុះបញ្ជីអត្រានុកូលដ្ឋានមានភាពរឹងមាំជាងមុន នៅក្នុងការផ្តល់សេវា ការបង្កើតសេវាទាំងនោះនៅតាមមន្ទីរពេទ្យរដ្ឋ ការលុបបំបាត់ថ្លៃសេវា គោលនយោបាយសាធារណៈដែលផ្សារភ្ជាប់ការចុះបញ្ជីកំណើត ទៅនឹងការទទួលបានយន្តការការពារសង្គម និងយុទ្ធនាការផ្តល់ព័ត៌មានទ្រង់ទ្រាយធំ”។[350]

## ៤.៤ មជ្ឈិមបូព៌ា និង អាហ្វ្រិកខាងជើង

នៅក្នុងតំបន់ MENA មិនបានបង្ហាញពីការអនុវត្តល្អៗនោះទេ។ ជាក់ស្តែង របាយការណ៍នាពេលថ្មីៗនេះថែងថា៖ “រូបភាពទូទៅ គឺជាតំបន់មួយ ដែលមានច្បាប់ស្តីពីសញ្ជាតិដែលមានគុណវិបត្តិយ៉ាងខ្លាំង ជាកន្លែងដែលទម្លាប់អនុវត្តនៃប្រតិកិរិយា តាមធម្មតា បានធ្វើឲ្យសញ្ជាតិរបស់ជនដែលគេមិនស្វាគមន៍ ស្ថិតនៅក្រោមការគំរាមកំហែង”។[351] ទោះបីជាលិខិតូបករណ៍ថ្នាក់តំបន់មួយចំនួនត្រូវបានអនុម័ត និង ត្រូវបានផ្តល់សច្ចាប័នយ៉ាងទូលំទូលាយ រួមបញ្ចូលទាំងធម្មនុញ្ញស្តីពីសិទ្ធិមនុស្សនៃប្រទេសអារ៉ាប់ ឆ្នាំ២០០៤ និង អនុសញ្ញាស្តីពីសិទ្ធិរបស់កុមារដែលកាន់សាសនាអ៊ីស្លាម ឆ្នាំ២០០៥ ក៏ដោយ ក៏វាគឺជាតំបន់មួយ ដែលមានភាពល្បីល្បាញអំពីយុទ្ធសាស្ត្រផ្នែកសញ្ជាតិដែលមានការរឹតត្បិតរបស់វា (ជាពិសេស នៅក្នុងរដ្ឋនានានៃប្រទេសអារ៉ាប់ក្នុងតំបន់ឈូងសមុទ្រ) ព្រមទាំងការរើសអើងយេនឌ័រ និងការរើសអើងសាសនាពាក់ព័ន្ធនឹងសញ្ជាតិផងដែរ។[352] នៅខណៈពេលដែលគ្មានប្រទេសនៃតំបន់ MENA ណាមួយមាន jus soli ដោយស្វ័យប្រវត្តិទេនោះ ប្រទេសជាច្រើនបានថែងអំពី jus soli ទ្វេដង។[353]



347 http://www.oas.org/en/sla/dil/docs/AG-RES_2887_XLVI-O-16.pdf

348 ចូរមើលមាត្រា ៦ នៃសេចក្តីសម្រេច ដែលមានចំណងជើងថា “ការទប់ស្កាត់ និង ការកាត់បន្ថយភាពគ្មានសញ្ជាតិ និង ការការពារជនគ្មានសញ្ជាតិនៅក្នុងទ្វីបអាមេរិក”។

349 https://data.unicef.org/resources/birth-registration-latin-america-caribbean-closing-gaps/

350 Ibid.

351 Zahra Albarazi “របាយការណ៍ GLOBALCIT ប្រចាំតំបន់ ស្តីពីភាពជាពលរដ្ឋ៖ មជ្ឈិមបូព៌ា និង អាហ្វ្រិកខាងជើង” (ត្រូវបានផ្តល់ជូន) ទំព័រទី ៩។

352 Ibid. ទំព័រទី ៣។ Albarazi ចង្អុលបង្ហាញថា ក្នុងចំណោម ២៥ ប្រទេសនៅទូទាំងពិភពលោក នៅតែមានការរើសអើងយេនឌ័រ ជាងពាក់កណ្តាលនៃប្រទេសទាំងនោះអាចត្រូវបានរកឃើញនៅក្នុងតំបន់ MENA។

353 Ibid. ទំព័រទី ១២។

# ៥. សេចក្តីសន្និដ្ឋាន និង អនុសាសន៍




© UNHCR

## ៥.១ ការចុះបញ្ជីកំណើត និង សញ្ជាតិ ជាវិធីកំណត់ព្រំដែនផ្នែកប្រជាសាស្ត្ររបស់រដ្ឋ

ជាតិ-រដ្ឋ "កំណត់ព្រំដែនផ្នែកភូមិសាស្ត្ររបស់ខ្លួនតាមរយៈដែនដី និងព្រំដែនផ្នែកប្រជាសាស្ត្ររបស់ខ្លួនតាមរយៈសញ្ជាតិ"។[354] ពលរដ្ឋនៃរដ្ឋមួយត្រូវបានចាត់ទុកថា ជាសមាជិករបស់សហគមន៍ដែលមាននយោបាយជាក់លាក់។ ជនដែលមិនមែនជាពលរដ្ឋគឺជា "ជនបរទេស" ដែលតាមធម្មតាពុំមានសិទ្ធិទទួលបានគុណប្រយោជន៍របស់សមាជិកភាព ឬការប្រព្រឹត្តិដូចគ្នានោះទេ។ ទោះបីជាយ៉ាងណាក៏ដោយ AMS ភាគច្រើន បានបង្ហាញនៅក្នុងរបាយការណ៍ប្រទេសរបស់ពួកគេថា ការទទួលបានសិទ្ធិស្មើគ្នារបស់ជនដែលមិនមែនជាពលរដ្ឋ ត្រូវបានធានាដោយច្បាប់ជាតិ រួមបញ្ចូលទាំងការចុះបញ្ជីកំណើតផងដែរ។ ការចុះបញ្ជីកំណើតរបស់កុមារគ្រប់រូបដែលកើតនៅក្នុងប្រទេសនោះត្រូវបានបញ្ញត្តិដោយច្បាប់នៅក្នុង AMS នីមួយៗ។ ទោះបីជាយ៉ាងណាក៏ដោយ ការទទួលបានការចុះបញ្ជីកំណើត និងការចុះបញ្ជីអត្រានុកូលដ្ឋានរបស់ក្រុមខុសៗគ្នាអាចមានការខុសគ្នា ពីប្រទេសមួយទៅប្រទេសមួយផ្សេងទៀត និងពីប្រជាជនមួយក្រុមទៅប្រជាជនមួយក្រុមផ្សេងទៀត។ ប្រទេសសិង្ហបុរី ដោយមានប្រព័ន្ធចុះបញ្ជីដែលបានធ្វើឌីជីថលនីយកម្ម។ ផ្តល់ការទទួលបានការចុះបញ្ជីកំណើតជាសកល នៅខណៈពេលដែលប្រជាជន ៧៥ លាននាក់នៅក្នុងប្រទេសឥណ្ឌូនេស៊ីនៅតែខ្វះខាតសំបុត្រកំណើត។[355] នៅប្រទេសហ្វីលីពីន និងប្រទេសថៃ ក្រុមប្រជាជនមួយចំនួននៅតែត្រូវបានគេទុកចោល នៅខាងក្រៅគ្រោងការណ៍ចុះបញ្ជី។ ប្រទេសទាំងពីរនេះ តាមរយៈកម្មវិធី និងគម្រោងពិសេសៗ បានខិតខំប្រឹងប្រែងផ្តល់ការទទួលបានការ ចុះបញ្ជីកំណើត និង ការចុះបញ្ជីអត្រានុកូលដ្ឋានដល់ក្រុមដែលពិបាកឈោងចាប់នៅតាមតំបន់នានា ដែលការចេញចូលដោយផ្ទាល់ និង ហេដ្ឋារចនាសម្ព័ន្ធនៅតែមានកម្រិត ចំណេះដឹង និង ការយល់ដឹងនៅមានកម្រិតទាប និងនៅក្នុងករណីមួយចំនួន មិនបាន ផ្តល់តម្លៃដល់សារសំខាន់នៃការចុះបញ្ជីកំណើតនិងការចុះបញ្ជីអត្រានុកូលដ្ឋាននោះទេ។ ប្រទេសកម្ពុជាបានកំពុងតែមានការអនុវត្តវិធីសាស្ត្រនានារួមបញ្ចូលទាំង កំណែទម្រង់ច្បាប់ និងការអនុម័តច្បាប់ជាក់លាក់ ស្តីពីការចុះបញ្ជីអត្រានុកូលដ្ឋាន។ ក្រុមចុះបញ្ជីចល័តភាគច្រើនមាននៅក្នុង AMS ។ ប្រទេសមួយចំនួនដូចជាវៀតណាមជាដើមបានធ្វើវិមជ្ឈការអំណាចចុះបញ្ជីកំណើត និងអនុសញ្ញាសកម្មភាពចុះបញ្ជីអត្រា-នុកូលដ្ឋានដទៃទៀត។ ទោះបីជាយ៉ាងណាក៏ដោយ លើកលែងតែនៅក្នុងប្រទេសមួយចំនួនតូចប៉ុណ្ណោះ ដូចជា ប្រទេសកម្ពុជា ប្រទេសថៃ និងប្រទេសវៀតណាមជាដើម ភាពស្របច្បាប់របស់ឪពុកម្តាយត្រូវបានតម្រូវដោយប្រទេសភាគច្រើន សម្រាប់ការចុះបញ្ជីកំណើត។ លក្ខខណ្ឌតម្រូវនេះ ធ្វើឲ្យក្រុមមនុស្សមួយចំនួន ដូចជាពលករទេសន្តរប្រវេសន៍ខុសច្បាប់ជនភៀសខ្លួន និង អ្នកស្វែងរកសិទ្ធិជ្រក-កោន ស្ថិតនៅខាងក្រៅប្រព័ន្ធចុះបញ្ជី។ ទោះបីជាមានបញ្ហាប្រឈមមួយចំនួនក្តី ក៏មានបញ្ជីដ៏វែងនៃទម្លាប់អនុវត្តល្អៗ ដែលរបាយការណ៍របស់ប្រទេស



354 William Wetherall សញ្ជាតិនៅក្នុងប្រទេសជប៉ុន នៅក្នុង Soo Im Lee, et al, (eds) ការខ្វល់ខ្វាយចិត្តចំពោះពិពិធភាពរបស់ប្រទេសជប៉ុន៖ ជាតិពន្ធុ ភាពជាពលរដ្ឋ និង ការអប់រំ ទីក្រុងញូវយ៉ក iUniverse, Inc., ញូវយ៉ក ឆ្នាំ២០០៦ ទំព័រទី ១១។

355 Asian Nikkei "ជនជាតិឥណ្ឌូនេស៊ី "ដែលគេមើលមិនឃើញ" បានជម្រុញឲ្យមានការទទួលបានសំបុត្រកំណើត" អាចស្វែងរកបាននៅ៖ https://asia.nikkei.com/Economy/Invisible-Indonesians-nudged-to-get-birth-certificates

នីមួយៗ បានសម្គាល់ឃើញដែលតាមរយៈបញ្ជីនេះ AMS អាចរៀនសូត្រពីគ្នាទៅវិញទៅមកដើម្បីដោះស្រាយបញ្ហានានាពាក់ព័ន្ធនឹង ការចុះបញ្ជីកំណើត និងការចុះបញ្ជីអត្រានុកូលដ្ឋាន។



ការសិក្សាមួយចំនួនបានបង្ហាញ តាមប្រវត្តិសាស្ត្រ រាល់ AMS ទាំងអស់បានផ្តល់កន្លែងស្នាក់នៅដល់មនុស្សមួយចំនួនធំនៅលើដែនដីរបស់ ពួកគេធ្វើឲ្យសហគមន៍ដែលមានសាវតាខុសៗគ្នា មានអារម្មណ៍ថា ពួកគេចែករំលែកវត្ថុមួយចំនួនជាមួយគ្នា និង បានបង្កើតទំនុកចិត្ត និងភាពស្មោះត្រង់ ដែលមានសារសំខាន់ចំពោះការបំពេញ មុខងាររបស់រដ្ឋមួយ។ ជាមួយនឹងការស្ថាបនាជាតិ-រដ្ឋមួយ “សហគមន៍នយោបាយនីមួយៗបានស្ថាបនាអ្វីមួយដែលហៅថាអត្តសញ្ញាណរួម ជាអារម្មណ៍ដ៏ខ្លាំងក្លានៃការជាសមាជិក និង ទំនាក់ទំនងដ៏ស្អិតរមួតនៅក្នុងសង្គមនៅក្នុងព្រំដែនរបស់ជាតិ-រដ្ឋនោះ”។[356] ជនដែលគិតថាជាតិនិយមលែងសំខាន់ទៀតហើយ “យល់ស្របថាការយល់ដល់សញ្ជាតិដូចគ្នាមួយបានអនុញ្ញាតឲ្យមានការប្រមូល ផ្តុំប្រជាជនរបស់ខ្លួននៅក្នុងផ្នែកនយោបាយ ដោយប្រើប្រាស់ដើមកំណើត ប្រវត្តិសាស្ត្រ ឬ ភាសាដូចគ្នា”។[357] អាស្រ័យហេតុនេះ អធិបតេយ្យភាព រដ្ឋនៃដែនដី បានក្លាយជាក្របខណ្ឌដ៏ចាំបាច់សម្រាប់ភាពជាពលរដ្ឋ ហើយភាពជាពលរដ្ឋក៏បានក្លាយជាក្របខណ្ឌដ៏ចាំបាច់សម្រាប់អធិបតេយ្យភាពផងដែរ។ “គេគិតថា ភាពជាពលរដ្ឋទាំងផ្លូវច្បាប់ និងជាសកម្មភាពត្រូវបានសន្មតជាមុនអំពីវត្តមាននៃសហគមន៍នយោបាយដែល មានដែនដីមួយ ដែលលាតសន្ធឹងទៅតាមពេលវេលា និង ជាចំណុចផ្តោតនៃអត្តសញ្ញាណរួម” ។[358] ទោះបីជាគំនិតនេះ កំពុងតែមានការប្រកួតប្រជែងពីព្រោះ សកលភាវូបនីយកម្ម ដែលធ្វើឲ្យព្រំដែននានា ងាយទទួលរងឥទ្ធិពល ពីខាងក្រៅក៏ដោយ ក៏រដ្ឋមួយចំនួនធំនៅតែពឹងផ្អែកលើសំនួនជាផ្លូវការ របស់សមាជិកភាព និងសហគមន៍នយោបាយ ដែលបានធ្វើស្ថាប័នភាវូបនីយកម្មជាផ្លូវការ និង សន្មតថារដ្ឋមានទាំងសិទ្ធិតាមផ្លូវច្បាប់ និងតាមសីលធម៌នៅក្នុងការជ្រើសរើសសមាជិករបស់ខ្លួន និងបិទ ឬបើកព្រំដែនរបស់ខ្លួន និងថា “ឯកាធិភាពលើដែនដី ត្រូវបានអនុវត្តតាមរយៈ គោលនយោបាយអន្តោប្រវេសន៍ និង គោលនយោបាយភាពជាពលរដ្ឋ”។[359]

ច្បាប់របស់ AMS ទាំងអស់ ត្រូវបានលាតត្រដាងដោយរបាយការណ៍ប្រចាំប្រទេសនានាក្នុងការកំណត់អ្នកដែលមានសិទ្ធិ និងអាចទទួលបានសមាជិកភាពតាមរយៈភាពជាពលរដ្ឋ/សញ្ជាតិរបស់រដ្ឋមួយ។ ហាក់បីដូចជា “មានគោលដៅរួមក្នុងការបង្កើនការរួបរួមគ្នាក្នុងចំណោមរដ្ឋនានា ពាក់ព័ន្ធនឹងគោលនយោបាយស្តីពីការទទួលបានភាពជាពលរដ្ឋ។ គោលនយោបាយទាំងនោះ តាមធម្មតា ត្រូវបានបែងចែកជាពីរប្រភេទ ធំៗ៖ jus soli ផ្តល់ភាពជាពលរដ្ឋដោយផ្អែក លើកំណើតនៅលើដែនដីរបស់រដ្ឋមួយ និង jus sanguinis ផ្តល់ភាពជាពលរដ្ឋដោយផ្អែកលើដើមកំណើត...” [360]

356 J.Habermas ការរួមបញ្ចូលអ្នកដទៃ នៅក្នុងការសិក្សាអំពីទ្រឹស្តីនយោបាយ C.Cronin និង P.de Greif, (eds.), Cambridge (Mass.), សារព័ត៌មាន MIT ឆ្នាំ១៩៩៨ ទំព័រ ១៣២។

357 Ibid.

358 ភាពជាពលរដ្ឋ ត្រូវបានបោះពុម្ពផ្សាយលើកទីមួយនៅថ្ងៃសុក្រ ទី១៣ ខែតុលា ឆ្នាំ២០០៦។

359 Seyla Benhabib សិទ្ធិរបស់អ្នកដទៃ៖ ជនបរទេស និវាសនជន និង ពលរដ្ឋ សារព័ត៌មានរបស់សាកលវិទ្យាល័យខេមប្រ៊ីជ ឆ្នាំ២០០៤ ទំព័រទី ៥។

360 T. Alexander Aleinikoff និង Douglas Klusmeyer (អ្នកដឹកនាំរួម) គោលនយោបាយស្តីពីភាពជាពលរដ្ឋសម្រាប់យុគសម័យទេសន្តរប្រវេសន៍ MPI វ៉ាស៊ីនតោន ឌីស៊ី ឆ្នាំ២០០២ ទំព័រទី ២។

ដោយមានកំណើន នៃបាតុភូតទេសន្តរប្រវេសន៍ រដ្ឋ jus sanguinis បានប្រឈមមុខនឹងការមានជនបរទេសជាច្រើនជំនាន់ស្នាក់នៅក្នុងព្រំដែនរបស់ពួកគេ ដូចជា PIDs នៅក្នុងប្រទេសហ្វីលីពីន និង ក្រុមជាតិពន្ធុមួយចំនួននៅក្នុងប្រទេសថៃ។ ប្រទេសមួយចំនួន នៅក្នុងតំបន់បានអនុម័តគោលនយោបាយ ដែលផ្តល់ភាពជាពលរដ្ឋដល់កុមារដែលកើត នៅក្រុមជនអន្តោប្រវេសន៍មួយចំនួន ស្របពេលជាមួយគ្នានោះ រដ្ឋភាគច្រើនបានកែសម្រួលវិធាននានានៃ jus soli ដើម្បីដាក់កម្រិតលើសិទ្ធិទទួលបានភាពជាពលរដ្ឋពីកំណើត ដល់កុមារដែលកើតជាកូនរបស់ជនអន្តោប្រវេសន៍ ដែលបានតាំងទីលំនៅនៅទីនោះ (មិនមែន ជាបណ្តោះអាសន្ន ឬគ្មានឯកសារនោះទេ)”។[361] នេះគឺជាករណីដែលកើតមាននៅក្នុងប្រទេសកម្ពុជា ឡាវ និងវៀតណាម។ នៅគ្រប់ករណីទាំងអស់ ភាពជាពលរដ្ឋត្រូវបានបង្កើតឡើងដោយកំណើត។ ដោយមិនគិតអំពីទម្រង់នានានៃមូលហេតុ ដែលពួកគេអនុវត្តតាមទេនោះ រដ្ឋមួយចំនួន (ប្រទេសកម្ពុជា ឡាវ ហ្វីលីពីន សិង្ហបុរី[362] និងវៀតណាម) មានច្បាប់ និងគោលនយោបាយដែលពិចារណាអំពីការផ្តល់ភាពជាពលរដ្ឋដល់ជនគ្មានសញ្ជាតិ ដែលកើតនៅក្នុងប្រទេស។[363] ភាពជាពលរដ្ឋមិនធ្លាប់ចាត់ទុកនរណាម្នាក់ដែលកើតនៅខាងក្រៅប្រទេស ជាជនមិនមែនពលរដ្ឋនោះទេ ប៉ុន្តែវាអាចទទួលបាន តាមរយៈសញ្ជាតូបនីយកម្ម ឬ នីតិវិធីចុះបញ្ជី។ រាល់ AMS ទាំងអស់ មានច្បាប់ដែលចែងអំពីសញ្ជាតូបនីយកម្មដោយមានលក្ខខណ្ឌតម្រូវខុសៗគ្នា រួមបញ្ចូលទាំងរយៈពេលនៃការស្នាក់នៅផងដែរ។ ទោះបីជាយ៉ាងណាក៏ដោយច្បាប់ដូចគ្នានេះរបស់ប្រទេសនីមួយៗ ចែងអំពីការបាត់បង់សញ្ជាតិតាមរយៈការបោះបង់ចោល ឬការដកហូត។ ប៉ុន្តែមានប្រទេសតែពីរប៉ុណ្ណោះដែលទទួលយកការមានសញ្ជាតិពីរ គឺប្រទេសហ្វីលីពីន និងប្រទេសថៃ។

ផ្អែកតាមរបាយការណ៍ ប្រចាំប្រទេសនានាដែលទទួលបាន AMS ទាំងអស់ផ្តល់ភាពជាពលរដ្ឋដោយផ្អែកលើឪពុកម្តាយច្រើនជាង ទីកន្លែងកំណើត មានន័យថា មនុស្សម្នាក់នឹងទទួលបានភាពជាពលរដ្ឋដោយស្វ័យប្រវត្តិ ប្រសិនបើពួកគេមានឪពុកម្តាយម្នាក់ ឬទាំងពីរនាក់ ជាពលរដ្ឋរបស់ប្រទេសដែលពាក់ព័ន្ធ ទោះបីជាពួកគេកើតនៅកន្លែងណាក៏ដោយ នៅខណៈពេលដែលកូនរបស់ជនមិនមែនជាពលរដ្ឋដែលកើតនៅក្នុងប្រទេសសាមី មិនមែនជាពលរដ្ឋដោយស្វ័យប្រវត្តិនោះទេ និងអាចក្លាយជាពលរដ្ឋតាមរយៈ នីតិវិធីនៃការធ្វើសញ្ជាតូបនីយកម្មតែមួយគត់។ នេះមានន័យថា មនុស្សម្នាក់ដែលប្រហែលជាមិនអាចនិយាយភាសាជាតិបាន មិនធ្លាប់រស់នៅក្នុងប្រទេស និងអ្នកដែលមានទំនាក់ទំនងជាមួយរដ្ឋតាមរយៈឪពុកម្តាយ ឬជីដូនជីតាដែលប្រហែលជាបានចាកចេញពីប្រទេសជាយូរមកហើយ ទទួលបានភាពជាពលរដ្ឋតាមផ្លូវច្បាប់ បានល្អប្រសើរជាកុមាររបស់ជនអន្តោប្រវេសន៍/ជនភៀសខ្លួន ឬជនជាតិដើមភាគតិចដែលកើតនៅក្នុងប្រទេស។

ដោយសារតែគ្មានការចុះបញ្ជីកំណើត ការទទួលបានឋានៈតាមផ្លូវច្បាប់ដ៏សមស្របត្រូវបានបិទ។ កុមារដែលមិនបានចុះបញ្ជី ត្រូវបានកាត់ទោសឲ្យ “បាត់បង់សិទ្ធិជាពលរដ្ឋ”[364] ដោយសារតែភាពចៃដន្យប៉ុណ្ណោះ មិនមែនតាមជម្រើសនោះទេ ដែលបានដាក់ពួកគេ ឲ្យស្ថិតនៅក្នុងព្រំដែនផ្នែកនយោបាយ ដលែបដិសធេសិទ្ធិរបស់ពួកគនៅក្នុងការចុះបញ្ជីកំណើត (និងសញ្ជាតិ)។ ដូច្នេះព្រំដែនផ្នែកនយោបាយផ្តល់ជូនមនុស្សនូវភាពមើលមិនឃើញ តាមផ្លូវច្បាប់ និងដកហូតសិទ្ធិមូលដ្ឋានរបស់ពួកគេ។ ចំណុចនេះ អនុញ្ញាតឲ្យមានប្រភេទមនុស្សខុសៗគ្នានៅក្នុងសង្គម។ “នយោបាយនៃភាពខុសគ្នា”ក៏បានលេចឡើងនៅក្នុងរបាយការណ៍មួយចំនួនផងដែរ ដែលនៅក្នុងចំណោម ជនដែលមានសញ្ជាតិដូចគ្នា

361 Ibid.

362 តាមរដ្ឋធម្មនុញ្ញ

363 ការកែសម្រួលត្រូវបានធ្វើឡើងដោយជនបង្គោលនៃប្រទេសសិង្ហបុរី។

364 សំនួនដែលត្រូវបានប្រើប្រាស់ដោយ Seyla Benhabib។

ពលរដ្ឋទាំងឡាយត្រូវបានគេប្រព្រឹត្តិចំពោះខ្លួនខុសៗគ្នា។ នៅក្នុងប្រទេសមួយចំនួនតូច ម្តាយពុំមានសិទ្ធិប្រគល់សញ្ជាតិទៅឲ្យកូន របស់នាងដោយស្វ័យប្រវត្តិនោះទេ។ ចំណុចនេះ ដោយមិនអាចបដិសេធបាន គឺជាការរើសអើងយេនឌ័រដែលត្រូវតែលុបបំបាត់ ពីព្រោះ AMS ទាំង អស់បានផ្តល់សច្ចាប័នលើ CEDAW រួចរាល់ហើយ ហើយគោលការណ៍គ្មានភាពរើសអើងបានលេចឡើង នៅក្នុងរដ្ឋធម្មនុញ្ញនៃគ្រប់ប្រទេសទាំងអស់។

ការត្រួតពិនិត្យឡើងវិញ លើរបាយការណ៍ទាំងអស់ដែលបានទទួល បានបង្ហាញនិន្នាការជាវិជ្ជមានមួយ នៅក្នុងចំណោមរដ្ឋសមាជិកអាស៊ានចំពោះគោលនយោបាយ ដែលមានភាពបើកចំហរជាងមុន ចំពោះទាំងការចុះបញ្ជីកំណើត/ការចុះបញ្ជីអត្រានុកូលដ្ឋាន និងការផ្តល់សញ្ជាតិ។ មានការព្រមព្រៀងគ្នាជាឯកច្ឆន្ទមួយចំនួនតូច នៅក្នុងកិច្ចប្រជុំពិគ្រោះយោបល់ថ្នាក់តំបន់ ស្តីពីការលើកកម្ពស់បរិយាប័ន្ន និងការអភិវឌ្ឍប្រកបដោយចីរភាពនៅក្នុងការកសាងសហគមន៍អាស៊ាន តាមរយៈការធានាចំពោះការទទួលស្គាល់អត្តសញ្ញាណ តាមផ្លូវច្បាប់របស់ស្ត្រី និងកុមារគ្រប់រូបនៅអាស៊ាន ក្នុងចំណោមការព្រមព្រៀងទាំងនោះ មានការព្រមព្រៀងចំនួនពីរដែលពាក់ព័ន្ធនឹងការចុះបញ្ជីកំណើត របស់កុមារបាត់ខ្លួន និងការផ្តល់សញ្ជាតិដោយស្វ័យប្រវត្តិនៅក្នុងប្រទេសដែលពួកគេ ត្រូវបានគេរកឃើញ។ ការព្រមព្រៀងជាឯកច្ឆន្ទមួយទៀតពាក់ព័ន្ធនឹង ការធានាភាពស្មើភាពរវាងឪពុក និងម្តាយនៅក្នុងផ្ទេរសញ្ជាតិរបស់គាត់ទៅកាន់កូនៗ របស់គាត់ដោយស្វ័យប្រវត្តិ។ និន្នាការនេះ គឺជាស្របគ្នានឹងសេចក្តីសង្កេតសន្និដ្ឋានដែល AMS បានទទួលពីគណៈកម្មាធិការ CEDAW និង CRC។

ជាក់ស្តែង តាមរយៈការត្រួតពិនិត្យសេចក្តីសង្កេតសន្និដ្ឋានរបស់គណៈកម្មាធិការ CEDAW និង CRC ប្រទេសជាច្រើនបានទទួលអនុសាសន៍ប្រហាក់ប្រហែលគ្នា ពាក់ព័ន្ធនឹងការចុះបញ្ជីកំណើត និងសញ្ជាតិ។ ទោះបីជាសេចក្តីសង្កេតសន្និដ្ឋានសម្រាប់ធ្វើរបាយការណ៍ដែលដាក់ជូន CEDAW និង CRC ហាក់បីដូចជាគ្មានបច្ចុប្បន្នភាព[365] ក៏ដោយក៏កង្វល់ជាច្រើនដែលត្រូវបានលើកឡើង ដោយគណៈកម្មាធិការ CEDAW និង CRC នៅតែមានភាពពាក់ព័ន្ធដែរ។ កង្វល់មួយចំនួនក្នុងចំណោមកង្វល់ទាំងនេះ នៅតែត្រូវបានឆ្លុះបញ្ចាំងនៅក្នុងរបាយការណ៍របស់ប្រទេសមួយចំនួន។ មានធាតុដូចៗគ្នាមួយចំនួន ដែលតម្រូវឲ្យមានការយកចិត្តទុកដាក់ពីសំណាក់ AMS ទាំងអស់ រួមមាន៖

- ធានាចំពោះការចុះបញ្ជីកំណើត របស់កុមារគ្រប់រូបដោយមិនគិតអំពីឋានៈតាមផ្លូវច្បាប់នោះទេ។ គួរតែផ្តល់ការយកចិត្តទុកដាក់ជាពិសេស ចំពោះក្រុមជាតិពន្ធុមួយចំនួននៅក្នុងប្រទេស ជនភៀសខ្លួន អ្នកស្វែងរកសិទ្ធិជ្រកកោន និង ពលករចំណាកស្រុក និងជនគ្មានសញ្ជាតិ។ នេះតំណាងឲ្យក្រុមដែលពិបាកទទួលបានសេវានានានៅតាមតំបន់ជនបទ និងតំបន់ដាច់ស្រយាលដែលអាចតម្រូវឲ្យមានវិធីសាស្ត្រពិសេសៗ និងកិច្ចប្រឹងប្រែងនានា ជាពិសេសសម្រាប់អ្នកម្តាយដែលមិនអាចនិយាយភាសាបាន។ ទម្លាប់អនុវត្តល្អៗ ដូចជាការដាក់ឲ្យមានការចុះបញ្ជីចល័តដោយ AMS ភាគច្រើន ផ្តល់គំរូមួយសម្រាប់ការ អនុវត្តបន្ទៀត
- ពង្រឹងយុទ្ធនាការបង្កើនការយល់ដឹង ជាសាធារណៈ និង អនុវត្តវិធីសាស្ត្រយ៉ាងតឹងរ៉ឹងដើម្បីធានាថាស្ត្រី/ក្រុមជាតិពន្ធុក្រីក្រ និង នៅតាមទីជនបទ បានដឹងអំពីលក្ខខណ្ឌដែលពាក់ព័ន្ធនឹងការចុះបញ្ជីកំណើត និងសំបុត្រកំណើត និងអាចទទួលបានសំបុត្រកំណើតនិងសេវាចុះបញ្ជីបានយ៉ាងងាយស្រួល

365 ឧទាហរណ៍៖ របាយការណ៍ CRC របស់ប្រទេសប្រ៊ុយណេដារូសាឡឹមត្រូវបានដាក់ជូននៅក្នុងឆ្នាំ២០១៣ របាយការណ៍ CRC របស់ប្រទេសកម្ពុជាត្រូវបានត្រួតពិនិត្យឡើងវិញនៅក្នុងឆ្នាំ២០១១ របាយការណ៍ CEDAW របស់ប្រទេសឥណ្ឌូនេស៊ីត្រូវបានត្រួតពិនិត្យឡើងវិញនៅក្នុងឆ្នាំ២០១២ របាយការណ៍ CRC របស់ប្រទេសម៉ាឡេស៊ីត្រូវបានត្រួតពិនិត្យឡើងវិញនៅក្នុងឆ្នាំ២០០៧ របាយការណ៍ CRC របស់ប្រទេសមីយ៉ាន់ម៉ាត្រូវបានត្រួតពិនិត្យឡើងវិញនៅក្នុងឆ្នាំ២០១២ របាយការណ៍ CRC របស់ប្រទេសហ្វីលីពីនត្រូវបានត្រួតពិនិត្យឡើងវិញនៅក្នុងឆ្នាំ២០០៩ របាយការណ៍ CRC របស់ប្រទេសសិង្ហបុរីត្រូវបានត្រួតពិនិត្យឡើងវិញនៅក្នុងឆ្នាំ២០១១ របាយការណ៍ CRC របស់ប្រទេសថៃត្រូវបានត្រួតពិនិត្យឡើងវិញនៅក្នុងឆ្នាំ២០១២ របាយការណ៍ CRC របស់ប្រទេសវៀតណាមត្រូវបានត្រួតពិនិត្យឡើងវិញនៅក្នុងឆ្នាំ២០១២។

- លុបបំបាត់ការរើសអើងស្ត្រី ដែលបានរៀបអាពាហ៍ពិពាហ៍ជាមួយជនបរទេសក្នុងការប្រគល់សញ្ជាតិជូនកូនរបស់ពួកគេដោយស្វ័យប្រវត្តិ។ ចំណុចនេះត្រូវបានអះអាងម្តងទៀត នៅក្នុងសេចក្តីសង្កេតសន្និដ្ឋាន និង ត្រូវបានលើកឡើងនៅក្នុងរបាយការណ៍របស់ប្រទេសមួយចំនួនផងដែរ
- លុបចោលថ្លៃសេវា (និងការផាកពិន័យ) សម្រាប់ការចុះបញ្ជីកំណើតយឺតពេល និងថ្លៃសំបុត្រកំណើត ព្រមទាំងថ្លៃសេវាក្រៅផ្លូវការដទៃទៀត ដែលត្រូវបានមើលឃើញថាបានអនុវត្តនៅក្នុង AMS មួយចំនួន
- ផ្តល់អាទិភាព ដល់ការទទួលយកអនុសញ្ញា ឆ្នាំ ១៩៥៤ ដែលពាក់ព័ន្ធនឹងឋានៈរបស់ជនគ្មានសញ្ជាតិ និង អនុសញ្ញា ឆ្នាំ១៩៦១ ស្តីពីការកាត់ បន្ថយភាពគ្មានសញ្ជាតិ
- ធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញ និង/ឬ ច្បាប់ដែលពាក់ព័ន្ធនឹងការចុះបញ្ជីអត្រានុកូលដ្ឋាន និងសញ្ជាតិ ដើម្បីធ្វើឲ្យរដ្ឋធម្មនុញ្ញ និងច្បាប់ទាំងនោះមានលក្ខណៈបើកចំហរជាងមុន និងលុបចោលបញ្ញត្តិដែលមានការរើសអើងចំពោះស្ត្រី និងជនដែលមិនមែនជាពលរដ្ឋ។

## ៥.២ អនុសាសន៍

ផ្អែកតាមរបាយការណ៍ប្រចាំប្រទេស កិច្ចពិភាក្សានៅក្នុងកិច្ចប្រជុំពិគ្រោះយោបល់ថ្នាក់តំបន់ ស្តីពីការលើកកម្ពស់បរិយាប័ន្ន និង ការអភិវឌ្ឍប្រកបដោយចីរភាពនៅក្នុងការកសាងសហគមន៍អាស៊ាន តាមរយៈការធានាចំពោះការទទួលស្គាល់អត្តសញ្ញាណតាមផ្លូវច្បាប់របស់ស្ត្រី និង កុមារគ្រប់រូបនៅអាស៊ាន និងសេចក្តីសង្កេតសន្និដ្ឋានដែលត្រូវបានធ្វើឡើងដោយគណៈកម្មាធិការ CEDAW និង CRC អនុសាសន៍នានាដូចខាងក្រោមត្រូវបានបង្កើតឡើងដូចខាងក្រោម៖

### សម្រាប់រដ្ឋសមាជិកអាស៊ាន

១. ដោះស្រាយរាល់បញ្ហាប្រឈមទាំងអស់ដែលត្រូវបានសម្គាល់ឃើញនៅក្នុងរបាយការណ៍ប្រចាំប្រទេសដែលត្រូវបានដាក់ជូន

២. អនុវត្តឱ្យបានឆាប់រហ័សនូវសេចក្តីសង្កេតសន្និដ្ឋានដែលត្រូវបានធ្វើឡើងដោយគណៈកម្មាធិការ CEDAW និង CRC ដូចបានបង្ហាញនៅក្នុងឧបសម្ព័ន្ធទី២ (ចូរមើលទំព័រទី ១២៤)។ នេះក៏រួមបញ្ចូលការដកហូតការរក្សាសិទ្ធិដែលត្រូវបានធ្វើឡើងដោយ CRC, CEDAW និង CRPD ពាក់ព័ន្ធនឹងការចុះបញ្ជីកំណើត និងសញ្ជាតិ ព្រមទាំងការទទួលយក និង ការផ្តល់សច្ចាប័នដល់អនុសញ្ញាអង្គការសហប្រជាជាតិស្តីពីភាពគ្មានសញ្ជាតិផងដែរ

៣. ត្រួតពិនិត្យឡើងវិញឲ្យបានហ្មត់ចត់លើរបាយការណ៍ប្រចាំប្រទេសដែលត្រូវបានដាក់ជូន ព្រមទាំងសេចក្តីសង្កេតសន្និដ្ឋានដែលត្រូវបានធ្វើឡើងដោយគណៈកម្មាធិការ CEDAW និង CRC និងសម្គាល់ឃើញបញ្ហាដែលអាចដោះស្រាយភ្លាមៗបាន ព្រមទាំង បញ្ហាដែលអាចដោះស្រាយបានក្នុងរយៈពេលមធ្យម និងរយៈពេលវែងផងដែរ។ គួរតែមានការពិចារណាអំពីផែនការសកម្មភាពដ៏ច្បាស់លាស់មួយ និងយន្តការដែលត្រូវអនុវត្ត

៤. ប្រើប្រាស់ឧបករណ៍ប៉ាន់ប្រមាណអំពីការចុះបញ្ជីអត្រានុកូលដ្ឋានក្រោមដំណើរការបាលី ដែលត្រូវបានរៀបចំដោយការិយាល័យគាំទ្រនៅក្នុងតំបន់សម្រាប់ដំណើរការបាលី (RSO)។[366] ឧបករណ៍នេះនឹងជួយសម្រួលដល់ការបង្កើតផែនការ និងគោលនយោបាយដើម្បីអនុវត្តការចុះបញ្ជីអត្រានុកូលដ្ឋាន រួមបញ្ចូលទាំងការចុះបញ្ជីកំណើតសម្រាប់ក្រុមដែលពិបាកទទួលសេវានៅក្នុងប្រទេសផងដែរ

366 ឧបករណ៍ប៉ាន់ប្រមាណអំពីការចុះបញ្ជីអត្រានុកូលដ្ឋានក្រោមដំណើរការបាលី https://www.baliprocess.net/UserFiles/baliprocess/File/Bali%20Process%20Civil%20Registration%20Assessment%20Toolkit%20FINAL.pdf

៥. ខិតខំប្រឹងប្រែងបំពេញតាមគោលដៅនានាដែលត្រូវបានកំណត់ដោយ ESCAP ស្តីពី CRVS ត្រឹមឆ្នាំ២០០៤ និងដោយ SDGs ស្តីពីការចុះបញ្ជីកំណើត និងការដោះស្រាយបញ្ហានានានៃភាពគ្មានសញ្ជាតិ ដើម្បីការមិនទុកនរណាម្នាក់ចោល

៦. មិនត្រឹមតែចូលរួមជាមួយគ្នាទៅវិញទៅមកនោះទេ ប៉ុន្តែថែមទាំងចូលរួមជាមួយភាគីពាក់ព័ន្ធដទៃទៀតនៅក្នុងការដោះស្រាយបញ្ហានានានៃការចុះបញ្ជីអត្រានុកូលដ្ឋាន និងភាពគ្មានរដ្ឋផងដែរ។ មេរៀននានាអាចទទួលបានពីប្រទេសហ្វីលីពីន ប្រទេសថៃ និងប្រទេសវៀតណាម។

## សម្រាប់ ACWC

១. ស្វែងរកមតិគាំទ្រលើបញ្ហាយ៉ាងតិចពីរ ដែលបានទទួលការព្រមព្រៀងជាឯកច្ឆន្ទ រួមមាន ធ្វើឲ្យការចុះបញ្ជីកំណើតមានលក្ខណៈជាសកល តាមរយៈការចុះបញ្ជីកំណើតរបស់កុមារបាត់ខ្លួនដោយស្វ័យប្រវត្តិ និងការផ្តល់សញ្ជាតិដោយស្វ័យប្រវត្តិ នៅក្នុងប្រទេសដែលពួកគេត្រូវបានគេរកឃើញ និងធានាភាពស្មើភាពរវាងឪពុក និងម្តាយនៅក្នុងផ្ទេរសញ្ជាតិរបស់គាត់ទៅកាន់កូនៗរបស់គាត់ដោយស្វ័យប្រវត្តិ

២. រួមគ្នាកំណត់ចន្លោះប្រហោង និងទម្លាប់អនុវត្តល្អៗដូចគ្នា ដែលបានរៀបរាប់នៅក្នុងការសំយោគថ្នាក់តំបន់ ដែលអាចចែករំលែកបាន ដើម្បីគាំទ្រដល់គ្នាទៅវិញទៅមកនៅក្នុងកិច្ចខិតខំប្រឹងប្រែងបំពេញចន្លោះប្រហោងទាំងនោះ

៣. លើកកម្ពស់ការចែករំលែកទម្លាប់អនុវត្តល្អៗ។ ប្រទេសមួយចំនួន ដូចជា ប្រទេសហ្វីលីពីន និងប្រទេសសិង្ហបុរីអាចចែករំលែកជាមួយ AMS ដទៃទៀត អំពីវិស័យដែលពួកគេទទួលបានជោគជ័យ។ ប្រទេសហ្វីលីពីនបានផ្តួចផ្តើមគំនិតអនុវត្តគម្រោង និងកម្មវិធីមួយចំនួនដើម្បីចូលទៅក្បែរក្រុមដែលពិបាកឈោងចាប់ នៅខណៈពេលដែលប្រទេសសិង្ហបុរីបានធ្វើឲ្យការចុះបញ្ជីកំណើតមានលក្ខណៈជាសកល តាមរយៈប្រព័ន្ធចុះបញ្ជីដែលបានធ្វើឌីជីថលនីយកម្ម។

៤. ធ្វើការសិក្សាបន្ថែមពាក់ព័ន្ធប្រជាជនដែលកំពុងផ្លាស់ទី។ ដោយសារតែអាស៊ានកំពុងតែប្រឈមមុខនឹងកំណើននៃការធ្វើអន្តោប្រវេសន៍ រួមបញ្ចូលទាំងនៅក្នុងចំណោមកុមារ និងស្ត្រីផងដែរនោះ បញ្ហាដែលត្រូវសិក្សាបន្ថែមមានជាប់ពាក់ព័ន្ធនឹងជនអន្តោប្រវេសន៍ ដូចជា បញ្ហាដែលពាក់ព័ន្ធនឹងកុមារមិនបានចុះបញ្ជី (គ្មានបញ្ជីកំណើត) កុមារដែលកំពុងបម្រើការងារ PWDs LGBTI ការរត់ពន្ធមនុស្ស និងការជួញដូរមនុស្សជាដើម។ របាយការណ៍របស់ប្រទេសហ្វីលីពីនបានផ្តល់អនុសាសន៍ឲ្យធ្វើការស្រាវជ្រាវបន្ថែមទៀត និងនៅក្នុងទ្រង់ទ្រាយកាន់តែធំ។ ប្រាកដណាស់ គំហើញដែលទាក់ទងនឹងបញ្ហាទាំងនេះ នៅក្នុងបរិបទនៃការធ្វើអន្តោប្រវេសន៍អាចរកឃើញបញ្ហានៃការការពារជាច្រើនទៀត ដែលគួរតែត្រូវបានយកមកពិចារណានៅក្នុងការដោះស្រាយបញ្ហានានាដែលទាក់ទងនឹងជនដែលប្រឈមនឹងហានិភ័យនៃភាពគ្មានសញ្ជាតិ[367]

៥. ពិចារណាលើកទឹកចិត្តអាស៊ានឲ្យបង្កើតយុទ្ធសាស្ត្រថ្នាក់តំបន់ ឬ ផែនការការងារស្តីពី CRVS

៦. លើកកម្ពស់ការបង្កើនការយល់ដឹង និងការកសាងសមត្ថភាពនៅក្នុងតំបន់ ដែលមានសារសំខាន់យ៉ាងខ្លាំង។ សិក្ខាសាលា/ការបណ្តុះបណ្តាលអំពីបញ្ហានានា ដូចជា ការចុះបញ្ជីកំណើត ភាពគ្មានសញ្ជាតិ ការទទួលបានសញ្ជាតិ និងផលប៉ះពាល់នៃកង្វះខាតការចុះបញ្ជីកំណើត និងសញ្ជាតិ អាចត្រូវបានផ្តួចផ្តើមគំនិតអនុវត្តរួមគ្នាដោយ ACWC។

៧. ការធ្វើសម្ភោធការសំយោគនេះនៅក្នុងតំបន់ បន្ទាប់ពីការសំយោគនេះត្រូវបានបញ្ចប់រួចរាល់ហើយ និងត្រូវបានអនុម័តដោយអ្នកតំណាងរបស់ ACWC ទាំងអស់ ដែលមិនត្រឹមតែដើម្បីបង្កើតការយល់ដឹងរបស់ទីភ្នាក់ងារដែលពាក់ព័ន្ធតែប៉ុណ្ណោះទេ ប៉ុន្តែ ថែមទាំងដើម្បីសម្គាល់ដៃគូយុទ្ធសាស្ត្រនៅក្នុងការដោះស្រាយបញ្ហានានាជុំវិញ CRVS ផងដែរ។

367 របាយការណ៍របស់ប្រទេសហ្វីលីពីន។

## សម្រាប់ UNHCR

១. បន្តផ្តល់ការគាំទ្រដល់ AMS នីមួយៗ ជាពិសេសនៅក្នុងទម្រង់នៃការផ្តល់ភាពជំនាញនៃកិច្ចសហការផ្នែកបច្ចេកទេស និងជំនួយផ្នែកហិរញ្ញវត្ថុ

២. ប្រើកម្មវិធីប្រចាំប្រទេសរបស់ UNHCR ឲ្យបានពេញលេញ ដើម្បីចូលរួមជាមួយ AMS នីមួយៗ ដូចត្រូវបានលើកឧទាហរណ៍នៅក្នុងករណីរបស់ប្រទេសហ្វីលីពីន

៣. សម្គាល់ឃើញជើងឯកនៅក្នុងចំណោម AMS ដើម្បីអនុវត្តគោលដៅនៃរួមបញ្ចូលអ្នករាល់គ្នានៅក្នុងរូបភាព និងការបញ្ចប់ភាពគ្មានសញ្ជាតិនៅក្នុងតំបន់។ ជើងឯកអាចពាក់ព័ន្ធនឹងបញ្ហាខុសៗគ្នា ដូចជា ការចុះបញ្ជីកំណើត ភាពគ្មានសញ្ជាតិ និងការលុបបំបាត់ការរើសអើងយេនឌ័រ

៤. ប្រើប្រាស់លទ្ធផលនៃការស្រាវជ្រាវសម្រាប់គោលនយោបាយ ការអភិវឌ្ឍសម្ភារ ការស្វែងរកមតិគាំទ្រ និងការបង្កើតថ្មីដទៃទៀតសម្រាប់ UNHCR។

៥. ចងក្រងទម្លាប់អនុវត្តល្អ និងសាច់រឿងនៃភាពជោគជ័យ នៅក្នុងទម្រង់ជាកូនសៀវភៅតូច ដោយសហការជាមួយ ACWC។

ការសំយោគនេះបញ្ចប់ដោយការអះអាងម្តងទៀតថា មនុស្សម្នាក់អាចជ្រើសរើសទស្សនៈផ្នែកនយោបាយរបស់គាត់បាន ប៉ុន្តែទោះបីជាតាមវិធីណាមួយក៏ដោយ គាត់មិនអាចជ្រើសរើសវប្បធម៌នៃកន្លែងដែលគាត់ស្ថិតនៅ ឬដែលគាត់ត្រូវបានគេចិញ្ចឹមនោះទេ ហើយប្រាកដណាស់គាត់មិនអាចជ្រើសរើសតំណពូជនៃគ្រួសាររបស់គាត់បានទេ។ មនុស្សជាច្រើន ជាពិសេសស្ត្រី និងកុមារ ត្រូវបានដកហូតឯកសារច្បាប់ដែលមិនមែនបណ្តាលមកពីកំហុសរបស់គាត់ផ្ទាល់នោះទេ។ ប្រសិនបើ AMS មានបំណងតំណាងឲ្យពួកគេ ក្នុងនាមជាសង្គមដែលមានការយកចិត្តទុកដាក់នោះ AMS នីមួយៗត្រូវខិតខំប្រឹងប្រែងឲ្យអស់ពីលទ្ធភាពដើម្បីរួមបញ្ចូលទទួលយកសមាជិកភាព និងផ្តល់គុណប្រយោជន៍របស់សមាជិកភាពដល់ជនទាំងនោះ ដែលសាវតានៃជាតិពន្ធុ និងវប្បធម៌របស់ពួកគេអាចខុសពីជាតិពន្ធុ និងវប្បធម៌របស់ពលរដ្ឋបច្ចុប្បន្ន។ ការចុះបញ្ជីកំណើត និងសញ្ជាតិគឺជាចំណុចសំខាន់សម្រាប់ AMS នីមួយៗនិងអាស៊ានទាំងមូល ដើម្បីក្លាយជាសង្គមដែលមានបរិយាប័ន្ន មានការយកចិត្តទុកដាក់ និងមានការចែករំលែក ដូចដែលបានបំផុសគំនិតដោយចក្ខុវិស័យរបស់អាស៊ានឆ្នាំ២០២៥។



# ៦. ឧបសម្ព័ន្ធ

## ឧបសម្ព័ន្ធទី១៖ ក្របខណ្ឌច្បាប់ដែលពាក់ព័ន្ធ នៅក្នុងរដ្ឋសមាជិកអាស៊ាន

**តារាងទី១៖ រដ្ឋសមាជិកអាស៊ាន និងការផ្តល់សច្ចាប័នរបស់ពួកគេលើសន្ធិសញ្ញាសិទ្ធិមនុស្ស (រួមបញ្ចូលទាំង អនុសញ្ញាស្តីពីជនភៀសខ្លួន និងភាពគ្មានសញ្ជាតិផងដែរ)**

| អនុសញ្ញា / ប្រទេស | សន្ធិសញ្ញាសិទ្ធិមនុស្ស | | | | | | | | | អនុសញ្ញាជនភៀសខ្លួន | | អនុសញ្ញាភាពគ្មានសញ្ជាតិ | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | CCPR | CESCR | CERD | CEDAW | CAT | CRC | CM W | CRPD | CED | ១៩៥១ | ១៩៦៧ | ១៩៥៤ | ១៩៦១ |
| ប្រ៊ុយណេ | X | X | X | ២០០៦[368] | X[369] | ១៩៩៥[370] | X | ២០១៦[371] | X | X | X | X | X |
| កម្ពុជា | ១៩៩២ | ១៩៩២ | ១៩៨៣ | ១៩៩២ | ១៩៩២ | ១៩៩២ | X | ២០១២ | ២០១៣ | ១៩៩២ | ១៩៩២ | X | X |
| ឥណ្ឌូនេស៊ី | ២០០៦[372] | ២០០៦[373] | ១៩៩៩[374] | ១៩៨៤[375] | ១៩៩៨[376] | ១៩៩០ | ២០១២ | ២០១១[377] | X | X | X | X | X |

368 ប្រទេសប្រ៊ុយណេដារូសាឡឹមបានចុះ ខ រក្សាសិទ្ធិចំពោះ CEDAW មាត្រា ៩ កថាខណ្ឌទី២ (សិទ្ធិស្មើភាពនៅក្នុងផ្ទេរសញ្ជាតិរបស់ពួកគេទៅកាន់កូនៗរបស់ពួកគេ) និង មាត្រា ២៩ កថាខណ្ឌទី១ (ការដោះស្រាយវិវាទដោយតុលាការយុត្តិធម៌អន្តរជាតិ)។

369 ប្រទេសប្រ៊ុយណេដារូសាឡឹមបានចុះហត្ថលេខាលើ CAT នៅឆ្នាំ២០១៥។

370 ប្រទេសប្រ៊ុយណេដារូសាឡឹមបានចុះ ខ រក្សាសិទ្ធិចំពោះ CRC មាត្រា ១៤ (សិទ្ធិទទួលបានសេរីភាពក្នុងការគិត សិទ្ធិមានមនសិការ និង សាសនា) មាត្រា ២០ កថាខណ្ឌទី ៣ (ការយកចិត្តទុកដាក់ជាពិសេសចំពោះកុមារដែលបានបាត់បង់មជ្ឈដ្ឋានគ្រួសារ) និងមាត្រា ២១ (ខ) (គ) (ឃ) និង (ង) បញ្ញត្តិដែលទាក់ទងនឹងសុំកូនអន្តរប្រទេស)។

371 ប្រទេសប្រ៊ុយណេដារូសាឡឹមបានចុះ ខ រក្សាសិទ្ធិចំពោះ CRPD “ពាក់ព័ន្ធនឹងបញ្ញត្តិនានានៃអនុសញ្ញាដែលបានពោល ដែលប្រហែលជាអាចផ្ទុយនឹងរដ្ឋធម្មនុញ្ញរបស់ប្រទេសប្រ៊ុយណេដារូសាឡឹម និងជំនឿ និងគោលការណ៍របស់សាសនាអ៊ីស្លាមដែលជាសាសនារបស់ប្រទេសប្រ៊ុយណេដារូសាឡឹម”។

372 ប្រទេសឥណ្ឌូនេស៊ីបានបង្កើតសេចក្តីប្រកាសមួយ ស្របតាម CCPR មាត្រា ១ (សិទ្ធិក្នុងការកំណត់ដោយខ្លួនឯង)។

373 ប្រទេសឥណ្ឌូនេស៊ីបានបង្កើតសេចក្តីប្រកាសមួយ ស្របតាម CESCR មាត្រា ១ (សិទ្ធិក្នុងការកំណត់ដោយខ្លួនឯង)។

374 ប្រទេសឥណ្ឌូនេស៊ីបានចុះ ខ រក្សាសិទ្ធិចំពោះ CERD មាត្រា ២២ (ការដោះស្រាយវិវាទដោយតុលាការយុត្តិធម៌អន្តរជាតិ)។

375 ប្រទេសឥណ្ឌូនេស៊ីបានចុះ ខ រក្សាសិទ្ធិចំពោះ CEDAW មាត្រា ២៩ កថាខណ្ឌទី ១ (ការដោះស្រាយវិវាទដោយតុលាការយុត្តិធម៌អន្តរជាតិ)។

376 ប្រទេសឥណ្ឌូនេស៊ីបានចុះ ខ រក្សាសិទ្ធិចំពោះ CAT មាត្រា ៣០ កថាខណ្ឌទី ១ (ការដោះស្រាយវិវាទដោយតុលាការយុត្តិធម៌អន្តរជាតិ)។ ប្រទេសនេះក៏បានបង្កើតសេចក្តីប្រកាសមួយដែរ “ថាបញ្ញត្តិនៃកថាខណ្ឌ ទី ១ និង ទី ២ និង ទី ៣ នៃមាត្រា ២០ នៃអនុសញ្ញានេះ នឹងត្រូវអនុវត្តដោយអនុលោមតាមគោលការណ៍នៃអធិបតេយ្យភាព និងបូរណភាពទឹកដីរបស់រដ្ឋយ៉ាងម៉ឺងម៉ាត់បំផុត”។

377 ប្រទេសឥណ្ឌូនេស៊ីបានចុះ ខ រក្សាសិទ្ធិចំពោះ CRPD មាត្រា ១ មាត្រា ៦ (១ និង ២) មាត្រា ៧ មាត្រា ៩ មាត្រា ១០ មាត្រា ២៤ និង មាត្រា ២៥។

| អនុសញ្ញា / ប្រទេស | សន្ធិសញ្ញាសិទ្ធិមនុស្ស | | | | | | | | | អនុសញ្ញាជនភៀសខ្លួន | | អនុសញ្ញាភាពគ្មានសញ្ជាតិ | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | CCPR | CESCR | CERD | CEDAW | CAT | CRC | CM W | CRPD | CED | ១៩៥១ | ១៩៦៧ | ១៩៥៤ | ១៩៦១ |
| **ឡាវ** | ២០០៩[378] | ២០០៧ | ១៩៧៤ | ១៩៨១ | ២០១២[379] | ១៩៩១ | X | ២០០៩ | X | X | X | X | X |
| **ម៉ាឡេស៊ី** | X | X | X | ១៩៩៥[380] | X | ១៩៩៥[381] | X | ២០១០[382] | X | X | X | X | X |
| **មីយ៉ាន់ម៉ា** | X | X | X | ១៩៩៧[383] | X | ១៩៩១ | X | ២០១១ | X | X | X | X | X |
| **ហ្វីលីពីន** | ១៩៨៦ | ១៩៧៤ | ១៩៦៧ | ១៩៨១ | ១៩៨៦ | ១៩៩០ | ១៩៩៥ | ២០០៨ | X | ១៩៨១ | ១៩៨១ | ២០១១ | X |

378 ប្រទេសឡាវ បានចុះ ខ រក្សាសិទ្ធិចំពោះ CCPR មាត្រា ២២ ( សិទ្ធិមានសេរីភាពខាងសមាគម ) និងបានបង្កើតសេចក្តីប្រកាសមួយ ស្របតាម មាត្រា ១ ( សិទ្ធិក្នុងការកំណត់ដោយខ្លួនឯង ) និងមាត្រា ១៨ ( សិទ្ធិទទួលបានសេរីភាពក្នុងការគិត សិទ្ធិមានមនសិការ និងសាសនា ) ។

379 ប្រទេសឡាវ បានចុះ ខ រក្សាសិទ្ធិចំពោះ CAT មាត្រា ២០ ( កិច្ចសហការជាមួយគណៈកម្មាធិការនៅក្នុងការត្រួតពិនិត្យព័ត៌មាន ) និងមាត្រា ៣០ កថាខណ្ឌទី ១ ( ការដោះស្រាយវិវាទដោយតុលាការយុត្តិធម៌ អន្តរជាតិ )។ លើសពីនេះទៀត ប្រទេសនេះបានបង្កើតសេចក្តីប្រកាសមួយ ស្របតាម មាត្រា ១ កថាខណ្ឌទី ១ ( និយមន័យរបស់ទារុណកម្ម ) និងមាត្រា ៨ កថាខណ្ឌទី ២ ( មូលដ្ឋានច្បាប់សម្រាប់ការធ្វើបត្យាប័ន )។

380 ប្រទេសម៉ាឡេស៊ី បានចុះ ខ រក្សាសិទ្ធិចំពោះ CEDAW មាត្រា ៩ កថាខណ្ឌទី ២ ( សិទ្ធិស្មើភាពនៅក្នុងផ្ទេរសញ្ជាតិរបស់ពួកគេទៅកាន់កូនៗរបស់ពួកគេ ) មាត្រា ១៦( ១ )( ក ) ( សិទ្ធិស្មើភាពគ្នាក្នុងការរៀបអាពាហ៍ពិពាហ៍ ) មាត្រា ១៦( ១ )( គ ) ( សិទ្ធិ និងទំនួលខុសត្រូវដូចគ្នានៅពេលមានចំណងអាពាហ៍ពិពាហ៍ និងនៅពេលរំលាយអាពាហ៍ពិពាហ៍ ) មាត្រា ១៦( ១ )( ច ) ( សិទ្ធិនិងទំនួលខុសត្រូវដូចគ្នា ចំពោះអាណាព្យាបាលភាព ការការពារ ការគ្រប់គ្រង និងសុំកូន ) មាត្រា ១៦( ១ )( ឆ ) ( សិទ្ធិស្មើភាពគ្នាក្នុងនាមជាស្វាមី និងភរិយា រួមបញ្ចូលទាំងសិទ្ធិជ្រើសរើសនាមត្រកូល វិជ្ជាជីវៈ និងមុខរបរផងដែរ )។ មានសេចក្តីប្រកាសមួយត្រូវបានធ្វើឡើងថា "ការទទួលយករបស់ប្រទេសម៉ាឡេស៊ី គឺអាស្រ័យលើការយល់ដឹងថា បញ្ញត្តិនានានៃអនុសញ្ញានេះពុំមានទំនាស់នឹងបញ្ញត្តិនានានៃច្បាប់របស់ Islamic Shari និងរដ្ឋធម្មនុញ្ញរបស់សហព័ន្ធនៃប្រទេសម៉ាឡេស៊ីនោះទេ"។

381 ប្រទេសម៉ាឡេស៊ី បានចុះ ខ រក្សាសិទ្ធិចំពោះ CRC មាត្រា ២ ( គោលការណ៍ទូទៅស្តីពីការរើសអើង ) មាត្រា ៧ ( សិទ្ធិទទួលបានការចុះបញ្ជីកំណើត សិទ្ធិទទួលបានឈ្មោះមួយ សិទ្ធិទទួលបានសញ្ជាតិមួយ និងសិទ្ធិស្គាល់ និងទទួលបានការថែទាំពីឪពុកម្តាយរបស់ពួកគេ ) មាត្រា ១៤ ( សិទ្ធិទទួលបានសេរីភាពក្នុងការគិត សេរីភាពខាងសតិសម្បជញ្ញៈ និងសេរីភាពខាងសាសនា ) មាត្រា ២៨( ១ )( ក ) ( សិទ្ធិទទួលបានការអប់រំដោយឥតបង់ថ្លៃ និងការអប់រំកម្រិតបឋមដែលមានលក្ខណៈជាកាតព្វកិច្ច ) និងមាត្រា ៣៧ ( ការការពារប្រឆាំងនឹងទារុណកម្ម ការប្រព្រឹត្តិទៅលើខ្លួន ឬ ការផ្តន្ទាទោសយ៉ាងឃោរឃៅ អមនុស្សធម៌ ឬ បន្ទាបបន្ថោកផ្សេងៗទៀត )។

382 ប្រទេសម៉ាឡេស៊ី បានចុះ ខ រក្សាសិទ្ធិចំពោះ CRPD មាត្រា ១៥ ( សេរីភាពចាកផុតពីការធ្វើទារុណកម្ម ឬ ការប្រព្រឹត្តិ ឬ ទណ្ឌកម្មឯទៀត ដែលឃោរឃៅ អមនុស្សធម៌ ឬ បន្ទាបបន្ថោក ) និងមាត្រា ១៨ ( សេរីភាពនៃការធ្វើដំណើរ និងការទទួលបានសញ្ជាតិ )។

383 ប្រទេសម៉ាឡេស៊ីបានចុះ ខ រក្សាសិទ្ធិចំពោះ CEDAW មាត្រា ២៩ ( ការដោះស្រាយវិវាទដោយតុលាការយុត្តិធម៌អន្តរជាតិ )។

| អនុសញ្ញា / ប្រទេស | សន្ធិសញ្ញាសិទ្ធិមនុស្ស | | | | | | | | | អនុសញ្ញាជនភៀសខ្លួន | | អនុសញ្ញាភាពគ្មានសញ្ជាតិ | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | CCPR | CESCR | CERD | CEDAW | CAT | CRC | CM W | CRPD | CED | ១៩៥១ | ១៩៦៧ | ១៩៥៤ | ១៩៦១ |
| សិង្ហបុរី | X | X | ២០១៧[384] | ១៩៩៥[385] | X | ១៩៩៥[386] | X | ២០១៣[387] | X | X | X | X | X |

384 ប្រទេសសិង្ហបុរី បានចុះ ខ រក្សាសិទ្ធិលើការអនុវត្តគោលនយោបាយរបស់ខ្លួនដែលពាក់ព័ន្ធនឹងការអនុញ្ញាតឲ្យចូល និងបទប្បញ្ញត្តិរបស់អ្នកកាន់ប័ណ្ណការងាររបស់ជនបរទេស និងបានធ្វើសេចក្តីប្រកាសស្របតាម CERD មាត្រា ២ (ការហាមឃាត់ការរើសអើងពូជសាសន៍តាមគ្រប់មធ្យោបាយដែលសមស្របទាំងអស់) មាត្រា ៦ (ការការពារ និងដំណោះស្រាយប្រកបដោយប្រសិទ្ធភាព និងសិទ្ធិស្វែងរកយុត្តិធម៌ និងការផ្តល់សំណងយ៉ាងគ្រប់គ្រាន់ ឬ សេចក្តីពេញចិត្ត) និង(ការដោះស្រាយវិវាទដោយតុលាការយុត្តិធម៌អន្តរជាតិ)។

385 ប្រទេសសិង្ហបុរី បានចុះ ខ រក្សាសិទ្ធិចំពោះ CEDAW មាត្រា ២(ក)-(ច) (គោលការណ៍ទូទៅស្តីពីការរើសអើងប្រឆាំងនឹងស្ត្រីភេទ) មាត្រា ១១(២) (ការរើសអើងនៅក្នុងវិស័យការងារ) មាត្រា ១៦(១)(ក) (សិទ្ធិដូចគ្នាក្នុងការរៀបអាពាហ៍ពិពាហ៍) មាត្រា ១៦(១)(គ) (សិទ្ធិ និងទំនួលខុសត្រូវដូចគ្នានៅពេលមានចំណងអាពាហ៍ពិពាហ៍ និងនៅពេលរំលាយអាពាហ៍ពិពាហ៍) មាត្រា ១៦(១)(ជ) (សិទ្ធិដូចគ្នាសម្រាប់ទាំងស្វាមី និងភរិយា ចំពោះទ្រព្យសម្បត្តិ) មាត្រា ១៦ កថាខណ្ឌទី ២ (ការរៀបអាពាហ៍ពិពាហ៍កូន) និងមាត្រា ២៩ កថាខណ្ឌទី ១ (ការដោះស្រាយវិវាទដោយតុលាការយុត្តិធម៌អន្តរជាតិ)។

386 ប្រទេសសិង្ហបុរី បានធ្វើសេចក្តីថ្លែងការណ៍ជាទូទៅមួយថា "រដ្ឋធម្មនុញ្ញ និងច្បាប់នានារបស់សាធារណរដ្ឋសិង្ហបុរី ផ្តល់កិច្ចការពារយ៉ាងគ្រប់គ្រាន់ និងសិទ្ធិ និងសេរីភាពមូលដ្ឋាន ដើម្បីឧត្តមប្រយោជន៍របស់កុមារ។ ការទទួលយកអនុសញ្ញានេះ ដោយសាធារណរដ្ឋសិង្ហបុរី មិនបានបញ្ជាក់ដោយតុល្យភាពអំពីការទទួលយកកាតព្វកិច្ចនានា លើសពីដែនកំណត់ ដែលត្រូវបានបញ្ញត្តិដោយរដ្ឋធម្មនុញ្ញរបស់សាធារណរដ្ឋសិង្ហបុរីនោះទេ និងមិនទទួលយកកាតព្វកិច្ចណាមួយនៅក្នុងការណែនាំអំពីសិទ្ធិណាមួយដែលលើសពីសិទ្ធិដែលត្រូវបានបញ្ញត្តិនៅក្រោមរដ្ឋធម្មនុញ្ញនោះទេ"។ ប្រទេសសិង្ហបុរីរក្សាសិទ្ធិក្នុងការអនុវត្តច្បាប់ និងលក្ខខណ្ឌដែលពាក់ព័ន្ធនឹងការចុះ ការបន្តមាន និងការទទួលបាន និងការមានកម្មសិទ្ធិលើភាពជាពលរដ្ឋរបស់ជនដែលគ្មាន ឬ លែងមានសិទ្ធិ ស្របតាមច្បាប់របស់សាធារណរដ្ឋសិង្ហបុរី។ ជាពិសេស ប្រទេសសិង្ហបុរីបានចុះ ខ រក្សាសិទ្ធិចំពោះ មាត្រា ២៨(១)(ក) (សិទ្ធិទទួលបានការអប់រំដោយឥតបង់ថ្លៃ និងការអប់រំកម្រិតបឋមដែលមានលក្ខណៈជាកាតព្វកិច្ច) និងមាត្រា ៣២ (សិទ្ធិទទួលបានការការពារពីការកេងប្រវ័ញ្ចផ្នែកសេដ្ឋកិច្ច និងការធ្វើការងារប្រកបដោយគ្រោះថ្នាក់ណាមួយ)។ បន្ថែមពីលើ ខ រក្សាសិទ្ធិទាំងនេះទៀត ប្រទេសសិង្ហបុរីបានធ្វើសេចក្តីប្រកាសចំពោះសិទ្ធិដែលបានកំណត់នៅក្នុងមាត្រា ១២ ដល់ ១៧ (សិទ្ធិត្រូវបានគេស្តាប់នៅក្នុងនីតិវិធីតុលាការ និងរដ្ឋបាល សិទ្ធិសម្តែងមតិដោយសេរី សិទ្ធិក្នុងការមានសេរីភាពគិតគូរ សិទ្ធិមានសេរីភាពខាងសមាគម សិទ្ធិទទួលបានឯកជនភាព និងទទួលបានព័ត៌មាន) មាត្រា ១៩ (ការការពារប្រឆាំងនឹងគ្រប់ទម្រង់ទាំងអស់នៃអំពើហិង្សា) និងមាត្រា ៣៧ (ការហាមឃាត់ការធ្វើទារុណកម្ម)។

387 ប្រទេសសិង្ហបុរី បានចុះ ខ រក្សាសិទ្ធិចំពោះ CRPD មាត្រា ១២ កថាខណ្ឌទី ៤ (ការការពារដើម្បីទប់ស្កាត់ការបំពាន នៅខណៈពេលអនុវត្តសមត្ថកិច្ចតាមផ្លូវច្បាប់) មាត្រា ២៥(ង) (ការរើសអើសនៅក្នុងការផ្តល់ធានារ៉ាប់រងសុខភាព និងធានារ៉ាប់រងជីវិត) និងមាត្រា ២៩(ក)(iii) (ធានាចំពោះការសម្តែងឆន្ទៈដោយសេរីរបស់ជនពិការ នៅក្នុងនាមជាអ្នកបោះឆ្នោត)។

| អនុសញ្ញា | សន្ធិសញ្ញាសិទ្ធិមនុស្ស | | | | | | | | | អនុសញ្ញាជនភៀសខ្លួន | | អនុសញ្ញាភាពគ្មានសញ្ជាតិ | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ប្រទេស | CCPR | CESCR | CERD | CEDAW | CAT | CRC | CM W | CRPD | CED | ១៩៥១ | ១៩៦៧ | ១៩៥៤ | ១៩៦១ |
| ថៃ | ១៩៩៦[388] | ១៩៩៩[389] | ២០០៣[390] | ១៩៨៥[391] | ២០០៧[392] | ១៩៩២[393] | X | ២០០៨ | X | X | X | X | X |
| វៀតណាម | ១៩៨២ | ១៩៨២ | ១៩៨២[394] | ១៩៨២[395] | ២០១៥[396] | ១៩៩០ | X | ២០១៥ | X | X | X | X | X |

388 ប្រទេសថៃ បានធ្វើសេចក្តីប្រកាស ស្របតាម CCPR មាត្រា ១ (សិទ្ធិក្នុងការកំណត់ដោយខ្លួនឯង) និងមាត្រា ២០ (ការហាមឃាត់ការឃោសនាអំពីសង្គ្រាម)។

389 ប្រទេសថៃ បានធ្វើសេចក្តីប្រកាស ស្របតាម CESCR មាត្រា ១ (សិទ្ធិក្នុងការកំណត់ដោយខ្លួនឯង)។

390 ប្រទេសថៃ បានចុះ ខ រក្សាសិទ្ធិចំពោះ CERD មាត្រា ៤ (ការលើកកម្ពស់ការរើសអើងដោយប្រើការឃោសនា) និងមាត្រា ២២ (ការដោះស្រាយវិវាទដោយតុលាការយុត្តិធម៌អន្តរជាតិ) និងធ្វើសេចក្តីប្រកាសផងដែរថា "ខ្លួនមិនបកស្រាយ និងអនុវត្តបញ្ញត្តិនានានៃអនុសញ្ញានេះ ជាការដាក់កាតព្វកិច្ចណាមួយលើព្រះរាជាណាចក្រថៃ ដែលលើសពីព្រំដែននៃរដ្ឋធម្មនុញ្ញ និងច្បាប់របស់ព្រះរាជាណាចក្រថៃនោះទេ។ លើសពីនេះទៀត ការបកស្រាយ និងពាក្យស្នើសុំទាំងនោះនឹងត្រូវបានដាក់កម្រិត ឬ ត្រូវមានសង្គតភាពជាមួយកាតព្វកិច្ចនានា ស្របតាមលិខិតូបករណ៍សិទ្ធិមនុស្សអន្តរជាតិដទៃទៀត ដែលព្រះរាជាណាចក្រថៃជាភាគី"។

391 ប្រទេសថៃ បានចុះ ខ រក្សាសិទ្ធិចំពោះ CEDAW មាត្រា ២៩ (ការដោះស្រាយវិវាទដោយតុលាការយុត្តិធម៌អន្តរជាតិ)។

392 ប្រទេសថៃ បានចុះ ខ រក្សាសិទ្ធិចំពោះ CAT មាត្រា ៣០ កថាខណ្ឌទី ១ (ការដោះស្រាយវិវាទដោយតុលាការយុត្តិធម៌អន្តរជាតិ)។ ប្រទេសនេះក៏បានបង្កើតសេចក្តីប្រកាសមួយ ស្របតាម មាត្រា ១ កថាខណ្ឌទី ១ (និយមន័យរបស់ទារុណកម្ម) មាត្រា ៤ (ការបញ្ជាក់ថា ទារុណកម្មនឹងត្រូវបានចែងថាជាបទល្មើស ដែលស្ថិតនៅក្រោមច្បាប់ព្រហ្មទណ្ឌ) និងមាត្រា ៥ (ការបង្កើតយុត្តាធិការលើបទល្មើសនានា ដែលអ្នកធ្វើទារុណកម្មដែលរងការចោទប្រកាន់ណាមួយ មិនអាចធ្វើបត្យាប័នបានទេ)។

393 ប្រទេសថៃ បានចុះ ខ រក្សាសិទ្ធិចំពោះ CRC មាត្រា ២២ (ការការពារកុមារស្វែងរកសិទ្ធិជ្រកកោន និងកុមារភៀសខ្លួន)។

394 ប្រទេសវៀតណាម បានចុះ ខ រក្សាសិទ្ធិចំពោះ CERD មាត្រា ២២ (ការដោះស្រាយវិវាទដោយតុលាការយុត្តិធម៌អន្តរជាតិ)។

395 ប្រទេសវៀតណាម បានចុះ ខ រក្សាសិទ្ធិចំពោះ CEDAW មាត្រា ២៩ កថាខណ្ឌទី ១ (ការដោះស្រាយវិវាទដោយតុលាការយុត្តិធម៌អន្តរជាតិ)។

396 ប្រទេសវៀតណាម បានធ្វើសេចក្តីប្រកាស ស្របតាម CAT មាត្រា ៨ កថាខណ្ឌទី ២ (មូលដ្ឋានច្បាប់សម្រាប់ការធ្វើបត្យាប័ន) មាត្រា ២០ (កិច្ចសហការជាមួយគណៈកម្មាធិការនៅក្នុងការត្រួតពិនិត្យព័ត៌មាន) និងមាត្រា ៣០ កថាខណ្ឌទី ១ (ការដោះស្រាយវិវាទដោយតុលាការយុត្តិធម៌អន្តរជាតិ)។ សូមកត់សម្គាល់ថា សេចក្តីប្រកាសដែលត្រូវបានធ្វើឡើងស្របតាម មាត្រា ២០ និង៣០ កថាខណ្ឌទី ១ ទំនងជា ខ រក្សាសិទ្ធិ ពីព្រោះវាបានបដិសេធចំពោះការចងកាតព្វកិច្ចដោយបញ្ញត្តិទាំងនេះ។

## តារាងទី២៖ ក្របខណ្ឌច្បាប់នៃ CRVS នៅក្នុងរដ្ឋសមាជិកអាស៊ាន

| ប្រទេស | អាជ្ញាធរមានសមត្ថកិច្ច | ច្បាប់ដែលអាចអនុវត្តបាន | | | |
|---|---|---|---|---|---|
| | | កំណើត | មរណភាព | អាពាហ៍ពិពាហ៍ | ឯកសារអត្តសញ្ញាណ |
| ប្រ៊ុយណេ ដារូសាឡឹម | ក្រសួងមហាផ្ទៃ (នាយកដ្ឋានអន្តោប្រវេសន៍ និង ការចុះបញ្ជីជាតិ) | • ច្បាប់ស្តីពីការចុះបញ្ជីកំណើត និង មរណភាព ឆ្នាំ ១៩២២ ជំពូក ៧៩ | • ច្បាប់ស្តីពីការចុះបញ្ជីកំណើត និង មរណភាព ឆ្នាំ ១៩២២ ជំពូក ៧៩ | • ច្បាប់ស្តីពីការចុះបញ្ជីអាពាហ៍ពិពាហ៍ ឆ្នាំ ១៩៨៤ ជំពូក ១២៤ (សម្រាប់អ្នកមិនកាន់សាសនាអ៊ីស្លាម)<br>• ច្បាប់គ្រួសារនៃសាសនាអ៊ីស្លាម ឆ្នាំ ១៩៩៩ ជំពូក ២១៧ (សម្រាប់អ្នកកាន់សាសនាអ៊ីស្លាម) | • ច្បាប់ស្តីពីការចុះបញ្ជីជាតិ ឆ្នាំ១៩៨៤ ជំពូក ១៩ |
| កម្ពុជា | ក្រសួងមហាផ្ទៃ (អគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម) | • អនុក្រឹត្យលេខ ១០៣ ស្តីពីអត្រានុកូលដ្ឋាន ឆ្នាំ ២០០០ ដូចបានធ្វើវិសោធនកម្មដោយអនុក្រឹត្យលេខ ៦០ នៅក្នុងឆ្នាំ២០០២[397] | • អនុក្រឹត្យលេខ ១០៣ ស្តីពីអត្រានុកូលដ្ឋាន ឆ្នាំ ២០០០ ដូចបានធ្វើវិសោធនកម្មដោយអនុក្រឹត្យលេខ ៦០ នៅក្នុងឆ្នាំ២០០២ | • ច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និង គ្រួសារ ឆ្នាំ ១៩៨៩<br>• អនុក្រឹត្យលេខ ១០៣ ស្តីពីអត្រានុកូលដ្ឋាន ឆ្នាំ២០០០ ដូចបានធ្វើវិសោធនកម្មដោយអនុក្រឹត្យលេខ ៦០ នៅក្នុងឆ្នាំ២០០២<br>• អនុក្រឹត្យលេខ ១៨៣ ស្តីពីដំណើរការ និង នីតិវិធីតាមផ្លូវច្បាប់នៃការរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋកម្ពុជា និង ជនបរទេស ឆ្នាំ២០០៨ | • អនុក្រឹត្យលេខ ៦០ ស្តីពីអត្តសញ្ញាណប័ណ្ណសញ្ជាតិកម្ពុជា ឆ្នាំ ២០០៧ |
| ឥណ្ឌូនេស៊ី | ក្រសួងមហាផ្ទៃ | • ច្បាប់លេខ ២៣/២៩៩៦ ស្តីពីរដ្ឋបាលប្រជាជន | • ច្បាប់លេខ ២៣/២៩៩៦ ស្តីពីរដ្ឋបាលប្រជាជន | • ច្បាប់លេខ ១/១៩៧៤ ស្តីពីអាពាហ៍ពិពាហ៍ | • ច្បាប់លេខ ២៣/២៩៩៦ ស្តីពីរដ្ឋបាលប្រជាជន |

397 អនុក្រឹត្យនេះបង្គាប់ថា ការចុះបញ្ជីកំណើតត្រូវតែបានអនុវត្តក្នុងរយៈពេល ៣០ ថ្ងៃ ហើយការចុះបញ្ជីមរណភាព និងអាពាហ៍ពិពាហ៍ត្រូវតែបានអនុវត្តក្នុងរយៈពេល ១៥ ថ្ងៃ។ សំបុត្រកំណើត សំបុត្រអាពាហ៍ពិពាហ៍ និង សំបុត្រមរណភាព ជាទូទៅ ត្រូវបានចេញក្នុងរយៈពេលបីថ្ងៃ ក្រោយពេលចុះបញ្ជី។

| ប្រទេស | អាជ្ញាធរមានសមត្ថកិច្ច | ច្បាប់ដែលអាចអនុវត្តបាន | | | |
|---|---|---|---|---|---|
| | | កំណើត | មរណភាព | អាពាហ៍ពិពាហ៍ | ឯកសារអត្តសញ្ញាណ |
| | (អគ្គនាយកដ្ឋានប្រជាជន និង ការចុះបញ្ជីអត្រានុកូលដ្ឋាន)<br><br>**ការិយាល័យប្រជាជន និង ការចុះបញ្ជី អត្រានុកូលដ្ឋាន** សម្រាប់រាជធានី/ទីក្រុង | • ច្បាប់លេខ ២៤/២០១៣ ស្តីពីរដ្ឋបាលប្រជាជន (វិសោធនកម្មនៃច្បាប់ ឆ្នាំ២០០៦)<br>• បទប្បញ្ញត្តិរបស់ប្រធានាធិបតី លេខ ២៥/២០០៨ ស្តីពីលក្ខខណ្ឌតម្រូវ និង នីតិវិធីសម្រាប់ការចុះបញ្ជីប្រជាជន និង ការចុះបញ្ជីអត្រានុកូលដ្ឋាន<br>• បទប្បញ្ញត្តិ MOHA លេខ ១១/២០១០ ពាក់ព័ន្ធនឹងគោលការណ៍ណែនាំស្តីពីការប្រមូលទិន្នន័យ និង ការចេញឯកសារប្រជាជន សម្រាប់ប្រជាជនងាយរងគ្រោះ<br>• បទប្បញ្ញត្តិ MOHA លេខ ៩/២០១៦ ស្តីពីការបង្កើនការគ្របដណ្តប់លើភាពជាកម្មសិទ្ធិលើសំបុត្រកំណើត<br>• បទប្បញ្ញត្តិរបស់ប្រធានាធិបតី លេខ ៩៦/២០១៨ ពាក់ព័ន្ធនឹងលក្ខខណ្ឌតម្រូវ និង នីតិវិធីសម្រាប់ការចុះបញ្ជីប្រជាជន និង ការចុះបញ្ជីអត្រានុកូលដ្ឋាន | • ច្បាប់លេខ ២៤/២០១៣ ស្តីពីរដ្ឋបាលប្រជាជន (វិសោធនកម្មនៃច្បាប់ ឆ្នាំ២០០៦)<br>• បទប្បញ្ញត្តិរបស់ប្រធានាធិបតី លេខ ៩៦/២០១៨ ពាក់ព័ន្ធនឹងលក្ខខណ្ឌតម្រូវ និង នីតិវិធីសម្រាប់ការចុះបញ្ជីប្រជាជន និង ការចុះបញ្ជីអត្រានុកូលដ្ឋាន | • ច្បាប់លេខ ២៣/២០០៦ ស្តីពីរដ្ឋបាលប្រជាជន<br>• ច្បាប់លេខ ២៤/២០១៣ ស្តីពីរដ្ឋបាលប្រជាជន (វិសោធនកម្មនៃច្បាប់ ឆ្នាំ២០០៦)<br>• បទប្បញ្ញត្តិរបស់ប្រធានាធិបតី លេខ ៩៦/២០១៨ ពាក់ព័ន្ធនឹងលក្ខខណ្ឌតម្រូវ និង នីតិវិធីសម្រាប់ការចុះបញ្ជីប្រជាជន និង ការចុះបញ្ជីអត្រានុកូលដ្ឋាន | • ច្បាប់លេខ ២៤/២០១៣ ស្តីពីរដ្ឋបាលប្រជាជន (វិសោធនកម្មនៃច្បាប់ ឆ្នាំ២០០៦)<br>• បទប្បញ្ញត្តិរបស់ប្រធានាធិបតី លេខ ២៥/២០០៨ ស្តីពីលក្ខខណ្ឌតម្រូវ និង នីតិវិធីសម្រាប់ការចុះបញ្ជីប្រជាជន និង ការចុះបញ្ជីអត្រានុកូលដ្ឋាន<br>• បទប្បញ្ញត្តិ MOHA លេខ ១១/២០១០ ពាក់ព័ន្ធនឹង គោលការណ៍ណែនាំស្តីពីការប្រមូលទិន្នន័យ និង ការចេញឯកសារប្រជាជន សម្រាប់ប្រជាជនងាយរងគ្រោះ<br>• បទប្បញ្ញត្តិ MOHA លេខ ៩/២០១៦ ស្តីពីការបង្កើនការគ្របដណ្តប់លើភាពជាកម្មសិទ្ធិលើសំបុត្រកំណើត<br>• បទប្បញ្ញត្តិ MOHA លេខ ២/២០១៦ គ្របដណ្តប់លើអត្តសញ្ញាណប័ណ្ណរបស់កុមារ |

| ប្រទេស | អាជ្ញាធរមានសមត្ថកិច្ច | ច្បាប់ដែលអាចអនុវត្តបាន | | | |
|---|---|---|---|---|---|
| | | កំណើត | មរណភាព | អាពាហ៍ពិពាហ៍ | ឯកសារអត្តសញ្ញាណ |
| **ឡាវ** | **ក្រសួងសន្តិសុខសាធារណៈ** (ទទួលខុសត្រូវចំពោះការចុះបញ្ជីសៀវភៅគ្រួសារ និង ការចេញអត្តសញ្ញាណប័ណ្ណ) **ក្រសួងមហាផ្ទៃ** (ទទួលខុសត្រូវចំពោះការចុះបញ្ជីកំណើត អាពាហ៍ពិពាហ៍ និង មរណភាព) **ក្រសួងយុត្តិធម៌** (ទទួលខុសត្រូវចំពោះការអនុម័ត និង ការផ្លាស់ប្តូរសញ្ជាតិ) | • ច្បាប់ស្តីពីការចុះបញ្ជីគ្រួសារ ឆ្នាំ២០០៩ | • ច្បាប់ស្តីពីការចុះបញ្ជីគ្រួសារ ឆ្នាំ២០០៩ | • ច្បាប់ស្តីពីការចុះបញ្ជីគ្រួសារ ឆ្នាំ២០០៩ | • ច្បាប់ស្តីពីការចុះបញ្ជីគ្រួសារ ឆ្នាំ២០០៩ |
| **ម៉ាឡេស៊ី** | **ក្រសួងមហាផ្ទៃ** (នាយកដ្ឋានចុះបញ្ជីជាតិ) | • ច្បាប់ស្តីពីការចុះបញ្ជីកំណើត និង មរណភាព ឆ្នាំ១៩៥៧ [ច្បាប់ ២៩៩] (សម្រាប់ឧបទ្វីបម៉ាឡេស៊ី)<br>• បទប្បញ្ញត្តិស្តីពីការចុះបញ្ជីកំណើត និង មរណភាព ឆ្នាំ១៩៤៨ (ជំពូក ១២៣) (នៅសាបា) និង ការចុះបញ្ជីកំណើត និង មរណភាព ឆ្នាំ១៩៥១ (ជំពូក ១០) (នៅ Sarawak) | • ច្បាប់ស្តីពីការចុះបញ្ជីកំណើត និង មរណភាព ឆ្នាំ១៩៥៧ [ច្បាប់ ២៩៩] (សម្រាប់ឧបទ្វីបម៉ាឡេស៊ី)<br>• បទប្បញ្ញត្តិស្តីពីការចុះបញ្ជីកំណើត និង មរណភាព ឆ្នាំ១៩៤៨ (ជំពូក ១២៣) (នៅសាបា) និង ការចុះបញ្ជីកំណើត និង មរណភាព ឆ្នាំ១៩៥១ (ជំពូក ១០) (នៅ Sarawak) | • កំណែទម្រង់ច្បាប់ (អាពាហ៍-ពិពាហ៍ និង ការលែងលះ) ឆ្នាំ១៩៧៦ [ច្បាប់ ១៦៤]<br>• ច្បាប់គ្រួសារនៃសាសនាអ៊ីស្លាម (ដែនដីសហព័ន្ធ) ឆ្នាំ១៩៨៤ [ច្បាប់ ៣០៣] (អនុវត្តចំពោះដែនដីសហព័ន្ធរួមមាន កូឡាឡាំពួរ Labuan និង Putrajaya តែប៉ុណ្ណោះ)<br>• អ្នកកាន់សាសនាអ៊ីស្លាម ដែលស្នាក់នៅក្នុងរដ្ឋ ១៤ | • ច្បាប់ស្តីពីការចុះបញ្ជីជាតិ ឆ្នាំ១៩៥៩ [ច្បាប់ ១៧៨] និង បទប្បញ្ញត្តិស្តីពីការចុះបញ្ជីជាតិ ឆ្នាំ១៩៩០ [P.U.(A)៤៧២/១៩៩០] |

| ប្រទេស | អាជ្ញាធរមានសមត្ថកិច្ច | ច្បាប់ដែលអាចអនុវត្តបាន | | | |
|---|---|---|---|---|---|
| | | កំណើត | មរណភាព | អាពាហ៍ពិពាហ៍ | ឯកសារអត្តសញ្ញាណ |
| | | | | ផ្សេងទៀតត្រូវបានគ្រប់គ្រងដោយច្បាប់គ្រួសារនៃសាសនាអ៊ីស្លាមរបស់រដ្ឋនីមួយៗ។<br>• បទប្បញ្ញត្តិស្តីពីការចុះបញ្ជីអាពាហ៍ពិពាហ៍ ឆ្នាំ១៩៥២ (លេខ ៥៣ នៃឆ្នាំ១៩៥២) (អនុវត្តចំពោះសាបា និង Sarawak សម្រាប់តែចុះបញ្ជីអាពាហ៍ពិពាហ៍ដែលភាគីម្ខាងកាន់សាសនាផ្សេងពីអ៊ីស្លាម និង សាសនាគ្រិស្តតែប៉ុណ្ណោះ។ | |
| **មីយ៉ាន់ម៉ា** | **ក្រសួងការងារ អន្តោប្រវេសន៍ និង ប្រជាជន** (នាយកដ្ឋានអន្តោប្រវេសន៍ នាយកដ្ឋានចុះបញ្ជីជាតិ និង ភាពជាពលរដ្ឋ នាយកដ្ឋានប្រជាជន) | • សេចក្តីជូនដំណឹងលេខ ១/២០១៤ (១៨-១១-២០១៤) អំណាចត្រូវបានប្រគល់ជូនស្របតាមមាត្រា ១៦ នៃច្បាប់ស្តីពីការធ្វើអន្តោប្រវេសន៍នៅប្រទេសមីយ៉ាន់ម៉ា (បញ្ញត្តិស្តីពីគ្រាអាសន្ន) ឆ្នាំ១៩៤៧[398] | • ច្បាប់ស្តីពីភាពជាពលរដ្ឋមីយ៉ាន់ម៉ា ឆ្នាំ១៩៨២<br>• វិធានស្តីពីការស្នាក់នៅជាអចិន្ត្រៃយ៍របស់ជនបរទេស ចេញថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០១៤ យោងតាម មាត្រា ១៦ ច្បាប់ស្តីពីការធ្វើអន្តោប្រវេសន៍នៅប្រទេសមីយ៉ាន់ម៉ា (បញ្ញត្តិស្តីពីគ្រាអាសន្ន) ឆ្នាំ១៩៤៧ – | • ច្បាប់អាពាហ៍ពិពាហ៍ពិសេសសម្រាប់ស្ត្រីកាន់សាសនាព្រះពុទ្ធនៅប្រទេសមីយ៉ាន់ម៉ា ឆ្នាំ២០១៥<br>• ច្បាប់ឯកពន្ធភាព ឆ្នាំ២០១៥ | • ច្បាប់ស្តីពីភាពជាពលរដ្ឋមីយ៉ាន់ម៉ា ឆ្នាំ១៩៨២<br>• វិធានស្តីពីការស្នាក់នៅជាអចិន្ត្រៃយ៍របស់ជនបរទេស ចេញថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០១៤ យោងតាម មាត្រា ១៦ ច្បាប់ស្តីពីការធ្វើអន្តោប្រវេសន៍នៅប្រទេសមីយ៉ាន់ម៉ា (បញ្ញត្តិស្តីពីគ្រាអាសន្ន) ឆ្នាំ១៩៤៧ – |

398 ហាក់បីដូចជាពុំមានច្បាប់ជាក់លាក់ ដែលពាក់ព័ន្ធនឹងការចុះបញ្ជីអត្រានុកូលដ្ឋាននៅប្រទេសមីយ៉ាន់ម៉ានោះទេ របាយការណ៍របស់ប្រទេសមីយ៉ាន់ម៉ា ទំព័រទី ៣។

| ប្រទេស | អាជ្ញាធរមានសមត្ថកិច្ច | ច្បាប់ដែលអាចអនុវត្តបាន | | | |
|---|---|---|---|---|---|
| | | កំណើត | មរណភាព | អាពាហ៍ពិពាហ៍ | ឯកសារអត្តសញ្ញាណ |
| | | • ច្បាប់ស្តីពីភាពជាពលរដ្ឋមីយ៉ាន់ម៉ា ឆ្នាំ១៩៨២[399]<br>• វិធានស្តីពីការស្នាក់នៅជាអចិន្ត្រៃយ៍របស់ជនបរទេស ចេញថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ ២០១៤ យោងតាម មាត្រា ១៦ ច្បាប់ស្តីពីការធ្វើអន្តោប្រវេសន៍នៅប្រទេសមីយ៉ាន់ម៉ា (បញ្ញត្តិស្តីពីគ្រាអាសន្ន) ឆ្នាំ១៩៤៧ – សេចក្តីជូនដំណឹងរបស់ក្រសួងអន្តោប្រវេសន៍ និង ប្រជាជន លេខ ១/២០១៤<br>• ច្បាប់ស្តីពីសិទ្ធិកុមារ ឆ្នាំ២០១៩ | សេចក្តីជូនដំណឹងរបស់ក្រសួងអន្តោប្រវេសន៍ និង ប្រជាជន លេខ ១/២០១៤ | | សេចក្តីជូនដំណឹងរបស់ក្រសួងអន្តោប្រវេសន៍ និង ប្រជាជន លេខ ១/២០១៤ |
| **ហ្វីលីពីន** | **អាជ្ញាធរស្ថិតិនៃប្រទេសហ្វីលីពីន** (**PSA**)<br>**នាយកដ្ឋានមហាផ្ទៃ និង រដ្ឋាភិបាលមូលដ្ឋាន** (**DILG**) | • ច្បាប់លេខ ៣៧៥៣ s. ១៩៣០ (ច្បាប់ស្តីពីបញ្ជីអត្រានុកូលដ្ឋាន<br>• ក្រឹត្យរបស់ប្រធានាធិបតីលេខ ៦៥១ s. ១៩៧៥ (តម្រូវឲ្យមានការចុះបញ្ជីកំណើត និង មរណភាពនៅក្នុងប្រទេសហ្វីលីពីន | • ច្បាប់លេខ ៣៧៥៣ s. ១៩៣០ (ច្បាប់ស្តីពីបញ្ជីអត្រានុកូលដ្ឋាន<br>• ក្រឹត្យរបស់ប្រធានាធិបតីលេខ ៦៥១ s. ១៩៧៥ (តម្រូវឲ្យមានការចុះបញ្ជីកំណើត និង មរណ-ភាពនៅក្នុងប្រទេសហ្វីលីពីន | • ច្បាប់លេខ ៣៦១៣ s. ១៩២៩ (ច្បាប់អាពាហ៍ពិពាហ៍)<br>• ច្បាប់លេខ ៣៧៥៣ s. ១៩៣០ (ច្បាប់ស្តីពីបញ្ជីអត្រានុកូលដ្ឋាន | • ច្បាប់សាធារណរដ្ឋលេខ ១១០៥៥ s. ២០១៨ (ច្បាប់ស្តីពីប្រព័ន្ធធ្វើអត្តសញ្ញាណកម្មនៃប្រទេសហ្វីលីពីន) |

399 មាត្រា ៩ ១០ និង១១ នៃច្បាប់ស្តីពីភាពជាពលរដ្ឋ ចែងអំពីការចុះបញ្ជីកំណើតរបស់ពលរដ្ឋដែលកើតនៅក្នុងប្រទេសមីយ៉ាន់ម៉ា កើតនៅក្រៅប្រទេសមីយ៉ាន់ម៉ា និងទោសទណ្ឌនៅពេលដែលកំណើតនោះមិនត្រូវបានចុះបញ្ជីរៀងៗខ្លួន។

| ប្រទេស | អាជ្ញាធរមានសមត្ថកិច្ច | ច្បាប់ដែលអាចអនុវត្តបាន | | | |
|---|---|---|---|---|---|
| | | កំណើត | មរណភាព | អាពាហ៍ពិពាហ៍ | ឯកសារអត្តសញ្ញាណ |
| | **ការិយាល័យមន្ត្រីអត្រានុកូលដ្ឋានជាន់ខ្ពស់** (**OCRG**)<br><br>**ទីតាំងផ្តល់សេវាដល់ជនបរទេសនៅប្រទេសហ្វីលីពីន** (**PFSP**)[400] | ដែលកើតឡើងចាប់ពីថ្ងៃទី ០១ ខែមករា ឆ្នាំ១៩៧៤ តទៅ)<br>• សេចក្តីប្រកាសលេខ ៣២៦ s. ១៩៩៤[401] | ដែលកើតឡើងចាប់ពីថ្ងៃទី ០១ ខែមករា ឆ្នាំ១៩៧៤ តទៅ)<br>• ក្រឹត្យរបស់ប្រធានាធិបតី លេខ ៨៥៦ s. ១៩៧៥ (ក្រមអនាម័យនៃប្រទេសហ្វីលីពីន)[402]<br>• សេចក្តីប្រកាសលេខ ៣២៦ s. ១៩៩៤ | • ក្រឹត្យរបស់ប្រធានាធិបតីលេខ ១០៨៣ s. ១៩៧៧ (ក្រមនៃច្បាប់ផ្ទាល់ខ្លួនរបស់អ្នកកាន់សាសនាអ៊ីស្លាម)[403]<br>• សេចក្តីប្រកាសលេខ ៣២៦ s. ១៩៩៤ | • ច្បាប់ស្តីពីវិធាន និង បទប្បញ្ញត្តិនៃការអនុវត្ត (IRR) របស់សាធារណរដ្ឋ លេខ ១១០៥៥ s. ២០១៨ |
| **សិង្ហបុរី** | **ក្រសួងមហាផ្ទៃ**<br>(អាជ្ញាធរអន្តោប្រវេសន៍ និង អាជ្ញាធរត្រួតពិនិត្យច្រកព្រំដែន)<br>(បញ្ជីកំណើត និង មរណភាព) | • ច្បាប់ស្តីពីការចុះបញ្ជីកំណើត និង មរណភាព (ជំពូក ២៦៧)[404] | • ច្បាប់ស្តីពីការចុះបញ្ជីកំណើត និង មរណភាព (ជំពូក ២៦៧) | • ធម្មនុញ្ញរបស់ស្ត្រី (ជំពូក ៣៥៣)<br>• ច្បាប់ស្តីពីការគ្រប់គ្រងច្បាប់នៃសាសនាអ៊ីស្លាម (ជំពូក ៣) | • ច្បាប់ស្តីពីការចុះបញ្ជីជាតិ (ជំពូក ២០១) |

400 សម្រាប់ពលរដ្ឋហ្វីលីពីនដែលនៅក្រៅប្រទេស របាយការណ៍របស់ប្រទេសហ្វីលីពីន។

401 សេចក្តីប្រកាសនេះបានប្រកាសថា ការចុះបញ្ជីកំណើត មរណភាព អាពាហ៍ពិពាហ៍ និង កុមារបាត់ខ្លួន គឺជាគោលនយោបាយជាតិរបស់រដ្ឋ និង លុបបំបាត់ថ្លៃសេវាចុះបញ្ជី របាយការណ៍របស់ប្រទេសហ្វីលីពីន។

402 វាចែងថា សំបុត្រមរណភាពគឺជាលក្ខខណ្ឌតម្រូវសម្រាប់ការបញ្ចុះសព។

403 តុលាការស្រុក Shari'a ដើរតួជាមន្ត្រីអត្រានុកូលដ្ឋានស្រុកសម្រាប់អាពាហ៍ពិពាហ៍ ការលែងលះ ការលុបចោលការលែងលះ និង ការបំប្លែងនានារបស់អ្នកកាន់សាសនាអ៊ីស្លាម នៅក្នុងយុត្តាធិការនៃដែនដីរបស់តុលាការដែលបានពោល។ របាយការណ៍របស់ប្រទេសហ្វីលីពីន (នីតិបញ្ញត្តិ និង ច្បាប់ករណី)។

404 ច្បាប់តម្រូវថា រាល់កំណើត ទារកស្លាប់នៅក្នុងពោះ និង មរណភាពទាំងអស់ ដែលកើតឡើងនៅក្នុងប្រទេសសិង្ហបុរី និង ដែនទឹករបស់ខ្លួន ត្រូវចុះបញ្ជីក្នុងរយៈពេល ១៤ ថ្ងៃបន្ទាប់ពីព្រឹត្តិការណ៍នោះបានកើតឡើង។

| ប្រទេស | អាជ្ញាធរមានសមត្ថកិច្ច | ច្បាប់ដែលអាចអនុវត្តបាន | | | |
|---|---|---|---|---|---|
| | | កំណើត | មរណភាព | អាពាហ៍ពិពាហ៍ | ឯកសារអត្តសញ្ញាណ |
| ថៃ | **ក្រសួងមហាផ្ទៃ** (នាយកដ្ឋានរដ្ឋបាលខេត្ត ការិយាល័យគ្រប់គ្រងការចុះបញ្ជី)<br><br>**បទប្បញ្ញត្តិរបស់ការិយាល័យចុះបញ្ជីកណ្តាល** (សម្រាប់ជនដែលមិនមែនជាពលរដ្ឋថៃ) | • ច្បាប់ស្តីពីការចុះបញ្ជីអត្រានុកូលដ្ឋាន ឆ្នាំ១៩៩១ ដែលត្រូវបានធ្វើវិសោធនកម្មដោយច្បាប់លេខ ២ នៅក្នុងឆ្នាំ២០០៨ និង ច្បាប់លេខ ៣ នៅក្នុងឆ្នាំ២០១៩ | • ច្បាប់ស្តីពីការចុះបញ្ជីអត្រានុកូលដ្ឋាន ឆ្នាំ ១៩៩១ ដែលត្រូវបានធ្វើវិសោធនកម្មដោយច្បាប់លេខ ២ នៅក្នុងឆ្នាំ២០០៨ និង ច្បាប់លេខ ៣ នៅក្នុងឆ្នាំ២០១៩ | • ច្បាប់ស្តីពីការចុះបញ្ជីគ្រួសារ ឆ្នាំ១៩៣៥ ដែលត្រូវបានធ្វើវិសោធនកម្មដោយច្បាប់លេខ ២ នៅក្នុងឆ្នាំ១៩៣៩ និង លេខ ៣ នៅក្នុងឆ្នាំ ១៩៩០ | • ច្បាប់ស្តីអត្តសញ្ញាណប័ណ្ណជាតិ ឆ្នាំ១៩៨៣ ដែលត្រូវបានធ្វើវិសោធនកម្មដោយច្បាប់លេខ ២ នៅក្នុងឆ្នាំ១៩៩៩និង លេខ ៣ នៅក្នុងឆ្នាំ ២០១១ (សម្រាប់ពលរដ្ឋថៃ)<br>• ច្បាប់ស្តីពីការចុះបញ្ជីអត្រានុកូលដ្ឋាន ឆ្នាំ១៩៩១ (បញ្ញត្តិជាក់លាក់សម្រាប់ជនដែលមិនមែនពលរដ្ឋ)[405] |
| វៀតណាម | **ក្រសួងយុត្តិធម៌** (នាយកដ្ឋានចុះបញ្ជីអត្រានុកូលដ្ឋាន សញ្ជាតិ និង យថាភូត) | • ច្បាប់ស្តីពីអត្រានុកូលដ្ឋាន ឆ្នាំ២០១៤ (ច្បាប់លេខ ៦០/២០១៤/QH១៣)<br>• ច្បាប់ស្តីពីកុមារ ឆ្នាំ២០១៦ (ច្បាប់លេខ ១០២/២០១៦/QH១៣)[406] | • ច្បាប់ស្តីពីអត្រានុកូលដ្ឋាន ឆ្នាំ២០១៤ (ច្បាប់លេខ ៦០/២០១៤/QH១៣)<br>• ច្បាប់ស្តីពីកុមារ ឆ្នាំ២០១៦ (ច្បាប់លេខ ១០២/២០១៦/QH១៣) | • ច្បាប់ស្តីពីអត្រានុកូលដ្ឋាន ឆ្នាំ២០១៤ (ច្បាប់លេខ ៦០/២០១៤/QH១៣) | • ច្បាប់ស្តីពីអត្តសញ្ញាណកម្មពលរដ្ឋ ឆ្នាំ២០១៤ (ច្បាប់លេខ ៥៩/២០១៤/QH១៣)<br>• ច្បាប់ស្តីពីការចូល ការចេញ ការឆ្លងកាត់ និង ការស្នាក់នៅរបស់ជនបរទេសនៅក្នុងប្រទេសវៀតណាម ឆ្នាំ២០១៤ (ច្បាប់លេខ ៤៧/២០១៤/QH១៣) |

405 ព័ត៌មានលម្អិតបន្ថែមទៀត អាចស្វែងរកបាននៅក្នុងបទប្បញ្ញត្តិរបស់ក្រសួង ស្តីពីកាតព្វកិច្ចរបស់ជនដែលមិនមែនជាពលរដ្ឋថៃ ក្រោមការចុះបញ្ជីអត្រានុកូលដ្ឋាន និង អត្រាថ្លៃសេវា ឆ្នាំ២០០៨ និង បទប្បញ្ញត្តិរបស់ការិយាល័យចុះបញ្ជីកណ្តាលស្តីពីការចេញអត្តសញ្ញាណប័ណ្ណជូនជនដែលមិនមែនជាពលរដ្ឋថៃ ឆ្នាំ២០០៨ របាយការណ៍របស់ប្រទេសថៃ។

406 ច្បាប់ស្តីពីកុមារ ឆ្នាំ២០១៦ មាត្រា ១៣ – "កុមារមានសិទ្ធិទទួលបានការចុះបញ្ជីកំណើត និង ការបញ្ជាក់អំពីមរណភាព ទទួលបាននាមត្រកូល និង នាមខ្លួន និង ទទួលបានភាពជាពលរដ្ឋ និង មានឪពុកម្តាយ សញ្ជាតិ និង យេនឌ័រដែលត្រូវបានសម្គាល់ឃើញរបស់គាត់ យ៉ាងស្របច្បាប់" របាយការណ៍របស់ប្រទេសវៀតណាម។

## តារាងទី៣៖ ក្រមខណ្ឌច្បាប់នៃសញ្ជាតិ និង ភាពជាពលរដ្ឋនៅក្នុងរដ្ឋសមាជិកអាស៊ាន

| ប្រទេស | អាជ្ញាធរមានសមត្ថកិច្ច | គោលការណ៍ | ច្បាប់ដែលអាចអនុវត្តបាន | បញ្ញត្តិ | | |
|---|---|---|---|---|---|---|
| | | | | ការទទួលបាន | ការបាត់បង់ | ការទទួលបានឡើងវិញ |
| ព្រុយណេដារូសាឡឹម | ក្រសួងមហាផ្ទៃ (នាយកដ្ឋានអន្តោប្រវេសន៍ និង ការចុះបញ្ជីជាតិ) | *Jus sanguinis* | ច្បាប់ស្តីពីសញ្ជាតិព្រុយណេ ឆ្នាំ ១៩៦១ (ជំពូក ១៥) | មាត្រា ៤ ៥ ៦ និង ៨ | មាត្រា ៩ ១០ និង ១១ | គ្មាន |
| កម្ពុជា | ក្រសួងមហាផ្ទៃ (អគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម) | *Jus sanguinis* និង *Jus soli* | ច្បាប់ស្តីពីសញ្ជាតិ ឆ្នាំ១៩៩៦[407] | មាត្រា ៤ ៥ ៧ ៨ ៩ ១០ ១១ ១២ ១៣ និង ១៤ | មាត្រា ១៨ | គ្មាន |
| ឥណ្ឌូនេស៊ី[408] | ក្រសួងច្បាប់ និង សិទ្ធិមនុស្ស | *Jus sanguinis* និង *Jus soli* | ច្បាប់លេខ ១២ ឆ្នាំ២០០៦ ស្តីពីភាពជាពលរដ្ឋនៃសាធារណរដ្ឋឥណ្ឌូនេស៊ី | មាត្រា ៤ ៥ ៩ ១៩ ២០ និង ២១ | មាត្រា ២៣ ២៦ និង ២៨ | មាត្រា ៣១ និង ៣២ |
| ឡាវ | ក្រសួងយុត្តិធម៌ | *Jus sanguinis* | ច្បាប់ស្តីពីសញ្ជាតិឡាវ ឆ្នាំ ២០០៤ | មាត្រា ១០ ១១ ១២ ១៣ ១៤ ១៥ និង ២៥ | មាត្រា ១៨ ១៩ និង ២០ | មាត្រា ២១ |
| ម៉ាឡេស៊ី | ក្រសួងមហាផ្ទៃ (នាយកដ្ឋានចុះបញ្ជីជាតិ) | *Jus sanguinis* និង *Jus soli* | រដ្ឋធម្មនុញ្ញរបស់សហព័ន្ធនៃប្រទេសម៉ាឡេស៊ី ឆ្នាំ១៩៥៧ ផ្នែក III – ភាពជាពលរដ្ឋ | ជំពូក ១ មាត្រា ១៤-២២ (ឧបសម្ព័ន្ធទីពីរនៃរដ្ឋធម្មនុញ្ញរបស់សហព័ន្ធ គួរតែត្រូវបានអានរួមគ្នា) | ជំពូក ២ មាត្រា ២៣-២៨ (ឧបសម្ព័ន្ធទីពីរនៃរដ្ឋធម្មនុញ្ញរបស់សហព័ន្ធ គួរតែត្រូវបានអានរួមគ្នា) | គ្មាន |

407 មានក្រមខណ្ឌច្បាប់ស្តីពីសញ្ជាតិជាច្រើនទៀតនៅក្នុងប្រទេសកម្ពុជា រួមមាន៖
អនុក្រឹត្យលេខ ២៨៦ ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១៣ ស្តីពីនីតិវិធីស្នើសុំសញ្ជាតិកម្ពុជា
អនុក្រឹត្យលេខ ២៨៦ ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១៣ ស្តីពីនីតិវិធីបោះបង់សញ្ជាតិ
អនុក្រឹត្យលេខ ២៨៧ ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១៣ ស្តីពីនីតិវិធីធ្វើសញ្ជាតូបនីកម្ម
ចូរមើលរបាយការណ៍របស់ប្រទេសកម្ពុជា។
408 ពុំមានព័ត៌មានត្រូវបានផ្តល់ជូនដោយរបាយការណ៍របស់ប្រទេសឥណ្ឌូនេស៊ីនោះទេ។

| ប្រទេស | អាជ្ញាធរមានសមត្ថកិច្ច | គោលការណ៍ | ច្បាប់ដែលអាចអនុវត្តបាន | បញ្ញត្តិ | | |
|---|---|---|---|---|---|---|
| | | | | ការទទួលបាន | ការបាត់បង់ | ការទទួលបានឡើងវិញ |
| **មីយ៉ាន់ម៉ា** | **ក្រសួងការងារ អន្តោប្រវេសន៍ និង ប្រជាជន** | *Jus sanguinis* | ច្បាប់ស្តីពីសញ្ជាតិមីយ៉ាន់ម៉ា ឆ្នាំ ១៩៨២ និង នីតិវិធីដែលពាក់ព័ន្ធនឹងច្បាប់ស្តីពីភាពជាពលរដ្ឋមីយ៉ាន់ម៉ា ឆ្នាំ១៩៨៣[409] | មាត្រា ៣ ៧ ២៣ និង ៥២<br>មាត្រា ៤២ ៤៣ ២៨ និង ៥០[410] | មាត្រា ១៦-១៩ (សម្រាប់ពលរដ្ឋ)<br>មាត្រា ៣៤-៣៨ (សម្រាប់ពលរដ្ឋតាមផ្លូវច្បាប់)<br>មាត្រា ៥៧-៦១ (សម្រាប់ពលរដ្ឋដែលបានធ្វើសញ្ជាតូបនីយកម្ម | គ្មាន |
| **ហ្វីលីពីន** | **ក្រសួងយុត្តិធម៌**<br>(នាយកដ្ឋានយុត្តិធម៌ ការិយាល័យអន្តោប្រវេសន៍) | *Jus sanguinis* | រដ្ឋធម្មនុញ្ញនៃសាធារណរដ្ឋហ្វីលីពីន ឆ្នាំ ១៩៨៧ មាត្រា IV | ផ្នែកទី១ | ផ្នែកទី៣ | ផ្នែកទី៣ |
| | | | ច្បាប់របស់រដ្ឋសហធន លេខ ៦៣ s. ១៩៣៦ (ច្បាប់ដែលចែងអំពីវិធីដែលភាពជាពលរដ្ឋហ្វីលីពីនអាចត្រូវបានបាត់បង់ ឬ ទទួលបានមកវិញ) | - | ផ្នែកទី១ | ផ្នែកទី២ និង ទី៣ |
| | | | ច្បាប់របស់រដ្ឋសហធន លេខ ៤៧៣ s. ១៩៣៩ (ច្បាប់ស្តីពីសញ្ជាតូបនីយ-កម្មដែលត្រូវបានកែសម្រួល) | ផ្នែកទី២ និង ទី៣ | - | - |
| | | | ច្បាប់របស់សាធារណរដ្ឋលេខ ៨១៧១ s. ១៩៩៥ (ច្បាប់ដែលចែងអំពី | - | - | ផ្នែកទី១ |

409 នីតិវិធី ឆ្នាំ១៩៨៣ រួមបញ្ចូល បណ្តុំនីតិវិធីខុសៗគ្នាចំនួនបី៖ នីតិវិធីដែលពាក់ព័ន្ធនឹងច្បាប់ស្តីពីភាពជាពលរដ្ឋរបស់ប្រទេសមីយ៉ាន់ម៉ា ឆ្នាំ១៩៨៣ (នីតិវិធី ឆ្នាំ១៩៨៣ ដែលពាក់ព័ន្ធនឹងភាពជាពលរដ្ឋ) លេខ ១៣/៨៣ ("នីតិវិធី ឆ្នាំ១៩៨៣ ដែលពាក់ព័ន្ធនឹងភាពជាពលរដ្ឋ") (ការបកប្រែមិនផ្លូវការ) នីតិវិធីដែលពាក់ព័ន្ធនឹងច្បាប់ស្តីពីភាពជាពលរដ្ឋរបស់ប្រទេសមីយ៉ាន់ម៉ា ឆ្នាំ១៩៨៣ (នីតិវិធី ឆ្នាំ១៩៨៣ ដែលពាក់ព័ន្ធនឹងភាពជាពលរដ្ឋតាមផ្លូវច្បាប់) លេខ ១៤/៨៣ ("នីតិវិធី ឆ្នាំ១៩៨៣ ដែលពាក់ព័ន្ធនឹងភាពជាពលរដ្ឋតាមផ្លូវច្បាប់") (ការបកប្រែមិនផ្លូវការ) និង នីតិវិធីដែលពាក់ព័ន្ធនឹងច្បាប់ស្តីពីភាពជាពលរដ្ឋរបស់ប្រទេសមីយ៉ាន់ម៉ា ឆ្នាំ១៩៨៣ (នីតិវិធី ឆ្នាំ១៩៨៣ ដែលពាក់ព័ន្ធនឹងភាពជាពលរដ្ឋដែលបានធ្វើសញ្ជាតូបនីយកម្ម) លេខ ១៥/៨៣ ("នីតិវិធី ឆ្នាំ១៩៨៣ ដែលពាក់ព័ន្ធនឹងភាពជាពលរដ្ឋដែលបានធ្វើសញ្ជាតូបនីយកម្ម") (ការបកប្រែមិនផ្លូវការ)។

410 សញ្ជាតូបនីយកម្ម – របាយការណ៍របស់ប្រទេសមីយ៉ាន់ម៉ា។

| ប្រទេស | អាជ្ញាធរមានសមត្ថកិច្ច | គោលការណ៍ | ច្បាប់ដែលអាចអនុវត្តបាន | បញ្ញត្តិ | | |
|---|---|---|---|---|---|---|
| | | | | ការទទួលបាន | ការបាត់បង់ | ការទទួលបានឡើងវិញ |
| | | | ការធ្វើមាតុភូមិនិវត្តន៍របស់ស្ត្រីហ្វីលីពីនដែលបានបាត់បង់ភាពជាពលរដ្ឋតាមរយៈការរៀបអាពាហ៍ពិពាហ៍ជាមួយជនបរទេស និង ពលរដ្ឋហ្វីលីពីនពីកំណើត) | | | |
| | | | ច្បាប់របស់សាធារណរដ្ឋលេខ ៩១៣៩ s. ២០០១ (ច្បាប់ស្តីពីសញ្ជាតូបនីយកម្មតាមផ្នែករដ្ឋបាល) | ផ្នែកទី២ និង ទី៣ | | |
| | | | ច្បាប់របស់សាធារណរដ្ឋលេខ ៩២២៥ s. ២០០៣ (ច្បាប់ដែលបង្កើតភាពពលរដ្ឋ របស់ពលរដ្ឋហ្វីលីពីនដែលទទួលបានភាពជាពលរដ្ឋបរទេសជាអចិន្ត្រៃយ៍ ដែលធ្វើវិសោធនកម្មដើម្បីគោលបំណងនៃច្បាប់របស់រដ្ឋសហធន លេខ ៦៣ ដែលដូចបានធ្វើវិសោធនកម្ម និង ដើម្បីគោលបំណងដទៃទៀត) | - | - | ផ្នែកទី៣ និង ទី៤ |
| **សិង្ហបុរី** | **ក្រសួងមហាផ្ទៃ** (អាជ្ញាធរអន្តោប្រវេសន៍ និង អាជ្ញាធរត្រួតពិនិត្យច្រកព្រំដែន) | *Jus sanguinis* និង *Jus soli* (មានលក្ខខណ្ឌ) | រដ្ឋធម្មនុញ្ញរបស់សាធារណរដ្ឋសិង្ហបុរី ឆ្នាំ១៩៦៥ (ផ្នែក X) | មាត្រា ១២១ ១២២ ១២៣ ១២៤ និង ១២៧ | មាត្រា ១២៨ ១២៩ ១៣០ ១៣១ ១៣២ ១៣៤ ១៣៥ និង ១៣៧ | គ្មាន |

| ប្រទេស | អាជ្ញាធរមានសមត្ថកិច្ច | គោលការណ៍ | ច្បាប់ដែលអាចអនុវត្តបាន | បញ្ញតិ | | |
|---|---|---|---|---|---|---|
| | | | | ការទទួលបាន | ការបាត់បង់ | ការទទួលបានឡើងវិញ |
| **ថៃ** | **ក្រសួងមហាផ្ទៃ** (នាយកដ្ឋានរដ្ឋបាលខេត្ត) | *Jus sanguinis* និង *Jus soli* (មានលក្ខខណ្ឌ) | ច្បាប់ស្តីពីសញ្ជាតិ ឆ្នាំ១៩៦៥ ដែលត្រូវបានធ្វើវិសោធនកម្មដោយច្បាប់លេខ ២ និង លេខ ៣ នៅក្នុងឆ្នាំ ១៩៩២ និង ច្បាប់លេខ ៤ នៅក្នុងឆ្នាំ២០០៨ និង ច្បាប់លេខ ៥ នៅក្នុងឆ្នាំ ២០១២ | មាត្រា ៧ ៩ ១០ ១១ ១២ និង ១២/១ | មាត្រា ១៣ ១៤ ១៦ ១៧ ១៨ ១៩ ២១ និង ២២ | មាត្រា ២៣ និង ២៤ |
| | | | ច្បាប់ស្តីពីសញ្ជាតិ លេខ ៤ ឆ្នាំ ២០០៨ | មាត្រា ២៣ | - | - |
| | | | ច្បាប់ស្តីពីការចុះបញ្ជីអត្រានុកូលដ្ឋាន លេខ ៣ ឆ្នាំ ២០១៩ | មាត្រា ១៩/២ កថាខណ្ឌទី ២ | - | - |
| **វៀតណាម** | **ក្រសួងយុត្តិធម៌** (នាយកដ្ឋានចុះបញ្ជីអត្រានុកូលដ្ឋាន សញ្ជាតិ និងយថាភូត) | *Jus sanguinis* និង *Jus soli* | ច្បាប់ស្តីពីសញ្ជាតិវៀតណាម ឆ្នាំ ២០០៨ (ច្បាប់លេខ ២៤/២០០៨/QH១២) ដូចត្រូវបានធ្វើវិសោធនកម្ម និង បំពេញបន្ថែមដោយច្បាប់លេខ ៥៦/២០១៤/QH១៣ | មាត្រា ១៣ ១៥ ១៦ ១៧ ១៨ ១៩ និង ២២ | មាត្រា ២៧ ៣១ និង ៣៣ | មាត្រា ២៣ |

### តារាងទី៤៖ ក្របខណ្ឌច្បាប់នៅក្នុងរដ្ឋសមាជិកអាស៊ាន ដែលពាក់ព័ន្ធនឹងការទទួលបានសញ្ជាតិដោយកូនដែលកើតពីពលរដ្ឋ

| ប្រទេស | កុមារកើតជាកូនរបស់ពលរដ្ឋនៅក្នុងប្រទេស | កុមារកើតជាកូនរបស់ពលរដ្ឋនៅក្រៅប្រទេស | កុមារកើតនៅក្នុងចំណងអាពាហ៍ពិពាហ៍ | កុមារកើតនៅក្រៅចំណងអាពាហ៍ពិពាហ៍ |
|---|---|---|---|---|
| ប្រ៊ុយណេដារូសាឡឹម | **ខចែង ៤(១)**<br>**[ដោយស្វ័យប្រវត្តិ]**<br>- កើតនៅក្នុងប្រទេសប្រ៊ុយណេ មុននៅ ឬ ក្រោយថ្ងៃដែលបានកំណត់ ឬ<br>- ឪពុកជាពលរដ្ឋប្រ៊ុយណេ។ | **ខចែង ៤(១)**<br>**[ដោយស្វ័យប្រវត្តិ]**<br>- កុមារកើតនៅក្រៅប្រទេសប្រ៊ុយណេ<br>- ឪពុកជាពលរដ្ឋប្រ៊ុយណេ<br>- ឪពុកធ្វើការនៅខាងប្រទេសប្រ៊ុយណេ ដើម្បីផ្តល់សេវាដល់រដ្ឋាភិបាល តាមរយៈក្រុមហ៊ុនណាមួយដែលបានចុះបញ្ជីនៅក្នុងប្រទេសប្រ៊ុយណេ។ | **ដូចគ្នានឹងខចែង ៤(១)**<br>**[ដោយស្វ័យប្រវត្តិ]**<br>- កុមារកើតនៅក្នុងប្រទេសប្រ៊ុយណេ<br>- ឪពុកជាពលរដ្ឋប្រ៊ុយណេ<br>ឬ<br>- កុមារកើតនៅក្រៅប្រទេសប្រ៊ុយណេ<br>- ឪពុកជាពលរដ្ឋប្រ៊ុយណេ<br>- ឪពុកធ្វើការនៅខាងប្រទេសប្រ៊ុយណេ ដើម្បីផ្តល់សេវាដល់រដ្ឋាភិបាល តាមរយៈក្រុមហ៊ុនណាមួយដែលបានចុះបញ្ជីនៅក្នុងប្រទេសប្រ៊ុយណេ។<br>**ខចែង ៦**<br>**[តាមឆន្ទានុសិទ្ធិ]**<br>- កូនដែលជាអនីតិជន<br>- ពាក្យស្នើសុំត្រូវបានធ្វើឡើងដោយឪពុក/ម្តាយ ឬ ឪពុក/ម្តាយចិញ្ចឹម ឬ អាណាព្យាបាល។ | មិនពាក់ព័ន្ធ |
| កម្ពុជា | **មាត្រា ៤(១)**<br>**[ដោយស្វ័យប្រវត្តិ]**<br>- ជាកុមារស្របច្បាប់ដែលកើតជាកូនរបស់ឪពុក/ម្តាយជាជនជាតិខ្មែរ ឬ ត្រូវបានទទួលស្គាល់ដោយឪពុក/ម្តាយជាជនជាតិខ្មែរ | **មាត្រា ៤(១)**<br>**[ដោយស្វ័យប្រវត្តិ]**<br>- ជាកុមារស្របច្បាប់ដែលកើតជាកូនរបស់ឪពុក/ម្តាយជាជនជាតិខ្មែរ ឬ ត្រូវបានទទួលស្គាល់ដោយឪពុក/ម្តាយជាជនជាតិខ្មែរ | **មាត្រា ៤(១)**<br>**[ដោយស្វ័យប្រវត្តិ]**<br>- ជាកុមារស្របច្បាប់ដែលកើតជាកូនរបស់ឪពុក/ម្តាយជាជនជាតិខ្មែរ | **មាត្រា ៤(១)**<br>**[ដោយស្វ័យប្រវត្តិ]**<br>- ជាកុមារស្របច្បាប់ដែលកើតជាកូនរបស់ឪពុក/ម្តាយជាជនជាតិខ្មែរ ឬ ត្រូវបានទទួលស្គាល់ដោយ ឪពុក/ម្តាយជាជនជាតិខ្មែរ។ |

| ប្រទេស | កុមារកើតជាកូនរបស់ពលរដ្ឋនៅក្នុងប្រទេស | កុមារកើតជាកូនរបស់ពលរដ្ឋនៅក្រៅប្រទេស | កុមារកើតនៅក្នុងចំណងអាពាហ៍ពិពាហ៍ | កុមារកើតនៅក្រៅចំណងអាពាហ៍ពិពាហ៍ |
|---|---|---|---|---|
| | ឬ<br>- មានសេចក្ដីសម្រេចរបស់តុលាការ ដែលបញ្ជាក់ថា កុមារនោះបានកើតជាកូនរបស់ឪពុក/ម្ដាយជាជនជាតិខ្មែរ។ | ឬ<br>- មានសេចក្ដីសម្រេចរបស់តុលាការ ដែលបញ្ជាក់ថា កុមារនោះបានកើតជាកូនរបស់ឪពុក/ម្ដាយជាជនជាតិខ្មែរ។ | | |
| ឥណ្ឌូនេស៊ី | ដូចគ្នានឹង **មាត្រា ៤(២)-(៨)**<br>និង<br>**មាត្រា ៤(១៣)**<br>**[ដោយស្វ័យប្រវត្តិ]**<br>- កើតជាកូនរបស់ឪពុកម្ដាយដែលបានទទួលភាពជាពលរដ្ឋឥណ្ឌូនេស៊ី និង បានស្លាប់មុនពេលធ្វើសច្ចាប្រណិធាន។ | **មាត្រា ៤(១២)**<br>**[ដោយស្វ័យប្រវត្តិ]**<br>- កើតជាកូនរបស់ឪពុកម្ដាយដែលជាពលរដ្ឋឥណ្ឌូនេស៊ីទាំងពីរនាក់ និង<br>- ឪពុកម្ដាយដែលជាពលរដ្ឋឥណ្ឌូនេស៊ីមិនអាចផ្ទេរសញ្ជាតិទៅឲ្យកូនបាននោះទេ ដោយសារច្បាប់ដែលនៅជាធរមាននៅក្នុងប្រទេសនៃកំណើត ដែលផ្ដល់ភាពជាពលរដ្ឋដល់កុមារម្នាក់នោះដោយស្វ័យប្រវត្តិ។ | **មាត្រា ៤(២)-(៦)**<br>**[ដោយស្វ័យប្រវត្តិ]**<br>- កើតជាកូនរបស់ឪពុកម្ដាយដែលជាពលរដ្ឋឥណ្ឌូនេស៊ីទាំងពីរនាក់<br>ឬ<br>- កើតជាកូនរបស់ឪពុកដែលជាពលរដ្ឋឥណ្ឌូនេស៊ី និង ម្ដាយជាជនបរទេស<br>ឬ<br>- កើតជាកូនរបស់ម្ដាយដែលជាពលរដ្ឋឥណ្ឌូនេស៊ី និង ឪពុកជាជនបរទេស<br>ឬ<br>- កើតជាកូនរបស់ម្ដាយដែលជាពលរដ្ឋឥណ្ឌូនេស៊ី និង ឪពុកជាជនគ្មានសញ្ជាតិ ឬជាជនបរទេស ដែលសញ្ជាតិរបស់ពួកគេមិនអាចផ្ទេរទៅកាន់កូនបានទេ<br>ឬ<br>- កើតជាកូនរបស់ឪពុកដែលជាពលរដ្ឋឥណ្ឌូនេស៊ី និង ម្ដាយជាជនបរទេស និង | **មាត្រា ៤(៧)-(៨)**<br>**[ដោយស្វ័យប្រវត្តិ]**<br>- កើតជាកូនរបស់ម្ដាយដែលជាពលរដ្ឋឥណ្ឌូនេស៊ី<br>ឬ<br>- កើតជាកូនរបស់ម្ដាយដែលជាជនបរទេស ដែលត្រូវបានអះអាងដោយឪពុកដែលជាពលរដ្ឋឥណ្ឌូនេស៊ី<br>- ការអះអាងនោះត្រូវបានប្រកាសមុនពេលដែលកូនមានវ័យ ១៨ ឆ្នាំ ឬ មុនពេលដែលកូនរៀបអាពាហ៍ពិពាហ៍។<br>**មាត្រា ៥**<br>**[ដោយស្វ័យប្រវត្តិ]**<br>- កើតជាកូនរបស់ឪពុកម្ដាយដែលជាពលរដ្ឋឥណ្ឌូនេស៊ីទាំងពីរនាក់<br>- មានអាយុក្រោម ១៨ ឆ្នាំ និង មិនទាន់រៀបអាពាហ៍ពិពាហ៍ និង<br>- មិនត្រូវបានសុំដោយស្របច្បាប់ដោយឪពុកដែលជាជនបរទេស។ |

| ប្រទេស | កុមារកើតជាកូនរបស់ពលរដ្ឋនៅក្នុងប្រទេស | កុមារកើតជាកូនរបស់ពលរដ្ឋនៅក្រៅប្រទេស | កុមារកើតនៅក្នុងចំណងអាពាហ៍ពិពាហ៍ | កុមារកើតនៅក្រៅចំណងអាពាហ៍ពិពាហ៍ |
|---|---|---|---|---|
| | | | - កើតជាកូននៅក្នុងរយៈពេល ៣០០ ថ្ងៃ បន្ទាប់ពីឪពុក ដែលជាពលរដ្ឋឥណ្ឌូនេស៊ី បានស្លាប់។ | សូមកត់សម្គាល់ថា សេចក្តីសម្រេចរបស់តុលាការរដ្ឋធម្មនុញ្ញ លេខ ៤៦PUU- VIII/២០១០ (បានធ្វើសេចក្តីសម្រេចនៅឆ្នាំ២០១២) បានសម្រេចចំពោះមាត្រា ៤៩(១) នៃច្បាប់អាពាហ៍ពិពាហ៍ "កុមារដែលកើតនៅក្រៅចំណងអាពាហ៍ពិពាហ៍មានទំនាក់ទំនងតាមផ្លូវច្បាប់នៃភាពជាពលរដ្ឋជាមួយម្តាយ និង គ្រួសាររបស់នាង និង ឪពុក និង គ្រួសាររបស់គាត់ ក្នុងលក្ខខណ្ឌដែលភាពជាឪពុកម្តាយអាចបញ្ជាក់តាមផ្នែកវិទ្យាសាស្ត្រ និង បច្ចេកវិទ្យា និង/ឬ ទម្រង់ណាមួយផ្សេងទៀតនៃភ័ស្តុតាង ដែលថា ឪពុកមានទំនាក់ទំនងសាច់ឈាមជាមួយកុមារម្នាក់នោះ"។ |
| ឡាវ | **មាត្រា ១០**<br>**[ដោយស្វ័យប្រវត្តិ]**<br>- កើតជាកូនរបស់ឪពុកម្តាយដែលមានសញ្ជាតិឡាវទាំងពីរនាក់<br><br>**មាត្រា ១១ កថាខណ្ឌទី ១(១)**<br>**[ដោយស្វ័យប្រវត្តិ]**<br>- កើតជាកូនរបស់ឪពុក/ម្តាយម្នាក់ដែលមានសញ្ជាតិឡាវ<br><br>**មាត្រា ១១ កថាខណ្ឌទី ៣**<br>**[ដោយស្វ័យប្រវត្តិ]** | **មាត្រា ១០**<br>**[ដោយស្វ័យប្រវត្តិ]**<br>- កើតជាកូនរបស់ឪពុកម្តាយដែលមានសញ្ជាតិឡាវទាំងពីរនាក់<br>**មាត្រា ១១ កថាខណ្ឌទី ១(២)**<br>**[ដោយស្វ័យប្រវត្តិ]**<br>- កើតជាកូនរបស់ឪពុក/ម្តាយម្នាក់ដែលមានសញ្ជាតិឡាវ និង<br>- យ៉ាងហោចឪពុក/ម្តាយម្នាក់មានអាសយដ្ឋានអចិន្ត្រៃយ៍នៅប្រទេសឡាវ។<br>**មាត្រា ១១ កថាខណ្ឌទី ២**<br>**[ដោយស្វ័យប្រវត្តិ]** | ដូចគ្នានឹង **មាត្រា ១០ និង ១១** | ដូចគ្នានឹង **មាត្រា ១០ និង ១១** |

| ប្រទេស | កុមារកើតជាកូនរបស់ពលរដ្ឋនៅក្នុងប្រទេស | កុមារកើតជាកូនរបស់ពលរដ្ឋនៅក្រៅប្រទេស | កុមារកើតនៅក្នុងចំណងអាពាហ៍ពិពាហ៍ | កុមារកើតនៅក្រៅចំណងអាពាហ៍ពិពាហ៍ |
|---|---|---|---|---|
| | - កើតជាកូនរបស់ឪពុក/ម្ដាយម្នាក់ដែលមានសញ្ជាតិឡាវ និង ឪពុក/ម្ដាយម្នាក់ទៀតជាជនគ្មានសញ្ជាតិ | - កើតជាកូនរបស់ឪពុក/ម្ដាយម្នាក់ដែលមានសញ្ជាតិឡាវ និង<br>- ឪពុកម្ដាយទាំងពីរនាក់មានអាសយដ្ឋានអចិន្ត្រៃយ៍នៅខាងក្រៅប្រទេសឡាវ និង<br>- ឪពុកម្ដាយធ្វើការសម្រេចចិត្តពាក់ព័ន្ធនឹងសញ្ជាតិរបស់កូន។<br>**មាត្រា ១១ កថាខណ្ឌទី ៣ [ដោយស្វ័យប្រវត្តិ]**<br>- កើតជាកូនរបស់ឪពុក/ម្ដាយម្នាក់ដែលមានសញ្ជាតិឡាវ និង ឪពុក/ម្ដាយម្នាក់ទៀតជាជនគ្មានសញ្ជាតិ | | |
| ម៉ាឡេស៊ី | **មាត្រា ១៤(១)(ក) + ខចែង ១(ខ) ផ្នែក I នៃឧបសម្ព័ន្ធទីពីរ [ដោយស្វ័យប្រវត្តិ]**<br>- កើតនៅក្នុងប្រទេសម៉ាឡេស៊ី នៅ ឬ នៅក្រោយថ្ងៃ Merdeka (ថ្ងៃទី៣១ ខែសីហា ឆ្នាំ១៩៥៧) និង មុនខែតុលា ឆ្នាំ១៩៦២<br>**មាត្រា ១៤(១)(ក) + ខចែង ១(គ) ផ្នែក I នៃឧបសម្ព័ន្ធទីពីរ [ដោយស្វ័យប្រវត្តិ]**<br>- កើតនៅក្នុងប្រទេសម៉ាឡេស៊ី នៅក្រោយខែកញ្ញា ឆ្នាំ១៩៦២ និង<br>- ឪពុក/ម្ដាយម្នាក់ជាពលរដ្ឋ ឬ មានទីលំនៅអចិន្ត្រៃយ៍នៅពេលកើត | **មាត្រា ១៤(១)(ក) + ខចែង១(ឃ) ផ្នែក I នៃឧបសម្ព័ន្ធទីពីរ [ដោយស្វ័យប្រវត្តិ]**<br>- កើតនៅក្រៅប្រទេស នៅ ឬ នៅក្រោយថ្ងៃ Merdeka<br>- មានឪពុកជាពលរដ្ឋម្នាក់ និង<br>- ឪពុកកើតនៅក្នុងប្រទេសម៉ាឡេស៊ី ឬ បម្រើសេវានៅក្រោមរដ្ឋាភិបាល។<br>**មាត្រា ១៤(១)(ក) + ខចែង ១(ង) ផ្នែក I នៃឧបសម្ព័ន្ធទីពីរ [ដោយស្វ័យប្រវត្តិ]**<br>- កើតនៅក្រៅប្រទេស នៅ ឬ នៅក្រោយថ្ងៃ Merdeka | ដូចគ្នានឹង **មាត្រា ១៤(១)** និង **មាត្រា ១៥(២)** | សូមកត់សម្គាល់ថា **ខចែង ១៧ ផ្នែក III នៃឧបសម្ព័ន្ធទីពីរ** បញ្ជាក់យ៉ាងច្បាស់ថា កុមារដែលកើតដោយមិនស្របច្បាប់នៅក្នុងប្រទេសម៉ាឡេស៊ីមិនមែនជាពលរដ្ឋរបស់ប្រទេសម៉ាឡេស៊ីនោះទេ លើកលែងតែម្ដាយរបស់កុមារម្នាក់នោះជាពលរដ្ឋម៉ាឡេស៊ី។ |

| ប្រទេស | កុមារកើតជាកូនរបស់ពលរដ្ឋនៅក្នុងប្រទេស | កុមារកើតជាកូនរបស់ពលរដ្ឋនៅក្រៅប្រទេស | កុមារកើតនៅក្នុងចំណងអាពាហ៍ពិពាហ៍ | កុមារកើតនៅក្រៅចំណងអាពាហ៍ពិពាហ៍ |
|---|---|---|---|---|
| | **មាត្រា ១៤(១)(ខ) + ឧបែង ១(ក) ផ្នែក II នៃឧបសម្ព័ន្ធទីពីរ [ដោយស្វ័យប្រវត្តិ]**<br>- កើតនៅក្នុងប្រទេសម៉ាឡេស៊ី នៅ ឬនៅក្រោយទិវាជាតិម៉ាឡេស៊ី (ថ្ងៃទី ១៦ ខែកញ្ញា ឆ្នាំ១៩៥៧) និង<br>- ឪពុក/ម្ដាយម្នាក់ជាពលរដ្ឋ ឬ មាន ទីលំនៅអចិន្ត្រៃយ៍នៅពេលកើត។<br><br>**មាត្រា ១៥(២) – ភាពជាពលរដ្ឋតាមរយៈការចុះបញ្ជី (ភរិយា និងកូនរបស់ពលរដ្ឋ) [តាមឆន្ទានុសិទ្ធិ]**<br>- មានអាយុក្រោម ២១ ឆ្នាំ និង<br>- មានឪពុក/ម្ដាយម្នាក់ (ឬនៅពេលស្លាប់) ជាពលរដ្ឋម៉ាឡេស៊ី។ | - មានឪពុកជាពលរដ្ឋម្នាក់ និង<br>- កំណើត (រួមបញ្ចូលទាំងកំណើតដែលកើតឡើងនៅក្នុងប្រទេសសិង្ហបុរី Sarawak ប្រទេសប្រ៊ុយណេ ឬ បរណេអូភាគខាងជើងផងដែរ) ត្រូវបានចុះបញ្ជីនៅក្នុងប្រទេសម៉ាឡេស៊ី ក្នុងរយៈពេលមួយឆ្នាំ ឬ យូរជាងនេះ ប្រសិនបើមានការអនុញ្ញាត។<br><br>**មាត្រា ១៤(១)(ក) + ឧបែង ២ ផ្នែក I នៃឧបសម្ព័ន្ធទីពីរ [ដោយស្វ័យប្រវត្តិ]**<br>- ជាពលរដ្ឋនៃចក្រភពអង់គ្លេស និងប្រទេសអាណានិគមមុនទិវាជាតិម៉ាឡេស៊ី<br>- ជានិវាសនជននៅក្នុងរដ្ឋសាបា ឬ Sarawak ឬប្រទេសប្រ៊ុយណេនៅថ្ងៃទិវាជាតិម៉ាឡេស៊ី និង<br>- បានកើតនៅលើដែនដីនានា ដែលរួមមានរដ្ឋសាបា ឬ Sarawak ឬ ក្លាយជាពលរដ្ឋរបស់រដ្ឋទាំងនោះ តាមរយៈការចុះបញ្ជីនៅលើដែនដីទាំងនោះ ឬ តាមរយៈលទ្ធផលនៃសញ្ញាតូបនីយកម្មនៅទីនោះ។ | | |

| ប្រទេស | កុមារកើតជាកូនរបស់ពលរដ្ឋនៅក្នុងប្រទេស | កុមារកើតជាកូនរបស់ពលរដ្ឋនៅក្រៅប្រទេស | កុមារកើតនៅក្នុងចំណងអាពាហ៍ពិពាហ៍ | កុមារកើតនៅក្រៅចំណងអាពាហ៍ពិពាហ៍ |
|---|---|---|---|---|
| | | **មាត្រា ១៤(១)(ខ) + ឧបែង ១(ខ) និង ឧបែង ២(២) ផ្នែក II នៃឧបសម្ព័ន្ធទីពីរ [ដោយស្វ័យប្រវត្តិ]**<br>- កើតនៅក្រៅប្រទេស នៅ ឬ នៅក្រោយទិវាជាតិម៉ាឡេស៊ី<br>- មានឪពុកជាពលរដ្ឋម្នាក់ និង<br>- ឪពុកកើតនៅក្នុងប្រទេសម៉ាឡេស៊ី ឬ បម្រើសេវាដែលស្ថិតនៅក្រោមរដ្ឋាភិបាល ឬ<br>- កើតមុនទិវាជាតិម៉ាឡេស៊ីនៅលើដែនដីនានា ដែលរួមមាន រដ្ឋសាបា ឬ Sarawak<br>- មានឪពុកជាពលរដ្ឋម្នាក់ និង<br>- ឪពុកកើតនៅក្នុងប្រទេសម៉ាឡេស៊ី ឬ បម្រើសេវាដែលស្ថិតនៅក្រោមរដ្ឋាភិបាល<br>**មាត្រា ១៤(១)(ខ) + ឧបែង ១(គ) ផ្នែក II នៃឧបសម្ព័ន្ធទីពីរ [ដោយស្វ័យប្រវត្តិ]**<br>- កើតនៅក្រៅប្រទេស នៅ ឬ នៅក្រោយទិវាជាតិម៉ាឡេស៊ី<br>- មានឪពុកជាពលរដ្ឋម្នាក់ និង<br>- កំណើត (រួមបញ្ចូលទាំងកំណើតដែលកើតឡើងនៅក្នុងប្រទេសប្រ៊ុយណេ ឬ នៅលើដែនដីដែលត្រូវបានបញ្ញត្តិសម្រាប់គោលបំណងនេះ តាមការបញ្ជារបស់ | | |

| ប្រទេស | កុមារកើតជាកូនរបស់ពលរដ្ឋនៅក្នុងប្រទេស | កុមារកើតជាកូនរបស់ពលរដ្ឋនៅក្រៅប្រទេស | កុមារកើតនៅក្នុងចំណងអាពាហ៍ពិពាហ៍ | កុមារកើតនៅក្រៅចំណងអាពាហ៍ពិពាហ៍ |
|---|---|---|---|---|
| | | Yang di-Pertuan Agong) ត្រូវបានចុះបញ្ជីនៅស្ថានកុងស៊ុល ឬ នៅក្នុងប្រទេសម៉ាឡេស៊ី ក្នុងរយៈពេលមួយឆ្នាំ ឬ យូរជាងនេះ ប្រសិនបើមានការអនុញ្ញាត។<br><br>**មាត្រា ១៤(១)(ខ) + ខចែង ១(ឃ) ផ្នែក II នៃឧបសម្ព័ន្ធទីពីរ**<br>**[ដោយស្វ័យប្រវត្តិ]**<br>- កើតនៅក្នុងប្រទេសសិង្ហបុរី[411] នៅ ឬ នៅក្រោយទិវាជាតិម៉ាឡេស៊ី<br>- ឪពុក/ម្ដាយម្នាក់ជាពលរដ្ឋ ឬ ជានិវាសនជនអចិន្ត្រៃយ៍នៅពេលកើត និង<br>- មិនមែនជាពលរដ្ឋដោយសារមូលហេតុផ្សេងពីកថាខណ្ឌនេះនោះទេ។<br><br>**មាត្រា ១៥(២)– ភាពជាពលរដ្ឋតាមរយៈការចុះបញ្ជី (ភរិយា និង កូនរបស់ពលរដ្ឋ)**<br>**[តាមឆន្ទានុសិទ្ធិ]**<br>- មានអាយុក្រោម ២១ ឆ្នាំ និង<br>- មានឪពុក/ម្ដាយម្នាក់ (ឬនៅពេលស្លាប់) ជាពលរដ្ឋម៉ាឡេស៊ី។ | | |

411 ប្រទេសសិង្ហបុរីទទួលបានឯករាជ្យពីប្រទេសម៉ាឡេស៊ីនៅថ្ងៃទី០៩ ខែសីហា ឆ្នាំ១៩៦៥។

| ប្រទេស | កុមារកើតជាកូនរបស់ពលរដ្ឋនៅក្នុងប្រទេស | កុមារកើតជាកូនរបស់ពលរដ្ឋនៅក្រៅប្រទេស | កុមារកើតនៅក្នុងចំណងអាពាហ៍ពិពាហ៍ | កុមារកើតនៅក្រៅចំណងអាពាហ៍ពិពាហ៍ |
|---|---|---|---|---|
| **មីយ៉ាន់ម៉ា** | **ភាពជាពលរដ្ឋ (ពេញលេញ)**<br>**មាត្រា ៣**<br>- ជាសមាជិករបស់ក្រុមជាតិពន្ធ Kachin, Kayah, Karen, Chin, Buramn, Mon, Rakhine ឬ Shan និង<br>- មានទីលំនៅអចិន្ត្រៃយ៍នៅក្នុងប្រទេសមីយ៉ាន់ម៉ា មុនឆ្នាំ១៨២៣។<br>**មាត្រា ៧**<br>**[ដោយស្វ័យប្រវត្តិ]**<br>- កើតនៅក្នុងប្រទេសមីយ៉ាន់ម៉ា ឬ នៅក្រៅប្រទេស ដែលមានឪពុកម្តាយទាំងពីរនាក់ជាពលរដ្ឋ<br>ឬ<br>- កើតនៅក្នុងប្រទេសមីយ៉ាន់ម៉ា ឬ នៅក្រៅប្រទេស ជាកូនរបស់ពលរដ្ឋ និងពលរដ្ឋតាមច្បាប់<br>ឬ<br>- កើតនៅក្នុងប្រទេសមីយ៉ាន់ម៉ា ឬ នៅក្រៅប្រទេស ជាកូនរបស់ពលរដ្ឋ និងពលរដ្ឋដែលបានធ្វើសញ្ជាតូបនីយកម្ម<br>ឬ | ដូចគ្នានឹង**មាត្រា ៧ និង មាត្រា ៨** | ដូចគ្នានឹង**មាត្រា ៧ និង មាត្រា ៨** | ដូចគ្នានឹង**មាត្រា ៧ និង មាត្រា ៨** |

| ប្រទេស | កុមារកើតជាកូនរបស់ពលរដ្ឋនៅក្នុងប្រទេស | កុមារកើតជាកូនរបស់ពលរដ្ឋនៅក្រៅប្រទេស | កុមារកើតនៅក្នុងចំណងអាពាហ៍ពិពាហ៍ | កុមារកើតនៅក្រៅចំណងអាពាហ៍ពិពាហ៍ |
|---|---|---|---|---|
| | - កើតនៅក្នុងប្រទេសមីយ៉ាន់ម៉ា ឬ នៅក្រៅប្រទេស ដែលម្នាក់ចំណោមឪពុកម្តាយរបស់ពួកគេជាពលរដ្ឋ ឬ ពលរដ្ឋតាមច្បាប់ ឬ ពលរដ្ឋ ដែលបានធ្វើសញ្ជាតូបនីយកម្ម និង<br>- ឪពុក/ម្តាយម្នាក់ទៀតជាកូនដែលមានឪពុកម្តាយទាំងពីរនាក់ជាពលរដ្ឋតាមច្បាប់<br><br>ឬ<br>- កើតនៅក្នុងប្រទេសមីយ៉ាន់ម៉ា ឬ នៅក្រៅប្រទេស ដែលម្នាក់ចំណោមឪពុកម្តាយរបស់ពួកគេជាពលរដ្ឋ ឬ ពលរដ្ឋតាមច្បាប់ ឬ ពលរដ្ឋ ដែលបានធ្វើសញ្ជាតូបនីយកម្ម និង<br>- ឪពុក/ម្តាយម្នាក់ទៀតជាកូនដែលមានឪពុកម្តាយទាំងពីរនាក់ជាពលរដ្ឋដែលបានធ្វើសញ្ជាតូប-នីយកម្ម<br><br>ឬ<br>- កើតនៅក្នុងប្រទេសមីយ៉ាន់ម៉ា ឬ នៅក្រៅប្រទេស ដែលម្នាក់ចំណោមឪពុកម្តាយរបស់ពួកគេជាពលរដ្ឋ ឬ ពលរដ្ឋតាមច្បាប់ ឬ ពលរដ្ឋ ដែលបានធ្វើសញ្ជាតូបនីយកម្ម និង<br>- ឪពុក/ម្តាយម្នាក់ទៀតជាកូនរបស់ពលរដ្ឋតាមច្បាប់ ឬ ពលរដ្ឋដែលបានធ្វើសញ្ជាតូបនីយកម្ម។ | | | |

| ប្រទេស | កុមារកើតជាកូនរបស់ពលរដ្ឋនៅក្នុងប្រទេស | កុមារកើតជាកូនរបស់ពលរដ្ឋនៅក្រៅប្រទេស | កុមារកើតនៅក្នុងចំណងអាពាហ៍ពិពាហ៍ | កុមារកើតនៅក្រៅចំណងអាពាហ៍ពិពាហ៍ |
|---|---|---|---|---|
| | **ភាពជាពលរដ្ឋតាមច្បាប់**<br>**មាត្រា ២៣**<br>**[តាមឆន្ទានុសិទ្ធិ]**<br>- បានដាក់ពាក្យស្នើសុំភាពជាពលរដ្ឋ ស្របតាមច្បាប់ស្តីពីភាពជាពលរដ្ឋ ឆ្នាំ១៩៤៨ មុនថ្ងៃទី ១៥ ខែតុលា ឆ្នាំ១៩៨២ និង<br>- មិនទទួលបានសេចក្តីសម្រេចណាមួយចំពោះពាក្យស្នើសុំរបស់ពួកគេនោះទេ<br>- អ្នកដាក់ពាក្យស្នើសុំភាពជាពលរដ្ឋស្របតាមច្បាប់ស្តីពីភាពជាពលរដ្ឋរបស់សហភាព អនុវត្តតាម ខចែង និង លក្ខណៈសម្បត្តិដែលអាចត្រូវបានកំណត់ថាជាពលរដ្ឋតាមច្បាប់ ដោយអង្គភាពកណ្តាល។[412]<br>**មាត្រា ៨(ក)**<br>**[តាមឆន្ទានុសិទ្ធិ]**<br>ក្រុមប្រឹក្សារដ្ឋ ដើម្បីអត្ថប្រយោជន៍របស់រដ្ឋ អាចផ្តល់ភាពជាពលរដ្ឋ ឬ ភាពជាពលរដ្ឋតាមច្បាប់ ឬ ភាពជាពលរដ្ឋដែលបានធ្វើសញ្ជាតូបនីយកម្ម ដល់នរណាម្នាក់ | | | |
| **ហ្វីលីពីន** | **មាត្រា ១(១)**<br>- ជាពលរដ្ឋហ្វីលីពីន ស្របតាមរដ្ឋធម្មនុញ្ញឆ្នាំ ១៩៣៥ និង ១៩៧៣ | ដូចគ្នានឹង **មាត្រា ១(១)-(៣)** | ដូចគ្នានឹង **មាត្រា ១(១)-(៣)** | ដូចគ្នានឹង **មាត្រា ១(១)-(៣)** |

412 ព័ត៌មានដែលមានបច្ចុប្បន្នភាពត្រូវបានផ្តល់ជូនដោយជនបង្គោលនៃប្រទេសមីយ៉ាន់ម៉ា។

| ប្រទេស | កុមារកើតជាកូនរបស់ពលរដ្ឋនៅក្នុងប្រទេស | កុមារកើតជាកូនរបស់ពលរដ្ឋនៅក្រៅប្រទេស | កុមារកើតនៅក្នុងចំណងអាពាហ៍ពិពាហ៍ | កុមារកើតនៅក្រៅចំណងអាពាហ៍ពិពាហ៍ |
|---|---|---|---|---|
| | **មាត្រា ១(២)**<br>- មានឪពុក/ម្តាយម្នាក់ជាពលរដ្ឋហ្វីលីពីន<br>**មាត្រា ១(៣)**<br>- កើតមុនថ្ងៃទី១៧ ខែមករា ឆ្នាំ១៩៧៣ មានម្តាយជាពលរដ្ឋហ្វីលីពីន និង ឪពុកជាជនបរទេស និង<br>- បានជ្រើសរើសភាពជាពលរដ្ឋហ្វីលីពីន នៅពេលពេញវ័យ។ | | | |
| សិង្ហបុរី | **មាត្រា ១២១**<br>**[ដោយស្វ័យប្រវត្តិ]**<br>- កើតនៅប្រទេសសិង្ហបុរី ក្រោយថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ១៩៦៣<br>- មានឪពុក (ដែលបានរៀបអាពាហ៍ពិពាហ៍ស្របច្បាប់ជាមួយម្តាយ) ឬ ម្តាយដែលជាពលរដ្ឋសិង្ហបុរី។<br><br>**មាត្រា ១២៤**<br>**[តាមឆន្ទានុសិទ្ធិ]**<br>- មានអាយុក្រោម ២១ ឆ្នាំ និង<br>- ជាកូនរបស់ពលរដ្ឋសិង្ហបុរី និង<br>- កំពុងស្នាក់នៅក្នុងប្រទេសសិង្ហបុរី | **មាត្រា ១២២(១)(ក) + មាត្រា ១២២(២)**<br>**[ដោយស្វ័យប្រវត្តិ]**<br>- កើតនៅក្រៅប្រទេសសិង្ហបុរី ក្រោយថ្ងៃទី ១៦ ខែកញ្ញា ឆ្នាំ១៩៦៣ ប៉ុន្តែមុនថ្ងៃទី ១៥ ខែឧសភា ឆ្នាំ២០០៤ (កាលបរិច្ឆេទចាប់ផ្តើមនៃខចែងទី ៧ របស់រដ្ឋធម្មនុញ្ញ (វិសោធនកម្ម) ច្បាប់ ឆ្នាំ២០០៤)<br>- មានឪពុកជាពលរដ្ឋសិង្ហបុរីពីកំណើត ឬ តាមរយៈការចុះបញ្ជី និង បានរៀបអាពាហ៍ពិពាហ៍ដោយស្របច្បាប់ជាមួយម្តាយ<br>- បានចុះបញ្ជីកំណើតតាមរយៈបេសកកម្មការទូត ឬ បេសកកម្មកុងស៊ុលរបស់ប្រទេសសិង្ហបុរី ក្នុងរយៈពេល ១ ឆ្នាំ ឬ យូរជាងនេះ ប្រសិនបើរដ្ឋាភិបាលអនុញ្ញាត និង | **មាត្រា ១២២(១)(ក) + មាត្រា ១២២(២)**<br>**[ដោយស្វ័យប្រវត្តិ]**<br>- កើតនៅក្រៅប្រទេសសិង្ហបុរី ក្រោយថ្ងៃទី ១៦ ខែកញ្ញា ឆ្នាំ១៩៦៣ ប៉ុន្តែមុនថ្ងៃទី ១៥ ខែឧសភា ឆ្នាំ២០០៤ (កាលបរិច្ឆេទចាប់ផ្តើមនៃខចែងទី ៧ របស់រដ្ឋធម្មនុញ្ញ (វិសោធនកម្ម) ច្បាប់ ឆ្នាំ២០០៤)<br>- មានឪពុកជាពលរដ្ឋសិង្ហបុរីពីកំណើត ឬ តាមរយៈការចុះបញ្ជី និង បានរៀបអាពាហ៍ពិពាហ៍ដោយស្របច្បាប់ជាមួយម្តាយ<br>- បានចុះបញ្ជីកំណើតតាមរយៈបេសកកម្មការទូត ឬ បេសកកម្មកុងស៊ុលរបស់ប្រទេសសិង្ហបុរី ក្នុងរយៈពេល ១ ឆ្នាំ ឬ យូរជាងនេះ ប្រសិនបើរដ្ឋាភិបាលអនុញ្ញាត និង | សូមកត់សម្គាល់ថា **ខចែង ១៥(១) ឧបសម្ព័ន្ធទីបី** បញ្ជាក់យ៉ាងច្បាស់ថា កុមារដែលកើតដោយមិនស្របច្បាប់នៅក្នុងប្រទេសសិង្ហបុរីមិនមែនជាពលរដ្ឋរបស់ប្រទេសសិង្ហបុរីនោះទេ លើកលែងតែម្តាយរបស់កុមារម្នាក់នោះជាពលរដ្ឋសិង្ហបុរី។ |

| ប្រទេស | កុមារកើតជាកូនរបស់ពលរដ្ឋនៅក្នុងប្រទេស | កុមារកើតជាកូនរបស់ពលរដ្ឋនៅក្រៅប្រទេស | កុមារកើតនៅក្នុងចំណងអាពាហ៍ពិពាហ៍ | កុមារកើតនៅក្រៅចំណងអាពាហ៍ពិពាហ៍ |
|---|---|---|---|---|
| | | - មិនបានទទួលភាពជាពលរដ្ឋនៃប្រទេសដែលគាត់កើត។<br><br>**មាត្រា ១២២(១)(ខ) + មាត្រា ១២២(២) [ដោយស្វ័យប្រវត្តិ]**<br>- កើតនៅក្រៅប្រទេសសិង្ហបុរី ក្រោយថ្ងៃទី ១៦ ខែកញ្ញា ឆ្នាំ១៩៦៣ ប៉ុន្តែ នៅ ឬ នៅមុនថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០០៤<br>- មានឪពុក ឬ ម្តាយជាពលរដ្ឋសិង្ហបុរីពីកំណើត ឬតាមរយៈការចុះបញ្ជី ឬ តាមដើមកំណើត<br>- បានចុះបញ្ជីកំណើតតាមរយៈបេសកកម្មការទូត ឬ បេសកកម្មកុងស៊ុលរបស់ប្រទេសសិង្ហបុរី ក្នុងរយៈពេល ១ ឆ្នាំ ឬ យូរជាងនេះ ប្រសិនបើរដ្ឋាភិបាលអនុញ្ញាត និង<br>- មិនបានទទួលភាពជាពលរដ្ឋនៃប្រទេសដែលគាត់កើត។<br><br>**មាត្រា ១២២(១)(ខ) + មាត្រា ១២២(៣) [ដោយស្វ័យប្រវត្តិ]** | - មិនបានទទួលភាពជាពលរដ្ឋនៃប្រទេសដែលគាត់កើត។<br><br>**មាត្រា ១២១ [ដោយស្វ័យប្រវត្តិ]**<br>- កើតនៅក្នុងប្រទេសសិង្ហបុរី ក្រោយថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ១៩៦៣<br>- មានឪពុក (ដែលបានរៀបអាពាហ៍ពិពាហ៍ស្របច្បាប់ជាមួយម្តាយ) ឬ ម្តាយដែលជាពលរដ្ឋសិង្ហបុរី<br>- ឪពុក និង ម្តាយបានរៀបអាពាហ៍ពិពាហ៍តាមផ្លូវច្បាប់។ | |

| ប្រទេស | កុមារកើតជាកូនរបស់ពលរដ្ឋនៅក្នុងប្រទេស | កុមារកើតជាកូនរបស់ពលរដ្ឋនៅក្រៅប្រទេស | កុមារកើតនៅក្នុងចំណងអាពាហ៍ពិពាហ៍ | កុមារកើតនៅក្រៅចំណងអាពាហ៍ពិពាហ៍ |
|---|---|---|---|---|
| | | - កើតនៅក្រៅប្រទេសសិង្ហបុរី<br>- មានឪពុក ឬ ម្តាយដែលជាពលរដ្ឋតាមដើមកំណើត និង<br>- ឪពុក/ម្តាយដែលជាពលរដ្ឋសិង្ហបុរីមានរយៈពេលស្នាក់នៅសរុបចំនួន ៥ ឆ្នាំ នៅក្នុងប្រទេសសិង្ហបុរី មុនពេលដែលកុមារកើត។<br><br>ឬ<br>- កើតនៅក្រៅប្រទេសសិង្ហបុរី<br>- មានឪពុក ឬ ម្តាយដែលជាពលរដ្ឋតាមដើមកំណើត និង<br>- ឪពុក/ម្តាយដែលជាពលរដ្ឋសិង្ហបុរីមានរយៈពេលស្នាក់នៅសរុបចំនួន ២ ឆ្នាំ នៅក្នុងរយៈពេល ៥ ឆ្នាំចុងក្រោយភ្លាមៗ មុនពេលដែលកុមារកើត។<br><br>**មាត្រា ១២៤**<br>**[តាមឆន្ទានុសិទ្ធិ]**<br>- មានអាយុក្រោម ២១ ឆ្នាំ<br>- ជាកូនរបស់ពលរដ្ឋសិង្ហបុរី និង<br>- កំពុងស្នាក់នៅក្នុងប្រទេសសិង្ហបុរី។ | | |

| ប្រទេស | កុមារកើតជាកូនរបស់ពលរដ្ឋនៅក្នុងប្រទេស | កុមារកើតជាកូនរបស់ពលរដ្ឋនៅក្រៅប្រទេស | កុមារកើតនៅក្នុងចំណងអាពាហ៍ពិពាហ៍ | កុមារកើតនៅក្រៅចំណងអាពាហ៍ពិពាហ៍ |
|---|---|---|---|---|
| ថៃ | **ខចែង ៧(១)**<br>**[ដោយស្វ័យប្រវត្តិ]**<br>- កើតជាកូនរបស់ឪពុក ឬ ម្តាយដែលជាពលរដ្ឋថៃ<br><br>**ខចែង ៩/៦**<br>**[ដោយស្វ័យប្រវត្តិ]**<br>- ត្រូវបានទទួលស្គាល់ថាជាពលរដ្ឋថៃដែលបានភៀសខ្លួន ដោយគណៈកម្មាធិការ<br><br>ឬ<br>- កើតជាកូនរបស់អ្នកដែលត្រូវបានគេទទួលស្គាល់ថាជាពលរដ្ឋថៃដែលបានភៀសខ្លួន ដោយគណៈកម្មាធិការ និង<br>- គ្មានសញ្ជាតិដទៃទៀត។<br><br>**ខចែង ៩/៧**<br>**[ដោយស្វ័យប្រវត្តិ]**<br>- ជាកូនរបស់ពលរដ្ឋថៃដែលបានផ្លាស់ប្តូរទីលំនៅ និង<br>- បានទទួលសញ្ជាតិថៃ ពីព្រោះឪពុកម្តាយរបស់គាត់ត្រូវបានគេទទួលស្គាល់ថាជាពលរដ្ឋថៃដែលបានភៀសខ្លួន។ | ដូចគ្នានឹង **ខចែង ៧(១) ៩/៦ និង ៩/៧ ដែរ** | ដូចគ្នានឹង **ខែចង ៧(១) ៩/៦ និង ៩/៧ ដែរ** | **ខចែង ៧(១) កថាខណ្ឌទី២**<br>**[ដោយស្វ័យប្រវត្តិ]**<br>- កើតជាកូនបង្កើតរបស់ឪពុកដែលជាពលរដ្ឋថៃ<br>- ឪពុកត្រូវតែមានការបញ្ជាក់អះអាងថាបានអនុលោមតាមបទប្បញ្ញត្តិរបស់ក្រសួង។ |

| ប្រទេស | កុមារកើតជាកូនរបស់ពលរដ្ឋនៅក្នុងប្រទេស | កុមារកើតជាកូនរបស់ពលរដ្ឋនៅក្រៅប្រទេស | កុមារកើតនៅក្នុងចំណងអាពាហ៍ពិពាហ៍ | កុមារកើតនៅក្រៅចំណងអាពាហ៍ពិពាហ៍ |
|---|---|---|---|---|
| វៀតណាម | **មាត្រា ១៣(២)**<br>**[ដោយស្វ័យប្រវត្តិ]**<br>- ជាពលរដ្ឋវៀតណាមដែលរស់នៅក្រៅប្រទេស និង មិនទាន់បានបាត់បង់សញ្ជាតិវៀតណាម និង<br>- ដាក់ការចុះបញ្ជីជូនបេសកកម្មតំណាងឲ្យជនជាតិវៀតណាមនៅក្រៅប្រទេស។<br><br>**មាត្រា ១៥**<br>**[ដោយស្វ័យប្រវត្តិ]**<br>- កើតនៅក្នុងប្រទេសវៀតណាម និង<br>- មានឪពុកម្តាយទាំងពីរនាក់ជាពលរដ្ឋវៀតណាម។<br><br>**មាត្រា ១៦**<br>**[ដោយស្វ័យប្រវត្តិ]**<br>- កើតនៅក្នុងប្រទេសវៀតណាម និង<br>- មានឪពុកម្តាយម្នាក់ជាពលរដ្ឋ និង ម្នាក់ទៀតជាជនគ្មានសញ្ជាតិ<br>ឬ<br>- កើតនៅក្នុងប្រទេសវៀតណាម និង<br>- មានម្តាយជាពលរដ្ឋ និង មិនស្គាល់ឪពុក<br>ឬ | **មាត្រា ១៣(២)**<br>**[ដោយស្វ័យប្រវត្តិ]**<br>- ជាពលរដ្ឋវៀតណាមដែលរស់នៅក្រៅប្រទេស និង មិនទាន់បានបាត់បង់សញ្ជាតិវៀតណាម និង<br>- ដាក់ការចុះបញ្ជីជូនបេសកកម្មតំណាងឲ្យជនជាតិវៀតណាមនៅក្រៅប្រទេស។<br><br>**មាត្រា ១៥**<br>**[ដោយស្វ័យប្រវត្តិ]**<br>- កើតនៅក្រៅប្រទេស និង<br>- មានឪពុកម្តាយទាំងពីរនាក់ជាពលរដ្ឋវៀតណាម។<br><br>**មាត្រា ១៦**<br>**[ដោយស្វ័យប្រវត្តិ]**<br>- កើតនៅក្រៅប្រទេស និង<br>- មានឪពុកម្តាយម្នាក់ជាពលរដ្ឋ និង ម្នាក់ទៀតជាជនគ្មានសញ្ជាតិ<br>ឬ<br>- កើតនៅក្រៅប្រទេស និង<br>- មានម្តាយជាពលរដ្ឋ និង មិនស្គាល់ឪពុក<br>ឬ | ដូចគ្នានឹង**មាត្រា ១៣(២) ១៥ និង ១៦** | ដូចគ្នានឹង**មាត្រា ១៣(២) ១៥ និង ១៦** |

| ប្រទេស | កុមារកើតជាកូនរបស់ពលរដ្ឋនៅក្នុងប្រទេស | កុមារកើតជាកូនរបស់ពលរដ្ឋនៅក្រៅប្រទេស | កុមារកើតនៅក្នុងចំណងអាពាហ៍ពិពាហ៍ | កុមារកើតនៅក្រៅចំណងអាពាហ៍ពិពាហ៍ |
|---|---|---|---|---|
| | - កើតនៅក្នុងប្រទេសវៀតណាម<br>- មានឪពុកម្ដាយម្នាក់ជាពលរដ្ឋ និងម្នាក់ទៀតជាជនបរទេស<br>- ឪពុកម្ដាយព្រមព្រៀងជាលាយលក្ខណ៍អក្សរថាកុមារនោះមានសញ្ជាតិវៀតណាម (ប្រសិនបើឪពុកម្ដាយមិនអាចព្រមព្រៀងគ្នាបានទេនោះ កុមារត្រូវមានសញ្ជាតិវៀតណា | - កើតនៅក្រៅប្រទេស<br>- មានឪពុកម្ដាយម្នាក់ជាពលរដ្ឋ និងម្នាក់ទៀតជាជនបរទេស<br>- ឪពុកម្ដាយព្រមព្រៀងជាលាយលក្ខណ៍អក្សរថាកុមារនោះមានសញ្ជាតិវៀតណាម។ | | |

## តារាងទី៥៖ ក្របខណ្ឌច្បាប់នៅក្នុងរដ្ឋសមាជិកអាស៊ាន ពាក់ព័ន្ធនឹងការទទួលបានសញ្ជាតិរបស់កុមារបាត់ខ្លួន និង កូនស្មុំ

| ប្រទេស | កុមារបាត់ខ្លួន/កូនស្មុំ |
|---|---|
| ប្រ៊ុយណេ ដារូសាឡឹម | **ខចែងទី ៦**<br>**[តាមឆន្ទានុសិទ្ធិ]**<br>- កូនដែលជាអនីតិជន និង<br>- ពាក្យស្នើសុំត្រូវបានធ្វើឡើងដោយឪពុក/ម្ដាយម្នាក់ ឬ ឪពុក/ម្ដាយចិញ្ចឹម ឬ អាណាព្យាបាល។ |
| កម្ពុជា | **មាត្រា ៤(២)**<br>**[ដោយស្វ័យប្រវត្តិ]**<br>- កើតនៅក្នុងប្រទេសកម្ពុជា និង<br>- មិនស្គាល់ម្ដាយ ឬ ឪពុក។<br>សូមកត់សម្គាល់ថា កុមារដែលទើបនឹងកើត ដែលត្រូវបានរកឃើញនៅក្នុងប្រទេសកម្ពុជា ត្រូវបានចាត់ទុកថាបានកើតនៅក្នុងប្រទេសកម្ពុជា។ |
| ឥណ្ឌូនេស៊ី | **មាត្រា ៤(១០)**<br>**[ដោយស្វ័យប្រវត្តិ]**<br>- ជាកុមារទើបនឹងកើត<br>- ត្រូវបានរកឃើញនៅក្នុងប្រទេសឥណ្ឌូនេស៊ី និង<br>- ជាកូនដែលយើងមិនអាចកំណត់ឪពុកម្ដាយរបស់ពួកគេបាន។<br><br>**មាត្រា ២១(២)**<br>**[តាមឆន្ទានុសិទ្ធិ]**<br>- ជាកុមារដែលមានសញ្ជាតិបរទេស មានអាយុក្រោម ៥ ឆ្នាំ<br>- ត្រូវបានស្មុំតាមរយៈនីតិវិធីច្បាប់ថាជាកូនរបស់ពលរដ្ឋឥណ្ឌូនេស៊ី និង<br>- បានបោះបង់ចោលសញ្ជាតិកាលពីមុន។ |
| ឡាវ | **មាត្រា ១៣**<br>**[តាមឆន្ទានុសិទ្ធិ]**<br>- ត្រូវបានរកឃើញនៅក្នុងប្រទេសឡាវ និង<br>- ជាកូនដែលយើងមិនស្គាល់អត្តសញ្ញាណឪពុកម្ដាយរបស់ពួកគេ។<br>សម្គាល់៖ ប្រសិនបើ មុនពេលដែលគាត់មានអាយុ ១៨ ឆ្នាំ មានភ័ស្តុតាងត្រូវបានរកឃើញថា ឪពុកម្ដាយរបស់គាត់ជាពលរដ្ឋបរទេស កុមាររូបនោះនឹងត្រូវបានចាត់ទុកជាពលរដ្ឋបរទេសពីកំណើត។<br><br>**មាត្រា ២៥**<br>**[តាមឆន្ទានុសិទ្ធិ]**<br>- ជាកុមារដែលមានសញ្ជាតិបរទេស ឬ គ្មានសញ្ជាតិ និង<br>- ត្រូវបានស្មុំមកចិញ្ចឹមដោយពលរដ្ឋឡាវ។ |

| ប្រទេស | កុមារបាត់ខ្លួន/កូនស៊ី |
|---|---|
| ម៉ាឡេស៊ី | **ខចែង ១៩ ខ ផ្នែក III នៃឧបសម្ព័ន្ធទីពីរ**<br>- ជាកុមារទើបនឹងកើត ដែលត្រូវបានរកឃើញនៅកន្លែងណាមួយ<br>- ត្រូវបានសន្មតជាមុនថាបានកើតនៅក្នុងប្រទេសម៉ាឡេស៊ី ជាកូនរបស់ម្តាយដែលជានិវាសនជន អចិន្ត្រៃយ៍ និង<br>- គ្មានភ័ស្តុតាងដែលផ្ទុយនឹងចំណុចខាងលើ។ |
| មីយ៉ាន់ម៉ា | **មាត្រា ៨(ក) [តាមឆន្ទានុសិទ្ធិ]**<br>ក្រុមប្រឹក្សារដ្ឋ ដើម្បីអត្ថប្រយោជន៍របស់រដ្ឋ អាចផ្តល់ភាពជាពលរដ្ឋ ភាពជាពលរដ្ឋតាមច្បាប់ ឬ ភាពជាពលរដ្ឋដែលបានធ្វើសញ្ជាតូបនីយកម្មដល់នរណាម្នាក់។ |
| ហ្វីលីពីន | **ករណីរបស់សមាជិកព្រឹទ្ធសភា Grace Poe៖ Mary Grace Natividad Poe- Llamanzares v. COMELEC, G.R. លេខ ២២១៦៩៧ ថ្ងៃទី០៨ ខែមីនា ឆ្នាំ២០១៦**<br>"តាមផ្លូវច្បាប់ កុមារបាត់ខ្លួនជាពលរដ្ឋដែលមានឋានៈពីកំណើត"។ |
| សិង្ហបុរី | **ខចែង ១៣ ឧបសម្ព័ន្ធទីបី**<br>- ជាកុមារទើបនឹងកើត ដែលត្រូវបានរកឃើញនៅក្នុងប្រទេសសិង្ហបុរី<br>- មិនស្គាល់ឪពុកម្តាយ និង មានឪពុកម្តាយដែលមិនអាចបញ្ជាក់បាន និង<br>- គ្មានភ័ស្តុតាងដែលផ្ទុយនឹងចំណុចខាងលើ។ |
| ថៃ | **ខចែង ៧ ស្ទួន កថាខណ្ឌទី ២ [តាមឆន្ទានុសិទ្ធិ]**<br>- កើតនៅក្នុងប្រទេសថៃ<br>- មានឪពុក ឬ ម្តាយជាជនបរទេស ដែលមានលិខិតអនុញ្ញាតស្នាក់នៅជាបណ្តោះអាសន្ន ឬ ស្នាក់នៅដោយខុសច្បាប់នៅក្នុងប្រទេសថៃ<br>- ឧទ្ទកាល័យបានកំណត់វិធាន និង លក្ខណវិនិច្ឆ័យសម្រាប់ក្រុមជាក់លាក់ និង<br>- សញ្ជាតិថៃត្រូវបានប្រគល់ជូនដោយរដ្ឋមន្ត្រី។<br><br>**ខចែង ១៩/២ កថាខណ្ឌទី ២ នៃច្បាប់ស្តីពីការចុះបញ្ជីអត្រានុកូលដ្ឋាន ឆ្នាំ២០១៩ [តាមឆន្ទានុសិទ្ធិ]**<br>- ត្រូវបានរកឃើញនៅក្នុងប្រទេសថៃ<br>- មិនដឹងអំពីឋានៈ និង សញ្ជាតិរបស់កំណើត<br>- បានចុះបញ្ជីនៅក្នុងប្រព័ន្ធចុះបញ្ជីអត្រានុកូលដ្ឋាន និង<br>- បានស្នាក់នៅក្នុងប្រទេសថៃ យ៉ាងតិច ១០ ឆ្នាំ។ |
| វៀតណាម | **មាត្រា ១៨**<br>- ជាកុមារទើបនឹងកើតដែលត្រូវគេបោះបង់ចោល ឬ កុមារដែលត្រូវបានរកឃើញនៅក្នុងប្រទេសវៀតណាម និង<br>- កុមារដែលមិនស្គាល់ឪពុកម្តាយ។<br>សូមកត់សម្គាល់ថា ប្រសិនបើកុមារមានអាយុក្រោម ១៥ ឆ្នាំ និង បានរកឃើញឪពុក/ម្តាយម្នាក់ ដែលមានសញ្ជាតិបរទេស កុមារនឹងលែងមានសញ្ជាតិវៀតណាមទៀតហើយ។ |

**តារាងទី៦៖ ក្របខណ្ឌច្បាប់នៅក្នុងរដ្ឋសមាជិកអាស៊ាន ពាក់ព័ន្ធនឹងការទទួលបានសញ្ជាតិដោយជនដែលមិនមែនជាពលរដ្ឋ (អាចរួមបញ្ចូលកុមារ/ជនគ្មានសញ្ជាតិ)**

| ប្រទេស | សម្រាប់កុមារ/ជនគ្មានសញ្ជាតិ | សញ្ជាតូបនីយកម្មដែលអាចកើតឡើងបានចំពោះជនគ្មានសញ្ជាតិ |
|---|---|---|
| ប្រ៊ុយណេដារូសាឡឹម | **ខចែងទី ៦**<br>**[តាមឆន្ទានុសិទ្ធិ]**<br>- កូនដែលជាអនីតិជន និង<br>- ពាក្យស្នើសុំត្រូវបានធ្វើឡើងដោយឪពុក/ម្តាយម្នាក់ ឬ ឪពុក/ម្តាយចិញ្ចឹម ឬ អាណាព្យាបាល។ | **ខចែង ៨(១) – បញ្ញត្តិទូទៅ**<br>**[តាមឆន្ទានុសិទ្ធិ]**<br>- បានស្នាក់នៅអស់រយៈពេល ២០ ឆ្នាំ ក្នុងរយៈពេល ២៥ ឆ្នាំចុងក្រោយ<br>- បានស្នាក់នៅអស់រយៈពេល ២ ឆ្នាំ ភ្លាមៗមុនពេលដាក់ពាក្យស្នើសុំ<br>- មានការស៊ើបអង្កេតផ្នែកសន្តិសុខយ៉ាងច្បាស់លាស់ និង<br>- ចេះភាសាម៉ាឡេ។ |
| កម្ពុជា | **មាត្រា ៤(២)**<br>**[ដោយស្វ័យប្រវត្តិ]**<br>- កើតនៅក្នុងប្រទេសកម្ពុជា<br>- មិនស្គាល់ម្តាយ ឬ ឪពុក។<br>សូមកត់សម្គាល់ថា កុមារដែលទើបនឹងកើត ដែលត្រូវបានរកឃើញនៅក្នុងប្រទេសកម្ពុជា ត្រូវបានចាត់ទុកថាបានកើតនៅក្នុងប្រទេសកម្ពុជា។ | **មាត្រា ៨ – បញ្ញត្តិទូទៅ**<br>**[តាមឆន្ទានុសិទ្ធិ]**<br>- មានអាកប្បកិរិយា និង សីលធម៌ល្អ<br>- មិនធ្លាប់ប្រព្រឹត្តិបទល្មើស<br>- បានស្នាក់នៅក្នុងប្រទេសកម្ពុជាអស់រយៈពេល ៧ ឆ្នាំជាបន្តបន្ទាប់<br>- ចេះភាសាខ្មែរ មានចំណេះដឹងអំពីប្រវត្តិសាស្ត្រ ទំនៀមទម្លាប់ និង ប្រពៃណីខ្មែរ និង<br>- មិនបង្កគ្រោះថ្នាក់ ឬ បន្ទុកដល់ប្រទេសកម្ពុជា។<br><br>**មាត្រា ៩ – សម្រាប់ជនបរទេសដែលកើតនៅក្នុងប្រទេសកម្ពុជា**<br>**[តាមឆន្ទានុសិទ្ធិ]**<br>- កើតនៅក្នុងប្រទេសកម្ពុជា<br>- មានអាកប្បកិរិយា និង សីលធម៌ល្អ<br>- មិនធ្លាប់ប្រព្រឹត្តិបទល្មើស<br>- បានស្នាក់នៅក្នុងប្រទេសកម្ពុជាអស់រយៈពេល ៣ ឆ្នាំជាបន្តបន្ទាប់<br>- ចេះភាសាខ្មែរ មានចំណេះដឹងអំពីប្រវត្តិសាស្ត្រ ទំនៀមទម្លាប់ និង ប្រពៃណីខ្មែរ និង<br>- មិនបង្កគ្រោះថ្នាក់ ឬ បន្ទុកដល់ប្រទេសកម្ពុជា។ |

| ប្រទេស | សម្រាប់កុមារ/ជនគ្មានសញ្ជាតិ | សញ្ជាតូបនីយកម្មដែលអាចកើតឡើងបានចំពោះជនគ្មានសញ្ជាតិ |
|---|---|---|
| | | **មាត្រា ១៣ – ផ្អែកលើគុណសម្បត្តិពិសេសៗ**<br>**[តាមឆន្ទានុសិទ្ធិ]**<br>- បានផ្តល់គុណសម្បត្តិ ឬ សមិទ្ធផលដ៏ពិសេសណាមួយ ដើម្បីផលប្រយោជន៍របស់ប្រទេសកម្ពុជា<br>- មានអាកប្បកិរិយា និង សីលធម៌ល្អ<br>- មិនធ្លាប់ប្រព្រឹត្តិបទល្មើស<br>- ចេះភាសាខ្មែរ មានចំណេះដឹងអំពីប្រវត្តិសាស្ត្រ ទំនៀមទម្លាប់ និង ប្រពៃណីខ្មែរ និង<br>- មិនបង្កគ្រោះថ្នាក់ ឬ បន្ទុកដល់ប្រទេសកម្ពុជា។<br>**មាត្រា ១៤ – ស្វាមី/ភរិយា ឬ កូន**<br>**[តាមឆន្ទានុសិទ្ធិ]**<br>- ជាស្វាមី/ភរិយា ឬ កូនរបស់អ្នកដាក់ពាក្យស្នើសុំដែលបានលើកឡើងនៅខាងលើ។ |
| ឥណ្ឌូនេស៊ី | មាត្រា ៤(៩)<br>**[ដោយស្វ័យប្រវត្តិ]**<br>- កើតនៅក្នុងប្រទេសឥណ្ឌូនេស៊ី<br>- សញ្ជាតិទាំងឪពុក និង ម្តាយ មិនអាចកំណត់បាន នៅពេលកុមារកើត។<br><br>មាត្រា ៤(១១)<br>**[ដោយស្វ័យប្រវត្តិ]**<br>- កើតនៅក្នុងប្រទេសឥណ្ឌូនេស៊ី<br>- មានទាំងឪពុក និង ម្តាយជាជនគ្មានសញ្ជាតិ ឬ មិនស្គាល់ឪពុកម្តាយ នៅពេលកុមារកើត។ | **មាត្រា ៩ – បញ្ញត្តិទូទៅ**<br>**[តាមឆន្ទានុសិទ្ធិ]**<br>- មានអាយុលើសពី ១៨ ឆ្នាំ ឬ បានរៀបអាពាហ៍ពិពាហ៍រួចហើយ<br>- បានស្នាក់នៅអស់រយៈពេលយ៉ាងតិច ៥ ឆ្នាំជាបន្តបន្ទាប់ ឬ ១០ ឆ្នាំ ដោយមិនជាប់លាប់<br>- មានសុខភាព និង សុខភាពផ្លូវចិត្តល្អ<br>- អាចនិយាយភាសាបាហាសាឥណ្ឌូនេស៊ីបាន និង មានចំណេះដឹងអំពីរដ្ឋ គោលការណ៍មូលដ្ឋានរបស់បញ្ចសិលា (Pancasila) និង រដ្ឋធម្មនុញ្ញ ឆ្នាំ១៩៤៥<br>- មិនធ្លាប់ត្រូវបានកាត់ទោសតាមផ្លូវច្បាប់ដោយសារទង្វើផ្នែកព្រហ្មទណ្ឌ និង ត្រូវបានកាត់ទោសឲ្យជាប់ពន្ធនាគាររយៈពេល ១ ឆ្នាំ ឬ លើសពីនេះ<br>- បោះបង់ចោលសញ្ជាតិណាមួយផ្សេងទៀតបន្ទាប់ពីទទួលបានភាពជាពលរដ្ឋឥណ្ឌូនេស៊ី<br>- មានប្រាក់ចំណូលឋិតថេរ និង<br>- ទូទាត់ថ្លៃធ្វើសញ្ជាតូបនីយកម្ម។<br>**មាត្រា ២០ – ផ្អែកលើគុណសម្បត្តិពិសេសៗ**<br>**[តាមឆន្ទានុសិទ្ធិ]**<br>- ស័ក្តិសមនឹងទទួលបានគុណសម្បត្តិសម្រាប់ការផ្តល់សេវាដល់ប្រទេសឥណ្ឌូនេស៊ី និង |

| ប្រទេស | សម្រាប់កុមារ/ជនគ្មានសញ្ជាតិ | សញ្ញាតូបនីយកម្មដែលអាចកើតឡើងបានចំពោះជនគ្មានសញ្ជាតិ |
|---|---|---|
| | | - ទទួលបានសេចក្ដីសម្រេចរបស់ក្រុមប្រឹក្សាអ្នកតំណាងឲ្យប្រជាជន។ |
| ឡាវ | **មាត្រា ១១ កថាខណ្ឌទី ៣**<br>**[ដោយស្វ័យប្រវត្តិ]**<br>- ជាកូនរបស់ឪពុកម្ដាយម្នាក់ដែលមានសញ្ជាតិឡាវ និង ម្នាក់ទៀតគ្មានសញ្ជាតិ<br><br>**មាត្រា ១២**<br>**[តាមឆន្ទានុសិទ្ធិ]**<br>- កើតនៅប្រទេសឡាវ<br>- មានឪពុកម្ដាយទាំងពីរនាក់ជាជនគ្មានសញ្ជាតិ ដែលកំពុងតែស្នាក់នៅជាអចិន្ត្រៃយ៍នៅក្នុងប្រទេសឡាវ និង បានធ្វើសមាហរណកម្មទៅក្នុងសង្គម និង វប្បធម៌របស់ប្រទេសឡាវ និង<br>- មានសំណើដែលត្រូវបានធ្វើឡើងដោយឪពុកម្ដាយ។<br>**មាត្រា ១៣**<br>**[តាមឆន្ទានុសិទ្ធិ]**<br>- ត្រូវបានរកឃើញនៅប្រទេសឡាវ និង<br>- មិនស្គាល់ឪពុកម្ដាយ។<br>សម្គាល់៖ ប្រសិនបើ មុនពេលដែលគាត់មានអាយុ ១៨ ឆ្នាំ មានភ័ស្ដុតាងត្រូវបានរកឃើញថា ឪពុកម្ដាយរបស់គាត់ជាពលរដ្ឋបរទេស កុមាររូបនោះនឹងត្រូវបានចាត់ទុកជាពលរដ្ឋបរទេសពីកំណើត។<br><br>**មាត្រា ២៥**<br>**[តាមឆន្ទានុសិទ្ធិ]**<br>- ជាកុមារដែលមានសញ្ជាតិបរទេស ឬ ជាកុមារគ្មានសញ្ជាតិ និង<br>- ត្រូវបានសុំដោយពលរដ្ឋឡាវ។ | **មាត្រា ១៤ – បញ្ញត្តិទូទៅ**<br>**[តាមឆន្ទានុសិទ្ធិ]**<br>- មានអាយុ ១៨ ឆ្នាំ ឡើងទៅ<br>- គោរពរដ្ឋធម្មនុញ្ញ និង ច្បាប់នានា<br>- និយាយ អាន និង សរសេរភាសាឡាវបានយ៉ាងស្ទាត់ជំនាញ<br>- បានធ្វើសមាហរណកម្មទៅក្នុងសង្គម និង វប្បធម៌របស់ប្រទេសឡាវ និង គោរពប្រពៃណីឡាវ<br>- មានសុខភាពល្អ<br>- មិនធ្លាប់ត្រូវបានកាត់ទោសឲ្យជាប់ពន្ធនាគារដោយតុលាការណាមួយនោះទេ<br>- ចូលរួមនៅក្នុងកិច្ចការពារ និង អភិវឌ្ឍប្រទេសឡាវ<br>- មិនបង្កក្ដីអន្តរាយចំពោះផលប្រយោជន៍ជាតិ<br>- យល់ព្រមបោះបង់ចោលសញ្ជាតិពីមុន<br>- មានទីលំនៅអចិន្ត្រៃយ៍នៅក្នុងប្រទេសឡាវ ក្នុងរយៈពេល ១០ ឆ្នាំជាបន្តបន្ទាប់ និង<br>- មានស្ថានភាពសេដ្ឋកិច្ចដែលមានលំនឹង។<br>**មាត្រា ១៥ – សម្រាប់ជនដែលមានជាតិសាសន៍ឡាវ**<br>**[តាមឆន្ទានុសិទ្ធិ]**<br>- មានអាយុ ១៨ ឆ្នាំ ឡើងទៅ<br>- គោរពរដ្ឋធម្មនុញ្ញ និង ច្បាប់នានា<br>- និយាយ អាន និង សរសេរភាសាឡាវបានយ៉ាងស្ទាត់ជំនាញ<br>- បានធ្វើសមាហរណកម្មទៅក្នុងសង្គម និង វប្បធម៌របស់ប្រទេសឡាវ និង គោរពប្រពៃណីឡាវ<br>- មានសុខភាពល្អ<br>- មិនធ្លាប់ត្រូវបានកាត់ទោសឲ្យជាប់ពន្ធនាគារដោយតុលាការណាមួយនោះទេ<br>- ចូលរួមនៅក្នុងកិច្ចការពារ និង អភិវឌ្ឍប្រទេសឡាវ<br>- មិនបង្កក្ដីអន្តរាយចំពោះផលប្រយោជន៍ជាតិ |

| ប្រទេស | សម្រាប់កុមារ/ជនគ្មានសញ្ជាតិ | សញ្ជាតូបនីយកម្មដែលអាចកើតឡើងបានចំពោះជនគ្មានសញ្ជាតិ |
|---|---|---|
| | | - មានទីលំនៅអចិន្ត្រៃយ៍នៅក្នុងប្រទេសឡាវ ក្នុងរយៈពេល ៥ ឆ្នាំជាបន្តបន្ទាប់ សម្រាប់បុគ្គលដែលបានទទួលសញ្ជាតិណាមួយផ្សេងទៀតកាលពីមុន ឬ មានទីលំនៅអចិន្ត្រៃយ៍នៅក្នុងប្រទេសឡាវ ក្នុងរយៈពេល ៣ ឆ្នាំ សម្រាប់ជនគ្មានសញ្ជាតិ និង<br>- មានស្ថានភាពសេដ្ឋកិច្ចដែលមានលំនឹង។ |
| ម៉ាឡេស៊ី | **មាត្រា ១៤(១)(ក) + ឧបែង ១(គ) ផ្នែក I នៃឧបសម្ព័ន្ធទីពីរ**<br>- កើតនៅក្នុងប្រទេសម៉ាឡេស៊ី នៅក្រោយខែកញ្ញា ឆ្នាំ១៩៦២ និង<br>- មិនអាចទទួលបានសញ្ជាតិណាមួយផ្សេងទៀត។<br>**មាត្រា ១៤(១)(ក) + ឧបែង ១(ង) និង ឧបែង ២(១) ផ្នែក II នៃឧបសម្ព័ន្ធទីពីរ**<br>- កើតនៅក្នុងប្រទេសម៉ាឡេស៊ី នៅ ឬ នៅក្រោយទិវាជាតិម៉ាឡេស៊ី និង<br>- មិនអាចទទួលបានសញ្ជាតិណាមួយផ្សេងទៀត ក្នុងរយៈពេល ១ ឆ្នាំ ក្រោយពេលកើត។<br>**មាត្រា ១៥ក [តាមឆន្ទានុសិទ្ធិ]**<br>- មានអាយុ ក្រោម ២១ ឆ្នាំ និង<br>- ត្រូវបានអនុញ្ញាតឲ្យចុះបញ្ជីជាពលរដ្ឋម៉ាឡេស៊ីដោយរដ្ឋាភិបាលនៃសហព័ន្ធ នៅក្នុងកាលៈទេសៈពិសេសៗ។<br>**មាត្រា ១៦ [តាមឆន្ទានុសិទ្ធិ]**<br>- មានអាយុ ១៨ ឆ្នាំ ឡើងទៅ<br>- កើតនៅក្នុងប្រទេសម៉ាឡេស៊ីមុនថ្ងៃ Merdeka<br>- បានស្នាក់នៅក្នុងប្រទេសម៉ាឡេស៊ីអស់រយៈពេលយ៉ាងតិច ៥ ឆ្នាំជាបន្តបន្ទាប់ ដែលរយៈពេលស្នាក់នៅសរុបមានចំនួន ៧ ឆ្នាំ<br>- មានអត្តចរិតល្អ និង<br>- ចេះភាសាម៉ាឡេ។ | **មាត្រា ១៩ – ភាពជាពលរដ្ឋតាមរយៈសញ្ជាតូបនីយកម្ម [តាមឆន្ទានុសិទ្ធិ]**<br>- មានអាយុលើសពី ២១ ឆ្នាំ<br>- បានស្នាក់នៅអស់រយៈពេល ១០ ឆ្នាំ ក្នុងរយៈពេល ១២ ឆ្នាំចុងក្រោយ<br>- បានស្នាក់នៅអស់រយៈពេល ១២ ខែ ភ្លាមៗមុនពេលដាក់ពាក្យស្នើសុំ<br>- មានអត្តចរិតល្អ<br>- ចេះភាសាម៉ាឡេ និង<br>- ធ្វើការស្បថសច្ចា។ |

| ប្រទេស | សម្រាប់កុមារ/ជនគ្មានសញ្ជាតិ | សញ្ជាតូបនីយកម្មដែលអាចកើតឡើងបានចំពោះជនគ្មានសញ្ជាតិ |
|---|---|---|
| **មីយ៉ាន់ម៉ា** | **មាត្រា ៨(ក) [តាមឆន្ទានុសិទ្ធិ]**<br>- ក្រុមប្រឹក្សារដ្ឋ ដើម្បីអត្ថប្រយោជន៍របស់រដ្ឋ អាចផ្តល់ភាពជាពលរដ្ឋ ឬ ភាពជាពលរដ្ឋតាមច្បាប់ ឬ ភាពជាពលរដ្ឋដែលបានធ្វើសញ្ជាតូប-នីយកម្មដល់នរណាម្នាក់។ | **មាត្រា ៤២ [តាមឆន្ទានុសិទ្ធិ]**<br>- បានចូល និង ស្នាក់នៅក្នុងប្រទេសមីយ៉ាន់ម៉ា នៅមុនថ្ងៃទី០៤ ខែមករា ឆ្នាំ១៩៤៨ និង<br>- មានកូនកើតនៅប្រទេសមីយ៉ាន់ម៉ា។ |
| **ហ្វីលីពីន** | **ខចែង ៣ (លក្ខណៈសម្បត្តិពិសេស) នៃច្បាប់របស់រដ្ឋសហធន លេខ ៤៧៣ (ការធ្វើសញ្ជាតូបនីយកម្មតាមប្រព័ន្ធតុលាការ)**<br>- បានស្នាក់នៅអស់រយៈពេល ៥ ឆ្នាំ<br>- មានការងារដែលមានកិត្តិយស ដែលស្ថិតនៅក្រោមរដ្ឋាភិបាលនៃប្រទេសហ្វីលីពីន<br>- បានបង្កើតឧស្សាហកម្មថ្មីមួយ ឬ បានណែនាំការច្នៃប្រឌិតដែលមានសារប្រយោជន៍ចំពោះប្រទេសហ្វីលីពីន<br>- បានរៀបអាពាហ៍ពិពាហ៍ជាមួយស្ត្រីហ្វីលីពីន<br>- បានចូលរួមជាគ្រូបង្រៀននៅក្នុងប្រទេសហ្វីលីពីននៅសាលារដ្ឋ ឬ សាលាឯកជនដែលមានកេរ្តិ៍ឈ្មោះអស់រយៈពេលមិនតិចជាង ២ ឆ្នាំ និង<br>- បានកើតនៅក្នុងប្រទេសហ្វីលីពីន។ | **ខចែង ១(៤) នៃរដ្ឋធម្មនុញ្ញ ឆ្នាំ១៩៨៧ [តាមឆន្ទានុសិទ្ធិ]**<br>- បានធ្វើសញ្ជាតូបនីយកម្មស្របតាមច្បាប់។<br><br>**បានកែសម្រួលច្បាប់ស្តីពីសញ្ជាតូបនីយកម្ម (ការធ្វើសញ្ជាតូបនីយកម្មតាមប្រព័ន្ធតុលាការ) ស្របតាមច្បាប់របស់រដ្ឋសហធន (C.A.) លេខ ៤៧៣**<br><br>**ច្បាប់ស្តីពីការធ្វើសញ្ជាតូបនីយកម្មតាមផ្នែករដ្ឋបាល ស្របតាមច្បាប់របស់សាធារណរដ្ឋ (R.A) លេខ ៩១៣៩ (ការធ្វើសញ្ជាតូបនីយកម្មតាមផ្នែករដ្ឋបាល)**<br><br>**ការធ្វើសញ្ជាតូបនីយកម្មដែលមានលក្ខណៈក្លាយ (ចូរមើល Republic v. Batugas, G.R. លេខ ១៨៣១១០ ថ្ងៃទី០៧ ខែតុលា ឆ្នាំ២០១៣ ដែលដកស្រង់ ខចែង ១៥ C.A. លេខ ៤៧៣)** |
| **សិង្ហបុរី** | **មាត្រា ១២៣ (១) [តាមឆន្ទានុសិទ្ធិ]**<br>- មានអាយុលើស ២១ ឆ្នាំ<br>- មានអត្តចរិតល្អ<br>- បានស្នាក់នៅអស់រយៈពេលសរុប មិនតិចជាង ១០ ឆ្នាំ ក្នុងរយៈពេល ១២ ឆ្នាំចុងក្រោយ ភ្លាមៗមុនកាលបរិច្ឆេទដាក់ពាក្យស្នើសុំ<br>- បានស្នាក់នៅអស់រយៈពេល ១២ ខែ ភ្លាមៗមុនពេលដាក់ពាក្យស្នើសុំ<br>- មានបំណងស្នាក់នៅជាអចិន្ត្រៃយ៍នៅក្នុងប្រទេសសិង្ហបុរី និង<br>- មានចំណេះដឹងកម្រិតដំបូងនៃភាសាណាមួយដូចតទៅ៖ ភាសាម៉ាឡេ ភាសាអង់គ្លេស ភាសាចិនកុកងឺ និង ភាសាតាមីល។ | **មាត្រា ១២៧ [តាមឆន្ទានុសិទ្ធិ]**<br>- មានអាយុលើសពី ២១ ឆ្នាំ<br>- បានស្នាក់នៅអស់រយៈពេលសរុប មិនតិចជាង ១០ ឆ្នាំ ក្នុងរយៈពេល ១២ ឆ្នាំចុងក្រោយ ភ្លាមៗមុនកាលបរិច្ឆេទដាក់ពាក្យស្នើសុំ<br>- បានស្នាក់នៅអស់រយៈពេល ១២ ខែ ភ្លាមៗមុនពេលដាក់ពាក្យស្នើសុំ<br>- មានអត្តចរិតល្អ<br>- មានចំណេះដឹងអំពីភាសាជាតិ និង<br>- ធ្វើការស្បថសច្ចា។ |

| ប្រទេស | សម្រាប់កុមារ/ជនគ្មានសញ្ជាតិ | សញ្ជាតូបនីយកម្មដែលអាចកើតឡើងបានចំពោះជនគ្មានសញ្ជាតិ |
|---|---|---|
| | **មាត្រា ១២៤ (២)**<br>**[តាមឆន្ទានុសិទ្ធិ]**<br>- មានអាយុក្រោម ២១ ឆ្នាំ និង<br>- ត្រូវបានអនុញ្ញាតឲ្យចុះបញ្ជីជាពលរដ្ឋសិង្ហបុរីដោយរដ្ឋាភិបាលនៅក្នុងកាលៈទេសៈពិសេសៗ។ | |
| ថៃ | **ខចែង ៧(២) [ដោយស្វ័យប្រវត្តិ]**<br>- កើតនៅក្នុងប្រទេសថៃ<br>- មានឪពុកម្ដាយទាំងពីរនាក់មានទីលំនៅអចិន្ត្រៃយ៍នៅក្នុងប្រទេសថៃ<br><br>**ខចែង ៧ ស្ទួន កថាខណ្ឌទី ២ [តាមឆន្ទានុសិទ្ធិ]**<br>- កើតនៅក្នុងប្រទេសថៃ<br>- មានឪពុក ឬ ម្ដាយជាជនបរទេស ដែលមានលិខិតអនុញ្ញាតស្នាក់នៅជាបណ្ដោះអាសន្ន ឬ ស្នាក់នៅដោយខុសច្បាប់នៅក្នុងប្រទេសថៃ<br>- ខុទ្ទកាល័យបានកំណត់វិធាន និង លក្ខណវិនិច្ឆ័យសម្រាប់ក្រុមជាក់លាក់ និង<br>- សញ្ជាតិថៃត្រូវបានប្រគល់ជូនដោយរដ្ឋមន្ត្រី។ | **ខចែង ១០ – បញ្ញត្តិទូទៅ**<br>**[តាមឆន្ទានុសិទ្ធិ]**<br>- មានអាយុលើសពី ២០ ឆ្នាំ<br>- មានអត្តចរិតល្អ<br>- មានមុខរបរទៀងទាត់<br>- បានស្នាក់នៅអស់រយៈពេល ៥ ឆ្នាំ និង<br>- ចេះភាសាថៃ។<br><br>**ខចែង ១១ – ផ្អែកលើគុណសម្បត្តិពិសេសៗ**<br>**[តាមឆន្ទានុសិទ្ធិ]**<br>- បានផ្ដល់សេវាពិសេសៗដល់ប្រទេសថៃ<br>- ជាកូន ភរិយា ឬ ស្វាមីរបស់ជនដែលបានធ្វើសញ្ជាតូបនីយកម្មជាពលរដ្ឋថៃ ឬ បានទទួលសញ្ជាតិថៃឡើងវិញ<br>- មានអាយុលើសពី ២០ ឆ្នាំ<br>- មានអាកប្បកិរិយាល្អ និង<br>- មានមុខរបរទៀងទាត់<br><br>ឬ<br>- បានផ្ដល់សេវាពិសេសៗដល់ប្រទេសថៃ<br>- ជាជនដែលធ្លាប់មានសញ្ជាតិថៃ |

| ប្រទេស | សម្រាប់កុមារ/ជនគ្មានសញ្ជាតិ | សញ្ជាតូបនីយកម្មដែលអាចកើតឡើងបានចំពោះជនគ្មានសញ្ជាតិ |
|---|---|---|
| | | - មានអាយុលើសពី ២០ ឆ្នាំ<br>- មានអាកប្បកិរិយាល្អ និង<br>- មានមុខរបរទៀងទាត់<br>ឬ<br>- បានផ្តល់សេវាពិសេសៗដល់ប្រទេសថៃ<br>- ជាស្វាមីរបស់ស្ត្រីជនជាតិថៃ<br>- មានអាយុលើសពី ២០ ឆ្នាំ<br>- មានអាកប្បកិរិយាល្អ និង<br>- មានមុខរបរទៀងទាត់។<br>**ខចែង ១២ កថាខណ្ឌទី ២ ន សម្រាប់កូនរបស់អ្នកដាក់ពាក្យស្នើសុំសញ្ជាតូបនីយកម្ម [តាមឆន្ទានុសិទ្ធិ]**<br>- ជាកូនរបស់អ្នកដាក់ពាក្យស្នើសុំធ្វើសញ្ជាតូបនីយកម្ម<br>- មានអាយុក្រោម ២០ ឆ្នាំ<br>- មានទីលំនៅនៅក្នុងប្រទេសថៃ និង<br>- មានអាកប្បកិរិយាល្អ។<br>**ខចែង ១២/១ – ពាក្យស្នើសុំសញ្ជាតូបនីយកម្មតាងនាមឲ្យជនដែលគ្មានសញ្ជាតិថៃ [តាមឆន្ទានុសិទ្ធិ]**<br>- ជាជនអសមត្ថភាពដែលបានកើតនៅក្នុងប្រទេសថៃ<br>- មានអាយុលើសពី ២០ ឆ្នាំ<br>- បានដាក់ពាក្យស្នើសុំដោយហិតូបត្ថម្ភកៈ ស្របតាមដីការបស់តុលាការ<br>- មានអាកប្បកិរិយាល្អ និង<br>- បានស្នាក់នៅអស់រយៈពេល ៥ ឆ្នាំ<br>ឬ<br>- ជាកុមារដែលស្នាក់នៅក្នុងផ្ទះថៃទាំសាធារណៈ ដែលបានចុះបញ្ជីជាមួយរដ្ឋមន្ត្រី អស់រយៈពេល ១០ ឆ្នាំ ឬ លើសពីនេះ |

| ប្រទេស | សម្រាប់កុមារ/ជនគ្មានសញ្ជាតិ | សញ្ជាតូបនីយកម្មដែលអាចកើតឡើងបានចំពោះជនគ្មានសញ្ជាតិ |
|---|---|---|
| | | - មានអាយុក្រោម ២០ ឆ្នាំ<br>- បានដាក់ពាក្យស្នើសុំដោយអ្នកគ្រប់គ្រងផ្ទះថៃទាំសាធារណៈ<br>- មានអាកប្បកិរិយាល្អ<br>- បានស្នាក់នៅអស់រយៈពេល ៥ ឆ្នាំ និង<br>- ចេះភាសាថៃ<br>ឬ<br>- ជាកូនដែលត្រូវបានសុំដោយប្រជាជនថៃ អស់រយៈពេល ៥ ឆ្នាំឡើងទៅ<br>- កើតនៅក្នុងប្រទេសថៃ<br>- មានអាយុក្រោម ២០ ឆ្នាំ<br>- បានដាក់ពាក្យស្នើសុំដោយឪពុក/ម្តាយចិញ្ចឹមជនជាតិថៃ<br>- មានអាកប្បកិរិយាល្អ<br>- បានស្នាក់នៅអស់រយៈពេល ៥ ឆ្នាំ និង<br>- ចេះភាសាថៃ។ |
| វៀតណាម | **មាត្រា ១៧(១)**<br>- កើតនៅក្នុងប្រទេសវៀតណាម<br>- មានឪពុកម្តាយទាំងពីរនាក់ជាជនគ្មានសញ្ជាតិ ដែលមានទីលំនៅអចិន្ត្រៃយ៍នៅក្នុងប្រទេសវៀតណាម។<br><br>**មាត្រា ១៧(២)**<br>- កើតនៅក្នុងប្រទេសវៀតណាម<br>- មានម្តាយជាជនគ្មានសញ្ជាតិ ដែលមានទីលំនៅអចិន្ត្រៃយ៍នៅក្នុងប្រទេសវៀតណាម និង<br>- មិនស្គាល់ឪពុក។ | **មាត្រា ១៩(១) – បញ្ញត្តិទូទៅ**<br>**[តាមឆន្ទានុសិទ្ធិ]**<br>- ជាពលរដ្ឋបរទេស ឬ ជាជនគ្មានសញ្ជាតិ ដែលស្នាក់នៅជាអចិន្ត្រៃយ៍នៅក្នុងប្រទេសវៀតណាម<br>- មានសមត្ថភាពធ្វើសកម្មភាពជាពលរដ្ឋយ៉ាងពេញលេញ<br>- គោរពរដ្ឋធម្មនុញ្ញ និង ច្បាប់នានារបស់ប្រទេសវៀតណាម<br>- យល់ភាសាវៀតណាមបានយ៉ាងគ្រប់គ្រាន់ដើម្បីធ្វើសមាហរណកម្មទៅក្នុងសហគមន៍<br>- បានស្នាក់នៅអស់រយៈពេល ៥ ឆ្នាំ<br>- មានសមត្ថភាពប្រកបរបរចិញ្ចឹមជីវិតនៅក្នុងប្រទេសវៀតណាម។<br>**មាត្រា ១៩(១) – ផ្អែកលើគុណសម្បត្តិពិសេស១**<br>**[តាមឆន្ទានុសិទ្ធិ]**<br>- បានធ្វើការរួមចំណែកដែលគួរឲ្យកោតសរសើរចំពោះការស្ថាបនា និង កិច្ចការពារជាតិរបស់ប្រទេសវៀតណាម ឬ ដែលមានសារប្រយោជន៍ចំពោះប្រទេសវៀតណាម |

| ប្រទេស | សម្រាប់កុមារ/ជនគ្មានសញ្ជាតិ | សញ្ជាតូបនីយកម្មដែលអាចកើតឡើងបានចំពោះជនគ្មានសញ្ជាតិ |
|---|---|---|
| | | - មានសមត្ថភាពធ្វើសកម្មភាពជាពលរដ្ឋយ៉ាងពេញលេញ និង<br>- គោរពរដ្ឋធម្មនុញ្ញ និង ច្បាប់នានារបស់ប្រទេសវៀតណាម។<br><br>**មាត្រា ២២**<br>**[តាមឆន្ទានុសិទ្ធិ]**<br>- ជាជនគ្មានសញ្ជាតិដែលមានឯកសារអត្តសញ្ញាណផ្ទាល់ខ្លួនមិនគ្រប់គ្រាន់<br>- បានស្នាក់នៅអស់រយៈពេល ២០ ឆ្នាំ និង<br>- គោរពរដ្ឋធម្មនុញ្ញ និង ច្បាប់នានារបស់ប្រទេសវៀតណាម។ |

តារាងទី៧៖ ក្របខណ្ឌច្បាប់នៅក្នុងរដ្ឋសមាជិកអាស៊ាន ពាក់ព័ន្ធនឹងការទទួលបានសញ្ជាតិតាមរយៈសញ្ជាតូបនីយកម្ម និង អាពាហ៍ពិពាហ៍

| ប្រទេស | តាមរយៈសញ្ជាតូបនីយកម្ម | តាមរយៈអាពាហ៍ពិពាហ៍ |
|---|---|---|
| ប្រ៊ុយណេ | **ខចែង ៨(១) – បញ្ញត្តិទូទៅ**<br>**[តាមឆន្ទានុសិទ្ធិ]**<br>- បានស្នាក់នៅអស់រយៈពេល ២០ ឆ្នាំ ក្នុងរយៈពេល ២៥ ឆ្នាំចុងក្រោយ<br>- បានស្នាក់នៅអស់រយៈពេល ២ ឆ្នាំ ភ្លាមៗមុនពេលដាក់ពាក្យស្នើសុំ<br>- មានការស៊ើបអង្កេតផ្នែកសន្តិសុខយ៉ាងច្បាស់លាស់ និង<br>- មានអត្តចរិតល្អ<br>- ចេះភាសាម៉ាឡេ។ | **ខចែង ៥(៦)-(៧)**<br>**[តាមឆន្ទានុសិទ្ធិ]**<br>- បានរៀបអាពាហ៍ពិពាហ៍ជាមួយពលរដ្ឋ<br>- មានអត្តចរិតល្អ។ |
| កម្ពុជា | **មាត្រា ៨ – បញ្ញត្តិទូទៅ**<br>**[តាមឆន្ទានុសិទ្ធិ]**<br>- មានអាកប្បកិរិយា និង សីលធម៌ល្អ<br>- មិនធ្លាប់ប្រព្រឹត្តិបទល្មើស<br>- បានស្នាក់នៅក្នុងប្រទេសកម្ពុជាអស់រយៈពេល ៧ ឆ្នាំជាបន្តបន្ទាប់<br>- ចេះភាសាខ្មែរ មានចំណេះដឹងអំពីប្រវត្តិសាស្ត្រ ទំនៀមទម្លាប់ និង ប្រពៃណីខ្មែរ និង<br>- មិនបង្កគ្រោះថ្នាក់ ឬ បន្ទុកដល់ប្រទេសកម្ពុជា។<br><br>**មាត្រា ៩ – សម្រាប់ជនបរទេសដែលកើតនៅក្នុងប្រទេសកម្ពុជា**<br>**[តាមឆន្ទានុសិទ្ធិ]**<br>- កើតនៅក្នុងប្រទេសកម្ពុជា<br>- មានអាកប្បកិរិយា និង សីលធម៌ល្អ<br>- មិនធ្លាប់ប្រព្រឹត្តិបទល្មើស<br>- បានស្នាក់នៅក្នុងប្រទេសកម្ពុជាអស់រយៈពេល ៣ ឆ្នាំជាបន្តបន្ទាប់<br>- ចេះភាសាខ្មែរ មានចំណេះដឹងអំពីប្រវត្តិសាស្ត្រ ទំនៀមទម្លាប់ និង ប្រពៃណីខ្មែរ និង<br>- មិនបង្កគ្រោះថ្នាក់ ឬ បន្ទុកដល់ប្រទេសកម្ពុជា។ | **មាត្រា ៥**<br>**[តាមឆន្ទានុសិទ្ធិ]**<br>- ជាភរិយា ឬ ស្វាមីរបស់ពលរដ្ឋ និង<br>- បានរស់នៅជាមួយគ្នាអស់រយៈពេល ៣ ឆ្នាំក្រោយពេលចុះបញ្ជីអាពាហ៍ពិពាហ៍។ |

| ប្រទេស | តាមរយៈសញ្ជាតូបនីយកម្ម | តាមរយៈអាពាហ៍ពិពាហ៍ |
|---|---|---|
| | **មាត្រា ១០ – សម្រាប់ក្រុមវិនិយោគិនទី១**<br>**[តាមឆន្ទានុសិទ្ធិ]**<br>- បានទទួលលិខិតអនុញ្ញាតឲ្យធ្វើការវិនិយោគ ពីក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា<br>- បានចំណាយមូលធនលើកដំបូង លើសពី ១.២៥០.០០០.០០០ រៀល<br>- មានអាកប្បកិរិយា និង សីលធម៌ល្អ<br>- មិនធ្លាប់ប្រព្រឹត្តិបទល្មើស<br>- ចេះភាសាខ្មែរ មានចំណេះដឹងអំពីប្រវត្តិសាស្ត្រ ទំនៀមទម្លាប់ និង ប្រពៃណីខ្មែរ និង<br>- មិនបង្កគ្រោះថ្នាក់ ឬ បន្ទុកដល់ប្រទេសកម្ពុជា។<br><br>**មាត្រា ១១ – សម្រាប់ក្រុមវិនិយោគិនទី២**<br>**[តាមឆន្ទានុសិទ្ធិ]**<br>- បានទទួលលិខិតអនុញ្ញាតឲ្យធ្វើការវិនិយោគតាមផ្លូវច្បាប់ពីរដ្ឋាភិបាល<br>- បានចំណាយមូលធនលើកដំបូង លើសពី ១.២៥០.០០០.០០០ រៀល<br>- មានអាកប្បកិរិយា និង សីលធម៌ល្អ<br>- មិនធ្លាប់ប្រព្រឹត្តិបទល្មើស<br>- ចេះភាសាខ្មែរ មានចំណេះដឹងអំពីប្រវត្តិសាស្ត្រ ទំនៀមទម្លាប់ និង ប្រពៃណីខ្មែរ និង<br>- មិនបង្កគ្រោះថ្នាក់ ឬ បន្ទុកដល់ប្រទេសកម្ពុជា។<br><br>**មាត្រា ១២ – សម្រាប់ម្ចាស់ជំនួយ**<br>**[តាមឆន្ទានុសិទ្ធិ]**<br>- ធ្វើការបរិច្ចាគជាសាច់ប្រាក់ទៅក្នុងថវិកាជាតិ ដែលមានចំនួនលើសពី ១.០០០.០០០.០០០ រៀល<br>- មានអាកប្បកិរិយា និង សីលធម៌ល្អ<br>- មិនធ្លាប់ប្រព្រឹត្តិបទល្មើស<br>- ចេះភាសាខ្មែរ មានចំណេះដឹងអំពីប្រវត្តិសាស្ត្រ ទំនៀមទម្លាប់ និង ប្រពៃណីខ្មែរ<br>- មិនបង្កគ្រោះថ្នាក់ ឬ បន្ទុកដល់ប្រទេសកម្ពុជា និង | |

| ប្រទេស | តាមរយៈសញ្ជាតូបនីយកម្ម | តាមរយៈអាពាហ៍ពិពាហ៍ |
|---|---|---|
| | - ដាក់ពាក្យស្នើសុំសញ្ជាតិខ្មែរ។<br>**មាត្រា ១៣ – ផ្អែកលើគុណសម្បត្តិពិសេស១**<br>**[តាមឆន្ទានុសិទ្ធិ]**<br>- បានផ្តល់គុណសម្បត្តិ ឬ សមិទ្ធផលដ៏ពិសេសណាមួយ ដើម្បីផលប្រយោជន៍របស់ប្រទេសកម្ពុជា<br>- មានអាកប្បកិរិយា និង សីលធម៌ល្អ<br>- មិនធ្លាប់ប្រព្រឹត្តិបទល្មើស<br>- ចេះភាសាខ្មែរ មានចំណេះដឹងអំពីប្រវត្តិសាស្ត្រ ទំនៀមទម្លាប់ និង ប្រពៃណីខ្មែរ និង<br>- មិនបង្កគ្រោះថ្នាក់ ឬ បន្ទុកដល់ប្រទេសកម្ពុជា។<br>**មាត្រា ១៤ – ស្វាមី/ភរិយា ឬ កូន**<br>**[តាមឆន្ទានុសិទ្ធិ]**<br>- ជាស្វាមី/ភរិយា ឬ កូនរបស់អ្នកដាក់ពាក្យស្នើសុំដែលបានលើកឡើងនៅខាងលើ។ | |
| ឥណ្ឌូនេស៊ី | **មាត្រា ៩ – បញ្ញត្តិទូទៅ**<br>**[តាមឆន្ទានុសិទ្ធិ]**<br>- មានអាយុលើសពី ១៨ ឆ្នាំ ឬ បានរៀបអាពាហ៍ពិពាហ៍រួចហើយ<br>- បានស្នាក់នៅអស់រយៈពេលយ៉ាងតិច ៥ ឆ្នាំជាបន្តបន្ទាប់ ឬ ១០ ឆ្នាំ ដោយមិនជាប់លាប់<br>- មានសុខភាព និង សុខភាពផ្លូវចិត្តល្អ<br>- អាចនិយាយភាសាបាហាសាឥណ្ឌូនេស៊ីបាន និង មានចំណេះដឹងអំពីរដ្ឋ គោលការណ៍មូលដ្ឋាននៃបញ្ចសិលា និង រដ្ឋធម្មនុញ្ញ ឆ្នាំ១៩៤៥<br>- មិនធ្លាប់ត្រូវបានកាត់ទោសតាមផ្លូវច្បាប់ដោយសារទង្វើផ្ទែកព្រហ្មទណ្ឌ និង ត្រូវបានកាត់ទោសឲ្យជាប់ពន្ធនាគាររយៈពេល ១ ឆ្នាំ ឬ លើសពីនេះ<br>- បោះបង់ចោលសញ្ជាតិណាមួយផ្សេងទៀតបន្ទាប់ពីទទួលបានភាពជាពលរដ្ឋឥណ្ឌូនេស៊ី<br>- មានប្រាក់ចំណូលបិតបេរ និង<br>- ទូទាត់ថ្លៃធ្វើសញ្ជាតូបនីយកម្ម។ | **មាត្រា ១៩**<br>**[តាមឆន្ទានុសិទ្ធិ]**<br>- បានរៀបអាពាហ៍ពិពាហ៍ដោយស្របច្បាប់ជាមួយពលរដ្ឋឥណ្ឌូនេស៊ី និង<br>- បានស្នាក់នៅអស់រយៈពេលយ៉ាងតិច ៥ ឆ្នាំជាបន្តបន្ទាប់ ឬ ១០ ឆ្នាំ ដោយមិនជាប់លាប់។ |

| ប្រទេស | តាមរយៈសញ្ជាតូបនីយកម្ម | តាមរយៈអាពាហ៍ពិពាហ៍ |
|---|---|---|
| | **មាត្រា ២០ – ផ្អែកលើគុណសម្បត្តិពិសេសៗ**<br>**[តាមឆន្ទានុសិទ្ធិ]**<br>- ស័ក្តិសមនឹងទទួលបានគុណសម្បត្តិសម្រាប់ការផ្តល់សេវាដល់ប្រទេសឥណ្ឌូនេស៊ី និង<br>- ទទួលបានសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាអ្នកតំណាងឲ្យប្រជាជន។ | |
| ឡាវ | **មាត្រា ១៤ – បញ្ញត្តិទូទៅ**<br>**[តាមឆន្ទានុសិទ្ធិ]**<br>- មានអាយុ ១៨ ឆ្នាំ ឡើងទៅ<br>- គោរពរដ្ឋធម្មនុញ្ញ និង ច្បាប់នានា<br>- និយាយ អាន និង សរសេរភាសាឡាវបានយ៉ាងស្ទាត់ជំនាញ<br>- បានធ្វើសមាហរណកម្មទៅក្នុងសង្គម និង វប្បធម៌របស់ប្រទេសឡាវ និង គោរពប្រពៃណីឡាវ<br>- មានសុខភាពល្អ<br>- មិនធ្លាប់ត្រូវបានកាត់ទោសឲ្យជាប់ពន្ធនាគារដោយតុលាការណាមួយនោះទេ<br>- ចូលរួមនៅក្នុងកិច្ចការពារ និង អភិវឌ្ឍប្រទេសឡាវ<br>- មិនបង្កក្តីអន្តរាយចំពោះផលប្រយោជន៍ជាតិ<br>- យល់ព្រមបោះបង់ចោលសញ្ជាតិពីមុន<br>- មានទីលំនៅអចិន្ត្រៃយ៍នៅក្នុងប្រទេសឡាវ ក្នុងរយៈពេល ១០ ឆ្នាំជាបន្តបន្ទាប់ និង<br>- មានស្ថានភាពសេដ្ឋកិច្ចដែលមានលំនឹង។<br>**មាត្រា ១៥ – សម្រាប់ជនដែលមានជាតិសាសន៍ឡាវ**<br>**[តាមឆន្ទានុសិទ្ធិ]**<br>- មានអាយុ ១៨ ឆ្នាំ ឡើងទៅ<br>- គោរពរដ្ឋធម្មនុញ្ញ និង ច្បាប់នានា<br>- និយាយ អាន និង សរសេរភាសាឡាវបានយ៉ាងស្ទាត់ជំនាញ<br>- បានធ្វើសមាហរណកម្មទៅក្នុងសង្គម និង វប្បធម៌របស់ប្រទេសឡាវ និង គោរពប្រពៃណីឡាវ<br>- មានសុខភាពល្អ<br>- មិនធ្លាប់ត្រូវបានកាត់ទោសឲ្យជាប់ពន្ធនាគារដោយតុលាការណាមួយនោះទេ<br>- ចូលរួមនៅក្នុងកិច្ចការពារ និង អភិវឌ្ឍប្រទេសឡាវ<br>- មិនបង្កក្តីអន្តរាយចំពោះផលប្រយោជន៍ជាតិ | គ្មាន |

| ប្រទេស | តាមរយៈសញ្ជាតូបនីយកម្ម | តាមរយៈអាពាហ៍ពិពាហ៍ |
| --- | --- | --- |
| | - មានទីលំនៅអចិន្ត្រៃយ៍នៅក្នុងប្រទេសឡាវ ក្នុងរយៈពេល ៥ ឆ្នាំជាបន្តបន្ទាប់ សម្រាប់បុគ្គលដែលបានទទួលសញ្ជាតិណាមួយផ្សេងទៀតកាលពីមុន ឬ មានទីលំនៅអចិន្ត្រៃយ៍នៅក្នុងប្រទេសឡាវ ក្នុងរយៈពេល ៣ ឆ្នាំ សម្រាប់ជនគ្មានសញ្ជាតិ និង<br>- មានស្ថានភាពសេដ្ឋកិច្ចដែលមានលំនឹង។ | |
| ម៉ាឡេស៊ី | **មាត្រា ១៩ – ភាពជាពលរដ្ឋតាមរយៈសញ្ជាតូបនីយកម្ម**<br>**[តាមឆន្ទានុសិទ្ធិ]**<br>- មានអាយុលើសពី ២១ ឆ្នាំ<br>- បានស្នាក់នៅអស់រយៈពេល ១០ ឆ្នាំ ក្នុងរយៈពេល ១២ ឆ្នាំចុងក្រោយ<br>- បានស្នាក់នៅអស់រយៈពេល ១២ ខែ ភ្លាមៗមុនពេលដាក់ពាក្យស្នើសុំ<br>- មានអត្តចរិតល្អ<br>- ចេះភាសាម៉ាឡេ និង<br>- ធ្វើការស្បថសច្ចា។ | **មាត្រា ១៥(១០ – ភាពជាពលរដ្ឋតាមរយៈការចុះបញ្ជី (ភរិយា ឬកូនៗរបស់ពលរដ្ឋ)**<br>**[តាមឆន្ទានុសិទ្ធិ]**<br>- ជាស្ត្រីដែលបានរៀបអាពាហ៍ពិពាហ៍ដោយស្របច្បាប់ជាមួយពលរដ្ឋម៉ាឡេស៊ី<br>- មានស្វាមីជាពលរដ្ឋម៉ាឡេស៊ីនៅដើមខែតុលា ឆ្នាំ១៩៦២<br>- បានស្នាក់នៅរយៈពេល ២ ឆ្នាំ ភ្លាមៗមុនពេលដាក់ពាក្យស្នើសុំ និង<br>- មានអត្តចរិតល្អ |
| មីយ៉ាន់ម៉ា | **មាត្រា ៤២**<br>**[តាមឆន្ទានុសិទ្ធិ]**<br>- បានចូល និង ស្នាក់នៅក្នុងប្រទេសមីយ៉ាន់ម៉ា នៅមុនថ្ងៃទី០៤ ខែមករា ឆ្នាំ១៩៤៨ និង<br>- មានកូនកើតនៅប្រទេសមីយ៉ាន់ម៉ា។<br>**មាត្រា ៤៣ និង ៤៤**<br>**[តាមឆន្ទានុសិទ្ធិ]**<br>- កើតនៅក្នុងប្រទេសមីយ៉ាន់ម៉ា ឬ នៅក្រៅប្រទេស ជាកូនរបស់ពលរដ្ឋ និង ជនបរទេស<br>- មានអាយុលើសពី ១៨ ឆ្នាំ<br>- អាចនិយាយភាសាជាតិណាមួយបានយ៉ាងល្អ<br>- មានអត្តចរិតល្អ និង<br>- មានសុខភាពផ្លូវចិត្តល្អ<br>ឬ | **មាត្រា ៤៥**<br>**[តាមឆន្ទានុសិទ្ធិ]**<br>- បានរៀបអាពាហ៍ពិពាហ៍ដោយស្របច្បាប់ជាមួយពលរដ្ឋ ពលរដ្ឋតាមច្បាប់ ឬ ពលរដ្ឋដែលបានធ្វើសញ្ជាតូបនីយកម្ម<br>- មានលិខិតបញ្ជាក់ការចុះបញ្ជីរបស់ជនបរទេសមុនឆ្នាំ១៩៨២<br>- មានអាយុលើសពី ១៨ ឆ្នាំ<br>- មានអត្តចរិតល្អ និង<br>- មានសុខភាពផ្លូវចិត្តល្អ<br>- ជាស្វាមី ឬ ភរិយាតែម្នាក់គត់ និង<br>- បានស្នាក់នៅអស់រយៈពេល ៣ ឆ្នាំ។ |

| ប្រទេស | តាមរយៈសញ្ជាតូបនីយកម្ម | តាមរយៈអាពាហ៍ពិពាហ៍ |
|---|---|---|
| | - កើតនៅក្នុងប្រទេសមីយ៉ាន់ម៉ា ឬ នៅក្រៅប្រទេស ជាកូនរបស់ពលរដ្ឋតាមច្បាប់ និង ពលរដ្ឋដែលបានធ្វើសញ្ជាតូបនីយកម្ម<br>- មានអាយុលើសពី ១៨ ឆ្នាំ<br>- អាចនិយាយភាសាជាតិណាមួយបានយ៉ាងល្អ<br>- មានអត្តចរិតល្អ និង<br>- មានសុខភាពផ្លូវចិត្តល្អ<br>ឬ<br>- កើតនៅក្នុងប្រទេសមីយ៉ាន់ម៉ា ឬ នៅក្រៅប្រទេស ជាកូនរបស់ពលរដ្ឋតាមច្បាប់ និង ជនបរទេស<br>- មានអាយុលើសពី ១៨ ឆ្នាំ<br>- អាចនិយាយភាសាជាតិណាមួយបានយ៉ាងល្អ<br>- មានអត្តចរិតល្អ និង<br>- មានសុខភាពផ្លូវចិត្តល្អ<br>ឬ<br>- កើតនៅក្នុងប្រទេសមីយ៉ាន់ម៉ា ឬ នៅក្រៅប្រទេស ជាកូនរបស់ពលរដ្ឋដែលបានធ្វើសញ្ជាតូបនីយកម្មទាំងពីរនាក់<br>- មានអាយុលើសពី ១៨ ឆ្នាំ<br>- អាចនិយាយភាសាជាតិណាមួយបានយ៉ាងល្អ<br>- មានអត្តចរិតល្អ និង<br>- មានសុខភាពផ្លូវចិត្តល្អ<br>ឬ<br>- កើតនៅក្នុងប្រទេសមីយ៉ាន់ម៉ា ឬ នៅក្រៅប្រទេស ជាកូនរបស់ពលរដ្ឋដែលបានធ្វើសញ្ជាតូបនីយកម្ម និង ជនបរទេស<br>- មានអាយុលើសពី ១៨ ឆ្នាំ<br>- អាចនិយាយភាសាជាតិណាមួយបានយ៉ាងល្អ<br>- មានអត្តចរិតល្អ និង<br>- មានសុខភាពផ្លូវចិត្តល្អ។ | |

| ប្រទេស | តាមរយៈសញ្ជាតូបនីយកម្ម | តាមរយៈអាពាហ៍ពិពាហ៍ |
|---|---|---|
| ហ្វីលីពីន | **ខចែង ១(៤) នៃរដ្ឋធម្មនុញ្ញ ឆ្នាំ១៩៨៧**<br>**[តាមឆន្ទានុសិទ្ធិ]**<br>- បានធ្វើសញ្ជាតូបនីយកម្មស្របតាមច្បាប់។<br>**បានកែសម្រួលច្បាប់ស្ដីពីសញ្ជាតូបនីយកម្ម (ការធ្វើសញ្ជាតូបនីយកម្មតាមប្រព័ន្ធតុលាការ) ស្របតាមច្បាប់របស់រដ្ឋសហធន (C.A.) លេខ ៤៧៣**<br>**ច្បាប់ស្ដីពីការធ្វើសញ្ជាតូបនីយកម្មតាមផ្នែករដ្ឋបាល ស្របតាមច្បាប់របស់សាធារណរដ្ឋ (R.A) លេខ ៩១៣៩ (ការធ្វើសញ្ជាតូបនីយកម្មតាមផ្នែករដ្ឋបាល)**<br>**ការធ្វើសញ្ជាតូបនីយកម្មដែលមានលក្ខណៈក្លាយ (ចូរមើល Republic v. Batugas, G.R. លេខ ១៨៣១១០ ថ្ងៃទី០៧ ខែតុលា ឆ្នាំ២០១៣ ដែលដកស្រង់ ខចែង ១៥ C.A. លេខ ៤៧៣)** | |
| សិង្ហបុរី | **មាត្រា ១២៧**<br>**[តាមឆន្ទានុសិទ្ធិ]**<br>- មានអាយុលើសពី ២១ ឆ្នាំ<br>- បានស្នាក់នៅអស់រយៈពេលសរុប មិនតិចជាង ១០ ឆ្នាំ ក្នុងរយៈពេល ១២ ឆ្នាំចុងក្រោយ ភ្លាមៗមុនកាលបរិច្ឆេទដាក់ពាក្យស្នើសុំ<br>- បានស្នាក់នៅអស់រយៈពេល ១២ ខែ ភ្លាមៗមុនពេលដាក់ពាក្យស្នើសុំ<br>- មានអត្តចរិតល្អ<br>- មានចំណេះដឹងអំពីភាសាជាតិ និង<br>- ធ្វើការស្បថសច្ចា។ | **មាត្រា ១២៣(២)**<br>**[តាមឆន្ទានុសិទ្ធិ]**<br>- ជាស្ត្រីដែលបានរៀបអាពាហ៍ពិពាហ៍ជាមួយពលរដ្ឋសិង្ហបុរី<br>- បានស្នាក់នៅ ក្នុងរយៈពេលមិនតិចជាង ២ ឆ្នាំជាបន្តបន្ទាប់មុនពេលដាក់ពាក្យស្នើសុំ<br>- មានបំណងស្នាក់នៅជាអចិន្ត្រៃយ៍នៅក្នុងប្រទេសសិង្ហបុរី និង<br>- មានអត្តចរិតល្អ។ |
| ថៃ | **ខចែង ១០ – បញ្ញត្តិទូទៅ**<br>**[តាមឆន្ទានុសិទ្ធិ]**<br>- មានអាយុលើសពី ២០ ឆ្នាំ<br>- មានអត្តចរិតល្អ<br>- មានមុខរបរទៀងទាត់<br>- បានស្នាក់នៅអស់រយៈពេល ៥ ឆ្នាំ និង<br>- ចេះភាសាថៃ។ | **ខចែង ៩**<br>**[តាមឆន្ទានុសិទ្ធិ]**<br>- ជាស្ត្រីបរទេស<br>- បានរៀបអាពាហ៍ពិពាហ៍ដោយស្របច្បាប់ជាមួយបុរសជនជាតិថៃ និង<br>- ដាក់ពាក្យស្នើសុំទៅកាន់មន្ត្រីមានសមត្ថកិច្ច។ |

| ប្រទេស | តាមរយៈសញ្ជាតូបនីយកម្ម | តាមរយៈអាពាហ៍ពិពាហ៍ |
|---|---|---|
| | **ខចែង ១១ – ផ្តែកលើគុណសម្បត្តិពិសេសៗ**<br>**[តាមឆន្ទានុសិទ្ធិ]**<br>- បានផ្តល់សេវាពិសេសៗដល់ប្រទេសថៃ<br>- ជាកូន ភរិយា ឬ ស្វាមីរបស់ជនដែលបានធ្វើសញ្ជាតូបនីយកម្មជាពលរដ្ឋថៃ ឬ បានទទួលសញ្ជាតិថៃឡើងវិញ<br>- មានអាយុលើសពី ២០ ឆ្នាំ<br>- មានអាកប្បកិរិយាល្អ និង<br>- មានមុខរបរទៀងទាត់<br>ឬ<br>- បានផ្តល់សេវាពិសេសៗដល់ប្រទេសថៃ<br>- ជាជនដែលធ្លាប់មានសញ្ជាតិថៃ<br>- មានអាយុលើសពី ២០ ឆ្នាំ<br>- មានអាកប្បកិរិយាល្អ និង<br>- មានមុខរបរទៀងទាត់<br>ឬ<br>- បានផ្តល់សេវាពិសេសៗដល់ប្រទេសថៃ<br>- ជាស្វាមីរបស់ស្ត្រីជនជាតិថៃ<br>- មានអាយុលើសពី ២០ ឆ្នាំ<br>- មានអាកប្បកិរិយាល្អ និង<br>- មានមុខរបរទៀងទាត់។<br>**ខចែង ១២ កថាខណ្ឌទី ២ – សម្រាប់កូនរបស់អ្នកដាក់ពាក្យស្នើសុំសញ្ជាតូបនីយកម្ម**<br>**[តាមឆន្ទានុសិទ្ធិ]**<br>- ជាកូនរបស់អ្នកដាក់ពាក្យស្នើសុំធ្វើសញ្ជាតូបនីយកម្ម<br>- មានអាយុក្រោម ២០ ឆ្នាំ<br>- មានទីលំនៅនៅក្នុងប្រទេសថៃ និង<br>- មានអាកប្បកិរិយាល្អ។ | |

| ប្រទេស | តាមរយៈសញ្ជាតូបនីយកម្ម | តាមរយៈអាពាហ៍ពិពាហ៍ |
|---|---|---|
| | **ឧទែង ១២/១ – ពាក្យស្នើសុំសញ្ជាតូបនីយកម្មតាងនាមឲ្យជនដែលគ្មានសញ្ជាតិថៃ [តាមឆន្ទានុសិទ្ធិ]**<br>- ជាជនអសមត្ថភាពដែលបានកើតនៅក្នុងប្រទេសថៃ<br>- មានអាយុលើសពី ២០ ឆ្នាំ<br>- បានដាក់ពាក្យស្នើសុំដោយហិតូបត្ថម្ភកៈ ស្របតាមដីការបស់តុលាការ<br>- មានអាកប្បកិរិយាល្អ និង<br>- បានស្នាក់នៅអស់រយៈពេល ៥ ឆ្នាំ<br>ឬ<br>- ជាកុមារដែលស្នាក់នៅក្នុងផ្ទះថៃទាំសាធារណៈ ដែលបានចុះបញ្ជីជាមួយរដ្ឋមន្ត្រី អស់រយៈពេល ១០ ឆ្នាំ ឬ លើសពីនេះ<br>- មានអាយុក្រោម ២០ ឆ្នាំ<br>- បានដាក់ពាក្យស្នើសុំដោយអ្នកគ្រប់គ្រងផ្ទះថៃទាំសាធារណៈ<br>- មានអាកប្បកិរិយាល្អ<br>- បានស្នាក់នៅអស់រយៈពេល ៥ ឆ្នាំ និង<br>- ចេះភាសាថៃ<br>ឬ<br>- ជាកូនដែលត្រូវបានសុំដោយប្រជាជនថៃ អស់រយៈពេល ៥ ឆ្នាំឡើងទៅ<br>- កើតនៅក្នុងប្រទេសថៃ<br>- មានអាយុក្រោម ២០ ឆ្នាំ<br>- បានដាក់ពាក្យស្នើសុំដោយឪពុក/ម្ដាយចិញ្ចឹមជនជាតិថៃ<br>- មានអាកប្បកិរិយាល្អ<br>- បានស្នាក់នៅអស់រយៈពេល ៥ ឆ្នាំ និង<br>- ចេះភាសាថៃ។ | |

| ប្រទេស | តាមរយៈសញ្ជាតូបនីយកម្ម | តាមរយៈអាពាហ៍ពិពាហ៍ |
|---|---|---|
| វៀតណាម | **មាត្រា ១៩(១) – បញ្ញត្តិទូទៅ**<br>**[តាមឆន្ទានុសិទ្ធិ]**<br>- ជាពលរដ្ឋបរទេស ឬ ជាជនគ្មានសញ្ជាតិ ដែលស្នាក់នៅជាអចិន្ត្រៃយ៍នៅក្នុងប្រទេសវៀតណាម<br>- មានសមត្ថភាពធ្វើសកម្មភាពជាពលរដ្ឋយ៉ាងពេញលេញ<br>- គោរពរដ្ឋធម្មនុញ្ញ និង ច្បាប់នានារបស់ប្រទេសវៀតណាម<br>- យល់ភាសាវៀតណាមបានយ៉ាងគ្រប់គ្រាន់ដើម្បីធ្វើសមាហរណកម្មទៅក្នុងសហគមន៍<br>- បានស្នាក់នៅអស់រយៈពេល ៥ ឆ្នាំ<br>- មានសមត្ថភាពប្រកបរបរចិញ្ចឹមជីវិតនៅក្នុងប្រទេសវៀតណាម។<br><br>**មាត្រា ១៩(២) – សម្រាប់ឪពុកម្តាយ និង កូនរបស់ពលរដ្ឋវៀតណាម**<br>**[តាមឆន្ទានុសិទ្ធិ]**<br>- ជាឪពុក/ម្តាយ ឬ កូនបង្កើតរបស់ពលរដ្ឋវៀតណាម<br>- មានសមត្ថភាពធ្វើសកម្មភាពជាពលរដ្ឋយ៉ាងពេញលេញ និង<br>- គោរពរដ្ឋធម្មនុញ្ញ និង ច្បាប់នានារបស់ប្រទេសវៀតណាម។<br><br>**មាត្រា ១៩(២) – ផ្អែកលើគុណសម្បត្តិពិសេសៗ**<br>**[តាមឆន្ទានុសិទ្ធិ]**<br>- បានធ្វើការរួមចំណែកដែលគួរឲ្យកោតសរសើរចំពោះការស្ថាបនា និង កិច្ចការពារជាតិរបស់ប្រទេសវៀតណាម ឬ ដែលមានសារប្រយោជន៍ចំពោះប្រទេសវៀតណាម<br>- មានសមត្ថភាពធ្វើសកម្មភាពជាពលរដ្ឋយ៉ាងពេញលេញ និង<br>- គោរពរដ្ឋធម្មនុញ្ញ និង ច្បាប់នានារបស់ប្រទេសវៀតណាម។ | មាត្រា ១៩(២)<br>**[តាមឆន្ទានុសិទ្ធិ]**<br>- ជាស្វាមី/ភរិយារបស់ពលរដ្ឋវៀតណាម<br>- មានសមត្ថភាពធ្វើសកម្មភាពជាពលរដ្ឋយ៉ាងពេញលេញ និង<br>- គោរពរដ្ឋធម្មនុញ្ញ និង ច្បាប់នានារបស់ប្រទេសវៀតណាម។ |

# ឧបសម្ព័ន្ធទី២៖ សម្រង់អនុសាសន៍ស្តីពីការចុះបញ្ជីកំណើត និង សញ្ជាតិ ពីសេចក្តីសង្កេតសន្និដ្ឋានដែលត្រូវបានធ្វើឡើងដោយគណៈកម្មាធិការសិទ្ធិកុមារ និង គណៈកម្មាធិការលុបបំបាត់ការរើសអើងប្រឆាំងនឹងស្ត្រីភេទ សម្រាប់ប្រទេសសមាជិកអាស៊ាន

## ប្រទេសប្រ៊ុយណេដារូសាឡឹម

### អំពីការចុះបញ្ជីកំណើត៖

- បន្តកិច្ចខិតខំប្រឹងប្រែងរបស់ខ្លួនដើម្បីធានាចំពោះការចុះបញ្ជីកំណើតកុមារគ្រប់រូប ជាពិសេស ការអនុវត្តយុទ្ធនាការបង្កើនការយល់ដឹងអំពីការចុះបញ្ជីកំណើត។[413]
- ពង្រឹងកិច្ចខិតខំប្រឹងប្រែងនៅក្នុងការអនុវត្តរាល់វិធានការទាំងអស់ដែលចាំបាច់ ដើម្បីធានាចំពោះការចុះបញ្ជីកំណើតរបស់កុមារគ្រប់រូបនៅតាមតំបន់ជនបទ និង នៅក្នុងទីក្រុង កុមារនៅក្នុងស្ថានភាពអន្តោប្រវេសន៍ រួមបញ្ចូលទាំងការធ្វើអន្តោប្រវេសន៍ខុសច្បាប់ផងដែរ និង កុមារនៅ Kampong Ayer។[414]

### អំពីសញ្ជាតិ៖

- ដក ខ រក្សាសិទ្ធិរបស់ខ្លួនចំពោះមាត្រា ៩ (២) នៃអនុសញ្ញា[415]
- ធ្វើវិសោធនកម្មច្បាប់ស្តីពីសញ្ជាតិ ដោយមានបំណងធ្វើឲ្យច្បាប់នេះអនុលោមតាមអនុសញ្ញានេះទាំងស្រុង និង ធ្វើឲ្យស្ត្រីប្រ៊ុយណេអាចផ្ទេរសញ្ជាតិរបស់ពួកគេទៅកាន់កូនៗ និង ស្វាមីដែលជាជនបរទេស របស់ពួកគេបានដោយផ្អែកលើមូលដ្ឋានស្មើភាពគ្នាជាមួយបុរសប្រ៊ុយណេ។[416]
- កែសម្រួលច្បាប់ស្តីពីសញ្ជាតិប្រ៊ុយណេ ដើម្បីធានាថា កុមារដែលមានឪពុក/ម្តាយម្នាក់ដែលជាពលរដ្ឋប្រ៊ុយណេទទួលបានភាពជាពលរដ្ឋប្រ៊ុយណេដោយស្មើភាពគ្នា ដោយមិនគិតថាតើពលរដ្ឋប្រ៊ុយណេនោះគឺជាឪពុក ឬ ម្តាយនោះទេ។[417]
- ត្រួតពិនិត្យឡើងវិញលើច្បាប់ស្តីពីសញ្ជាតិប្រ៊ុយណេ និង ច្បាប់ដែលពាក់ព័ន្ធដទៃទៀត ដែលទាក់ទងនឹងសញ្ជាតិដើម្បីធានា ថាស្ត្រីប្រ៊ុយណេអាចផ្ទេរសញ្ជាតិទៅកាន់កូនៗរបស់ពួកគេបានដោយស្វ័យប្រវត្តិ និង ពង្រឹងវិធីសាស្ត្រដើម្បីធ្វើសញ្ជាតូបនីយកម្មកុមារគ្មានសញ្ជាតិ និង រៀបចំយុទ្ធនាការបង្កើនការយល់ដឹងនៅក្នុងចំណោមឪពុកម្តាយ និង អាណាព្យាបាលរបស់កុមារគ្មានសញ្ជាតិ។[418]

---

413 គណៈកម្មាធិការសិទ្ធិកុមារនៃ UN សេចក្តីសង្កេតសន្និដ្ឋានសម្រាប់ប្រទេសប្រ៊ុយណេដារូសាឡឹម ឆ្នាំ២០០៣។

414 គណៈកម្មាធិការសិទ្ធិកុមារនៃ UN សេចក្តីសង្កេតសន្និដ្ឋានសម្រាប់ប្រទេសប្រ៊ុយណេដារូសាឡឹម ឆ្នាំ២០១៦។

415 គណៈកម្មាធិការលុបបំបាត់ការរើសអើងប្រឆាំងនឹងស្ត្រីភេទ (CEDAW) នៃ UN សេចក្តីសង្កេតសន្និដ្ឋានស្តីពីការរួមបញ្ចូលគ្នានៃរបាយការណ៍តាមកាលកំណត់លើកទីមួយ និង លើកទីពីរ របស់ប្រទេសប្រ៊ុយណេដារូសាឡឹម https://tbinternet.ohchr.org/_layouts/treatybodyexternal/Download.aspx?symbolno=CEDAW/C/BRN/CO/1-2&Lang=En

416 គណៈកម្មាធិការលុបបំបាត់ការរើសអើងប្រឆាំងនឹងស្ត្រីភេទ (CEDAW) នៃ UN សេចក្តីសង្កេតសន្និដ្ឋានស្តីពីការរួមបញ្ចូលគ្នានៃរបាយការណ៍តាមកាលកំណត់លើកទីមួយ និង លើកទីពីរ របស់ប្រទេសប្រ៊ុយណេដារូសាឡឹម https://tbinternet.ohchr.org/_layouts/treatybodyexternal/Download.aspx?symbolno=CEDAW/C/BRN/CO/1 -2&Lang=En

417 គណៈកម្មាធិការសិទ្ធិកុមារ (CRC) នៃ UN បញ្ជីបញ្ហាដែលទាក់ទងនឹងការរួមបញ្ចូលគ្នានៃរបាយការណ៍តាមកាលកំណត់លើកទីពីរ និង លើកទីបី របស់ប្រទេសប្រ៊ុយណេដារូសាឡឹម ថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០១៥ CRC/C/BRN/Q/២-៣ អាចស្វែងរកបាននៅ៖ https://www.refworld.org/docid/56a0872a4.html

418 គណៈកម្មាធិការសិទ្ធិកុមារនៃ UN សេចក្តីសង្កេតសន្និដ្ឋានសម្រាប់ប្រទេសប្រ៊ុយណេដារូសាឡឹម ឆ្នាំ២០១៦។

## ប្រទេសកម្ពុជា

### អំពីការចុះបញ្ជីកំណើត៖

- ធានាចំពោះការចុះបញ្ជីកំណើតដោយឥតគិតថ្លៃសម្រាប់កុមារគ្រប់រូប ដោយមិនគិតអំពីឋានៈតាមផ្លូវច្បាប់ និង ដើមកំណើតរបស់ឪពុកម្តាយរបស់ពួកគេនោះទេ និង ធានាថាកុមារដែលមានដើមកំណើតជាជនជាតិវៀតណាម ទទួលបានការចុះបញ្ជីកំណើត ឯកសារអត្តសញ្ញាណ ការអប់រំសាធារណៈ និង សេវាថែទាំ សុខភាពបានយ៉ាង មាន ប្រសិទ្ធភាព។[419]

### អំពីសញ្ជាតិ៖

- ពង្រឹងកិច្ចខិតខំប្រឹងប្រែងជួយសម្រួលដល់ការចុះបញ្ជីកំណើតរបស់កុមារ ដែលមានម្តាយដែលជាជនជាតិវៀតណាម និង ការទទួលបានភាពជាពលរដ្ឋរបស់ពួកគេ[420]
- ពិចារណាទទួលយកអនុសញ្ញា ឆ្នាំ១៩៥៤ ដែលទាក់ទងនឹងឋានៈរបស់ជនគ្មានសញ្ជាតិ និង អនុសញ្ញា ឆ្នាំ១៩៦១ ស្តីពីការកាត់បន្ថយភាពគ្មានសញ្ជាតិ[421]
- ជួយសម្រួលដល់ការទទួលបានឯកសារអត្តសញ្ញាណកម្ម និង ធានាចំពោះសិទ្ធិរបស់កុមារគ្មានសញ្ជាតិ ដែលកើតនៅលើដែនដីនៃប្រទេសកម្ពុជា ដែលជនកូនរបស់ជាគ្មានសញ្ជាតិ ឲ្យទទួលបានសញ្ជាតិ។[422]

## ប្រទេសឥណ្ឌូនេស៊ី

### អំពីការចុះបញ្ជីកំណើត៖

- ធានាថាកុមារគ្រប់រូបដែលកើតនៅក្នុងប្រទេសឥណ្ឌូនេស៊ីត្រូវបានចុះបញ្ជី និង បានចេញសំបុត្រកំណើត ដោយមិនគិតអំពីសញ្ជាតិ សាសនា និង ឋានៈនៅពេលកើតរបស់ពួកគេនោះទេ និង ថាការចុះបញ្ជីកំណើតបានទទួលការជួយសម្រួល និង ត្រូវបានធ្វើឡើងដោយឥតគិតថ្លៃ នៅគ្រប់ទីកន្លែងទាំងអស់ និង នៅគ្រប់កាលៈទេសៈទាំងអស់
- លុបចោលការចង្អុលបង្ហាញអំពីទំនាក់ទំនងផ្នែកសាសនានៅលើអត្តសញ្ញាណប័ណ្ណ និង ភ្ជិតចន្លោះប្រហោងនៅក្នុងច្បាប់ ដែលអាចធ្វើឲ្យកុមារមួយចំនួនគ្មានសញ្ជាតិ[423]

---

419 គណៈកម្មាធិការសិទ្ធិកុមារនៃ UN សេចក្តីសង្កេតសន្និដ្ឋានសម្រាប់ប្រទេសកម្ពុជា ឆ្នាំ២០១១។

420 គណៈកម្មាធិការសិទ្ធិកុមារ (CRC) នៃ UN បញ្ជីបញ្ហាដែលទាក់ទងនឹងការរួមបញ្ចូលគ្នានៃរបាយការណ៍តាមកាលកំណត់លើកទីពីរ និង លើកទីបីរបស់ប្រទេសកម្ពុជា (CRC/C/KHM/២-៣) ចូរមើល CRC/C/SR.១៦៣៩ ធ្វើឡើងនៅថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១១ អាចស្វែងរកបាននៅ៖ https://tbinternet.ohchr.org/_layouts/treatybodyexternal/Download.aspx?symbolno=CRC/C/KHM/CO/2&Lang=En។

គណៈកម្មាធិការ (CRC) មានក្តីកង្វល់ថា កូនរបស់ជនអន្តោប្រវេសន៍ខុសច្បាប់ ពុំមានសិទ្ធិទទួលបានការចុះបញ្ជីកំណើត និង ថាគ្រួសាររបស់ជនជាតិវៀតណាម ជាញឹកញាប់ បានទទួលការបដិសេធ នៅពេលដែលពួកគេព្យាយាមដើម្បីទទួលបានសំបុត្រកំណើតសម្រាប់កូនៗរបស់ពួកគេ។

421 គណៈកម្មាធិការលុបបំបាត់ការរើសអើងប្រឆាំងនឹងស្ត្រីភេទ (CEDAW) នៃ UN បញ្ជីបញ្ហា និង សំណួរនានាមាននៅក្នុង CEDAW/C/KHM/Q/៤-៥ ហើយការឆ្លើយតបរបស់រដ្ឋាភិបាលកម្ពុជាមាននៅក្នុង CEDAW/C/KHM/Q/៤-៥/Add.១ អាចស្វែងរកបាននៅ៖ https://tbinternet.ohchr.org/_layouts/treatybodyexternal/Download.aspx?symbolno=CEDAW/C/KHM/CO/4-5&Lang=En។

គណៈកម្មាធិការ (CEDAW) មានកង្វល់ថា ស្ត្រីជនជាតិវៀតណាម ត្រូវឆ្លងកាត់ការលំបាកជាច្រើននៅក្នុងការចុះបញ្ជីកំណើត និង ការទទួលបានភាពជាពលរដ្ឋកម្ពុជា ដែលធ្វើឲ្យពួកគេប្រឈមមុខនឹងហានិភ័យនៃភាពគ្មានសញ្ជាតិ។ គណៈកម្មាធិការបានទាមទារឲ្យរដ្ឋភាគីធ្វើសកម្មភាព។

422 គណៈកម្មាធិការសិទ្ធិមនុស្សនៃ UN សេចក្តីសង្កេតសន្និដ្ឋានសម្រាប់ប្រទេសកម្ពុជា ឆ្នាំ២០១៥។

423 គណៈកម្មាធិការសិទ្ធិកុមារ (CRC) នៃ UN ការរួមបញ្ចូលគ្នានៃរបាយការណ៍តាមកាលកំណត់លើកទីបី និង លើកទីបួន របស់ប្រទេសឥណ្ឌូនេស៊ី (CRC/C/IDN/៣-៤) នៅក្នុងកិច្ចប្រជុំ លើកទី ១៨៩០ និង ១៨៩១ របស់ខ្លួន ចូរមើល CRC/C/SR.១៨៩០ និង ១៨៩១ និង ត្រូវបានអនុម័តនៅក្នុងកិច្ចប្រជុំលើកទី ១៩០១ ដែលធ្វើឡើងនៅថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០១៤ អាចស្វែងរកបាននៅ៖ https://tbinternet.ohchr.org/_layouts/treatybodyexternal/Download.aspx?symbolno=CRC/C/IDN/CO/3 -4&Lang=En

- ធានាចំពោះការអនុវត្តប្រកបដោយប្រសិទ្ធភាពនូវច្បាប់លេខ ២៣/២០០២ ស្តីពីកិច្ចការពារកុមារ ដែលចែងថា កុមារគ្រប់រូបត្រូវតែទទួលបានអត្តសញ្ញាណពីកំណើត និង ច្បាប់លេខ ២៣/២០០៦ ស្តីពីរដ្ឋបាលប្រជាជន ដែលចែងថា ការចេញសំបុត្រកំណើតត្រូវតែឥតគិតថ្លៃ និង បង្កើតយន្តការពិនិត្យតាមដានមួយ ដើម្បីធានាចំពោះការអនុវត្តច្បាប់ទាំងនេះ[424]
- ពង្រឹងយុទ្ធនាការបង្កើតការយល់ដឹងជាសាធារណៈរបស់ខ្លួន និង អនុវត្តវិធីសាស្ត្រដ៏រឹងមាំ ដើម្បីធានាថា ស្ត្រីក្រីក្រ និង ស្ត្រីនៅតាមទីជនបទបានដឹងអំពីលក្ខខណ្ឌតម្រូវដែលទាក់ទងនឹងការចុះបញ្ជីកំណើត និង លិខិតបញ្ជាក់នានា និង អាចទទួលបានសំបុត្រកំណើត និង សេវាចុះបញ្ជី ដែលផ្តល់ជូនដោយរដ្ឋាភិបាល បានយ៉ាងងាយស្រួល។[425]

### អំពីពីសញ្ជាតិ៖

- ទទួលយកអនុសញ្ញា ឆ្នាំ១៩៥៤ ដែលទាក់ទងនឹងឋានៈរបស់ជនគ្មានសញ្ជាតិ និង អនុសញ្ញា ឆ្នាំ១៩៦១ ស្តីពីការកាត់បន្ថយភាពគ្មានសញ្ជាតិ[426]
- ពិចារណាទទួលយកអនុសញ្ញា ឆ្នាំ១៩៥៤ ដែលទាក់ទងនឹងឋានៈរបស់ជនគ្មានសញ្ជាតិ និង អនុសញ្ញា ឆ្នាំ១៩៦១ ស្តីពីការកាត់បន្ថយភាពគ្មានសញ្ជាតិ។[427]

## ប្រទេសឡាវ

### អំពីការចុះបញ្ជីកំណើត៖

- បង្កើនការយល់ដឹងអំពីសារសំខាន់នៃការចុះបញ្ជីកំណើតបន្ថែមទៀត
- ធ្វើឲ្យនីតិវិធីមានភាពសាមញ្ញ រួមទាំង តាមរយៈការបន្តបង្កើតរចនាសម្ព័ន្ធនៃការចុះបញ្ជីចល័តផងដែរ
- លុបបំបាត់ការលួចលាក់គិតថ្លៃសេវា និង ចំណាយនានាដែលពាក់ព័ន្ធនឹងការចុះបញ្ជី ដែលមានផលជះអវិជ្ជមានចំពោះអត្រានៃការចុះបញ្ជីកំណើត
- លៃលកធនធានមនុស្ស និងធនធានហិរញ្ញវត្ថុឲ្យបានគ្រប់គ្រាន់ ជាពិសេស សម្រាប់ក្រសួងមហាផ្ទៃ ក្នុងគោលបំណងជម្រុញការចុះបញ្ជីកំណើតរបស់កុមារ និង ការចេញសំបុត្រកំណើតបន្ថែមទៀត។[428]
- ជួយសម្រួលដល់ការចុះបញ្ជីកំណើតរបស់កុមារឲ្យបានទាន់ពេលវេលា ជាពិសេសនៅតាមទីជនបទ និង តំបន់ដាច់ស្រយាល ដើម្បីរៀបចំយុទ្ធនាការបង្កើនការយល់ដឹង លុបបំបាត់ឧបសគ្គផ្នែកភាសា និង ប្រើប្រាស់អង្គភាពចុះបញ្ជីអត្រានុកូលដ្ឋានចល័ត។[429]

---

424 Ibid.

425 Ibid.

426 Ibid.

427 គណៈកម្មាធិការលុបបំបាត់ការរើសអើងប្រឆាំងនឹងស្ត្រីភេទ (CEDAW) នៃ UN ការរួមបញ្ចូលគ្នានៃរបាយការណ៍តាមកាលកំណត់លើកទីប្រាំមួយ និង លើកទីប្រាំពី របស់ប្រទេសឥណ្ឌូនេស៊ី (CEDAW/C/IDN/៦-៧) បញ្ជីបញ្ហា និង សំណួរនានាមាននៅក្នុង CEDAW/C/IDN/Q/៦-៧ ហើយការឆ្លើយតបរបស់រដ្ឋាភិបាលឥណ្ឌូនេស៊ីមាននៅក្នុង CEDAW/C/IDN/Q/៦-៧/Add.១ អាចស្វែងរកបាននៅ៖ https://tbinternet.ohchr.org/_layouts/treatybodyexternal/Download.aspx?symbolno=CEDAW/C/IDN/CO/6-7&Lang=En។

428 គណៈកម្មាធិការសិទ្ធិកុមារ (CRC) នៃ UN ការរួមបញ្ចូលគ្នានៃរបាយការណ៍តាមកាលកំណត់លើកទីបី រហូតដល់ លើកទីប្រាំមួយ របស់សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ (CRC/C/LAO/៣-៦) ចូរមើល CRC/C/SR.២៣១៨ និង CRC/C/SR.២៣១៩ សេចក្តីសង្ខេបសន្និដ្ឋាន ដែលត្រូវបានអនុម័តនៅថ្ងៃទី០៥ ខែតុលា ឆ្នាំ២០១៨ អាចស្វែងរកបាននៅ៖ https://tbinternet.ohchr.org/_layouts/treatybodyexternal/Download.aspx?symbolno=CRC/C/LAO/CO/3 -6&Lang=En

គណៈកម្មាធិការនៅតែមានកង្វល់ថា ក្នុងចំណោម ៧៥ ភាគរយនៃកុមារដែលមានអាយុក្រោម ៥ ឆ្នាំ ដែលបានចុះបញ្ជីរួចហើយ មានកុមារតែ ៣៣ ភាគរយប៉ុណ្ណោះដែលមានសំបុត្រកំណើត។ វាក៏ពាក់ព័ន្ធនឹងចំណាយដែលទាក់ទងនឹងការចុះបញ្ជី ដែលជាឧបសគ្គមួយ ព្រមទាំង ភាពខុសគ្នារវាងទីក្រុង និង តំបន់ជនបទ ពាក់ព័ន្ធនឹងចំនួនកុមារដែលមានសំបុត្រកំណើតផងដែរ។

429 គណៈកម្មាធិការលុបបំបាត់ការរើសអើងប្រឆាំងនឹងស្ត្រីភេទ (CEDAW) នៃ UN ការរួមបញ្ចូលគ្នានៃរបាយការណ៍តាមកាលកំណត់លើកទីប្រាំបី និង លើកទីប្រាំបួន របស់សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ (CEDAW/C/LAO/៨-៩) បញ្ជីបញ្ហា និង សំណួរនានាមាននៅក្នុង CEDAW/C/LAO/Q/៨-៩ ហើយការឆ្លើយតបរបស់រដ្ឋភាគីមាននៅក្នុង CEDAW/C/LAO/Q/៨-៩/Add.១ អាចស្វែងរកបាននៅ៖ https://tbinternet.ohchr.org/_layouts/treatybodyexternal/Download.aspx?symbolno=CEDAW/C/LAO/CO/8 -9&Lang=En។

# ប្រទេសម៉ាឡេស៊ី

**អំពីការចុះបញ្ជីកំណើត៖**

- បន្តអនុវត្តប្រព័ន្ធចុះបញ្ជីកំណើតប្រកបដោយប្រសិទ្ធភាព និង ដោយឥតគិតថ្លៃនៅគ្រប់ដំណាក់កាលទាំងអស់ ដែលគ្របដណ្តប់លើដែនដីរបស់ខ្លួនយ៉ាងពេញលេញ និង រៀបចំយុទ្ធនាការបង្កើនការយល់ដឹងដើម្បីផ្សព្វផ្សាយទៅកាន់តំបន់ដែលដាច់ស្រយាលខ្លាំងជាងគេបំផុតនៃដែនដីរបស់ខ្លួន
- ពង្រឹងប្រព័ន្ធចុះបញ្ជីកំណើតរបស់កុមារដែលមិនមែនជាពលរដ្ឋម៉ាឡេស៊ី ដែលកើតនៅក្នុងប្រទេសម៉ាឡេស៊ី កូនរបស់ម្តាយដែលចិញ្ចឹមកូនតែម្នាក់ឯង និង កូនដែលកើតនៅតាមតំបន់ដាច់ស្រយាលនៃប្រទេស។ ស្របពេលជាមួយគ្នានោះ កុមារដែលគ្មានឯកសារផ្លូវការ គួរតែត្រូវបានអនុញ្ញាតឲ្យទទួលបានសេវាមូលដ្ឋាន ដូចជា សេវាសុខាភិបាល និង ការអប់រំ ជាដើម នៅខណៈពេលរង់ចាំការចុះបញ្ជីយ៉ាងត្រឹមត្រូវនោះ។[430]

**អំពីសញ្ជាតិ៖**

- ធ្វើវិសោធនកម្មគ្រប់បញ្ញត្តិទាំងអស់នៃរដ្ឋធម្មនុញ្ញរបស់សហព័ន្ធ ដែលបដិសេធសិទ្ធិស្មើភាពរបស់ស្ត្រី ដែលពាក់ព័ន្ធនឹងការផ្ទេរសញ្ជាតិរបស់ពួកគេទៅឲ្យកូនៗ និង ស្វាមីដែលជាជនបរទេស របស់ពួកគេ
- ឲ្យរដ្ឋភាគីផ្តល់សច្ចាប័នលើអនុសញ្ញាដែលទាក់ទងនឹងឋានៈរបស់ជនគ្មានសញ្ជាតិ និង អនុសញ្ញាស្តីពីការកាត់បន្ថយភាពគ្មានសញ្ជាតិ។[431]

# ប្រទេសមីយ៉ាន់

**អំពីការចុះបញ្ជីកំណើត៖**

- ពង្រឹងកិច្ចខិតខំប្រឹងប្រែងរបស់ខ្លួន ដើម្បីធានាចំពោះការចុះបញ្ជីកុមារគ្រប់រូបដែលបានកើតនៅក្នុងរដ្ឋភាគីបានយ៉ាងមានប្រសិទ្ធភាព ដោយមិនគិតអំពីដើមកំណើតរបស់ពួកគេ និង ដោយគ្មានការរើសអើងនោះទេ
- អនុវត្តវិធីសាស្រ្តពិសេសៗដើម្បីពង្រឹងប្រព័ន្ធចុះបញ្ជីកំណើត ទទួលបានសេវាចុះបញ្ជីកាន់តែច្រើន និង គិតគូរ និង ការបណ្តុះបណ្តាលមន្ត្រីផ្នែកចុះបញ្ជី ដោយមានបំណងធានាចំពោះកុមារគ្រប់រូប
- អភិវឌ្ឍផែនការមួយដើម្បីផ្តល់ការចុះបញ្ជីកំណើតដល់កុមារគ្រប់រូបដែលមិនទាន់បានចុះបញ្ជីកំណើត រហូតដល់ពួកគេមានអាយុ ១៨ ឆ្នាំ
- លុបចោលការរឹតត្បិតតាមភាពជាក់ស្តែង ដើម្បីធានាថាកុមារគ្រប់រូបត្រូវបានចុះបញ្ជីនៅពេលកើត ដោយគ្មានការរើសអើង

---

430 គណៈកម្មាធិការសិទ្ធិកុមារ (CRC) នៃ UN របាយការណ៍តាមកាលកំណត់លើកទីមួយរបស់ប្រទេសម៉ាឡេស៊ី (CRC/C/MYS/1) ចូរមើល CRC/C/SR.១២១៦ និង ១២១៧ សេចក្តីសង្កេតសន្និដ្ឋាន ដែលត្រូវបានអនុម័តនៅថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ២០០៧ អាចស្វែងរកបាននៅ៖ https://tbinternet.ohchr.org/_layouts/treatybodyexternal/Download.aspx?symbolno=CRC/C/MYS/CO/1&Lang=En។

គណៈកម្មាធិការបានកត់សម្គាល់ថា ការដាក់ជូនរបាយការណ៍ CRC លើកចុងក្រោយបង្អស់ ដោយរដ្ឋាភិបាលនៃប្រទេសម៉ាឡេស៊ី បានចុះកាលបរិច្ឆេទត្រឡប់ទៅកាន់ឆ្នាំ២០០៧ វិញ។ ទោះបីជាយ៉ាងណាក៏ដោយ រហូតមកដល់ឆ្នាំ២០១៨ នៅពេលដែលមានការត្រួតពិនិត្យឡើងវិញលើ UPR លើកទី ២ ក្រុមការងារហាប់បីដូចជាបានលើកឡើងអំពីកង្វល់នានា និង បានផ្តល់អនុសាសន៍ដូចៗគ្នា។

431 គណៈកម្មាធិការលុបបំបាត់ការរើសអើងប្រឆាំងនឹងស្ត្រីភេទ (CEDAW) នៃ UN ការរួមបញ្ចូលគ្នានៃរបាយការណ៍តាមកាលកំណត់លើកទីបី រហូតដល់ លើកទីប្រាំរបស់ប្រទេសម៉ាឡេស៊ី (CEDAW/C/MYS/៣-៥) បញ្ជីបញ្ហា និង សំណួរនានាមាននៅក្នុង CEDAW/C/MYS/Q/៣-៥ ហើយការឆ្លើយតបរបស់រដ្ឋភាគីមាននៅក្នុង CEDAW/C/MYS/Q/៣-៥/Add.១ អាចស្វែងរកបាននៅ៖https://tbinternet.ohchr.org/_layouts/treatybodyexternal/Download.aspx?symbolno=CEDAW/C/MYS/CO/3-5&Lang=En។

- ធានាចំពោះការចុះបញ្ជីកំណើតជាចាំបាច់សម្រាប់កុមារដែលកើតនៅក្នុងជំរុំជនភៀសខ្លួននៅក្នុងប្រទេស ដើម្បីការពារពួកគេពីភាពគ្មានសញ្ជាតិ។[432]

### អំពីសញ្ជាតិ៖

- ដោះស្រាយចំណុចចន្លោះប្រហោងដែលមាននៅក្នុងច្បាប់ស្តីពីភាពជាពលរដ្ឋនាពេលបច្ចុប្បន្ន ដែលនាំឲ្យមានភាពគ្មានសញ្ជាតិ
- ទទួលយកអនុសញ្ញា ឆ្នាំ១៩៥៤ ដែលទាក់ទងនឹងឋានៈរបស់ជនគ្មានសញ្ជាតិ និង អនុសញ្ញា ឆ្នាំ១៩៦១ ស្តីពីការកាត់បន្ថយភាពគ្មានសញ្ជាតិ
- និរាករណ៍បញ្ញត្តិនៃច្បាប់នានាដែលចែងអំពីប្រភេទខុសៗគ្នានៃភាពជាពលរដ្ឋ
- លុបចោលការចង្អុលបង្ហាញអំពីជាតិពន្ធុនៅលើអត្តសញ្ញាណប័ណ្ណ[433]
- លើសពីនេះទៀត គណៈកម្មាធិការ CEDAW នៃ UN ក៏បានបញ្ជាក់ឡើងវិញអំពីអនុសាសន៍កាលពីមុនរបស់ខ្លួន (ចូរមើល CEDAW/C/MMR/CO/៣ កថាខណ្ឌទី ៣១ និង ៣៣) និង ផ្តល់អនុសាសន៍ឲ្យរដ្ឋភាគីធ្វើវិសោធនកម្មច្បាប់ស្តីពីភាពជាពលរដ្ឋ ឆ្នាំ១៩៨២ ដើម្បីផ្តល់ភាពជាពលរដ្ឋដល់និវាសនជននៅក្នុងរដ្ឋភាគី ជាពិសេស ស្ត្រី និង កុមារី នៅរដ្ឋ Rakhine ភាគខាងជើង ធ្វើដូច្នេះ ពួកគេអាចទទួលបានសិទ្ធិមនុស្សទាំងអស់ដោយសេរី។[434]

## ប្រទេសហ្វីលីពីន

### អំពីការចុះបញ្ជីកំណើត៖

- បន្ត និង ពង្រឹងកិច្ចខិតខំប្រឹងប្រែងរបស់ខ្លួនដើម្បីអភិវឌ្ឍប្រព័ន្ធចុះបញ្ជីកំណើតដែលមានប្រសិទ្ធភាព និង ដោយឥតគិតថ្លៃសម្រាប់កុមារគ្រប់រូប
- ពង្រឹងប្រព័ន្ធចុះបញ្ជីអត្រានុកូលដ្ឋាននៅ Barangay (BCRS) ដើម្បីធ្វើឲ្យប្រព័ន្ធចុះបញ្ជីអត្រានុកូលដ្ឋានអាចត្រូវបានប្រើប្រាស់នៅថ្នាក់មូលដ្ឋានបានកាន់តែច្រើន
- ធានាចំពោះការលៃលកធនធានហិរញ្ញវត្ថុ ធនធានមនុស្ស និង ធនធានដទៃទៀតបានយ៉ាងគ្រប់គ្រាន់សម្រាប់មណ្ឌលចុះបញ្ជី
- អនុវត្តវិធីសាស្ត្រនានាបន្ថែមទៀត រួមបញ្ចូលទាំង សេវាចល័ត ផងដែរ ដើម្បីធានាចំពោះការទទួលបានការចុះបញ្ជីបានយ៉ាងងាយស្រួលពីសំណាក់ប្រជាជន រួមបញ្ចូលទាំង ប្រជាជននៅតាមតំបន់ដាច់ស្រយាលបំផុតនៃប្រទេសផងដែរ ដោយផ្តោតការយកចិត្តទុកដាក់ជាពិសេសលើកុមារដែលកាន់សាសនាអ៊ីស្លាម និង កុមារជនជាតិដើមភាគតិចដែលរស់នៅ Mindanao
- ដាក់ចេញនូវយន្តការលើកទឹកចិត្ត និង ផ្តល់ការចុះបញ្ជីយឺតពេលដោយឥតគិតថ្លៃ[435]

---

432 គណៈកម្មាធិការលុបបំបាត់ការរើសអើងប្រឆាំងនឹងស្ត្រីភេទ (CEDAW) នៃ UN ការរួមបញ្ចូលគ្នានៃរបាយការណ៍តាមកាលកំណត់លើកទីបួន និង លើកទីប្រាំរបស់ប្រទេសមីយ៉ាន់ម៉ា (CEDAW/C/MMR/៤-៥) ចូរមើល CEDAW/C/SR.១៤០៧ និង ១៤០៨ បញ្ជីបញ្ហា និង សំណួរនានាមាននៅក្នុង CEDAW/C/MMR/Q/៤-៥ ហើយការឆ្លើយតបរបស់ប្រទេសមីយ៉ាន់ម៉ាមាននៅក្នុង CEDAW/C/MMR/Q/៤-៥/Add.១. អាចស្វែងរកបាននៅ៖https://tbinternet.ohchr.org/_layouts/treatybodyexternal/Download.aspx?symbolno=CEDAW%2fC%2fMMR%2fCO%2f4-5&Lang=en

433 Ibid គណៈកម្មាធិការសិទ្ធិកុមារ (CRC) នៃ UN។

434 Ibid គណៈកម្មាធិការលុបបំបាត់ការរើសអើងប្រឆាំងនឹងស្ត្រីភេទ (CEDAW) នៃ UN។

435 គណៈកម្មាធិការសិទ្ធិកុមារ (CRC) នៃ UN ការរួមបញ្ចូលគ្នានៃរបាយការណ៍តាមកាលកំណត់លើកទីបី និង លើកទីបួន របស់ប្រទេសហ្វីលីពីន (CRC/C/PHL/៣-៤) ចូរមើល CRC/C/SR.១៤២៨ និង ១៤២៩ សេចក្តីសង្កេតសន្និដ្ឋានត្រូវបានអនុម័តនៅថ្ងៃទី០២ ខែតុលា ឆ្នាំ២០០៩ អាចស្វែងរកបាននៅ៖https://tbinternet.ohchr.org/_layouts/treatybodyexternal/Download.aspx?symbolno=CRC/C/PHL/CO/3-4&Lang=En

- បញ្ជាក់ឡើងវិញអំពីអនុសាសន៍កាលពីមុនរបស់ខ្លួន ដើម្បីផ្តល់ការជួយសម្រួលបន្ថែមទៀតថា ឪពុកម្តាយ ដោយមិនគិតអំពីឋានៈនៃការស្នាក់នៅរបស់ពួកគេទេនោះ អាចចុះបញ្ជីកូនរបស់ពួកគេ ដែលបានកើតនៅក្រៅប្រទេស និង ធានាថា កូនដែលមិនបានចុះបញ្ជី ដោយគ្មានឯកសារផ្លូវការ ត្រូវបានអនុញ្ញាតឲ្យទទួលបានសេវាមូលដ្ឋាន ដូចជា សេវាសុខាភិបាល និង ការអប់រំ ជាដើម បន្ទាប់ពីពួកគេបានត្រឡប់មកកាន់ប្រទេសហ្វីលីពីនវិញ នៅខណៈពេលរង់ចាំការចុះបញ្ជីយ៉ាងត្រឹមត្រូវនោះ។[436]

### អំពីសញ្ជាតិៈ

- ផ្តល់ការជួយសម្រួលបន្ថែមទៀតថា ឪពុកម្តាយ ដោយមិនគិតអំពីឋានៈនៃការស្នាក់នៅរបស់ពួកគេទេនោះ អាចចុះបញ្ជីកូនរបស់ពួកគេ ដែលបានកើតនៅក្រៅប្រទេស និង ធានាថា កូនដែលមិនបានចុះបញ្ជី ដោយគ្មានឯកសារផ្លូវការនោះ ត្រូវបានអនុញ្ញាតឲ្យទទួលបានសេវាមូលដ្ឋាន ដូចជា សេវាសុខាភិបាល និង ការអប់រំ ជាដើម បន្ទាប់ពីពួកគេបានត្រឡប់មកកាន់ប្រទេសហ្វីលីពីនវិញ នៅខណៈពេលរង់ចាំការចុះបញ្ជីយ៉ាងត្រឹមត្រូវនោះ។[437]

## ប្រទេសសិង្ហបុរី

### អំពីសញ្ជាតិៈ

- កែសម្រួលច្បាប់ស្តីពីសញ្ជាតិរបស់ខ្លួន ដោយមានបំណងការពារកុមារពីការដកហូតភាពជាពលរដ្ឋរបស់ពួកគេ និង ពិចារណាផ្តល់ភាពជាពលរដ្ឋដល់កុមារគ្រប់រូបដែលកើតនៅមុនឆ្នាំ២០០៤ ដែលមានម្តាយជាពលរដ្ឋសិង្ហបុរី[438]
- បោះពុម្ពផ្សាយស្ថិតិដែលមានបច្ចុប្បន្នភាព អំពីចំនួនជនគ្មានសញ្ជាតិនៅក្នុងរដ្ឋភាគី ដោយបែងចែកតាមភេទ យេនឌ័រ ជាតិពន្ធុ ឋានៈនៃការស្នាក់នៅ និង បុគ្គលិកលក្ខណៈដទៃទៀតដែលពាក់ព័ន្ធ
- កែសម្រួលច្បាប់ ដើម្បីធានាថា កុមារដែលកើតនៅក្នុងប្រទេសសិង្ហបុរី ដែលមិនអាចទទួលបានសញ្ជាតិណាមួយផ្សេងទៀត អាចទទួលបានសញ្ជាតិសិង្ហបុរីដោយស្វ័យប្រវត្តិ
- ផ្តល់សច្ចាប័នលើអនុសញ្ញា ឆ្នាំ១៩៥១ ទាក់ទងនឹងឋានៈរបស់ជនភៀសខ្លួន និង ពិធីសារ ឆ្នាំ១៩៦៧ នៃអនុសញ្ញានេះ
- ផ្តល់សច្ចាប័នលើអនុសញ្ញា ឆ្នាំ១៩៥៤ ដែលទាក់ទងនឹងឋានៈរបស់ជនគ្មានសញ្ជាតិ និង អនុសញ្ញា ឆ្នាំ១៩៦១ ស្តីពីការកាត់បន្ថយភាពគ្មានសញ្ជាតិ។[439]

---

436 Ibid.

437 Ibid.

438 គណៈកម្មាធិការសិទ្ធិកុមារ (CRC) នៃ UN ការរួមបញ្ចូលគ្នានៃរបាយការណ៍តាមកាលកំណត់លើកទីពីរ និង លើកទីបី របស់ប្រទេសសិង្ហបុរី (CRC/C/SGP/២-៣) CRC/C/SR.១៥៩០ និង ១៥៩១ សេចក្តីសង្កេតសន្និដ្ឋានត្រូវបានអនុម័តនៅថ្ងៃទី០៤ ខែកុម្ភៈ ឆ្នាំ២០១១ អាចស្វែងរកបាននៅ៖ https://tbinternet.ohchr.org/_layouts/treatybodyexternal/Download.aspx?symbolno=CRC/C/SGP/CO/2-3&Lang=En។

គណៈកម្មាធិការបានកត់សម្គាល់ឃើញការស្វាគមន៍ចំពោះការធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញ នៅខែមេសា ឆ្នាំ២០០៤ ដែលអនុញ្ញាតឲ្យកុមារទទួលបានភាពជាពលរដ្ឋតាមរយៈដើមកំណើតដែលទទួលបានពីម្តាយរបស់ពួកគេ គណៈកម្មាធិការបានធ្វើការកត់សម្គាល់ដោយមានកង្វល់ថា ច្បាប់ដែលបានធ្វើវិសោធនកម្មនេះត្រូវបានអនុវត្តតែចំពោះកុមារដែលកើតនៅ ឬ នៅក្រោយថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០០៤ តែប៉ុណ្ណោះ។ គណៈកម្មាធិការមានកង្វល់ថា នៅតែមានកុមារគ្មានសញ្ជាតិមួយចំនួននៅក្នុងរដ្ឋភាគីដដែល និង ថា ក្រោមកាលៈទេសៈពិសេសៗ កុមារអាចត្រូវគេដកហូតភាពជាពលរដ្ឋរបស់ពួកគេ ស្របតាមមាត្រា ១២៩.២(ក) នៃរដ្ឋធម្មនុញ្ញ។

439 គណៈកម្មាធិការលុបបំបាត់ការរើសអើងប្រឆាំងនឹងស្ត្រីភេទ (CEDAW) នៃ UN របាយការណ៍តាមកាលកំណត់លើកទីប្រាំរបស់ប្រទេសសិង្ហបុរី (CEDAW/C/SGP/៥) ចូរមើល CEDAW/C/SR.១៥៣៤ និង CEDAW/C/SR.១៥៣៥ បញ្ជីបញ្ហា និង សំណួរនានាមាននៅក្នុង CEDAW/C/SGP/Q/៥ ហើយការឆ្លើយតបរបស់ប្រទេសសិង្ហបុរីមាននៅក្នុង CEDAW/C/SGP/Q/៥/Add.១. អាចស្វែងរកបាននៅ៖

https://tbinternet.ohchr.org/_layouts/treatybodyexternal/Download.aspx?symbolno=CEDAW/C/SGP/CO/5&Lang=En។

គណៈកម្មាធិការបានបង្ហាញអំពីកង្វល់របស់ខ្លួនចំពោះកង្វះខាតព័ត៌មានផ្លូវការអំពីចំនួនជនគ្មានសញ្ជាតិនៅក្នុងរដ្ឋភាគី និង កង្វះខាតកិច្ចការពារដោយស្របច្បាប់ ដើម្បីធានាថា កុមារដែលនៅក្នុងរដ្ឋភាគី ដែលមិនអាចទទួលបានសញ្ជាតិផ្សេងទៀត ទទួលបានសញ្ជាតិសិង្ហបុរីដោយស្វ័យប្រវត្តិ។

# ប្រទេសថៃ

## អំពីការចុះបញ្ជីកំណើត៖

- អនុវត្តវិធានការនានាដើម្បីធានាចំពោះការចុះបញ្ជីកំណើតសម្រាប់កុមារគ្រប់រូបដែលកើតនៅលើដែនដីរបស់ខ្លួន ជាពិសេស កុមារដែលមិនបានចុះបញ្ជី ដោយសារស្ថានភាពសេដ្ឋកិច្ចរបស់ឪពុកម្តាយពួកគេ ជាតិពន្ធុ និង ស្ថានភាពនៃការធ្វើអន្តោប្រវេសន៍
- អនុវត្តកម្មវិធីអប់រំជាសាធារណៈ រួមបញ្ចូលទាំង យុទ្ធនាការផ្តល់ការចុះបញ្ជីកំណើតដល់កុមារដែលបានកើតនៅក្នុងដែនដីនៃរដ្ឋភាគី ប៉ុន្តែមិនទាន់បានចុះបញ្ជីផងដែរ
- លុបចោលការពិន័យជាប្រាក់ចំពោះការចុះបញ្ជីយឺតពេល និង អនុវត្តវិធានការជំនួស ដើម្បីធានាចំពោះការចុះបញ្ជីកុមារទើបនឹងកើតបានយ៉ាងទាន់ពេលវេលា[440]
- ពង្រឹងកិច្ចខិតខំប្រឹងប្រែងជួយសម្រួលដល់ការចុះបញ្ជីកំណើតរបស់កុមារ ជាពិសេស កុមារនៅតាម ទីជនបទ និង តំបន់ដាច់ស្រយាល តាមរយៈការរៀបចំយុទ្ធនាការបង្កើនការយល់ដឹង និង លុបបំបាត់ឧបសគ្គផ្នែកភាសា។[441]

## អំពីសញ្ជាតិ៖

- ត្រួតពិនិត្យឡើងវិញបន្ថែមទៀត និង អនុម័តច្បាប់ ដើម្បីធានាថា កុមារគ្រប់រូបដែលប្រឈមនឹងហានិភ័យនៃការក្លាយជាគ្មានសញ្ជាតិ រួមបញ្ចូលទាំង កុមារនៃក្រុមមនុស្សដែលជួបការលំបាក ត្រូវបានផ្តល់ជូននូវការទទួលបានសញ្ជាតិថៃ
- ពិចារណាផ្តល់សច្ចាប័នលើអនុសញ្ញា ឆ្នាំ១៩៥៤ ដែលទាក់ទងនឹងឋានៈរបស់ជនគ្មានសញ្ជាតិ និង ពិធីសារប្រតិបត្តិការ ឆ្នាំ១៩៦៧ របស់អនុសញ្ញានោះ និង អនុសញ្ញា ឆ្នាំ១៩៦១ ស្តីពីការកាត់បន្ថយភាពគ្មានសញ្ជាតិ។[442]
- អនុម័តការធ្វើវិសោធនកម្មច្បាប់បន្ថែមទៀត ដើម្បីធានាថា ស្ត្រី និង បុរស ទទួលបានសិទ្ធិស្មើគ្នានៅក្នុងការផ្ទេរសញ្ជាតិរបស់ពួកគេទៅកាន់ស្វាមីដែលជាជនបរទេស
- ធានាថា ដោយគ្មានភាពយឺតយ៉ាវនោះទេ ស្ត្រីនៅក្នុងក្រុមជាតិពន្ធុភាគតិច និង ក្រុមជនជាតិដើមភាគតិច មានសិទ្ធិទទួលបានសញ្ជាតិ ដូចគ្នានឹងបុរសដែរ រួមបញ្ចូលទាំង តាមរយៈការលុបបំបាត់ឧបសគ្គនានាដែលទាក់ទងនឹងភាសា ការិយាធិបតេយ្យ លក្ខខណ្ឌតម្រូវរបស់និវាសនជន អក្ខរកម្ម និង ឥរិយាបថរបស់មន្ត្រី ធានាថា ពួកគេទទួលបានសិទ្ធិសេរីភាពក្នុងការធ្វើដំណើរ និង ទទួលបានការអប់រំ ការងារ ការថែទាំសុខភាព និង កិច្ចការពារសង្គមបានដោយគ្មានការរឹតត្បិតដែលមិនត្រឹមត្រូវ។

---

440 គណៈកម្មាធិការសិទ្ធិកុមារ (CRC) នៃ UN របាយការណ៍តាមកាលកំណត់លើកទីបី និង លើកទីបួន របស់ប្រទេសថៃ (CRC/C/THA/៣-៤) សេចក្តីសង្កេតសន្និដ្ឋានត្រូវបានអនុម័តនៅថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០១២ (ចូរមើល CRC/C/SR.១៦៩៧) អាចស្វែងរកបាននៅ៖https://tbinternet.ohchr.org/_layouts/treatybodyexternal/Download.aspx?symbolno=CRC/C/THA/CO/3 -4&Lang=En។

គណៈកម្មាធិការបានបង្ហាញអំពីកង្វល់ ថា កុមារជាច្រើននាក់ ជាពិសេស កុមារក្រីក្រ កូនរបស់ក្រុមជនជាតិដើមភាគតិច និង ជនអន្តោប្រវេសន៍នៅតែមិនទាន់បានចុះបញ្ជី។ នៅតែមានកង្វល់ដែលថា រដ្ឋភាគីនៅតែបន្តធ្វើការផាកពិន័យ ទោះបីជាមានកម្រិតទាបក៏ដោយ ចំពោះការចុះបញ្ជីកុមារយឺតពេល។

441 គណៈកម្មាធិការលុបបំបាត់ការរើសអើងប្រឆាំងនឹងស្ត្រីភេទ (CEDAW) នៃ UN ការរួមបញ្ចូលគ្នានៃរបាយការណ៍តាមកាលកំណត់លើកទីប្រាំមួយ និង លើកទីប្រាំពីររបស់ប្រទេសថៃ (CEDAW/C/THA/៦-៧) ចូរមើល CEDAW/C/SR.១៥០៤ និង CEDAW/C/SR.១៥០៥ បញ្ជីបញ្ហា និង សំណួរនានាមាននៅក្នុង CEDAW/C/THA/Q/៦-៧ ហើយការឆ្លើយតបរបស់ប្រទេសថៃមាននៅក្នុង CEDAW/C/THA/Q/៦-៧/Add.១. អាចស្វែងរកបាននៅ៖ https://tbinternet.ohchr.org/_layouts/treatybodyexternal/Download.aspx?symbolno=CEDAW/C/THA/CO/6 -7&Lang=En

គណៈកម្មាធិការនៅតែមានកង្វល់ថា ទោះបីជាមានវិធីសាស្ត្រនានាត្រូវបានអនុម័តដោយរដ្ឋភាគីក្តី ក៏កុមារជាច្រើននាក់មិនទទួលបានការចុះបញ្ជីកំណើត ឬ មានកង្វះខាតឯកសារចុះបញ្ជីកំណើត ដូច្នេះ ធ្វើឲ្យពួកគេងាយរងគ្រោះនឹងការក្លាយជាជនគ្មានសញ្ជាតិ។

442 Ibid គណៈកម្មាធិការសិទ្ធិកុមារ (CRC) នៃ UN។

គណៈកម្មាធិការនៅតែមានកង្វល់ថា មនុស្សជាច្រើននាក់ រួមបញ្ចូលទាំង កុមារ ផងដែរ ជាពិសេស កុមារនៅក្នុងក្រុមជនជាតិដើមភាគតិច និង កូនរបស់ពលករចំណាកស្រុក ជនភៀសខ្លួន និង អ្នកស្វែងរកសិទ្ធិជ្រកកោននៅតែគ្មានសញ្ជាតិ ឬ អាចក្លាយជាគ្មានសញ្ជាតិ។

- ផ្តល់សច្ចាប័នលើអនុសញ្ញា ឆ្នាំ១៩៥៤ ដែលទាក់ទងនឹងឋានៈរបស់ជនគ្មានសញ្ជាតិ និង អនុសញ្ញា ឆ្នាំ១៩៦១ ស្តីពីការកាត់បន្ថយភាពគ្មានសញ្ជាតិ។

## ប្រទេសវៀតណាម

### អំពីការចុះបញ្ជីកំណើត៖

- រំឭកឡើងវិញអំពីអនុសាសន៍របស់ខ្លួនកាលពីមុន (CRC/C/១៥/Add.២០០ កថាខណ្ឌទី ៣២) បានផ្តល់អនុសាសន៍ឲ្យប្រទេសវៀតណាមបន្ត និង ពង្រឹងកិច្ចខិតខំប្រឹងប្រែងរបស់ខ្លួន ដើម្បីធានាចំពោះការចុះបញ្ជីនៅពេលកើត របស់កុមារគ្រប់រូប ដោយផ្តោតការយកចិត្តទុកដាក់ជាពិសេសលើកុមារដែលរស់នៅតាមតំបន់ជនបទ និង តំបន់ភ្នំ
- រៀបចំយុទ្ធនាការបង្កើនការយល់ដឹង ស្តីពីសិទ្ធិរបស់កុមារគ្រប់រូបចំពោះការចុះបញ្ជីនៅពេលកើត ដោយមិនគិតអំពីសាវតាផ្នែកសង្គម និង ជាតិពន្ធុ និង ឋានៈជានិវាសនជនរបស់ឪពុកម្តាយនោះទេ។[443]

### អំពីសញ្ជាតិ៖

- អនុម័តច្បាប់ និង នីតិវិធីដែលមានប្រសិទ្ធភាពសម្រាប់ការផ្តល់សិទ្ធិជ្រកកោន និង ឋានៈរបស់ជនភៀសខ្លួន និង ផ្តល់កិច្ចការពារដោយផ្អែកលើមូលដ្ឋាននៃការធ្វើទុក្ខបុកម្នេញលើយេនឌ័រ
- បន្តជួយសម្រួលដល់ការកាត់បន្ថយភាពគ្មានសញ្ជាតិ ជាពិសេស ការទទួលបានសញ្ជាតិវៀតណាមឡើងវិញ ដោយស្ត្រីដែលបានក្លាយជាគ្មានសញ្ជាតិ តាមរយៈការបោះបង់ចោលសញ្ជាតិនោះ
- ជម្រុញការទទួលយកអនុសញ្ញា ឆ្នាំ១៩៥១ ទាក់ទងនឹងឋានៈរបស់ជនភៀសខ្លួន និង ពិធីសារ ឆ្នាំ១៩៦៧ អនុសញ្ញា ឆ្នាំ១៩៥៤ ដែលទាក់ទងនឹងឋានៈរបស់ជនគ្មានសញ្ជាតិ និង អនុសញ្ញា ឆ្នាំ១៩៦១ ស្តីពីការកាត់បន្ថយភាពគ្មានសញ្ជាតិ។[444]

---

443 គណៈកម្មាធិការសិទ្ធិកុមារ (CRC) នៃ UN ការរួមបញ្ចូលគ្នានៃរបាយការណ៍តាមកាលកំណត់លើកទីបី និង លើកទីបួន របស់ប្រទេសវៀតណាម (CRC/C/VNM/៣-៤) (ចូរមើល CRC/C/SR.១៧០២ និង ១៧០៣) សេចក្តីសង្កេតសន្និដ្ឋានត្រូវបានអនុម័តនៅថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១២ អាចស្វែងរកបាននៅ៖ https://tbinternet.ohchr.org/_layouts/treatybodyexternal/Download.aspx?symbolno=CRC/C/VNM/CO/3-4&Lang=En។

គណៈកម្មាធិការបានបង្ហាញអំពីកង្វល់របស់ខ្លួនថា ភាពខុសគ្នាផ្នែកភូមិសាស្ត្រ និង ជាតិពន្ធុដែលនៅតែបន្តកើតឡើង នៅក្នុងអត្រានៃការចុះបញ្ជីកំណើត ដែលអត្រាទាបបំផុតនៅតែស្ថិតនៅក្នុងតំបន់ក្រីក្រជាងគេបំផុតចំនួនពីរ គឺតំបន់ភ្នំនៅភាគពាយព្យ និង ភាគកណ្តាល។ គណៈកម្មាធិការក៏មានកង្វល់បន្ថែមទៀតដែរថា ឪពុកម្តាយ ជាពិសេសនៅតាមតំបន់ដាច់ស្រយាល មិនមែនតែងតែដឹងអំពីលក្ខខណ្ឌតម្រូវសម្រាប់ការចុះបញ្ជីកំណើត និង សារសំខាន់នៃការចុះបញ្ជីកំណើតនោះទេ។

444 គណៈកម្មាធិការលុបបំបាត់ការរើសអើងប្រឆាំងនឹងស្ត្រីភេទ (CEDAW) នៃ UN ការរួមបញ្ចូលគ្នានៃរបាយការណ៍តាមកាលកំណត់លើកទីប្រាំពីរ និង លើកទីប្រាំបីរបស់ប្រទេសវៀតណាម (CEDAW/C/VNM/៧-៨) ថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០១៥ បញ្ជីបញ្ហា និង សំណួរនានាមាននៅក្នុង CEDAW/C/VNM/Q/៧-៨ ហើយការឆ្លើយតបរបស់ប្រទេសវៀតណាមមាននៅក្នុង CEDAW/C/VNM/Q/៧-៨/Add.១. អាចស្វែងរកបាននៅ៖ https://tbinternet.ohchr.org/_layouts/treatybodyexternal/Download.aspx?symbolno=CEDAW/C/VNM/CO/7 -8&Lang=En។

គណៈកម្មាធិការបានកត់សម្គាល់ថា ពុំមាននីតិវិធីសម្រាប់ផ្តល់សិទ្ធិជ្រកកោន ឬ កំណត់ឋានៈរបស់ជនភៀសខ្លួននោះទេ ទោះបីជាមានការធានាចំពោះសិទ្ធិជ្រកកោនស្របតាមរដ្ឋធម្មនុញ្ញក៏ដោយ និងថា មានស្ត្រីគ្មានសញ្ជាតិចំនួន ៨០០ នាក់ ដែលបានបាត់បង់សញ្ជាតិវៀតណាមរបស់ពួកគេ ដោយបានទទួលបរាជ័យនៅក្នុងការប៉ុនប៉ងទទួលបានសញ្ជាតិមួយផ្សេងទៀត។



ASEAN VIET NAM 2020

UNHCR
The UN Refugee Agency

Ministry of Social Affairs Veterans and Youth Rehabilitation

MINISTRY OF WOMEN'S AFFAIRS